

ឯកសារគម្ពីព្រះត្រៃបិដកស្កាននេះ
ត្រូវបានថតចេញពី ច្បាប់គម្ពីរព្រះត្រៃបិដកជប៉ុន ៗ

ឯកសារគម្ពីរព្រះត្រៃបិដកនេះ ចាប់ពីភាគ៥១ ដល់ ភាគ១១០
ត្រូវបានរៀបចំធ្វើឡើងដោយ គេហទំព័រ៥000ឆ្នាំ បូជា
ចំពោះព្រះពុទ្ធសាសនា សម្រាប់ជាធម្មទាន ៗ

ផ្តល់សៀវភៅគម្ពីរព្រះត្រៃបិដកសម្រាប់ការងារ
ដោយ ឧបាសិកា កាំង ហ្គិចណៃ ៗ

គ្រប់គ្រងគម្រោង (ទូទៅ និងផ្នែកបច្ចេកទេស)
ដោយ ឧបាសក ស្រុង-ចាន់ណា ៗ

ត្រួតពិនិត្យឡើងវិញ
ដោយ ចន-ស្រីស្រស់ ៗ

ថតស្កានដោយ
ប្អូនប្រុស ម៉ាន់ សាវ៉េត

www.5000-years.org

ក្រោមការឧបត្ថម្ភយ៉ាងក្រៃលែងអំពី៖

- ឧបាសិកា កាំង ហ៊ុចណៃ (ភ្នំពេញ)
- ឧបាសក ផុត លីស្រុង និង ឧបាសិកា លី សុខា ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក សរ ចន និង ឧបាសិកា អ៊ូច សាវៀង ព្រមទាំងបុត្រ (បាត់ដំបង)
- ឧបាសក ជា ស៊ីវត្ថានា និងឧបាសិកា ឃុន សូនីម៉ា ព្រមទាំងបុត្រី ជា សុមេធាធីតា (ស.វ.អ)
- លោក ជឹម-ជា និងលោកស្រី រតនី ស្រីមុំ (ភ្នំពេញ)
- ឧបាសក ផែង យឿន (កូរ៉េ)
- លោក ស៊ុក ចាន់សេរី (បន្ទាយមានជ័យ)
- ឧបាសិកា យ៉ា វ៉ារី (បន្ទាយមានជ័យ)
- ប្អូនស្រី យ៉ា សុភ: (បន្ទាយមានជ័យ)
- ឧបាសិកា កោ សេង (ភ្នំពេញ)
- លោកស្រី ប៉ាន សុគន្ធានីន និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក ស្រុង ចាន់ណា និង ឧបាសិកា ចន ស្រីស្រស់
  ព្រមទាំងបុត្រ ចាន់ណា សុធារនីរាជ, ចាន់ណា សុធារនិរោធ (ភ្នំពេញ)
- លោកស្រី ស្រុង ចាន់រស្មី និង ស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- កញ្ញា ស្រុង ចាន់រតនា (ភ្នំពេញ)
- លោក ស្រុង យូហេង (ភ្នំពេញ)
- លោក នង សុផល (កូរ៉េ)
- ប្អូនស្រី សុខ អេង (កំពង់ចាម)
- កញ្ញា ចន កក្កដា (បាត់ដំបង)
- លោកស្រី ចន សត្យា និងលោក ទួត សេរីស័ក ព្រមទាំងបុត្រ (ភ្នំពេញ)
- លោក ចន រចនា (បាត់ដំបង)
- កញ្ញា សែ សុផារី (បាត់ដំបង)
- កញ្ញា យឿម សុផានី (បាត់ដំបង)
- លោក ម៉ៅ គន្ធា និងលោកស្រី ធៀង សេដ្ឋា (បាត់ដំបង)
- លោក សៅ សារ៉ុម (បាត់ដំបង)
- ព្រះតេជព្រះគុណ ឌុំ សារ: (ព្រះចៅអធិការវត្ត សម សាន្ត ខេត្តបាត់ដំបង)
- ឧបាសិកា វ៉ាន់ លុយ និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- លោកស្រី ហួ ច័ន្ទសុវណ្ណ និងស្វាមី ព្រមទាំងបុត្រ (ស.វ.អ)

# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្តីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
# ខុទ្ទកនិកាយ ចូឡនិទ្ទេស
# ទុតិយភាគ
# ៦៨

ពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ

ព. ស. ២៥០៨

## ឧទ្ទិសកថា

យើងខ្ញុំ សូមផ្ដល់ស្នារតីសូត្រព្រះធម៌ឧទ្ទិសជូនជនជាតិខ្មែរ ។

ឥឡូវ យើងខ្ញុំអាចជូនគម្ពីរព្រះត្រៃបិដកនេះ ទៅអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិខ្មែរបានហើយ ។

ព្រះធម៌នៃព្រះពុទ្ធជាម្ចាស់នេះ ត្រូវបានសូត្រចេញពីជម្រៅដួងចិត្តនៃអ្នកកាន់ព្រះពុទ្ធសាសនា
ជនជាតិជប៉ុន ។

このカンボジア版南伝大蔵経を
カンボジアの佛教徒へ
贈ることができることに感謝します。
これが日本の佛教徒の心です。

It is with a deep sense of gratitude that I present the translation of the complete TRIPITAKA to Cambodian Buddhists on behalf of the Japanese Buddhist community.

# អារម្ភកថា

ជូនចំពោះជនជាតិខ្មែរ ជាទីរាប់អាន !

ជូនចំពោះជនជាតិខ្មែរដែលកាន់ព្រះពុទ្ធសាសនា ជាទីគោរព !

គម្ពីរព្រះត្រៃបិដកខ្មែរនេះ ត្រូវបាន " ក្រុមជំនុំព្រះត្រៃបិដក " នៃពុទ្ធសាសនបណ្ឌិត្យ នៅភ្នំពេញ បកប្រែពីភាសាបាលីមកជាភាសាខ្មែរ តាំងពីឆ្នាំ ១៩៣០ ទៅឆ្នាំ ១៩៦៨ គឺត្រូវចំណាយពេល ៣៩ ឆ្នាំ ទើបបានសម្រេចហើយសព្វគ្រប់ ។ នេះពិតជាកំណាប់ព្រះធម៌របស់ព្រះពុទ្ធសាសនាខ្មែរ ហើយក៏ជាកំណាប់វប្បធម៌ខាងផ្នែកបោះពុម្ពរបស់ជនជាតិខ្មែរផងដែរ ។ យើងខ្ញុំ ពុទ្ធសាសនិកជាតិជប៉ុន មានសន្តានចិត្តរីករាយនឹងបោះពុម្ពជាថ្មីឡើងវិញ ដោយសង្ឃឹមថា ព្រះពុទ្ធសាសនាខ្មែរក៏នឹងរុងរឿងឡើងវិញដែរ ។

នេះគឺជាអំណោយពីជម្រៅដួងចិត្ត ជូនទៅដល់ជនជាតិខ្មែរទាំងអស់ ព្រមទាំងមនុស្សជាតិទូទៅ នៅក្នុងពិភពលោកនេះ ដែលមានចិត្តស្រឡាញ់សន្តិភាព ។

ខ្មែរបានរងសោកនាដកម្មដែលមិនធ្លាប់មានពីមុនមក ។ ម្យ៉ាងទៀត ព្រះពុទ្ធសាសនាខ្មែរ ក៏ត្រូវអន្តរាយយ៉ាងខ្លាំង ក៏ប៉ុន្តែឥឡូវនេះ យើងទាំងអស់គ្នា បានឈានជើងកន្លងផុតពីសេចក្តីទុក្ខសោកដ៏ធ្ងន់ធ្ងរនេះ ចាកផុតពីអំពើឃោរឃៅ បញ្ចប់គំនុំគុំគួន ដើរតាមពុទ្ធដីកាព្រះបរមគ្រូ ខិតខំព្យាយាមធ្វើឱ្យមានសន្តិភាពក្នុងពិភពលោក ។

ការណ៍ដែលយើងខ្ញុំជូនគម្ពីរព្រះត្រៃបិដកពេលនេះ គឺជានិមិត្តរូបនៃការប្តេជ្ញាចិត្តរបស់អ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុនថា យើងខ្ញុំធ្វើសហប្រតិបត្តិការដើម្បីសន្តិភាពក្នុងពិភពលោក ដើម្បីទុកជាភស្តុតាងនៃចំណងមេត្រីភាព និងមិត្តភាពរវាងប្រជាជាតិជប៉ុន និងប្រជាជាតិខ្មែរ ។

ថ្ងៃនក្ខត្តឫក្ស កក្កដា ឆ្នាំ ១៩៩៤

សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ

**អ្នកតំណាងចាត់ការ** The Rev. Seikyo Muchaku

**ប្រធានការិយាល័យ** The Rev. Eiitsu Shinohara

**អ្នកចាត់ការ**

The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

# 『トリピタカ』復刻進呈にあたって

親愛なるカンボジアの皆さん！
敬愛するカンボジアの仏教徒の皆さん！

カンボジア版『トリピタカ』は、プノンペンの仏教研究所が、仏教界の英知を集め、1930年から1968年まで、39年の歳月をかけて翻訳し、分類し、集大成して完成されました。まさにカンボジア仏教の法宝であると共に、カンボジア出版文化の至宝です。日本仏教徒の有志は、カンボジア仏教の復興再生を願いつつ、これを復刻刊行し、贈らせていただきます。

これはカンボジア仏教徒のみならず、カンボジア全人民、否、平和を愛する地球上のすべての人々への、心からの贈り物です。

カンボジアは、古今未會有の悲劇を体験しました。カンボジア仏教もこの受難の時代に壊滅的な打撃を受けました。しかし、今はその悲しみを乗りこえ、瞋りを離れ、怨みを恕し、ブッダの教えに従い、世界平和の実現に努力するときです。

この本の贈呈は、日本の仏教徒も共々に、世界平和のために努力することを誓うしるしであり、相互の連帯と友情の証なのです。

合掌

1994年7月吉日

カンボジア版トリピタカ（南伝大蔵経）復刻救援委員会

世話人代表　無着　成恭
事務局長　篠原　鋭一

世話人　松永　然道　有馬　実成
伊藤　佳通　渡井　奎一
杉谷　義純　茂田　真澄
前田　利勝　中島　教之
永　六輔

# Acknowledgment

Dear Cambodian friends and respected members of the Cambodian Buddhist community,

It is a matter of great joy that the translation into Cambodian of the Pali Tripitaka has been completed and published. The Tripitaka Commisson of the Buddhist Institute, Phnom Penh, launched the translation project in 1930 and completed the translation, after 39 years of effort, in 1968.

The Cambodian translation of this great work will not only become a cherished treasure of the Cambodian Buddhist community but will also be an important milestone in the history of publication in Cambodia.

The revival and prosperity of Buddhism in Cambodia are the ardent wish of the Japanese Buddhist community, it is in this spirit that we have completed this important project and now present the entire work to the Cambodian Buddhist community, it is a gift not only to the Buddhist community in Cambodia but also to all Cambodian people and all peace-loving people in the world.

Cambodia experienced great tragedies in modern times, and the Cambodian Buddhist community also underwent severe trials and suffered crushing blows during this period. But now a time has come to surmount grief and anger, to forgive, and to start working again for world peace.

This great work is a symbol of the Japanese Buddhist community's resolve to work with our Cambodian brothers and sisters toward world peace and is a testimony to the friendship between our people.

With hands joined in reverence.
July 1994

**TRIPITAKA PUBLISHING SUPPORT COMMITTEE**
Project Manager : The Rev. Seikyo Muchaku
Secretary General : The Rev. Eiitsu Shinohara
Management Team :
The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

# សុត្តន្តបិដក

## ខុទ្ទកនិកាយ ចូឡនិទ្ទេស

## ទុតិយភាគ

៦៨

ព. ស. ២៥០៥

# សុត្តន្តបិដកេ

## ខុទ្ទកនិកាយស្ស ចូឡនិទ្ទេសោ

## ទុតិយោ ភាគោ

---

### ឧទយមាណវកបញ្ហានិទ្ទេសោ

(១) ឈាយឹ វិរជមាសីនំ (ឥច្ចាយស្មា ឧទយោ)
កតកិច្ចំ អនាសវំ
បារគុំ សព្វធម្មានំ
អត្ថិ បញ្ហេន អាគមំ
អញ្ញាវិមោក្ខំ បព្រូហិ
អវិជ្ជាយ បភេទនំ ។

(២) ឈាយឹ វិរជមាសីនន្តិ ឈាយិន្តិ ភគវា បឋមេនបិ ឈានេន ឈាយី ទុតិយេនបិ ឈានេន ឈាយី តតិយេនបិ ឈានេន ឈាយី ចតុត្ថេនបិ ឈានេន ឈាយី សវិតក្កសវិចារេនបិ ឈានេន ឈាយី អវិតក្កវិចារមត្តេនបិ ឈានេន ឈាយី

# សុត្តន្តបិដក

# ខុទ្ទកនិកាយ ចូឡនិទ្ទេស

# ទុតិយភាគ

---

## ឧទយមាណវកប្បញ្ហានិទ្ទេស

(១) (ឧទយៈមានអាយុក្រាបទូលដូច្នេះថា) ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយប្រស្នា ទើបមកគាល់ (ដើម្បីសួរ) ព្រះអង្គជាអ្នកមានឈាន មានព្រះសន្តានប្រាសចាកធូលី ទ្រង់គង់នៅ ទ្រង់មានកិច្ចធ្វើរួចហើយ មិនមានអាសវៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង សូមព្រះអង្គសំដែងអញ្ញាវិមោក្ខ ជាគ្រឿងទំលាយអវិជ្ជា ។

(២) អធិប្បាយពាក្យថា ជាអ្នកមានឈាន មានព្រះសន្តានប្រាសចាកធូលី ទ្រង់គង់នៅ ត្រង់ពាក្យថា មានឈាន គឺព្រះមានព្រះភាគ មានឈាន ដោយបឋមជ្ឈានផង មានឈាន ដោយទុតិយជ្ឈានផង មានឈាន ដោយតតិយជ្ឈានផង មានឈាន ដោយចតុត្ថជ្ឈានផង មានឈាន ដោយឈាន ប្រកបដោយវិតក្កៈនឹងវិចារៈផង មានឈាន ដោយឈានមិនមានវិតក្កៈ មានតែវិចារៈផង

អវិតក្កាវិចារេនបិ ឈានេន ឈាយី សប្បីតិកេ-
នបិ ឈានេន ឈាយី និប្បីតិកេនបិ ឈានេន
ឈាយី សាតសហគតេនបិ ឈានេន ឈាយី
ឧបេក្ខាសហគតេនបិ ឈានេន ឈាយី សុញ្ញ-
តេនបិ ឈានេន ឈាយី អនិមិត្តេនបិ ឈានេន
ឈាយី អប្បណិហិតេនបិ ឈានេន ឈាយី
លោកិយេនបិ ឈានេន ឈាយី លោកុត្តរេនបិ
ឈានេន ឈាយី ឈានរតោ ឯកត្តមនុយុត្តោ
សទត្ថគរុកោតិ ឈាយី ។ វិរជន្តិ រាគោ រជោ
ទោសោ រជោ មោហោ រជោ កោធោ រជោ
ឧបនាហោ រជោ ។ បេ ។ សព្វាកុសលាភិ-
សង្ខារា រជា ។ តេ រជា ពុទ្ធស្ស ភគវតោ
បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្ក-
តា អាយតឹ អនុប្បាទធម្មា តស្មា ពុទ្ធោ អរជោ
វិរជោ រជាបគតោ រជវិប្បហីនោ រជវិប្បមុត្តោ ។

មានឈាន ដោយឈានមិនមានវិតក្កៈ មិនមានវិចារៈផង មានឈាន ដោយឈានប្រកបដោយបីតិផង មានឈាន ដោយឈានមិនមានបីតិផង មានឈាន ដោយឈានប្រកបដោយសុខផង មានឈាន ដោយឈានប្រកបដោយឧបេក្ខាផង មានឈាន ដោយឈាន ប្រកបដោយសុញ្ញត-វិមោក្ខផង មានឈាន ដោយឈាន ប្រកបដោយអនិមិត្តវិមោក្ខផង មានឈាន ដោយឈាន ប្រកបដោយអប្បណិហិតវិមោក្ខផង មានឈាន ដោយឈានជាលោកិយផង មានឈាន ដោយឈានជាលោកុត្តរផង ជាបុគ្គលត្រេកអរក្នុងឈាន ប្រកបរឿយៗនូវភាពជាបុគ្គលម្នាក់ឯង ធួន់ក្នុងប្រយោជន៍របស់ខ្លួន ហេតុនោះ (លោកពោលថា) អ្នកមានឈាន ។ ពាក្យថា ប្រាសចាកធូលី សេចក្តីថា ធូលីគឺរាគៈ ធូលីគឺទោសៈ ធូលីគឺមោហៈ ធូលីគឺកោធៈ ធូលីគឺឧបនាហៈ ។ បេ ។ ធូលីគឺអភិសង្ខារជាអកុសលទាំងអស់ ។ ធូលីទាំងនោះ ព្រះពុទ្ធមានជោគលះបង់ ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនមានវិបភាព មានការមិនកើតតទៅជាធម្មតា ហេតុនោះ ព្រះពុទ្ធឈ្មោះថា មិនមានធូលី ប្រាសចាកធូលី មានធូលីទៅប្រាស លះបង់ធូលី ផុតស្រឡះចាកធូលី ។

ឧទយមាណវកប្បញ្ហានិទ្ទេសោ

រាគោ រជោ ន ច បន រេណុ វុច្ចតិ
រាគស្សេតំ អធិវចនំ រជោតិ
ឯតំ រជំ វិប្បជហិត្វ ចក្ខុមា(១)
តស្មា ជិនោ វិគតរជោតិ វុច្ចតិ
ទោសោ រជោ ន ច បន រេណុ វុច្ចតិ
ទោសស្សេតំ អធិវចនំ រជោតិ
ឯតំ រជំ វិប្បជហិត្វ ចក្ខុមា
មោហោ រជោ ន ច បន រេណុ វុច្ចតិ
តស្មា ជិនោ វិគតរជោតិ វុច្ចតិ
មោហស្សេតំ អធិវចនំ រជោតិ
ឯតំ រជំ វិប្បជហិត្វ ចក្ខុមា
តស្មា ជិនោ វិគតរជោតិ វុច្ចតីតិ ។

វិរជំ ។ អាសីនន្តិ និសិន្នោ ភគវា បាសាណកេ ចេតិយេតិ អាសីនោ ។

នគស្ស បស្សេ អាសីនំ មុនឹ ទុក្ខស្ស បារគុំ
សាវកា បយិរុបាសន្តិ តេវិជ្ជា មច្ចុហាយិនោតិ ។

ឯវម្បិ ភគវា អាសីនោ ។ អថវា ភគវា សព្វោស្សុក្កបដិប្បស្សទ្ធត្តា អាសីនោ វុត្ថវាសោ ចិណ្ណចរណោ ។បេ។

---

១ ម. បដិវិនោទេត្វា ន ចក្ខុមា ។

## ឧទយមាណវកបញ្ហានិទ្ទេស

ធូលីសំដៅយករាគៈ មិនមែនលំអងទេ ពាក្យថា ធូលីនុ៎ះ ជាឈ្មោះរាគៈ ព្រះជិនស្រីមានបញ្ញាចក្ខុ លះបង់ធូលីនុ៎ះហើយ ហេតុនោះ ទើបលោកហៅថាអ្នកមានធូលីទៅប្រាស ធូលីសំដៅយកទោសៈ មិនមែនលំអងទេ ពាក្យថា ធូលីនុ៎ះ ជាឈ្មោះទោសៈ ព្រះជិនស្រីមានបញ្ញាចក្ខុ លះបង់ធូលីនុ៎ះហើយ ហេតុនោះ ទើបលោកហៅថាអ្នកមានធូលីទៅប្រាស ធូលីសំដៅយកមោហៈ មិនមែនលំអងទេ ពាក្យថាធូលីនុ៎ះ ជាឈ្មោះមោហៈ ព្រះជិនស្រីមានបញ្ញា-ចក្ខុ លះបង់ធូលីនុ៎ះហើយ ហេតុនោះ ទើបលោកហៅថាអ្នកមានធូលីទៅប្រាស ។

ហេតុនោះ (លោកពោលថា) ប្រាសចាកធូលី ។ ពាក្យថា ទ្រង់គង់នៅ គឺព្រះមានព្រះភាគ ទ្រង់គង់ក្បែរបាសាណកចេតិយ ហេតុនោះ ទើបឈ្មោះថា ទ្រង់គង់នៅ ។

ពួកសាវ័កអ្នកមានត្រៃវិជ្ជា លះបង់មច្ចុហើយ ចូលទៅអង្គុយ
ជិតព្រះមុនី ទ្រង់ដល់ត្រើយនៃទុក្ខ គង់ខាងក្នុំ ។

ព្រះមានព្រះភាគឈ្មោះថាទ្រង់គង់នៅ យ៉ាងនេះក៏បាន ។ មួយទៀត ព្រះមានព្រះភាគឈ្មោះថាទ្រង់គង់នៅ ព្រោះព្រះអង្គរំងាប់សេចក្តីខ្វល់ខ្វាយ ទាំងពួងហើយទ្រង់មានព្រហ្មចរិយៈនៅហើយ មានចរណធម៌សន្សំហើយ ។ បេ ។

ជាតិជរាមរណសំសារេ នត្ថិ តស្ស បុនព្ភវោតិ ឯវម្បិ ភគវា អាសីនោតិ ឈាយឹ វិរជមាសីនំ ។ ឥច្ចាយស្មា ឧទយោតិ ឥច្ចាតិ បទសន្ធិ ។ បេ ។ បទានុបុព្ពតាមេតំ ឥច្ចាតិ ។ អាយស្មាតិ បិយវចនំ គរុវចនំ សគារវសប្បតិស្សាធិវចនមេតំ អាយស្មាតិ ។ ឧទយោតិ តស្ស ព្រាហ្មណស្ស នាមំ ។ បេ ។ អភិលាបោតិ ឥច្ចាយស្មា ឧទយោ ។

(៣) កតកិច្ចំ អនាសវន្តិ ពុទ្ធស្ស ភគវតោ កតកិច្ចំ ករណីយាករណីយំ បហីនំ ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អនភាវង្កតំ អាយតឹ អនុប្បាទធម្មំ តស្មា ពុទ្ធោ កតកិច្ចោ ។

យស្ស បរិបតា(១) នត្ថិ ឆិន្នសោតស្ស ភិក្ខុនោ
កិច្ចាកិច្ចំ បហីនស្ស បរិឡាហោ ន វិជ្ជតីតិ ។

កតកិច្ចំ ។ អនាសវន្តិ អាសវាតិ ចត្តារោ អាសវា កាមាសវោ ភវាសវោ ទិដ្ឋាសវោ អវិជ្ជាសវោ ។

១ ម. យស្ស ច វិសតា ។

ភពបីគឺ ជាតិជរាមរណសង្សារ មិនមានដល់ព្រះមានព្រះភាគនោះ ហេតុនោះ ព្រះមានព្រះភាគ ឈ្មោះថាទ្រង់គង់នៅ យ៉ាងនេះក៏បាន ហេតុនោះលោកពោលថា អ្នកមានឈានប្រាសចាកធូលីទ្រង់គង់នៅ ។ ពាក្យថា ដូច្នេះ ក្នុងបទថា ឥទយៈមានអាយុពោលដូច្នេះ គឺជាការតបទ ។ បេ ។ ពាក្យថាដូច្នេះនេះ ជាលំដាប់បទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ជាពាក្យគោរព ពាក្យថា មានអាយុនេះ ជាពាក្យពោលដោយគោរពកោតក្រែង ។ ពាក្យថា ឥទយៈ ជាឈ្មោះ ។ បេ ។ ជាពាក្យហៅនូវព្រាហ្មណ៍នោះ ហេតុនោះ (ទើបមានពាក្យថា) ឥទយៈមានអាយុពោលដូច្នេះ ។

(៣) ពាក្យថា ទ្រង់មានកិច្ចធ្វើរួចហើយ មិនមានអាសវៈ គឺកិច្ចគួរធ្វើនឹងមិនគួរធ្វើ ព្រះពុទ្ធមានជោគលះបង់ផ្តាច់ផ្តិលបុសគល់ ធ្វើឲ្យសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនមានបែបភាព មិនមានការកើតតទៅជាធម្មតា ហេតុនោះ ព្រះពុទ្ធឈ្មោះថាមានកិច្ចធ្វើហើយ ។

> ភិក្ខុណាមិនមានតណ្ហា សេចក្តីក្តៅក្រហាយ នៃភិក្ខុនោះ
> ដែលជាអ្នកកាត់ផ្តាច់នូវខ្សែនៃតណ្ហា លះបង់នូវកិច្ចគួរធ្វើ
> នឹងមិនគួរធ្វើ រមែងមិនមាន ។

ហេតុនោះ(លោកពោលថា)មានកិច្ចធ្វើរួចហើយ។ពាក្យថាអាសវៈ ក្នុងបទថា មិនមានអាសវៈបានដល់អាសវៈ៤គឺកាមាសវៈភវាសវៈទិដ្ឋាសវៈអវិជ្ជាសវៈ។

តេ អាសវា ពុទ្ធស្ស ភគវតោ បហីនា ឧច្ឆិន្នមូលា
តាលាវត្ថុកតា អនភាវង្កតា អាយតឹអនុប្បាទធម្មា
តស្មា ពុទ្ធោ អនាសវាតិ កតកិច្ចំ អនាសវំ ។

(២) បារគុំ សព្វធម្មានន្តិ ភគវា សព្វធម្មានំ
អភិញ្ញាបារគូ បរិញ្ញាបារគូ បហានបារគូ ភាវនាបា-
រគូ សច្ឆិកិរិយាបារគូ សមាបត្តិបារគូ អភិញ្ញាបារគូ
សព្វធម្មានំ បរិញ្ញាបារគូ សព្វទុក្ខានំ បហានបារគូ
សព្វកិលេសានំ ភាវនាបារគូ ចតុន្នំ មគ្គានំ សច្ឆិ-
កិរិយាបារគូ និរោធស្ស សមាបត្តិបារគូ សព្វសមា-
បត្តីនំ ។ សោ វសិប្បត្តោ បារមិប្បត្តោ អរិយស្មឹ
សីលស្មឹ វសិប្បត្តោ បារមិប្បត្តោ អរិយស្មឹ សមា-
ធិស្មឹ វសិប្បត្តោ បារមិប្បត្តោ អរិយាយ បញ្ញា-
យ វសិប្បត្តោ បារមិប្បត្តោ អរិយាយ វិមុត្តិយា

អាសវៈទាំងនោះ ព្រះពុទ្ធមានរោគលះបង់ ផ្ដិលផ្ដាច់ឫសគល់ ធ្វើឲ្យសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនមានបែបភាព មិនមានការកើតតទៅជាធម្មតា ហេតុនោះ ព្រះពុទ្ធឈ្មោះថាមិនមានអាសវៈ ហេតុនោះ (លោកពោលថា) ទ្រង់មានកិច្ចធ្វើរួចហើយ មិនមានអាសវៈ ។

(៤) ពាក្យថា ទ្រង់ដល់ត្រើយនៃធម៌ទាំងពួង គឺព្រះមានព្រះភាគទ្រង់ដល់ត្រើយនៃការត្រាស់ដឹងធម៌ទាំងពួង ដល់ត្រើយនៃការកំណត់ដឹង ដល់ត្រើយនៃការលះបង់ ដល់ត្រើយនៃការចម្រើន ដល់ត្រើយនៃការធ្វើឲ្យជាក់ច្បាស់ ដល់ត្រើយនៃសមាបត្តិ ដល់ត្រើយនៃការត្រាស់ដឹងធម៌ទាំងពួង ដល់ត្រើយនៃការកំណត់ដឹងទុក្ខទាំងពួង ដល់ត្រើយនៃការលះកិលេសទាំងពួង ដល់ត្រើយនៃការចម្រើនមគ្គទាំង ៤ ដល់ត្រើយនៃការធ្វើឲ្យជាក់ច្បាស់នូវនិរោធ ដល់ត្រើយនៃការចូលកាន់សមាបត្តិទាំងពួង ។ ព្រះអង្គដល់នូវការស្ទាត់ ដល់ត្រើយក្នុងអរិយសីល ដល់នូវការស្ទាត់ ដល់ត្រើយក្នុងអរិយសមាធិ ដល់នូវការស្ទាត់ ដល់ត្រើយក្នុងអរិយបញ្ញា ដល់នូវការស្ទាត់ ដល់ត្រើយក្នុងអរិយវិមុត្តិ

សោ បារគតោ បារប្បត្តោ អន្តគតោ អន្តប្បត្តោ កោដិគតោ កោដិប្បត្តោ បរិយន្តគតោ បរិយន្តប្បត្តោ វោសានគតោ វោសានប្បត្តោ តាណគតោ តាណប្បត្តោ លេណគតោ លេណប្បត្តោ ចរណគតោ ចរណប្បត្តោ(១) អភយគតោ អភយប្បត្តោ អច្ចុតគតោ អច្ចុតប្បត្តោ អមតគតោ អមតប្បត្តោ និព្វានគតោ និព្វានប្បត្តោ សោ វុដ្ឋវាសោ ចិណ្ណចរណោ ។ បេ ។ ជាតិជរាមរណសំសារោ នត្ថិ តស្ស បុនព្ភវោតិ បារគុំ សព្វធម្មានំ ។

(៤) អត្ថិ បញ្ហេន អាគមន្តិ បញ្ហត្ថិកាម្ហា អាគតា បញ្ហបុច្ឆកាម្ហា អាគតា បញ្ហំ សោតុកាមា អាគតម្ហាតិ ឯវម្បិ អត្ថិ បញ្ហេន អាគមំ ។ អថវា បញ្ហត្ថិកានំ បញ្ហបុច្ឆកានំ បញ្ហំ សោតុកាមានំ អាគមំ អភិក្កមនំ(២) ឧបសង្កមនំ(៣) អត្ថីតិ ឯវម្បិ អត្ថិ បញ្ហេន អាគមំ ។

---

១ ម. សរណាគតោ សរណាបត្តោ ។ ២ ម. អាគមនំ ។ ៣ ម. ឯត្ថន្តរេ បយិរុបាសនន្តិ ទិស្សតិ ។

ព្រះអង្គទៅកាន់ត្រើយ ដល់ត្រើយ ទៅកាន់ទីបំផុត ដល់ទីបំផុត ទៅកាន់ទីខានចុង ដល់ទីខានចុង ទៅកាន់ទីបំផុតជុំវិញ ដល់ទីបំផុតជុំវិញ ទៅកាន់ទីចុងបំផុត ដល់ទីចុងបំផុត ទៅកាន់ទីជាទីពឹង ដល់ទីជាទីពឹង ទៅកាន់ទីជាទីពួន ដល់ទីជាទីពួន ទៅកាន់ទីជាទីប្រព្រឹត្ត ដល់ទីជាទីប្រព្រឹត្ត ទៅកាន់ទីមិនមានភ័យ ដល់ទីមិនមានភ័យ ទៅកាន់ទីទៀងទាត់ ដល់ទីទៀងទាត់ ទៅកាន់ទីមិនស្លាប់ ដល់ទីមិនស្លាប់ ទៅកាន់ព្រះនិព្វាន ដល់ព្រះនិព្វាន ព្រះមានព្រះភាគនោះ ទើបឈ្មោះថា ជាបុគ្គលមានអរិយវាសៈនៅរួចហើយ មានចរណធម៌សន្សំហើយ ។ បេ ។ ភពថ្មី គឺជាតិ ជរា និងមរណៈ សង្សារ មិនមានដល់ព្រះមានព្រះភាគនោះ ហេតុនោះ (លោកពោលថា) ដល់ត្រើយនៃធម៌ទាំងពួង ។

(៤) ពាក្យថា ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយប្រស្នាទើបមកគាល់ សេចក្តីថា ពួកខ្ញុំព្រះអង្គត្រូវការដោយប្រស្នាទើបមក ជាអ្នកសួរប្រស្នាទើបមក ចង់ស្តាប់ប្រស្នាទើបមក ហេតុនោះ (លោកពោលថា) ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយប្រស្នាទើបមកគាល់ យ៉ាងនេះក៏បាន ។ មួយទៀត ការមក ការចូលមក ការចូលមកគាល់ របស់ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយប្រស្នា ជាអ្នកសួរប្រស្នា ចង់ស្តាប់ប្រស្នា ហេតុនោះ (លោកពោលថា) ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយប្រស្នាទើបមក យ៉ាងនេះក៏បាន ។

## ឧទយមាណវបុច្ឆានិទ្ទេសោ

អថវា បញ្ហាគមោ តុយ្ហំ អត្ថិ ត្វម្បិ(១) បហុ វិសវី អលមត្តោ មយា សទ្ធឹ បុច្ឆិតុំ កថេតុំ វិស្សជ្ជេតុំ វហស្សេតំ ភារន្តិ ឯវម្បិ អត្ថិ បញ្ហេន អាគមំ ។

(៦) អញ្ញាវិមោក្ខំ សំព្រូហីតិ អញ្ញាវិមោក្ខោ វុច្ចតិ អរហត្តវិមោក្ខោ ។ អរហត្តវិមោក្ខំ សំព្រូហិ អាចិក្ខាហិ ទេសេហិ បញ្ញបេហិ បដ្ឋបេហិ វិវរាហិ វិភជាហិ ឧត្តានីករោហិ បកាសេហីតិ អញ្ញាវិមោក្ខំ សំព្រូហិ ។

(៧) អវិជ្ជាយ បភេទនន្តិ អវិជ្ជាយ ភេទនំ បភេទនំ បហានំ វូបសមំ បដិនិស្សគ្គំ បដិប្បស្សទ្ធិំ អមតំ និព្វានន្តិ អវិជ្ជាយ បភេទនំ ។ តេនាហ សោ ព្រាហ្មណោ

ឈាយឹ វិរជមាសីនំ (ឥច្ចាយស្មា ឧទយោ)
កតកិច្ចំ អនាសវំ
បារគុំ សព្វធម្មានំ
អត្ថិ បញ្ហេន អាគមំ
អញ្ញាវិមោក្ខំ សំព្រូហិ
អវិជ្ជាយ បភេទនន្តិ ។

១ ម. ឯត្តន្តរេ បារគូតិ ទិស្សតិ ។

ឬថា ការមកដោយប្រស្នាមានដល់ព្រះអង្គ ។ ជាបុគ្គលរាប ជាបុគ្គលមានព្យាយាម ជាបុគ្គលល្អមដើម្បីសួរ សំដែង ដោះស្រាយ ពន្យល់ពោល ជាមួយនឹងខ្ញុំព្រះអង្គ ហេតុនោះ (លោកពោលថា) ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយប្រស្នាទើបមក យ៉ាងនេះក៏បាន ។

(៦) ពាក្យថា សូមព្រះអង្គសំដែងអញ្ញាវិមោក្ខ សេចក្ដីថា អរហត្តវិមោក្ខ លោកហៅថា អញ្ញាវិមោក្ខ ។ សូមព្រះអង្គសំដែង ប្រាប់ ពន្យល់ ប្រញ័ប្ត តាំងផ្ដើម បើក បែក ធ្វើឲ្យងាយ ប្រកាស នូវអរហត្តវិមោក្ខ ហេតុនោះ (លោកពោលថា) សូមព្រះអង្គសំដែងអញ្ញាវិមោក្ខ ។

(៧) ពាក្យថា ជាគ្រឿងទម្លាយអវិជ្ជា គឺជាគ្រឿងបំបែក ទម្លាយ លះបង់ រំងាប់ លះចោល កំចាត់បង់នូវអវិជ្ជា គឺអមតនិព្វាន ហេតុនោះ (លោកពោលថា) ជាគ្រឿងទម្លាយអវិជ្ជា ។ ហេតុនោះ ព្រាហ្មណ៍នោះពោលហើយថា

> (ឧទយៈមានអាយុក្រាបទូលដូច្នេះថា) ខ្ញុំព្រះអង្គជាអ្នកត្រូវ
> ការដោយប្រស្នាទើបមកគាល់ (ដើម្បីសួរ) ព្រះអង្គជាអ្នក
> មានឈាន មានព្រះសន្ដានប្រាសចាកធូលី ទ្រង់គង់នៅ
> ទ្រង់មានកិច្ចធ្វើរួចហើយ មិនមានអាសវៈ ទ្រង់ដល់នូវ
> ត្រើយនៃធម៌ទាំងពួង សូមព្រះអង្គសំដែងអញ្ញាវិមោក្ខជា
> គ្រឿងទម្លាយអវិជ្ជា ។

(៨) បហានំ កាមច្ឆន្ទានំ (ឧទយាតិ ភគវា)

ទោមនស្សាន ចូភយំ

ថីនស្ស ច បនូទនំ

កុក្កុច្ចានំ និវារណំ ។

(៩) បហានំ កាមច្ឆន្ទានន្តិ ឆន្ទាតិ យោ កាមេសុ កាមច្ឆន្ទោ កាមរាគោ កាមនន្ទី កាមតណ្ហា កាមសិនេហោ កាមបរិឡាហោ កាមមុច្ឆា កាមជ្ឈោសានំ កាមោឃោ កាមយោគោ កាមុបាទានំ កាមច្ឆន្ទនីវរណំ ។ បហានំ កាមច្ឆន្ទានន្តិ កាមច្ឆន្ទានំ បហានំ វូបសមោ បដិនិស្សគ្គោ បដិប្បស្សទ្ធិ អមតំ និព្ពានន្តិ បហានំ កាមច្ឆន្ទានំ ។ ឧទយាតិ ភគវាតិ ឧទយាតិ ភគវា តំ ព្រាហ្មណំ នាមេន អាលបតិ ។ ភគវាតិ គារវាធិវចនមេតំ ។ បេ ។ សច្ចិកា បញ្ញត្តិ យទិទំ ភគវាតិ ឧទយាតិ ភគវា ។

(៨) (ព្រះមានព្រះភាគត្រាស់ថា) ម្នាលឧទយៈ តថាគតសំដែងថា ការលះនូវអកុសលធម៌ទាំងពីរ គឺកាមច្ឆន្ទៈនឹងទោមនស្សផង ការបន្ទោបង់ចិត្តរួញាកផង ការហាមឃាត់កុក្កុច្ចៈទាំងឡាយផង (ជាអញ្ញាវិមោក្ខ) ។

(៩) ពាក្យថា ការលះកាមច្ឆន្ទៈ ត្រង់ពាក្យថា ឆន្ទៈ បានដល់សេចក្តីពេញចិត្តចំពោះកាម សេចក្តីត្រេកត្រអាលចំពោះកាម សេចក្តីរីករាយចំពោះកាម សេចក្តីប្រាថ្នាក្នុងកាម សេចក្តីស្នេហាក្នុងកាម សេចក្តីស្រេកឃ្លានក្នុងកាម សេចក្តីអន្ទះអន្ទែងក្នុងកាម សេចក្តីជ្រប់ចុះក្នុងកាម សេចក្តីងប់ក្នុងកាម ឱឃៈគឺកាម យោគៈគឺកាម ឧបាទានគឺកាម នីវរណៈគឺកាម-ឆន្ទៈក្នុងកាមទាំងឡាយ ។ ពាក្យថា ការលះ កាមច្ឆន្ទៈ គឺការលះ ការរំងាប់ ការលះបង់ ការកំចាត់បង់កាមច្ឆន្ទៈ អមតនិព្វាន ហេតុនោះ (ទ្រង់ត្រាស់ថា) ការលះកាមច្ឆន្ទៈ ។ ពាក្យថា ឧទយៈ ក្នុងបទថា ព្រះមានព្រះភាគ (ត្រាស់ថា) ម្នាលឧទយៈ គឺព្រះមានព្រះភាគត្រាស់ហៅព្រាហ្មណ៍នោះដោយឈ្មោះ ។ ត្រង់ពាក្យថា ព្រះមានព្រះភាគនុ៎ះ ជាពាក្យនិយាយដោយគោរព ។ បេ ។ បញ្ញត្តិថា មានព្រះភាគ នេះ (កើត) ព្រោះការត្រាស់ដឹង ហេតុនោះ (ទើបមានពាក្យថា) ព្រះមានព្រះភាគត្រាស់ថា ម្នាលឧទយៈ ។

ឧទយមាណវកប្បញ្ហានិទ្ទេសោ

(១០) ទោមនស្សាន ចូភយន្តិ ទោមនស្សន្តិ យំ ចេតសិកំ អសាតំ ចេតសិកំ ទុក្ខំ ចេតោសម្ផស្សជំ អសាតំ ទុក្ខំ វេទយិតំ ចេតោសម្ផស្សជា អសាតា ទុក្ខា វេទនា ។ ទោមនស្សាន ចូភយន្តិ កាមច្ឆន្ទស្ស ច ទោមនស្សស្ស ច ឧភិន្នំ បហានំ វូបសមោ បដិនិស្សគ្គោ បដិប្បស្សទ្ធិ អមតំ និព្វានន្តិ ទោមនស្សាន ចូភយំ ។

(១១) ថីនស្ស ច បនូទនន្តិ យា ចិត្តស្ស អកល្លតា អកម្មញ្ញតា ឱលីយនា សល្លីយនា លីនំ លីយនា លីយិតត្តំ ថីនំ ថីយនា ថីយិតត្តំ ។ ថីនស្ស ច បនូទនន្តិ ថីនស្ស ច បនូទនំ បហានំ វូបសមោ បដិនិស្សគ្គោ បដិប្បស្សទ្ធិ អមតំ និព្វានន្តិ ថីនស្ស ច បនូទនំ ។

(១២) កុក្កុច្ចានំ និវារណន្តិ កុក្កុច្ចានន្តិ ហត្ថកុក្កុច្ចម្បិ កុក្កុច្ចំ បាទកុក្កុច្ចម្បិ កុក្កុច្ចំ ហត្ថបាទកុក្កុច្ចម្បិ កុក្កុច្ចំ អកប្បិយេ កប្បិយសញ្ញិតា កប្បិយេ អកប្បិយសញ្ញិតា

ឧទយមាណវកប្បញ្ហានិទ្ទេស

(១០) ពាក្យថា ការលះបង់នូវអកុសលធម៌ទាំងពីរ គឺទោមនស្ស ត្រង់ពាក្យថា ទោមនស្ស បានដល់ចេតសិកដែលមិនជាទីត្រេកអរ ចេតសិកជាទុក្ខ ការទទួលអារម្មណ៍មិនជាទីត្រេកអរ ជាទុក្ខ ដែលកើតអំពីសម្ផស្សនៃចិត្ត គឺវេទនាមិនជាទីត្រេកអរ ជាទុក្ខ ដែលកើតអំពីសម្ផស្សនៃចិត្ត ។ ពាក្យថា ការលះនូវអកុសលធម៌ទាំងពីរ គឺទោមនស្ស បានសេចក្តីថា ការលះ ការរំងាប់ ការលះបង់ ការកំចាត់បង់ នូវអកុសលធម៌ទាំង ២ គឺកាមច្ឆន្ទៈ នឹងទោមនស្ស (ដៅចំពោះ) អមតនិព្វាន ហេតុនោះ (ទ្រង់ត្រាស់ថា) ការលះនូវអកុសលធម៌ទាំងពីរ គឺពួកទោមនស្ស ។

(១១) ពាក្យថា ការបន្ទោបង់ចិត្តរួញរា បានដល់ភាពនៃចិត្តមិនស្រួល មិនគួរដល់ការងារ កិរិយារួញ ការរួញរា ការក្រាញ អាការនៃការក្រាញ ភាពនៃការក្រាញ ការប្រអុស អាការនៃការប្រអូស ភាពនៃការប្រអូស ។ ពាក្យថា ការបន្ទោបង់ចិត្តរួញរា គឺការបន្ទោបង់ ការលះបង់ ការរំងាប់ ការលះចោល ការស្ងប់រម្ងាប់ចិត្តរួញរា (ដៅចំពោះ) អមតនិព្វាន ហេតុនោះ (ទ្រង់ត្រាស់ថា) ការបន្ទោបង់ចិត្តរួញរា ។

(១២) ពាក្យថា កុក្កុច្ចៈទាំងឡាយ ក្នុងបទថា ការហាមឃាត់កុក្កុច្ចៈទាំងឡាយ បានដល់ ការរពឹសដៃ ហៅថាកុក្កុច្ចៈក៏បាន ការរពឹសជើងហៅថាកុក្កុច្ចៈក៏បាន ការរពឹសទាំងដៃទាំងជើង ហៅថា កុក្កុច្ចៈក៏បាន សេចក្តីសំគាល់ថាគួរ ក្នុងរបស់ដែលមិនគួរ សំគាល់ថាមិនគួរ ក្នុងរបស់ដែលគួរ

វជ្ជេ អវជ្ជសញ្ញិតា អវជ្ជេ វជ្ជសញ្ញិតា យំ ឯវរូបំ កុក្កុច្ចំ កុក្កុច្ចាយនា កុក្កុច្ចាយិតត្តំ ចេតសោ វិប្បដិសារោ មនោវិលេខោ ឥទំ វុច្ចតិ កុក្កុច្ចំ ។ អបិច ទ្វីហិ ការណេហិ ឧប្បជ្ជតិ កុក្កុច្ចំ ចេតសោ វិប្បដិសារោ មនោវិលេខោ កតត្តា ច អកតត្តា ច ។ កថំ កតត្តា ច អកតត្តា ច ឧប្បជ្ជតិ កុក្កុច្ចំ ចេតសោ វិប្បដិសារោ មនោវិលេខោ ។ កតំ មេ កាយទុច្ចរិតំ អកតំ មេ កាយសុចរិតន្តិ ឧប្បជ្ជតិ កុក្កុច្ចំ ចេតសោ វិប្បដិសារោ មនោវិលេខោ ។ កតំ មេ វចីទុច្ចរិតំ អកតំ មេ វចីសុចរិតន្តិ កតំ មេ មនោទុច្ចរិតំ អកតំ មេ មនោសុចរិតន្តិ កតោ មេ បាណាតិបាតោ អកតា មេ បាណាតិបាតា វេរមណីតិ កតំ មេ អទិន្នាទានំ អកតា មេ អទិន្នាទានា វេរមណីតិ កតោ មេ កាមេសុ មិច្ឆាចារោ អកតា មេ កាមេសុ មិច្ឆាចារា វេរមណីតិ កតោ មេ មុសាវាទោ អកតា មេ មុសាវាទា វេរមណីតិ

សេចក្តីសំគាល់ថាមិនមានទោសក្នុងរបស់ដែលមានទោស សេចក្តីសំគាល់ថាមានទោសក្នុងរបស់ដែលមិនមានទោស សេចក្តីរពឹស អាការនៃការប្រ-ព្រឹត្តិរពឹស ភាពនៃការប្រព្រឹត្តិរពឹស សេចក្តីក្តៅក្រហាយចិត្ត គំនូសនៃចិត្តណា មានសភាពយ៉ាងនេះ នេះលោកហៅថាកុក្កុច្ចៈ ។ មួយទៀត សេច-ក្តីរពឹស សេចក្តីក្តៅក្រហាយចិត្ត គំនូសនៃចិត្ត តែងកើតដោយហេតុពីរ គឺ ព្រោះភាពនៃការធ្វើ ១ ព្រោះភាពនៃការមិនធ្វើ ១ ។ ចុះសេចក្តីរពឹស សេចក្តីក្តៅក្រហាយចិត្ត គំនូសនៃចិត្ត កើតព្រោះភាពនៃការធ្វើ ១ ព្រោះភាពនៃការមិនធ្វើ ១ តើដូចម្តេច ។ សេចក្តីរពឹស សេចក្តីក្តៅក្រហាយចិត្ត គំនូសនៃចិត្ត កើតឡើងដោយគំនិតដូច្នេះថា កាយ-ទុច្ចរិត អាត្មាអញបានធ្វើ កាយសុចរិត អាត្មាអញមិនបានធ្វើឡើយ ។ សេចក្តីរពឹស សេចក្តីក្តៅក្រហាយចិត្ត គំនូសនៃចិត្ត កើតឡើងដោយគំនិតដូច្នេះ ថា វចីទុច្ចរិតអាត្មាអញបានធ្វើ វចីសុចរិតអាត្មាអញមិនបានធ្វើឡើយថា មនោទុច្ចរិត អាត្មាអញបានធ្វើ មនោសុចរិត អាត្មាអញមិនបានធ្វើឡើយ ថា បាណាតិបាត អាត្មាអញបានធ្វើ ការវៀរចាកបាណាតិបាត អាត្មាអញមិនបានធ្វើឡើយ ថា អទិន្នាទាន អាត្មាអញបានធ្វើ ការវៀរចាកអទិន្នាទាន អាត្មាអញមិនបានធ្វើឡើយ ថា កាមេសុមិច្ឆាចារ អាត្មាអញបានធ្វើ ការវៀរចាកកាមេសុមិច្ឆាចារ អាត្មាអញមិនបានធ្វើឡើយថា មុសា-វាទអាត្មាអញបានធ្វើ ការវៀរចាកមុសាវាទ អាត្មាអញមិនបានធ្វើឡើយ

## ឧទេបមាណោកប្បញ្ញានិទ្ទេសោ

កតា មេ បិសុណា វាចា អកតា មេ បិសុណាយ វាចាយ វេរមណីតិ កតា មេ ផរុសា វាចា អកតា មេ ផរុសាយ វាចាយ វេរមណីតិ កតោ មេ សម្ផប្ប-លាបោ អកតា មេ សម្ផប្បលាបា វេរមណីតិ កតា មេ អភិជ្ឈា អកតា មេ អនភិជ្ឈាតិ កតោ មេ ព្យា-បាទោ អកតោ មេ អព្យាបាទោតិ កតា មេ មិច្ឆា-ទិដ្ឋិ អកតា មេ សម្មាទិដ្ឋីតិ ឧប្បជ្ជតិ កុក្កុច្ចំ ចេត-សោ វិប្បដិសារោ មនោវិលេខោ ។ ឯវំ កតត្តា ច អកតត្តា ច ឧប្បជ្ជតិ កុក្កុច្ចំ ចេតសោ វិប្បដិសារោ មនោវិលេខោ ។ អថវា សីលេសុម្ហិ អបរិបូរការីតិ ឧប្បជ្ជតិ កុក្កុច្ចំ ចេតសោ វិប្បដិសារោ មនោវិលេ-ខោ ។ ឥន្ទ្រិយេសុម្ហិ អគុត្តទ្វារោតិ ភោជនេ អមត្តញ្ញុ-ម្ហីតិ ជាគរិយំ អននុយុត្តោម្ហីតិ ន សតិសម្បជញ្ញេន ស-មន្នាគតោម្ហីតិ អភាវិតា មេ ចត្តារោ សតិបដ្ឋានាតិ អភាវិតា មេ ចត្តារោ សម្មប្បធានាតិ អភាវិតា មេ ចត្តារោ ឥទ្ធិបាទាតិ អភាវិតានិ មេ បញ្ចិន្ទ្រិយានីតិ

ថា បិសុណាវាចា អាត្មាអញបានធ្វើ ការវៀរចាកបិសុណាវាចា អាត្មាអញមិនបានធ្វើឡើយ ថា ផរុសវាចា អាត្មាអញបានធ្វើ ការវៀរចាកផរុសវាចា អាត្មាអញមិនបានធ្វើឡើយ ថា សម្ផប្បលាបៈ អាត្មាអញបានធ្វើ ការវៀរចាកសម្ផប្បលាបៈ អាត្មាអញមិនបានធ្វើឡើយ ថា អភិជ្ឈា អាត្មាអញបានធ្វើ ការមិនមានអភិជ្ឈា អាត្មាអញមិនបានធ្វើឡើយ ថា ព្យាបាទ អាត្មាអញបានធ្វើ ការមិនព្យាបាទ អាត្មាអញមិនបានធ្វើឡើយ ថា មិច្ឆាទិដ្ឋិអាត្មាអញបានធ្វើ សម្មាទិដ្ឋិ អាត្មាអញមិនបានធ្វើឡើយ ៗ សេចក្តីរពឹស សេចក្តីក្តៅក្រហាយចិត្ត គំនូសនៃចិត្ត កើតឡើង ព្រោះភាពនៃការធ្វើ និងភាពនៃការមិនធ្វើ យ៉ាងនេះ ៗ មួយទៀត សេចក្តីរពឹស ការក្តៅក្រហាយចិត្ត គំនូសនៃចិត្ត កើតឡើងដោយគំនិតដូច្នេះថា អាត្មាអញមិនបានបំពេញក្នុងសីលទាំងឡាយទេ ៗ សេចក្តីរពឹស ការក្តៅក្រហាយចិត្ត គំនូសនៃចិត្តកើតឡើងដោយគំនិតដូច្នេះថា អាត្មាអញមិនបានគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ថា អាត្មាអញមិនដឹងប្រមាណក្នុងភោជនទេ ថា អាត្មាអញមិនបានប្រកបរឿយៗ នូវសេចក្តីភ្ញាក់រឭកទេ ថា អាត្មាអញមិនបានប្រកបដោយសតិ និងសម្បជញ្ញៈទេ ថា សតិប្បដ្ឋានទាំង ៤ អាត្មាអញមិនបានចម្រើនទេ ថា សម្មប្បធានទាំង៤អាត្មាអញមិនបានចម្រើនទេ ថា ឥទ្ធិបាទ ៤ អាត្មាអញមិនបានចម្រើនទេ ថា ឥន្ទ្រិយ ៥ អាត្មាអញមិនបានចម្រើនទេ

អភាវិតានិ មេ បញ្ច ពលានីតិ អភាវិតា មេ សត្ត
ពោជ្ឈង្គាតិ អភាវិតោ មេ អរិយោ អដ្ឋង្គិកោ មគ្គោតិ
ទុក្ខំ មេ អបរិញ្ញាតន្តិ សមុទយោ មេ អប្បហីនោតិ
មគ្គោ មេ អភាវិតោតិ និរោធោ មេ អសច្ឆិកតោតិ
ឧប្បជ្ជតិ កុក្កុច្ចំ ចេតសោ វិប្បដិសារោ មនោវិ-
លេខោ ។ កុក្កុច្ចានំ និវារណន្តិ កុក្កុច្ចានំ អាវ-
រណំ និវរណំ បហានំ វូបសមោ បដិនិស្សគ្គោ ប-
ដិប្បស្សទ្ធិ អមតំ និព្វានន្តិ កុក្កុច្ចានំ និវារណំ ។
តេនាហ ភគវា

បហានំ កាមច្ឆន្ទានំ (ឧទយាតិ ភគវា)
ទោមនស្សាន ចូភយំ
ថីនស្ស ច បនូទនំ
កុក្កុច្ចានំ និវារណន្តិ ។

(១៣) ឧបេក្ខាសតិសំសុទ្ធំ ធម្មតក្កបុរេជវំ
អញ្ញាវិមោក្ខំ បព្រូមិ អវិជ្ជាយ បភេទនំ ។

ថា ពលៈ ៥ អាត្មាអញមិនបានចម្រើនទេ ថា ពោជ្ឈង្គ៍ទាំង ៧ អាត្មាអញមិនបានចម្រើនទេ ថា មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ អាត្មាអញមិនបានចម្រើនទេ ថា ទុក្ខ អាត្មាអញមិនបានកំណត់ដឹងទេ ថា សមុទ័យ អាត្មាអញមិនបានលះបង់ទេ ថា មគ្គ អាត្មាអញ មិនបានចម្រើនទេ ថា និរោធ អាត្មាអញមិនបានធ្វើឲ្យជាក់ច្បាស់ទេ ។ ពាក្យថា ការហាមឃាត់កុក្កុច្ចៈទាំងឡាយ បានន័យថា ការទប់ ការពាំង ការលះ ការរំងាប់ ការលះចោល ការស្ងប់រម្ងាប់កុក្កុច្ចៈ (ដោយចំពោះ) អមតនិព្វាន ហេតុនោះ (ទ្រង់ត្រាស់ថា) ការហាមឃាត់កុក្កុច្ចៈទាំងឡាយ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

(ព្រះមានព្រះភាគត្រាស់ថា ម្នាលឧទយៈ តថាគតសំដែងថា)
ការលះនូវអកុសលធម៌ទាំង ២ គឺ កាមច្ឆន្ទៈ នឹងទោមនស្ស
ផង ការបន្ទោបង់ចិត្តរួញរាផង ការហាមឃាត់កុក្កុច្ចៈ
ទាំងឡាយផង (ជាអញ្ញាវិមោក្ខ) ។

(១៣) មួយទៀត តថាគតសំដែង នូវឧបេក្ខានឹងសតិ ដ៏
បរិសុទ្ធ នូវការត្រិះរិះធម៌ស្មុះទៅមុន ថាជាអញ្ញាវិមោក្ខ
ជាគ្រឿងទម្លាយអវិជ្ជា ។

(១៤) ឧបេក្ខាសតិសំសុទ្ធន្តិ ឧបេក្ខាតិ យា ចតុត្ថជ្ឈានេ ឧបេក្ខា ឧបេក្ខនា អជ្ឈុបេក្ខនា ចិត្តសមថោ ចិត្តប្បសាទតា មជ្ឈត្តតា ចិត្តស្ស ។ សតីតិ យា ចតុត្ថជ្ឈានេ ឧបេក្ខំ អារព្ភ សតិ អនុស្សតិ ។បេ។ សម្មាសតីតិ ឧបេក្ខាសតិ ។ សំសុទ្ធន្តិ ចតុត្ថជ្ឈានេ ឧបេក្ខា ច សតិ ច សុទ្ធា ហោន្តិ សំសុទ្ធា បរិយោទាតា អនង្គណា វិគតុបក្កិលេសា មុទុភូតា កម្មនិយា ឋិតា អានេញ្ជប្បត្តាតិ ឧបេក្ខាសតិសំសុទ្ធំ ។

(១៥) ធម្មតក្កបុរេជវន្តិ ធម្មតក្កោ វុច្ចតិ សម្មាសង្កប្បោ ។ សោ អាទិតោ ហោតិ បុរតោ ហោតិ បុព្វង្គមោ ហោតិ អញ្ញាវិមោក្ខស្សាតិ ឯវម្បិ ធម្មតក្កបុរេជវំ ។ អថវា ធម្មតក្កោ វុច្ចតិ សម្មាទិដ្ឋិ ។ សា អាទិតោ ហោតិ បុរតោ ហោតិ បុព្វង្គមា ហោតិ អញ្ញាវិមោក្ខស្សាតិ ឯវម្បិ ធម្មតក្កបុរេជវំ ។ អថវា ធម្មតក្កោ វុច្ចតិ ចតុន្នំ មគ្គានំ បុព្វភាគេ វិបស្សនា ។

ឧទយមាណវកប្បញ្ហានិទ្ទេស

(១៨) ពាក្យថា ឧបេក្ខា ក្នុងបទថា ឧបេក្ខា នឹងសតិដ៏បរិសុទ្ធ បានដល់ការព្រងើយ អាការព្រងើយ អាការនៃចិត្តសោះអង្គើយ ការស្ងប់ចិត្ត សេចក្តីថាស្អាតនៃចិត្ត ភាពនៃចិត្តជាកណ្តាល ក្នុងចតុត្ថជ្ឈាន ។ ពាក្យថា សតិ បានដល់ស្មារតី ការរលឹករឿយៗ ។ បេ ។ ការរលឹកដោយប្រពៃ ប្រារព្ធឧបេក្ខា ក្នុងចតុត្ថជ្ឈាន ហេតុនោះ (ទ្រង់ត្រាស់ថា) ឧបេក្ខានឹងសតិ ។ ពាក្យថា បរិសុទ្ធ បានដល់ឧបេក្ខា នឹងសតិក្នុងចតុត្ថជ្ឈាន ជាធម្មជាតិដ៏ស្អាត ស្អាតព្រម ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស ជាធម្មជាតិទន់ក្ងន់ គួរដល់ការងារ ជាធម្មជាតិនឹងធឹង ដល់នូវការមិនកម្រើក ហេតុនោះ (ទ្រង់ត្រាស់ថា) ឧបេក្ខា នឹងសតិ ដ៏បរិសុទ្ធ ។

(១៩) ពាក្យថា ការត្រិះរិះធម៌ស្ទុះទៅមុន សេចក្តីថា សម្មាសង្កប្បៈ លោកហៅថា ការត្រិះរិះធម៌ ។ សម្មាសង្កប្បៈនោះ ជាខាងដើម ជាខាងមុខ ជាប្រធាន នៃអញ្ញាវិមោក្ខ ហេតុនោះ (ទ្រង់ត្រាស់ថា) ការត្រិះរិះធម៌ស្ទុះទៅមុន យ៉ាងនេះក៏បាន ។ មួយទៀត សម្មាទិដ្ឋិ លោកហៅថា ការត្រិះរិះធម៌ ។ សម្មាទិដ្ឋិនោះ ជាខាងដើម ជាខាងមុខ ជាប្រធាន នៃអញ្ញាវិមោក្ខ ហេតុនោះ (ទ្រង់ត្រាស់ថា) ការត្រិះរិះធម៌ស្ទុះទៅមុន យ៉ាងនេះក៏បាន ។ ឬថា វិបស្សនា ក្នុងចំណែកខាងដើមនៃមគ្គទាំង ៤ លោកហៅថា ការត្រិះរិះធម៌ ។

សា អាសេវិតា ហោតិ ភាវិតា ហោតិ ពហុលីកតា ហោតិ អញ្ញាវិមោក្ខស្សាតិ ឯវម្បិ ធម្មតក្កបុរេជវំ ។

(១៦) អញ្ញាវិមោក្ខំ សំព្រូមីតិ អញ្ញាវិមោក្ខោ វុច្ចតិ អរហត្តវិមោក្ខោ ។ អរហត្តវិមោក្ខំ សំព្រូមិ អាចិក្ខាមិ ទេសេមិ បញ្ញបេមិ បដ្ឋបេមិ វិវរាមិ វិភជាមិ ឧត្តានីករោមីតិ អញ្ញាវិមោក្ខំ សំព្រូមិ ។

(១៧) អវិជ្ជាយ បភេទនន្តិ អវិជ្ជាយាតិ ទុក្ខេ អញ្ញាណំ ។ បេ ។ អវិជ្ជាលង្គី មោហោ អកុសលមូលំ ។ អវិជ្ជាយ បភេទនន្តិ អវិជ្ជាយ ភេទនំ បភេទនំ បហានំ វូបសមោ បដិនិស្សគ្គោ បដិប្បស្សទ្ធិ អមតំ និព្វានន្តិ អវិជ្ជាយ បភេទនំ ។ តេនាហ ភគវា

ឧបេក្ខាសតិសំសុទ្ធំ ធម្មតក្កបុរេជវំ
អញ្ញាវិមោក្ខំ សំព្រូមិ អវិជ្ជាយ បភេទនន្តិ ។

(១៨) កឹសុ សំយោជនោ លោកោ កឹសុ តស្ស វិចារណំ
កិស្សស្សុ(១) វិប្បហានេន និព្វានំ ឥតិ វុច្ចតិ ។

---

១ ម. កឹ យស្ស ។

វិបស្សនានោះ ជាខាងដើម ជាខាងមុខ ជាប្រធាន នៃអញ្ញាវិមោក្ខ ហេតុនោះ (ទ្រង់ត្រាស់ថា) ការត្រិះរិះធម៌ស្ទុះទៅមុន យ៉ាងនេះក៏បាន ។

(១៦) ពាក្យថា តថាគតសំដែងថា អញ្ញាវិមោក្ខ គឺ អរហត្តវិមោក្ខ លោកហៅថា អញ្ញាវិមោក្ខ តថាគតពោលដោយប្រពៃ ប្រាប់ សំដែង ប្រញ័ត្ត តាំងផ្តើម បើក វែកញែក ធ្វើឲ្យងាយនូវអរហត្តវិមោក្ខ ហេតុនោះ (ទ្រង់ត្រាស់ថា) តថាគតសំដែងថា អញ្ញាវិមោក្ខ ។

(១៧) ពាក្យថា អវិជ្ជា ក្នុងបទថា ជាគ្រឿងទម្លាយអវិជ្ជា បានដល់ការមិនដឹងក្នុងទុក្ខ ។ បេ ។ គន្លឹះគឺអវិជ្ជា មោហៈ អកុសលមូល ។ ពាក្យថា ជាគ្រឿងទម្លាយអវិជ្ជា បានន័យថា ការបំបែក ការទម្លាយ ការលះ ការរំងាប់ ការលះបោល ការកំចាត់បង់នូវអវិជ្ជា គឺអមតនិព្វាន ហេតុនោះ(ទ្រង់ត្រាស់ថា) ជាគ្រឿងទម្លាយអវិជ្ជា ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

(មួយទៀត) តថាគតសំដែង នូវឧបេក្ខានិងសតិ ដ៏
បរិសុទ្ធ នូវការត្រិះរិះធម៌ស្ទុះទៅមុន ថាជាអញ្ញាវិមោក្ខ
ជាគ្រឿងទម្លាយអវិជ្ជា ។

(១៨) (ឧទយមាណពទូលសួរថា) សត្វលោកមានអ្វីជាគ្រឿង
ចងទុក អ្វីជាគ្រឿងត្រាច់ទៅ របស់សត្វលោកនោះ
ដែលលោកពោលថា និព្វាន តើព្រោះការលះអ្វីបាន ។

## ឧទយមាណវកបញ្ហានិទ្ទេសោ

(១៩) កឹសុ សញ្ញោជនោ លោកោតិ កឹ លោកស្ស សំយោជនំ លគ្គនំ ពន្ធនំ ឧបក្កិលេសោ កេន លោកោ យុត្តោ បយុត្តោ អាយុត្តោ សមាយុត្តោ លគ្គោ លគ្គិតោ បលិពុទ្ធោតិ កឹសុ សញ្ញោជនោ លោកោ ។

(២០) កឹសុ តស្ស វិចារណន្តិ កឹ តស្ស ចារណំ វិចារណំ បដិវិចារណំ កេន លោកោ ចរតិ វិចរតិ បដិវិចរតីតិ កឹសុ តស្ស វិចារណំ ។

(២១) កិស្សស្ស វិប្បហានេន និព្ពានំ ឥតិ វុច្ចតីតិ កិស្សស្ស វិប្បហានេន វូបសមេន បដិនិស្សគ្គេន បដិប្បស្សទ្ធិយា និព្ពានំ ឥតិ វុច្ចតិ បវុច្ចតិ កថិយតិ ភណិយតិ ទីបិយតិ វោហរិយតីតិ កិស្សស្ស វិប្បហានេន និព្ពានំ ឥតិ វុច្ចតិ ។ តេនាហ សោ ព្រាហ្មណោ

កឹសុ សញ្ញោជនោ លោកោ កឹសុ តស្ស វិចារណំ
កិស្សស្ស វិប្បហានេន និព្ពានំ ឥតិ វុច្ចតីតិ ។

(១៩) ពាក្យថា សត្វលោកមានអ្វីជាគ្រឿងចងទុក គឺអ្វីជាគ្រឿងប្រកបព្រម ជាគ្រឿងជាប់ ជាចំណង ជាឧបក្កិលេសនៃសត្វលោក គឺថា សត្វលោកប្រកប ប្រកបសព្វ ប្រកបទួទៅ ផ្សំ ជាប់ ទាក់ ចំពាក់ ដោយអ្វី ហេតុនោះ (លោកសួរថា) សត្វលោកមានអ្វីជាគ្រឿងប្រកបព្រម ។

(២០) ពាក្យថា អ្វីជាគ្រឿងត្រាច់ទៅរបស់សត្វលោកនោះ គឺអ្វីជាគ្រឿងដើរ ត្រាច់ទៅ ត្រាច់រង្គាត់របស់សត្វលោកនោះ គឺ សត្វលោកដើរ ត្រាច់ទៅ ត្រាច់រង្គាត់ដោយអ្វី ហេតុនោះ (លោកសួរថា) អ្វីជាគ្រឿងត្រាច់ទៅ របស់សត្វលោកនោះ ។

(២១) ពាក្យថា ដែលលោកពោលថានិព្វាន តើព្រោះការលះអ្វីបាន គឺដែលលោកហៅ ពោល ថ្លែង សំដែង ពន្យល់ថានិព្វាន តើដោយការលះ ការរំងាប់ ការរលាស់ចោល ការស្ងប់រម្ងាប់នូវអ្វី ហេតុនោះ (លោកសួរថា) ដែលលោកពោលថា និព្វាន តើព្រោះការលះអ្វីបាន ។ ហេតុនោះ ព្រាហ្មណ៍នោះ ពោលថា

សត្វលោកមានអ្វីជាគ្រឿងចងទុក អ្វីជាគ្រឿងត្រាច់ទៅ
របស់សត្វលោកនោះ ដែលលោកពោលថា និព្វាន តើ
ព្រោះការលះអ្វីបាន ។

(២២) នន្ទិសញ្ញោជនោ លោកោ វិតក្កស្ស វិចារណា
តណ្ហាយ វិប្បហានេន និព្វានំ ឥតិ វុច្ចតិ ។

(២៣) នន្ទិសញ្ញោជនោ លោកោតិ នន្ទិ វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ ។ យា នន្ទិ លោកស្ស សញ្ញោជនំ លគ្គនំ ពន្ធនំ ឧបក្កិលេសោ ឥមាយ នន្ទិយា លោកោ យុត្តោ បយុត្តោ អាយុត្តោ សមាយុត្តោ លគ្គោ លគ្គិតោ បលិពុទ្ធោតិ នន្ទិសញ្ញោជនោ លោកោ ។

(២៤) វិតក្កស្ស វិចារណាតិ វិតក្កាតិ នវ វិតក្កា កាមវិតក្កោ ព្យាបាទវិតក្កោ វិហឹសាវិតក្កោ ញាតិវិតក្កោ ជនបទវិតក្កោ អមរវិតក្កោ បរានុទ្ទយតាបដិសំយុត្តោ វិតក្កោ លាភសក្ការសិលោកបដិសំយុត្តោ

(២២) ( ព្រះមានព្រះភាគត្រាស់ថា ) សត្វលោកមានសេចក្តីរីករាយជាគ្រឿងចងទុក សេចក្តីត្រិះរិះទាំងឡាយជាគ្រឿងត្រាច់ទៅរបស់សត្វលោកនោះ ដែលលោកពោលថា និព្វាន ព្រោះការលះតណ្ហាបាន ។

(២៣) ពាក្យថា សត្វលោក មានសេចក្តីរីករាយជាគ្រឿងចងទុក សេចក្តីថា តណ្ហា លោកហៅថា សេចក្តីរីករាយ បានខាងសេចក្តីត្រេកត្រអាល ការត្រេកត្រអាលខ្លាំង ។បេ។ ការសំឡឹងរំពៃ (ទ្រព្យអ្នកដទៃ) លោភៈ អកុសលមូល ។ សេចក្តីរីករាយណាដែលជាគ្រឿងប្រកបព្រម ជាគ្រឿងជាប់ ជាគ្រឿងចង ជាឧបក្កិលេសនៃលោក សត្វលោក ប្រកប ប្រកបសព្វ ប្រកបទូទៅ ផ្សំ ជាប់ ទាក់ បំពាក់ ដោយសេចក្តីរីករាយនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) សត្វលោកមានសេចក្តីរីករាយជាគ្រឿងចងទុក ។

(២៤) ពាក្យថា សេចក្តីត្រិះរិះទាំងឡាយ ក្នុងបទថា សេចក្តីត្រិះរិះទាំងឡាយ ជាគ្រឿងត្រាច់ទៅ របស់សត្វលោកនោះ នបាដល់សេចក្តីត្រិះរិះ ៩ គឺ សេចក្តីត្រិះរិះក្នុងកាម សេចក្តីត្រិះរិះក្នុងព្យាបាទ សេចក្តីត្រិះរិះក្នុងវិហឹសា សេចក្តីត្រិះរិះក្នុងញាតិ សេចក្តីត្រិះរិះក្នុងជនបទ សេចក្តីត្រិះរិះក្នុងការមិនស្លាប់ សេចក្តីត្រិះរិះប្រកបចំពោះដោយភាពនៃសេចក្តីអាណិតដល់ជនដទៃ សេចក្តីត្រិះរិះប្រកបចំពោះដោយលាភសក្ការៈ នឹងសេចក្តីសរសើរ

## ឧទយមាណវបុច្ឆានិទ្ទេសោ

វិតក្កោ អនវញ្ញត្តិប្បដិសំយុត្តោ វិតក្កោ ឥមេ វុច្ចន្តិ នវ វិតក្កា ។ ឥមេ នវ វិតក្កា អស្ស លោកស្ស ចារណា វិចារណា បដិវិចារណា ឥមេហិ នវហិ វិតក្កេហិ សោ លោកោ ចរតិ វិចរតិ បដិវិចរតីតិ វិតក្កស្ស វិចារណា ។

(២៨) តណ្ហាយ វិប្បហានេន និព្វានំ ឥតិ វុច្ចតីតិ តណ្ហាយាតិ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ តណ្ហាយ វិប្បហានេន និព្វានំ ឥតិ វុច្ចតីតិ តណ្ហាយ វិប្បហានេន វូបសមេន បដិនិស្សគ្គេន បដិប្បស្សទ្ធិយា និព្វានំ ឥតិ វុច្ចតិ បវុច្ចតិ កថិយតិ ភណិយតិ ទីបិយតិ វោហារិយតីតិ តណ្ហាយ វិប្បហានេន និព្វានំ ឥតិ វុច្ចតិ ។ តេនាហ ភគវា

នន្ទិសញ្ញោជនោ លោកោ វិតក្កស្ស វិចារណា
តណ្ហាយ វិប្បហានេន និព្វានំ ឥតិ វុច្ចតីតិ ។
(២៩) កថំ សតស្ស ចរតោ វិញ្ញាណំ ឧបរុជ្ឈតិ
ភគវន្តំ បុដ្ឋុមាគម្ម តំ សុណោម វចោ តវ ។

សេចក្តីត្រិះរិះ ប្រកបដោយការមិនបង់ឲ្យគេមើលងាយ ទាំងនេះហៅថា សេចក្តីត្រិះរិះ ៩ ។ សេចក្តីត្រិះរិះទាំង ៩ នេះ ជាគ្រឿងដើរទៅ ត្រាច់ទៅ ត្រាច់រង្គាត់ទៅនៃសត្វលោកនោះ គឺថា សត្វលោកនោះដើរទៅ ត្រាច់ទៅ ត្រាច់រង្គាត់ទៅដោយសារសេចក្តីត្រិះរិះ ៩ នេះ ហេតុនោះ (ទ្រង់ត្រាស់ថា) សេចក្តីត្រិះរិះទាំងឡាយ ជាគ្រឿងត្រាច់ទៅរបស់សត្វលោកនោះ ។

(២៥) ពាក្យថា តណ្ហា ក្នុងបទថា ដែលលោកពោលថា និព្វាន ព្រោះការលះបង់តណ្ហា បានដល់រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រស-តណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ពាក្យថា ដែលលោកពោលថា និព្វាន ព្រោះការលះបង់តណ្ហា គឺថាដែលលោក ហៅ ពោល ថ្លែង សំដែង បំភ្លឺ ពន្យល់ ថានិព្វាន ព្រោះការលះ ការរំងាប់ ការរលាស់ចោល ការស្ងប់រម្ងាប់ តណ្ហា ហេតុនោះ (ទ្រង់ត្រាស់ថា) ដែលលោកពោលថា និព្វាន ព្រោះការលះតណ្ហា ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

> សត្វលោក មានសេចក្តីរីករាយជាគ្រឿងចងទុក សេចក្តី
> ត្រិះរិះទាំងឡាយ ជាគ្រឿងត្រាច់ទៅរបស់សត្វលោកនោះ
> ដែលលោកហៅថា និព្វាន ព្រោះការលះតណ្ហាបាន ។

> (២៦) បុគ្គលមានស្មារតី ប្រព្រឹត្តទៅដូចម្តេច វិញ្ញាណទើប
> រលត់ ពួកខ្ញុំព្រះអង្គមកគាល់ ដើម្បីទូលសួរព្រះមានព្រះ
> ភាគ នឹងបានស្តាប់ព្រះពុទ្ធដីកា របស់ព្រះអង្គ ។

(២៧) ឯវំ សតស្ស ចរតោតិ ឯវំ សតស្ស សម្បជានស្ស ចរតោ វិចរតោ ឥរិយតោ វត្តយតោ បាលយតោ យបយតោ យាបយតោតិ ឯវំ សតស្ស ចរតោ ។

(២៨) វិញ្ញាណំ ឧបរុជ្ឈតីតិ វិញ្ញាណំ និរុជ្ឈតិ វូបសម្មតិ អត្ថំ គច្ឆតិ បដិប្បស្សម្ភតីតិ វិញ្ញាណំ ឧបរុជ្ឈតិ ។

(២៩) ភគវន្តំ បុដ្ឋុមាគម្ហាតិ ពុទ្ធំ ភគវន្តំ បុដ្ឋុំ បុច្ឆិតុំ យាចិតុំ អជ្ឈេសិតុំ បសាទេតុំ អាគម្ហា អាគតម្ហា ឧបាគតម្ហា សម្បត្តម្ហា តយា សទ្ធឹ សមាគតម្ហាតិ ភគវន្តំ បុដ្ឋុមាគម្ហា ។

(៣០) តំ សុណោម វចោ តវាតិ តវន្តិ តុយ្ហំ វចនំ ព្យបថំ ទេសនំ អនុសន្ធឹ សុណោម ឧគ្គណ្ហាម ឧបធារេម ឧបលក្ខេមាតិ តំ សុណោម វចោ តវ ។ តេនាហ សោ ព្រាហ្មណោ

(២៧) ពាក្យថា បុគ្គលមានស្មារតី ប្រព្រឹត្តទៅដូចម្តេច គឺបុគ្គលមានស្មារតី ដឹងព្រម ត្រាច់ទៅ ត្រាច់ទៅផ្សេងៗ ដើរទៅ ប្រព្រឹត្តទៅ រក្សា យាត្រា យាត្រាទៅ ដូចម្តេច ហេតុនោះ (លោកសួរថា) បុគ្គលមានស្មារតី ប្រព្រឹត្តទៅ ដូចម្តេច ។

(២៨) ពាក្យថា វិញ្ញាណទើបរលត់ គឺវិញ្ញាណរលត់ ស្ងប់ អស្តង្គត ស្ងប់រំងាប់ ហេតុនោះ (លោកសួរថា) វិញ្ញាណទើបរលត់ ។

(២៩) ពាក្យថា ពួកខ្ញុំព្រះអង្គមកគាល់ ដើម្បីទូលសួរព្រះមានព្រះភាគ គឺ ពួកខ្ញុំព្រះអង្គ មក មកដល់ មកគាល់ ដល់ព្រម មកជួបជុំ ជាមួយនឹងព្រះអង្គ ដើម្បីទូលសួរ សាកសួរ អង្វរ អារាធនា ជ្រះថ្លា ចំពោះព្រះពុទ្ធមានជោគ ហេតុនោះ (លោកសួរថា) ពួកខ្ញុំព្រះអង្គមកគាល់ ដើម្បីទូលសួរព្រះមានព្រះភាគ ។

(៣០) ពាក្យថា ព្រះអង្គ ក្នុងបទថា នឹងបានស្តាប់ព្រះពុទ្ធដីការបស់ព្រះអង្គ គឺពួកខ្ញុំព្រះអង្គ ស្តាប់ រៀន បង្ហាំទុក កំណត់ទុក នូវព្រះវាចា ការពោល ការសំដែង អនុសន្ធិរបស់ព្រះអង្គ ហេតុនោះ (លោកសួរថា) នឹងបានស្តាប់ព្រះពុទ្ធដីការបស់ព្រះអង្គ ។ ហេតុនោះ ព្រាហ្មណ៍នោះ ពោលថា

ឧទយមាណវកបញ្ហានិទ្ទេសោ

កថំ សតស្ស ចរតោ វិញ្ញាណំ ឧបរុជ្ឈតិ

ភគវន្តំ បុដ្ឋុមាគម្ម តំ សុណោម វចោ ភគវតិ ។

(៣១) អជ្ឈត្តញ្ច ពហិទ្ធា ច វេទនំ នាភិនន្ទតោ

ឯវំ សតស្ស ចរតោ វិញ្ញាណំ ឧបរុជ្ឈតិ ។

(៣២) អជ្ឈត្តញ្ច ពហិទ្ធា ច វេទនំ នាភិនន្ទតោតិ

អជ្ឈត្តំ វេទនាសុ វេទនានុបស្សី វិហរន្តោ វេទនំ នាភិនន្ទតិ នាភិវទតិ ន អជ្ឈោសាយ តិដ្ឋតិ អភិនន្ទនំ អភិវទនំ អជ្ឈោសានំ គាហំ បរាមាសំ អភិ-និវេសំ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវង្គមេ-តិ ។ ពហិទ្ធា វេទនាសុ វេទនានុបស្សី វិហរន្តោ វេទនំ នាភិនន្ទតិ នាភិវទតិ ន អជ្ឈោសាយ តិដ្ឋតិ អភិន-ន្ទនំ អភិវទនំ អជ្ឈោសានំ គាហំ បរាមាសំ អភិនិវេសំ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវង្គមេតិ ។

បុគ្គលមានស្មារតី ប្រព្រឹត្តទៅដូចម្ដេច វិញ្ញាណទើបរលត់ ពួកខ្ញុំព្រះអង្គមកគាល់ ដើម្បីទូលសួរព្រះមានព្រះភាគ នឹងបានស្ដាប់ព្រះពុទ្ធដីកា របស់ព្រះអង្គ ។

[៣១] (ព្រះមានព្រះភាគត្រាស់ថា) កាលបុគ្គលមិនរីករាយ ចំពោះវេទនាទាំងខាងក្នុងទាំងខាងក្រៅ មានស្មារតីប្រព្រឹត្តទៅ យ៉ាងនេះ វិញ្ញាណទើបរលត់ ។

[៣២] អធិប្បាយពាក្យថា កាលបុគ្គលមិនរីករាយ ចំពោះវេទនាទាំងខាងក្នុង ទាំងខាងក្រៅ គឺបុគ្គលកាលពិចារណាឃើញវេទនា ក្នុងវេទនាទាំងឡាយខាងក្នុង មិនរីករាយ មិនសរសើរ មិនឋិតនៅក្នុងសេចក្ដីជ្រប់ចិត្ត ចំពោះវេទនា គឺថា លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនមានបែបភាព នូវការរីករាយ ការសរសើរ ការជ្រប់ចិត្ត ការកួបកាន់ ការស្ទាបអង្អែល ការប្រកាន់ ។ បុគ្គលកាលពិចារណាឃើញវេទនា ក្នុងវេទនាទាំងឡាយ ខាងក្រៅ មិនរីករាយ មិនសរសើរ មិនឋិតនៅក្នុងការជ្រប់ចិត្ត ចំពោះវេទនា លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនមានបែបភាព នូវការរីករាយ ការសរសើរ ការជ្រប់ចិត្ត ការកួបកាន់ ការស្ទាបអង្អែល ការប្រកាន់ ។

អជ្ឈត្តពហិទ្ធា វេទនាសុ វេទនានុបស្សី វិហរន្តោ វេទនំ នាភិនន្ទតិ នាភិវទតិ ន អជ្ឈោសាយ តិដ្ឋតិ អភិនន្ទនំ អភិវទនំ អជ្ឈោសានំ គាហំ បរាមាសំ អភិនិវេសំ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវង្គមេតិ ។

អជ្ឈត្តំ សមុទយធម្មានុបស្សី វេទនាសុ វិហរន្តោ អជ្ឈត្តំ វយធម្មានុបស្សី វេទនាសុ វិហរន្តោ អជ្ឈត្តំ សមុទយវយធម្មានុបស្សី វេទនាសុ វិហរន្តោ ពហិទ្ធា សមុទយធម្មានុបស្សី វេទនាសុ វិហរន្តោ ពហិទ្ធា វយធម្មានុបស្សី វេទនាសុ វិហរន្តោ ពហិទ្ធា សមុទយវយធម្មានុបស្សី វេទនាសុ វិហរន្តោ អជ្ឈត្តពហិទ្ធា សមុទយធម្មានុបស្សី វេទនាសុ វិហរន្តោ អជ្ឈត្តពហិទ្ធា វយធម្មានុបស្សី វេទនាសុ វិហរន្តោ អជ្ឈត្តពហិទ្ធា សមុទយវយធម្មានុបស្សី វេទនាសុ វិហរន្តោ វេទនំ នាភិនន្ទតិ នាភិវទតិ ន អជ្ឈោសាយ តិដ្ឋតិ អភិនន្ទនំ អភិវទនំ អជ្ឈោសានំ គាហំ បរាមាសំ អភិនិវេសំ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវង្គមេតិ ។

បុគ្គលកាលពិចារណាឃើញវេទនា ក្នុងវេទនាទាំងឡាយខាងក្នុងទាំងខាងក្រៅ មិនរីករាយ មិនសរសើរ មិនឋិតនៅក្នុងការជ្រប់ចិត្ត ចំពោះវេទនា គឺលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនមានបែបភាព នូវការរីករាយ សរសើរ ជ្រប់ចិត្ត ក្ពួបកាន់ ស្ទាបអង្អែល ប្រកាន់ ៗ បុគ្គលកាលពិចារណាឃើញនូវការកើតឡើងជាធម្មតា ក្នុងវេទនាទាំងឡាយខាងក្នុង កាលពិចារណាឃើញនូវការវិនាសទៅជាធម្មតា ក្នុងវេទនាទាំងឡាយខាងក្នុង កាលពិចារណាឃើញនូវការកើតឡើងនិងការវិនាសទៅជាធម្មតា ក្នុងវេទនាទាំងឡាយខាងក្នុង កាលពិចារណាឃើញ នូវការកើតឡើងជាធម្មតា ក្នុងវេទនាទាំងឡាយខាងក្រៅ កាលពិចារណាឃើញនូវការវិនាសទៅជាធម្មតា ក្នុងវេទនាទាំងឡាយខាងក្រៅ កាលពិចារណាឃើញនូវការកើតឡើង និងការវិនាសទៅជាធម្មតា ក្នុងវេទនាទាំងឡាយខាងក្រៅ កាលពិចារណាឃើញនូវការកើតឡើងជាធម្មតា ក្នុងវេទនាទាំងឡាយខាងក្នុងទាំងខាងក្រៅ កាលពិចារណាឃើញនូវការវិនាសទៅជាធម្មតា ក្នុងវេទនាទាំងឡាយខាងក្នុងទាំងខាងក្រៅ កាលពិចារណាឃើញនូវការកើតឡើងនិងការវិនាសទៅជាធម្មតា ក្នុងវេទនាទាំងឡាយខាងក្នុងទាំងខាងក្រៅ មិនរីករាយ មិនសរសើរ មិនឋិតនៅក្នុងសេចក្តីជ្រប់ចិត្ត ចំពោះវេទនា គឺលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនមានបែបភាព នូវការរីករាយ សរសើរ ជ្រប់ចិត្ត ក្ពួបកាន់ ស្ទាបអង្អែល ប្រកាន់ ៗ

## ឧទយមាណវកបញ្ហានិទ្ទេសោ

ឥមេហិ ទ្វាទសហាការេហិ វេទនាសុ វេទនានុបស្សី វិហរន្តោ វេទនំ នាភិនន្ទតិ នាភិវទតិ ន អជ្ឈោសាយ តិដ្ឋតិ អភិនន្ទំ អភិវទំ អជ្ឈោសានំ ។ បេ ។ អនភាវង្គមេតិ ។ អថវា វេទនំ អនិច្ចតោ បស្សន្តោ វេទនំ នាភិនន្ទតិ នាភិវទតិ ន អជ្ឈោសាយ តិដ្ឋតិ អភិនន្ទំ អភិវទំ អជ្ឈោសានំ គាហំ បរាមាសំ អភិនិវេសំ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវង្គមេតិ ។ វេទនំ ទុក្ខតោ រោគតោ គណ្ឌតោ សល្លតោ អឃតោ អាពាធតោ ។បេ។ អនិស្សរណតោ បស្សន្តោ វេទនំ នាភិនន្ទតិ នាភិវទតិ ន អជ្ឈោសាយ តិដ្ឋតិ អភិនន្ទំ អភិវទំ អជ្ឈោសានំ គាហំ បរាមាសំ អភិនិវេសំ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវង្គមេតិ ។ ឥមេហិ ទ្វាចត្តាឡីសាយ អាការេហិ វេទនាសុ វេទនានុបស្សី វិហរន្តោ វេទនំ នាភិនន្ទតិ នាភិវទតិ ន អជ្ឈោសាយ តិដ្ឋតិ អភិនន្ទំ អភិវទំ អជ្ឈោសានំ គាហំ បរាមាសំ អភិនិវេសំ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវង្គមេតីតិ អជ្ឈត្តញ្ច ពហិទ្ធា ច វេទនំ នាភិនន្ទតោ ។

## ឧទយមាណវកប្បញ្ហានិទ្ទេស

បុគ្គលកាលពិចារណាឃើញវេទនា ក្នុងវេទនាទាំងឡាយ ដោយអាការទាំង១៦ នេះ មិនរីករាយ មិនសរសើរ មិនឋិតនៅក្នុងការជ្រប់ចិត្តចំពោះវេទនា ។បេ។ ឲ្យដល់នូវការមិនមានបែបភាព នូវការរីករាយ ការសរសើរ ការជ្រប់ចិត្ត ។ មួយទៀត បុគ្គលកាលឃើញវេទនាដោយសេចក្តីថា មិនទៀង មិនរីករាយ មិនសរសើរ មិនឋិតនៅក្នុងការជ្រប់ចិត្ត ចំពោះវេទនា គឺលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនមានបែបភាព នូវការរីករាយ ការសរសើរ ការជ្រប់ចិត្ត ការកួបកាន់ ការស្ទាបអង្អែល ការប្រកាន់ ។ បុគ្គលកាលឃើញវេទនាដោយសេចក្តីថា ជាទុក្ខ ជារោគ ជាពក ជាសរ ជាសេចក្តីលំបាក ជាអាពាធ ។បេ។ ដោយសេចក្តីថា មិនជាទីរលាស់ទុក្ខ មិនរីករាយ មិនសរសើរ មិនឋិតនៅក្នុងសេចក្តីជ្រប់ចិត្តចំពោះវេទនា គឺលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនមានបែបភាព នូវការរីករាយ ការសរសើរ ការជ្រប់ចិត្ត ការកួបកាន់ ការស្ទាបអង្អែល ការប្រកាន់ ។ បុគ្គលកាលពិចារណាឃើញវេទនា ក្នុងវេទនាទាំងឡាយ ដោយអាការទាំងសែសិបពីរនេះ មិនរីករាយ មិនសរសើរ មិនឋិតនៅក្នុងសេចក្តីជ្រប់ចិត្ត ចំពោះវេទនា គឺលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនមានបែបភាព នូវការរីករាយ ការសរសើរ ការជ្រប់ចិត្ត ការកួបកាន់ ការស្ទាបអង្អែល ការប្រកាន់ ហេតុនោះ (ទ្រង់ត្រាស់ថា) កាលបុគ្គលមិនរីករាយ ចំពោះវេទនាទាំងឡាយ ទាំងខាងក្នុង ទាំងខាងក្រៅ ។

(៣៣) ឯវំ សតស្ស ចរតោតិ ឯវំ សតស្ស សម្បជានស្ស ចរតោ វិចរតោ ឥរិយតោ វត្តយតោ បាលយតោ យបយតោ យាបយតោតិ ឯវំ សតស្ស ចរតោ ។

(៣៤) វិញ្ញាណំ ឧបរុជ្ឈតីតិ បុញ្ញាភិសង្ខារសហគតំ វិញ្ញាណំ អបុញ្ញាភិសង្ខារសហគតំ វិញ្ញាណំ អានេញ្ជាភិសង្ខារសហគតំ វិញ្ញាណំ និរុជ្ឈតិ វូបសម្មតិ អត្ថំ គច្ឆតិ បដិប្បស្សម្ភតីតិ វិញ្ញាណំ ឧបរុជ្ឈតិ ។ តេនាហ ភគវា

អជ្ឈត្តញ្ច ពហិទ្ធា ច វេទនំ នាភិនន្ទតោ
ឯវំ សតស្ស ចរតោ វិញ្ញាណំ ឧបរុជ្ឈតីតិ ។

សហ គាថាបរិយោសានា ។បេ។ សត្ថា មេ ភន្តេ ភគវា សាវកោហមស្មីតិ ។

ឧទយមាណវកប្បញ្ហានិទ្ទេសោ តេរសមោ ។

(៣៣) ពាក្យថា មានស្មារតី ប្រព្រឹត្តទៅ យ៉ាងនេះ គឺបុគ្គលមានស្មារតី ដឹងខ្លួនយ៉ាងនេះ ត្រាច់ទៅ ត្រាច់ទៅផ្សេងៗ ដើរទៅ ប្រព្រឹត្តទៅ រក្សា យាត្រា យាត្រាទៅ ហេតុនោះ (ទ្រង់ត្រាស់ថា) មានស្មារតីប្រព្រឹត្តទៅ យ៉ាងនេះ ។

(៣៤) ពាក្យថា វិញ្ញាណទើបរលត់ បានដល់ វិញ្ញាណដែលប្រកបដោយបុញ្ញាភិសង្ខារ វិញ្ញាណដែលប្រកបដោយអបុញ្ញាភិសង្ខារ វិញ្ញាណដែលប្រកបដោយអានេញ្ជាភិសង្ខារ រលត់ ស្ងប់ អស្តង្គត រំងាប់ ហេតុនោះ (ទ្រង់ត្រាស់ថា) វិញ្ញាណទើបរលត់ ។ ហេតុនោះព្រះមានព្រះភាគត្រាស់ថា

កាលបុគ្គលមិនរីករាយ ចំពោះវេទនាទាំងខាងក្នុងទាំងខាងក្រៅ
មានស្មារតី ប្រព្រឹត្តទៅយ៉ាងនេះ វិញ្ញាណទើបរលត់ ។

លុះចប់គាថា ។ បេ ។ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គសូមជាសាវ័ក ។

ចប់ ឧទយមាណវកបញ្ហានិទ្ទេស ទី ១៣ ។

# ពោសាលមាណវកប្បញ្ហានិទ្ទេសោ

(៣៥) យោ អតីតំ អាទិសតិ (ឥច្ចាយស្មា ពោសាលោ)

អនេជោ ឆិន្នសំសយោ
បារគូ សព្វធម្មានំ
អត្ថិ បញ្ហេន អាគមំ ។

(៣៦) យោ អតីតំ អាទិសតីតិ យោតិ យោ សោ ភគវា សយម្ភូ អនាចរិយកោ បុព្វេ អននុស្សុតេសុ ធម្មេសុ សាមំ សច្ចានិ អភិសម្ពុជ្ឈិ តត្ថ ច សព្វញ្ញុតំ បត្តោ ពលេសុ ច វសីភាវំ ។ អតីតំ អាទិសតីតិ ភគវា អត្តនោ ច បរេសញ្ច អតីតម្បិ អាទិសតិ អនាគតម្បិ អាទិសតិ បច្ចុប្បន្នម្បិ អាទិសតិ ។

កថំ ភគវា អត្តនោ អតីតំ អាទិសតិ ។ ភគវា អត្តនោ អតីតំ ឯកម្បិ ជាតឹ អាទិសតិ ទ្វេបិ ជាតិយោ អាទិសតិ តិស្សោបិ ជាតិយោ អាទិសតិ ចតស្សោបិ ជាតិយោ អាទិសតិ បញ្ចបិ ជាតិយោ អាទិសតិ ទសបិ ជាតិយោ

# ពោសាលមាណវកប្បញ្ហានិទ្ទេស

(៣៥) (ពោសាលៈមានអាយុ ក្រាបទូលដូច្នេះថា) ព្រះមានព្រះភាគអង្គណា ពោលអាងកាលជាអតីត មិនមានសេចក្ដីញាប់ញ័រ ទ្រង់កាត់សេចក្ដីសង្ស័យ ទ្រង់ដល់ត្រើយ នៃធម៌ទាំងពួងហើយ ពួកខ្ញុំព្រះអង្គជាអ្នកត្រូវការដោយប្រស្នា ទើបមកគាល់ (ដើម្បីទូលសួរព្រះមានព្រះភាគនោះ) ។

(៣៦) អធិប្បាយពាក្យថា ព្រះមានព្រះភាគអង្គណា ពោលអាងកាលជាអតីត ត្រង់ពាក្យថា អង្គណា សំដៅដល់ព្រះមានព្រះភាគ ព្រះអង្គត្រាស់ដឹងឯង ឥតមានអាចារ្យ បានត្រាស់ដឹងសច្ចៈទាំងឡាយ ដោយព្រះអង្គឯង ក្នុងធម៌ដែលព្រះអង្គមិនធ្លាប់បានស្ដាប់មកក្នុងកាលមុន ទ្រង់សម្រេចសព្វញ្ញុតញ្ញាណក្នុងធម៌ទាំងឡាយនោះផង សម្រេចនូវភាពស្ទាត់ក្នុងពលធម៌ទាំងឡាយផង ។ ពាក្យថា ទ្រង់ពោលអាងកាលជាអតីត បានដល់ព្រះមានព្រះភាគ ទ្រង់ពោលអាងកាលជាអតីតផង ទ្រង់ពោលអាងកាលជាអនាគតផង ទ្រង់ពោលអាងកាលជាបច្ចុប្បន្នផង របស់ព្រះអង្គនិងពួកសត្វដទៃ ។

ព្រះមានព្រះភាគ ទ្រង់ពោលអាងកាលជាអតីតរបស់ព្រះអង្គ តើដូចម្ដេច ។ ព្រះមានព្រះភាគ ទ្រង់ពោលអាងអតីតជាតិ របស់ព្រះអង្គ ១ ជាតិខ្លះ ទ្រង់ពោលអាង ២ ជាតិខ្លះ ទ្រង់ពោលអាង ៣ ជាតិខ្លះ ទ្រង់ពោលអាង៤ជាតិខ្លះ ទ្រង់ពោលអាង៥ជាតិខ្លះ ទ្រង់ពោលអាង១០ជាតិខ្លះ

អាទិសតិ វីសម្បិ ជាតិយោ អាទិសតិ តឹសម្បិ ជាតិយោ អាទិសតិ ចត្តាឡីសម្បិ ជាតិយោ អាទិសតិ បញ្ញាសម្បិ ជាតិយោ អាទិសតិ ជាតិសតម្បិ ជាតិសហស្សម្បិ ជាតិសតសហស្សម្បិ អនេកេបិ សំវដ្ដកប្បេ អនេកេបិ វិវដ្ដកប្បេ អនេកេបិ សំវដ្ដវិវដ្ដកប្បេ អាទិសតិ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធូបបន្នោតិ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អាទិសតិ ឯវំ ភគវា អត្តនោ អតីតំ អាទិសតិ ។

កថំ ភគវា បរេសំ អតីតំ អាទិសតិ ។ ភគវា បរេសំ អតីតំ ឯកម្បិ ជាតឹ អាទិសតិ ទ្វេបិ ជាតិយោ អាទិសតិ ។បេ។ អនេកេបិ សំវដ្ដវិវដ្ដកប្បេ អាទិសតិ

ទ្រង់ពោលអាង ២០ ជាតិខ្លះ ទ្រង់ពោលអាង ៣០ ជាតិខ្លះ ទ្រង់ពោលអាង ៤០ ជាតិខ្លះ ទ្រង់ពោលអាង ៥០ ជាតិខ្លះ ទ្រង់ពោលអាងមួយរយជាតិខ្លះ មួយពាន់ជាតិខ្លះ មួយសែនជាតិខ្លះ សំវដ្តកប្បជាច្រើនខ្លះ វិវដ្តកប្បជាច្រើនខ្លះ សំវដ្តវិវដ្តកប្បជាច្រើនខ្លះថា តថាគត បានកើតក្នុងភពឯណោះ មាននាមយ៉ាងនេះ មានគោត្រយ៉ាងនេះ មានវណ្ណៈយ៉ាងនេះ មានអាហារយ៉ាងនេះ សោយសុខនឹងទុក្ខយ៉ាងនេះ មានអាយុត្រឹមប៉ុណ្ណេះ លុះតថាគតនោះច្យុតចាកអត្តភាពនោះហើយ ក៏បានទៅកើតក្នុងភពឯណោះដែលកើតក្នុងភពនោះ ក៏មាននាមយ៉ាងនេះ មានគោត្រយ៉ាងនេះ មានវណ្ណៈយ៉ាងនេះ មានអាហារយ៉ាងនេះ សោយសុខនឹងទុក្ខយ៉ាងនេះ មានអាយុត្រឹមប៉ុណ្ណេះ តថាគតនោះ លុះច្យុតចាកអត្តភាពនោះហើយ ក៏បានមកកើតក្នុងភពនេះ ព្រះមានព្រះភាគ ទ្រង់ពោលអាងការនៅអាស្រ័យក្នុងកាលមុន ជាច្រើនប្រការ ព្រមទាំងអាការ (គឺវណ្ណៈនឹងអាហារជាដើម) ព្រមទាំងឧទ្ទេស (គឺឈ្មោះនឹងគោត្រជាដើម) ដោយប្រការដូច្នេះ ព្រះមានព្រះភាគ ទ្រង់ពោលអាងកាលជាអតីត របស់ព្រះអង្គ យ៉ាងនេះ ។

ព្រះមានព្រះភាគ ទ្រង់ពោលអាងកាលជាអតីតរបស់ពួកសត្វដទៃ តើដូចម្តេច ។ ព្រះមានព្រះភាគ ទ្រង់ពោលអាងអតីតជាតិរបស់ពួកសត្វដទៃ ១ ជាតិខ្លះ ទ្រង់ពោលអាង២ជាតិខ្លះ ។បេ។ ទ្រង់ពោលអាង សំវដ្តវិវដ្តកប្បដ៏ច្រើនខ្លះ

ពោសាលមាណវបុច្ឆានិទ្ទេសោ

អមុត្រាសិំ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទិំ តត្រាបាសិំ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធូបបន្នោតិ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អាទិសតិ ឯវំ ភគវា បរេសំ អតីតំ អាទិសតិ ។

ភគវា បញ្ច ជាតកសតានិ ភាសន្តោ អត្តនោ ច បរេសញ្ច អតីតំ អាទិសតិ មហាបទិយសុត្តំ(១) ភាសន្តោ អត្តនោ ច បរេសញ្ច អតីតំ អាទិសតិ មហាសុទស្សនិយសុត្តំ ភាសន្តោ អត្តនោ ច បរេសញ្ច អតីតំ អាទិសតិ មហាគោវិន្ទិយសុត្តំ ភាសន្តោ អត្តនោ ច បរេសញ្ច អតីតំ អាទិសតិ មឃទេវសុត្តំ ភាសន្តោ អត្តនោ ច បរេសញ្ច អតីតំ អាទិសតិ ។

---

១ ម. មហាបទានិយសុត្តំ ។

ថា (សត្វនេះ) បានកើតក្នុងភពឯណោះ បាននាមយ៉ាងនេះ បានគោត្រយ៉ាងនេះ មានវណ្ណៈយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខទុក្ខយ៉ាងនេះ មានអាយុត្រឹមប៉ុណ្ណេះ សត្វនោះច្យុតចាកអត្តភាពនោះហើយ ក៏បានទៅកើតក្នុងភពឯណោះ ដែលកើតក្នុងភពនោះ មាននាមយ៉ាងនេះ មានគោត្រយ៉ាងនេះ មានវណ្ណៈយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខទុក្ខយ៉ាងនេះ មានអាយុត្រឹមប៉ុណ្ណេះ សត្វនោះច្យុតចាកអត្តភាពនោះហើយ ក៏បានមកកើតក្នុងភពនេះ ព្រះមានព្រះភាគទ្រង់ពោលអាងការនៅអាស្រ័យក្នុងកាលមុន ច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ ព្រះមានព្រះភាគទ្រង់ពោលអាងកាលជាអតីត របស់ពួកសត្វដទៃ យ៉ាងនេះឯង ។

ព្រះមានព្រះភាគទ្រង់សំដែងជាតកទាំង ៥០០ ឈ្មោះថាពោលអាងកាលជាអតីតរបស់ព្រះអង្គផង របស់ពួកសត្វដទៃផង ទ្រង់សំដែងមហាធនិយសូត្រ ឈ្មោះថាពោលអាងកាលជាអតីតរបស់ព្រះអង្គផង របស់ពួកសត្វដទៃផង ទ្រង់សំដែងមហាសុទស្សនសូត្រ ឈ្មោះថាពោលអាងកាលជាអតីតរបស់ព្រះអង្គផង របស់ពួកសត្វដទៃផង ទ្រង់សំដែងមហាគោវិន្ទសូត្រ ឈ្មោះថាពោលអាងកាលជាអតីតរបស់ព្រះអង្គផង របស់ពួកសត្វដទៃផង ទ្រង់សំដែងមឃទេវសូត្រ ឈ្មោះថាពោលអាងកាលជាអតីតរបស់ព្រះអង្គផង របស់ពួកសត្វដទៃផង ។

វុត្តញ្ហេតំ ភគវតា អតីតំ ខោ ចុន្ទ អទ្ធានំ អារព្ភ តថាគតស្ស សតានុសារិ ញាណំ ហោតិ សោ យាវតកំ អាកង្ខតិ តាវតកំ អនុស្សរតិ អនាគតំ ខោ ចុន្ទ ។ បេ ។ បច្ចុប្បន្នំ ខោ ចុន្ទ អទ្ធានំ អារព្ភ តថាគតស្ស ពោធិជំ ញាណំ ឧប្ប-ជ្ជតិ អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ ។ ឥន្ទ្រិយបរោបរិយត្តញាណំ តថាគតស្ស តថាគតពលំ សត្តានំ អាសយានុសយេ ញាណំ តថាគតស្ស តថា-គតពលំ យមកប្បាដិហីរិយញាណំ តថាគតស្ស តថាគតពលំ មហាករុណាសមាបត្តិញាណំ តថា-គតស្ស តថាគតពលំ សព្វញ្ញុតញ្ញាណំ តថាគតស្ស តថាគតពលំ អនាវរណញាណំ តថាគតស្ស តថា-គតពលំ សព្វត្ថ អសង្គមប្បដិហតមនាវរណញាណំ តថាគតស្ស តថាគតពលំ ។ ឯវំ ភគវា អត្តនោ ច បរេសញ្ច អតីតម្បិ អាទិសតិ អនាគតម្បិ អា-ទិសតិ បច្ចុប្បន្នម្បិ អាទិសតិ អាចិក្ខតិ ទេសេតិ បញ្ញបេតិ បដ្ឋបេតិ វិវរតិ វិភជតិ ឧត្តានី-ករោតិ បកាសេតីតិ យោ អតីតំ អាទិសតិ ។

ដូចព្រះពុទ្ធដីកាដែលព្រះមានព្រះភាគត្រាស់ដូច្នេះថា ម្នាលចុន្ទៈ ញាណជាគ្រឿងរលឹកតាមនូវស្មារតីនៃព្រះតថាគត ប្រារព្ធកាលជាអតីត រមែងមាន ព្រះតថាគតនោះ ប្រាថ្នាត្រឹមណា រលឹកឃើញបានត្រឹមនោះ ម្នាលចុន្ទៈ ញាណជាគ្រឿងរលឹកតាមនូវស្មារតីនៃព្រះតថាគត ប្រារព្ធនូវកាលជាអនាគត ។ បេ ។ ម្នាលចុន្ទៈ ញាណដែលកើតអំពីពោធិនៃព្រះតថាគត ប្រារព្ធកាលជាបច្ចុប្បន្ន រមែងកើតឡើងថា ជាតិនេះ មានក្នុងទីបំផុត ការកើតទៀតក្នុងកាលឥឡូវនេះមិនមាន ។ ឥន្ទ្រិយបរោបរិយត្តញ្ញាណ ជាតថាគតពល របស់ព្រះតថាគត សត្តានំអាសយានុសយញ្ញាណ ជាតថាគតពល របស់ព្រះតថាគត យមកប្បាដិហីរិយញ្ញាណ ជាតថាគតពល របស់ព្រះតថាគត មហាករុណាសមាបត្តិញ្ញាណ ជាតថាគតពល របស់ព្រះតថាគត សព្វញ្ញុតញ្ញាណ ជាតថាគតពល របស់ព្រះតថាគត អនាវរណញ្ញាណ ជាតថាគតពល របស់ព្រះតថាគត សព្វត្ថអសង្គមប្បដិហតមនាវរណញ្ញាណ ជាតថាគតពល របស់ព្រះតថាគត ។ ព្រះមានព្រះភាគ ទ្រង់ពោលអាងជាតិជាអតីតផង ពោលអាងជាតិជាអនាគតផង ទ្រង់ពោលអាង ប្រាប់ សំដែង ប្រញ៉ត្ត តាំងផ្តើម បើក វែកញែក ធ្វើឲ្យរាក់ ប្រកាស នូវជាតិជាបច្ចុប្បន្ន របស់ព្រះអង្គផង របស់ពួកសត្វដទៃផង យ៉ាងនេះ ហេតុនោះ (លោកពោលថា) ព្រះមានព្រះភាគអង្គណា ពោលអាង កាលជាអតីត ។

ធោតកមាណវកប្បញ្ហានិទ្ទេសោ

ឥច្ចាយស្មា ធោតកោតិ ឥច្ចាតិ បទសន្ធិ ។ អាយស្មាតិ បិយវចនំ ។ ធោតកោតិ តស្ស ព្រាហ្មណស្ស នាមំ ។ បេ ។ អភិលាបោតិ ឥច្ចាយស្មា ធោតកោ ។

(៣៧) អនេជោ ឆិន្នសំសយោតិ ឯជា វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា លោភោ អកុសលមូលំ ។ សា ឯជា តណ្ហា ពុទ្ធស្ស ភគវតោ បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតិំអនុប្បាទធម្មា តស្មា ពុទ្ធោ អនេជោ ។ ឯជាយ បហីនត្តា អនេជោ ។ ភគវា លាភេបិ ន ឥញ្ជតិ អលាភេបិ ន ឥញ្ជតិ យសេបិ ន ឥញ្ជតិ អយសេបិ ន ឥញ្ជតិ បសំសាយបិ ន ឥញ្ជតិ និន្ទាយបិ ន ឥញ្ជតិ សុខេបិ ន ឥញ្ជតិ ទុក្ខេបិ ន ឥញ្ជតិ ន ចលតិ ន វេធតិ ន បវេធតិ ន សម្បវេធតីតិ អនេជោ ។ ឆិន្នសំសយោតិ សំសយោ វុច្ចតិ វិចិកិច្ឆា ទុក្ខេ កង្ខា ។ បេ ។ ឆម្ភិតត្តំ ចិត្តស្ស មនោវិលេខោ ។

ពាក្យថា ដូច្នេះ ក្នុងបទថា ធោតកៈ មានអាយុ ពោលដូច្នេះ ជាការតបទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ។ ពាក្យថា ធោតកៈ ជាឈ្មោះ ។ បេ ។ ជាពាក្យហៅព្រាហ្មណ៍នោះ ហេតុនោះ (ទើបមានពាក្យថា) ធោតកៈមានអាយុពោលដូច្នេះ ។

(៣៧) ពាក្យថា មិនមានសេចក្ដីញាប់ញ័រ ទ្រង់កាត់សេចក្ដីសង្ស័យ សេចក្ដីថា តណ្ហា លោកហៅថា សេចក្ដីញាប់ញ័រ បានខាងតម្រេក តម្រេកខ្លាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ សេចក្ដីញាប់ញ័រគឺតណ្ហានោះ ព្រះពុទ្ធមានជោគ ទ្រង់លះបង់ ផ្ដិលផ្ដាច់ឫសគល់ ធ្វើឲ្យសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនមានបែបភាព មិនឲ្យមានការកើតតទៅជាធម្មតា ហេតុនោះ ព្រះពុទ្ធ ឈ្មោះថាមិនមានសេចក្ដីញាប់ញ័រ ។ ព្រោះទ្រង់លះសេចក្ដីញាប់ញ័រ ទើបឈ្មោះថាមិនមានសេចក្ដីញាប់ញ័រ ។ ព្រះមានព្រះភាគមិនញាប់ញ័រក្នុងលាភផង មិនញាប់ញ័រក្នុងអលាភផង មិនញាប់ញ័រក្នុងយសផង មិនញាប់ញ័រក្នុងអយសផង មិនញាប់ញ័រក្នុងសេចក្ដីសរសើរផង មិនញាប់ញ័រក្នុងនិន្ទាផង មិនញាប់ញ័រក្នុងសុខផង មិនញាប់ញ័រ មិនកម្រើក មិនរន្ធត់ មិនកក្រើក មិនកក្រើកព្រមក្នុងទុក្ខផង ហេតុនោះ ទើបឈ្មោះថាមិនមានសេចក្ដីញាប់ញ័រ ។ ពាក្យថា ទ្រង់កាត់សេចក្ដីសង្ស័យ សេចក្ដីថា វិចិកិច្ឆា លោកហៅថា សេចក្ដីសង្ស័យ គឺសេចក្ដីសង្ស័យក្នុងទុក្ខ ។ បេ ។ សេចក្ដីញាប់ញ័រនៃចិត្ត សេចក្ដីស្រេមស្រាមនៃចិត្ត ។

សោ សំសយោ ពុទ្ធស្ស ភគវតោ ឆិន្នោ ឧច្ឆិន្នោ សមុច្ឆិន្នោ វូបសន្តោ បដិប្បស្សទ្ធោ អភព្វុប្បត្តិកោ ញាណគ្គិនា ទឌ្ឍោ តស្មា ពុទ្ធោ ឆិន្នសំសយោតិ អនេជោ ឆិន្នសំសយោ ។

(៣៨) បារគូ សព្ពធម្មានន្តិ ភគវា សព្ពធម្មានំ អភិញ្ញាបារគូ បរិញ្ញាបារគូ បហានបារគូ ភាវនាបារគូ សច្ឆិកិរិយាបារគូ សមាបត្តិបារគូ អភិញ្ញាបារគូ សព្ពធម្មានំ ។ បេ ។ ជាតិជរាមរណសំសារោ នត្ថិ តស្ស បុនព្ភវោតិ បារគូ សព្ពធម្មានំ ។

(៣៩) អត្ថិ បញ្ហេន អាគមន្តិ បញ្ហត្ថិកម្ហា អាគតា ។ បេ ។ សន្ធេស្សតុំ ភណិតុន្តិ ឯវម្បិ អត្ថិ បញ្ហេន អាគមំ ។ តេនាហ សោ ព្រាហ្មណោ

សេចក្តីសង្ស័យនោះ ព្រះពុទ្ធមានជោគ ទ្រង់កាត់ ផ្តាច់ ផ្តិលផ្តាច់ រំលាប់ ស្ងប់រម្ងាប់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណ ហើយ ហេតុនោះ ព្រះពុទ្ធឈ្មោះថា កាត់សេចក្តីសង្ស័យ ហេតុនោះ (លោកពោលថា) មិនមានសេចក្តីញាប់ញ័រ ទ្រង់កាត់សេចក្តីសង្ស័យ ។

(៣៨) ពាក្យថា ទ្រង់ដល់ត្រើយនៃធម៌ទាំងពួង គឺព្រះមានព្រះភាគទ្រង់ដល់ត្រើយនៃការត្រាស់ដឹង ដល់ត្រើយនៃការកំណត់ដឹង ដល់ត្រើយនៃការលះបង់ ដល់ត្រើយនៃការចម្រើន ដល់ត្រើយនៃការធ្វើឲ្យជាក់ច្បាស់ ដល់ត្រើយនៃសមាបត្តិ នៃធម៌ទាំងពួង គឺថាទ្រង់ដល់ត្រើយនៃការត្រាស់ដឹងនូវធម៌ទាំងពួង ។ បេ ។ ភពថ្មីគឺជាតិ ជរា មរណៈ សង្សារ នៃព្រះមានព្រះភាគនោះ មិនមាន ហេតុនោះ (លោកពោលថា) ទ្រង់ដល់ត្រើយនៃធម៌ទាំងពួង ។

(៣៩) ពាក្យថា ពួកខ្ញុំព្រះអង្គជាអ្នកត្រូវការដោយប្រស្នា ទើបមកគាល់ គឺពួកខ្ញុំព្រះអង្គត្រូវការដោយប្រស្នា ទើបមក ។ បេ ។ ដើម្បីបំភ្លឺ ដើម្បីសំដែង ហេតុនោះ (លោកពោលថា) ពួកខ្ញុំព្រះអង្គជាអ្នកត្រូវការដោយប្រស្នា ទើបមកគាល់ យ៉ាងនេះក៏បាន ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

ពោសាលមាណវកបញ្ហានិទ្ទេសោ

យោ អតីតំ អាទិសតិ (ឥច្ចាយស្មា
ពោសាលោ)

អនេជោ ឆិន្នសំសយោ
បារគុ សព្វធម្មានំ
អត្ថិ បញ្ហេន អាគមន្តិ ។

(៤០) វិភូតរូបសញ្ញិស្ស សព្វកាយប្បហាយិនោ
អជ្ឈត្តញ្ច ពហិទ្ធា ច នត្ថិ កិញ្ចីតិ បស្សតោ
ញាណំ សក្កានុបុច្ឆាមិ កថំ នេយ្យោ តថាវិធោ ។

(៤១) វិភូតរូបសញ្ញិស្សាតិ កតមា រូបសញ្ញា ។ រូបាវចរសមាបត្តិំ សមាបន្នស្ស វា ឧបបន្នស្ស វា ទិដ្ឋធម្មសុខវិហារស្ស វា សញ្ញា សញ្ជាននា សញ្ជាននត្តំ អយំ រូបសញ្ញា ។ វិភូតរូបសញ្ញិស្សាតិ ចតស្សោ អរូបសមាបត្តិយោ លាភិស្ស រូបសញ្ញា វិភូតា ហោន្តិ វិគតា អតិក្កន្តា សមតិក្កន្តា វីតិវត្តាតិ វិភូតរូបសញ្ញិស្ស ។

## ពោសាលមាណវកបញ្ហានិទ្ទេស

(បោសាលមានអាយុក្រាបទូលដូច្នេះថា) ព្រះមានព្រះភាគអង្គណា ពោលអាងកាលជាអតីត មិនមានសេចក្តីញាប់ញ័រ ទ្រង់កាត់សេចក្តីសង្ស័យ ទ្រង់ដល់ត្រើយនៃធម៌ទាំងពួង ពួកខ្ញុំព្រះអង្គជាអ្នកត្រូវការ ដោយប្រស្នា ទើបមកគាល់ (ដើម្បីទូលសួរព្រះមានព្រះភាគនោះ) ។

(៤០) បពិត្រព្រះអង្គជាសក្យពង្ស ខ្ញុំព្រះអង្គសូមទូលសួរអំពីវិញ្ញាណរបស់បុគ្គលអ្នកមានរូបសញ្ញាជាក់ច្បាស់ អ្នកលះបង់រូបារម្មណ៍ទាំងអស់ អ្នកឃើញទាំងខាងក្នុងទាំងខាងក្រៅថា វត្ថុបន្តិចបន្តួចមិនមាន បុគ្គលមានសភាពដូច្នោះ តើព្រះអង្គជ្រាបដោយប្រការដូចម្តេច ។

(៤១) ពាក្យថា អ្នកមានរូបសញ្ញាជាក់ច្បាស់ មានសំនួរថា រូបសញ្ញាតើដូចម្តេច ។ សេចក្តីសំគាល់ អាការនៃសេចក្តីសំគាល់ ភាពនៃសេចក្តីសំគាល់ របស់បុគ្គលអ្នកចូលកាន់រូបាវចរសមាបត្តិក្តី អ្នកញុំាងរូបាវចរសមាបត្តិឲ្យកើតក្តី អ្នកមានឈានសុខជាគ្រឿងនៅក្នុងបច្ចុប្បន្នក្តី នេះឈ្មោះថា រូបសញ្ញា ។ ពាក្យថា អ្នកមានរូបសញ្ញាជាក់ច្បាស់ បានន័យថា បុគ្គលអ្នកបានអរូបសមាបត្តិទាំង ៤ ហើយ រមែងមានរូបសញ្ញា (ការសំគាល់រូប) ប្រាកដ ធ្វើឲ្យជាក់ច្បាស់ កន្លង រំលង ប្រព្រឹត្តកន្លង ហេតុនោះ (លោកពោលថា) អ្នកមានរូបសញ្ញាជាក់ច្បាស់ ។

(៤២) សព្ពកាយប្បហាយិនោតិ សព្ពោ តស្ស សប្បដិសន្ធិកោ រូបកាយោ បហីនោ តទង្គសមតិក្កមវិក្ខម្ភនប្បហានេន បហីនោ តស្ស រូបកាយោតិ សព្ពកាយប្បហាយិនោ ។

(៤៣) អជ្ឈត្តញ្ច ពហិទ្ធា ច នត្ថិ កិញ្ចីតិ បស្សតោតិ នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនសមាបត្តិ ។ កឹការណា នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនសមាបត្តិ ។ វិញ្ញាណញ្ចាយតនសមាបត្តឹ សតោ សមាបជ្ជិត្វា តតោ វុដ្ឋហិត្វា តញ្ញេវ វិញ្ញាណំ អភាវេតិ វិភាវេតិ អន្តរធាបេតិ នត្ថិ កិញ្ចីតិ បស្សតិ ។ តំការណា នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនសមាបត្តីតិ អជ្ឈត្តញ្ច ពហិទ្ធា ច នត្ថិ កិញ្ចីតិ បស្សតោ ។

(៤៤) ញាណំ សក្កានុបុច្ឆាមីតិ សក្កាតិ សក្កោ ។ ភគវា សក្យកុលា បព្ពជិតោតិបិ សក្កោ ។ បេ ។ បហីនភយភេរវោ វិគតលោមហំសោតិបិ សក្កោ ។

(៤២) ពាក្យថា អ្នកលះរូបារម្មណ៍ទាំងអស់ សេចក្តីថា រូបកាយ ប្រកបដោយបដិសន្ធិទាំងអស់ បុគ្គលនោះលះបង់ហើយ គឺថារូបកាយបុគ្គលនោះលះបង់ហើយ ដោយវិក្ខម្ភនប្បហាន ដែលប្រព្រឹត្តកន្លង នូវតទង្គប្បហាន ហេតុនោះ (លោកពោលថា) អ្នកលះរូបារម្មណ៍ទាំងអស់ ។

(៤៣) ពាក្យថា អ្នកឃើញទាំងខាងក្នុងទាំងខាងក្រៅថា វត្ថុបន្តិចបន្តួចមិនមាន ត្រង់ពាក្យថា វត្ថុបន្តិចបន្តួចមិនមាន បានដល់អាកិញ្ចញ្ញាយតនសមាបត្តិ ។ អាកិញ្ចញ្ញាយតនសមាបត្តិ ដោយបរិកម្មថា វត្ថុបន្តិចបន្តួចមិនមាន តើព្រោះហេតុអ្វី ។ បុគ្គលមានស្មារតីចូលវិញ្ញាណញ្ចាយតនសមាបត្តិ លុះចេញចាកសមាបត្តិនោះហើយ ក៏ធ្វើវិញ្ញាណនោះឯង ឲ្យវិនាស បាត់បង់ សាបសូន្យទៅវិញ ឈ្មោះថាឃើញថា វត្ថុបន្តិចបន្តួចមិនមាន ។ អាកិញ្ចញ្ញាយតនសមាបត្តិ ដោយបរិកម្មថា វត្ថុបន្តិចបន្តួចមិនមាន ព្រោះហេតុនោះឯង ហេតុនោះ (លោកពោលថា) អ្នកឃើញទាំងខាងក្នុងទាំងខាងក្រៅថា វត្ថុបន្តិចបន្តួចមិនមាន ។

(៤៤) ពាក្យថា សក្យពង្ស ក្នុងបទថា បពិត្រព្រះអង្គជាសក្យពង្ស ខ្ញុំព្រះអង្គសូមទូលសួរ អំពីញាណ គឺ ព្រះមានព្រះភាគ ឈ្មោះថា សក្យពង្ស ។ ដែលព្រះមានព្រះភាគ ឈ្មោះសក្យៈ ព្រោះទ្រង់ចេញចាកសក្យត្រកូលហើយបួស ក៏បាន ។ បេ ។ ឈ្មោះសក្យៈ ព្រោះព្រះអង្គលះបង់ភ័យនឹងសេចក្តីតក់ស្លុត ប្រាសចាកការព្រឺរោម ក៏បាន ។

ញាណំ សក្កានុបុច្ឆាមីតិ តស្ស ញាណំ បុច្ឆាមិ កីទិសំ កឹសណ្ឋិតំ កឹបការំ កឹបដិភាគំ ឥច្ឆិតព្វ-ន្តិ ញាណំ សក្កានុបុច្ឆាមិ ។

(៤៩) កថំ នេយ្យោ តថាវិធោតិ កថំ សោ នេតព្វោ វិនេតព្វោ អភិនេតព្វោ បញ្ញាបេតព្វោ អ-ភិនិជ្ឈាបេតព្វោ បេក្ខេតព្វោ បសាទេតព្វោ កថ-មស្ស ឧត្តរិញាណំ ឧប្បាទេតព្វំ ។ តថាវិធោតិ តថាវិធោ តាទិសោ តស្សណ្ឋិតោ តប្បការោ ត-ប្បដិភាគោ យោ សោ អាកិញ្ចញ្ញាយតនសមាប-ត្តិលាភីតិ កថំ នេយ្យោ តថាវិធោ ។ តេនាហ សោ ព្រាហ្មណោ

វិភូតរូបសញ្ញិស្ស សព្វកាយប្បហាយិនោ
អជ្ឈត្តញ្ច ពហិទ្ធា ច នត្ថិ កិញ្ចីតិ បស្សតោ
ញាណំ សក្កានុបុច្ឆាមិ កថំ នេយ្យោ តថាវិធោតិ ។

ពាក្យថា បពិត្រព្រះអង្គជាសក្យពង្ស ខ្ញុំព្រះអង្គសូមទូលសួរអំពីញាណ បានន័យថា ខ្ញុំព្រះអង្គសូមទូលសួរញាណ របស់បុគ្គលនោះ ថា ប្រាកដដូចម្តេច មានទ្រង់ទ្រាយដូចម្តេច មានប្រការដូចម្តេច មានចំណែកប្រៀបដូចម្តេច ដែលបុគ្គលគប្បីប្រាថ្នា ហេតុនោះ (លោកពោលថា) បពិត្រព្រះអង្គជាសក្យពង្ស ខ្ញុំព្រះអង្គសូមទូលសួរអំពីញាណ ។

(៤៥) ពាក្យថា បុគ្គលមានសភាពដូច្នោះ តើព្រះអង្គជ្រាបដោយប្រការដូចម្តេច សេចក្តីថា បុគ្គលនោះ តើព្រះអង្គជ្រាប ជ្រាបសព្វ ជ្រាបច្បាស់ យល់ច្បាស់ ពិនិត្យច្បាស់ សំឡឹង ជ្រះថ្លា ដោយប្រការដូចម្តេច គឺថាញាណដ៏ក្រៃលែង របស់បុគ្គលនោះ ព្រះអង្គគប្បីឲ្យកើតឡើងដូចម្តេច ។ ពាក្យថា មានសភាពដូច្នោះ គឺមានប្រការដូច្នោះ ប្រាកដដូច្នោះ មានទ្រង់ទ្រាយដូច្នោះ មានសភាពដូច្នោះ មានចំណែកប្រៀបដូច្នោះ បានដល់បុគ្គលអ្នកបានអាកិញ្ចញ្ញាយតនសមាបត្តិ ហេតុនោះ (លោកពោលថា) បុគ្គលមានសភាពដូច្នោះ តើព្រះអង្គជ្រាបដោយប្រការដូចម្តេច ហេតុនោះ ព្រាហ្មណ៍នោះពោលថា

បពិត្រព្រះអង្គជាសក្យពង្ស ខ្ញុំព្រះអង្គសូមទូលសួរអំពីញាណរបស់
បុគ្គលអ្នកមានរូបសញ្ញាដាក់ច្បាស់អ្នកលះបង់រូបារម្មណ៍ទាំងអស់ អ្នក
ឃើញទាំងខាងក្នុងទាំងខាងក្រៅថា វត្ថុបន្តិចបន្តួចមិនមាន បុគ្គល
មានសភាពដូច្នោះ តើព្រះអង្គជ្រាប ដោយប្រការដូចម្តេច ។

(៤៦) វិញ្ញាណដ្ឋិតិយោ សព្វា (បោសាលាតិ ភគវា)

អភិជានំ តថាគតោ

តិដ្ឋន្តមេនំ ជានាតិ

វិមុត្តំ តប្បរាយណំ ។

(៤៧) វិញ្ញាណដ្ឋិតិយោ សព្វាតិ ភគវា អភិសង្ខារវសេន ចតស្សោ វិញ្ញាណដ្ឋិតិយោ ជានាតិ បដិសន្ធិវសេន សត្ត វិញ្ញាណដ្ឋិតិយោ ជានាតិ ។ កថំ ភគវា អភិសង្ខារវសេន ចតស្សោ វិញ្ញាណដ្ឋិតិយោ ជានាតិ ។ វុត្តញ្ហេតំ ភគវតា រូបុបាយំ វា ភិក្ខវេ វិញ្ញាណំ តិដ្ឋមានំ តិដ្ឋតិ រូបារម្មណំ រូបប្បតិដ្ឋំ នន្ទូបសេចនំ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជតិ វេទនូបាយំ វា ភិក្ខវេ ។បេ។ សញ្ញូបាយំ វា ភិក្ខវេ ។បេ។ សង្ខារូបាយំ វា ភិក្ខវេ វិញ្ញាណំ តិដ្ឋមានំ តិដ្ឋតិ សង្ខារារម្មណំ សង្ខារប្បតិដ្ឋំ នន្ទូបសេចនំ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជតីតិ ។ ឯវំ ភគវា អភិសង្ខារវសេន ចតស្សោ វិញ្ញាណដ្ឋិតិយោ ជានាតិ ។

(៤៦) (ព្រះមានព្រះភាគត្រាស់ថា ម្នាលបោសាលៈ) ព្រះតថាគត ទ្រង់ជ្រាបច្បាស់នូវវិញ្ញាណដ្ឋិតិទាំងពួង ទើបទ្រង់ជ្រាបនូវបុគ្គលនោះ ដែលកំពុងរស់នៅ មានចិត្តផប់(ក្នុងអាកិញ្ចញ្ញាយតនៈ) មានអាកិញ្ចញ្ញាយតនៈនោះ ប្រព្រឹត្តទៅខាងមុខ ។

(៤៧) ពាក្យថា វិញ្ញាណដ្ឋិតិទាំងពួង អធិប្បាយថា ព្រះមានព្រះភាគទ្រង់ជ្រាបវិញ្ញាណដ្ឋិតិ ៤ ដោយអំណាចអភិសង្ខារ ទ្រង់ជ្រាបវិញ្ញាណដ្ឋិតិ ៧ ដោយអំណាចបដិសន្ធិ ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបវិញ្ញាណដ្ឋិតិ ៤ ដោយអំណាចអភិសង្ខារ តើដូចម្ដេច ។ ព្រះពុទ្ធដីកាដែលព្រះមានព្រះភាគត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ វិញ្ញាណអាស្រ័យរូបខ្លះហើយឋិតនៅ រមែងឋិតនៅ មានរូបជាអារម្មណ៍ មានរូបជាទីតម្កល់ មានសេចក្ដីត្រេកអរជាគ្រឿងសេព រមែងដល់នូវសេចក្ដីចម្រើន សេចក្ដីលូតលាស់ សេចក្ដីទូលំទូលាយ ម្នាលភិក្ខុទាំងឡាយ (វិញ្ញាណ) អាស្រ័យវេទនាខ្លះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ (វិញ្ញាណ) អាស្រ័យសញ្ញាខ្លះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណអាស្រ័យសង្ខារខ្លះ ហើយឋិតនៅ រមែងឋិតនៅ មានសង្ខារជាអារម្មណ៍ មានសង្ខារជាទីតម្កល់ មានសេចក្ដីត្រេកអរជាគ្រឿងសេព ដល់នូវសេចក្ដីចម្រើន សេចក្ដីលូតលាស់ សេចក្ដីទូលំទូលាយ ។ ព្រះមានព្រះភាគទ្រង់ជ្រាបវិញ្ញាណដ្ឋិតិ ៤ ដោយអំណាចអភិសង្ខារ យ៉ាងនេះ ។

## បោសាលមាណវកប្បញ្ហានិទ្ទេសោ

កថំ ភគវា បដិសន្ធិវសេន សត្ត វិញ្ញាណដ្ឋិតិយោ ជានាតិ ។ វុត្តញ្ហេតំ ភគវតា សន្តិ ភិក្ខវេ សត្តា នានត្តកាយា នានត្តសញ្ញិនោ សេយ្យថាបិ មនុស្សា ឯកច្ចេ ច ទេវា ឯកច្ចេ ច វិនិបាតិកា អយំ បឋមា វិញ្ញាណដ្ឋិតិ សន្តិ ភិក្ខវេ សត្តា នានត្តកាយា ឯកត្តសញ្ញិនោ សេយ្យថាបិ ទេវា ព្រហ្មកាយិកា បឋមាភិនិព្វត្តា អយំ ទុតិយា វិញ្ញាណដ្ឋិតិ សន្តិ ភិក្ខវេ សត្តា ឯកត្តកាយា នានត្តសញ្ញិនោ សេយ្យថាបិ ទេវា អាភស្សរា អយំ តតិយា វិញ្ញាណដ្ឋិតិ សន្តិ ភិក្ខវេ សត្តា ឯកត្តកាយា ឯកត្តសញ្ញិនោ សេយ្យថាបិ ទេវា សុភកិណ្ហកា អយំ ចតុត្ថា វិញ្ញាណដ្ឋិតិ ស-ន្តិ ភិក្ខវេ សត្តា សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិ-ការា អនន្តោ អាកាសោតិ អាកាសានញ្ចាយ-តនូបគា អយំ បញ្ចមា វិញ្ញាណដ្ឋិតិ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនូបគា អយំ ឆដ្ឋា វិញ្ញាណដ្ឋិតិ

ព្រះមានព្រះភាគទ្រង់ជ្រាបវិញ្ញាណដ្ឋិតិ ៧ ដោយអំណាចបដិសន្ធិ តើដូចម្តេច ។ ព្រះមានព្រះភាគ ត្រាស់ព្រះពុទ្ធដីកានេះថា ម្នាលភិក្ខុទាំងឡាយ មានពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នា ដូចពួកមនុស្សនឹងទេវតាពួកខ្លះ វិនិបាតិកៈពួកខ្លះ នេះវិញ្ញាណដ្ឋិតិទី ១ ម្នាលភិក្ខុទាំងឡាយ មានពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាដូចគ្នា ដូចពួកទេវតា ប្រព្រឹត្តទៅក្នុងពួកព្រហ្ម កើតដោយបឋមជ្ឈាន នេះវិញ្ញាណដ្ឋិតិទី ២ ម្នាលភិក្ខុទាំងឡាយ មានពួកសត្វមានកាយដូចគ្នា មានសញ្ញាផ្សេងគ្នា ដូចពួកទេវតាជាន់អាភស្សរៈ នេះវិញ្ញាណដ្ឋិតិទី ៣ ម្នាលភិក្ខុទាំងឡាយ មានពួកសត្វមានកាយដូចគ្នា មានសញ្ញាដូចគ្នា ដូចពួកទេវតាជាន់សុភកិណ្ហកៈ នេះវិញ្ញាណដ្ឋិតិទី៤ ម្នាលភិក្ខុទាំងឡាយ មានពួកសត្វព្រោះប្រព្រឹត្តកន្លងរូបសញ្ញាដោយប្រការទាំងពួង ដល់នូវការវិនាសនៃបដិឃសញ្ញា មិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ចូលអាកាសានញ្ចាយតនៈ ដោយបរិកម្មថា អាកាសមិនមានទីបំផុត នេះវិញ្ញាណដ្ឋិតិទី ៥ (ពួកសត្វ) ប្រព្រឹត្តកន្លងអាកិញ្ចញ្ញាយតនៈ ដោយប្រការទាំងពួង ចូលវិញ្ញាណញ្ចាយតនៈ ដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុត នេះវិញ្ញាណដ្ឋិតិទី ៦

សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនុបគា អយំ សត្តមា វិញ្ញាណដ្ឋិតីតិ ។ ឯវំ ភគវា បដិសន្ធិវសេន សត្ត វិញ្ញាណដ្ឋិតិយោ ជានាតីតិ វិញ្ញាណដ្ឋិតិយោ សព្វា ។ ពោសាលាតិ ភគវាតិ ពោសាលាតិ ភគវា តំ ព្រាហ្មណំ នាមេន អាលបតិ ។ ភគវាតិ គារវាធិវចនមេតំ ។បេ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ ពោសាលាតិ ភគវា ។

(៤៨) អភិជានំ តថាគតោតិ អភិជានន្តោ អភិជានន្តោ បដិវិជានន្តោ បដិវិជ្ឈន្តោ ។ តថាគតោតិ វុត្តញ្ហេតំ ភគវតា អតីតញ្ចេបិ ចុន្ទ ហោតិ អភូតំ អតច្ឆំ អនត្ថញ្ហិតំ ន តំ តថាគតោ ព្យាករោតិ អតីតញ្ចេបិ ចុន្ទ ហោតិ ភូតំ តច្ឆំ អនត្ថសញ្ហិតំ តម្បិ តថាគតោ ន ព្យាករោតិ អតីតញ្ចេបិ ចុន្ទ ហោតិ ភូតំ តច្ឆំ អត្ថសញ្ហិតំ តត្រ កាលញ្ញូ តថាគតោ ហោតិ តស្ស បញ្ហស្ស វេយ្យាករណាយ អនាគតញ្ចេបិ ចុន្ទ ហោតិ ។បេ។

ពួកសត្វប្រព្រឹត្តកន្លងវិញ្ញាណញ្ចាយតនៈ ដោយប្រការទាំងពួង ចូលអាកិញ្ចញ្ញាយតនៈ ដោយបរិកម្មថា របស់តិចតួចមិនមាន នេះវិញ្ញាណដ្ឋិតិទី ៧ ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបវិញ្ញាណដ្ឋិតិ ៧ ដោយអំណាចបដិសន្ធិ យ៉ាងនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) វិញ្ញាណដ្ឋិតិទាំងពួង ។ ពាក្យថា ពោសាល: ក្នុងបទថា ព្រះមានព្រះភាគត្រាស់ថា ម្នាលពោសាល: គឺព្រះមានព្រះភាគត្រាស់ហៅព្រាហ្មណ៍នោះ តាមឈ្មោះ ។ ពាក្យថា ព្រះមានព្រះភាគ នុះជាពាក្យនិយាយដោយគោរព ។ បេ ។ បញ្ញត្តិថា ព្រះមានព្រះភាគ នេះកើតព្រោះការត្រាស់ដឹង ហេតុនោះ (ទើបមានពាក្យថា) ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលពោសាល: ។

(៤៨) អធិប្បាយពាក្យថា ព្រះតថាគតទ្រង់ជ្រាបច្បាស់ ត្រង់ពាក្យថា ជ្រាបច្បាស់ គឺយល់ច្បាស់ ដឹងប្រាកដ ចាក់ធ្លុះ ។ ពាក្យថា ព្រះតថាគត មានន័យដូចតទៅនេះ មែនពិត ព្រះមានព្រះភាគទ្រង់ត្រាស់ពាក្យនេះថា ម្នាលចុន្ទ: បើពាក្យអតីត ជាពាក្យមិនពិត មិនទៀង មិនប្រកបដោយប្រយោជន៍ ព្រះតថាគតមិនពោលពាក្យនោះ ម្នាលចុន្ទ: បើពាក្យអតីត ជាពាក្យពិត ទៀងត្រង់ តែមិនប្រកបដោយប្រយោជន៍ ព្រះតថាគតក៏មិនពោលពាក្យនោះ ម្នាលចុន្ទ: បើពាក្យអតីត ជាពាក្យពិត ទៀងត្រង់ ប្រកបដោយប្រយោជន៍ ព្រះតថាគត ជាអ្នកដឹងកាលគួរ ទើបព្យាករប្រស្នានោះ ក្នុងពាក្យនោះ ម្នាលចុន្ទ: បើពាក្យអនាគត ។ បេ ។

បច្ចុប្បន្នេបិ ចុន្ទ ហោតិ អភូតំ អតច្ឆំ អនត្ថសញ្ហិតំ ន តំ តថាគតោ ព្យាករោតិ បច្ចុប្បន្នេបិ ចុន្ទ ហោតិ ភូតំ តច្ឆំ អនត្ថសញ្ហិតំ តម្បិ តថាគតោ ន ព្យាករោតិ បច្ចុប្បន្នេបិ ចុន្ទ ហោតិ ភូតំ តច្ឆំ អត្ថសញ្ហិតំ តត្រ កាលញ្ញូ តថាគតោ ហោតិ តស្ស បញ្ហស្ស វេយ្យា-ករណាយ ឥតិ ខោ ចុន្ទ អតីតានាគតបច្ចុប្បន្នេសុ ធម្មេសុ តថាគតោ កាលវាទី ភូតវាទី អត្ថវាទី ធម្មវាទី វិនយវាទី តស្មា តថាគតោតិ វុច្ចតិ ។ យំ ខោ ចុន្ទ សទេវកស្ស លោកស្ស សមារ-កស្ស សព្រហ្មកស្ស សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា សព្វំ តថា-គតេន អភិសម្ពុទ្ធំ តស្មា តថាគតោតិ វុច្ចតិ ។ យញ្ច ចុន្ទ រត្តឹ តថាគតោ អនុត្តរំ សម្មាស-ម្ពោធឹ អភិសម្ពុជ្ឈតិ យញ្ច រត្តឹ អនុបាទិសេ-សាយ និព្វានធាតុយា បរិនិព្វាយតិ យំ ឯតស្មឹ អន្តរេ ភាសតិ លបតិ និទ្ទិសតិ សព្វំ តថេវ ហោតិ នោ អញ្ញថា តស្មា តថាគតោតិ វុច្ចតិ ។

ម្នាលចុន្ទៈ បើពាក្យបច្ចុប្បន្ន ជាពាក្យមិនពិត មិនទៀងត្រង់ មិនប្រកបដោយប្រយោជន៍ ព្រះតថាគតមិនពោលពាក្យនោះ ម្នាលចុន្ទៈ បើពាក្យបច្ចុប្បន្ន ជាពាក្យពិត ទៀងត្រង់ តែមិនប្រកបដោយប្រយោជន៍ ព្រះតថាគត ក៏មិនពោលពាក្យនោះ ម្នាលចុន្ទៈ បើពាក្យបច្ចុប្បន្ន ជាពាក្យពិត ទៀងត្រង់ ប្រកបដោយប្រយោជន៍ ព្រះតថាគតជាអ្នកដឹងកាលគួរ ទើបព្យាករប្រស្នានោះ ក្នុងពាក្យនោះ ម្នាលចុន្ទៈ ព្រះតថាគតជាអ្នកពោលតាមកាល ពោលពាក្យពិត ពោលអត្ថ ពោលធម៌ ពោលវិន័យ ក្នុងធម៌ទាំងឡាយជាអតីត អនាគត បច្ចុប្បន្ន ដោយប្រការដូច្នេះឯង ហេតុនោះ ទើបហៅថា ព្រះតថាគត ។ ម្នាលចុន្ទៈ ធម្មជាតណា ដែលលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក-ទាំងពួកសត្វ ព្រមទាំងសមណៈនឹងព្រាហ្មណ៍ មនុស្សជាសម្មតិទេពនឹងមនុស្សដ៏សេស ឃើញ ឮ ប៉ះពាល់ ដឹងច្បាស់ សម្រេច ស្វែងរក ពិចារណា ធម្មជាតទាំងអស់នោះ ព្រះតថាគតត្រាស់ដឹងហើយ ដោយចិត្ត ហេតុនោះ ទើបហៅថា ព្រះតថាគត ។ ម្នាលចុន្ទៈ ព្រះតថាគតត្រាស់ដឹងសម្មាសម្ពោធិញ្ញាណដ៏ក្រៃលែងក្នុងរាត្រីណា បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ក្នុងរាត្រីណា រមែងពោល ចរចា សំដែងនូវពាក្យណា ក្នុងចន្លោះនៃការត្រាស់ដឹងនឹងការបរិនិព្វាននោះ របស់ទាំងអស់នោះ នៅដូចដែល មិនប្រែប្រួលទេ ហេតុនោះ ទើបហៅថា ព្រះតថាគត ។

យថាវាទី ភិក្ខវេ តថាគតោ តថាការី យថាការី តថាវាទី ឥតិ យថាវាទី តថាការី យថាការី តថាវាទី តស្មា តថាគតោតិ វុច្ចតិ ។ សទេវកេ ភិក្ខវេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ តថាគតោ អភិភូ អនភិភូតោ អញ្ញទត្ថុទសោ វសវត្តី តស្មា តថាគតោតិ វុច្ចតីតិ អភិជានំ តថាគតោ ។

(៤៩) តិដ្ឋន្តមេនំ ជានាតីតិ ភគវា ឥធដ្ឋញ្ញេវ ជានាតិ កម្មាភិសង្ខារវសេន អយំ បុគ្គលោ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជិស្សតីតិ ។ ភគវា ឥធដ្ឋញ្ញេវ ជានាតិ កម្មាភិសង្ខារវសេន អយំ បុគ្គលោ កាយស្ស ភេទា បរម្មរណា តិរច្ឆានយោនឹ ឧបបជ្ជិស្សតីតិ ។ ភគវា ឥធដ្ឋញ្ញេវ ជានាតិ កម្មាភិសង្ខារវសេន អយំ បុគ្គលោ កាយស្ស ភេទា បរម្មរណា បិត្តិវិសយំ ឧបបជ្ជិស្សតីតិ ។

ម្នាលចុន្ទៈ ព្រះតថាគត ពោលយ៉ាងណា ធ្វើយ៉ាងនោះ ធ្វើយ៉ាងណា ពោលយ៉ាងនោះ ព្រោះហេតុតែព្រះតថាគត ពោលយ៉ាងណា ធ្វើយ៉ាងនោះ ធ្វើយ៉ាងណា ពោលយ៉ាងនោះ ហេតុនោះ ទើបហៅថា ព្រះតថាគត ។ ម្នាលចុន្ទៈ ព្រះតថាគតគ្របសង្កត់នូវលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក នូវពួកសត្វ ព្រមទាំងសមណៈនឹងព្រាហ្មណ៍ មនុស្សជាសម្មតិ-ទេពនឹងមនុស្សដ៏សេស មិនមានអ្នកណាគ្របសង្កត់បាន តែងឃើញពិត ញ៉ាំងអំណាចឲ្យប្រព្រឹត្តទៅ ហេតុនោះ ទើបហៅថា ព្រះតថាគត ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រះតថាគត ទ្រង់ជ្រាបច្បាស់ ។

(៤៩) ពាក្យថា ទើបទ្រង់ជ្រាបនូវបុគ្គលនោះ ដែលកំពុងរស់នៅ អធិប្បាយថា ព្រះមានព្រះភាគទ្រង់ជ្រាប នូវបុគ្គលដែលឋិតនៅក្នុងទីនេះឯង ដោយអំណាចកម្មាភិសង្ខារថា បុគ្គលនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅនឹងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ព្រះមានព្រះភាគទ្រង់ជ្រាបនូវបុគ្គល ដែលឋិតនៅក្នុងទីនេះឯង ដោយអំណាចកម្មាភិសង្ខារថា បុគ្គលនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងកំណើតតិរច្ឆាន ។ ព្រះមានព្រះភាគទ្រង់ជ្រាបនូវបុគ្គលដែលឋិតនៅ ក្នុងទីនេះឯង ដោយអំណាចកម្មាភិសង្ខារថា បុគ្គលនេះលុះបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងបិត្តិវិស័យ ។

ភគវា ឥធដ្ឋញ្ញេវ ជានាតិ កម្មាភិសង្ខារវសេន អយំ បុគ្គលោ កាយស្ស ភេទា បរម្មរណា មនុស្សេសុ ឧបបជ្ជិស្សតីតិ ។ ភគវា ឥធដ្ឋញ្ញេវ ជានាតិ កម្មាភិសង្ខារវសេន អយំ បុគ្គលោ(១) កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជិស្សតីតិ ។ វុត្តញ្ហេតំ ភគវតា ឥធ បនាហំ សារីបុត្ត ឯកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ តថាយំ បុគ្គលោ បដិបន្នោ តថា ច ឥរិយតិ តញ្ច មគ្គំ សមារូឡ្ហោ យថា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជិស្សតីតិ ។ ឥធ បនាហំ សារីបុត្ត ឯកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ តថាយំ បុគ្គលោ បដិបន្នោ តថា ច ឥរិយតិ តញ្ច មគ្គំ សមារូឡ្ហោ យថា កាយស្ស ភេទា បរម្មរណា តិរច្ឆានយោនឹ ឧបបជ្ជិស្សតីតិ ។ ឥធ បនាហំ សារីបុត្ត ឯកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ តថាយំ បុគ្គលោ បដិបន្នោ

១ ម. ឯត្ថន្តរេ សុប្បដិបន្នោតិ ទិស្សតិ ។

## ពោសាលមាណវកប្បញ្ហានិទ្ទេស

ព្រះមានព្រះភាគទ្រង់ជ្រាប នូវបុគ្គលដែលឋិតនៅក្នុងទីនេះឯង ដោយអំណាចកម្មាភិសង្ខារថា បុគ្គលនេះលុះបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងពួកមនុស្ស ។ ព្រះមានព្រះភាគទ្រង់ជ្រាប នូវបុគ្គលដែលឋិតនៅក្នុងទីនេះឯង ដោយអំណាចកម្មាភិសង្ខារថា បុគ្គលនេះលុះបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ។ ដូចពាក្យដែលព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលសារីបុត្ត តថាគតកំណត់ដឹងចិត្ត របស់បុគ្គលពួកខ្លះក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា បុគ្គលនេះប្រតិបត្តិដូច្នោះ ប្រព្រឹត្តដូច្នោះ ឡើងកាន់ផ្លូវនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលសារីបុត្ត តថាគតកំណត់ដឹងចិត្ត របស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា បុគ្គលនេះប្រតិបត្តិដូច្នោះ ប្រព្រឹត្តដូច្នោះ ឡើងកាន់ផ្លូវនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងកំណើតតិរច្ឆាន ។ ម្នាលសារីបុត្ត តថាគតកំណត់ដឹងចិត្ត របស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា បុគ្គលនេះប្រតិបត្តិដូច្នោះ ប្រព្រឹត្តដូច្នោះ

តថា ច ឥរិយតិ តញ្ច មគ្គំ សមារូឡ្ហោ យថា កាយស្ស ភេទា បរម្មរណា បិត្តិវិសយំ ឧបបជ្ជិស្សតីតិ ។ ឥធ បនាហំ សារីបុត្ត ឯកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ តថាយំ បុគ្គលោ បដិបន្នោ តថា ច ឥរិយតិ តញ្ច មគ្គំ សមារូឡ្ហោ យថា កាយស្ស ភេទា បរម្មរណា មនុស្សេសុ ឧបបជ្ជិស្សតីតិ ។ ឥធ បនាហំ សារីបុត្ត ឯកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ តថាយំ បុគ្គលោ បដិបន្នោ តថា ច ឥរិយតិ តញ្ច មគ្គំ សមារូឡ្ហោ យថា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជិស្សតីតិ ។ ឥធ បនាហំ សារីបុត្ត ឯកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ តថាយំ បុគ្គលោ បដិបន្នោ តថា ច ឥរិយតិ តញ្ច មគ្គំ សមារូឡ្ហោ យថា អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សតីតិ តិដ្ឋន្តមេវំ ជានាតិ ។

ឡើងកាន់ផ្លូវនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងបិត្តិវិស័យ ។ ម្នាលសារីបុត្ត តថាគតកំណត់ដឹងចិត្តរបស់បុគ្គលពួកខ្លះក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា បុគ្គលនោះ ប្រតិបត្តិដូច្នោះ ប្រព្រឹត្តដូច្នោះ ឡើងកាន់ផ្លូវនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងពួកមនុស្ស ។ ម្នាលសារីបុត្ត តថាគតកំណត់ដឹងចិត្តរបស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា បុគ្គលនេះ ប្រតិបត្តិដូច្នោះ ប្រព្រឹត្តដូច្នោះ ឡើងកាន់ផ្លូវនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើត ក្នុងសុគតិ សួគ៌ ទេវលោក ។ ម្នាលសារីបុត្ត តថាគតកំណត់ដឹងចិត្ត របស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា បុគ្គលនេះប្រតិបត្តិដូច្នោះ ប្រព្រឹត្តដូច្នោះ ឡើងកាន់ផ្លូវនោះ នឹងត្រាស់ដឹងដោយខ្លួនឯង ធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ហើយសម្រេចសម្រាន្តនៅក្នុងបច្ចុប្បន្ន ហេតុនោះ (ទ្រង់ត្រាស់ថា) ទើបទ្រង់ជ្រាបនូវបុគ្គលនោះ ដែលកំពុងរស់នៅ ។

(៥០) វិមុត្តំ តប្បរាយន្តិ វិមុត្តន្តិ អាកិញ្ចញ្ញា-
យតនេ វិមុត្តំ តទធិមុត្តំ តទាធិបតេយ្យំ ។ អថវា
កកក ជាជាតិ អយំ បុគ្គលោ រូបាធិមុត្តោ សទ្ទាធិ-
មុត្តោ គន្ធាធិមុត្តោ រសាធិមុត្តោ ផោដ្ឋព្វាធិមុត្តោ
កុលាធិមុត្តោ គណាធិមុត្តោ អាវាសាធិមុត្តោ លាភា-
ធិមុត្តោ យសាធិមុត្តោ បសំសាធិមុត្តោ សុខាធិមុត្តោ
ចីវរាធិមុត្តោ បិណ្ឌបាតាធិមុត្តោ សេនាសនាធិមុត្តោ
គិលានប្បច្ចយភេសជ្ជបរិក្ខារាធិមុត្តោ សុត្តន្តាធិមុត្តោ
វិនយាធិមុត្តោ អភិធម្មាធិមុត្តោ បំសុកូលិកង្គាធិមុត្តោ
តេចីវរិកង្គាធិមុត្តោ បិណ្ឌបាតិកង្គាធិមុត្តោ សបទា-
នចារិកង្គាធិមុត្តោ ឯកាសនិកង្គាធិមុត្តោ បត្តបិណ្ឌិ-
កង្គាធិមុត្តោ ខលុបច្ឆាភត្តិកង្គាធិមុត្តោ អារញ្ញិក-
ង្គាធិមុត្តោ រុក្ខមូលិកង្គាធិមុត្តោ អព្ភោកាសិកង្គាធិ-
មុត្តោ សោសានិកង្គាធិមុត្តោ យថាសន្ថតិកង្គាធិ-
មុត្តោ នេសជ្ជិកង្គាធិមុត្តោ បឋមជ្ឈានាធិមុត្តោ ទុតិយ-
ជ្ឈានាធិមុត្តោ តតិយជ្ឈានាធិមុត្តោ ចតុត្ថជ្ឈានាធិមុត្តោ

បោសាលមាណវកប្បញ្ហានិទ្ទេស

(៩០) អធិប្បាយថា អ្នកមានចិត្តជាប់ (ក្នុងអាកិញ្ចញ្ញាយតនៈ) មាន អាកិញ្ចញ្ញាយតនៈនោះប្រព្រឹត្តទៅខាងមុខ ត្រង់ពាក្យថា អ្នកមានចិត្តជាប់ គឺមានចិត្តជាប់ក្នុងអាកិញ្ចញ្ញាយតនៈ ជាប់ក្នុងអាកិញ្ចញ្ញាយតនៈនោះ មាន អាកិញ្ចញ្ញាយតនៈនោះជាអធិបតី ។ មួយទៀត ព្រះមានព្រះភាគទ្រង់ ជ្រាបថា បុគ្គលនេះជាប់ក្នុងរូប ជាប់ក្នុងសំឡេង ជាប់ក្នុងក្លិន ជាប់ក្នុងរស ជាប់ក្នុងផោដ្ឋព្វៈ ជាប់ក្នុងត្រកូល ជាប់ក្នុងគណៈ ជាប់ក្នុងអាវាស ជាប់ក្នុង លាភ ជាប់ក្នុងយស ជាប់ក្នុងសេចក្តីសរសើរ ជាប់ក្នុងសុខ ជាប់ក្នុងចីវរ ជាប់ក្នុងបិណ្ឌបាត ជាប់ក្នុងសេនាសនៈ ជាប់ក្នុងគិលានប្បច្ច័យភេសជ្ជបរិក្ខារ ជាប់ក្នុងព្រះសូត្រ ជាប់ក្នុងវិន័យ ជាប់ក្នុងអភិធម្ម ជាប់ក្នុងបំសុកូលិកង្គៈ ជាប់ក្នុងតេចីវរិកង្គៈ ជាប់ក្នុងបិណ្ឌបាតិកង្គៈ ជាប់ក្នុងសបទានចារិកង្គៈ ជាប់ ក្នុងឯកាសនិកង្គៈ ជាប់ក្នុងបត្តបិណ្ឌិកង្គៈ ជាប់ក្នុងខលុបច្ឆាភត្តិកង្គៈ ជាប់ក្នុង អារញ្ញិកង្គៈ ជាប់ក្នុងរុក្ខមូលិកង្គៈ ជាប់ក្នុងអព្ភោកាសិកង្គៈ ជាប់ក្នុងសោសា- និកង្គៈ ជាប់ក្នុងយថាសន្ថតិកង្គ ជាប់ក្នុងនេសជ្ជិកង្គ ជាប់ក្នុងបឋម- ជ្ឈាន ជាប់ក្នុងទុតិយជ្ឈាន ជាប់ក្នុងតតិយជ្ឈាន ជាប់ក្នុងចតុត្ថជ្ឈាន

អាកាសានញ្ចាយតនសមាបត្តាធិមុត្តោ វិញ្ញាណញ្ចាយតនសមាបត្តាធិមុត្តោ អាកិញ្ចញ្ញាយតនសមាបត្តាធិមុត្តោ នេវសញ្ញានាសញ្ញាយតនសមាបត្តាធិមុត្តោតិ វិមុត្តំ ។ តប្បរាយណន្តិ អាកិញ្ចញ្ញាយតនមយំ តប្បរាយណំ កម្មប្បរាយណំ វិបាកប្បរាយណំ កម្មគរុកំ បដិសន្ធិគរុកំ ។ អថវា ភគវា ជានាតិ អយំ បុគ្គលោ រូបប្បរាយណោ ។ បេ ។ នេវសញ្ញានាសញ្ញាយតនសមាបត្តិប្បរាយណោតិ វិមុត្តំ តប្បរាយណំ ។ តេនាហ ភគវា

វិញ្ញាណដ្ឋិតិយោ សព្វា (ពោសាលាតិ ភគវា)
អភិជានំ តថាគតោ
តិដ្ឋន្តមេនំ ជានាតិ
វិមុត្តំ តប្បរាយណន្តិ ។

ជាប់ក្នុងអាកាសានញ្ចាយតនសមាបត្តិ ជាប់ក្នុងវិញ្ញាណញ្ចាយតនសមាបត្តិ ជាប់ក្នុងអាកិញ្ចញ្ញាយតនសមាបត្តិ ជាប់ក្នុងនេវសញ្ញានាសញ្ញាយតនសមា-បត្តិ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកមានចិត្តជាប់ ។ ពាក្យថា មានអាកិញ្ចញ្ញាយតនៈប្រព្រឹត្តទៅខាងមុខ គឺ សម្រេចដោយអាកិញ្ចញ្ញាយ-តនៈ មានសមាបត្តិនោះប្រព្រឹត្តទៅខាងមុខ មានកម្មប្រព្រឹត្តទៅខាងមុខ មានវិបាកប្រព្រឹត្តទៅខាងមុខ ធ្ងន់ដោយកម្ម ធ្ងន់ដោយបដិសន្ធិ ។ មួយវិញទៀត ព្រះមានព្រះភាគទ្រង់ជ្រាបថា បុគ្គលនេះ មានរូបប្រព្រឹត្តទៅខាងមុខ ។ បេ ។ មាននេវសញ្ញានាសញ្ញាយតនសមាបត្តិប្រព្រឹត្តទៅខាងមុខ ហេតុនោះ (ទ្រង់ត្រាស់ថា) ជាអ្នកមានចិត្តជាប់ក្នុងអាកិញ្ចញ្ញាយតនៈ មានអាកិញ្ចញ្ញាយតនៈនោះប្រព្រឹត្តទៅខាងមុខ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

(ព្រះមានព្រះភាគត្រាស់ថា ម្នាលពោសាលៈ) ព្រះតថាគត
ទ្រង់ជ្រាបច្បាស់នូវវិញ្ញាណដ្ឋិតិទាំងពួង ទើបទ្រង់ជ្រាបនូវបុគ្គល
នោះ ដែលកំពុងរស់នៅ មានចិត្តជាប់ក្នុងអាកិញ្ចញ្ញាយតនៈ
មានអាកិញ្ចញ្ញាយតនៈនោះប្រព្រឹត្តទៅខាងមុខ ។

ពោសាលមាណវកបុច្ឆានិទ្ទេសោ

(៥១) អាកិញ្ចញ្ញសម្ភវំ ញត្វា នន្ទិសញ្ញោជនំ ឥតិ

ឯវមេតំ អភិញ្ញាយ តតោ តត្ថ វិបស្សតិ

ឯតំ ញាណំ តថំ តស្ស ព្រាហ្មណស្ស វុសីមតោ ។

(៥២) អាកិញ្ចញ្ញសម្ភវំ ញត្វាតិ អាកិញ្ចញ្ញសម្ភវោ វុច្ចតិ អាកិញ្ចញ្ញាយតនសំវត្តនិកោ កម្មាភិសង្ខារោ ។ អាកិញ្ចញ្ញាយតនសំវត្តនិកំ កម្មាភិសង្ខារំ អាកិញ្ចញ្ញសម្ភវោតិ ញត្វា លគ្គនន្តិ ញត្វា ពន្ធនន្តិ ញត្វា បលិពោធោតិ ញត្វា ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វាតិ អាកិញ្ចញ្ញសម្ភវំ ញត្វា ។

(៥៣) នន្ទិសញ្ញោជនំ ឥតីតិ នន្ទិសញ្ញោជនំ វុច្ចតិ អរូបរាគោ ។ អរូបរាគេន តំ កម្មំ លគ្គំ លគ្គិតំ បលិពុទ្ធំ អរូបរាគំ នន្ទិសញ្ញោជនន្តិ ញត្វា លគ្គនន្តិ ញត្វា

ពោសាលមាណវកបញ្ហានិទ្ទេស

(៥១) បុគ្គលដឹងនូវការកើតព្រមនៃអាកិញ្ចញ្ញា ដឹងនូវសេចក្តីរីករាយ ជាគ្រឿងប្រកបដូច្នេះ លុះដឹងច្បាស់សេចក្តីនុ៎ះយ៉ាងនេះ ហើយចេញអំពីសមាបត្តិនោះ រមែងឃើញច្បាស់ក្នុងសមាបត្តិនោះ នេះឯងជាញាណដ៏ពិតប្រាកដរបស់ព្រាហ្មណ៍ដែលមានព្រហ្មចរិយៈនៅរួចហើយនោះ ។

(៥២) ពាក្យថា ដឹងនូវការកើតព្រមនៃអាកិញ្ចញ្ញា សេចក្តីថា កម្មាភិសង្ខារ ដែលញុំាងអាកិញ្ចញ្ញាយតនៈ ឲ្យប្រព្រឹត្តទៅព្រម លោកហៅថា ការកើតព្រមនៃអាកិញ្ចញ្ញា ។ បុគ្គល ដឹងនូវកម្មាភិសង្ខារ ដែលញុំាងអាកិញ្ចញ្ញាយតនៈឲ្យប្រព្រឹត្តទៅព្រមថា ការកើតព្រម នៃអាកិញ្ចញ្ញា ដឹងថាជាគ្រឿងជាប់ ដឹងថាជាចំណង ដឹង ស្គាល់ ស្ទង់មើល ពិចារណា ចម្រើន ធ្វើឲ្យប្រាកដថាជាគ្រឿងកង្វល់ ហេតុនោះ (ទ្រង់ត្រាស់ថា) ដឹងនូវការកើតព្រមនៃអាកិញ្ចញ្ញា ។

(៥៣) ពាក្យថា សេចក្តីរីករាយជាគ្រឿងប្រកបដូច្នេះ គឺសេចក្តីត្រេកត្រអាលក្នុងអរូប ហៅថា សេចក្តីរីករាយជាគ្រឿងប្រកប ។ កម្មនោះជាប់ ជាប់ស្អិត ខ្វល់ ដោយសេចក្តីត្រេកត្រអាលក្នុងអរូប បុគ្គលដឹងនូវសេចក្តីត្រេកត្រអាលក្នុងអរូបថា សេចក្តីរីករាយជាគ្រឿងប្រកប ដឹងថាជាគ្រឿងជាប់

ពន្ធនន្តិ ញត្វា បលិពោធោតិ ញត្វា ជានិត្វា តុលយិត្វា តិរយិត្វា វិភាវយិត្វា វិភូតំ កត្វា ។ ឥតីតិ បទសន្ធិ ។ បេ ។ បទានុបុព្វតាមេតំ ឥតីតិ នន្ទិសញ្ញោជនំ ឥតិ ។

(៥៤) ឯវមេតំ អភិញ្ញាយាតិ ឯវំ ឯតំ អភិញ្ញាយ ជានិត្វា តុលយិត្វា តិរយិត្វា វិភាវយិត្វា វិភូតំ កត្វាតិ ឯវមេតំ អភិញ្ញាយ ។

(៥៥) តតោ តត្ថ វិបស្សតីតិ អាកិញ្ចញ្ញាយតនំ សមាបជ្ជិត្វា តតោ វុដ្ឋហិត្វា តត្ថ ជាតេ ចិត្តចេតសិកេ ធម្មេ អនិច្ចតោ វិបស្សតិ ទុក្ខតោ វិបស្សតិ រោគតោ ។ បេ ។ អនិស្សរណតោ វិបស្សតិ ទក្ខតិ ឱលោកេតិ និជ្ឈាយតិ ឧបបរិក្ខតីតិ តតោ តត្ថ វិបស្សតិ ។

(៥៦) ឯតំ ញាណំ តថំ តស្សាតិ ឯតំ ញាណំ តច្ឆំ ភូតំ យាថាវំ អវិបរីតំ តស្សាតិ ឯតំ ញាណំ តថំ តស្ស ។

ដឹងថាជាគ្រឿងចង ដឹង ស្គាល់ ស្ទង់មើល ពិចារណា ចម្រើន ធ្វើឲ្យជាក់ច្បាស់ថាជាកង្វល់ ។ ពាក្យថា ដូច្នេះ ជាការតបទ ។ បេ ។ ពាក្យថា ដូច្នេះ នេះជាលំដាប់បទ ហេតុនោះ (ទ្រង់ត្រាស់ថា) សេចក្តីរីករាយជាគ្រឿងប្រកបដូច្នេះ ។

(៥៤) ពាក្យថា លុះដឹងច្បាស់ សេចក្តីនុ៎ះយ៉ាងនេះហើយ គឺ ដឹង ស្គាល់ ស្ទង់មើល ពិចារណា ចម្រើន ធ្វើឲ្យប្រាកដនូវសេចក្តីនុ៎ះយ៉ាងនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) លុះដឹងច្បាស់សេចក្តីនុ៎ះយ៉ាងនេះហើយ ។

(៥៥) ពាក្យថា ចេញអំពីសមាបត្តិនោះ រមែងឃើញច្បាស់ក្នុងសមាបត្តិនោះ គឺចូលអាកិញ្ចញ្ញាយតនៈ ហើយចេញចាកសមាបត្តិនោះ រមែងឃើញច្បាស់ នូវពួកធម៌គឺចិត្តនិងចេតសិក ដែលកើតក្នុងសមាបត្តិនោះថា មិនទៀង ឃើញច្បាស់ថាជាទុក្ខ យល់ច្បាស់ ឃើញ ក្រឡេកមើល សំឡឹងមើល កំណត់មើលថាជារោគ ។ បេ ។ ថាមិនជាទីរលាស់ទុក្ខ ហេតុនោះ (ទ្រង់ត្រាស់ថា) ចេញអំពីសមាបត្តិនោះ រមែងឃើញច្បាស់ក្នុងសមាបត្តិនោះ ។

(៥៦) ពាក្យថា នេះឯងជាញាណដ៏ពិតប្រាកដ របស់ព្រាហ្មណ៍នោះ សេចក្តីថា ញាណនុ៎ះរបស់ព្រាហ្មណ៍នោះ ជាធម្មជាតពិត ទៀងប្រាកដ មិនប្រែប្រួល ហេតុនោះ (ទ្រង់ត្រាស់ថា) នេះឯងជាញាណដ៏ពិតប្រាកដ របស់ព្រាហ្មណ៍នោះ ។

(៨៧) ព្រាហ្មណស្ស វុសីមតោតិ ព្រាហ្មណស្សាតិ សត្តន្នំ ធម្មានំ ពាហិតត្តា ព្រាហ្មណោ ។បេ។ អនិស្សិតោ តាទិ បវុច្ចតេ ស ព្រហ្មាតិ ព្រាហ្មណស្ស ។ វុសីមតោតិ កល្យាណបុថុជ្ជនេ ឧបាទាយ សត្ត សេក្ខា អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ វសន្តិ សំវសន្តិ អាវសន្តិ បរិវសន្តិ ។ អរហា វុសិតវា កតករណីយោ ឱហិតភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសញ្ញោជនោ សម្មទញ្ញា វិមុត្តោ សោ វុដ្ឋវាសោ ចិណ្ណចរណោ ។បេ។ ជាតិជរាមរណសំសារោ នត្ថិ តស្ស បុនព្ភវោតិ ព្រាហ្មណស្ស វុសីមតោ ។ តេនាហ ភគវា

## បោសាលមាណវកបញ្ហានិទ្ទេស

(៥៧) ពាក្យថា របស់ព្រាហ្មណ៍ ក្នុងបទថា របស់ព្រាហ្មណ៍ ដែលមានព្រហ្មចរិយៈនៅរួចហើយ គឺឈ្មោះថាព្រាហ្មណ៍ ព្រោះបន្សាត់បង់ធម៌ទាំង ៧ ។ បេ ។ ជាបុគ្គលមិនអាស្រ័យកិលេស មិនញាប់ញ័រ បុគ្គលនោះ លោកហៅថា ព្រាហ្មណ៍ ហេតុនោះ (ទ្រង់ត្រាស់ថា) របស់ព្រាហ្មណ៍ ។ ពាក្យថា មានព្រហ្មចរិយៈនៅរួចហើយ បានដល់ពួកសេក្ខៈទាំង ៧ រាប់បញ្ចូលទាំងកល្យាណបុថុជ្ជន រមែងនៅ នៅគ្រប់គ្រង នៅថែទាំ នៅនិត្យ ដើម្បីសម្រេចគុណវិសេសដែលមិនទាន់ដល់ ដើម្បីបានធម៌ដែលមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលមិនទាន់ធ្វើឲ្យជាក់ច្បាស់ ។ ព្រះអរហន្តមានព្រហ្មចរិយៈនៅរួចហើយ មានករណីយកិច្ចធ្វើរួចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍ខ្លួនសម្រេចហើយ មានសញ្ញោជនៈក្នុងភពអស់រលីងហើយ មានចិត្តផុតស្រឡះហើយ ព្រោះដឹងដោយប្រពៃ ព្រះអរហន្តនោះ ឈ្មោះថាមានអរិយវាសនៅរួចហើយ មានចរណៈសន្សំហើយ ។ បេ ។ ភពថ្មី គឺ ជាតិ ជរា មរណៈ សង្សារ របស់ព្រះអរហន្តនោះមិនមានទេ ហេតុនោះ (ទ្រង់ត្រាស់ថា) របស់ព្រាហ្មណ៍ ដែលមានព្រហ្មចរិយៈនៅរួចហើយ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

អាកិញ្ចញ្ញាសម្ភវំ ញត្វា នន្ទិសំយោជនំ ឥតិ

ឯវមេតំ អភិញ្ញាយ តតោ តត្ថ វិបស្សតិ

ឯតំ ញាណំ តថំ តស្ស ព្រាហ្មណស្ស វុសីមតោតិ ។

សហ គាថាបរិយោសានា ។ បេ ។ សត្ថា មេ ភន្តេ ភគវា សាវកោហមស្មីតិ ។

បោសាលមាណវកប្បញ្ហានិទ្ទេសោ ចុទ្ទសមោ ។

បុគ្គល ដឹងនូវការកើតព្រម នៃអាកិញ្ចញ្ញា ដឹងនូវសេចក្តីរីករាយជាគ្រឿងប្រកប ដូច្នេះ លុះដឹងច្បាស់សេចក្តីនុ៎ះយ៉ាងនេះ ហើយចេញ អំពីសមាបត្តិនោះ រមែងឃើញច្បាស់ក្នុងសមាបត្តិនោះ នេះឯងជាញាណដ៏ពិតប្រាកដ របស់ព្រាហ្មណ៍ ដែលមានព្រហ្មចរិយធម៌នៅរួចហើយនោះ ។ លុះចប់គាថា ។ បេ ។ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គសូមជាសាវ័ក ។

ចប់ ពោសាលមាណវកប្បញ្ហានិទ្ទេស ទី ១៤ ។

---

# មោឃរាជមាណវកប្បញ្ហានិទ្ទេសោ

(៨៨) ទ្វាហំ សក្កំ អបុច្ឆិស្សំ

(ឥច្ចាយស្មា មោឃរាជា)

ន មេ ព្យាកាសិ ចក្ខុមា
យាវតតិយញ្ច ទេវីសិ
ព្យាករោតីតិ មេ សុតំ ។

(៨៩) ទ្វាហំ សក្កំ អបុច្ឆិស្សន្តិ សោ ព្រាហ្មណោ ទ្វិក្ខត្តុំ ពុទ្ធំ ភគវន្តំ បញ្ហំ អបុច្ឆិ តស្ស ភគវា បញ្ហំ បុដ្ឋោ ន ព្យាកាសិ ចក្ខុសមនន្តរា[1] ឥមស្ស ព្រាហ្មណស្ស ឥន្ទ្រិយបរិបាកោ ភវិស្សតីតិ ។ សក្កាតិ សក្កោ ។ ភគវា សក្យកុលា បព្វជិតោតិបិ សក្កោ ។ អឌ្ឍោ មហទ្ធនោ ធនវាតិបិ សក្កោ ។ តស្សិមានិ ធនានិ សេយ្យថីទំ សទ្ធាធនំ សីលធនំ ហិរិធនំ ឱត្តប្បធនំ សុតធនំ ចាគធនំ

---

១ ម. តទន្តរា ។

# មោឃរាជមាណវកប្បញ្ហានិទ្ទេស

(៤៨) (មោឃរាជមានអាយុ ទូលដូច្នេះថា) បពិត្រព្រះអង្គជាសក្កៈ ខ្ញុំព្រះអង្គបានទូលសួរ អស់វារៈពីរដងរួចហើយ ព្រះអង្គមានចក្ខុ ទ្រង់មិនទាន់ដោះស្រាយ ចំពោះខ្ញុំព្រះអង្គនៅឡើយ ខ្ញុំព្រះអង្គបានឮថា ព្រះអង្គជាទេវឫសី (កាលបើមានគេសាកសួរ) អស់វារៈបីដង ទ្រង់តែងតែព្យាករពុំខាន ។

(៤៩) ពាក្យថា បពិត្រព្រះអង្គជាសក្កៈ ខ្ញុំព្រះអង្គបានទូលសួរ អស់វារៈពីរដងរួចហើយ អធិប្បាយថា ព្រាហ្មណ៍នោះ បានទូលសួរប្រស្នាចំពោះព្រះពុទ្ធមានព្រះភាគ អស់វារៈពីរដងរួចហើយ តែព្រះមានព្រះភាគ កាលព្រាហ្មណ៍នោះសួរប្រស្នាហើយ ទ្រង់មិនទាន់ព្យាករនៅឡើយ ដោយទ្រង់ព្រះតម្រិះថា ព្រាហ្មណ៍នេះ នឹងមានឥន្ទ្រិយចាស់ក្លា ក្នុងកាលជាលំដាប់ស្មើនៃធម្មចក្ខុ ។ ពាក្យថា បពិត្រព្រះអង្គជាសក្កៈ គឺព្រះមានព្រះភាគ ឈ្មោះថាសក្កៈ ។ ដែលព្រះមានព្រះភាគឈ្មោះសក្កៈ ព្រោះហេតុទ្រង់ចេញចាកសក្យត្រកូលហើយបួសក៏បាន ។ ឬថា ឈ្មោះសក្កៈ ព្រោះហេតុទ្រង់ស្ដុកស្ដម្ភ មានទ្រព្យច្រើន មានធនធាន ក៏បាន ។ នេះទ្រព្យរបស់ព្រះអង្គ គឺ ទ្រព្យគឺសទ្ធា ទ្រព្យគឺសីល ទ្រព្យគឺហិរិ ទ្រព្យគឺឱត្តប្បៈ ទ្រព្យគឺសុតៈ ទ្រព្យគឺចាគៈ

បញ្ញាធនំ សតិបដ្ឋានធនំ សម្មប្បធានធនំ ឥទ្ធិបាទធនំ ឥន្ទ្រិយធនំ ពលធនំ ពោជ្ឈង្គធនំ មគ្គធនំ ផលធនំ និព្វានធនំ ។ ឥមេហិ អនេកវិធេហិ ធនរតនេហិ អឌ្ឍោ មហទ្ធនោ ធនវាតិបិ សក្កោ ។ អថវា សក្កោ បហុ វិសវី អលមត្តោ សូរោ វីរោ វិក្កន្តោ អភិរុ អច្ឆម្ភី អនុត្រាសី អបលាយី បហីនភយភេរវោ វិគតលោមហំសោតិបិ សក្កោតិ ទ្វាហំ សក្ក ។ អបុច្ឆិស្សន្តិ ទ្វាហំ សក្ក អបុច្ឆិស្សំ អយាចិស្សំ អជ្ឈេសិស្សំ បសាទយិស្សន្តិ ទ្វាហំ សក្ក អបុច្ឆិស្សំ ។ ឥច្ចាយស្មា មោឃរាជាតិ ឥច្ចាតិ បទសន្ធិ ។ អាយស្មាតិ បិយវចនំ ។ មោឃរាជាតិ តស្ស ព្រាហ្មណស្ស នាមំ ។ បេ ។ អភិលាបោតិ ឥច្ចាយស្មា មោឃរាជា ។

ទ្រព្យគឺបញ្ញា ទ្រព្យគឺសតិប្បដ្ឋាន ទ្រព្យគឺសម្មប្បធាន ទ្រព្យគឺឥទ្ធិបាទ ទ្រព្យគឺឥន្ទ្រិយ ទ្រព្យគឺពលៈ ទ្រព្យគឺពោជ្ឈង្គ ទ្រព្យគឺមគ្គ ទ្រព្យគឺផល ទ្រព្យគឺនិព្វាន ។ ព្រះនាមសក្កៈ ព្រោះហេតុព្រះអង្គស្តុកស្តម្ភ មានទ្រព្យច្រើន មានធនធាន ដោយទ្រព្យដ៏ប្រសើរ ច្រើនប្រការទាំងនេះ ក៏បាន ។ ពុំនោះសោត ឈ្មោះសក្កៈ ព្រោះហេតុទ្រង់អង់អាច មោះមុត ក្លាហាន មានព្យាយាមតស៊ូ ក្លៀវក្លា សង្វាត ប្រឹងប្រែង មិនខ្លាច មិនរន្ធត់ មិនតក់ស្លុត មិនរត់ចោល លះភ័យគួរខ្លាច មិនព្រឺរោម ក៏បាន ។ ហេតុនោះ (លោកពោលថា) បពិត្រព្រះអង្គជាសក្កៈ ខ្ញុំព្រះអង្គ (បានទូលសួរ) អស់វារៈពីរដងរួចហើយ ។ ពាក្យថា ខ្ញុំព្រះអង្គបានទូលសួរ (សេចក្ដីថា) បពិត្រព្រះអង្គជាសក្កៈ ខ្ញុំព្រះអង្គបានទូលសួរ បានអង្វរ បានអារាធនា បានជ្រះថ្លា អស់វារៈពីរដងរួចហើយ ហេតុនោះ (លោកពោលថា) បពិត្រព្រះអង្គជាសក្កៈ ខ្ញុំព្រះអង្គបានទូលសួរ អស់វារៈពីរដងរួចហើយ ។ ពាក្យថា ដូច្នេះ នៃបទថា មោឃរាជមានអាយុទូលដូច្នេះ គឺជាការតបទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ។ ពាក្យថា មោឃរាជ ជាឈ្មោះ ។ បេ ។ ជាពាក្យសម្រាប់ហៅព្រាហ្មណ៍នោះ ហេតុនោះ (មានពាក្យថា) មោឃរាជមានអាយុទូលដូច្នេះ ។

## ហេមកមាណវបុច្ឆានិទ្ទេសោ

(៦០) ន មេ ព្យាកាសិ ចក្ខុមាតិ ន មេ ព្យាកាសីតិ មេ ន អាចិក្ខិ(១) ន ទេសេសិ ន បញ្ញបេសិ ន បដ្ឋបេសិ ន វិវរិ ន វិភជិ ន ឧត្តានីអកាសិ ន បកាសេសិ ។ ចក្ខុមាតិ ភគវា បញ្ចហិ ចក្ខូហិ ចក្ខុមា មំសចក្ខុនាបិ ចក្ខុមា ទិព្វចក្ខុនាបិ ចក្ខុមា បញ្ញាចក្ខុនាបិ ចក្ខុមា ពុទ្ធចក្ខុនាបិ ចក្ខុមា សមន្តចក្ខុនាបិ ចក្ខុមា ។

កថំ ភគវា មំសចក្ខុនាបិ ចក្ខុមា ។ មំសចក្ខុម្ហិ ភគវតោ បញ្ច វណ្ណា សំវិជ្ជន្តិ នីលោ ច វណ្ណោ បីតកោ ច វណ្ណោ លោហិតកោ ច វណ្ណោ កណ្ហោ ច វណ្ណោ ឱទាតោ ច វណ្ណោ ។ យត្ថ ច អក្ខិលោមានិ បតិដ្ឋិតានិ តំ នីលំ ហោតិ សុនីលំ បាសាទិកំ ទស្សនេយ្យំ ឧម្មារបុប្ផសមានំ ។ តស្ស បរតោ បីតកំ ហោតិ សុបីតកំ សុវណ្ណវណ្ណំ បាសាទិកំ ទស្សនេយ្យំ កណ្ណិការបុប្ផសមានំ ។

---

១ ម. អាចិក្ខសិ ។

(៦០) អធិប្បាយ ពាក្យថា ព្រះអង្គមានចក្ខុ ទ្រង់មិនទាន់ដោះស្រាយចំពោះខ្ញុំព្រះអង្គនៅឡើយ ត្រង់ពាក្យថា មិនទាន់ដោះស្រាយចំពោះខ្ញុំព្រះអង្គ គឺមិនទាន់ប្រាប់ មិនទាន់សំដែង មិនទាន់បញ្ញត្ត មិនទាន់តាំងទុក មិនទាន់បើក មិនទាន់ចែក មិនទាន់ធ្វើឲ្យងាយ មិនទាន់ប្រកាសដល់ខ្ញុំព្រះអង្គ ។ ពាក្យថា មានចក្ខុ គឺ ព្រះមានព្រះភាគ ទ្រង់មានចក្ខុដោយចក្ខុ ៥ គឺ មានចក្ខុដោយមំសចក្ខុ ១ មានចក្ខុដោយទិព្វចក្ខុ ១ មានចក្ខុដោយបញ្ញាចក្ខុ ១ មានចក្ខុដោយពុទ្ធចក្ខុ ១ មានចក្ខុដោយសមន្តចក្ខុ ១ ។

ព្រះមានព្រះភាគ ទ្រង់មានចក្ខុ ដោយមំសចក្ខុ តើដូចម្តេច ។ គឺក្នុងមំសចក្ខុរបស់ព្រះមានព្រះភាគ មានសម្បុរ ៥ គឺ សម្បុរខៀវ ១ សម្បុរលឿង ១ សម្បុរក្រហម ១ សម្បុរខ្មៅ ១ សម្បុរ-ស ១ ។ ទីណា ដែលមានរោមព្រះនេត្រប្រតិស្ឋាននៅ ទីនោះឯង មានសម្បុរខៀវ ខៀវស្រស់ គួរជ្រះថ្លា គួរក្រឡេកមើល ជាទីដូចផ្កាត្រកៀត ។ ទីខាងនាយអំពីនោះ មានសម្បុរលឿង លឿងស្រស់ មានសម្បុរដូចមាស គួរជ្រះថ្លា គួរក្រឡេកមើល ជាទីដូចផ្កាកណ្ណិការ ។

ឧភយតោ ច អក្ខិកូបានិ(១) ភគវតោ លោហិតកានិ ហោន្តិ សុលោហិតកានិ បាសាទិកានិ ទស្សនេយ្យានិ ឥន្ទគោបកសមានានិ ។ មជ្ឈេ កណ្ហំ ហោតិ សុកណ្ហំ អលូខំ សិនិទ្ធំ បាសាទិកំ ទស្សនេយ្យំ អឡារិដ្ឋកសមានំ ។ តស្ស បរតោ ឱទាតំ ហោតិ សុឱទាតំ សេតំ បណ្ឌរំ បាសាទិកំ ទស្សនេយ្យំ ឱសធិតារកសមានំ ។ តេន ភគវា បាកតិកមំសចក្ខុនា អត្តភាវបរិយាបន្នេន បុរិមសុចរិតកម្មាភិនិព្វត្តេន សមន្តា យោជនំ បស្សតិ ទិវា ចេវ រត្តិញ្ច ។ យទាបិ ចតុរង្គសមន្នាគតោ អន្ធការោ ហោតិ សុរិយោ ច អត្ថង្គមិតោ ហោតិ កាឡបក្ខោ ច ឧបោសថោ ហោតិ តិព្វោ ច វនសណ្ឌោ ហោតិ មហា ច អកាលមេឃោ អព្ភុដ្ឋិតោ ហោតិ ឯវរូបេ ចតុរង្គសមន្នាគតេ អន្ធការេ សមន្តា យោជនំ បស្សតិ ។ នត្ថិ សោ កុដ្ដោ វា កវាដំ វា បាការោ វា បព្វតោ វា គច្ឆោ វា លតា វា អាវរណំ រូបានំ ទស្សនាយ ។

---

១ ម. អក្ខិកូដានិ ។

មួយទៀត រណ្តៅព្រះនេត្រទាំងពីរខាង របស់ព្រះមានព្រះភាគ មានសម្បុរក្រហម ក្រហមប្រាល គួរជ្រះថ្លា គួរក្រឡេកមើល ជាទីដូចសម្បុរមេក្លៀង ៗ ទីត្រង់កណ្តាល មានសម្បុរខ្មៅ ខ្មៅស្រស់ មិនសៅហ្មង ស្និទ្ធ គួរជ្រះថ្លា គួរក្រឡេកមើល ជាទីដូចសម្បុរផ្លែផ្គាំ ៗ ទីខាងនាយពីនោះ មានសម្បុរ-ស សភ្លឹង សស្រស់ សថ្លា គួរជ្រះថ្លា គួរក្រឡេកមើល ជាទីដូចផ្កាយព្រឹក ៗ ហេតុនោះបានជា ព្រះមានព្រះភាគតែងទតឃើញមួយយោជន៍ដោយជុំវិញ ទាំងថ្ងៃទាំងយប់ ដោយមំសចក្ខុធម្មតា ដែលកប់បញ្ចូលក្នុងអត្តភាព កើតដោយផលនៃសុចរិតកម្មក្នុងកាលមុន ៗ សូម្បីក្នុងកាលណា ដែលមានងងឹតប្រកបដោយអង្គបួន គឺព្រះអាទិត្យអស្តង្គត ១ ឧបោសថខាងកាឡបក្ខ ១ ដងព្រៃយ៉ាងក្រាស់ជិត ១ មហាអកាលមេឃ (ភ្លៀងធំខុសកាល) ប្រាកដឡើង ១ ក្នុងកាលនោះ ព្រះមានព្រះភាគទតឃើញមួយយោជន៍ដោយជុំវិញ ក្នុងទីងងឹតប្រកបដោយអង្គបួន មានសភាពយ៉ាងនេះ ៗ ផ្ទះកំពូលក្តី សន្ទឹកទ្វារក្តី កំពែងក្តី ភ្នំក្តី គុម្ពឈើក្តី វល្លិក្តី ជាគ្រឿងពាំងនូវការឃើញរូបនោះ មិនមានឡើយ ៗ

ឯកញ្ចេ តិលផលំ និមិត្តំ កត្វា តិលវាហេ បក្ខិ-
បេយ្យ តញ្ញេវ តិលផលំ ឧទ្ធរេយ្យ ។ ឯវំ បរិសុទ្ធំ
ភគវតោ បកតិមំសចក្ខុ ។ ឯវំ ភគវា មំសចក្ខុ-
នាបិ ចក្ខុមា ។

កថំ ភគវា ទិព្វេន ចក្ខុនាបិ ចក្ខុមា ។ ភគវា
ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន
។ បេ ។ យថាកម្មូបគេ សត្តេ បជានាតិ ។ អាក-
ង្ខមានោ ច ភគវា ឯកម្បិ លោកធាតុំ បស្សេយ្យ
ទ្វេបិ លោកធាតុយោ បស្សេយ្យ តិស្សោបិ លោក-
ធាតុយោ បស្សេយ្យ ចតស្សោបិ លោកធាតុ-
យោ បស្សេយ្យ បញ្ចបិ លោកធាតុយោ បស្សេ-
យ្យ ទសបិ លោកធាតុយោ បស្សេយ្យ វីសម្បិ
លោកធាតុយោ បស្សេយ្យ តឹសម្បិ លោក-
ធាតុយោ បស្សេយ្យ ចត្តាឡីសម្បិ លោកធាតុយោ
បស្សេយ្យ បញ្ញាសម្បិ លោកធាតុយោ បស្សេយ្យ
សតម្បិ លោកធាតុយោ បស្សេយ្យ សហស្សិម្បិ
ចូឡនិកំ លោកធាតុំ បស្សេយ្យ ទ្វិសហស្សិម្បិ

ប្រសិនបើបុគ្គលដាក់គ្រាប់ល្ងមួយគ្រាប់ ក្នុងរទេះ ដែលពេញដោយគ្រាប់ល្ង ធ្វើឲ្យជាគ្រឿងសំគាល់ ព្រះមានព្រះភាគ គប្បីរើសយកគ្រាប់ល្ងនោះ ដដែលវិញបាន ។ មំសចក្ខុធម្មតារបស់ព្រះមានព្រះភាគ បរិសុទ្ធយ៉ាងនេះ ។ ព្រះមានព្រះភាគ ទ្រង់មានចក្ខុដោយមំសចក្ខុ យ៉ាងនេះឯង ។

ព្រះមានព្រះភាគ ទ្រង់មានចក្ខុដោយទិព្វចក្ខុ តើដូចម្តេច ។ ព្រះមានព្រះភាគ ទ្រង់មានចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធកន្លងផុតចក្ខុរបស់មនុស្សធម្មតា ។ បេ ។ ទ្រង់ជ្រាបច្បាស់នូវសត្វទាំងឡាយ ដែលរង្គាត់ទៅតាមយថាកម្ម ។ បើព្រះមានព្រះភាគ ប្រាថ្នា (បង់ឃើញ) គប្បីទតឃើញលោកធាតុមួយក៏បាន ឃើញលោកធាតុ ២ ក៏បាន ឃើញលោកធាតុ ៣ ក៏បាន ឃើញលោកធាតុ ៤ ក៏បាន ឃើញលោកធាតុ ៥ ក៏បាន ឃើញលោកធាតុ ១០ ក៏បាន ឃើញលោកធាតុ ២០ ក៏បាន ឃើញលោកធាតុ ៣០ ក៏បាន ឃើញលោកធាតុ ៤០ ក៏បាន ឃើញលោកធាតុ ៥០ ក៏បាន ឃើញលោកធាតុ ១០០ ក៏បាន ឃើញលោកធាតុតូចចំនួន ១ ពាន់ ក៏បាន ឃើញលោកធាតុកណ្តាល ចំនួន ២ ពាន់ ក៏បាន

មជ្ឈិមិកំ លោកធាតុំ បស្សេយ្យ តិសហស្សិម្បិ លោកធាតុំ បស្សេយ្យ មហាសហស្សិម្បិ លោកធាតុំ បស្សេយ្យ ។ យាវតកំ វា បន អាកង្ខេយ្យ តាវតកំ បស្សេយ្យ ។ ឯវំ វិសុទ្ធំ ភគវតោ ទិព្វចក្ខុ ។ ឯវំ ភគវា ទិព្វចក្ខុនាបិ ចក្ខុមា ។

កថំ ភគវា បញ្ញាចក្ខុនាបិ ចក្ខុមា ។ ភគវា មហាបញ្ញោ បុថុបញ្ញោ ហាសបញ្ញោ ជវនបញ្ញោ តិក្ខបញ្ញោ និព្វេធិកបញ្ញោ បញ្ញាប្បភេទកុសលោ បភិន្នញាណោ អធិគតប្បដិសម្ភិទោ(១) ចតុវេសារជ្ជប្បត្តោ ទសពលធារី បុរិសាសភោ បុរិសសីហោ បុរិសនាគោ បុរិសាជញ្ញោ បុរិសធោរយ្ហោ អនន្តញាណោ អនន្តតេជោ អនន្តយសោ អឌ្ឍោ មហទ្ធនោ ធនវា នេតា វិនេតា អនុនេតា បញ្ញាបេតា និជ្ឈាបេតា បេក្ខតា បសាទេតា ។

១ ម. អធិគតប្បដិសម្ភិទប្បត្តោ ។

ឃើញលោកធាតុចំនួន៣ពាន់ ក៏បាន ឃើញលោកធាតុមានពាន់ដ៏ច្រើន ក៏បាន ។ មិនតែប៉ុណ្ណោះ ព្រះមានព្រះភាគ មានប្រាជ្ញា (នឹងឃើញ) ត្រឹមណា គប្បីឃើញបានត្រឹមណោះ ។ ទិព្វចក្ខុរបស់ព្រះមានព្រះភាគ បរិសុទ្ធយ៉ាងនេះ ។ ព្រះមានព្រះភាគទ្រង់មានចក្ខុ ដោយទិព្វចក្ខុ យ៉ាងនេះឯង ។

ព្រះមានព្រះភាគ ទ្រង់មានចក្ខុ ដោយបញ្ញាចក្ខុ តើដូចម្តេច ។ ព្រះមានព្រះភាគ ទ្រង់មានប្រាជ្ញាច្រើន មានប្រាជ្ញាក្រាស់ មានប្រាជ្ញារីករាយ មានប្រាជ្ញារហ័ស មានប្រាជ្ញាមោះមុត មានប្រាជ្ញាជាគ្រឿងទំលាយកិលេស ទ្រង់ឈ្លាសក្នុងប្រភេទនៃប្រាជ្ញា ទ្រង់បែកព្រះញាណ ទ្រង់បានបដិសម្ភិទា ទ្រង់សម្រេចចតុវេសារជ្ជញាណ ទ្រទ្រង់នូវកំឡាំង ១០ ជាបុរសប្រសើរ ជាបុរសអង់អាច ជាបុរសនាគ ជាបុរសអាជានេយ្យ ជាបុរសនាំទៅនូវធុរៈ ជាអនន្តញាណ មានតេជៈមិនមានទីបំផុត មានយសមិនមានទីបំផុត ទ្រង់ស្តុកស្តម្ភ មានទ្រព្យច្រើន មានធនធាន ទ្រង់ដឹកនាំ ទ្រង់ទូន្មាន ប្រៀនប្រដៅ ទ្រង់ពន្យល់ ទ្រង់ដឹកនាំឲ្យគិតគូរ ទ្រង់ឲ្យគេយល់ ទ្រង់ធ្វើឲ្យជ្រះថ្លា ។

សោ ហិ ភគវា អនុប្បន្នស្ស មគ្គស្ស ឧប្បាទេតា អសញ្ជាតស្ស មគ្គស្ស សញ្ជាបេតា(១) អនក្ខាតស្ស មគ្គស្ស អក្ខាតា មគ្គញ្ញូ មគ្គវិទូ មគ្គកោវិទោ ។ មគ្គានុគា ច បន ឯតរហិ សាវកា វិហរន្តិ បច្ឆាសមន្នាគតោ ។ សោ ហិ ភគវា ជានំ ជានាតិ បស្សំ បស្សតិ ចក្ខុភូតោ ញាណភូតោ ធម្មភូតោ ព្រហ្មភូតោ វត្តា បវត្តា អត្ថស្ស និន្នេតា អមតស្ស ទាតា ធម្មស្សាមិ តថាគតោ ។ នត្ថិ តស្ស ភគវតោ អញ្ញាតំ អទិដ្ឋំ អវិទិតំ អសច្ឆិកតំ អផុស្សិតំ បញ្ញាយ ។ អតីតានាគតប្បច្ចុប្បន្នំ ឧបាទាយ សព្វេ ធម្មា សព្វាការេន ពុទ្ធស្ស ភគវតោ ញាណមុខេ អាបាថំ អាគច្ឆន្តិ ។ យំ កិញ្ចិ នេយ្យំ នាម អត្ថិ ជានិតព្វំ អត្តត្ថោ វា បរត្ថោ វា ឧភយត្ថោ វា ទិដ្ឋធម្មិកោ វា អត្ថោ សម្បរាយិកោ វា អត្ថោ ឧត្តានោ វា អត្ថោ គម្ភីរោ វា អត្ថោ គូឡ្ហោ វា អត្ថោ បដិច្ឆន្នោ វា អត្ថោ នេយ្យោ វា អត្ថោ នីតោ វា

---

១ ម. សញ្ជនេតា ។

## មោឃរាជមាណវកប្បញ្ហានិទ្ទេស

ព្រះមានព្រះភាគអង្គនោះ ទ្រង់ញុំាងមគ្គដែលមិនទាន់កើតឲ្យកើតឡើង ទ្រង់ញុំាងមគ្គដែលមិនទាន់កើតបានឲ្យកើតមាន ទ្រង់ប្រាប់ផ្លូវដែលមិនទាន់ប្រាប់ ទ្រង់ស្គាល់ផ្លូវ ទ្រង់ជ្រាបផ្លូវ ទ្រង់ឈ្លាសវៃក្នុងផ្លូវ ។ ចំណែកពួកសាវ័ក ឥឡូវនេះ គ្រាន់តែជាអ្នកដើរតាមផ្លូវ ដើរតាមក្រោយ ។ ព្រះមានព្រះភាគអង្គនោះ ទ្រង់ជ្រាបហេតុដែលគួរជ្រាប ទ្រង់ឃើញហេតុដែលគួរឃើញ មានចក្ខុ មានញាណ មានធម៌ មានធម៌ដ៏ប្រសើរ ទ្រង់ជាអ្នកស្តីប្រដៅ ទ្រង់ពោលរំលឹកបង្អោនទៅរកប្រយោជន៍ ឲ្យនូវព្រះនិព្វាន ជាធម្មស្វាមិ ជាតថាគត ។ មិនមាន (វត្ថុអ្វីមួយ) ដែលព្រះមានព្រះភាគអង្គនោះ មិនបានដឹង មិនបានឃើញ មិនបានជ្រាប មិនបានធ្វើឲ្យជាក់ច្បាស់ មិនបានប៉ះពាល់ដោយប្រាជ្ញា ។ ធម៌ទាំងអស់ រាប់ទាំងអតីត អនាគតនិងបច្ចុប្បន្ន រមែងមកកាន់រង្វង់ក្នុងប្រធាននៃព្រះញាណរបស់ព្រះពុទ្ធមានព្រះភាគ ដោយអាការៈសព្វគ្រប់ ។ ឈ្មោះថាធម្មជាតដែលគប្បីដឹងណាមួយ ដែលជារបស់គួរដឹង គឺប្រយោជន៍ខ្លួនក្តី ប្រយោជន៍ជនដទៃក្តី ប្រយោជន៍ទាំងពីរក្តី ប្រយោជន៍ជាបច្ចុប្បន្នក្តី ប្រយោជន៍ក្នុងលោកខាងមុខក្តី ប្រយោជន៍រាក់ក្តី ប្រយោជន៍ជ្រៅក្តី ប្រយោជន៍លាក់លៀមក្តី ប្រយោជន៍កំបិតកំបាំងក្តី ប្រយោជន៍ដែលគួរដឹងក្តី ប្រយោជន៍ដែលបានដឹងហើយក្តី

អត្ថោ អនវជ្ជោ ច អត្ថោ និក្កិលេសោ ច អត្ថោ វោទានោ ច អត្ថោ បរមត្ថោ ច សព្វន្តំ អត្ថា ពុទ្ធញាណេ បរិវត្តន្តិ ។ សព្វំ កាយកម្មំ ពុទ្ធស្ស ភគវតោ ញាណានុបរិវត្តតិ សព្វំ វចីកម្មំ ញាណានុបរិវត្តតិ សព្វំ មនោកម្មំ ញាណានុបរិវត្តតិ ។ អតីតេ ពុទ្ធស្ស ភគវតោ អប្បដិហតំ ញាណំ អនាគតេ ពុទ្ធស្ស ភគវតោ អប្បដិហតំ ញាណំ បច្ចុប្បន្នេ ពុទ្ធស្ស ភគវតោ អប្បដិហតំ ញាណំ ។ យាវតកំ នេយ្យំ តាវតកំ ញាណំ យាវតកំ ញាណំ តាវតកំ នេយ្យំ នេយ្យបរិយន្តិកំ ញាណំ ញាណបរិយន្តិកំ នេយ្យំ នេយ្យំ អតិក្កមិត្វា ញាណំ នប្បវត្តតិ ញាណំ អតិក្កមិត្វា នេយ្យបថោ នត្ថិ អញ្ញមញ្ញំ បរិយន្តដ្ឋាយិនោ តេ ធម្មា ។ យថា ទ្វិន្នំ សមុគ្គបដលានំ សុសិតានំ ហេដ្ឋិមំ

ប្រយោជន៍មិនមានទោសក្តី ប្រយោជន៍មិនមានកិលេសក្តី ប្រយោជន៍ផូរផង់ក្តី ប្រយោជន៍ដ៏ល្អិតក្តី ធម្មជាតទាំងអស់នោះ រមែងវិលនៅក្នុងខាងក្នុងពុទ្ធញាណ ។ កាយកម្មទាំងអស់ រមែងប្រព្រឹត្តទៅតាមព្រះញាណរបស់ព្រះពុទ្ធមានព្រះភាគ វចីកម្មទាំងអស់ រមែងប្រព្រឹត្តទៅតាមព្រះញាណ មនោកម្មទាំងអស់ រមែងប្រព្រឹត្តទៅតាមព្រះញាណ (របស់ព្រះពុទ្ធមានព្រះភាគ) ។ ញាណរបស់ព្រះពុទ្ធមានព្រះភាគ មិនមានទើសទាល់ក្នុងអតីត ញាណរបស់ព្រះពុទ្ធមានព្រះភាគ មិនមានទើសទាល់ក្នុងអនាគត ញាណរបស់ព្រះពុទ្ធមានព្រះភាគ មិនមានទើសទាល់ក្នុងបច្ចុប្បន្ន ។ ធម្មជាតដែលគប្បីដឹង មានកំណត់ត្រឹមណា ព្រះញាណ ក៏មានកំណត់ត្រឹមនោះ ព្រះញាណមានកំណត់ត្រឹមណា ធម្មជាតដែលគប្បីដឹង ក៏មានកំណត់ត្រឹមនោះ ព្រះញាណមានធម្មជាតដែលគប្បីដឹង ជាកំណត់ ធម្មជាតដែលគប្បីដឹង ក៏មានព្រះញាណជាកំណត់ ព្រះញាណប្រព្រឹត្តកន្លង នូវធម្មជាតដែលគប្បីដឹង មិនបានគន្លងនៃធម្មជាតដែលគប្បីដឹង ក៏ប្រព្រឹត្តកន្លងនូវព្រះញាណមិនបាន ធម៌ទាំងនោះ តាំងនៅក្នុងទីបំផុតនៃគ្នានឹងគ្នា ។ ដូចបាតស្ក្រគពីរ ដែលគេគ្របហើយយ៉ាងជិតស្និទ្ធ គឺបាតស្ក្រគខាងក្រោម

## មោឃរាជមាណវកបញ្ហានិទ្ទេសោ

សមុទ្ទបដលំ ឧបរិមំ នាតិវត្តតិ ឧបរិមំ សមុទ្ទបដលំ ហេដ្ឋិមំ នាតិវត្តតិ អញ្ញមញ្ញំ បរិយន្តដ្ឋាយិនោ ឯវមេវ ពុទ្ធស្ស ភគវតោ ញេយ្យញ្ច ញាណញ្ច អញ្ញមញ្ញំ បរិយន្តដ្ឋាយិនោ យាវតកំ ញេយ្យំ តាវតកំ ញាណំ យាវតកំ ញាណំ តាវតកំ ញេយ្យំ ញេយ្យបរិយន្តិកំ ញាណំ ញាណបរិយន្តិកំ ញេយ្យំ ញេយ្យំ អតិក្កមិត្វា ញាណំ នប្បវត្តតិ ញាណំ អតិក្កមិត្វា ញេយ្យបថោ នត្ថិ អញ្ញមញ្ញំ បរិយន្តដ្ឋាយិនោ តេ ធម្មា ។ សព្វធម្មេសុ ពុទ្ធស្ស ភគវតោ ញាណំ បវត្តតិ ។ សព្វេ ធម្មា ពុទ្ធស្ស ភគវតោ អាវជ្ជនប្បដិពទ្ធា អាកង្ខប្បដិពទ្ធា មនសិការប្បដិពទ្ធា ចិត្តុប្បាទប្បដិពទ្ធា ។ សព្វសត្តេសុ ពុទ្ធស្ស ភគវតោ ញាណំ បវត្តតិ ។

មិនប្រព្រឹត្តកន្លងបាតស្មុគ្រខាងលើ បាតស្មុគ្រខាងលើ ក៏មិនប្រព្រឹត្ត កន្លងបាតស្មុគ្រខាងក្រោម ( បាតស្មុគ្រទាំងនោះ ) តាំងនៅក្នុង ទីបំផុត នៃគ្នានឹងគ្នា យ៉ាងណាមិញ ធម្មជាតដែលគប្បីដឹងក្តី ព្រះ ញាណក្តី របស់ព្រះពុទ្ធមានព្រះភាគ ក៏តាំងនៅក្នុងទីបំផុតនៃគ្នានឹងគ្នា យ៉ាងនោះដែរ គឺធម្មជាតដែលគប្បីដឹងមានកំណត់ត្រឹមណា ព្រះញាណ ក៏មានកំណត់ត្រឹមនោះ ព្រះញាណមានកំណត់ត្រឹមណា ធម្មជាតដែល គប្បីដឹងក៏មានកំណត់ត្រឹមនោះ ព្រះញាណមានធម្មជាតដែលគប្បីដឹងជា កំណត់ ធម្មជាតដែលគប្បីដឹងក៏មានព្រះញាណជាកំណត់ ព្រះញាណ ប្រព្រឹត្តកន្លងធម្មជាតដែលគប្បីដឹងមិនបាន គន្លងនៃធម្មជាតដែលគប្បី ដឹង ក៏ប្រព្រឹត្តកន្លងព្រះញាណមិនបាន ធម៌ទាំងនោះ តាំងនៅ ក្នុងទីបំផុត នៃគ្នានឹងគ្នា ។ ព្រះញាណរបស់ព្រះពុទ្ធមានព្រះភាគ រមែងប្រព្រឹត្តទៅក្នុងធម៌ទាំងពួង ។ ធម៌ទាំងពួង រមែងជាប់ចំពាក់ ដោយការពេររក ជាប់ចំពាក់ដោយការប្រាថ្នា ជាប់ចំពាក់ដោយការ នឹក ជាប់ចំពាក់ដោយការតាំងចិត្ត របស់ព្រះពុទ្ធមានព្រះភាគ ។ ព្រះ ញាណរបស់ព្រះពុទ្ធមានព្រះភាគ រមែងប្រព្រឹត្តទៅក្នុងសត្វទាំងពួង ។

សព្វេសំ សត្តានំ ភគវា អាសយំ ជានាតិ អនុសយំ ជានាតិ ចរិតំ ជានាតិ អធិមុត្តឹ ជានាតិ អប្បរជក្ខេ មហារជក្ខេ តិក្ខិន្ទ្រិយេ មុទិន្ទ្រិយេ ស្វាការេ ទ្វាការេ សុវិញ្ញាបយេ ទុវិញ្ញាបយេ ភព្វាភព្វេ សត្តេ បជានាតិ ។ សទេវកោ លោកោ សមារកោ សព្រហ្មកោ សស្សមណព្រាហ្មណី បជា សទេវមនុស្សា អន្តោពុទ្ធញាណេ បរិវត្តតិ ។ យថា យេ កេចិ មច្ឆកច្ឆបា អន្តមសោ តិមិតិមិង្គលំ ឧបាទាយ អន្តោមហាសមុទ្ទេ បរិវត្តន្តិ ឯវមេវ សទេវកោ លោកោ សមារកោ សព្រហ្មកោ សស្សមណព្រាហ្មណី បជា សទេវមនុស្សា អន្តោពុទ្ធញាណេ បរិវត្តតិ ។ យថា យេ កេចិ បក្ខី អន្តមសោ គរុឡំ វេនតេយ្យំ ឧបាទាយ អាកាសស្ស បទេសេ បរិវត្តន្តិ ឯវមេវ សារីបុត្តសមា បញ្ញាយ(១) តេបិ យេបិ តេ ពុទ្ធញាណស្ស បទេសេ បរិវត្តន្តិ ។

១ ម. ឯត្តន្តរេ សមន្នាគតាតិ ទិស្សតិ ។

ព្រះមានព្រះភាគ តែងជ្រាបអាសយធម៌ ជ្រាបអនុស័យធម៌ ជ្រាបចរិត ជ្រាបអធិមុត្តិនៃពួកសត្វទាំងពួង តែងជ្រាបពួកសត្វ ដែលមានធូលីតិចក្នុងភ្នែកមានធូលីច្រើនក្នុងភ្នែក មានឥន្ទ្រិយរឹង មានឥន្ទ្រិយទន់ មានអាការៈល្អ មានអាការៈអាក្រក់ ជាសត្វឲ្យត្រាស់ដឹងងាយ ឲ្យត្រាស់ដឹងក្រ ជាសត្វមានភ័ព្វនឹងឥតភ័ព្វ ។ លោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ពួកសត្វព្រមទាំងសមណៈនឹងព្រាហ្មណ៍ ទាំងមនុស្ស ជាសម្មតិទេពនឹងមនុស្សសាមញ្ញ ក៏រមែងវិលនៅតែខាងក្នុងពុទ្ធ-ញាណ ។ ដូចហ្វូងត្រីនឹងអណ្ដើកណាមួយ ដោយហោចទៅ ទោះបីត្រីឈ្មោះតិមិ នឹងត្រីឈ្មោះតិមិង្គលៈ រមែងវិលនៅតែខាងក្នុងមហាសមុទ្រយ៉ាងណា លោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ពួកសត្វព្រមទាំងសមណៈនឹងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនឹងមនុស្សសាមញ្ញ ក៏រមែងវិលនៅតែខាងក្នុងពុទ្ធញាណ យ៉ាងនោះឯង ។ ដូចពួកបក្សីណាមួយ ដោយហោចទៅ សូម្បីគ្រុឌឈ្មោះវេនតេយ្យៈ តែងវិលនៅ តែក្នុងប្រទេសនៃអាកាស យ៉ាងណាមិញ ពួកជនណាដែលមានប្រាជ្ញា ស្មើដោយប្រាជ្ញារបស់ព្រះសារីបុត្ត សូម្បីពួកជនទាំងនោះ ក៏រមែងវិលនៅតែខាងក្នុងប្រទេសនៃពុទ្ធញាណ យ៉ាងនោះឯង

## មោឃរាជមាណវកប្បញ្ហានិទ្ទេសោ

ពុទ្ធញាណំ ទេវមនុស្សានំ ញាណំ ផរិត្វា អតិក្កមិត្វា តិដ្ឋតិ ។ យេបិ តេ ខត្តិយបណ្ឌិតា ព្រាហ្មណបណ្ឌិតា គហបតិបណ្ឌិតា សមណបណ្ឌិតា និបុណា កតបរប្បវាទា វាលវេធិរូបា តេ ភិន្ទន្តា មញ្ញេ ចរន្តិ បញ្ញាគតេន ទិដ្ឋិគតានិ ។ តេ បញ្ហំ អភិសង្ខរិត្វា អភិសង្ខរិត្វា តថាគតំ ឧបសង្កមិត្វា បុច្ឆន្តិ(២) ។ កថិតា វិសជ្ជិតា ច តេ បញ្ហា ភគវតា ហោន្តិ និទ្ទិដ្ឋការណា ឧបក្ខិត្តកា ច ។ តេ ភគវតោ សម្បជ្ជន្តិ ។ អថខោ ភគវា តត្ថ អតិរោចតិ យទិទំ បញ្ញាយាតិ ឯវំ ភគវា បញ្ញាចក្ខុនាបិ ចក្ខុមា ។

កថំ ភគវា ពុទ្ធចក្ខុនាបិ ចក្ខុមា ។ ភគវា ពុទ្ធចក្ខុនា លោកំ វោលោកេន្តោ អទ្ទស សត្តេ អប្បរជក្ខេ មហារជក្ខេ តិក្ខិន្ទ្រិយេ មុទិន្ទ្រិយេ ស្វាការេ ទ្វាការេ សុវិញ្ញាបយេ

---

១ ម. ឯត្ថន្តរេ គុឡ្ហានិ ច បដិច្ឆន្នានីតិ ទិស្សតិ ។

ពុទ្ធញាណ រមែងផ្សាយគ្របប្រាជ្ញានៃពួកទេវតានិងមនុស្ស ហើយប្រតិស្ថាននៅ ។ ពួកជនណាមួយ ទោះបីជាខត្តិយបណ្ឌិតក្តី ព្រាហ្មណបណ្ឌិតក្តី គហបតិបណ្ឌិតក្តី សមណបណ្ឌិតក្តី ដែលមានប្រាជ្ញាល្អិត ស្គាល់ថ្វីមាត់របស់ជនដទៃ ស្រដៀងនឹងខ្មាន់ធ្នូ អ្នកបាញ់រោមទ្រាយ ពួកជនទាំងនោះ មានអាការៈដូចជាទំលាយបង់នូវទិដ្ឋិ ដោយប្រាជ្ញា ( ខ្លួន ) ហើយប្រព្រឹត្តទៅ ។ ពួកជនទាំងនោះប្រឹងតាក់តែងនូវប្រស្នា លុះតាក់តែងហើយក៏ចូលទៅសួរព្រះតថាគត ។ ប្រស្នាទាំងនោះ លុះព្រះមានព្រះភាគ បានសំដែងបានដោះស្រាយហើយ ក៏បែរទៅជាប្រស្នាមានហេតុ គួរសំដែងចេញនឹងពង្រីកចេញបាន ។ ពួកជនទាំងនោះក៏នាំគ្នាចុះចូលព្រះមានព្រះភាគ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់រុងរឿងកន្លងដោយប្រាជ្ញាក្នុងទីប្រជុំនោះ ហេតុនោះ ព្រះមានព្រះភាគ ទ្រង់មានចក្ខុដោយបញ្ញាចក្ខុ យ៉ាងនេះ ។

ព្រះមានព្រះភាគ ទ្រង់មានចក្ខុដោយពុទ្ធចក្ខុ តើដូចម្តេច ។ ព្រះមានព្រះភាគ ទ្រង់ប្រមើលមើលលោកដោយពុទ្ធចក្ខុ បានទតឃើញពួកសត្វដែលមានធូលីតិចក្នុងភ្នែក មានធូលីច្រើនក្នុងភ្នែក មានឥន្ទ្រិយរឹង មានឥន្ទ្រិយទន់ មានអាការៈល្អ មានអាការៈអាក្រក់ ឲ្យគ្រាស់ដឹងងាយ

ទុវិញ្ញាបយេ អប្បេកច្ចេ បរលោកវជ្ជភយទស្សាវិនោ វិហរន្តេ ។ សេយ្យថាបិ នាម ឧប្បលិនិយំ វា បទុមិនិយំ វា បុណ្ឌរីកិនិយំ វា អប្បេកច្ចានិ ឧប្បលានិ វា បទុមានិ វា បុណ្ឌរីកានិ វា ឧទកេ ជាតានិ ឧទកេ សវឌ្ឍានិ ឧទកានុគ្គតានិ អន្តោនិមុគ្គបោសិតានិ អប្បេកច្ចានិ ឧប្បលានិ វា បទុមានិ វា បុណ្ឌរីកានិ វា ឧទកេ ជាតានិ ឧទកេ សំវឌ្ឍានិ សមោទកណ្ឋិតានិ អប្បេកច្ចានិ ឧប្បលានិ វា បទុមានិ វា បណ្ឌរីកានិ វា ឧទកេ ជាតានិ ឧទកេ សំវឌ្ឍានិ ឧទកា អច្ចុគ្គម្ម តិដ្ឋន្តិ អនុបលិត្តានិ ឧទកេន ឯវមេវ ភគវា ពុទ្ធចក្ខុនា លោកំ វោលោកេន្តោ អទ្ទស សត្តេ អប្បរជក្ខេ មហារជក្ខេ តិក្ខិន្ទ្រិយេ មុទិន្ទ្រិយេ ស្វាការេ ទ្វាការេ សុវិញ្ញាបយេ ទុវិញ្ញាបយេ អប្បេកច្ចេ បរលោកវជ្ជភយទស្សាវិនោ វិហរន្តេ ។

ឲ្យត្រាសដឹងក្រ សត្វដំពូកខ្លះ ឃើញភ័យ ក្នុងទោសខាងបរលោក ។ ដូចក្នុងគុម្ពព្រលិតក្តី គុម្ពឈូកក្រហមក្តី គុម្ពឈូកសក្តី ផ្កាព្រលិត ឬផ្កាឈូកក្រហម ឬក៏ផ្កាឈូកស ដំពូកខ្លះ កើតក្នុងទឹក ចំរើនក្នុងទឹក លូតលាស់ក្នុងទឹក ដុះកប់ខាងក្នុងនៅឡើយ ផ្កាព្រលិតឬផ្កាឈូកក្រហម ឬក៏ផ្កាឈូកស ដំពូកខ្លះ កើតក្នុងទឹក ចម្រើនក្នុងទឹក ឋិតនៅស្មើនឹងទឹកហើយ ផ្កាព្រលិត ឬផ្កាឈូកក្រហម ឬក៏ផ្កាឈូកស ដំពូកខ្លះ កើតក្នុងទឹក ចម្រើនក្នុងទឹក ឋិតនៅផុតអំពីទឹក មិនទទឹកដោយទឹកឡើយ យ៉ាងណាមិញ ព្រះមានព្រះភាគទ្រង់ប្រមើលមើលលោកដោយពុទ្ធចក្ខុ បានឃើញពួកសត្វ ដែលមានធូលីតិចក្នុងភ្នែក មានធូលីច្រើនក្នុងភ្នែក មានឥន្ទ្រិយរឹង មានឥន្ទ្រិយទន់ មានអាការៈល្អ មានអាការៈមិនល្អ ឲ្យត្រាស់ដឹងងាយ ឲ្យត្រាស់ដឹងក្រ សត្វដំពូកខ្លះ ឃើញភ័យ ក្នុងទោសខាងបរលោក ក៏យ៉ាងនោះឯង ។

## មោឃរាជមាណវកប្បញ្ហានិទ្ទេសោ

ជានាតិ ភគវា អយំ បុគ្គលោ រាគចរិតោ អយំ ទោសចរិតោ អយំ មោហចរិតោ អយំ វិតក្កចរិតោ អយំ សទ្ធាចរិតោ អយំ ញាណចរិតោតិ ។ រាគចរិតស្ស ភគវា បុគ្គលស្ស អសុភកថំ កថេតិ ។ ទោសចរិតស្ស ភគវា បុគ្គលស្ស មេត្តាភាវនំ អាចិក្ខតិ ។ មោហចរិតំ ភគវា បុគ្គលំ ឧទ្ទេសបរិបុច្ឆាយ កាលេន ធម្មស្សវនេ កាលេន ធម្មសាកច្ឆាយ គរុសំវាសេ និវេសេតិ ។ វិតក្កចរិតស្ស ភគវា បុគ្គលស្ស អានាបានស្សតឹ អាចិក្ខតិ ។ សទ្ធាចរិតស្ស ភគវា បុគ្គលស្ស បសាទនីយំ និមិត្តំ អាចិក្ខតិ ពុទ្ធសុពោធឹ(១) ធម្មសុធម្មតំ សង្ឃសុបដិបត្តឹ សីលានិ ច អត្តនោ ។ ញាណចរិតស្ស ភគវា បុគ្គលស្ស វិបស្សនានិមិត្តំ អាចិក្ខតិ អនិច្ចាការំ ទុក្ខាការំ អនត្តាការំ ។

---

១ ម. ពុទ្ធសុពុទ្ធតំ ។

## ហេឃរាដមាណវកប្បញ្ញាតិទ្ទេស

ព្រះមានព្រះភាគ ទ្រង់ជ្រាបថា បុគ្គលនេះជារាគចរិត នេះជាទោសចរិត នេះជាមោហចរិត នេះជាវិតក្កចរិត នេះជាសទ្ធាចរិត នេះជាញាណចរិត ។ ព្រះមានព្រះភាគ ទ្រង់សំដែងអសុភកថា ចំពោះបុគ្គលជារាគចរិត ។ ព្រះមានព្រះភាគ ទ្រង់ប្រាប់មេត្តាភាវនា ចំពោះបុគ្គលជាទោសចរិត ។ ព្រះមានព្រះភាគ ទ្រង់ញុំាងបុគ្គលជាមោហចរិត ឲ្យតាំងនៅក្នុងធម្មស្សវនៈតាមកាល ក្នុងធម្មសាកច្ឆាតាមកាល និងការនៅរួមជាមួយគ្រូដើម្បីរៀននិងការសាកសួរ ។ ព្រះមានព្រះភាគ ទ្រង់ប្រាប់អានាបានស្សតិ ចំពោះបុគ្គលជាវិតក្កចរិត ។ ព្រះមានព្រះភាគ ទ្រង់ប្រាប់និមិត្តដែលគួរជ្រះថ្លា គឺការត្រាស់ដឹងប្រពៃនៃព្រះពុទ្ធ សភាពនៃធម៌ជាធម៌ល្អ ការប្រតិបត្តិប្រពៃនៃព្រះសង្ឃ និងសីលរបស់ខ្លួន ចំពោះបុគ្គលជាសទ្ធាចរិត ។ ព្រះមានព្រះភាគទ្រង់ប្រាប់វិបស្សនានិមិត្ត គឺអាការៈមិនទៀង អាការៈជាទុក្ខនិងអាការៈជាអនត្តា ចំពោះបុគ្គលជាញាណចរិត ។

សេលេ យថា បព្វតមុទ្ធនិដ្ឋិតោ
យថាបិ បស្សេ ជនតំ សមន្តតោ
តថូបមំ ធម្មមយំ សុមេធ
បាសាទមារុយ្ហ សមន្តចក្ខុ
សោកាវតិណ្ណំ ជនតមបេតសោកោ
អវេក្ខស្សុ ជាតិជរាភិភូតន្តិ ។

ឯវំ ភគវា ពុទ្ធចក្ខុនាបិ ចក្ខុមា ។

កថំ ភគវា សមន្តចក្ខុនាបិ ចក្ខុមា ។ សមន្តចក្ខុ វុច្ចតិ សព្វញ្ញុតញ្ញាណំ ។ ភគវា សព្វញ្ញុតញ្ញាណេន ឧបេតោ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ ។

ន តស្ស អទិដ្ឋមិធត្ថិ កិញ្ចិ
អថោ អវិញ្ញាតមជានិតព្វំ
សព្វំ អភិញ្ញាសិ យទត្ថិ នេយ្យំ
តថាគតោ តេន សមន្តចក្ខូតិ ។

បពិត្រព្រះសុមេធៈ ព្រះអង្គប្រកបដោយសមន្តចក្ខុ ទ្រង់មិន
មានសោក សូមព្រះអង្គឡើងកាន់ប្រាសាទ ជាវិការៈនៃធម៌
ហើយ ក្រឡេកមើលពួកជន ដែលដេរដាសដោយសោក
ត្រូវជាតិជរាគ្របសង្កត់ ដូចជាបុរសឈរនៅលើកំពូលភ្នំ ជា
វិការៈនៃថ្ម ហើយក្រឡេកមើលពួកជន ដែលឋិតនៅក្នុងទី
ជុំវិញ ដូច្នោះចុះ ។

ព្រះមានព្រះភាគ ទ្រង់មានចក្ខុដោយពុទ្ធចក្ខុ យ៉ាងនេះ ។

ព្រះមានព្រះភាគ ទ្រង់មានចក្ខុ ដោយសមន្តចក្ខុ តើដូចម្តេច ។ សព្វញ្ញុតញ្ញាណ លោកហៅថា សមន្តចក្ខុ ។ ព្រះមានព្រះភាគ ទ្រង់ដល់ ដល់ព្រម មកដល់ មកដល់ព្រម ចូលទៅជិត ចូលទៅជិតព្រម ប្រកបហើយដោយសព្វញ្ញុតញ្ញាណ ។

អ្វីមួយក្នុងលោកនេះ ដែលព្រះតថាគតនោះ មិនឃើញ
ឬមិនជ្រាបហើយ មិនគប្បីជ្រាប មិនមានទេ របស់ណា
ដែលគួរដឹង ព្រះតថាគត ជ្រាបច្បាស់នូវរបស់នោះទាំង
អស់ ហេតុនោះ ទើបឈ្មោះថាសមន្តចក្ខុ ។

## មោឃរាជមាណវកប្បញ្ហានិទ្ទេសោ

ឯវំ ភគវា សមន្តចក្ខុនាបិ ចក្ខុមាតិ ន មេ ព្យាកាសិ ចក្ខុមា ។

(៦១) យាវតតិយញ្ច ទេវិសិ ព្យាករោតីតិ មេ សុតន្តិ យាវតតិយំ ពុទ្ធោ សហធម្មិកំ បញ្ហំ បុដ្ឋោ ព្យាករោតិ នោ សម្ព្យាយតីតិ ឯវំ មយា ឧគ្គហិតំ ឯវំ មយា ឧបធារិតំ ឯវំ មយា ឧបលក្ខិតំ ។ ទេវិសីតិ ភគវា ទេវោ ចេវ ឥសិ ចាតិ ទេវិសិ ។ យថា រាជបព្វជិតា វុច្ចន្តិ រាជិសយោ ព្រាហ្មណបព្វជិតា វុច្ចន្តិ ព្រាហ្មណិសយោ ឯវមេវ ភគវា ទេវោ ចេវ ឥសិ ចាតិ ទេវិសិ ។ អថវា ភគវា បព្វជិតោតិបិ ឥសិ ។ មហន្តំ សីលក្ខន្ធំ ឯសិ គវេសិ បរិយេសីតិបិ ឥសិ ។ មហន្តំ សមាធិក្ខន្ធំ មហន្តំ បញ្ញាក្ខន្ធំ មហន្តំ វិមុត្តិក្ខន្ធំ មហន្តំ វិមុត្តិញាណទស្សនក្ខន្ធំ ឯសិ គវេសិ បរិយេសីតិបិ ឥសិ ។

ព្រះមានព្រះភាគ ទ្រង់មានចក្ខុដោយសមន្តចក្ខុ យ៉ាងនេះ ហេតុនោះ (លោកពោលថា) ព្រះអង្គមានចក្ខុ ទ្រង់មិនទាន់ដោះស្រាយដល់ខ្ញុំព្រះអង្គនៅឡើយ ។

(៦១) ពាក្យថា ខ្ញុំព្រះអង្គបានឮថា ព្រះអង្គជាទេវឫសី (កាលបើមានគេសាកសួរ) អស់វារៈបីដង ទ្រង់តែងព្យាករពុំខាន អធិប្បាយថា ខ្ញុំព្រះអង្គបានរៀនមកយ៉ាងនេះ ខ្ញុំព្រះអង្គបានចាំទុកមកយ៉ាងនេះ ខ្ញុំព្រះអង្គបានកំណត់ទុកមកយ៉ាងនេះថា ព្រះពុទ្ធដែលគេសួរប្រស្នាប្រកបដោយធម៌ ត្រឹមវារៈជាគំរប់ ៣ តែងទ្រង់ព្យាករ មិនទើសទាល់ ។ ពាក្យថា ព្រះអង្គជាទេវឫសី គឺព្រះមានព្រះភាគ ឈ្មោះថាទេវឫសី ព្រោះហេតុទ្រង់ជាវិសុទ្ធិទេពផង ជាឫសីផង ។ ដូចពួករាជបព្វជិត គេហៅថា រាជឫសី ពួកព្រាហ្មណបព្វជិត គេហៅថា ព្រហ្មឫសី យ៉ាងណាមិញ ព្រះមានព្រះភាគ ឈ្មោះថាទេវឫសី ព្រោះហេតុទ្រង់ជាវិសុទ្ធិទេពផង ជាឫសីផង ក៏យ៉ាងនោះដែរ ។ មួយទៀត ព្រះមានព្រះភាគ ឈ្មោះថាឫសី ព្រោះហេតុទ្រង់ជាបព្វជិត ដូច្នេះក៏បាន ។ ព្រះមានព្រះភាគ ឈ្មោះថាឫសី ព្រោះទ្រង់រក ស្វែងរក ស្វះស្វែង នូវសីលក្ខន្ធដ៏ធំ ដូច្នេះក៏បាន ។ ព្រះមានព្រះភាគ ឈ្មោះថាឫសី ព្រោះទ្រង់រក ស្វែងរក ស្វះស្វែង នូវសមាធិក្ខន្ធដ៏ធំ បញ្ញាខន្ធដ៏ធំ វិមុត្តិក្ខន្ធដ៏ធំ វិមុត្តិញាណទស្សនក្ខន្ធដ៏ធំ ដូច្នេះក៏បាន ។

មហតោ តមោកាយស្ស បទាលនំ មហតោ វិបល្លាសស្ស បភេទនំ មហតោ តណ្ហាសល្លស្ស អព្ពុឡ្ហនំ មហតោ ទិដ្ឋិសង្ឃាតស្ស វិនិវេឋនំ មហតោ មានធ្វជស្ស បាតនំ មហតោ អភិសង្ខារស្ស វូបសមំ មហតោ ឱឃស្ស និត្ថរណំ មហតោ ភារស្ស និក្ខេបនំ មហតោ សំសារវដ្ដស្ស ឧបច្ឆេទំ មហតោ សន្តាបស្ស និព្វាបនំ មហតោ បរិឡាហស្ស បដិប្បស្សទ្ធិំ មហតោ ធម្មទ្ធជស្ស ឧស្សាបនំ ឯសតិ គវេសតិ បរិយេសតីតិបិ ឥសិ ។ មហន្តេ សតិបដ្ឋានេ មហន្តេ សម្មប្បធានេ មហន្តេ ឥទ្ធិបាទេ មហន្តានិ ឥន្ទ្រិយានិ មហន្តានិ ពលានិ មហន្តេ ពោជ្ឈង្គេ មហន្តំ អរិយំ អដ្ឋង្គិកំ មគ្គំ មហន្តំ និព្វានំ ឯសតិ គវេសតិ បរិយេសតីតិបិ ឥសិ ។ មហេសក្ខេហិ វា សត្តេហិ ឯសិតោ គវេសិតោ បរិយេសិតោ កហំ ពុទ្ធោ កហំ ភគវា កហំ ទេវទេវោ កហំ នរាសភោតិបិ ឥសីតិ ។ យាវតតិយញ្ច ទេវិសិ ព្យាករោតីតិ មេ សុតំ ។

ព្រះមានព្រះភាគ ឈ្មោះថាឫសី ព្រោះទ្រង់រក ស្វែងរក ស្វះស្វែងនូវការទំលាយបង់ នូវគំនរងងឹតដ៏ធំ ការទំលាយបង់នូវវិបល្លាសៈដ៏ធំ ការដកឡើងនូវសរ គឺតណ្ហាដ៏ធំ ការរុះរើចេញ នូវខ្សែ គឺទិដ្ឋិដ៏ធំ ការទំលាក់ចុះនូវទង់ជ័យ គឺមានះដ៏ធំ ការរម្ងាប់នូវអភិសង្ខារដ៏ធំ ការរើចេញចាកឱឃៈដ៏ធំ ការដាក់ចុះនូវភារៈដ៏ធំ ការផ្តាច់បង់ នូវសំសារវដ្តដ៏ធំ ការរំលត់នូវកំដៅដ៏ធំ ការរម្ងាប់បង់នូវការក្តៅក្រហាយដ៏ធំ នឹងការលើកឡើងនូវទង់ជ័យ គឺធម៌ដ៏ធំ ដូច្នេះក៏បាន ។ ព្រះមានព្រះភាគ ទ្រង់រក ឈ្មោះថាឫសី ព្រោះទ្រង់ស្វែងរក ស្វះស្វែងនូវសតិប្បដ្ឋានដ៏ធំ សម្មប្បធានដ៏ធំ ឥទ្ធិបាទដ៏ធំ ឥន្ទ្រិយដ៏ធំ ពលៈដ៏ធំ ពោជ្ឈង្គដ៏ធំ អរិយមគ្គប្រកបដោយអង្គ ៨ ដ៏ធំ នឹងព្រះនិព្វានដ៏ធំ ដូច្នេះក៏បាន ។ ឈ្មោះថាឫសី ព្រោះ (ព្រះមានព្រះភាគ) ត្រូវពួកសត្វមានស័ក្តិធំ គួររក ស្វែងរក ស្វះស្វែងថា ព្រះពុទ្ធ (គង់នៅ) ក្នុងទីណា ព្រះមានព្រះភាគ (គង់នៅ) ក្នុងទីណា ព្រះវិសុទ្ធិទេព (គង់នៅ) ក្នុងទីណា ព្រះនរាសភៈ (គង់នៅ) ក្នុងទីណា ហេតុនោះ (លោកពោលថា) ខ្ញុំព្រះអង្គបានឮថា ព្រះអង្គជាទេវឫសី (កាលបើមានគេសាកសួរ) អស់ពរៈបីដង ទ្រង់តែងព្យាករពុំខាន ៗ

មោឃរាជមាណវកប្បញ្ហានិទ្ទេសោ

តេនាហ សោ ព្រាហ្មណោ

ទ្វាហំ សក្ក អបុច្ឆិស្សំ (ឥច្ចាយស្មា
មោឃរាជា)
ន មេ ព្យាកាសិ ចក្ខុមា
យាវតតិយញ្ច ទេវិសិ
ព្យាករោតីតិ មេ សុតន្តិ ។

(៦២) អយំ លោកោ បរោ លោកោ
ព្រហ្មលោកោ សទេវកោ
ទិដ្ឋិន្តេ នាភិជានាតិ
គោតមស្ស យសស្សិនោ ។

(៦៣) អយំ លោកោ បរោ លោកោតិ អយំ លោកោតិ មនុស្សលោកោ ។ បរោ លោកោតិ មនុស្សលោកំ ឋបេត្វា សព្វោ បរោ លោកោតិ អយំ លោកោ បរោ លោកោ ។

(៦៤) ព្រហ្មលោកោ សទេវកោតិ ព្រហ្មលោកោ សទេវកោ សមារកោ សស្សមណព្រាហ្មណី បជា សទេវមនុស្សាតិ ព្រហ្មលោកោ សទេវកោ ។

ហេតុនោះ ព្រាហ្មណ៍នោះ ពោលថា

(មោឃរាជមានអាយុ ក្រាបទូលដូច្នេះថា) បពិត្រព្រះអង្គជាសក្កៈ ខ្ញុំព្រះអង្គ បានទូលសួរ (ព្រះអង្គ) អស់វារៈពីរដងរួចហើយ ព្រះអង្គមានចក្ខុ ទ្រង់មិនទាន់ដោះស្រាយដល់ខ្ញុំព្រះអង្គនៅឡើយ ខ្ញុំព្រះអង្គបានឮថា ព្រះអង្គជាទេវឫសី (កាលបើមានគេសាកសួរ) អស់វារៈបីដង ទ្រង់តែងព្យាករពុំខាន ។

(៦២) លោកនេះ លោកដទៃ ព្រហ្មលោក ព្រមទាំងទេវលោក រមែងមិនទាន់ដឹងច្បាស់ នូវសេចក្ដីយល់ឃើញរបស់ព្រះអង្គ ជាព្រះគោតម ដ៏ទ្រង់យសទេ ។

(៦៣) ពាក្យថា លោកនេះ របស់បទថា លោកនេះ លោកដទៃ បានដល់មនុស្សលោក ។ ពាក្យថា លោកដទៃ គឺលោកដទៃទាំងអស់ លើកលែងតែមនុស្សលោកចេញ ហេតុនោះ (លោកពោលថា) លោកនេះ លោកដទៃ ។

(៦៤) ពាក្យថា ព្រហ្មលោក ព្រមទាំងទេវលោក បានដល់ព្រហ្មលោក ព្រមទាំងទេវលោក មារលោក ពួកសត្វព្រមទាំងសមណៈនឹងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនឹងមនុស្សសាមញ្ញ ហេតុនោះ (លោកពោលថា) ព្រហ្មលោក ព្រមទាំងទេវលោក ។

(៦៥) ទិដ្ឋិន្តេ នាភិជានាតីតិ តុយ្ហំ ទិដ្ឋឹ ខន្តឹ រុចឹ លទ្ធឹ អជ្ឈាសយំ អធិប្បាយំ លោកោ ន ជានាតិ អយំ ឯវំទិដ្ឋិកោ ឯវំខន្តិកោ ឯវំរុចិកោ ឯវំលទ្ធិកោ ឯវំអជ្ឈាសយោ ឯវំអធិប្បាយោតិ ន ជានាតិ ន បស្សតិ ន ទក្ខតិ នាធិគច្ឆតិ ន វិន្ទតិ ន បដិលភតីតិ ទិដ្ឋិន្តេ នាភិជានាតិ ។

(៦៦) គោតមស្ស យសស្សិនោតិ ភគវា យសប្បត្តោតិ យសស្សី ។ អថវា ភគវា សក្កតោ គរុកតោ មានិតោ បូជិតោ អបចិតោ លាភី ចីវរបិណ្ឌបាតសេនាសនគិលានបច្ចយភេសជ្ជបរិក្ខារានន្តិ គោតមស្ស យសស្សិនោ ។ តេនាហ សោ ព្រាហ្មណោ

អយំ លោកោ បរោ លោកោ
ព្រហ្មលោកោ សទេវកោ
ទិដ្ឋិន្តេ នាភិជានាតិ
គោតមស្ស យសស្សិនោ ។

(៦៥) ពាក្យថា មិនទាន់ដឹងច្បាស់ នូវសេចក្តីឃើញរបស់ព្រះអង្គ គឺសត្វលោកមិនទាន់ដឹងនូវសេចក្តីយល់ឃើញ សេចក្តីចូលចិត្ត សេចក្តីគាប់ចិត្ត លទ្ធិ អធ្យាស្រ័យ បំណងរបស់ព្រះអង្គ គឺថាមិនទាន់ដឹង មិនទាន់ឃើញ មិនទាន់យល់ មិនទាន់ជួបប្រទះ មិនទាន់បាន មិនបានចំពោះថា សមណៈនេះ មានសេចក្តីយល់ឃើញយ៉ាងនេះ មានសេចក្តីចូលចិត្តយ៉ាងនេះ មានសេចក្តីគាប់ចិត្តយ៉ាងនេះ មានលទ្ធិយ៉ាងនេះ មានអធ្យាស្រ័យយ៉ាងនេះ មានបំណងយ៉ាងនេះទេ ហេតុនោះ (លោកពោលថា) មិនទាន់ដឹងច្បាស់នូវសេចក្តីយល់ឃើញរបស់ព្រះអង្គទេ ។

(៦៦) ពាក្យថា ជាព្រះគោតម ដ៏ទ្រង់យស គឺព្រះមានព្រះភាគ ឈ្មោះថាមានយស ព្រោះហេតុទ្រង់ដល់នូវយស ។ ឬថា ព្រះមានព្រះភាគ មានគេធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង ទ្រង់បាន ចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ហេតុនោះ (លោកពោលថា) ជាព្រះគោតមដ៏ទ្រង់យស ។ ហេតុនោះ ព្រាហ្មណ៍នោះ ពោលថា

លោកនេះ លោកដទៃ ព្រហ្មលោក ព្រមទាំងទេវលោក
រមែងមិនទាន់ដឹងច្បាស់ នូវសេចក្តីយល់ឃើញរបស់ព្រះអង្គ
ជាព្រះគោតម ដ៏ទ្រង់យសទេ ។

មោឃរាជមាណវកបញ្ហានិទ្ទេសោ

(៦៧) ឯវំ អភិក្កន្តទស្សាវឹ អត្ថិ បញ្ហេន អាគមំ

កថំ លោកំ អវេក្ខន្តំ មច្ចុរាជា ន បស្សតិ ។

(៦៨) ឯវំ អភិក្កន្តទស្សាវិន្តិ ឯវំ អភិក្កន្តទស្សាវឹ អគ្គទស្សាវឹ សេដ្ឋទស្សាវឹ វិសេដ្ឋទស្សាវឹ បាមោក្ខ-ទស្សាវឹ ឧត្តមទស្សាវឹ បវរទស្សាវិន្តិ ឯវំ អភិក្កន្ត-ទស្សាវឹ ។

(៦៩) អត្ថិ បញ្ហេន អាគមន្តិ បញ្ហត្ថិកម្ហា អា-គតា ។បេ។ សន្ទស្សេតុំ ភណិតុន្តិ ឯវម្បិ អត្ថិ បញ្ហេន អាគមំ ។

(៧០) កថំ លោកំ អវេក្ខន្តន្តិ កថំ អវេក្ខ-ន្តំ បច្ចវេក្ខន្តំ តុលយន្តំ តីរយន្តំ វិភាវយន្តំ វិភូតំ ករោន្តន្តិ កថំ លោកំ អវេក្ខន្តំ ។

(៦៧) ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយប្រស្នា ទើបមកគាល់ (ដើម្បីទូលសួរ) ចំពោះព្រះអង្គទ្រង់ឃើញវិសេសយ៉ាងនេះ ចុះបុគ្គលសំឡឹងឃើញលោក ដោយប្រការៈដូចម្តេច មច្ចុរាជទើបមិនឃើញ ។

(៦៨) ពាក្យថា ព្រះអង្គទ្រង់ឃើញវិសេសយ៉ាងនេះ គឺទ្រង់ឃើញវិសេស ឃើញច្បាស់ ឃើញប្រសើរផុត ឃើញប្រសើរវិសេស ឃើញជាប្រធាន ឃើញដ៏ឧត្តម ឃើញដ៏ថ្លៃថ្លាយ៉ាងនេះ ហេតុនោះ (លោកពោលថា) ព្រះអង្គឃើញវិសេសយ៉ាងនេះ ។

(៦៩) ពាក្យថា ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយប្រស្នាទើបមកគាល់ គឺពួកខ្ញុំព្រះអង្គមានសេចក្តីត្រូវការដោយប្រស្នា ទើបមកគាល់ ។ បេ ។ ដើម្បីសន្ទនា ដើម្បីក្រាបបង្គំទូលសួរ ហេតុនោះ (លោកពោលថា) ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយប្រស្នា ទើបមកគាល់ យ៉ាងនេះក៏មាន ។

(៧០) ពាក្យថា បុគ្គលសំឡឹងឃើញលោកដោយប្រការដូចម្តេច គឺសំឡឹងឃើញ ពិចារណាឃើញ រំពឹងឃើញ ត្រិះរិះឃើញ ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដ (នូវលោក) ដោយប្រការដូចម្តេច ហេតុនោះ (លោកពោលថា) បុគ្គលសំឡឹងឃើញលោក ដោយប្រការដូចម្តេច ។

(៧១) មច្ចុរាជា ន បស្សតីតិ មច្ចុរាជា ន បស្សតិ ន ទក្ខតិ នាធិគច្ឆតិ ន វិន្ទតិ ន បដិលភតីតិ មច្ចុរាជា ន បស្សតិ ។ តេនាហ សោ ព្រាហ្មណោ

ឯវំ អភិក្កន្តទស្សាវឹ អត្ថិ បញ្ហេន អាគមំ
កថំ លោកំ អវេក្ខន្តំ មច្ចុរាជា ន បស្សតីតិ ។

(៧២) សុញ្ញតោ លោកំ អវេក្ខស្សុ មោឃរាជ
សទា សតោ
អត្តានុទិដ្ឋឹ ឩហច្ច ឯវំ មច្ចុតរោ សិយា
ឯវំ លោកំ អវេក្ខន្តំ មច្ចុរាជា ន បស្សតិ ។

(៧៣) សុញ្ញតោ លោកំ អវេក្ខស្សូតិ លោកន្តិ និរយលោកោ តិរច្ឆានលោកោ បេត្តិវិសយលោកោ មនុស្សលោកោ ទេវលោកោ ខន្ធលោកោ ធាតុលោកោ អាយតនលោកោ អយំ លោកោ បរោ លោកោ ព្រហ្មលោកោ សទេវកោ ។

(៧១) ពាក្យថា មច្ចុរាជទើបមិនឃើញ គឺមច្ចុរាជទើបមិនឃើញ មិនយល់ មិនជួបប្រទះ មិនបាន មិនបានចំពោះ ហេតុនោះ (លោកពោលថា) មច្ចុរាជទើបមិនឃើញ ។ ហេតុនោះ ព្រាហ្មណ៍នោះពោលថា

ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយប្រស្នា ទើបមកគាល់ (ដើម្បីទូលសួរ) ចំពោះព្រះអង្គ ទ្រង់ឃើញវិសេសយ៉ាងនេះ
ចុះបុគ្គលសំឡឹងឃើញលោកដោយប្រការដូចម្តេច មច្ចុរាជទើបមិនឃើញ ។

(៧២) (ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា) ម្នាលមោឃរាជ
អ្នកចូរមានស្មារតីគ្រប់កាល សំឡឹងឃើញលោក ដោយសភាពជារបស់សូន្យ (ព្រោះ) បុគ្គលដកអត្តានុទិដ្ឋិចេញ
ទើបឆ្លងផុតចាកមច្ចុ បុគ្គលសំឡឹងឃើញលោក យ៉ាងនេះ មច្ចុរាជទើបមិនឃើញ ។

(៧៣) អធិប្បាយពាក្យថា អ្នកចូរសំឡឹងឃើញលោក ដោយសភាពជារបស់សូន្យ ត្រង់ពាក្យថា លោក បានដល់ និរយលោក តិរច្ឆានលោក បិត្តិវិសយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក លោកនេះ លោកដទៃ ព្រហ្មលោក ព្រមទាំងទេវលោក ។

## មោឃរាជមាណវកប្បញ្ហានិទ្ទេសោ

អញ្ញតរោ ភិក្ខុ ភគវន្តំ ឯតទវោច លោកោ លោកោតិ ភន្តេ ភគវតា វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ លោកោតិ វុច្ចតិ ។ លុជ្ជតីតិ ខោ ភិក្ខុ លោកោតិ វុច្ចតិ ។ កិញ្ច លុជ្ជតិ ។ ចក្ខុ លុជ្ជតិ រូបា លុជ្ជន្តិ ចក្ខុវិញ្ញាណំ លុជ្ជតិ ចក្ខុសម្ផស្សោ លុជ្ជតិ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ លុជ្ជតិ សោតំ លុជ្ជតិ សទ្ទា លុជ្ជន្តិ ឃានំ លុជ្ជតិ គន្ធា លុជ្ជន្តិ ជិវ្ហា លុជ្ជតិ រសា លុជ្ជន្តិ កាយោ លុជ្ជតិ ផោដ្ឋព្វា លុជ្ជន្តិ មនោ លុជ្ជតិ ធម្មា លុជ្ជន្តិ មនោវិញ្ញាណំ លុជ្ជតិ មនោសម្ផស្សោ លុជ្ជតិ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ លុជ្ជតិ លុជ្ជតីតិ ខោ ភិក្ខុ តស្មា លោកោតិ វុច្ចតិ ។

## មោឃរាជមាណវកប្បញ្ហានិទ្ទេស

ភិក្ខុមួយរូប បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ តែងត្រាស់ថា លោក លោក ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន សភាវៈដែលហៅថា លោក តើមានកំណត់ដូចម្តេច ៗ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ សភាវៈដែលហៅថា លោក ព្រោះហេតុវិនាស ៗ អ្វីតែងវិនាស ៗ ចក្ខុតែងវិនាស ពួករូបតែងវិនាស ចក្ខុវិញ្ញាណតែងវិនាស ចក្ខុសម្ផស្សតែងវិនាស ធម្មជាតណាមួយ ដែលបុគ្គលទទួល ជាសុខឬទុក្ខ ឬមិនមែនទុក្ខមិនមែនសុខ រមែងកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ ធម្មជាតនោះ តែងវិនាសទៅ ត្រចៀកតែងវិនាស ពួកសំឡេងតែងវិនាស ច្រមុះតែងវិនាស ពួកក្លិនតែងវិនាស អណ្តាតតែងវិនាស ពួករសតែងវិនាស កាយតែងវិនាស ពួកផ្សព្វតែងវិនាស ចិត្តតែងវិនាស ពួកធម្មារម្មណ៍តែងវិនាស មនោវិញ្ញាណតែងវិនាស មនោសម្ផស្សតែងវិនាស ធម្មជាតណាមួយដែលបុគ្គលទទួល ជាសុខឬទុក្ខ ឬមិនមែនទុក្ខមិនមែនសុខ កើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ ធម្មជាតនោះ រមែងវិនាស ម្នាលភិក្ខុ ហេតុនោះ សភាវៈដែលហៅថា លោក ព្រោះហេតុវិនាស ដូច្នេះឯង ៗ

សុញ្ញតោ លោកំ អវេក្ខស្សូតិ ទ្វីហិ ការណេហិ សុញ្ញតោ លោកំ អវេក្ខតិ អវស្សិយបវត្តសល្លក្ខណវសេន វា តុច្ឆសង្ខារសមនុបស្សនាវសេន វា ។

កថំ អវស្សិយបវត្តសល្លក្ខណវសេន សុញ្ញតោ លោកំ អវេក្ខតិ ។ រូបេ វសោ ន លព្ភតិ វេទនាយ វសោ ន លព្ភតិ សញ្ញាយ វសោ ន លព្ភតិ សង្ខារេសុ វសោ ន លព្ភតិ វិញ្ញាណេ វសោ ន លព្ភតិ ។ វុត្តញ្ហេតំ ភគវតា រូបំ ភិក្ខវេ អនត្តា រូបញ្ច ហិទំ ភិក្ខវេ អត្តា អភវិស្ស នយិទំ រូបំ អាពាធាយ សំវត្តេយ្យ លព្ភេថ ច រូបេ ឯវំ មេ រូបំ ហោតុ ឯវំ មេ រូបំ មា អហោសីតិ យស្មា ច ខោ ភិក្ខវេ រូបំ អនត្តា តស្មា រូបំ អាពាធាយ សំវត្តតិ ន ច លព្ភតិ រូបេ ឯវំ មេ រូបំ ហោតុ ឯវំ មេ រូបំ មា អហោសីតិ វេទនា អនត្តា វេទនា

ពាក្យថា អ្នកចូរសំឡឹងឃើញលោក ដោយសភាពជារបស់សូន្យ សេចក្តីថា បុគ្គល សំឡឹងឃើញលោក ដោយសភាពជារបស់សូន្យ ដោយហេតុពីរ គឺដោយអំណាចនៃការកំណត់សង្ខារដែលប្រព្រឹត្តទៅថា មិនមានអំណាច ១ ដោយអំណាចនៃការពិចារណាឃើញរឿយ ៗ នូវសង្ខារថាជារបស់ទទេ ១ ។

បុគ្គល សំឡឹងឃើញលោក ដោយសភាពជារបស់សូន្យ ដោយអំណាចនៃការកំណត់សង្ខារ ដែលប្រព្រឹត្តទៅថាមិនមានអំណាច តើដូចម្តេច ។ បុគ្គលមិនបានអំណាចក្នុងរូប មិនបានអំណាចក្នុងវេទនា មិនបានអំណាចក្នុងសញ្ញា មិនបានអំណាចក្នុងសង្ខារទាំងឡាយ មិនបានអំណាចក្នុងវិញ្ញាណ ។ ដូចព្រះពុទ្ធដីកានេះ ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ រូប មិនមែនជារបស់ខ្លួន ម្នាលភិក្ខុទាំងឡាយ ប្រសិនបើរូបនេះ ជារបស់ខ្លួនពិតមែន រូបនេះមិនគប្បីប្រព្រឹត្តទៅ ដើម្បីអាពាធទេ ទាំងបុគ្គលគប្បីបានក្នុងរូបថា សូមឲ្យរូបអាត្មាមានយ៉ាងនេះ កុំឲ្យរូបអាត្មា មានយ៉ាងនេះឡើយ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែរូប មិនមែនជារបស់ខ្លួន ហេតុនោះ រូបទើបប្រព្រឹត្តទៅដើម្បីអាពាធ ទាំងបុគ្គលមិនបានក្នុងរូបថា សូមឲ្យរូបអាត្មា មានយ៉ាងនេះ កុំឲ្យរូបអាត្មា មានយ៉ាងនេះឡើយ វេទនា មិនមែនជារបស់ខ្លួន

ច ហិទំ ភិក្ខវេ អត្តា អភវិស្ស នយិទំ វេទនា អាពា-
ធាយ សំវត្តេយ្យ លព្ភេថ ច វេទនាយ ឯវំ មេ វេទ-
នា ហោតុ ឯវំ មេ វេទនា មា អហោសីតិ យស្មា
ច ខោ ភិក្ខវេ វេទនា អនត្តា តស្មា វេទនា អាពា-
ធាយ សំវត្តតិ ន ច លព្ភតិ វេទនាយ ឯវំ មេ
វេទនា ហោតុ ឯវំ មេ វេទនា មា អហោសីតិ សញ្ញា
អនត្តា សញ្ញា ច ហិទំ ភិក្ខវេ អត្តា អភវិស្ស
នយិទំ សញ្ញា អាពាធាយ សំវត្តេយ្យ លព្ភេថ ច
សញ្ញាយ ឯវំ មេ សញ្ញា ហោតុ ឯវំ មេ សញ្-
ញា មា អហោសីតិ យស្មា ច ខោ ភិក្ខវេ
សញ្ញា អនត្តា តស្មា សញ្ញា អាពាធាយ សំ-
វត្តតិ ន ច លព្ភតិ សញ្ញាយ ឯវំ មេ សញ្ញា ហោតុ
ឯវំ មេ សញ្ញា មា អហោសីតិ សង្ខារា អនត្តា
សង្ខារា ច ហិទំ ភិក្ខវេ អត្តា អភវិស្សំសុ(១) នយិទំ
សង្ខារា អាពាធាយ សំវត្តេយ្យុំ លព្ភេថ ច សង្ខារេសុ

---

១ ម. អភវិស្ស ។

## មោឃរាជមាណវកបញ្ហានិទ្ទេស

ម្នាលភិក្ខុទាំងឡាយ ប្រសិនបើវេទនានេះ ជារបស់ខ្លួនពិតមែន វេទនានេះ មិនគប្បីប្រព្រឹត្តទៅ ដើម្បីអាពាធទេ ទាំងបុគ្គលគប្បីបានក្នុងវេទនាថា សូមឲ្យវេទនារបស់អាត្មា មានយ៉ាងនេះ កុំឲ្យវេទនារបស់អាត្មា មានយ៉ាងនេះឡើយ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែវេទនា មិនមែនជារបស់ខ្លួន ហេតុនោះ វេទនាទើបប្រព្រឹត្តទៅ ដើម្បីអាពាធ ទាំងបុគ្គលមិនបានក្នុងវេទនាថា សូមឲ្យវេទនារបស់អាត្មាមានយ៉ាងនេះ កុំឲ្យវេទនារបស់អាត្មា មានយ៉ាងនេះឡើយ សញ្ញាមិនមែនជារបស់ខ្លួនទេ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើសញ្ញានេះ ជារបស់ខ្លួនពិតមែន សញ្ញានេះមិនគប្បីប្រព្រឹត្តទៅ ដើម្បីអាពាធទេ ទាំងបុគ្គលគប្បីបានក្នុងសញ្ញាថា សូមឲ្យសញ្ញារបស់អាត្មា មានយ៉ាងនេះ កុំឲ្យសញ្ញារបស់អាត្មាមានយ៉ាងនេះឡើយ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែសញ្ញា មិនមែនជារបស់ខ្លួន ហេតុនោះ សញ្ញាទើបប្រព្រឹត្តទៅ ដើម្បីអាពាធ ទាំងបុគ្គលមិនបានក្នុងសញ្ញាថា សូមឲ្យសញ្ញារបស់អាត្មា មានយ៉ាងនេះ កុំឲ្យសញ្ញារបស់អាត្មា មានយ៉ាងនេះឡើយ សង្ខារទាំងឡាយ មិនមែនជារបស់ខ្លួនទេ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើសង្ខារទាំងឡាយនេះ ជារបស់ខ្លួនពិតមែន សង្ខារទាំងឡាយនេះ មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធទេ ទាំងបុគ្គលគប្បីបាន ក្នុងសង្ខារទាំងឡាយថា

ឯវំ មេ សង្ខារា ហោន្តុ ឯវំ មេ សង្ខារា មា អហោ-
សុន្តិ យស្មា ច ខោ ភិក្ខវេ សង្ខារា អនត្តា តស្មា
សង្ខារា អាពាធាយ សំវត្តន្តិ ន ច លព្ភតិ សង្ខារេសុ
ឯវំ មេ សង្ខារា ហោន្តុ ឯវំ មេ សង្ខារា មា អហោសុន្តិ
វិញ្ញាណំ អនត្តា វិញ្ញាណញ្ច ហិទំ ភិក្ខវេ អត្តា
អភវិស្ស នយិទំ វិញ្ញាណំ អាពាធាយ សំវត្តេយ្យ
លព្ភេថ ច វិញ្ញាណេ ឯវំ មេ វិញ្ញាណំ ហោតុ
ឯវំ មេ វិញ្ញាណំ មា អហោសីតិ យស្មា ច
ខោ ភិក្ខវេ វិញ្ញាណំ អនត្តា តស្មា វិញ្ញាណំ
អាពាធាយ សំវត្តតិ ន ច លព្ភតិ វិញ្ញាណេ ឯវំ
មេ វិញ្ញាណំ ហោតុ ឯវំ មេ វិញ្ញាណំ មា
អហោសីតិ ។ វុត្តញ្ហេតំ ភគវតា នាយំ ភិក្ខវេ
កាយោ តុម្ហាកំ នបិ បរេសំ បុរាណមិទំ

សូមឲ្យសង្ខារទាំងឡាយរបស់អាត្មាមានយ៉ាងនេះ កុំឲ្យសង្ខារទាំងឡាយរបស់អាត្មាមានយ៉ាងនេះឡើយ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែសង្ខារទាំងឡាយ មិនមែនជារបស់ខ្លួន ហេតុនោះ សង្ខារទាំងឡាយ ទើបប្រព្រឹត្តទៅ ដើម្បីអាពាធ ទាំងបុគ្គលមិនបានក្នុងសង្ខារទាំងឡាយថា សូមឲ្យសង្ខារទាំងឡាយរបស់អាត្មា មានយ៉ាងនេះ កុំឲ្យសង្ខារទាំងឡាយរបស់អាត្មាមានយ៉ាងនេះឡើយ វិញ្ញាណមិនមែនជារបស់ខ្លួនទេ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ វិញ្ញាណនេះជារបស់ខ្លួនពិតមែន វិញ្ញាណនេះមិនគប្បីប្រព្រឹត្តទៅ ដើម្បីអាពាធទេ ទាំងបុគ្គលគប្បីបានក្នុងវិញ្ញាណថា សូមឲ្យវិញ្ញាណរបស់អាត្មា មានយ៉ាងនេះ កុំឲ្យវិញ្ញាណរបស់អាត្មាមានយ៉ាងនេះឡើយ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែវិញ្ញាណ មិនមែនជារបស់ខ្លួន ហេតុនោះ វិញ្ញាណទើបប្រព្រឹត្តទៅ ដើម្បីអាពាធ ទាំងបុគ្គលមិនបានក្នុងវិញ្ញាណថា សូមឲ្យវិញ្ញាណរបស់អាត្មា មានយ៉ាងនេះ កុំឲ្យវិញ្ញាណរបស់អាត្មា មានយ៉ាងនេះឡើយ ។ មួយទៀត ព្រះពុទ្ធដីកានេះ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាយនេះ មិនមែនជារបស់អ្នកទាំងឡាយទេ ទាំងមិនមែនជារបស់ជនទាំងឡាយដទៃទេ

## មោឃរាជមាណវកប្បញ្ហានិទ្ទេសោ

ភិក្ខវេ កម្មំ សង្ខតំ អភិសញ្ចេតយិតំ វេទនិយំ ទដ្ឋព្វំ តត្រ ភិក្ខវេ សុតវា អរិយសាវកោ បដិច្ចសមុប្បាទញ្ញេវ សាធុកំ យោនិសោ មនសិករោតិ ឥតិ ឥមស្មឹ សតិ ឥទំ ហោតិ ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ ឥមស្មឹ អសតិ ឥទំ ន ហោតិ ឥមស្ស និរោធា ឥទំ និរុជ្ឈតិ យទិទំ អវិជ្ជាបច្ចយា សង្ខារា សង្ខារបច្ចយា វិញ្ញាណំ វិញ្ញាណបច្ចយា នាមរូបំ នាមរូបបច្ចយា សឡាយតនំ សឡាយតនបច្ចយា ផស្សោ ផស្សបច្ចយា វេទនា វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានបច្ចយា ភវោ ភវបច្ចយា ជាតិ ជាតិបច្ចយា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ អវិជ្ជាយត្វេវ អសេសវិរាគនិរោធា

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីឃើញថា កាយនេះកើតអំពីកម្ម
ចាស់ដែលបច្ច័យប្រជុំតាក់តែង មានចេតនាជាមូល ជាទីតាំងនៃវេទនា
ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក អ្នកចេះដឹង តែងធ្វើទុកក្នុងចិត្តដោយ
ឧបាយយ៉ាងប្រពៃ ចំពោះធម៌ដែលកើតអាស្រ័យគ្នានឹងគ្នាក្នុងកាយនោះថា
កាលបើធម្មជាតនេះមាន ធម្មជាតនេះក៏មាន ធម្មជាតនេះកើតឡើងព្រោះ
ការកើតឡើងនៃធម្មជាតនេះ កាលបើធម្មជាតនេះមិនមាន ធម្មជាតនេះក៏មិន
មាន ធម្មជាតនេះរលត់ ព្រោះការរលត់ធម្មជាតនេះ គឺថាសង្ខារទាំងឡាយ
(កើតមាន) ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ (កើតមាន) ព្រោះសង្ខារ
ជាបច្ច័យ នាមរូប (កើតមាន) ព្រោះវិញ្ញាណជាបច្ច័យ សឡាយតនៈ
(កើតមាន) ព្រោះនាមរូបជាបច្ច័យ ផស្សៈ (កើតមាន) ព្រោះសឡាយ-
តនៈជាបច្ច័យ វេទនា (កើតមាន) ព្រោះផស្សៈជាបច្ច័យ តណ្ហា (កើតមាន)
ព្រោះវេទនាជាបច្ច័យ ឧបាទាន (កើតមាន) ព្រោះតណ្ហាជាបច្ច័យ ភព
(កើតមាន) ព្រោះឧបាទានជាបច្ច័យ ជាតិ (កើតមាន) ព្រោះភពជា
បច្ច័យ ការចាស់ ស្លាប់ សោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត ចង្អៀត
ណែនក្នុងចិត្តទាំងឡាយ កើតមាន ព្រោះជាតិជាបច្ច័យ កិរិយាកើតឡើង
នៃកងទុក្ខទាំងអស់នេះ រមែងកើតមានយ៉ាងនេះ មួយទៀត កិរិយារលត់
សង្ខារ ព្រោះកិរិយាវិនាសទៅរលត់ទៅ មិនមានសេសសល នៃអវិជ្ជា

សង្ខារនិរោធោ សង្ខារនិរោធា វិញ្ញាណនិរោធោ វិញ្ញាណនិរោធា នាមរូបនិរោធោ នាមរូបនិរោធា សឡាយតននិរោធោ សឡាយតននិរោធា ផស្សនិ-រោធោ ផស្សនិរោធា វេទនានិរោធោ វេទនានិរោធា តណ្ហានិរោធោ តណ្ហានិរោធា ឧបាទាននិរោធោ ឧបាទាននិរោធា ភវនិរោធោ ភវនិរោធា ជាតិនិរោ-ធោ ជាតិនិរោធា ជរាមរណំ សោកបរិទេវទុក្ខទោ-មនស្សុបាយាសា និរុជ្ឈន្តិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។ ឯវំ អវស្សិយ-បវត្តសលក្ខណាវសេន សុញ្ញតោ លោកំ អវេក្ខតិ ។

កថំ តុច្ឆសង្ខារសមនុបស្សនាវសេន សុញ្ញតោ លោកំ អវេក្ខតិ ។ រូបេ សារោ ន លព្ភតិ វេទនាយ សារោ ន លព្ភតិ សញ្ញាយ សារោ ន លព្ភតិ សង្ខារេ-សុ សារោ ន លព្ភតិ វិញ្ញាណេ សារោ ន លព្ភតិ ។

កិរិយារលត់វិញ្ញាណ ព្រោះកិរិយារលត់សង្ខារ កិរិយារលត់នាមរូប ព្រោះកិរិយារលត់វិញ្ញាណ កិរិយារលត់សឡាយតនៈ ព្រោះកិរិយារលត់នាមរូប កិរិយារលត់ផស្សៈ ព្រោះកិរិយារលត់សឡាយតនៈ កិរិយារលត់វេទនា ព្រោះកិរិយារលត់ផស្សៈ កិរិយារលត់តណ្ហា ព្រោះកិរិយារលត់វេទនា កិរិយារលត់ឧបាទាន ព្រោះកិរិយារលត់តណ្ហា កិរិយារលត់ភព ព្រោះកិរិយារលត់ឧបាទាន កិរិយារលត់ជាតិ ព្រោះកិរិយារលត់ភព ការចាស់ ស្លាប់ សោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត ចង្អៀតចង្អល់ចិត្តទាំងឡាយ តែងរលត់ទៅ ព្រោះកិរិយារលត់ជាតិ កិរិយារលត់កងទុក្ខទាំងអស់នេះ មានយ៉ាងនេះ ។ បុគ្គលសំឡឹងឃើញលោកដោយសភាពជារបស់សូន្យ ដោយអំណាចនៃការកំណត់សង្ខារ ដែលប្រព្រឹត្តទៅថាមិនមានអំណាច យ៉ាងនេះឯង ។

បុគ្គលសំឡឹងឃើញលោក ដោយសភាពជារបស់សូន្យ ដោយអំណាចនៃការពិចារណាឃើញរឿយៗ នូវសង្ខារថាជារបស់ទទេ តើដូចម្តេច ។ គឺបុគ្គលមិនបានខ្វឹមក្នុងរូប មិនបានខ្វឹមក្នុងវេទនា មិនបានខ្វឹមក្នុងសញ្ញា មិនបានខ្វឹមក្នុងសង្ខារទាំងឡាយ មិនបានខ្វឹមក្នុងវិញ្ញាណទេ ។

រូបំ អស្សារំ និស្សារំ សារាបគតំ និច្ចសារសារេន វា សុខសារសារេន វា អត្តសារសារេន វា និច្ចេន វា ធុវេន វា សស្សតេន វា អវិបរិណាមធម្មេន វា ។ វេទនា អស្សារា និស្សារា សារាបគតា សញ្ញា អស្សារា និស្សារា សារាបគតា សង្ខារា អស្សារា និស្សារា សារាបគតា វិញ្ញាណំ អស្សារំ និស្សារំ សារាបគតំ និច្ចសារសារេន វា សុខសារសារេន វា អត្តសារសារេន វា និច្ចេន វា ធុវេន វា សស្ស-តេន វា អវិបរិណាមធម្មេន វា ។ យថា នឡោ អស្សារោ និស្សារោ សារាបគតោ យថា ច ឯរណ្ឌោ អស្សារោ និស្សារោ សារាបគតោ យថា ច ឧទុម្ព-រោ អស្សារោ និស្សារោ សារាបគតោ យថា ច សេ-តគច្ឆោ អស្សារោ និស្សារោ សារាបគតោ យថា ច ផាលិភទ្ទកោ អស្សារោ និស្សារោ សារាបគតោ យថា ច ផេណុបិណ្ឌោ អស្សារោ និស្សារោ សារាបគតោ

មោឃរាជមាណវកបញ្ហានិទ្ទេស

រូបជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម ដោយខ្លឹមមានខ្លឹមគឺទៀងក្ដី ដោយខ្លឹមមានខ្លឹមគឺសុខក្ដី ដោយខ្លឹមមានខ្លឹមគឺរបស់ខ្លួនក្ដី ដោយភាពជារបស់ទៀងក្ដី យឺនយូរក្ដី ឋិតថេរក្ដី មិនប្រែប្រួលជាធម្មតាក្ដី ។ វេទនាជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម សញ្ញាជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម សង្ខារទាំងឡាយ ជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម វិញ្ញាណ ជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម ដោយខ្លឹមមានខ្លឹមគឺទៀងក្ដី ដោយខ្លឹមមានខ្លឹមគឺសុខក្ដី ដោយខ្លឹមមានខ្លឹមគឺរបស់ខ្លួនក្ដី ដោយភាពជារបស់ទៀងក្ដី យឺនយូរក្ដី ឋិតថេរក្ដី មិនប្រែប្រួលជាធម្មតាក្ដី ។ ប្រៀបដូចដើមបបុស ជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម ឬដូចដើមល្ហុងខ្វែ ជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម យ៉ាងណាមិញ មួយទៀត ដូចដើមល្វា ជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម យ៉ាងណាមិញ ឬដូចដើមសេតគច្ឆព្រឹក្ស ( ពក់ស ) ជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម យ៉ាងណាមិញ មួយទៀត ដូចដើមបាលកន្ទុកព្រឹក្ស '( រលួសបាយ ) ជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម យ៉ាងណាមិញ ឬដូចជាដុំពពុះទឹក ជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម យ៉ាងណាមិញ

យថា ច ពុព្ពុឡកំ អសារកំ និស្សារកំ សារាបគតំ យថា ច កទលិក្ខន្ធោ អសារកោ និស្សារកោ សារាបគតោ យថា ច មាយា អសារកា និស្សារកា សារាបគតា ឯវមេវ រូបំ អសារកំ និស្សារកំ សារាបគតំ និច្ចសារសារេន វា សុខសារសារេន វា អត្តសារសារេន វា និច្ចេន វា ធុវេន វា សស្សតេន វា អវិបរិណាមធម្មេន វា វេទនា អសារកា និស្សារកា សារាបគតា សញ្ញា អសារកា និស្សារកា សារាបគតា សង្ខារា អសារកា និស្សារកា សារាបគតា វិញ្ញាណំ អសារកំ និស្សារកំ សារាបគតំ និច្ចសារសារេន វា សុខសារសារេន វា អត្តសារសារេន វា និច្ចេន វា ធុវេន វា សស្សតេន វា អវិបរិណាមធម្មេន វា ។ ឯវំ តុច្ឆសង្ខារសមនុបស្សនាវសេន សុញ្ញតោ លោកំ អវេក្ខតិ ។ ឥមេហិ ទ្វីហិ ការណេហិ សុញ្ញតោ លោកំ អវេក្ខតិ ។

មួយទៀត ដូចក្រពេញទឹក ជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម យ៉ាងណាមិញ ឬដូចដើមចេក ជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម យ៉ាងណាមិញ មួយទៀត ដូចថ្ងៃបណ្ដើរកូន ជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម យ៉ាងណាមិញ រូបជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម ដោយខ្លឹមមានខ្លឹមគឺទៀងក្ដី ដោយខ្លឹមមានខ្លឹមគឺសុខក្ដី ដោយខ្លឹមមានខ្លឹមគឺរបស់ខ្លួនក្ដី ដោយភាពជារបស់ទៀងក្ដី យឺនយូរក្ដី ឋិតថេរក្ដី មិនប្រែប្រួលជាធម្មតាក្ដី វេទនាជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម សញ្ញាជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម សង្ខារទាំងឡាយ ជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម វិញ្ញាណជារបស់មិនមានខ្លឹម ឥតខ្លឹម ប្រាសចាកខ្លឹម ដោយខ្លឹមមានខ្លឹមគឺទៀងក្ដី ដោយខ្លឹមមានខ្លឹមគឺសុខក្ដី ដោយខ្លឹមមានខ្លឹមគឺរបស់ខ្លួនក្ដី ដោយភាពជារបស់ទៀងក្ដី យឺនយូរក្ដី ឋិតថេរក្ដី មិនប្រែប្រួលជាធម្មតាក្ដី ក៏យ៉ាងនោះដែរ ៗ បុគ្គលសំឡឹងឃើញលោក ដោយសភាពជារបស់សូន្យ ដោយអំណាចការពិចារណារឿយ ៗ នូវសង្ខារថាជារបស់ទទេ យ៉ាងនេះ ៗ បុគ្គលសំឡឹងឃើញលោក ដោយសភាពជារបស់សូន្យ ដោយហេតុពីរប្រការនេះឯង ៗ

## មោឃរាជមាណវកបញ្ហានិទ្ទេសោ

អបិច ឆហាការេហិ សុញ្ញតោ លោកំ អវេក្ខតិ រូបំ អនិស្សរិយតោ អកាមការិយតោ អផាសុនិយតោ អវសវត្តនតោ បវត្តិតោ វិវិត្តតោ អវេក្ខតិ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ អនិស្សរិយតោ អកាមការិយតោ អផាសុនិយតោ អវសវត្តនតោ បវត្តិតោ វិវិត្តតោ អវេក្ខតិ ៗ ឯវំ ឆហាការេហិ សុញ្ញតោ លោកំ អវេក្ខតិ ៗ អបិច ទសហាការេហិ សុញ្ញតោ លោកំ អវេក្ខតិ រូបំ រិត្តតោ តុច្ឆតោ សុញ្ញតោ អនត្តតោ អសារកតោ វធកតោ វិភវតោ អឃមូលតោ សាសវតោ សង្ខតតោ អវេក្ខតិ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ រិត្តតោ តុច្ឆតោ សុញ្ញតោ អនត្តតោ អសារកតោ វធកតោ វិភវតោ អឃមូលតោ

មោឃរាជមាណវកប្បញ្ហានិទ្ទេស

មួយទៀត បុគ្គលសំឡឹងឃើញលោក ដោយសភាពជារបស់សូន្យ ដោយអាការៈ ៦ គឺសំឡឹងឃើញរូប ដោយសភាពជារបស់មិនមានអ្វីជាឥស្សរៈ ១ មិនលុះតាមប្រាថ្នា ១ មិនជាទីសប្បាយ ១ មិនលុះអំណាចខ្លួន ១ ប្រព្រឹត្ត ( ជាប់ដោយបច្ច័យ ) ១ ជារបស់ទទេ ១ សំឡឹងឃើញវេទនា សញ្ញា សង្ខារ វិញ្ញាណ ដោយសភាពជារបស់មិនមានអ្វីជាឥស្សរៈ មិនលុះតាមប្រាថ្នា មិនជាទីសប្បាយ មិនលុះអំណាចខ្លួន ប្រព្រឹត្ត ( ជាប់ដោយបច្ច័យ ) ជារបស់ទទេ ។ បុគ្គលសំឡឹងឃើញលោក ដោយសភាពជារបស់សូន្យ ដោយអាការៈ ៦ យ៉ាងនេះឯង ។ មួយទៀត បុគ្គលសំឡឹងឃើញលោកដោយសភាពជារបស់សូន្យ ដោយអាការៈ ១០ គឺសំឡឹងឃើញរូប ដោយសភាពជារបស់គ្មាន ១ របស់ទទេ ១ របស់សូន្យ ១ របស់មិនមែនខ្លួនប្រាណ ១ របស់មិនមានខ្លឹម ១ ជាអ្នកសម្លាប់ ១ របស់មិនចម្រើន ១ របស់បង្កទុក្ខ ១ របស់ប្រកបដោយអាសវៈ ១ របស់ដែលបច្ច័យប្រជុំតាក់តែង ១ សំឡឹងឃើញ វេទនា សញ្ញា សង្ខារ វិញ្ញាណ ដោយសភាពជារបស់គ្មាន របស់ទទេ របស់សូន្យ របស់មិនមែនខ្លួនប្រាណ របស់មិនមានខ្លឹម ជាអ្នកសម្លាប់ របស់មិនចម្រើន របស់បង្កទុក្ខ

សាសវតោ សង្ខតតោ អវេក្ខតិ ។ ឯវំ ឆហាការេហិ សុញ្ញតោ លោកំ អវេក្ខតិ ។ អបរេហិ ទ្វាទសហាការេហិ សុញ្ញតោ លោកំ អវេក្ខតិ រូបំ ន សត្តោ ន ជីវោ ន នរោ ន មាណវោ ន ឥត្ថី ន បុរិសោ ន អត្តា ន អត្តនិយំ ន អហំ ន មម ន កោចិ អត្ថិ វេទនា សញ្ញា សង្ខារា វិញ្ញាណំ ន សត្តោ ន ជីវោ ន នរោ ន មាណវោ ន ឥត្ថី ន បុរិសោ ន អត្តា ន អត្តនិយំ ន អហំ ន មម ន កោចិ អត្ថិ ។ ឯវំ ទ្វាទសហាការេហិ សុញ្ញតោ លោកំ អវេក្ខតិ ។

វុត្តញ្ហេតំ ភគវតា យំ ភិក្ខវេ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ទីឃរត្តំ ហិតាយ សុខាយ ភវិស្សតិ កិញ្ច ភិក្ខវេ ន តុម្ហាកំ រូបំ ភិក្ខវេ ន តុម្ហាកំ

របស់ប្រកបដោយអាសវៈ របស់ដែលបច្ច័យប្រជុំតាក់តែង ។ បុគ្គលសំឡឹងឃើញលោក ដោយសភាពជារបស់សូន្យ ដោយអាការៈ ១០ យ៉ាងនេះឯង ។ មួយទៀត បុគ្គលសំឡឹងឃើញលោក ដោយសភាពជារបស់សូន្យ ដោយអាការៈ ១២ គឺឃើញថា រូបមិនមែនសត្វ ១ មិនមែនជីវៈ ១ មិនមែនបុរស ១ មិនមែននរៈ ១ មិនមែនមាណព ១ មិនមែនស្រី ១ មិនមែនប្រុស ១ មិនមែនខ្លួន ១ មិនមែនរបស់ខ្លួន ១ មិនមែនយើង ១ មិនមែនរបស់យើង ១ មិនមែនជាបុគ្គលណា ៗ ១ ឃើញថា វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនមែនសត្វ មិនមែនជីវៈ មិនមែនបុរស មិនមែននរៈ មិនមែនមាណព មិនមែនស្រី មិនមែនប្រុស មិនមែនខ្លួន មិនមែនរបស់ខ្លួន មិនមែនយើង មិនមែនរបស់យើង មិនមែនជាបុគ្គលណា ៗ ។ បុគ្គលសំឡឹងឃើញលោក ដោយសភាពជារបស់សូន្យ ដោយអាការៈ ១២ យ៉ាងនេះឯង ។

ដូចព្រះពុទ្ធដីកា ដែលព្រះមានព្រះភាគត្រាស់ហើយនេះថា ម្នាលភិក្ខុទាំងឡាយ របស់ណា មិនមែនជារបស់ពួកអ្នក ពួកអ្នកចូរលះបង់របស់នោះ របស់នោះដែលពួកអ្នកបានលះបង់ហើយ នឹងបានជាប្រយោជន៍ បានសេចក្ដីសុខ អស់កាលយូរ ម្នាលភិក្ខុទាំងឡាយ របស់អ្វី ដែលមិនមែនជារបស់ពួកអ្នក ម្នាលភិក្ខុទាំងឡាយ រូបមិនមែនជារបស់ពួកអ្នក

តំ បជហថ តំ វោ បហីនំ ទីឃរត្តំ ហិតាយ
សុខាយ ភវិស្សតិ វេទនា ភិក្ខវេ ន តុម្ហាកំ
តំ បជហថ សា វោ បហីនា ទីឃរត្តំ ហិតាយ
សុខាយ ភវិស្សតិ សញ្ញា ភិក្ខវេ ន តុម្ហាកំ
តំ បជហថ សា វោ បហីនា ទីឃរត្តំ ហិតាយ
សុខាយ ភវិស្សតិ សង្ខារា ភិក្ខវេ ន តុម្ហាកំ
តេ បជហថ តេ វោ បហីនា ទីឃរត្តំ ហិតាយ
សុខាយ ភវិស្សន្តិ វិញ្ញាណំ ភិក្ខវេ ន តុម្ហាកំ
តំ បជហថ តំ វោ បហីនំ ទីឃរត្តំ ហិតាយ
សុខាយ ភវិស្សតិ ។ តំ កឹ មញ្ញថ ភិក្ខវេ យំ
ឥមស្មឹ ជេតវនេ តិណកដ្ឋសាខាបលាសំ តំ ជនោ
ហរេយ្យ វា ឌហេយ្យ វា យថាបច្ចយំ វា ករេយ្យ
អបិ នុ តុម្ហាកំ ឯវមស្ស អម្ហេ ជនោ ហរតិ
វា ឌហតិ វា យថាបច្ចយំ វា ករោតីតិ ។
នោ ហេតំ ភន្តេ ។ តំ កិស្ស ហេតុ ។

មោឃរាជមាណវកបញ្ហានិទ្ទេស

ពួកអ្នកចូរលះបង់រូបនោះ រូបនោះដែលពួកអ្នកលះបង់ហើយ នឹងបានជាប្រយោជន៍ បានសេចក្តីសុខ អស់កាលយូរ ម្នាលភិក្ខុទាំងឡាយ វេទនាមិនមែនជារបស់ពួកអ្នក ពួកអ្នកចូរលះបង់វេទនានោះ វេទនានោះដែលពួកអ្នកលះបង់ហើយ នឹងបានជាប្រយោជន៍ បានសេចក្តីសុខ អស់កាលយូរ ម្នាលភិក្ខុទាំងឡាយ សញ្ញាមិនមែនជារបស់ពួកអ្នក ពួកអ្នកចូរលះបង់សញ្ញានោះ សញ្ញានោះ ដែលពួកអ្នកលះបង់ហើយ នឹងបានជាប្រយោជន៍ បានសេចក្តីសុខអស់កាលយូរ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មិនមែនជារបស់ពួកអ្នក ពួកអ្នកចូរលះបង់សង្ខារទាំងនោះ សង្ខារទាំងនោះ ដែលពួកអ្នកលះបង់ហើយ នឹងបានជាប្រយោជន៍ បានសេចក្តីសុខអស់កាលយូរ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណ មិនមែនជារបស់ពួកអ្នក ពួកអ្នកចូរលះបង់វិញ្ញាណនោះ វិញ្ញាណនោះដែលពួកអ្នកលះបង់ហើយ នឹងបានជាប្រយោជន៍ បានសេចក្តីសុខ អស់កាលយូរ ៗ ម្នាលភិក្ខុទាំងឡាយ ពួកអ្នកសំគាល់ហេតុនោះថាដូចម្តេច ស្មៅ ឈើ មែកឈើ ស្លឹកឈើណា ក្នុងវត្តជេតពននេះ ជនគប្បីនាំទៅក្តី ដុតក្តី ធ្វើឲ្យត្រូវតាមបច្ច័យក្តី នូវរបស់នោះ តើពួកអ្នកគិតយ៉ាងនេះថា ជននាំទៅក្តី ដុតក្តី ធ្វើឲ្យត្រូវតាមបច្ច័យក្តី នូវពួកយើងដែរឬ ៗ បពិត្រព្រះអង្គដ៏ចម្រើន ដំណើរនោះមិនដូច្នោះទេ ៗ ដំណើរនោះ ព្រោះហេតុអ្វី ៗ

ន នោ ឯវំ ភន្តេ អត្តា វា អត្តនិយំ វាតិ ។ ឯវមេវ ខោ ភិក្ខវេ យំ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ទីឃរត្តំ ហិតាយ សុខាយ ភវិស្សតិ កិញ្ច ភិក្ខវេ ន តុម្ហាកំ រូបំ ភិក្ខវេ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ទីឃរត្តំ ហិតាយ សុខាយ ភវិស្សតិ វេទនា សញ្ញា សង្ខារា វិញ្ញាណំ ភិក្ខវេ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ទីឃរត្តំ ហិតាយ សុខាយ ភវិស្សតីតិ ។ ឯវម្បិ សុញ្ញតោ លោកំ អវេក្ខតិ ។

អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច សុញ្ញោ លោកោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ- ខោ ភន្តេ សុញ្ញោ លោកោតិ វុច្ចតិ ។

បពិត្រព្រះអង្គដ៏ចម្រើន (ព្រោះថា) ខ្លួនក្តី របស់សម្រាប់ខ្លួនក្តី មិនមែនជារបស់ពួកខ្ញុំព្រះអង្គឡើយ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះ ពិតយ៉ាងនេះហើយ របស់ណាមិនមែនជារបស់ពួកអ្នកទេ ពួកអ្នកចូរលះបង់របស់នោះ របស់នោះដែលពួកអ្នកលះបង់ហើយ នឹងបានជាប្រយោជន៍ បានសេចក្តីសុខអស់កាលយូរ ម្នាលភិក្ខុទាំងឡាយ របស់អ្វី ដែលមិនមែនជារបស់ពួកអ្នក ម្នាលភិក្ខុទាំងឡាយ រូបមិនមែនជារបស់ពួកអ្នក ពួកអ្នកចូរលះបង់រូបនោះ រូបនោះដែលពួកអ្នកលះបង់ហើយ នឹងបានជាប្រយោជន៍ បានសេចក្តីសុខអស់កាលយូរ ម្នាលភិក្ខុទាំងឡាយ វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនមែនជារបស់ពួកអ្នក ពួកអ្នកចូរលះបង់វេទនា សញ្ញា សង្ខារ វិញ្ញាណនោះ វេទនា សញ្ញា សង្ខារ វិញ្ញាណនោះ ដែលពួកអ្នកលះបង់ហើយ នឹងបានជាប្រយោជន៍ បានសេចក្តីសុខអស់កាលយូរ ។ បុគ្គលសំឡឹងឃើញលោក ដោយសភាពជារបស់សូន្យ យ៉ាងនេះឯង ។

ព្រះអានន្ទមានអាយុ បានទូលសួរព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគត្រាស់ថា លោកសូន្យ បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គទ្រង់ត្រាស់ថា លោកសូន្យ តើដោយហេតុដូចម្តេច ។

## មោឃរាជមាណវកប្បញ្ហានិទ្ទេសោ

យស្មា ខោ អានន្ទ សុញ្ញំ អត្តេន វា អត្តនិយេន
វា តស្មា សុញ្ញោ លោកោតិ វុច្ចតិ កិញ្ចានន្ទ សុញ្ញំ
អត្តេន វា អត្តនិយេន វា ។ ចក្ខុ សុញ្ញំ រូបា សុញ្ញា
ចក្ខុវិញ្ញាណំ សុញ្ញំ ចក្ខុសម្ផស្សោ សុញ្ញោ យម្បិទំ
ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា
ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ សុញ្ញំ អត្តេន វា
អត្តនិយេន វា សោតំ សុញ្ញំ សទ្ទា សុញ្ញា ឃា-
នំ សុញ្ញំ គន្ធា សុញ្ញា ជិវ្ហា សុញ្ញា រសា សុញ្ញា
កាយោ សុញ្ញោ ផោដ្ឋព្វា សុញ្ញា មនោ សុញ្ញោ
ធម្មា សុញ្ញា មនោវិញ្ញាណំ សុញ្ញំ មនោសម្ផស្សោ
សុញ្ញោ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ
វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ
សុញ្ញំ អត្តេន វា អត្តនិយេន វា យស្មា ច ខោ
អានន្ទ សុញ្ញំ អត្តេន វា អត្តនិយេន វា តស្មា
សុញ្ញោ លោកោតិ វុច្ចតីតិ ។ ឯវម្បិ សុញ្ញតោ
លោកំ អវេក្ខតិ ។

## មោឃរាជមាណវកបញ្ហានិទ្ទេស

ព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ ព្រោះហេតុតែធម្មជាតសូន្យចាកខ្លួន ឬចាកវត្ថុសម្រាប់ខ្លួន ហេតុនោះ ទើបតថាគតពោលថា លោកសូន្យ ម្នាលអានន្ទ ចុះធម្មជាតអ្វី សូន្យចាកខ្លួន ឬចាកវត្ថុសម្រាប់ខ្លួន ។ ភ្នែកសូន្យ រូបទាំងឡាយសូន្យ ចក្ខុវិញ្ញាណសូន្យ ចក្ខុសម្ផស្សសូន្យ សូម្បីធម្មជាតសម្រាប់ទទួលអារម្មណ៍ណា ជាសុខ ឬជាទុក្ខ ឬមិនជាទុក្ខមិនជាសុខ កើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ ធម្មជាតនោះក៏សូន្យចាកខ្លួន ឬចាកវត្ថុសម្រាប់ខ្លួន ត្រចៀកសូន្យ សំឡេងទាំងឡាយសូន្យ ច្រមុះសូន្យ ក្លិនទាំងឡាយសូន្យ អណ្តាតសូន្យ រសទាំងឡាយសូន្យ កាយសូន្យ ផ្សព្វទាំងឡាយសូន្យ មនៈសូន្យ ធម្មារម្មណ៍សូន្យ មនោវិញ្ញាណសូន្យ មនោសម្ផស្សសូន្យ មួយទៀត សូម្បីធម្មជាតសម្រាប់ទទួលអារម្មណ៍ណា ជាសុខ ឬជាទុក្ខ ឬមិនជាទុក្ខមិនជាសុខ កើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ ធម្មជាតនោះ ក៏សូន្យចាកខ្លួន ឬចាកវត្ថុសម្រាប់ខ្លួន ម្នាលអានន្ទ ព្រោះហេតុតែធម្មជាតសូន្យចាកខ្លួន ឬចាកវត្ថុសម្រាប់ខ្លួន ទើបតថាគតពោលថា លោកសូន្យ ។ បុគ្គលសំឡឹងឃើញលោក ដោយសភាពជារបស់សូន្យ យ៉ាងនេះឯង ។

សុទ្ធំ ធម្មសមុប្បាទំ   សុទ្ធំ សង្ខារសន្តតឹ
បស្សន្តស្ស យថាភូតំ   ន ភយំ ហោតិ គាមណិ
តិណកដ្ឋសមំ លោកំ   យទា បញ្ញាយ បស្សតិ
ន អញ្ញំ បត្ថយេ កិញ្ចិ   អញ្ញត្រ អប្បដិសន្ធិយាតិ ។

ឯវម្បិ សុញ្ញតោ លោកំ អវេក្ខតិ ។

វុត្តញ្ហេតំ ភគវតា ឯវមេវ ភិក្ខវេ ភិក្ខុ រូបំ សមន្នេសតិ យាវតា រូបស្ស គតិ វេទនំ សមន្នេសតិ យាវតា វេទនាយ គតិ សញ្ញំ សមន្នេសតិ យាវតា សញ្ញាយ គតិ សង្ខារេ សមន្នេសតិ យាវតា សង្ខារានំ គតិ វិញ្ញាណំ សមន្នេសតិ យាវតា វិញ្ញាណស្ស គតិ តស្ស ភិក្ខុនោ រូបំ សមន្នេសតោ យាវតា រូបស្ស គតិ វេទនំ សមន្នេសតោ យាវតា វេទនាយ គតិ សញ្ញំ សមន្នេសតោ យាវតា សញ្ញាយ គតិ សង្ខារេ សមន្នេសតោ យាវតា សង្ខារានំ គតិ

ម្នាលគាមណិ កាលបុគ្គលឃើញ តាមពិត នូវការកើតឡើងនៃធម៌ដ៏បរិសុទ្ធ នឹងការដាច់តនៃសង្ខារដ៏បរិសុទ្ធ ភ័យនោះមិនមានទេ កាលណាបុគ្គលឃើញលោក ថាស្មើគ្នានឹងស្មៅឬឈើ ដោយប្រាជ្ញា បុគ្គលមិនគប្បីប្រាថ្នារបស់ដទៃណាមួយឡើយ វៀរលែងតែព្រះនិព្វានដែលមិនមានបដិសន្ធិ ។ បុគ្គលសំឡឹងឃើញលោក ដោយសភាពជារបស់សូន្យ យ៉ាងនេះឯង ។

មួយទៀត ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះមែនហើយ ភិក្ខុស្វែងរករូប រហូតដល់ដំណើររបស់រូប ស្វែងរកវេទនា រហូតដល់ដំណើររបស់វេទនា ស្វែងរកសញ្ញា រហូតដល់ដំណើររបស់សញ្ញា ស្វែងរកសង្ខារទាំងឡាយ រហូតដល់ដំណើររបស់សង្ខារទាំងឡាយ ស្វែងរកវិញ្ញាណ រហូតដល់ដំណើររបស់វិញ្ញាណ កាលភិក្ខុនោះ ស្វែងរករូប រហូតដល់ដំណើររបស់រូប ស្វែងរកវេទនា រហូតដល់ដំណើររបស់វេទនា ស្វែងរកសញ្ញា រហូតដល់ដំណើររបស់សញ្ញា ស្វែងរកសង្ខារទាំងឡាយ រហូតដល់ដំណើររបស់សង្ខារទាំងឡាយ

វិញ្ញាណំ សមន្នេសតោ យាវតា វិញ្ញាណស្ស គតិ យម្ហិ យស្ស ហោតិ អហន្តិ វា មមន្តិ វា អស្មីតិ វា តម្ហិ តស្ស ច ហោតីតិ ។ ឯវម្បិ សុញ្ញតោ លោកំ អវេក្ខតិ ។

សុញ្ញតោ លោកំ អវេក្ខស្សូតិ សុញ្ញតោ លោកំ អវេក្ខស្សុ បច្ចវេក្ខស្សុ តុលេហិ តីរេហិ វិភាវេហិ វិភូតំ ករោហីតិ សុញ្ញតោ លោកំ អវេក្ខស្សុ ។

(៧៤) មោឃរាជ សទា សតោតិ មោឃរាជាតិ ភគវា តំ ព្រាហ្មណំ នាមេន អាលបតិ ។ សទាតិ សព្វកាលំ ។ បេ ។ បច្ឆិមេ វយោខន្ធេ ។ សតោតិ ចតូហិ ការណេហិ សតោ កាយេ កាយានុបស្សនាសតិបដ្ឋានំ ភាវេន្តោ សតោ ។ បេ ។ សោ វុច្ចតិ សតោតិ មោឃរាជ សទា សតោ ។

ស្វែងរកវិញ្ញាណ រហូតដល់ដំណើរ របស់វិញ្ញាណ សេចក្តីប្រកាន់ណា របស់ភិក្ខុណាថា អញក្តី របស់អញក្តី អញមានក្តី សូម្បីសេចក្តីប្រកាន់នោះ របស់ភិក្ខុនោះ ក៏មិនមានទេ ។ បុគ្គលសំឡឹងឃើញលោក ដោយសភាពជារបស់សូន្យ យ៉ាងនេះឯង ។

ពាក្យថា អ្នកចូរសំឡឹងឃើញលោក ដោយសភាពជារបស់សូន្យ គឺអ្នកចូរសំឡឹងមើល ចូរពិចារណា ចូរប្រៀបផ្ទឹម ចូររំពឹង ចូរធ្វើឲ្យប្រាកដ ចូរធ្វើឲ្យច្បាស់លាស់ នូវលោក ដោយសភាពជារបស់សូន្យ ហេតុនោះ (ទ្រង់ត្រាស់ថា) អ្នកចូរសំឡឹងឃើញលោក ដោយសភាពជារបស់សូន្យ ។

[៧៨] ពាក្យថា មោឃរាជ របស់បទថា ម្នាលមោឃរាជ អ្នកចូរមានស្មារតីគ្រប់កាល គឺព្រះមានព្រះភាគ ត្រាស់ហៅព្រាហ្មណ៍នោះចំឈ្មោះ ។ ពាក្យថា គ្រប់កាល គឺអស់កាលទាំងពួង ។ បេ ។ ក្នុងគំនរវ័យជាបំផុត ។ ពាក្យថា មានស្មារតី គឺមានស្មារតីដោយហេតុ ៤ គឺកំពុងចម្រើនកាយានុបស្សនាសតិប្បដ្ឋានក្នុងកាយ ឈ្មោះថាមានស្មារតី ។ បេ ។ បុគ្គលនោះ លោកហៅថា មានស្មារតី ហេតុនោះ (ទ្រង់ត្រាស់ថា) ម្នាលមោឃរាជ អ្នកចូរមានស្មារតី គ្រប់កាល ។

(៧៥) អត្តានុទិដ្ឋី ឧហច្ចាតិ អត្តានុទិដ្ឋិ វុច្ចតិ វីសតិវត្ថុកា សក្កាយទិដ្ឋិ ។ ឥធ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្មស្ស អកោវិទោ អរិយធម្មេ អវិនីតោ សប្បុរិសានំ អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិសធម្មេ អវិនីតោ រូបំ អត្តតោ សមនុបស្សតិ រូបវន្តំ វា អត្តានំ អត្តនិ វា រូបំ រូបស្មឹ វា អត្តានំ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ អត្តតោ សមនុបស្សតិ វិញ្ញាណវន្តំ វា អត្តានំ អត្តនិ វា វិញ្ញាណំ វិញ្ញាណស្មឹ វា អត្តានំ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ទិដ្ឋិគហនំ ទិដ្ឋិកន្តារោ ទិដ្ឋិវិសូកាយិកំ ទិដ្ឋិវិប្ផន្ទិតំ ទិដ្ឋិសំយោជនំ គាហោ បតិដ្ឋាហោ អភិនិវេសោ បរាមាសោ កុម្មគ្គោ មិច្ឆាបថោ មិច្ឆត្តំ តិត្ថាយតនំ វិបរិយេសគ្គាហោ វិបរីតគ្គាហោ វិបល្លាសគ្គាហោ មិច្ឆាគាហោ អយាថាវកស្មឹ យាថាវកន្តិ គាហោ យាវតា ទ្វាសដ្ឋិ ទិដ្ឋិគតានិ អយំ អត្តានុទិដ្ឋិ ។ អត្តានុទិដ្ឋី ឧហច្ចាតិ អត្តានុទិដ្ឋី ឧហច្ច សមុហច្ច ឧទ្ធរិត្វា សមុទ្ធរិត្វា ឧប្បាដយិត្វា សមុប្បាដយិត្វា បជហិត្វា វិនោទេត្វា

## មោឃរាជមាណវកប្បញ្ហានិទ្ទេស

(៧៥) ពាក្យថា បុគ្គលដកអត្តានុទិដ្ឋិចេញ អធិប្បាយថា សក្កា-
យទិដ្ឋិ មានវត្ថុ ២០ លោកហៅថា អត្តានុទិដ្ឋិ ។ បុថុជ្ជន អ្នកមិនចេះ
ដឹងក្នុងលោកនេះ មិនឃើញពួកព្រះអរិយៈ មិនឈ្លាសវៃចំពោះអរិយ-
ធម៌ មិនបានទូន្មានខ្លួន ក្នុងអរិយធម៌ មិនឃើញពួកសប្បុរស មិន
ឈ្លាសវៃចំពោះសប្បុរសធម៌ មិនបានទូន្មានខ្លួនក្នុងសប្បុរសធម៌ រមែង
ពិចារណាឃើញនូវរូបថាខ្លួន នូវខ្លួនថាមានរូបខ្លះ នូវរូបក្នុងខ្លួនខ្លះ នូវខ្លួន
ក្នុងរូបខ្លះ ពិចារណាឃើញ នូវវេទនា សញ្ញា សង្ខារ វិញ្ញាណថាខ្លួន
នូវខ្លួនថាមានវិញ្ញាណខ្លះ នូវវិញ្ញាណក្នុងខ្លួនខ្លះ នូវខ្លួនក្នុងវិញ្ញាណខ្លះ
សេចក្ដីឃើញ សេចក្ដីយល់ ការប្រកាន់តាមយល់ ផ្លូវដាច់ស្រយាល
គឺទិដ្ឋិ សត្រូវ គឺទិដ្ឋិ ការញាប់ញ័រ គឺទិដ្ឋិ សំយោជនៈ គឺទិដ្ឋិ ការ
ប្រកាន់ ការប្រកាន់មាំ ការប្រកាន់ស្អិត ការបបោសអង្អែល ផ្លូវអាក្រក់
ផ្លូវខុស សេចក្ដីខុស លទ្ធិដូចជាកំពង់ ការប្រកាន់ឆ្វេង ការប្រកាន់
យៀងឃ្លាត ការប្រកាន់វិបល្លាស ការប្រកាន់ខុស ការប្រកាន់ថាពិត
ក្នុងរបស់មិនពិត ទិដ្ឋិ ៦២ ទាំងប៉ុន្មាន យ៉ាងនេះ ឯណា នេះជាអត្តានុ-
ទិដ្ឋិ ។ ពាក្យថា បុគ្គល ដកអត្តានុទិដ្ឋិចេញ គឺ ដក ដករំលើង
កើប កើបរំលើង គាស់ គាស់រំលើង លះបង់ បន្ទោបង់

ព្យន្តីកត្វា អនភាវង្គមេត្វាតិ អត្តានុទិដ្ឋឹ ឩហច្ច ។

(៧៦) ឯវំ មច្ចុតរោ សិយាតិ ឯវំ មច្ចុម្បិ តរេយ្យាសិ ជរម្បិ តរេយ្យាសិ មរណម្បិ តរេយ្យាសិ ឧត្តរេយ្យាសិ សមតិក្កមេយ្យាសិ វីតិវត្តេយ្យាសីតិ ឯវំ មច្ចុតរោ សិយា ។

(៧៧) ឯវំ លោកំ អវេក្ខន្តន្តិ ឯវំ លោកំ អវេក្ខន្តំ បច្ចវេក្ខន្តំ តុលយន្តំ តីរយន្តំ វិភាវយន្តំ វិភូតំ ករោន្តន្តិ ឯវំ លោកំ អវេក្ខន្តំ ។

(៧៨) មច្ចុរាជា ន បស្សតីតិ មារោបិ មច្ចុរាជា មរណម្បិ មច្ចុរាជា ។ ន បស្សតីតិ មច្ចុរាជា ន បស្សតិ ន ទក្ខតិ នាធិគច្ឆតិ ន វិន្ទតិ ន បដិល-ភតិ ។ វុត្តញ្ហេតំ ភគវតា សេយ្យថាបិ ភិក្ខវេ អារញ្ញ-កោ មិគោ អរញ្ញេ បវនេ ចរមានោ វិស្សត្ថោ គច្ឆតិ វិស្សត្ថោ តិដ្ឋតិ វិស្សត្ថោ និសីទតិ វិស្សត្ថោ សេយ្យំ

ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនមានបែបភាព នៃអត្តានុទិដ្ឋិ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលដកអត្តានុទិដ្ឋិចេញ ។

(៧៦) ពាក្យថា ទើបឆ្លងផុតចាកមច្ចុ យ៉ាងនេះ គឺនឹងឆ្លងចាកមច្ចុផង ឆ្លងចាកជរាផង ឆ្លង ឆ្លងឡើង ឆ្លងរំលង ប្រព្រឹត្តកន្លងមរណៈផង យ៉ាងនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) ទើបឆ្លងផុតចាកមច្ចុ យ៉ាងនេះ ។

(៧៧) ពាក្យថា បុគ្គលសំឡឹងឃើញនូវលោកយ៉ាងនេះ គឺបុគ្គលកំពុងសំឡឹងមើល ពិចារណា ប្រៀបផ្ទឹម ត្រិះរិះ ធ្វើឲ្យច្បាស់ ធ្វើឲ្យប្រាកដនូវលោក យ៉ាងនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលសំឡឹងឃើញលោក យ៉ាងនេះ ។

(៧៨) ពាក្យថា មច្ចុរាជទើបមិនឃើញ អធិប្បាយថា មារឈ្មោះថាមច្ចុរាជ សេចក្តីស្លាប់ ឈ្មោះថាមច្ចុរាជ ។ ពាក្យថា មិនឃើញ គឺមច្ចុរាជ មិនឃើញ មិនយល់ មិនជួបប្រទះ មិនបាន មិនបានចំពោះ ។ ដូចព្រះពុទ្ធដីកា ដែលព្រះមានព្រះភាគត្រាស់ហើយនេះថា ម្នាលភិក្ខុទាំងឡាយ ដូចម្រឹគដែលនៅក្នុងព្រៃ ត្រាច់ទៅក្នុងព្រៃធំ រមែងដើរឥតរង្កៀស ឈរឥតរង្កៀស អង្គុយឥតរង្កៀស ដេកឥតរង្កៀស

កាប្យេតិ តំ តិស្ស ហោតុ អនាសាទគតោ ភិក្ខវេ លុទ្ទស្ស(១) ឯវមេវ ខោ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អន្ធមកាសិ មារំ អបទំ(២) វធិត្វា មារចក្ខុំ អទស្សនំ គតោ បាបិមតោ បុនចបរំ ភិក្ខវេ ភិក្ខុ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ តតិយំ ឈានំ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ អយំ ភិក្ខវេ ភិក្ខុ អន្ធមកាសិ មារំ អបទំ វធិត្វា មារចក្ខុំ អទស្សនំ គតោ បាបិមតោ បុនចបរំ ភិក្ខវេ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អន្ធមកាសិ មារំ អបទំ វធិត្វា

១ ម. ទុក្ខស្ស ។ ២ ម. អបរំ ។

ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះម្រឹគនុះមិន នៅក្នុងគន្លងរបស់ព្រាន យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុស្ងាត់ ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយចូលបឋម-ជ្ឈាន ដែលមានវិតក្កៈនឹងវិចារៈ មានបីតិនិងសុខ ដែលកើតអំពីសេចក្តី ស្ងប់ស្ងាត់ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថាបានធ្វើមារឲ្យ ខ្វាក់ សម្រាប់មិនឲ្យមានស្នាមជើង ដល់នូវការមិនឃើញដោយភ្នែកនៃ មារដែលមានចិត្តបាប ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុ ព្រោះរម្ងាប់ វិតក្កៈនឹងវិចារៈ ចូលទុតិយជ្ឈាន ជាធម្មជាតកើតមាន ក្នុងសន្តាន ប្រកបដោយសេចក្តីជ្រះថ្លា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ នឹងវិចារៈ មានតែបីតិនិងសុខ ដែលកើតអំពីសមាធិ ចូលតតិយជ្ឈាន ចតុត្ថជ្ឈាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថា បានធ្វើ នូវមារ ឲ្យខ្វាក់ សម្រាប់មិនឲ្យមានស្នាមជើង ដល់នូវការមិនឃើញ ដោយភ្នែកនៃមារ ដែលមានចិត្តបាប ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុ ព្រោះកន្លងរូបសញ្ញា ដោយសព្វគ្រប់ ធ្វើបដិឃសញ្ញាឲ្យវិនាស មិនធ្វើទុកក្នុងចិត្ត នូវនានត្តសញ្ញា ហើយចូលអាកាសានញ្ចាយតនៈ ដោយបរិកម្មថា អាកាស មិនមានទីបំផុត ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថា បានធ្វើមារឲ្យខ្វាក់ សម្រាប់ មិនឲ្យមានស្នាមជើង

## ពោសាលមាណវកប្បញ្ហានិទ្ទេសោ

មារចក្ខុអទស្សនំ គតោ បាបិមតោ បុនចបរំ ភិក្ខវេ ភិក្ខុ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ បញ្ញាយ ចស្ស ទិស្វា អាសវា បរិក្ខីណា ហោន្តិ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អន្ធមកាសិ មារំ អបទំ វធិត្វា មារចក្ខុអទស្សនំ គតោ បាបិមតោ តិណ្ណោ លោកេ វិសត្តិកំ សោ វិស្សត្ថោ គច្ឆតិ វិស្សត្ថោ តិដ្ឋតិ វិស្សត្ថោ និសីទតិ វិស្សត្ថោ សេយ្យំ កប្បេតិ តំ កិស្ស ហេតុ អនាបាថគតោ ភិក្ខវេ បាបិមតោតិ មច្ចុរាជា ន បស្សតិ ។ តេនាហ ភគវា

ដល់នូវការមិនឃើញដោយភ្នែកនៃមារដែលមានចិត្តបាប ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុ កន្លងអាកាសានញ្ចាយតនៈដោយសព្វគ្រប់ ហើយចូលវិញ្ញាណញ្ចាយតនៈដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុត កន្លងវិញ្ញាណញ្ចាយតនៈដោយសព្វគ្រប់ ហើយចូលអាកិញ្ចញ្ញាយតនៈដោយបរិកម្មថា អ្វីតិចតួចមិនមាន កន្លងអាកិញ្ចញ្ញាយតនៈដោយសព្វគ្រប់ ហើយចូលនេវសញ្ញានាសញ្ញាយតនៈ កន្លងនេវសញ្ញានាសញ្ញាយតនៈដោយសព្វគ្រប់ ហើយចូលសញ្ញាវេទយិតនិរោធ លុះភិក្ខុនោះ បានឃើញដោយប្រាជ្ញា អាសវៈទាំងឡាយ ក៏អស់រលីង ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថា បានធ្វើមារឲ្យខ្វាក់ សម្លាប់មិនឲ្យមានស្នាមជើង ដល់នូវការមិនឃើញដោយភ្នែក នៃមារដែលមានចិត្តបាប ឆ្លងតណ្ហា ឈ្មោះវិសត្តិកាក្នុងលោកបាន ភិក្ខុនោះ រមែងដើរឥតរង្កៀស ឈរឥតរង្កៀស អង្គុយឥតរង្កៀស ដេកឥតរង្កៀស ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុនោះមិនទៅក្នុងគន្លង របស់មារមានចិត្តបាប ក៏យ៉ាងនោះដែរ ហេតុនោះ (ទ្រង់ត្រាស់ថា) មច្ចុរាជ ទើបមិនឃើញ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

សុញ្ញតោ លោកំ អវេក្ខស្សុ មោឃរាជ សទា

សតោ

អត្តានុទិដ្ឋឹ ឩហច្ច ឯវំ មច្ចុតរោ សិយា

ឯវំ លោកំ អវេក្ខន្តំ មច្ចុរាជា ន បស្សតីតិ ។

សហ គាថាបរិយោសានា ។ បេ ។ សត្ថា មេ ភន្តេ

ភគវា សាវកោហមស្មីតិ ។

មោឃរាជមាណវកបញ្ហានិទ្ទេសោ បណ្ណរសមោ ។

ម្នាលមោឃរាជ អ្នកចូរមានស្មារតីគ្រប់កាល សំឡឹងឃើញលោក ដោយសភាពជារបស់សូន្យ (ព្រោះ) បុគ្គលដកអត្តានុទិដ្ឋិចេញ ទើបឆ្លងផុតចាកមច្ចុ បុគ្គលសំឡឹងឃើញលោកយ៉ាងនេះ មច្ចុរាជទើបមិនឃើញ ។

ព្រមដោយការចប់គាថា ។ បេ ។ បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ ជាសាស្ដារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គសូមជាសាវ័ក ។

ចប់ មោឃរាជមាណវកបញ្ហានិទ្ទេស ទី ១៥ ។

# បិង្គិយមាណវកប្បញ្ហានិទ្ទេសោ

(៧៩) ជិណ្ណោហមស្មិ អពលោ វិវណ្ណោ

(ឥច្ចាយស្មា បិង្គិយោ)

នេត្តា ន សុទ្ធា សវនំ ន ផាសុ
មាហម្បនស្សំ មោមុហោ អន្តរាយ
អាចិក្ខ ធម្មំ យមហំ វិជញ្ញំ
ជាតិជ្ជរាយ ឥធ វិប្បហានំ ។

(៨០) ជិណ្ណោហមស្មិ អពលោ វិវណ្ណោតិ ជិណ្ណោ វុឌ្ឍោ(១) មហល្លកោ អទ្ធគតោ វយោអនុប្បត្តោ វីសវស្សសតិកោ ជាតិយា ។ អពលោតិ ទុព្វលោ អប្បពលោ អប្បថាមោ ។ វិវណ្ណោតិ វីតវណ្ណោ វិគតវណ្ណោ យា សា បុរិមា សុភា វណ្ណនិភា សា អន្តរហិតា អាទីនវោ បាតុភូតោតិ ជិណ្ណោហមស្មិ អពលោ វិវណ្ណោ ។ ឥច្ចាយស្មា បិង្គិយោតិ ឥច្ចាតិ បទសន្ធិ ។ អាយស្មាតិ បិយវចនំ ។

---

១ ម. វីតវណ្ណោតិ ជិណ្ណោហមស្មីតិ ជិណ្ណោ វុឌ្ឍោ ។

# បិង្គិយមាណវកបញ្ហានិទ្ទេស

(៧៩) (បិង្គិយៈមានអាយុ ក្រាបទូលដូច្នេះថា) ខ្ញុំព្រះអង្គជាមនុស្សគ្រាំគ្រា មានកំឡាំងខ្សោយ ប្រាសចាកសម្បុរ ទាំងភ្នែកក៏មិនស្អាត ការស្តាប់(១)ក៏មិនស្រួល សូមកុំឲ្យខ្ញុំព្រះអង្គជាបុគ្គលវង្វេង ខូចក្នុងចន្លោះឡើយ ខ្ញុំព្រះអង្គគប្បីដឹងធម៌ណា ដែលជាគ្រឿងលះបង់ជាតិនឹងជរា ក្នុងទីនេះ សូមព្រះអង្គត្រាស់ប្រាប់ធម៌នោះឲ្យទាន ។

(៨០) ពាក្យថា ខ្ញុំព្រះអង្គជាមនុស្សគ្រាំគ្រា មានកំឡាំងខ្សោយ ប្រាសចាកសម្បុរ គឺជាមនុស្សគ្រាំគ្រា ចម្រើនហើយ មានអាយុច្រើន រស់នៅបានយូរឆ្នាំមកហើយ មានវ័យដល់ហើយតាមលំដាប់ មានអាយុ១២០ឆ្នាំអំពីកំណើត ។ ពាក្យថា មានកំឡាំងខ្សោយ គឺ មានកំឡាំងថយ មានកំឡាំងកាយតិច មានកំឡាំងចិត្តតិច ។ ពាក្យថា ប្រាសចាកសម្បុរ គឺ ប្រាសចាកសម្បុរ បាត់សម្បុរ ពន្នឹសម្បុរដ៏ល្អណា មានក្នុងកាលមុន ពន្នឹសម្បុរដ៏ល្អនោះបាត់ទៅ ទោសក៏កើតប្រាកដ ហេតុនោះ (លោកពោលថា) ខ្ញុំព្រះអង្គជាមនុស្សគ្រាំគ្រា មានកំឡាំងខ្សោយ ប្រាសចាកសម្បុរ ។ ពាក្យថា បិង្គិយៈមានអាយុក្រាបទូលដូច្នេះ ត្រង់ពាក្យថា ដូច្នេះ គឺជាការតបទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ។

---

១ ត្រចៀក

បិង្គិយោតិ តស្ស ព្រាហ្មណស្ស នាមំ ។ បេ ។ អភិលាបោតិ ឥច្ចាយស្មា បិង្គិយោ ។

(៨១) នេត្តា ន សុទ្ធា សវនំ ន ផាសូតិ នេត្តា អសុទ្ធា អវិសុទ្ធា អបរិសុទ្ធា អវោទាតា នោ តថា ចក្ខុនា រូបំ បស្សាមីតិ នេត្តា ន សុទ្ធា ។ សវនំ ន ផាសូតិ សោតំ អសុទ្ធំ អវិសុទ្ធំ អបរិសុទ្ធំ អវោទាតំ នោ តថា សោតេន សទ្ទំ សុណោមីតិ នេត្តា ន សុទ្ធា សវនំ ន ផាសុ ។

(៨២) មាហម្បនស្សំ មោមុហោ អន្តរាយាតិ មាហំ នស្សំ បនស្សំ វិនស្សំ(១) ។ មោមុហោតិ អវិទ្វា អវិជ្ជាគតោ អញ្ញាណី អវិភាវី ទុប្បញ្ញោ ។ អន្តរាយាតិ តុយ្ហំ ធម្មំ ទិដ្ឋិំ បដិបទំ មគ្គំ អនញ្ញាយ អនាវិកត្វា អវិទិតំ កត្វា អប្បដិលភិត្វា អផុសយិត្វា អសច្ឆិកត្វា អន្តរាយេវ កាលំ ករេយ្យន្តិ មាហម្បនស្សំ មោមុហោ អន្តរាយ ។

---

១ ម. នស្សន្តិ មាហំ នស្សំ មាហំ វិនស្សំ មាហំ បនស្សំ ។

ពាក្យថា បិង្គិយៈ ជាឈ្មោះ ។បេ។ ជាពាក្យសម្រាប់ហៅព្រាហ្មណ៍នោះ ហេតុនោះ (ទើបមានពាក្យថា) បិង្គិយៈ មានអាយុក្រាបទូលដូច្នេះ ។

(៨១) ពាក្យថា ភ្នែកមិនស្អាត ការស្ដាប់មិនស្រួល គឺភ្នែកទាំងពីរ មិនស្អាត មិនម៉ត់ចត់ មិនបរិសុទ្ធ មិនផូរផង់ គឺខ្ញុំព្រះអង្គ មិនឃើញរូបដោយភ្នែក ដោយប្រការដូច្នោះ ហេតុនោះ (លោកពោលថា) ភ្នែកមិនស្អាត ។ ពាក្យថា ការស្ដាប់មិនស្រួល គឺត្រចៀកមិនស្អាត មិនម៉ត់ចត់ មិនបរិសុទ្ធ មិនផូរផង់ គឺខ្ញុំព្រះអង្គ មិនឮសំឡេងដោយត្រចៀក ដោយប្រការដូច្នោះ ហេតុនោះ (លោកពោលថា) ភ្នែកមិនស្អាត ការស្ដាប់មិនស្រួល ។

(៨២) ពាក្យថា សូមកុំឲ្យខ្ញុំព្រះអង្គជាបុគ្គលវង្វេង ខូចក្នុងចន្លោះឡើយ គឺសូមកុំឲ្យខ្ញុំព្រះអង្គលាញ ខូច វិនាសឡើយ ។ ពាក្យថា ជាបុគ្គលវង្វេង គឺជាបុគ្គលមិនយល់ ដល់នូវសេចក្ដីល្ងង់ខ្លៅ មិនដឹង មិនវាងវៃ ឥតប្រាជ្ញា ។ ពាក្យថា ក្នុងចន្លោះ គឺខ្ញុំព្រះអង្គមិនដឹង មិនធ្វើឲ្យជាក់ច្បាស់ មិនធ្វើឲ្យប្រាកដ មិនបានចំពោះ មិនពាល់ត្រូវ មិនធ្វើឲ្យជាក់ច្បាស់ នូវធម៌ ទិដ្ឋិ បដិបទា មគ្គ របស់ព្រះអង្គ ហើយធ្វើមរណកាល ក្នុងចន្លោះ ហេតុនោះ (លោកពោលថា) សូមកុំឲ្យខ្ញុំព្រះអង្គជាបុគ្គលវង្វេង ខូចក្នុងចន្លោះឡើយ ។

(៨៣) អាចិក្ខ ធម្មំ យមហំ វិជញ្ញន្តិ អាចិក្ខ ធម្មន្តិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ ចត្តារោ សតិបដ្ឋានេ ចត្តារោ សម្មប្បធានេ ចត្តារោ ឥទ្ធិបាទេ បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គេ អរិយំ អដ្ឋង្គិកំ មគ្គំ និព្វានញ្ច និព្វានគាមិនិញ្ច បដិបទំ អាចិក្ខ ទេសេហិ បញ្ញបេហិ បដ្ឋបេហិ វិវរហិ វិភជាហិ ឧត្តានីករោហិ បកាសេហីតិ អាចិក្ខ ធម្មំ ។ យមហំ វិជញ្ញន្តិ យមហំ ជានេយ្យំ វិជានេយ្យំ បដិវិជានេយ្យំ បដិវិជ្ឈេយ្យំ អធិគច្ឆេយ្យំ ផុសេយ្យំ សច្ឆិករេយ្យន្តិ អាចិក្ខ ធម្មំ យមហំ វិជញ្ញំ ។

(៨៤) ជាតិជរាយ ឥធ វិប្បហានន្តិ ឥធេវ ជាតិជរាមរណស្ស បហានំ វូបសមោ បដិនិស្សគ្គោ បដិប្បស្សទ្ធិ អមតំ និព្វានន្តិ ជាតិជរាយ ឥធ វិប្បហានំ ។ តេនាហ សោ ព្រាហ្មណោ

## បិង្គិយមាណវកបញ្ហានិទ្ទេស

(៨៣) អធិប្បាយពាក្យថា ខ្ញុំព្រះអង្គគប្បីដឹងធម៌ណា សូមព្រះអង្គត្រាស់ប្រាប់ធម៌នោះ ត្រង់ពាក្យថា សូមព្រះអង្គត្រាស់ប្រាប់ធម៌នោះ គឺ សូមព្រះអង្គប្រាប់ សំដែង បញ្ញត្ត តាំងផ្ដើម បើក វែកញែក ធ្វើឲ្យរាក់ ប្រកាសនូវព្រហ្មចរិយៈ មានពីរោះបទដើម ពីរោះបទកណ្ដាល ពីរោះបទចុង ព្រមទាំងអត្ថ ព្រមទាំងព្យញ្ជនៈ ដ៏ពេញ បរិបូណ៌ បរិសុទ្ធទាំងអស់ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ និព្វាន នឹងនិព្វានគាមិនីបដិបទា ហេតុនោះ (លោកពោលថា) សូមព្រះអង្គត្រាស់ប្រាប់ធម៌នោះ ។ ពាក្យថា ខ្ញុំព្រះអង្គគប្បីដឹងធម៌ណា គឺខ្ញុំព្រះអង្គគប្បីដឹង យល់ច្បាស់ ដឹងច្បាស់លាស់ ចាក់ធ្លុះចំពោះ បានលុះ ពាល់ត្រូវ ធ្វើឲ្យជាក់ច្បាស់ នូវធម៌ណា ហេតុនោះ (លោកពោលថា) ខ្ញុំព្រះអង្គគប្បីដឹងធម៌ណា សូមព្រះអង្គត្រាស់ប្រាប់ធម៌នោះ ។

(៩៤) ពាក្យថា ជាគ្រឿងលះបង់ជាតិនឹងជរា ក្នុងទីនេះ គឺការលះបង់ រម្ងាប់បង់ រលាស់ចោល រម្ងាប់នូវជាតិជរា នឹងមរណៈ ក្នុងទីនេះឯង គឺអមតនិព្វាន ហេតុនោះ (លោកពោលថា) ជាគ្រឿងលះបង់ជាតិនឹងជរា ក្នុងទីនេះ ។ ហេតុនោះ ព្រាហ្មណ៍នោះ ពោលថា

ជិណ្ណោហមស្មិ អពលោ វីវណ្ណោ

(ឥច្ចាយស្មា បិង្គិយោ)

នេត្តា ន សុទ្ធា សវនំ ន ផាសុ

មាហំ នស្សំ មោមុហោ អន្តរាយ

អាចិក្ខ ធម្មំ យមហំ វិជញ្ញំ

ជាតិជ្ជរា ឥធ វិប្បហានន្តិ ។

(៨៥) ទិស្វាន រូបេសុ វិហញ្ញមានេ

(បិង្គិយាតិ ភគវា)

រុប្បន្តិ រូបេសុ ជនា បមត្តា

តស្មា តុវំ បិង្គិយ អប្បមត្តោ

ជហស្សុ រូបំ អបុនព្ភវាយ ។

(៨៦) ទិស្វាន រូបេសុ វិហញ្ញមានេតិ រូបេសូតិ ចត្តារោ ច មហាភូតា ចតុន្នញ្ច មហាភូតានំ ឧបាទាយរូបំ ។ សត្តា រូបហេតុ រូបប្បច្ចយា រូប-ការណា ហញ្ញន្តិ វិហញ្ញន្តិ ឧបហញ្ញន្តិ ឧបឃា-តយន្តិ រូបេ សតិ វិវិធកម្មការណា ការេន្តិ

(បិង្គិយៈមានកាយក្រាបទូលដូច្នេះថា) ខ្ញុំព្រះអង្គជាមនុស្ស គ្រាំគ្រា មានកម្លាំងខ្សោយ ប្រាសចាកសម្បុរ ទាំងភ្នែក ក៏មិនស្អាត ការស្តាប់ ក៏មិនស្រួល សូមកុំឲ្យខ្ញុំព្រះអង្គជាបុគ្គលវង្វេង ខូចក្នុងចន្លោះឡើយ ខ្ញុំព្រះអង្គគប្បីដឹងធម៌ណា ដែលជាគ្រឿងលះបង់ជាតិនិងជរា ក្នុងទីនេះ សូមព្រះអង្គត្រាស់ប្រាប់ធម៌នោះឲ្យទាន ។

(៨៥) (ព្រះមានព្រះភាគត្រាស់ថា ម្នាលបិង្គិយៈ) ពួកជនដែលប្រហែស ឃើញសត្វទាំងឡាយកំពុងលំបាក ព្រោះរូប ក៏លំបាកព្រោះរូប ម្នាលបិង្គិយៈ ហេតុនោះ អ្នកចូរជាបុគ្គលមិនប្រហែស លះបង់រូបទៅ ដើម្បីការមិនកើតទៀត ។

(៨៦) អធិប្បាយពាក្យថា ឃើញសត្វទាំងឡាយកំពុងលំបាកព្រោះរូប ត្រង់ពាក្យថា រូប បានដល់មហាភូតរូបបួនផង រូបដែលអាស្រ័យនឹងមហាភូតរូបបួនផង ។ សត្វទាំងឡាយលំបាក ឈឺចាប់ ក្តៅក្រហាយ បង្អៀតបង្អល់ ព្រោះហេតុនៃរូប ព្រោះរូបជាបច្ច័យ ព្រោះដំណើរនៃរូប កាលបើរូបមាន សត្វទាំងឡាយ ត្រូវគេធ្វើនូវកម្មការណ៍ផ្សេង ៗ

## បិង្គិយមាណវបុច្ឆានិទ្ទេសោ

កសាហិបិ តាឡេន្តិ វេត្តហិបិ តាឡេន្តិ អឌ្ឍទណ្ឌកេ-

ហិបិ តាឡេន្តិ ហត្ថម្បិ ឆិន្ទន្តិ បាទម្បិ ឆិន្ទន្តិ ហត្ថ-

បាទម្បិ ឆិន្ទន្តិ កណ្ណម្បិ ឆិន្ទន្តិ នាសម្បិ ឆិន្ទន្តិ

កណ្ណនាសម្បិ ឆិន្ទន្តិ ពិលង្គថាលិកម្បិ ការេន្តិ

សង្ខមុណ្ឌិកម្បិ ការេន្តិ រាហុមុខម្បិ ការេន្តិ ជោតិ-

មាលិកម្បិ ការេន្តិ ហត្ថប្បជ្ជោតិកម្បិ ការេន្តិ

ឯរកវត្តិកម្បិ ការេន្តិ ចីរកវាសិកម្បិ ការេន្តិ

ឯណេយ្យកម្បិ ការេន្តិ ពលិសមំសិកម្បិ ការេន្តិ

## បិង្គិយមាណវកប្បញ្ហានិទ្ទេស

*គឺវាយដោយរំពាត់ខ្លះ វាយដោយផ្តៅខ្លះ វាយដោយកំណាត់ឈើខ្លះ កាត់ដៃខ្លះ កាត់ជើងខ្លះ កាត់ដៃនឹងជើងខ្លះ កាត់ត្រចៀកខ្លះ កាត់ច្រមុះខ្លះ កាត់ត្រចៀកនឹងច្រមុះខ្លះ ធ្វើពិលង្គថាលិកកម្ម(១)ខ្លះ ធ្វើសង្ខមុណ្ឌកកម្ម(២)ខ្លះ ធ្វើរាហុមុខកម្ម(៣)ខ្លះ ធ្វើជោតិមាលិកកម្ម(៤)ខ្លះ ធ្វើហត្ថប្បជ្ជោតិកកម្ម(៥)ខ្លះ ធ្វើឯរកវត្តិកកម្ម(៦)ខ្លះ ធ្វើចិរកវាសិកកម្ម(៧)ខ្លះ ធ្វើឯណេយ្យកកម្ម(៨)ខ្លះ ធ្វើពលិសមំសិកកម្ម(៩)ខ្លះ*

---

១ បោះលលាក្បាលដាក់ដែកក្តៅឲ្យខួរពុះខ្ជោលឡើង ។ ២ ពន្លះស្បែកតាំងពីបបូរមាត់លើ, គុម្ពត្រចៀកសងខាង នឹងកញ្ចឹងកហើយខាត់ឆ្អឹងឲ្យរលីងដូចសម្បុរស័ង្ខ ។ ៣ យកកង្វារបើកមាត់ ហើយអុជភ្លើងក្នុងមាត់ ឬដាប់មាត់ឲ្យធ្លាយដល់គុម្ពត្រចៀកទាំងពីរ ធ្វើឲ្យឈាមហូរចេញតាមមាត់ ។ ៤ រុំខ្លួនទាំងអស់ដោយសំពត់ប្រេង ហើយដុត ។ ៥ រុំដៃទាំងពីរដោយសំពត់ប្រេងហើយដុត ។ ៦ ចៀរស្បែកជាចំរៀកតាំងពីកដល់កជើងហើយដឹកឲ្យដើរជាន់លើស្បែកខ្លួន ។ ៧ ចៀរស្បែកពីក ទុកត្រឹមចង្កេះ ហើយចៀរពីចង្កេះដល់កជើង ។ ៨ ស៊កក្រវិលដែកត្រង់កជើង នឹងជង្គង់ទាំងពីរ ហើយដោតនឹងបង្គោលដែកឲ្យអ្នកទោសឈរ ដុតភ្លើងជុំវិញ ។ ៩ យកកង្វារដែក មានមុខសងខាង ឆ្វារយកស្បែកសាច់សរសៃចេញ ។

តិស្សមេត្តេយ្យសុត្តនិទ្ទេសវណ្ណនា ។

កហាបណិកម្បិ ករោន្តិ ខារាបតច្ឆិកម្បិ ករោន្តិ
បលិឃបរិវត្តិកម្បិ ករោន្តិ បលាលបីឋកម្បិ ករោន្តិ
តត្តេនបិ តេលេន ឱសិញ្ចន្តិ សុនខេហិបិ ខាទាបេ-
ន្តិ ជីវន្តម្បិ សូលេ ឧត្តាសេន្តិ អសិនា សីសំ ឆិន្ទន្តិ ។
ឯវំ សត្តា រូបហេតុ រូបប្បច្ចយា រូបការណា ហញ្ញន្តិ
វិហញ្ញន្តិ ឧបហញ្ញន្តិ ឧបឃាតិយន្តិ ។ ឯវំ ហញ្ញ-
មានេ វិហញ្ញមានេ ទិស្វា បស្សិត្វា តុលយិត្វា តីរ-
យិត្វា វិភាវយិត្វា វិភូតំ កត្វាតិ ទិស្វាន រូបេសុ
វិហញ្ញមានេ ។ បិង្គិយាតិ ភគវា បិង្គិយាតិ ភគវា តំ
ព្រាហ្មណំ នាមេន អាលបតិ ។ ភគវាតិ គារវាធិវច-
នមេតំ ។ បេ ។ យទិទំ ភគវាតិ បិង្គិយាតិ ភគវា ។

ធ្វើកហាបណិកកម្ម(១)ខ្លះ ធ្វើខារាបតច្ឆិកកម្ម(២)ខ្លះ ធ្វើបលិឃបរិវត្តិកកម្ម(៣)ខ្លះ ធ្វើបលាលបីឋកកម្ម(៤)ខ្លះ ស្រោចដោយប្រេងដែលក្តៅខ្លះ ឲ្យឆ្កែខាំខ្លះ ឲ្យដេកផ្ងារលើឈើអណ្តោតទាំងរស់ខ្លះ កាត់ក្បាលដោយដាវខ្លះ ។ សត្វទាំងឡាយលំបាក ឈឺចាប់ ក្តៅក្រហាយ ចង្អៀតចង្អល់ ព្រោះរូបជាហេតុ ព្រោះរូបជាបច្ច័យ ព្រោះរូបជាដំណើរ ដោយប្រការយ៉ាងនេះ ។ ឃើញ ចួប ពិចារណា ត្រិះរិះ សំដែង ធ្វើឲ្យប្រាកដនូវសត្វទាំងឡាយ កំពុងលំបាក ក្តៅក្រហាយ យ៉ាងនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) ឃើញសត្វទាំងឡាយ កំពុងលំបាកព្រោះរូប ។ ពាក្យថា ម្នាលបិង្គិយៈ ក្នុងបទថា ព្រះមានព្រះភាគត្រាស់ថា ម្នាលបិង្គិយៈ គឺព្រះមានព្រះភាគ ត្រាស់ហៅព្រាហ្មណ៍នោះចំឈ្មោះ ។ ពាក្យថា ព្រះមានព្រះភាគ នុ៎ះជាពាក្យពោលដោយគោរព ។ បេ ។ បញ្ញត្តិថា ព្រះមានព្រះភាគ នេះ ហេតុនោះ (មានពាក្យថា) ព្រះមានព្រះភាគត្រាស់ថា ម្នាលបិង្គិយៈ ។

---

១ អារសាច់ម៉ុន ១ កហាបណៈ ។ ២ យកអាវុធប្រហារសរីរៈហើយយកទឹកក្រុតលាបកិនយកស្បែកសាច់សសៃចេញ ឲ្យនៅសល់តែរាងឆ្អឹង ។ ៣ ឲ្យដេកផ្អៀងហើយដោតដែកស្រួចត្រង់ត្រចៀក កប់ទៅនឹងផែនដី ហើយចាប់ជើងបង្វិល ។ ៤ ដំឆ្អឹងឲ្យខ្ទេចទាំងតែមិនឲ្យដាច់ស្បែកក្រៅហើយមូរសាច់ជាដុំរុំនឹងសក់ ។ តិស្សមេត្តេយ្យសុត្តនិទ្ទេសវណ្ណនា ។

## បិង្គិយមាណវបុច្ឆានិទ្ទេសោ

(៨៧) រុប្បន្តិ រូបេសុ ជនា បមត្តាតិ រុប្បន្តីតិ
រុប្បន្តិ កុប្បន្តិ បីឡយន្តិ ឃដ្ដយន្តិ ព្យាធិតា ទោម-
នស្សិតា ហោន្តិ ចក្ខុរោគេន រុប្បន្តិ កុប្បន្តិ បីឡ-
យន្តិ ឃដ្ដយន្តិ ព្យាធិតា ទោមនស្សិតា ហោន្តិ សោ-
តរោគេន ។ បេ ។ ឌំសមកសវាតាតបសិរឹសបសម្ផ-
ស្សេហិ រុប្បន្តិ កុប្បន្តិ បីឡយន្តិ ឃដ្ដយន្តិ ព្យាធិតា
ទោមនស្សិតា ហោន្តីតិ រុប្បន្តិ រូបេសុ ។ អថវា
ចក្ខុស្មឹ ហីយមានេ ហាយមានេ បរិហាយមានេ វេ-
មានេ វិគច្ឆមានេ អន្តរធាយមានេ រុប្បន្តិ ។ បេ ។
ទោមនស្សិតា ហោន្តិ សោតស្មឹ ឃានស្មឹ ជិវ្ហាយ
កាយស្មឹ រូបស្មឹ សទ្ទស្មឹ គន្ធស្មឹ រសស្មឹ ផោដ្ឋព្វស្មឹ
កុលស្មឹ គណស្មឹ អាវាសស្មឹ លាភស្មឹ យសស្មឹ ប-
សំសាយ សុខស្មឹ ចីវរស្មឹ បិណ្ឌបាតស្មឹ សេនាសន-
ស្មឹ គិលានប្បច្ចយភេសជ្ជបរិក្ខារស្មឹ ហីយមានេ ហា-
យមានេ បរិហាយមានេ វេមានេ វិគច្ឆមានេ អន្តរធា-
យមានេ រុប្បន្តិ កុប្បន្តិ បីឡយន្តិ ឃដ្ដយន្តិ ព្យាធិតា
ទោមនស្សិតា ហោន្តីតិ ឯវម្បិ រុប្បន្តិ រូបេសុ ។

## បិង្គិយមាណវកប្បញ្ហានិទ្ទេស

(៨៧) អធិប្បាយពាក្យថា ពួកជនដែលប្រហែស ក៏លំបាកព្រោះរូប ត្រង់ពាក្យថា លំបាក គឺលំបាក កម្រើក បៀតបៀន ខ្ពាំងខ្ពប់ ខ្វាច ដល់នូវទោមនស្ស ដោយពេគក្នុងភ្នែក លំបាក កម្រើក បៀតបៀន ខ្ពាំងខ្ពប់ ខ្វាច ដល់នូវទោមនស្ស ដោយពេគក្នុងត្រចៀក ។ បេ ។ លំបាក កម្រើក បៀតបៀន ខ្ពាំងខ្ពប់ ខ្វាច ដល់នូវទោមនស្ស ដោយសម្ផស្សនៃរបោម មូស ខ្យល់ កំដៅថ្ងៃ សត្វលូន ហេតុនោះ (ទ្រង់ត្រាស់ថា) ក៏លំបាកព្រោះរូប ។ មួយទៀត សត្វទាំងឡាយ កាលបើភ្នែក សាបសូន្យ បាត់បង់ រលប់រលាយ វិនាស ទៅប្រាស អន្តរធាន ក៏លំបាក ។ បេ ។ ដល់នូវទោមនស្ស សត្វទាំងឡាយ កាលត្រចៀក ច្រមុះ អណ្តាត កាយ រូប សំឡេង ក្លិន រស ផ្សព្វ ត្រកូល ពួក អាវាស លាភ យស សេចក្តីសរសើរ សុខ ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារ សាបសូន្យ បាត់បង់ រលប់រលាយ វិនាស ទៅប្រាស អន្តរធាន លំបាក កម្រើក ត្រូវសេចក្តីវិនាសបៀតបៀន ខ្ពាំងខ្ពប់ ខ្វាច ដល់នូវទោមនស្ស ហេតុនោះ (ទ្រង់ត្រាស់ថា) ក៏លំបាកព្រោះរូប យ៉ាងនេះក៏បាន ។

ជនាតិ ខត្តិយា ច ព្រាហ្មណា ច វេស្សា ច សុទ្ទា ច គហដ្ឋា ច បព្វជិតា ច ទេវា ច មនុស្សា ច ។ បមត្តាតិ បមាទោ វត្តព្វោ កាយទុច្ចរិតេ វា វចីទុច្ចរិតេ វា មនោទុច្ចរិតេ វា បញ្ចសុ វា កាមគុណេសុ ចិត្តស្ស វោស្សគ្គោ វោស្សគ្គានុប្បទានំ កុសលានំ វា ធម្មានំ ភាវនាយ អសាតច្ចកិរិយតា អនដ្ឋិតកិរិយតា ឱលីនវុត្តិតា និក្ខិត្តច្ឆន្ទតា និក្ខិត្តធុរតា អនាសេវនា អភាវនា អពហុលីកម្មំ អនធិដ្ឋានំ អននុយោគោ បមាទោ យោ ឯវរូបោ បមាទោ បមជ្ជនា បមជ្ជិតត្តំ អយំ វុច្ចតិ បមាទោ ។ ឥមិនា បមាទេន សមន្នាគតា ជនា បមត្តាតិ វុច្ចន្តិ រូបេសុ ជនា បមត្តា ។

(៨៨) តស្មា តុវំ បិង្គិយ អប្បមត្តោតិ តស្មាតិ តស្មា តំការណា តំហេតុ តប្បច្ចយា តំនិទានា ឯវំ អាទីនវំ សម្បស្សមានោ រូបេសូតិ តស្មា តុវំ បិង្គិយ ។

ពាក្យថា ពួកជន បានដល់ពួកក្សត្រ ព្រាហ្មណ៍ អ្នកជំនួញ អ្នកគ្រួ គ្រហស្ថ បព្វជិត ទេវតា មនុស្ស ។ ពាក្យថា ប្រហែស គឺការប្រហែស ខ្ញុំត្រូវពោលដូចតទៅនេះ ការបណ្តោយចិត្ត ការផ្តល់កម្លាំងដល់ការបណ្តោយចិត្តទៅ ក្នុងកាយទុច្ចរិត ក្នុងវចីទុច្ចរិត ក្នុងមនោទុច្ចរិត ឬក្នុងកាមគុណទាំង ៥ ក្តី ភាពនៃកិរិយាមិនធ្វើរឿយ ៗ ភាពនៃកិរិយាមិនតាំងនៅ ភាពនៃកិរិយាប្រព្រឹត្តធូរថយ ការដាក់ចុះនូវឆន្ទៈ ការដាក់ចុះនូវធុរៈ ការមិនសេព ការមិនចម្រើន ការមិនធ្វើឲ្យច្រើន ការមិនអធិដ្ឋាន ការមិនប្រកបរឿយ ៗ ក្នុងការចម្រើនធម៌ជាកុសលក្តី ឈ្មោះថាការប្រហែស សេចក្តីធ្វេសប្រហែស ការបណ្តែតបណ្តោយ ភាពនៃសេចក្តីភ្លេចភាំង ដែលមានសភាពយ៉ាងនេះ ឯណា នេះលោកហៅថា ការប្រហែស ។ ពួកជនប្រកបដោយសេចក្តីប្រហែសនេះ ឈ្មោះថា អ្នកប្រហែស ហេតុនោះ (ទ្រង់ត្រាស់ថា) ពួកជនប្រហែស ក៏លំបាកព្រោះរូប ។

(៨៨) ពាក្យថា ម្នាលបិង្គិយៈ ព្រោះហេតុនោះ អ្នកចូរជាបុគ្គលមិនប្រហែស ត្រង់ពាក្យថា ព្រោះហេតុនោះ គឺព្រោះហេតុដូច្នោះ ព្រោះការណ៍នោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ បុគ្គលកាលឃើញច្បាស់នូវទោស ក្នុងរូបយ៉ាងនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) ម្នាលបិង្គិយៈ ហេតុនោះ អ្នក(ចូរជាបុគ្គលមិនប្រហែស) ។

អប្បមត្តោតិ សក្កច្ចការី សាតច្ចការី ។ បេ ។ អប្បមត្តោ កុសលេសុ ធម្មេសូតិ តស្មា តុវំ បិង្គិយ អប្បមត្តោ ។

(៨៩) ជហស្សុ រូបំ អបុនព្ភវាយាតិ រូបន្តិ ចត្តារោ ច មហាភូតា ចតុន្នញ្ច មហាភូតានំ ឧបាទាយរូបំ ។ ជហស្សុ រូបន្តិ រូបំ ជហស្សុ រូបំ បជហស្សុ រូបំ វិនោទេហិ រូបំ ព្យន្តីករោហិ រូបំ អនភាវង្គមេហីតិ ជហស្សុ រូបំ ។ អបុនព្ភវាយាតិ យថា តេ រូបំ ឥធេវ និរុជ្ឈេយ្យ បុន បដិសន្ធិកោ ន និព្វត្តេយ្យ កាមធាតុយា វា រូបធាតុយា វា អរូបធាតុយា វា កាមភវេ វា រូបភវេ វា អរូបភវេ វា សញ្ញាភវេ វា អសញ្ញាភវេ វា នេវសញ្ញានាសញ្ញាភវេ វា ឯកវោការភវេ វា ចតុវោការភវេ វា បញ្ចវោការភវេ វា បុន គតិយា វា ឧបបត្តិយា វា បដិសន្ធិយា វា សំសារេ វា វដ្តេ វា ន ជនេយ្យ ន សញ្ជនេយ្យ ន និព្វត្តេយ្យ នាភិនិព្វត្តេយ្យ ឥធេវ និរុជ្ឈេយ្យ វូបសមេយ្យ អត្ថំ គច្ឆេយ្យ

ពាក្យថា ចូរជាបុគ្គលមិនប្រហែស គឺធ្វើដោយគោរព ធ្វើឲ្យរឿយ ៗ ៗ បេ ៗ មិនប្រហែសក្នុងកុសលធម៌ទាំងឡាយ ហេតុនោះ (ទ្រង់ត្រាស់ថា) ម្នាលបិង្គិយៈ ហេតុនោះ អ្នកចូរជាបុគ្គលមិនប្រហែស ។

(៨៩) អធិប្បាយពាក្យថា ចូរលះបង់រូប ដើម្បីការមិនកើតទៀត ត្រង់ពាក្យថា រូប បានដល់មហាភូតរូប ៤ នឹងរូបអាស្រ័យមហាភូតរូប ៤ ។ ពាក្យថា ចូរលះបង់រូប គឺចូរលះបង់រូប ចូរបោលរូប ចូរបន្ទោបង់រូប ចូរធ្វើឲ្យវិនាសរូប ចូរឲ្យរូបវិនាស ហេតុនោះ (ទ្រង់ត្រាស់ថា) ចូរលះបង់រូប ។ ពាក្យថា ដើម្បីការមិនឲ្យកើតទៀត អធិប្បាយថា រូបរបស់អ្នកគប្បីរលត់ក្នុងភពនេះ យ៉ាងណា បដិសន្ធិភព មិនគប្បីកើតទៀត ក្នុងកាមធាតុក្តី ក្នុងរូបធាតុក្តី ក្នុងអរូបធាតុក្តី ក្នុងកាមភពក្តី ក្នុងរូបភពក្តី ក្នុងអរូបភពក្តី ក្នុងសញ្ញាភពក្តី ក្នុងអសញ្ញាភពក្តី ក្នុងនេវសញ្ញានាសញ្ញាភពក្តី ក្នុងឯកវោការភពក្តី ក្នុងចតុវោការភពក្តី ក្នុងបញ្ចវោការភពក្តី គឺ មិនគប្បីកើត មិនគប្បីបង្កើត មិនគប្បីកកើត មិនគប្បីកើតចំពោះទៀត ក្នុងគតិក្តី ក្នុងឧបបត្តិក្តី ក្នុងបដិសន្ធិក្តី ក្នុងសំសារក្តី ក្នុងវដ្តៈក្តី គឺថា គប្បីរលត់ ស្ងប់រម្ងាប់ ដល់នូវការតាំងនៅមិនបាន

បដិប្បស្សទ្ធិយាតិ ជហស្សុ រូបំ អបុនព្ភវាយ ។ តេនាហ ភគវា

ទិស្វាន រូបេសុ វិហញ្ញមានេ (បិង្គិយាតិ ភគវា)
រុប្បន្តិ រូបេសុ ជនា បមត្តា
តស្មា តុវំ បិង្គិយ អប្បមត្តោ
ជហស្សុ រូបំ អបុនព្ភវាយាតិ ។

(៩០) ទិសា ចតស្សោ វិទិសា ចតស្សោ
ឧទ្ធំ អធោ ទស ទិសា ឥមាយោ
ន តុយ្ហំ អទិដ្ឋំ អសុតាមុតំ វា
អថោ អវិញ្ញាតំ កិញ្ចិ នមត្ថិ លោកេ
អាចិក្ខ ធម្មំ យមហំ វិជញ្ញំ
ជាតិជរាយ ឥធ វិប្បហានំ ។

(៩១) ទិសា ចតស្សោ វិទិសា ចតស្សោ ឧទ្ធំ អធោ ទស ទិសា ឥមាយោតិ ទស ទិសា ន តុយ្ហំ អទិដ្ឋំ អសុតំ អមុតំ អវិញ្ញាតំ កិញ្ចិ អត្តត្ថោ វា បរត្ថោ វា ឧភយត្ថោ វា

រម្ងាប់ចំពោះ ក្នុងភពនេះឯង ក៏យ៉ាងនោះដែរ ហេតុនោះ (ទ្រង់ត្រាស់ថា) ចូរលះបង់រូប ដើម្បីការមិនកើតទៀត ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

(ព្រះមានព្រះភាគត្រាស់ថា ម្នាលបិង្គិយៈ) ពួកជនដែលប្រហែស ឃើញសត្វទាំងឡាយ កំពុងលំបាកព្រោះរូប ក៏លំបាកព្រោះរូប ម្នាលបិង្គិយៈ ហេតុនោះ អ្នកចូរជាបុគ្គលមិនប្រហែស លះបង់រូបទៅ ដើម្បីការមិនកើតទៀត ។

[៩០] ទិសទាំង ១០ នេះ គឺ ទិសធំ ៤ ទិសតូច ៤ ទិសខាងលើ ១ ទិសខាងក្រោម ១ របស់អ្វីបន្តិចបន្តួច ឈ្មោះថា ព្រះអង្គមិនធ្លាប់ឃើញ មិនធ្លាប់ឮ មិនធ្លាប់ប៉ះពាល់ មិនមានទេ មួយទៀត របស់អ្វីបន្តិចបន្តួច ក្នុងលោក ឈ្មោះថាព្រះអង្គមិនធ្លាប់ជ្រាប មិនមានទេ ខ្ញុំព្រះអង្គគប្បីដឹងធម៌ណា ដែលជាគ្រឿងលះបង់ជាតិនិងជរា ក្នុងទីនេះ សូមព្រះអង្គត្រាស់ប្រាប់ធម៌នោះឲ្យទាន ។

[៩១] ពាក្យថា ទិសទាំង១០ នេះ គឺទិសធំ ៤ ទិសតូច ៤ ទិសខាងលើ១ ទិសខាងក្រោម១ សេចក្តីថា ក្នុងទិសទាំង១០ របស់អ្វីបន្តិចបន្តួច ដែលជាប្រយោជន៍ខ្លួនក្តី ប្រយោជន៍អ្នកដទៃក្តី ប្រយោជន៍ទាំងពីរក្តី

## បិង្គិយមាណវកប្បញ្ហានិទ្ទេសោ

ទិដ្ឋធម្មិកោ វា អត្ថោ សម្បរាយិកោ វា អត្ថោ ។ បេ ។ បរមត្ថោ វា នត្ថិ ន សន្តិ ន សំវិជ្ជតិ នុបលព្ភន្តីតិ ន តុយ្ហំ អទិដ្ឋំ អសុតាមុតំ វា អថោ អវិញ្ញាតំ កិញ្ចិ នមត្ថិ លោកេ ។

(៩២) អាចិក្ខ ធម្មំ យមហំ វិជញ្ញន្តិ អាចិក្ខ ធម្មន្តិ អាទិកល្យាណំ ។ បេ ។ និព្វានគាមិនិញ្ច បដិបទំ អាចិក្ខ ទេសេហិ បញ្ញបេហិ បដ្ឋបេហិ វិវរាហិ វិភជាហិ ឧត្តានីករោហិ បកាសេហីតិ អាចិក្ខ ធម្មំ ។ យមហំ វិជញ្ញន្តិ យមហំ ជានេយ្យំ វិជានេយ្យំ បដិវិជានេយ្យំ បដិវិជ្ឈេយ្យំ អធិគច្ឆេយ្យំ ផុសេយ្យំ សច្ឆិករេយ្យន្តិ អាចិក្ខ ធម្មំ យមហំ វិជញ្ញំ ។

(៩៣) ជាតិជរាយ ឥធ វិប្បហានន្តិ ឥធេវ

ប្រយោជន៍ប្រព្រឹត្តទៅក្នុងបច្ចុប្បន្នក្តី ប្រយោជន៍ប្រព្រឹត្តទៅក្នុងលោកខាងមុខក្តី ។បេ។ ប្រយោជន៍ដ៏ឧត្តមក្តី ឈ្មោះថាព្រះអង្គមិនធ្លាប់ឃើញ មិនធ្លាប់ឮ មិនធ្លាប់ប៉ះពាល់ មិនធ្លាប់ជ្រាប មិនមាន គ្មាន ឥតអង្គឹមាន គឺថា មិនទាន់បានទេ ហេតុនោះ (លោកពោលថា) របស់អ្វីបន្តិចបន្តួច ឈ្មោះថាព្រះអង្គមិនធ្លាប់ឃើញ មិនធ្លាប់ឮ មិនធ្លាប់ប៉ះពាល់ មិនមានទេ មួយទៀត របស់អ្វីបន្តិចបន្តួច ក្នុងលោក ឈ្មោះថាព្រះអង្គមិនធ្លាប់ជ្រាប មិនមានទេ ។

(៩២) ពាក្យថា សូមព្រះអង្គត្រាស់ប្រាប់ធម៌ ក្នុងបទថា ខ្ញុំព្រះអង្គគប្បីដឹងធម៌ណា សូមព្រះអង្គត្រាស់ប្រាប់ធម៌នោះ គឺសូមព្រះអង្គប្រាប់ សំដែង បញ្ញត្ត តាំងផ្តើម បើក វែកញែក ធ្វើឲ្យរាក់ ប្រកាស នូវធម៌ ឲ្យមានពីរោះបទដើម ។បេ។ នឹងនិព្វានគាមិនិបដិបទា ហេតុនោះ (លោកពោលថា) សូមព្រះអង្គត្រាស់ប្រាប់ធម៌នោះ ។ ពាក្យថា ខ្ញុំព្រះអង្គគប្បីដឹងធម៌ណា គឺខ្ញុំព្រះអង្គគប្បីដឹង ដឹងច្បាស់ ដឹងជាក់ ចាក់ធ្លុះ ត្រាស់ដឹង ពាល់ត្រូវ ធ្វើឲ្យជាក់ច្បាស់ ហេតុនោះ (លោកពោលថា) ខ្ញុំព្រះអង្គគប្បីដឹងធម៌ណា សូមព្រះអង្គត្រាស់ប្រាប់ធម៌នោះ ។

(៩៣) ពាក្យថា ជាគ្រឿងលះបង់ជាតិនឹងជរា ក្នុងទីនេះ

ជាតិជរាមរណស្ស បហានំ រូបសមោ បដិនិស្សគ្គោ
បដិប្បស្សទ្ធិ អមតំ និព្វានន្តិ ជាតិជ្ជរាយ ឥធ
វិប្បហានំ ។ តេនាហ សោ ព្រាហ្មណោ

ទិសា ចតស្សោ វិទិសា ចតស្សោ
ឧទ្ធំ អធោ ទស ទិសា ឥមាយោ
ន តុយ្ហំ អទិដ្ឋំ អសុតាមុតំ វា
អថោ អវិញ្ញាតំ កិញ្ចិ នមត្ថិ លោកេ
អាចិក្ខ ធម្មំ យមហំ វិជញ្ញំ
ជាតិជ្ជរាយ ឥធ វិប្បហានន្តិ ។

(៩៤) តណ្ហាធិបន្នេ មនុជេ បេក្ខមានោ
(បិង្គិយាតិ ភគវា)
សន្តាបជាតេ ជរសា បរេតេ
តស្មា តុវំ បិង្គិយ អប្បមត្តោ
ជហស្សុ តណ្ហំ អបុនព្ភវាយ ។

(៩៥) តណ្ហាធិបន្នេ មនុជេ បេក្ខមានោតិ
តណ្ហាតិ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា
រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។

គឺការលះបង់ ការរម្ងាប់បង់ ការរលាស់ចោល ការរម្ងាប់នូវជាតិជរានិងមរណៈ គឺអមតនិព្វាន ក្នុងទីនេះឯង ហេតុនោះ (លោកពោលថា) ជាគ្រឿងលះបង់ជាតិនិងជរាក្នុងទីនេះ ។ ហេតុនោះ ព្រាហ្មណ៍នោះ ពោលថា

ទិសទាំង ១០ នេះ គឺទិសធំ ៤ ទិសតូច ៤ ទិសខាងលើ ១
ទិសខាងក្រោម១ របស់អ្វីបន្តិចបន្តួច ឈ្មោះថាព្រះអង្គមិនធ្លាប់
ឃើញ មិនធ្លាប់ឮ មិនធ្លាប់ប៉ះពាល់ មិនមានទេ មួយទៀត
របស់អ្វីបន្តិចបន្តួច ក្នុងលោក ឈ្មោះថាព្រះអង្គមិនធ្លាប់ជ្រាប
មិនមានទេ ខ្ញុំព្រះអង្គគប្បីដឹងធម៌ណា ដែលជាគ្រឿងលះបង់
ជាតិនិងជរា ក្នុងទីនេះ សូមព្រះអង្គ ត្រាស់ប្រាប់ធម៌នោះឲ្យបាន ។

[៩៤] (ព្រះមានព្រះភាគត្រាស់ថា ម្នាលបិង្គិយៈ) អ្នកកាលបើ
សំឡឹងមើល នូវពួកមនុស្សដែលត្រូវតណ្ហាគ្របសង្កត់ ត្រូវ
សេចក្តីក្តៅក្រហាយកើតមាន ត្រូវជរាបៀតបៀន ម្នាលបិង្គិយៈ
អ្នកនឹងទៅជាបុគ្គលមិនប្រហែស ព្រោះការឃើញនោះ ហេតុ
នេះ អ្នកចូរលះបង់តណ្ហា ដើម្បីការមិនកើតទៀត ។

[៩៥] ពាក្យថា អ្នកកាលបើសំឡឹងមើល នូវពួកមនុស្ស ដែលត្រូវតណ្ហាគ្របសង្កត់ ត្រង់ពាក្យថា តណ្ហា បានដល់ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។

## បិង្គិយមាណវកបញ្ហានិទ្ទេសោ

តណ្ហាធិបន្នេតិ តណ្ហាអធិបន្នេ តណ្ហានុគតេ តណ្ហានុសដេ តណ្ហាយាបន្នេ អភិភូតេ បរិយាទិន្នចិត្តេ ។ មនុជេតិ សត្តាធិវចនំ ។ បេក្ខមានោតិ បេក្ខមានោ ទក្ខមានោ ឱលោកយមានោ និជ្ឈាយមានោ ឧបបរិក្ខមានោតិ តណ្ហាធិបន្នេ មនុជេ បេក្ខមានោ ។ បិង្គិយាតិ ភគវា ព្រាហ្មណំ នាមេន អាលបតិ ។

(៩៦) សន្តាបជាតេ ជរសា បរេតេតិ សន្តាបជាតេតិ ជាតិយា សន្តាបជាតេ ជរាយ សន្តាបជាតេ ព្យាធិនា សន្តាបជាតេ មរណេន សន្តាបជាតេ សោកបរិទេវទុក្ខទោមនស្សុបាយាសេហិ សន្តាបជាតេ នេរយិកេន ទុក្ខេន សន្តាបជាតេ ។ បេ ។ ទិដ្ឋិព្យសនេន ទុក្ខេន សន្តាបជាតេ ឦតិជាតេ ឧបទ្ទវជាតេ ឧបសគ្គជាតេតិ សន្តាបជាតេ ។

ពាក្យថា ដែលត្រូវតណ្ហាគ្របសង្កត់ គឺ តណ្ហាគ្របសង្កត់ ទៅតាមតណ្ហា ពាសទៅតាមតណ្ហា ជ្រមុជចុះក្នុងតណ្ហា ត្រូវតណ្ហាគ្របសង្កត់ មានចិត្តគឺតណ្ហារួបរឹត ។ ពាក្យថា ពួកមនុស្ស គឺជាឈ្មោះនៃសត្វ ។ ពាក្យថា កាលបើសំឡឹងមើល គឺ កាលបើសំឡឹងមើល ក្រឡេកមើល រមិលមើល ពិនិត្យមើល ពិចារណាមើល (ហេតុនោះ) ទ្រង់ត្រាស់ថា អ្នកកាលបើសំឡឹងមើលពួកមនុស្ស ដែលត្រូវតណ្ហាគ្របសង្កត់ ។ ពាក្យថា ម្នាលបិង្គិយៈ គឺ ព្រះមានព្រះភាគត្រាស់ហៅព្រាហ្មណ៍ចំឈ្មោះ ។

(៩៦) ពាក្យថា ត្រូវសេចក្តីក្តៅក្រហាយកើតមាន ត្រូវជរាបៀតបៀន ត្រង់ពាក្យថា ត្រូវសេចក្តីក្តៅក្រហាយកើតមាន គឺ កើតសេចក្តីក្តៅក្រហាយព្រោះជាតិ កើតសេចក្តីក្តៅក្រហាយព្រោះជរា កើតសេចក្តីក្តៅក្រហាយព្រោះព្យាធិ កើតសេចក្តីក្តៅក្រហាយព្រោះមរណៈ កើតសេចក្តីក្តៅក្រហាយព្រោះសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស នឹងសេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយ កើតសេចក្តីក្តៅក្រហាយ ព្រោះទុក្ខប្រព្រឹត្តទៅក្នុងនរក ។ បេ ។ កើតសេចក្តីក្តៅក្រហាយ កើតមានចង្រៃ កើតមានឧបទ្រព កើតមានឧបសគ្គ អំពីទុក្ខ ព្រោះវិនាសទិដ្ឋិ ហេតុនោះ ( ទ្រង់ត្រាស់ថា ) ត្រូវសេចក្តីក្តៅក្រហាយកើតមាន ។

ជរសា បរេតោតិ ជរាយ ផុដ្ឋោ បរេតោ សមោហិតោ ជាតិយា អនុគតោ ជរាយ អនុសដោ ព្យាធិនា អភិភូតោ មរណេន អព្ភាហតោ អតាណោ អលេណោ អសរណោ អសរណីភូតោតិ សន្តាបជាតោ ជរសា បរេតោ ។

(៩៧) តស្មា តុវំ បិង្គិយ អប្បមត្តោតិ តស្មាតិ តស្មា តំការណា តំហេតុ តប្បច្ចយា តំនិទានា ឯវំ អាទីនវំ សម្បស្សមានោ តណ្ហាយាតិ តស្មា តុវំ បិង្គិយ ។ អប្បមត្តោតិ សក្កច្ចការី សាតច្ចការី ។បេ។ អប្បមត្តោ កុសលេសុ ធម្មេសូតិ តស្មា តុវំ បិង្គិយ អប្បមត្តោ ។

(៩៨) ជហស្សុ តណ្ហំ អបុនព្ភវាយាតិ តណ្ហាតិ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្ពតណ្ហា ធម្មតណ្ហា ។ ជហស្សុ តណ្ហន្តិ តណ្ហំ ជហស្សុ តណ្ហំ បជហស្សុ តណ្ហំ វិនោទេហិ តណ្ហំ ព្យន្តីករោហិ តណ្ហំ អនភាវង្គមេហីតិ ជហស្សុ តណ្ហំ ។

ពាក្យថា ត្រូវដកបៀតបៀន គឺត្រូវដកប៉ះពាល់ បៀតបៀន របឹត ប្រព្រឹត្ត ទៅតាមជាតិ ទាសទៅដោយដក ត្រូវព្យាធិគ្របសង្កត់ ត្រូវមរណៈកំចាត់ មិនមានទីពំនាក់ មិនមានទីជ្រក មិនមានទីពឹង មិនមានទីរំពឹង ហេតុនោះ (ទ្រង់ត្រាស់ថា) ត្រូវសេចក្តីក្តៅក្រហាយកើតមាន ត្រូវដកបៀតបៀន ។

(៩៧) ពាក្យថា ម្នាលបិង្គិយៈ អ្នកនឹងទៅជាបុគ្គលមិនប្រហែស ព្រោះការឃើញនោះ ត្រង់ពាក្យថា ព្រោះការឃើញនោះ គឺព្រោះហេតុនោះ ព្រោះដំណើរនោះ ព្រោះហេតុដូច្នោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ បុគ្គលកាលបើឃើញទោសនៃតណ្ហាយ៉ាងនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) ម្នាលបិង្គិយៈ អ្នក ... ព្រោះការឃើញនោះ ។ ពាក្យថា នឹងជាបុគ្គលមិនប្រហែស គឺនឹងជាបុគ្គលធ្វើដោយគោរព ធ្វើរឿយ ៗ ។ បេ ។ មិនប្រហែសក្នុងកុសលធម៌ ហេតុនោះ (ទ្រង់ត្រាស់ថា) ម្នាលបិង្គិយៈ អ្នកនឹងជាបុគ្គលមិនប្រហែស ព្រោះការឃើញនោះ ។

(៩៨) ពាក្យថា ចូរលះបង់តណ្ហា ដើម្បីការមិនកើតទៀត ត្រង់ពាក្យថា តណ្ហា បានដល់រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ពាក្យថា ចូរលះបង់តណ្ហា គឺចូរលះបង់តណ្ហា បន្ទោបង់តណ្ហា បន្សាបង់តណ្ហា ធ្វើឲ្យវិនាសតណ្ហា ញុំាងតណ្ហាឲ្យដល់នូវការមិនកើតមាន ហេតុនោះ (ទ្រង់ត្រាស់ថា) ចូរលះបង់តណ្ហា ។

## បិង្គិយមាណវកប្បញ្ហានិទ្ទេសោ

អបុនព្ភវាយាតិ យថា តេ រូបំ ឥធេវ និរុជ្ឈេយ្យ បុន បដិសន្ធិ ភវោ ន និព្វត្តេយ្យ កាមធាតុយា វា រូបធាតុយា វា អរូបធាតុយា វា កាមភវេ វា រូបភវេ វា អរូបភវេ វា សញ្ញាភវេ វា អសញ្ញាភវេ វា នេវសញ្ញានាសញ្ញាភវេ វា ឯកវោការភវេ វា ចតុវោការភវេ វា បញ្ចវោការភវេ វា បុន គតិយា វា ឧបបត្តិយា វា បដិសន្ធិយា វា សំសារេ វា វដ្ដេ វា ន ជនេយ្យ ន សញ្ជនេយ្យ ន និព្វត្តេយ្យ នាភិនិព្វត្តេយ្យ ឥធេវ និរុជ្ឈេយ្យ វូបសមេយ្យ អត្ថំ គច្ឆេយ្យ បដិប្បស្សម្ភេយ្យាតិ ជហស្សុ តណ្ហំ អបុនព្ភវាយ ។ តេនាហ ភគវា

តណ្ហាភិបន្នេ មនុជេ បេក្ខមានោ
(បិង្គិយាតិ ភគវា)
សន្តាបជាតេ ជរសា បរេតេ
តស្មា តុវំ បិង្គិយ អប្បមត្តោ
ជហស្សុ តណ្ហំ អបុនព្ភវាយាតិ ។

## បិង្គិយមាណវកបញ្ហានិទ្ទេស

ពាក្យថា ដើម្បីការមិនកើតទៀត គឺ រូបរបស់អ្នក គប្បីរលត់ក្នុងទីនេះឯងយ៉ាងណា បដិសន្ធិភព មិនគប្បីកើតទៀត ក្នុងកាមធាតុក្តី រូបធាតុក្តី អរូបធាតុក្តី កាមភពក្តី រូបភពក្តី អរូបភពក្តី សញ្ញាភពក្តី អសញ្ញាភពក្តី នេវសញ្ញានាសញ្ញាភពក្តី ឯកវោការភពក្តី ចតុវោការភពក្តី បញ្ចវោការភពក្តី គឺមិនកើត មិនបង្កើត មិនកកើត មិនកើតចំពោះក្នុងគតិ ឧបបត្តិ បដិសន្ធិ សំសារ និងវដ្តៈទៀត គឺថាគប្បីរលត់ គប្បីចូលទៅរម្ងាប់ គប្បីដល់នូវការតាំងនៅមិនបាន គប្បីរម្ងាប់ចំពោះក្នុងភពនេះឯង ក៏យ៉ាងនោះឯង ហេតុនោះ (ទ្រង់ត្រាស់ថា) ចូរលះបង់តណ្ហា ដើម្បីការមិនកើតទៀត ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

(ព្រះមានព្រះភាគត្រាស់ថា ម្នាលបិង្គិយៈ) អ្នកកាលបើសំឡឹង
មើលពួកមនុស្ស ដែលត្រូវតណ្ហាគ្របសង្កត់ ត្រូវសេចក្តី
ក្តៅក្រហាយកើតមាន ត្រូវជរាបៀតបៀន ម្នាលបិង្គិយៈ
អ្នកនឹងទៅជាបុគ្គលមិនប្រហែស ព្រោះការឃើញនោះ ហេតុ
នេះ អ្នកចូរលះបង់តណ្ហា ដើម្បីការមិនកើតទៀត ។

(៩៩) សហ គាថាបរិយោសានា តេន ព្រាហ្មណេន សទ្ធឹ ឯកច្ឆន្ទា ឯកប្បយោគា ឯកាធិប្បាយា ឯកវាសនវាសិតា តេសំ អនេកបាណសហស្សានំ វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ តស្ស ច ព្រាហ្មណស្ស វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ។ សហ ចក្ខុប្បដិលាភា អជិនជដាវាកចីរតិទណ្ឌកមណ្ឌលុកេសា ច មស្សុ ច អន្តរហិតា ។ ភណ្ឌុកាសាយវត្ថវសនោ សង្ឃាដិបត្តចីវរធរោ អន្វត្ថប្បដិបត្តិយា បញ្ជលិកោ ភគវន្តំ នមស្សមានោ និសិន្នោ ហោតិ សត្ថា មេ ភន្តេ ភគវា សាវកោហមស្មីតិ ។

បិង្គិយមាណវកបញ្ហានិទ្ទេសោ សោឡសមោ ។

(៩៩) កន្លងពេលដំណាលគ្នានឹងចប់ព្រះគាថា ពួកសត្វទាំងឡាយណា មានឆន្ទៈតែមួយ មានប្រយោគតែមួយ មានបំណងតែមួយ នៅដោយការនៅតែមួយ ជាមួយនឹងព្រាហ្មណ៍នោះ ធម្មចក្ខុ គឺសោតាបត្តិមគ្គ ប្រាសចាកធូលី ប្រាសចាកមន្ទិល កើតឡើងដល់ពាន់នៃសត្វទាំងឡាយដ៏ច្រើននោះថា ធម្មជាតណានីមួយ មានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានកិរិយារលត់ទៅវិញជាធម្មតា មួយទៀត ធម្មចក្ខុ ប្រាសចាកធូលី ប្រាសចាកមន្ទិល កើតឡើងដល់ព្រាហ្មណ៍នោះថា ធម្មជាតណាមួយ មានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានកិរិយារលត់ទៅវិញជាធម្មតា ។ ស្បែកខ្លា កន្ទួយសក់ សំពត់សម្បកឈើ ឈើច្រត់ កុណ្ឌី សក់នឹងពុកមាត់ បាត់ទៅកន្លងពេលដំណាលគ្នានឹងការបានចក្ខុ ។ ព្រាហ្មណ៍នោះ ជាភិក្ខុមានកណ្ឌៈ នឹងសម្លៀកបំពាក់សំពត់កាសាយៈ ទ្រទ្រង់សង្ឃាដិបាត្រនឹងចីវរ អង្គុយប្រណម្យអញ្ជលីនមស្ការព្រះមានព្រះភាគ ដោយការសម្រេចប្រយោជន៍ដ៏សមគួរ បានពោលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគជាគ្រូនៃខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គសូមជាសាវ័ក ។

ចប់ បិង្គិយមាណវកបញ្ហានិទ្ទេស ទី ១៦ ។

# សោឡសមាណវកបញ្ហានិគមនិទ្ទេសោ

(១០០) ឥទមវោច ភគវា មគធេសុ វិហរន្តោ បាសាណកេ ចេតិយេ បរិចារិកសោឡសន្នំ ព្រាហ្មណានំ អជ្ឈិដ្ឋោ បុដ្ឋោ បុដ្ឋោ បញ្ហំ ព្យាកាសិ ។

(១០១) ឥទមវោច ភគវាតិ ឥមំ បារាយនំ អវោច ។ ភគវាតិ គារវាធិវចនមេតំ ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ភគវាតិ ឥទមវោច ភគវា ។

(១០២) មគធេសុ វិហរន្តោតិ មគធនាមកេ ជនបទេ ។ វិហរន្តោតិ វិហរន្តោ ឥរិយន្តោ វត្តេន្តោ បាលេន្តោ យបេន្តោ យាបេន្តោ ។ បាសាណកេ ចេតិយេតិ បាសាណកចេតិយំ វុច្ចតិ ពុទ្ធាសនន្តិ មគធេសុ វិហរន្តោ បាសាណកេ ចេតិយេ ។

# សោឡសមាណវកប្បញ្ហានិគមនិទ្ទេស

(១០០) ព្រះមានព្រះភាគ កាលគង់នៅ នាបាសាណកចេតិយ ក្នុងមគធជនបទ ទ្រង់បានសំដែងធម៌នេះ កាលព្រាហ្មណ៍ ទាំង ១៦ ជាអ្នកបំរើ (នៃពាវរីព្រាហ្មណ៍) អារាធនាសួរហើយ ៗ ព្រះអង្គក៏បានទ្រង់ដោះស្រាយប្រស្នា ។

(១០១) ពាក្យថា ព្រះមានព្រះភាគ ទ្រង់បានសំដែងធម៌នេះ គឺ បានសំដែងបារាយនៈនេះ ។ ពាក្យថា ព្រះមានព្រះភាគ នុ៎ះ ជាពាក្យពោលដោយគោរព ។ បេ ។ បញ្ញត្តិថា ព្រះមានព្រះភាគ នេះ (កើត) ព្រោះការត្រាស់ដឹង ហេតុនោះ (លោកពោលថា) ព្រះមានព្រះភាគទ្រង់បានសំដែងធម៌នេះ ។

(១០២) ពាក្យថា កាលគង់នៅក្នុងមគធជនបទ គឺក្នុងជនបទមានឈ្មោះថា មគធៈ ។ ពាក្យថា កាលគង់នៅ គឺកាលឋិតនៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ ។ ពាក្យថា បាសាណកចេតិយ សេចក្តីថា ពុទ្ធាសនៈ លោកហៅថា បាសាណចេតិយ ហេតុនោះ (លោកពោលថា) កាលគង់នៅនាបាសាណកចេតិយ ក្នុងមគធជនបទ ។

(១០៣) បរិចារិកសោឡសន្នំ ព្រាហ្មណានន្តិ បិត្តិយោ(១) ព្រាហ្មណោ ពាវរិស្ស ព្រាហ្មណស្ស សេដ្ឋោ សេដ្ឋវរោ(២) បរិចារិកោ បិត្តិយេន(៣) តេ សោឡសាតិ ឯវម្បិ បរិចារិកសោឡសន្នំ ព្រាហ្មណានំ ។ អថវា តេ សោឡស ព្រាហ្មណា ពុទ្ធស្ស ភគវតោ សេដ្ឋា សេដ្ឋវរា បរិចារិកា សិយុន្តិ ឯវម្បិ បរិចារិកសោឡសន្នំ ព្រាហ្មណានំ ។

(១០៤) អជ្ឈិដ្ឋោ បុដ្ឋោ បុដ្ឋោ បញ្ហំ ព្យាកាសីតិ អជ្ឈិដ្ឋោ អជ្ឈេសិតោ ។ បុដ្ឋោ បុដ្ឋោតិ បុដ្ឋោ បុច្ឆិតោ យាចិតោ អជ្ឈេសិតោ បសាទិតោ ។ បញ្ហំ ព្យាកាសីតិ បញ្ហំ ព្យាកាសិ អាចិក្ខិ ទេសេសិ បញ្ញបេសិ បដ្ឋបេសិ វិវរិ វិភជិ ឧត្តានីមកាសិ បកាសេសីតិ អជ្ឈិដ្ឋោ បុដ្ឋោ បុដ្ឋោ បញ្ហំ ព្យាកាសិ(៤) ។

---

១ ម. សិត្តិយោ ។ ២ បដ្ឋោ បដ្ឋបរោ ។ ៣ សិស្សេហិ តេន ។ ៤ ម. ព្យាកាសិ តេនេតំ វុច្ចតិ ។ ឥតោ បរំ មរម្មបោត្ថកេ ឥទមធិកំ ភគវា មគធេសុ វិហរន្តោ បាសាណកេ ចេតិយេ បរិចារិកសោឡសន្នំ ព្រាហ្មណានំ អជ្ឈិដ្ឋោ បុដ្ឋោ បុដ្ឋោ បញ្ហំ ព្យាកាសីតិ ទិស្សតិ ។

(១០៣) ពាក្យថា កាលត្រូវព្រាហ្មណ៍ជាអ្នកបំរើទាំង១៦ សេចក្តីថា បទ្ធិយព្រាហ្មណ៍ ជាអ្នកបំរើ ប្រសើរ ថ្លៃថ្លា នៃពាវរីព្រាហ្មណ៍ ព្រាហ្មណ៍ទាំង ១៦ នាក់នោះ រាប់ទាំងបទ្ធិយព្រាហ្មណ៍ផង ហេតុនោះ (លោកពោលថា) កាលព្រាហ្មណ៍ទាំង១៦ ជាអ្នកបំរើ យ៉ាងនេះក៏បាន ។ ឬថា ព្រាហ្មណ៍ទាំង១៦ នោះ ជាអ្នកបំរើ ប្រសើរ ថ្លៃថ្លា នៃព្រះពុទ្ធមានព្រះភាគ ហេតុនោះ (លោកពោលថា) កាលព្រាហ្មណ៍ទាំង ១៦ ជាអ្នកបំរើ យ៉ាងនេះក៏បាន ។

(១០៤) ពាក្យថា អារាធនា សួរហើយ ៗ ព្រះអង្គក៏បានទ្រង់ដោះស្រាយប្រស្នា គឺ អារាធនាហើយ និមន្តហើយ ។ ពាក្យថា សួរហើយ ៗ គឺសួរហើយ សួរបញ្ជាក់ហើយ អង្វរហើយ អារាធនាហើយ ឲ្យជ្រះថ្លាហើយ ។ ពាក្យថា ទ្រង់ដោះស្រាយប្រស្នា គឺទ្រង់ដោះស្រាយ ប្រាប់ សំដែង បញ្ញត្ត តាំងផ្តើម បើក វែកញែក ធ្វើឲ្យរាក់ ប្រកាសនូវប្រស្នា ហេតុនោះ (លោកពោលថា) អារាធនា សួរហើយ ៗ ព្រះអង្គក៏បានទ្រង់ដោះស្រាយប្រស្នា ។

## សោឡសមាណវកប្បញ្ហានិគមនិទ្ទេសោ

(១០៤) ឯកមេកស្ស ចេបិ បញ្ហស្ស អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មំ បដិបជ្ជេយ្យ គច្ឆេយ្យេវ ជរាមរណស្ស បារំ បារគមនីយា ឥមេ ធម្មាតិ តស្មា ឥមស្ស ធម្មបរិយាយស្ស បារាយនន្តេវ អធិវចនំ ។

(១០៥) ឯកមេកស្ស ចេបិ បញ្ហស្សាតិ ឯកមេកស្ស ចេបិ អជិតប្បញ្ហស្ស ឯកមេកស្ស ចេបិ តិស្សមេត្តេយ្យប្បញ្ហស្ស ឯកមេកស្ស ចេបិ បុណ្ណកប្បញ្ហស្ស ឯកមេកស្ស ចេបិ មេត្តគូបញ្ហស្ស ឯកមេកស្ស ចេបិ ធោតកប្បញ្ហស្ស ឯកមេកស្ស ចេបិ ឧបសីវប្បញ្ហស្ស ឯកមេកស្ស ចេបិ នន្ទប្បញ្ហស្ស ឯកមេកស្ស ចេបិ ហេមកប្បញ្ហស្ស ឯកមេកស្ស ចេបិ តោទេយ្យប្បញ្ហស្ស ឯកមេកស្ស ចេបិ កប្បប្បញ្ហស្ស ឯកមេកស្ស ចេបិ ជតុកណ្ណីបញ្ហស្ស ឯកមេកស្ស ចេបិ ភទ្រាវុធប្បញ្ហស្ស ឯកមេកស្ស ចេបិ ឧទយប្បញ្ហស្ស ឯកមេកស្ស ចេបិ បោសាលប្បញ្ហស្ស ឯកមេកស្ស

(១០៥) ប្រសិនបើបុគ្គល បានដឹងអត្ថ បានដឹងធម៌ នៃប្រស្នាមួយ ៗ ហើយប្រតិបត្តិនូវធម៌ ដ៏សមគួរដល់ធម៌ បុគ្គលនោះ នឹងទៅកាន់ត្រើយនៃជរានឹងមរណៈ ពុំខាន (ព្រោះថា) ធម៌ទាំងនេះ ជាធម៌គួរនាំសត្វទៅកាន់ត្រើយគឺព្រះនិព្វាន ហេតុនោះ ពាក្យថា បារាយនៈ ជាឈ្មោះនៃធម្មបរិយាយនេះ ។

(១០៦) ពាក្យថា ប្រសិនបើ នៃប្រស្នាមួយ ៗ គឺ ប្រសិនបើ នៃប្រស្នាអជិតមាណពមួយ ៗ ប្រសិនបើ នៃប្រស្នាតិស្សមេត្តេយ្យមាណពមួយ ៗ ប្រសិនបើ នៃប្រស្នាបុណ្ណកមាណពមួយ ៗ ប្រសិនបើ នៃប្រស្នាមេត្តគូមាណពមួយ ៗ ប្រសិនបើ នៃប្រស្នាធោតកមាណពមួយ ៗ ប្រសិនបើ នៃប្រស្នាឧបសីវមាណពមួយ ៗ ប្រសិនបើ នៃប្រស្នានន្ទមាណពមួយ ៗ ប្រសិនបើ នៃប្រស្នាហេមកមាណពមួយ ៗ ប្រសិនបើ នៃប្រស្នាតោទេយ្យមាណពមួយ ៗ ប្រសិនបើ នៃប្រស្នាកប្បមាណពមួយ ៗ ប្រសិនបើ នៃប្រស្នាជតុកណ្ណីមាណពមួយ ៗ ប្រសិនបើ នៃប្រស្នាភទ្រាវុធមាណពមួយ ៗ ប្រសិនបើ នៃប្រស្នាឧទយមាណពមួយ ៗ ប្រសិនបើ នៃប្រស្នាបោសាលមាណពមួយ ៗ

ចេតិ មោឃរាជព្រាហ្មណស្ស ឯកមេកស្ស ចេតិ បិង្គិយព្រាហ្មណស្សាតិ ឯកមេកស្ស ចេតិ បញ្ហស្ស ។

(១០៧) អត្ថមញ្ញាយ ធម្មមញ្ញាយាតិ ស្វេវ បញ្ហោ ធម្មោ វិសជ្ជនំ អត្ថោតិ អត្ថំ អញ្ញាយ ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វាតិ អត្ថមញ្ញាយ ។ ធម្មមញ្ញាយាតិ ធម្មំ អញ្ញាយ ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វាតិ ធម្មមញ្ញាយ ។

(១០៨) ធម្មានុធម្មំ បដិបជ្ជេយ្យាតិ សម្មាបដិបទំ អនុលោមបដិបទំ អបច្ចនីកបដិបទំ អន្វត្ថបដិបទំ ធម្មានុធម្មបដិបទំ បដិបជ្ជេយ្យាតិ ធម្មានុធម្មំ បដិបជ្ជេយ្យ ។

(១០៩) គច្ឆេយ្យ ជរាមរណស្ស បារន្តិ ជរាមរណបារំ វុច្ចតិ អមតំ និព្ពានំ យោ សោ សព្វសង្ខារសមថោ សព្វូបធិបដិនិស្សគ្គោ តណ្ហក្ខយោ វិរាគោ និរោធោ និព្ពានំ ។ គច្ឆេយ្យ ជរាមរណស្ស បារន្តិ បារំ គច្ឆេយ្យ

ប្រសិនបើ នៃប្រស្នាមោឃរាជមាណពមួយ ៗ ប្រសិនបើ នៃប្រស្នាបិង្គិយមាណពមួយ ៗ ហេតុនោះ (លោកពោលថា) ប្រសិនបើ នៃប្រស្នាមួយៗ ។

(១០៧) ពាក្យថា បានដឹងអត្ថ បានដឹងធម៌ គឺបានដឹង យល់ ពិចារណា ត្រិះរិះ សំដែង ធ្វើឲ្យប្រាកដនូវសេចក្តីថា ធម៌គឺប្រស្នានោះឯង អត្ថគឺការដោះស្រាយនោះឯង ហេតុនោះ (លោកពោលថា) បានដឹងអត្ថ ។ ពាក្យថា បានដឹងធម៌ គឺបានដឹង យល់ ពិចារណា ត្រិះរិះ សំដែង ធ្វើឲ្យប្រាកដនូវធម៌ ហេតុនោះ (លោកពោលថា) បានដឹងធម៌ ។

(១០៨) ពាក្យថា ប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ គឺ ប្រតិបត្តិសម្មាបដិបទា អនុលោមប្បដិបទា អបច្ចនីកប្បដិបទា អន្វត្ថប្បដិបទា ធម្មានុធម្មប្បដិបទា ហេតុនោះ (លោកពោលថា) ប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ ។

(១០៩) ពាក្យថា ទៅកាន់ត្រើយ នៃជរានិងមរណៈ ពុំខាន សេចក្តីថា អមតនិព្វាន លោកហៅថា ត្រើយនៃជរានិងមរណៈ បានដល់ សេចក្តីរម្ងាប់សង្ខារទាំងពួង ការរលាស់ចោលឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ និព្វាន ។ ពាក្យថា នឹងទៅកាន់ត្រើយ នៃជរានិងមរណៈពុំខាន បានសេចក្តីថា នឹងទៅកាន់ត្រើយ

បារំ អធិគច្ឆេយ្យ បារំ ផុសេយ្យ បារំ សច្ឆិករេយ្យាតិ គច្ឆេយ្យ ជរាមរណស្ស បារំ ។

(១១០) បារគមនីយា(១) ឥមេ ធម្មាតិ ឥមេ ធម្មា បារគមនីយា បារំ បាបេន្តិ បារំ សម្បាបេន្តិ បារំ សមនុបាបេន្តិ ជរាមរណស្ស តារណាយ សំវត្តន្តីតិ បារគមនីយា ឥមេ ធម្មា ។

(១១១) តស្មា ឥមស្ស ធម្មបរិយាយស្សាតិ តស្មាតិ តស្មា តំការណា តំហេតុ តប្បច្ចយា តំនិទានាតិ តស្មា ។ ឥមស្ស ធម្មបរិយាយស្សាតិ ឥមស្ស បារាយនស្សាតិ តស្មា ឥមស្ស ធម្មបរិយាយស្ស ។

(១១២) បារាយនន្តេវ អធិវចនន្តិ បារំ វុច្ចតិ អមតំ និព្វានំ យោ សោ សព្វសង្ខារសមថោ សព្វុបធិប្បដិនិស្សគ្គោ តណ្ហក្ខយោ វិរាគោ និរោធោ និព្វានំ ។ អយនំ វុច្ចតិ មគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ អធិវចនន្តិ នាមំ សង្ខា សមញ្ញា បញ្ញត្តិ ។ បេ ។

---

១ ម. បារំគមនិយោ ។

នឹងបានត្រើយ នឹងប៉ះពាល់ត្រើយ នឹងធ្វើឲ្យជាក់ច្បាស់នូវត្រើយ ហេតុនោះ (លោកពោលថា) នឹងទៅកាន់ត្រើយ នៃជរានឹងមរណៈពុំមាន ។

(១១០) ពាក្យថា ធម៌ទាំងនេះ ជាធម៌គួរនាំសត្វទៅកាន់ត្រើយ សេចក្ដីថា ធម៌ទាំងនេះ ជាធម៌គួរនាំសត្វទៅកាន់ត្រើយ គឺ ញុំាងសត្វឲ្យដល់ត្រើយ ឲ្យដល់ព្រមនូវត្រើយ ឲ្យដល់ស៊ប់នូវត្រើយ គឺ ជាប្រព្រឹត្តទៅដើម្បីឆ្លងជរានឹងមរណៈ ហេតុនោះ (លោកពោលថា) ធម៌ទាំងនេះ ជាធម៌គួរនាំសត្វទៅកាន់ត្រើយ ។

(១១១) ពាក្យថា ហេតុនោះ . . .នៃធម្មបរិយាយនេះ ត្រង់ពាក្យថា ហេតុនោះ គឺ ព្រោះហេតុនោះ ព្រោះដំណើរនោះ ព្រោះហេតុដូច្នោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ ហេតុនោះ (លោកពោលថា) ហេតុនោះ ។ ពាក្យថា នៃធម្មបរិយាយនេះ គឺ នៃបារាយនៈនេះ ហេតុនោះ (លោកពោលថា) ហេតុនោះ . . . នៃធម្មបរិយាយនេះ ។

(១១២) ពាក្យថា បារាយនៈ ជាឈ្មោះ សេចក្ដីថា អមតនិព្វាន លោកហៅថា បារៈ បានខាងការរម្ងាប់សង្ខារទាំងពួង ការលះបង់ឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ និព្វាន ។ មគ្គគឺសម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ លោកហៅថា អាយនៈ ។ ពាក្យថា ឈ្មោះ គឺជានាម ការរាប់ សេចក្ដីសំគាល់ បញ្ញត្តិ ។ បេ ។

អភិលា ហោតិ ចាគយនន្តេវ អធិវចនំ ។

(១១៣) អជិតោ តិស្សមេត្តេយ្យោ បុណ្ណកោ អថ មេត្តគូ
ធោតកោ ឧបសីវោ ច នន្ទោ ច អថ ហេមកោ
តោទេយ្យកប្បា ទុភយោ ជតុកណ្ណី ច បណ្ឌិតោ
ភទ្រាវុធោ ឧទយោ ច បោសាលោ ចាបិ
ព្រាហ្មណោ
មោឃរាជា ច មេធាវី បិង្គិយោ ច មហាឥសិ
ឯតេ ពុទ្ធំ ឧបាគញ្ឆុំ សម្បន្នចរណំ ឥសឹ
បុច្ឆន្តា និបុណេ បញ្ហេ ពុទ្ធសេដ្ឋំ ឧបាគមុំ ។

(១១៤) ឯតេ ពុទ្ធំ ឧបាគញ្ឆុន្តិ ឯតេតិ(១) ព្រាហ្មណា ។ ពុទ្ធោតិ យោ សោ ភគវា សយម្ភូ អនាចរិយកោ បុព្វេ អននុស្សុតេសុ ធម្មេសុ សាមំ សច្ចានិ អភិសម្ពុជ្ឈិ តត្ថ ច សព្វញ្ញុតំ បត្តោ ពលេសុ ច វសីភាវំ ។ ពុទ្ធោតិ កេនដ្ឋេន ពុទ្ធោ ។

---

១ ម. ឯតេតិ សោឡសបារាយនិយា ព្រាហ្មណា ។

ជាពាក្យសម្រាប់ហៅ ហេតុនោះ (លោកពោលថា) ពាក្យថា ធាកយនៈ ជាឈ្មោះ ។

(១១៣) អជិតៈ ១ តិស្សមេត្តេយ្យៈ ១ បុណ្ណកៈ ១ មេត្តគូ ១ ធោតកៈ ១ ឧបសីវៈ ១ នន្ទៈ ១ ហេមកៈ ១ ជនទាំងពីរនាក់ គឺ តោទេយ្យៈ ១ កប្បៈ ១ នឹងជតុកណ្ណីបណ្ឌិត ១ ភទ្រាវុធ ១ ឧទយៈ ១ បោសាលព្រាហ្មណ៍ ១ មោឃរាជ ជាអ្នកប្រាជ្ញ ១ បិង្គិយៈ ជាអ្នកស្វែងរកគុណធំ ១ ព្រាហ្មណ៍ទាំង ១៦ នាក់នុ៎ះ ចូលមកគាល់ព្រះពុទ្ធជាឥសី ទ្រង់មានចរណៈបរិបូណ៌ បានចូលមកគាល់ សួរប្រស្នាដ៏ល្អិត ចំពោះព្រះពុទ្ធប្រសើរ ។

(១១៤) អធិប្បាយពាក្យថា ព្រាហ្មណ៍ទាំង ១៦ នាក់នុ៎ះ ចូលមកគាល់ព្រះពុទ្ធ ត្រង់ពាក្យថា នុ៎ះ គឺពួកព្រាហ្មណ៍នុ៎ះ ។ ពាក្យថា ព្រះពុទ្ធ បានដល់ព្រះមានព្រះភាគទ្រង់ត្រាស់ដឹងឯង មិនមានបុគ្គលជាអាចារ្យ បានត្រាស់ដឹងដោយព្រះអង្គឯង នូវសច្ចៈទាំងឡាយ ក្នុងធម៌ទាំងឡាយដែលព្រះអង្គមិនធ្លាប់ឮហើយក្នុងកាលមុន ទាំងបានដល់សព្វញ្ញុតញ្ញាណក្នុងសច្ចៈទាំងនោះ នឹងភាវៈស្ទាត់ក្នុងពលៈទាំងឡាយ ។ សំនួរត្រង់ពាក្យថា ព្រះពុទ្ធ ចុះឈ្មោះថាព្រះពុទ្ធ ដោយអត្ថដូចម្តេច ។

ពុជ្ឈិតា សច្ចានីតិ ពុទ្ធោ ។ ពោធេតា បជាយាតិ ពុទ្ធោ ។ សព្វញ្ញុតាយ ពុទ្ធោ ។ សព្វទស្សាវិតាយ ពុទ្ធោ ។ អភិញ្ញេយ្យតាយ ពុទ្ធោ ។ វិកសិតាយ ពុទ្ធោ ។ ខីណាសវសង្ខាតេន ពុទ្ធោ ។ និរុបក្កិលេសសង្ខាតេន ពុទ្ធោ ។ ឯកន្តវីតរាគោតិ ពុទ្ធោ ។ ឯកន្តវីតទោសោតិ ពុទ្ធោ ។ ឯកន្តវីតមោហោតិ ពុទ្ធោ ។ ឯកន្តនិក្កិលេសោតិ ពុទ្ធោ ។ ឯកាយនមគ្គំ គតោតិ ពុទ្ធោ ។ ឯកោ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោតិ ពុទ្ធោ ។ អពុទ្ធិវិហតត្តា ពុទ្ធិប្បដិលាភា ពុទ្ធោ ។ ពុទ្ធោតិ នេតំ នាមំ មាតរា កតំ ន បិតរា កតំ ន ភាតរា កតំ ន ភគិនិយា កតំ

ឈ្មោះថាព្រះពុទ្ធ ព្រោះហេតុទ្រង់ត្រាស់ដឹងសច្ចៈទាំងឡាយ ។ ឈ្មោះថាព្រះពុទ្ធ ព្រោះហេតុទ្រង់ញុំាងពពួកសត្វឲ្យត្រាស់ដឹង ។ ឈ្មោះថាព្រះពុទ្ធ ព្រោះព្រះអង្គដឹងធម៌ទាំងពួង ។ ឈ្មោះថាព្រះពុទ្ធ ព្រោះព្រះអង្គឃើញធម៌ទាំងពួង ។ ឈ្មោះថាព្រះពុទ្ធ ព្រោះព្រះអង្គដឹងច្បាស់ ។ ឈ្មោះថាព្រះពុទ្ធ ព្រោះព្រះអង្គរីកហើយ ។ ឈ្មោះថាព្រះពុទ្ធ ព្រោះគេពោលថា ព្រះអង្គមានអាសវៈអស់ហើយ ។ ឈ្មោះថាព្រះពុទ្ធ ព្រោះគេពោលថា ព្រះអង្គមានឧបក្កិលេសចេញហើយ ។ ឈ្មោះថាព្រះពុទ្ធ ព្រោះហេតុទ្រង់ប្រាសចាករាគៈដោយចំណែកមួយ ។ ឈ្មោះថាព្រះពុទ្ធ ព្រោះហេតុទ្រង់ប្រាសចាកទោសៈដោយចំណែកមួយ ។ ឈ្មោះថាព្រះពុទ្ធ ព្រោះហេតុទ្រង់ប្រាសចាកមោហៈដោយចំណែកមួយ ។ ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុទ្រង់មានកិលេសចេញហើយដោយចំណែកមួយ ។ ឈ្មោះថាព្រះពុទ្ធ ព្រោះហេតុទ្រង់ទៅហើយកាន់ផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង ។ ឈ្មោះថាព្រះពុទ្ធ ព្រោះហេតុទ្រង់ជាបុគ្គលឯក ត្រាស់ដឹងចំពោះសម្មាសម្ពោធិញ្ញាណ មិនមានគុណជាតដទៃក្រៃលែងជាង ។ ឈ្មោះថាព្រះពុទ្ធ ព្រោះទ្រង់កំចាត់បង់សេចក្ដីល្ងង់ព្រោះការបាននូវប្រាជ្ញា ។ ព្រះនាមព្រះពុទ្ធនុ៎ះ មិនមែនព្រះមាតាថ្វាយ មិនមែនព្រះបិតាថ្វាយ មិនមែនបងប្អូនប្រុសថ្វាយ មិនមែនបងប្អូនស្រីថ្វាយ

ន មិត្តាមច្ចេហិ កតំ ន ញាតិសាលោហិតេហិ កតំ ន សមណព្រាហ្មណេហិ កតំ ន ទេវតាហិ កតំ វិមោក្ខន្តិកមេតំ ពុទ្ធានំ ភគវន្តានំ ពោធិយា មូលេ សហ សព្វញ្ញុតញ្ញាណស្ស បដិលាភា សច្ឆិកា បញ្ញត្តិ យទិទំ ពុទ្ធោតិ ពុទ្ធំ ។ យេ តេ ពុទ្ធំ ឧបគច្ឆន្តិ យេ តេ ពុទ្ធំ ឧបគមឹសុ ឧបសង្កមឹសុ បយិរុបាសឹសុ បរិបុច្ឆឹសុ បរិបញ្ហឹសូតិ យេ តេ ពុទ្ធំ ឧបគច្ឆុំ ។

(១១៩) សម្បន្នចរណំ ឥសិន្តិ ចរណំ វុច្ចតិ សីលាចារនិប្ផត្តិ ។ សីលសំវរោបិ ចរណំ ឥន្ទ្រិយសំវរោបិ ចរណំ ភោជនេ មត្តញ្ញុតាបិ ចរណំ ជាគរិយានុយោគោបិ ចរណំ សត្តបិ សទ្ធម្មា ចរណំ ចត្តារិបិ ឈានានិ ចរណំ ។ សម្បន្នចរណន្តិ សម្បន្នចរណំ សេដ្ឋចរណំ បាមោក្ខចរណំ ឧត្តមចរណំ បវរចរណន្តិ សម្បន្នចរណំ ។

មិនមែនពួកមិត្តនិងអាមាត្យថ្វាយ មិនមែនពួកញាតិនិងសាលោហិតថ្វាយ មិនមែនពួកសមណព្រាហ្មណ៍ថ្វាយ មិនមែនពួកទេវតាថ្វាយទេ ព្រះនាមថា ព្រះពុទ្ធ នុ៎ះ របស់ព្រះពុទ្ធទាំងឡាយមានព្រះភាគ ជាព្រះនាមកើតក្នុងទីបំផុតនៃវិមោក្ខ បញ្ញត្តិថា ព្រះពុទ្ធ នេះ កើតព្រោះការត្រាស់ដឹងព្រមដោយការបានចំពោះនូវសព្វញ្ញុតញ្ញាណ ទៀបគល់ពោធិព្រឹក្ស ហេតុនោះ (លោកពោលថា) ព្រះពុទ្ធ ។ ពាក្យថា នុ៎ះ ចូលមកគាល់ព្រះពុទ្ធ គឺ ព្រាហ្មណ៍ទាំងនុ៎ះ ចូលមករក ចូលមកជិត មកអង្គុយជិត សាកសួរដណ្តឹងសួរ នូវព្រះពុទ្ធ ហេតុនោះ (លោកពោលថា) ព្រាហ្មណ៍ទាំង ១៦ នាក់នុ៎ះ ចូលមកគាល់ព្រះពុទ្ធ ។

(១១៩) ពាក្យថា ជាឥសី មានចរណៈបរិបូណ៌ អធិប្បាយថា ការសម្រេចដោយសីលាចារៈ លោកហៅថា ចរណៈ ។ ការសង្រួមសីល ឈ្មោះថាចរណៈ ការសង្រួមឥន្ទ្រិយ ឈ្មោះថាចរណៈ ភាពជាអ្នកដឹងប្រមាណក្នុងភោជន ឈ្មោះថាចរណៈ ការប្រកបរឿយ ៗ នូវសេចក្តីភ្ញាក់រឭក ឈ្មោះថាចរណៈ ព្រះសទ្ធម្មទាំង ៧ ឈ្មោះថាចរណៈ ឈានទាំង ៤ ឈ្មោះថាចរណៈ ។ ពាក្យថា មានចរណៈបរិបូណ៌ គឺមានចរណៈគ្រប់គ្រាន់ មានចរណៈដ៏ប្រសើរ មានចរណៈជាប្រធាន មានចរណៈដ៏ឧត្តម មានចរណៈដ៏ថ្លៃថ្លា ហេតុនោះ (លោកពោលថា) មានចរណៈបរិបូណ៌ ។

## សោឡសមាណវកប្បញ្ហានិគមនិទ្ទេសោ

ឥសិន្តិ ឥសិ ។ ភគវា មហន្តំ សីលក្ខន្ធំ ឯសិ គវេសិ បរិយេសីតិ ឥសិ ។បេ។ មហេសក្ខេហិ វា សត្តេហិ ឯសិតោ គវេសិតោ បរិយេសិតោ កហំ ពុទ្ធោ កហំ ភគវា កហំ ទេវទេវោ កហំ នរាសភោតិ ឥសីតិ សម្ពន្ធចរណំ ឥសិ ។

(១១៦) បុច្ឆា និបុណោ បញ្ហោតិ បុច្ឆាតិ បុច្ឆា យាចនា អជ្ឈេសនា បសាទនា ។ និបុណោ បញ្ហោតិ គម្ភីរោ ទុទ្ទសោ ទុរនុពោធោ សន្តោ បណីតោ អតក្កាវចរោ និបុណោ បណ្ឌិតវេទនីយោ បញ្ហោតិ បុច្ឆា និបុណោ បញ្ហោ ។

(១១៧) ពុទ្ធសេដ្ឋំ ឧទាគមុន្តិ ពុទ្ធោតិ យោ សោ ភគវា ។បេ។ សច្ឆិកា បញ្ញត្តិ យទិទំ ពុទ្ធោតិ ។ សេដ្ឋន្តិ អគ្គំ សេដ្ឋំ វិសេដ្ឋំ បាមោក្ខំ ឧត្តមំ បវរន្តិ ពុទ្ធសេដ្ឋំ ។ ឧទាគមុន្តិ ឧទាគមឹសុ ឧបសង្កមឹសុ

ពាក្យថា ជាឥសី គឺជាអ្នកស្វែង ។ ព្រះមានព្រះភាគ ឈ្មោះថាឥសី ព្រោះហេតុទ្រង់ស្វែង ស្វែងរក ស្វះស្វែងនូវសីលក្ខន្ធដ៏ធំ ។ បេ ។ ឬថា ឈ្មោះថាឥសី ព្រោះហេតុព្រះមានព្រះភាគ ត្រូវសត្វទាំងឡាយមានសក្តិធំ រកស្វែង ស្វះស្វែងថា ព្រះពុទ្ធគង់ក្នុងទីណា ព្រះមានព្រះភាគគង់ក្នុងទីណា ព្រះពុទ្ធជាទេវតាដ៏ធំជាងទេវតា គង់ក្នុងទីណា ព្រះពុទ្ធជានរៈអង់អាច គង់ក្នុងទីណា ហេតុនោះ (លោកពោលថា) ជាឥសី មានចរណៈបរិបូណ៌ ។

(១១៦) ពាក្យថា សួរប្រស្នាដ៏ល្អិត ត្រង់ពាក្យថា សួរ គឺសួរ អង្វរ អារាធនា ជ្រះថ្លា ។ ពាក្យថា ប្រស្នាដ៏ល្អិត គឺ ប្រស្នាដ៏ជ្រាលជ្រៅ ដែលបុគ្គលឃើញបានដោយកម្រ ត្រាស់ដឹងបានដោយកម្រ ដ៏ល្អិតឧត្តម មិនជាទីស្ទង់ដោយសេចក្តីត្រិះរិះ ជាប្រស្នាដ៏ម៉ត់ចត់ មានតែបណ្ឌិតទើបដឹងបាន ហេតុនោះ (លោកពោលថា) សួរប្រស្នាដ៏ល្អិត ។

(១១៧) ពាក្យថា ព្រះពុទ្ធ ក្នុងបទថា ចូលមកគាល់ព្រះពុទ្ធប្រសើរ គឺ ព្រះមានព្រះភាគ ។ បេ ។ បញ្ញត្តិថា ព្រះពុទ្ធ នេះ (កើត) ព្រោះការត្រាស់ដឹង ។ ពាក្យថា ប្រសើរ គឺ លើស ប្រសើរ ប្រសើរវិសេស ជាប្រធាន ឧត្តម ថ្លៃថ្លា ហេតុនោះ (លោកពោលថា) ព្រះពុទ្ធប្រសើរ ។ ពាក្យថា ចូលមកគាល់ គឺ ចូលមករក ចូលមកជិត

បយិរុបាសឹសុ បរិបុច្ឆឹសុ បរិបញ្ហឹសូតិ ពុទ្ធសេដ្ឋំ ឧបាគមុំ ។ តេនេតំ វុច្ចតិ

ឯតេ ពុទ្ធំ ឧបាគញ្ឆុំ សម្បន្នចរណំ ឥសឹ

បុច្ឆន្តា និបុណេ បញ្ហេ ពុទ្ធសេដ្ឋំ ឧបាគមុន្តិ ។

(១១៨) តេសំ ពុទ្ធោ ព្យាកាសិ

បញ្ហំ បុដ្ឋោ យថាតថំ

បញ្ហានំ វេយ្យាករណេន

តោសេសិ ព្រាហ្មណេ មុនិ ។

(១១៩) តេសំ ពុទ្ធោ ព្យាកាសីតិ តេសន្តិ សោឡសន្នំ បារាយនិយានំ ព្រាហ្មណានំ ។ ពុទ្ធោតិ យោ សោ ភគវា ។បេ។ សច្ឆិកា បញ្ញត្តិ យទិទំ ពុទ្ធោតិ ។ ព្យាកាសីតិ តេសំ ពុទ្ធោ ព្យាកាសិ អាចិក្ខិ ទេសេសិ បញ្ញបេសិ បដ្ឋបេសិ វិវរិ វិភជិ ឧត្តានីមកាសិ បកាសេសីតិ តេសំ ពុទ្ធោ ព្យាកាសិ ។

ចូលមកអង្គុយជិត សាកសួរ ដណ្តឹងសួរ ហេតុនោះ (លោកពោលថា) ចូលមកគាល់ព្រះពុទ្ធប្រសើរ ។ ហេតុនោះ លោកពោលពាក្យនេះថា

ព្រាហ្មណ៍ទាំង ១៦នាក់នុ៎ះ ចូលមកគាល់ព្រះពុទ្ធ
ជាឥសី ទ្រង់មានចរណៈបរិបូណ៌ បានចូលមកគាល់
សួរប្រស្នាដ៏ល្អិត ចំពោះព្រះពុទ្ធប្រសើរ ។

(១១៨) ព្រះពុទ្ធ ដែលព្រាហ្មណ៍ទាំងនោះ សួរប្រស្នា
ហើយ ក៏ទ្រង់ព្យាករហើយ តាមសេចក្តីពិត ព្រះ
មុនិ បានទ្រង់ញុំាងពួកព្រាហ្មណ៍ឲ្យត្រេកអរ
ដោយការព្យាករណ៍ប្រស្នាទាំងឡាយ ។

(១១៩) ពាក្យថា ព្រះពុទ្ធ ដែលព្រាហ្មណ៍ទាំងនោះ(សួរប្រស្នាហើយ) ក៏ទ្រង់ព្យាករហើយ ត្រង់ពាក្យថា ដែលព្រាហ្មណ៍ទាំងនោះ គឺដែលពួកព្រាហ្មណ៍ទាំង ១៦ ជាអ្នកសួរទៅកាន់ត្រើយ ។ ពាក្យថា ព្រះពុទ្ធ បានដល់ព្រះមានព្រះភាគ ។ បេ ។ បញ្ញត្តិថា ព្រះពុទ្ធ នេះ (កើត) ព្រោះការត្រាស់ដឹង ។ ពាក្យថា ទ្រង់ព្យាករហើយ គឺ ព្រះពុទ្ធទ្រង់ព្យាករ ប្រាប់ សំដែង តែងតាំង តាំងផ្តើម បើក វែកញែក ធ្វើឲ្យរាក់ ប្រកាសហើយ ចំពោះជនទាំងនោះ ហេតុនោះ (លោកពោលថា) ព្រះពុទ្ធដែលព្រាហ្មណ៍ទាំងនោះ (សួរប្រស្នាហើយ) ទ្រង់ព្យាករហើយ ។

## សោឡសមាណវកប្បញ្ហានិគមនិទ្ទេសោ

(១២០) បញ្ហំ បុដ្ឋា យថាតថន្តិ បញ្ហំ បុដ្ឋាតិ បញ្ហំ បុច្ឆិតោ យាចិតោ អជ្ឈេសិតោ បសាទិតោ ។ យថាតថន្តិ យថា អាចិក្ខិតព្វំ តថា អាចិក្ខិ យថា ទេសិតព្វំ តថា ទេសេសិ យថា បញ្ញបេតព្វំ តថា បញ្ញបេសិ យថា បដ្ឋបេតព្វំ តថា បដ្ឋបេសិ យថា វិវរិតព្វំ តថា វិវរិ យថា វិភជិតព្វំ តថា វិភជិ យថា ឧត្តានីកាតព្វំ តថា ឧត្តានីមកាសិ យថា បកាសេតព្វំ តថា បកាសេសីតិ បញ្ហំ បុដ្ឋា យថាតថំ ។

(១២១) បញ្ហានំ វេយ្យាករណេនាតិ បញ្ហានំ វេយ្យាករណេន អាចិក្ខនេន ទេសនេន បញ្ញបនេន បដ្ឋបនេន វិវរេន វិភជនេន ឧត្តានីកម្មេន បកាសនេនាតិ បញ្ហានំ វេយ្យាករណេន ។

(១២២) តោសេសិ ព្រាហ្មណោ មុនីតិ តោសេសីតិ តោសេសិ វិតោសេសិ បសាទេសិ អារាធេសិ អត្តមនេ អកាសិ ។

(១៦០) ពាក្យថា សួរប្រស្នាហើយ . . . តាមសេចក្តីពិត ត្រង់ពាក្យថា សួរប្រស្នាហើយ គឺ អង្វរ អារាធនា ឲ្យជ្រះថ្លាហើយ នូវប្រស្នា ។ ពាក្យថា តាមសេចក្តីពិត គឺ គួរប្រាប់យ៉ាងណា ទ្រង់ប្រាប់យ៉ាងនោះ គួរសំដែងយ៉ាងណា ទ្រង់សំដែងយ៉ាងនោះ គួរតែងតាំងយ៉ាងណា ទ្រង់តែងតាំងយ៉ាងនោះ គួរតាំងផ្តើមយ៉ាងណា ទ្រង់តាំងផ្តើមយ៉ាងនោះ គួរបើកយ៉ាងណា ទ្រង់បើកយ៉ាងនោះ គួរវែកញែកយ៉ាងណា ទ្រង់វែកញែកយ៉ាងនោះ គួរធ្វើឲ្យរាក់យ៉ាងណា ទ្រង់ធ្វើឲ្យរាក់យ៉ាងនោះ គួរប្រកាសយ៉ាងណា ទ្រង់ប្រកាសយ៉ាងនោះ ហេតុនោះ (លោកពោលថា) សួរប្រស្នាហើយ . . . តាមសេចក្តីពិត ។

(១៦១) ពាក្យថា ដោយការព្យាករណ៍ប្រស្នាទាំងឡាយ គឺ ដោយការព្យាករណ៍ ការប្រាប់ ការសំដែង ការតែងតាំង ការតាំងផ្តើម ការបើក ការវែកញែក ការធ្វើឲ្យរាក់ ការប្រកាស នូវប្រស្នាទាំងឡាយ ហេតុនោះ (លោកពោលថា) ដោយការព្យាករណ៍ប្រស្នាទាំងឡាយ ។

(១៦២) ពាក្យថា ឲ្យត្រេកអរ ក្នុងបទថា ព្រះមុនិបានទ្រង់ញុំាងពួកព្រាហ្មណ៍ឲ្យត្រេកអរ គឺ ឲ្យត្រេកអរ ឲ្យត្រេកអរវិសេស ឲ្យជ្រះថ្លា ឲ្យស្រស់ស្រាយ បានធ្វើពួកព្រាហ្មណ៍ទាំងនោះឲ្យមានចិត្តរីករាយ ។

ព្រាហ្មណេតិ សោឡស បារាយនិយេ ព្រាហ្មណេ ។ មុនីតិ មោនំ វុច្ចតិ ញាណំ យា បញ្ញា បជានានា ។ បេ ។ សង្គជាលមតិច្ច សោ មុនីតិ តោសេសិ ព្រាហ្មណេ មុនិ ។ តេនេតំ វុច្ចតិ

តេសំ ពុទ្ធោ ព្យាកាសិ   បញ្ហេ បុដ្ឋោ យថាតថំ
បញ្ហានំ វេយ្យាករណេន   តោសេសិ ព្រាហ្មណេ
មុនីតិ ។

(១២៣) តេ តោសិតា ចក្ខុមតា   ពុទ្ធេនាទិច្ចពន្ធុនា
ព្រហ្មចរិយមចរឹសុ   វរបញ្ញស្ស សន្តិកេ ។

(១២៤) តេ តោសិតា ចក្ខុមតាតិ តេតិ សោឡស បារាយនិយា ព្រាហ្មណា ។ តោសិតាតិ តោសិតា វិតោសិតា បសាទិតា អារាធិតា អត្តមនា កតាតិ តេ តោសិតា ។

ពាក្យថា ញុំាងពួកព្រាហ្មណ៍ គឺ ពន្យល់ពួកព្រាហ្មណ៍ទាំង ១៦ ដែលជាអ្នកគួរដល់ត្រើយ ។ ពាក្យថា ព្រះមុនិ សេចក្តីថា ញាណ លោកហៅថា មោនៈ បានដល់ បញ្ញា ការដឹងច្បាស់ ។ បេ ។ បុគ្គលណាកន្លងបង់នូវបណ្តាញ ជាគ្រឿងជាប់ចំពាក់ បុគ្គលនោះ ឈ្មោះថាមុនិ ហេតុនោះ (លោកពោលថា) ព្រះមុនិបានទ្រង់ញុំាងពួកព្រាហ្មណ៍ឲ្យត្រេកអរ ។ ហេតុនោះ លោកពោលពាក្យនេះថា

ព្រះពុទ្ធ ដែលព្រាហ្មណ៍ទាំងនោះ សួរប្រស្នាហើយ ក៏ទ្រង់
ព្យាករហើយ តាមសេចក្តីពិត ព្រះមុនិ បានញុំាងពួកព្រាហ្មណ៍
ឲ្យត្រេកអរ ដោយការព្យាករណ៍ប្រស្នាទាំងឡាយ ។

(១២៣) ជនទាំងនោះ ដែលព្រះពុទ្ធទ្រង់ជាផៅពង្ស នៃព្រះ
អាទិត្យ មានចក្ខុ បានឲ្យត្រេកអរហើយ ក៏បានប្រព្រឹត្ត
ព្រហ្មចរិយៈ ក្នុងសំណាក់ព្រះសាស្តា មានបញ្ញាប្រសើរ ។

(១២៤) ពាក្យថា ជនទាំងនោះ ដែលព្រះពុទ្ធ មានចក្ខុ បានឲ្យត្រេកអរហើយ ត្រង់ពាក្យថា ជនទាំងនោះ គឺពួកព្រាហ្មណ៍ ទាំង ១៦ ដែលគួរទៅកាន់ត្រើយ ។ ពាក្យថា បានឲ្យត្រេកអរ គឺបានឲ្យត្រេកអរ ឲ្យត្រេកអរវិសេស ឲ្យជ្រះថ្លា ឲ្យស្រស់ស្រាយ ធ្វើឲ្យមានចិត្តរីករាយ ហេតុនោះ (លោកពោលថា) ជនទាំងនោះ . . . បានឲ្យត្រេកអរហើយ ។

សោឡសមាណវកប្បញ្ហានិគមនិទ្ទេសោ

ចក្ខុមតាតិ ភគវា បញ្ចហិ ចក្ខូហិ ចក្ខុមា មំស-
ចក្ខុនាបិ ចក្ខុមា ទិព្វចក្ខុនាបិ ចក្ខុមា បញ្ញា-
ចក្ខុនាបិ ចក្ខុមា ពុទ្ធចក្ខុនាបិ ចក្ខុមា សមន្ត-
ចក្ខុនាបិ ចក្ខុមា ។ កថំ ភគវា មំសចក្ខុនាបិ
ចក្ខុមា ។បេ។ ឯវំ ភគវា សមន្តចក្ខុនាបិ
ចក្ខុអាតិ តេ តោសិតា ចក្ខុមតា ។

(១២៤) ពុទ្ធេនាទិច្ចពន្ធុនាតិ ពុទ្ធេនាតិ យោ
សោ ភគវា ។បេ។ សច្ឆិកា បញ្ញត្តិ យទិទំ
ពុទ្ធោតិ ។ អាទិច្ចពន្ធុនាតិ អាទិច្ចោ វុច្ចតិ សុរិ-
យោ ។ សោ គោតមោ គោត្តេន ភគវាបិ គោត-
មោ គោត្តេន ភគវា សុរិយស្ស គោត្តញាតកោ
គោត្តពន្ធុ តស្មា ពុទ្ធោ អាទិច្ចពន្ធូតិ ពុទ្ធេនាទិច្ច-
ពន្ធុនា ។

(១២៥) ព្រហ្មចរិយមចរឹសូតិ ព្រហ្មចរិយំ
វុច្ចតិ អសទ្ធម្មសមាបត្តិយា អារតិ វិរតិ
បដិវិរតិ វេរមណី វិរមណំ អកិរិយា

ពាក្យថា មានចក្ខុ គឺ ព្រះមានព្រះភាគ មានចក្ខុដោយចក្ខុ ៥ គឺមានចក្ខុដោយមំសចក្ខុ ១ មានចក្ខុដោយទិព្វចក្ខុ ១ មានចក្ខុដោយបញ្ញាចក្ខុ ១ មានចក្ខុដោយពុទ្ធចក្ខុ ១ មានចក្ខុដោយសមន្តចក្ខុ ១ ។ ព្រះមានព្រះភាគ មានចក្ខុដោយមំសចក្ខុ តើដូចម្តេច ។ បេ ។ ព្រះមានព្រះភាគ មានចក្ខុដោយសមន្តចក្ខុ យ៉ាងនេះ ហេតុនោះ (លោកពោលថា) ជនទាំងនោះដែលព្រះពុទ្ធមានចក្ខុ បានឲ្យត្រេកអរហើយ ។

(១២៥) ពាក្យថា ព្រះពុទ្ធទ្រង់ជាផៅពង្ស នៃព្រះអាទិត្យ ត្រង់ពាក្យថា ព្រះពុទ្ធ បានដល់ព្រះមានព្រះភាគ ។ បេ ។ បញ្ញត្តិថា ព្រះពុទ្ធនេះ (កើត) ព្រោះការត្រាស់ដឹង ។ ពាក្យថា ទ្រង់ជាផៅពង្សនៃព្រះអាទិត្យ សេចក្តីថា សុរិយៈ លោកហៅថា ព្រះអាទិត្យ ។ សុរិយៈនោះជាគោតមៈដោយគោត្រ ព្រះមានព្រះភាគក៏ជាគោតមៈដោយគោត្រ ព្រះមានព្រះភាគ ជាញាតិដោយគោត្រ ជាផៅពង្សដោយគោត្រនៃសុរិយៈ ហេតុនោះ ព្រះពុទ្ធ ឈ្មោះថាជាផៅពង្សនៃព្រះអាទិត្យ ហេតុនោះ (លោកពោលថា) ដែលព្រះពុទ្ធទ្រង់ជាផៅពង្ស នៃព្រះអាទិត្យ ។

(១២៦) ពាក្យថា បានប្រព្រឹត្តព្រហ្មចរិយៈ សេចក្តីថា ការវៀរ ការវាង ការវាងស្រឡះ ចេតនាជាហេតុវៀរ ការវៀរ ការមិនធ្វើ

អការណំ អនាបត្តិ វេលាអនតិក្កមោ សេតុឃាតោ ។ អបិច និប្បរិយាយេន ព្រហ្មចរិយំ វុច្ចតិ អរិយោ អដ្ឋង្គិកោ មគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។ ព្រហ្មចរិយមចរឹសូតិ ព្រហ្មចរិយំ អចរឹសុ សមាទាយ វត្តឹសូតិ ព្រហ្មចរិយមចរឹសុ ។

(១២៧) វរបញ្ញស្ស សន្តិកេតិ វរបញ្ញស្ស អគ្គបញ្ញស្ស សេដ្ឋបញ្ញស្ស បាមោក្ខបញ្ញស្ស ឧត្តមបញ្ញស្ស បវរបញ្ញស្ស ។ សន្តិកេតិ សន្តិកេ សាមន្តា អាសន្នេ អវិទូរេ ឧបក្កដ្ឋេតិ វរបញ្ញស្ស សន្តិកេ ។ តេនេតំ វុច្ចតិ

ការមិនសាង ការមិនសម្ភព ការមិនប្រព្រឹត្តិកន្លងកម្រិត ការផ្តាច់ស្ពាន ក្នុងការប្រកបដោយអសទ្ធម្ម លោកហៅថា ព្រហ្មចរិយៈ ។ មួយទៀត បើពោលដោយអំណាចនិប្បរិយាយ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ គឺ ប្រាជ្ញាយល់ឃើញត្រូវ សេចក្តីត្រិះរិះត្រូវ សំដីត្រូវ ការងារត្រូវ ការចិញ្ចឹមជីវិតត្រូវ ការព្យាយាមត្រូវ សេចក្តីរលឹកត្រូវ ការតម្កល់ចិត្តឲ្យនឹងត្រូវ លោកហៅថា ព្រហ្មចរិយៈ ។ ពាក្យថា បានប្រព្រឹត្តព្រហ្មចរិយៈ គឺ បានប្រព្រឹត្ត ប្រព្រឹត្តសមាទានព្រហ្មចរិយៈ ហេតុនោះ (លោកពោលថា) ក៏បានប្រព្រឹត្តព្រហ្មចរិយៈ ។

(១៤៧) ពាក្យថា ក្នុងសំណាក់ព្រះសាស្តា មានប្រាជ្ញាប្រសើរ គឺ ព្រះសាស្តាមានប្រាជ្ញាប្រសើរ មានប្រាជ្ញាដ៏លើស មានប្រាជ្ញាប្រសើរបំផុត មានប្រាជ្ញាជាប្រធាន មានប្រាជ្ញាដ៏ឧត្តម មានប្រាជ្ញាដ៏ថ្លៃថ្លា ។ ពាក្យថា ក្នុងសំណាក់ គឺ ក្នុងសំណាក់ ក្បែរ ជិត មិនឆ្ងាយ កៀក ហេតុនោះ (លោកពោលថា) ក្នុងសំណាក់ព្រះសាស្តា មានប្រាជ្ញាប្រសើរ ។ ហេតុនោះ លោកពោលពាក្យនេះថា

## សោឡសមាណវកប្បញ្ហានិគមនិទ្ទេសោ

តេ តោសិតា ចក្ខុមតា ពុទ្ធេនាទិច្ចពន្ធុនា

ព្រហ្មចរិយមចរឹសុ វរប្បញ្ញស្ស សន្តិកេតិ ។

(១២៨) ឯកមេកស្ស បញ្ហស្ស យថា ពុទ្ធេន ទេសិតំ

តថា យោ បដិបជ្ជេយ្យ គច្ឆេ បារំ អបារតោ ។

(១២៩) ឯកមេកស្ស បញ្ហស្សាតិ ឯកមេកស្ស អជិតប្បញ្ហស្ស ឯកមេកស្ស តិស្សមេត្តេយ្យប្បញ្ហស្ស ។ បេ ។ ឯកមេកស្ស បិង្គិយប្បញ្ហស្សាតិ ឯកមេ-កស្ស បញ្ហស្ស ។

(១៣០) យថា ពុទ្ធេន ទេសិតន្តិ ពុទ្ធោតិ យោ សោ ភគវា ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិ-ទំ ពុទ្ធោតិ ។ យថា ពុទ្ធេន ទេសិតន្តិ យថា ពុទ្ធេ-ន អាចិក្ខិតំ ទេសិតំ បញ្ញបិតំ បដ្ឋបិតំ វិវរិតំ វិ-ភត្តំ ឧត្តានីកតំ បកាសិតន្តិ យថា ពុទ្ធេន ទេ-សិតំ ។

សោឡសមាណវកប្បញ្ហានិគមនិទ្ទេស

ជនទាំងនោះដែលព្រះពុទ្ធទ្រង់ជាផៅពង្សនៃព្រះអាទិត្យ
មានចក្ខុ បានឲ្យត្រេកអរហើយ ក៏បានប្រព្រឹត្តព្រហ្ម-
ចរិយៈ ក្នុងសំណាក់ព្រះសាស្តា មានប្រាជ្ញាប្រសើរ ។
(១២៨) សេចក្តីនៃប្រស្នាមួយ ៗ ដែលព្រះពុទ្ធសំដែងហើយ
យ៉ាងណា បើបុគ្គលណាប្រតិបត្តិតាមយ៉ាងនោះ បុគ្គល
នោះ នឹងចេញអំពីទីមិនមែនត្រើយ ទៅកាន់ត្រើយបាន ។

(១២៩) ពាក្យថា នៃប្រស្នាមួយ ៗ គឺនៃប្រស្នាអជិតមាណពមួយ ៗ នៃប្រស្នាតិស្សមេត្តេយ្យមាណពមួយៗ ។ បេ ។ នៃប្រស្នាបិង្គិយមាណពមួយ ៗ ហេតុនោះ (លោកពោលថា) នៃប្រស្នាមួយ ៗ ។

(១៣០) ពាក្យថា ដែលព្រះពុទ្ធសំដែងហើយ យ៉ាងណា ត្រង់ពាក្យថា ព្រះពុទ្ធ បានដល់ព្រះមានព្រះភាគ ។ បេ ។ បញ្ញត្តិថា ព្រះពុទ្ធ នេះ (កើត) ព្រោះការត្រាស់ដឹង ។ ពាក្យថា ដែលព្រះពុទ្ធសំដែងហើយ យ៉ាងណា សេចក្តីថា ដែលព្រះពុទ្ធប្រាប់ សំដែង តែងតាំង តាំងផ្តើម បើក វែកញែក ធ្វើឲ្យពក់ ប្រកាសហើយ យ៉ាងណា ហេតុនោះ (លោកពោលថា) ដែលព្រះពុទ្ធសំដែងហើយ យ៉ាងណា ។

(១៣១) តថា យោ បដិបជ្ជេយ្យាតិ សម្មាបដិបទំ អនុលោមបដិបទំ អបច្ចនីកបដិបទំ អន្វត្ថបដិបទំ ធម្មានុធម្មបដិបទំ បដិបជ្ជេយ្យាតិ តថា យោ បដិបជ្ជេយ្យ ។

(១៣២) គច្ឆេ ទ្វារំ អទ្វារតោតិ ទ្វារំ វុច្ចតិ អមតំ និព្វានំ យោ សោ សព្វសង្ខារសមថោ សព្វូបធិបដិនិស្សគ្គោ តណ្ហក្ខយោ វិរាគោ និរោធោ និព្វានំ ។ អទ្វារំ វុច្ចន្តិ កិលេសា ច ខន្ធា ច អភិសង្ខារា ច ។ គច្ឆេ ទ្វារំ អទ្វារតោតិ អទ្វារតោ ទ្វារំ គច្ឆេយ្យ ទ្វារំ អធិគច្ឆេយ្យ ទ្វារំ ផុសេយ្យ ទ្វារំ សច្ឆិករេយ្យាតិ គច្ឆេ ទ្វារំ អទ្វារតោ ។ តេនេតំ វុច្ចតិ

(១៣១) ពាក្យថា បើបុគ្គលណាប្រតិបត្តិតាម យ៉ាងនោះ គឺ បើបុគ្គលប្រតិបត្តិសម្មាបដិបទា អនុលោមប្បដិបទា អបច្ចនីកប្បដិបទា អន្វត្ថប្បដិបទា ធម្មានុធម្មប្បដិបទា ហេតុនោះ (លោកពោលថា) បើបុគ្គលណាប្រតិបត្តិតាម យ៉ាងនោះ ។

(១៣២) ពាក្យថា បុគ្គលនោះនឹងចេញអំពីទីមិនមែនត្រើយ ទៅកាន់ត្រើយ សេចក្តីថា អមតនិព្វាន លោកហៅថា ត្រើយ បានដល់សេចក្តីរម្ងាប់សង្ខារទាំងពួង ការរលាស់ចោលឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក សេចក្តីរលត់ និព្វាន ។ កិលេសទាំងឡាយ ខន្ធទាំងឡាយ នឹងអភិសង្ខារទាំងឡាយ លោកហៅថា ទីមិនមែនត្រើយ ។ ពាក្យថា បុគ្គលនោះ នឹងចេញអំពីទីមិនមែនត្រើយ ទៅកាន់ត្រើយ គឺ បុគ្គលនោះនឹងចេញ អំពីទីមិនមែនត្រើយ ទៅកាន់ត្រើយ បានត្រើយ ពាល់ត្រូវត្រើយ ធ្វើឲ្យជាក់ច្បាស់ត្រើយ ហេតុនោះ (លោកពោលថា) បុគ្គលនោះ នឹងចេញអំពីទីមិនមែនត្រើយ ទៅកាន់ត្រើយ ។ ហេតុនោះ លោកពោលពាក្យនេះថា

សោឡសមាណវកបញ្ហានិទ្ទេសោ

ឯកាមេកស្ស បញ្ហស្ស យថា ពុទ្ធេន ទេសិតំ
តថា យោ បដិបជ្ជេយ្យ គច្ឆេ បារំ អបារតោតិ ។

(១៣៣) អបារា បារំ គច្ឆេយ្យ ភាវេន្តោ មគ្គមុត្តមំ
មគ្គោ សោ បារគមនាយ តស្មា បារាយនំ ឥតិ ។

(១៣៤) អបារា បារំ គច្ឆេយ្យាតិ អបារំ វុច្ចតិ កិលេសា ច ខន្ធា ច អភិសង្ខារា ច ។ បារំ វុច្ចតិ អមតំ និព្វានំ យោ សោ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហក្ខយោ វិរាគោ និរោធោ និព្វានំ ។ អបារា បារំ គច្ឆេយ្យាតិ អបារា បារំ គច្ឆេយ្យ បារំ អធិគច្ឆេយ្យ បារំ ផុសេយ្យ បារំ សច្ឆិករេយ្យាតិ អបារា បារំ គច្ឆេយ្យ ។

សេចក្ដីនៃប្រស្នាមួយ ៗ ដែលព្រះពុទ្ធសំដែងហើយ យ៉ាងណា បើបុគ្គលណាប្រតិបត្តិតាម យ៉ាងនោះ បុគ្គលនោះនឹងចេញអំពីទីមិនមែនត្រើយ ទៅកាន់ត្រើយបាន ។

(១៣៣) បុគ្គលកាលចម្រើនមគ្គដ៏ឧត្តម នឹងចេញអំពីទីមិនមែនត្រើយ ទៅកាន់ត្រើយបាន មគ្គនោះតែងប្រព្រឹត្តទៅដើម្បីទៅកាន់ត្រើយ ហេតុនោះ មគ្គ (លោកពោលថា) បារាយនៈ ដោយប្រការដូច្នេះ ។

(១៣៤) ពាក្យថា នឹងចេញអំពីទីមិនមែនត្រើយ ទៅកាន់ត្រើយ គឺ កិលេសទាំងឡាយ ខន្ធទាំងឡាយ នឹងអភិសង្ខារទាំងឡាយ លោកហៅថា ទីមិនមែនត្រើយ ។ អមតនិព្វាន លោកហៅថា ត្រើយ បានដល់សេចក្ដីរម្ងាប់សង្ខារទាំងពួង ការរលាស់ចោលឧបធិទាំងពួង ការអស់តណ្ហា សេចក្ដីប្រាសចាកតម្រេក សេចក្ដីរលត់ និព្វាន ។ ពាក្យថា នឹងចេញអំពីទីមិនមែនត្រើយ ទៅកាន់ត្រើយ បានសេចក្ដីថា នឹងចេញអំពីទីមិនមែនត្រើយ ទៅកាន់ត្រើយ បានត្រើយ ពាល់ត្រើយ ធ្វើឲ្យជាក់ច្បាស់នូវត្រើយ ហេតុនោះ (លោកពោលថា) នឹងចេញអំពីទីមិនមែនត្រើយទៅកាន់ត្រើយ ។

(១៣៥) ភាវេន្តោ មគ្គមុត្តមន្តិ មគ្គន្តិ មគ្គោ វុច្ចតិ អរិយោ អដ្ឋង្គិកោ មគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ។ ឧត្តមន្តិ អគ្គំ សេដ្ឋំ វិសេដ្ឋំ បាមោក្ខំ ឧត្តមំ បវរន្តិ មគ្គមុត្តមំ ។ ភាវេន្តោតិ ភាវេន្តោ អាសេវន្តោ ពហុលីករោន្តោតិ ភាវេន្តោ មគ្គមុត្តមំ ។

(១៣៦) មន្តោ សោ ឆារកមឆាយាតិ មន្តោ បណ្ឌោ បជោ បជ្ជោ អញ្ញសំ វិជុមាយំ ឆារ ឧត្តរសេតុ បក្ខលោ សត្តមោ ។ ឆារកមឆាយាតិ ឆារកមឆាយ ឆារសម្បូបឆាយ ឆារសមកុធាបឆាយ ជរាមរណស្ស តរណាយាតិ មន្តោ សោ ឆារកមឆាយ ។

(១៣៧) តស្មា ឆាកាយំ ឥតីតិ តស្មាតិ តស្មា តំការណា តំហេតុ តប្បច្ចយោ តំនិទានា ។

(១៣៥) ពាក្យថា មគ្គ ក្នុងបទថា កាលចម្រើនមគ្គ ដ៏ឧត្តម សេចក្តីថា មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ គឺ ប្រាជ្ញាយល់ឃើញត្រូវ ។ បេ ។ ការតម្កល់ចិត្តឲ្យនឹងត្រូវ លោកហៅថា មគ្គ ។ ពាក្យថា ដ៏ឧត្តម គឺ ដ៏លើស ដ៏ប្រសើរ ដ៏ប្រសើរវិសេស ជាប្រធាន ឧត្តម ថ្លៃថ្លា ហេតុនោះ (លោកពោលថា) មគ្គដ៏ឧត្តម ។ ពាក្យថា កាលចម្រើន គឺ កាលចម្រើន កាលសេព កាលធ្វើឲ្យច្រើន ហេតុនោះ (លោកពោថា) កាលចម្រើនមគ្គដ៏ឧត្តម ។

(១៣៦) ពាក្យថា មគ្គនោះតែងប្រព្រឹត្តទៅ ដើម្បីទៅកាន់ត្រើយ គឺ ផ្លូវ តម្រាយ គន្លង ប្រទេសសម្រាប់ទៅដោយដើង ទីសម្រាប់ដើរ ទីសម្រាប់ដើរទៅដើរមក ទូក ស្ពានសម្រាប់ឆ្លង ផែ ពោងពាយ ។ ពាក្យថា ដើម្បីទៅកាន់ត្រើយ គឺ ដើម្បីទៅកាន់ត្រើយ ដើម្បីដល់ព្រមនូវត្រើយ ដើម្បីដល់ឆាប់នូវត្រើយ គឺថា ដើម្បីឆ្លងជរានិងមរណៈ ហេតុនោះ (លោកពោលថា) មគ្គនោះតែងប្រព្រឹត្តទៅ ដើម្បីទៅកាន់ត្រើយ ។

(១៣៧) ពាក្យថា ហេតុនោះ ក្នុងបទថា ហេតុនោះ (លោកពោលថា) បារាយនៈ ដោយប្រការដូច្នេះ គឺ ព្រោះហេតុនោះ ព្រោះដំណើរនោះ ព្រោះដូច្នោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ ។

សោឡសមាណវកប្បញ្ហានិទ្ទេសោ

ឥទំ វុច្ចតិ អមតំ និព្វានំ យោ សោ សព្វសង្ខារ-
សមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរា-
គោ និរោធោ និព្វានំ ។ អាយនំ វុច្ចតិ មគ្គោ ។
ឥតីតិ បទសន្ធិ ។ បេ ។ បទានុបុព្វតាមេតំ ឥតីតិ
តស្មា បារាយនំ ឥតិ ។ តេនេតំ វុច្ចតិ

អបារា បារំ គច្ឆេយ្យ ការេត្ថ មគ្គមុត្តមំ
មគ្គោ សោ បារគមនាយ តស្មា បារាយនំ ឥតីតិ ។

(១៣៨) បារាយនមនុគាយិស្សំ (ឥច្ចាយស្មា បិង្គិយោ)
(យថា អទ្ទក្ខិ តថា អក្ខាសិ)
វិមលោ ភូរិមេធសោ
និក្កាមោ និព្វនោ នាថោ
កិស្ស ហេតុ មុសា ភណេ ។

អមតនិព្វាន លោកហៅថា ត្រើយ បានដល់សេចក្ដីរម្ងាប់សង្ខារទាំងពួង ការរលាស់ចោលឧបធិទាំងពួង ការអស់តណ្ហា សេចក្ដីប្រាសចាកតម្រេក សេចក្ដីរលត់ និព្វាន ។ មគ្គ លោកហៅថា អាយនៈ ។ ពាក្យថា ដោយប្រការដូច្នេះ គឺជាការតបទ ។ បេ ។ ពាក្យថា ដូច្នេះ នុ៎ះជាលំដាប់បទ ហេតុនោះ (លោកពោលថា) បារាយនៈ ដោយប្រការដូច្នេះ ។ ហេតុនោះ លោកពោលពាក្យនេះថា

បុគ្គលកាលចម្រើនមគ្គដ៏ឧត្ដម នឹងចេញអំពីទីមិនមែនត្រើយ ទៅកាន់ត្រើយបាន មគ្គនោះតែងប្រព្រឹត្តទៅ ដើម្បីទៅកាន់ត្រើយ ហេតុនោះ មគ្គ (លោកពោលថា) បារាយនៈ ដោយប្រការដូច្នេះ ។

[១៣៨] (បិង្គិយៈមានអាយុពោលដូច្នោះថា) ខ្ញុំនឹងច្រៀងតាមបារាយនៈ ព្រះមានព្រះភាគ ព្រះអង្គមានមន្ទិលគឺកិលេសទៅប្រាសហើយ មានប្រាជ្ញាដូចផែនដី មានកាមចេញហើយ មានព្រៃចេញហើយ ជាព្រះពុទ្ធនាគ (ទ្រង់ឃើញហើយយ៉ាងណា ទ្រង់ពោលយ៉ាងនោះ) ទ្រង់នឹងពោលមុសាព្រោះហេតុដូចម្ដេចកើត ។

(១៣៩) បារាយនមនុគាយិស្សន្តិ គីតមនុគាយិស្សំ កថិតមនុគាយិស្សំ ភណិតមនុគាយិស្សំ ភាសិតមនុគាយិស្សន្តិ បារាយនមនុគាយិស្សំ ។ ឥច្ចាយស្មា បិង្គិយោតិ ឥច្ចាតិ បទសន្ធិ ។ បេ ។ បទានុបុព្ពតាមេតំ ឥច្ចាតិ ។ អាយស្មាតិ បិយវចនំ គរុវចនំ សគារវសប្បតិស្សាធិវចនមេតំ អាយស្មាតិ ។ បិង្គិយោតិ តស្ស ថេរស្ស នាមំ សង្ខា សមញ្ញា បញ្ញត្តិ វោហារោ នាមំ នាមកម្មំ នាមធេយ្យំ និរុត្តិ ព្យញ្ជនំ អភិលាបោតិ ឥច្ចាយស្មា បិង្គិយោ ។

(១៤០) យថា អទ្ទក្ខិ តថា អក្ខាសីតិ យថា អទ្ទក្ខិ តថា អក្ខាសិ អាចិក្ខិ ទេសេសិ បញ្ញបេសិ បដ្ឋបេសិ វិវរិ វិភជិ ឧត្តានីមកាសិ បកាសេសិ សព្វេ សង្ខារា អនិច្ចាតិ ។ បេ ។

(១៣៩) ពាក្យថា ខ្ញុំនឹងប្រៀងតាមបារាយនៈ គឺ ខ្ញុំនឹងប្រៀងតាមបម្រៀង នឹងប្រៀងតាមភាសិតដែលព្រះមានព្រះភាគសំដែងហើយ នឹងប្រៀងតាមភាសិត ដែលព្រះមានព្រះភាគពោលហើយ នឹងប្រៀងតាមភាសិត (របស់ព្រះមានព្រះភាគ) ហេតុនោះ (លោកពោលថា) ខ្ញុំនឹងប្រៀងតាមបារាយនៈ ។ ពាក្យថា ដូច្នេះ ក្នុងបទថា បិង្គិយៈមានអាយុពោលដូច្នេះ គឺជាការតបទ ។ បេ ។ ពាក្យថា ដូច្នេះ នុះជាលំដាប់បទ ។ ពាក្យថា មានអាយុ គឺពាក្យជាទីស្រឡាញ់ ជាពាក្យពោលដោយគោរព ពាក្យថា មានអាយុ នុះ ជាពាក្យពោលដោយការគោរពកោតក្រែង ។ ពាក្យថា បិង្គិយៈ គឺ ជាឈ្មោះ ជាពាក្យសម្រាប់រាប់ ជាគ្រឿងសំគាល់ ជាបញ្ញត្តិ ជាវោហារ ជានាម ជានាមកម្ម ជានាមប្បញ្ញត្តិ ជាសំដី ជាគ្រឿងបញ្ជាក់ ជាគ្រឿងប្រកាស នៃព្រះថេរៈនោះ ហេតុនោះ (លោកពោលថា) បិង្គិយៈមានអាយុពោលដូច្នេះ ។

(១៤០) ពាក្យថា ទ្រង់ឃើញយ៉ាងណា ទ្រង់ពោលយ៉ាងនោះ គឺ ទ្រង់ឃើញយ៉ាងណា ទ្រង់ពោល ប្រាប់ សំដែង តែងតាំង តាំងផ្តើម បើកវែកញែក ធ្វើឲ្យរាក់ ប្រកាស យ៉ាងនោះថា សង្ខារទាំងពួងមិនទៀង ។ បេ ។

យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ យថា អទ្ទក្ខិ តថា អក្ខាសិ អាចិក្ខិ ទេសេសិ បញ្ញបេសិ បដ្ឋបេសិ វិវរិ វិភជិ ឧត្តានីមកាសិ បកាសេសីតិ យថា អទ្ទក្ខិ តថា អក្ខាសិ ។

(១៤១) វិមលោ ភូរិមេធសោតិ វិមលោតិ រា-គោ មលំ ទោសោ មលំ មោហោ មលំ កោ-ធោ មលំ ឧបនាហោ មលំ ។បេ។ សព្វាកុស-លាភិសង្ខារា មលា ។ តេ មលា ពុទ្ធស្ស ភគវ-តោ បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្ក-តា អាយតឹអនុប្បាទធម្មា តស្មា ពុទ្ធោ អមលោ វិ-មលោ និម្មលោ មលាបគតោ មលវិប្បហីនោ មល-វិប្បមុត្តោ សព្វមលវីតិវត្តោ ។ ភូរិ វុច្ចតិ បថវី ។

ធម្មជាតឯណានីមួយ មានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះមានកិរិយារលត់ទៅវិញជាធម្មតា ទ្រង់ឃើញយ៉ាងណា ទ្រង់ពោលប្រាប់ សំដែង តែងតាំង តាំងផ្តើម បើក វែកញែក ធ្វើឲ្យរាក់ ប្រកាសហើយ យ៉ាងនោះ ហេតុនោះ (លោកពោលថា) ទ្រង់ឃើញយ៉ាងណា ទ្រង់ពោលយ៉ាងនោះ ។

(១៨១) អធិប្បាយពាក្យថា មានមន្ទិលទៅប្រាសហើយ មានប្រាជ្ញាដូចផែនដី ត្រង់ពាក្យថា មានមន្ទិលទៅប្រាសហើយ សេចក្តីថា រាគៈឈ្មោះថាមន្ទិល ទោសៈឈ្មោះថាមន្ទិល មោហៈឈ្មោះថាមន្ទិល ក្រោធឈ្មោះថាមន្ទិល ការចងក្រោធទុក ឈ្មោះថាមន្ទិល ។ បេ ។ អភិសង្ខារ ជាអកុសលទាំងពួង ឈ្មោះថាមន្ទិល ។ មន្ទិលទាំងនោះ ព្រះពុទ្ធមានព្រះភាគ ទ្រង់លះបង់ កាត់ផ្តាច់ឫសចេញហើយ ធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនកើតមាន មានកិរិយាមិនកើតតទៅជាធម្មតា ហេតុនោះ ព្រះពុទ្ធឈ្មោះថាមិនមានមន្ទិល មានមន្ទិលទៅប្រាសហើយ ដ៏ស្អាត ចាកមន្ទិល ប្រាសចាកមន្ទិល លះបង់មន្ទិល រួចស្រឡះចាកមន្ទិល ប្រព្រឹត្តកន្លង នូវមន្ទិលទាំងពួង ។ បឋពី លោកហៅថា ផែនដី ។

ភគវា ឥមាយ បថវីសមាយ វិបុលាយ វិត្ថតាយ បញ្ញាយ សមន្នាគតោ ។ មេធា វុច្ចតិ បញ្ញា យា បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ។ ភគវា ឥមាយ មេធាយ បញ្ញាយ ឧបេតោ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ តស្មា ពុទ្ធោ ភូរិមេធសោតិ វិមលោ ភូរិមេធសោ ។

(១៦២) និក្កាមោ និព្វនោ នាថោតិ កាមាតិ ឧទ្ទានតោ ទ្វេ កាមា វត្ថុកាមា ច កិលេសកាមា ច ។ បេ ។ ឥមេ វុច្ចន្តិ វត្ថុកាមា ។ បេ ។ ឥមេ វុច្ចន្តិ កិលេសកាមា ។ ពុទ្ធស្ស ភគវតោ វត្ថុកាមា បរិញ្ញាតា កិលេសកាមា បហីនា ។ វត្ថុកាមានំ បរិញ្ញាតត្តា កិលេសកាមានំ បហីនត្តា ភគវា ន កាមេ កាមេតិ ន កាមេ បត្ថេតិ ន កាមេ បិហេតិ ន កាមេ អភិជប្បតិ ។

ព្រះមានព្រះភាគ ប្រកបព្រមហើយ ដោយប្រាជ្ញាដ៏ធំទូលាយ ស្មើ ដោយប្រថពីនេះ ។ ប្រាជ្ញា លោកហៅថា មេធា បានដល់បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ សេចក្តីឃើញត្រូវ ។ ព្រះមានព្រះភាគ អែប អែបនែប កប ប្រកប ចូលទៅដល់ ចូលទៅដល់ព្រម ប្រកបព្រម ដោយមេធាគឺប្រាជ្ញានេះ ហេតុនោះ ព្រះពុទ្ធឈ្មោះថាមានប្រាជ្ញាដូចផែនដី ហេតុនោះ (លោកពោលថា) មានមន្ទិលទៅប្រាសហើយ មានប្រាជ្ញាដូចផែនដី ។

(១៦៦) អធិប្បាយពាក្យថា មានកាមចេញហើយ មានព្រៃចេញហើយ ជាព្រះពុទ្ធនាគ ត្រង់ពាក្យថា កាម បើពោលតាមឧទ្ទាន កាមមាន ២ គឺវត្ថុកាម ១ កិលេសកាម ១ ។ បេ ។ ទាំងនេះ លោកហៅថា វត្ថុកាម ។ បេ ។ ទាំងនេះ លោកហៅថា កិលេសកាម ។ វត្ថុកាម ព្រះពុទ្ធមានព្រះភាគកំណត់ដឹងហើយ កិលេសកាម ទ្រង់លះបង់ហើយ ។ ព្រោះទ្រង់កំណត់ដឹងវត្ថុកាម ព្រោះទ្រង់លះកិលេសកាម ព្រះមានព្រះភាគ ឈ្មោះថាមិនប្រាថ្នាកាមទាំងឡាយ មិនបង់បានកាមទាំងឡាយ មិនស្រឡាញ់កាមទាំងឡាយ មិនជាប់ព្រះហឫទ័យនឹងកាមទាំងឡាយ ។

យេ កាមេ កាមេន្តិ កាមេ បត្ថេន្តិ កាមេ បិហាយន្តិ កាមេ អភិជប្បន្តិ តេ កាមកាមិនោ រាគរាគិនោ សញ្ញាសញ្ញិនោ ។ ភគវា ន កាមេ កាមេតិ ន កាមេ បត្ថេតិ ន កាមេ បិហេតិ ន កាមេ អភិជប្បតិ តស្មា ពុទ្ធោ អកាមោ និក្កាមោ ចត្តកាមោ វន្តកាមោ មុត្តកាមោ បហីនកាមោ បដិនិស្សដ្ឋកាមោ វីតរាគោ វិគតរាគោ ចត្តរាគោ វន្តរាគោ មុត្តរាគោ បហីនរាគោ បដិនិស្សដ្ឋរាគោ និច្ឆាតោ និព្វុតោ សីតិភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន អត្តនា វិហរតីតិ និក្កាមោ ។ និព្វនោតិ រាគោ វនំ ទោសោ វនំ មោហោ វនំ កោធោ វនំ ឧបនាហោ វនំ ។ បេ ។ សព្វាកុសលាភិសង្ខារា វនា ។ តេ វនា ពុទ្ធស្ស ភគវតោ បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា

## តោទេយ្យមាណវកប្បញ្ហានិគមនិទ្ទេស

ជនទាំងឡាយណា នៅប្រាថ្នាកាមទាំងឡាយ ចង់បានកាមទាំងឡាយ ស្រឡាញ់កាមទាំងឡាយ ជាប់ចិត្តនឹងកាមទាំងឡាយ ជនទាំងឡាយនោះ ឈ្មោះថាមានសេចក្ដីប្រាថ្នាកាម មានសេចក្ដីត្រេកអរដោយរាគៈ មានសេចក្ដីសំគាល់ដោយកាមសញ្ញា ។ ព្រះមានព្រះភាគ មិនប្រាថ្នាកាមទាំងឡាយ មិនចង់បានកាមទាំងឡាយ មិនស្រឡាញ់កាមទាំងឡាយ មិនជាប់ព្រះហឫទ័យនឹងកាមទាំងឡាយ ហេតុនោះ ព្រះពុទ្ធឈ្មោះថាមិនមានកាម មានកាមចេញហើយ ចោលកាម ខ្ជាក់កាម លែងកាម លះកាម រលាស់ចោលកាម ប្រាសចាករាគៈ មានរាគៈទៅបាត់ហើយ ចោលរាគៈ ខ្ជាក់រាគៈ លែងរាគៈ លះរាគៈ រលាស់ចោលរាគៈ ប្រាសចាកសេចក្ដីប្រាថ្នា មានទុក្ខរលត់ហើយ មានសេចក្ដីត្រជាក់កើតហើយ សោយសុខ មានខ្លួនដូចជាព្រហ្ម សម្រេចសម្រាន្តនៅ ហេតុនោះ (លោកពោលថា) មានកាមចេញហើយ ។ ពាក្យថា មានព្រៃចេញហើយ សេចក្ដីថា រាគៈឈ្មោះថាព្រៃ ទោសៈឈ្មោះថាព្រៃ មោហៈឈ្មោះថាព្រៃ ក្រោធឈ្មោះថាព្រៃ ការចងក្រោធទុកឈ្មោះថាព្រៃ ។បេ។ អភិសង្ខារជាអកុសលទាំងពួងឈ្មោះថាព្រៃ ។ ព្រៃទាំងនោះ ព្រះពុទ្ធមានព្រះភាគលះបង់ ផ្ដាច់ផ្ដិលឫសគល់ ធ្វើឲ្យមានទីនៅដូចជាទីនៅនៃដើមត្នោត

អនភាវង្កតា អាយតឹ អនុប្បាទធម្មា តស្មា ពុទ្ធោ អវ-នោ និព្វនោ វនាបគតោ វនវិប្បហីនោ វនវិប្បមុត្តោ សព្វវនវីតិវត្តោតិ និព្វនោ ។ នាគោតិ ភគវា អាគុំ ន ករោតីតិ នាគោ ។ ន គច្ឆតីតិ នាគោ ។ ន អាគច្ឆតីតិ នាគោ ។ បេ ។ ឯវំ ភគវា ន អាគច្ឆតីតិ នាគោតិ និក្កាមោ និព្វនោ នាគោ ។

(១៤៣) កិស្ស ហេតុ មុសា ភណតិ កិស្ស ហេតូតិ កិស្ស ហេតុ កឹការណា កឹបច្ចយា កិស្ស ហេតុ ។ មុសា ភណតិ មោសវជ្ជំ ភ-ណេយ្យ មុសាវាទំ ភណេយ្យ អនរិយវាទំ ភណេ-យ្យ ។ ឥធេកច្ចោ សភគ្គតោ វា បរិសគ្គតោ វា ញាតិមជ្ឈគតោ វា(១) រាជកុលមជ្ឈគតោ វា អភិនី-តោ សក្ខិបុដ្ឋោ ឯហិ ភោ បុរិស យំ ជានាសិ តំ

---

១ ម. ឯត្ថន្តរេ បូគមជ្ឈគតោ វាតិ បាឋោ ទិស្សតិ ។

ឲ្យដល់នូវការមិនមានទីកើត មានកិរិយាមិនកើតតទៅជាធម្មតា ហេតុនោះ ព្រះពុទ្ធ ឈ្មោះថាមិនមានព្រៃ មានព្រៃចេញហើយ ប្រាសចាកព្រៃ លះបង់ព្រៃ រួចស្រឡះចាកព្រៃ ប្រព្រឹត្តកន្លងព្រៃទាំងអស់ ហេតុនោះ (លោកពោលថា) មានព្រៃចេញហើយ ។ ពាក្យថា ព្រះពុទ្ធនាគ គឺព្រះមានព្រះភាគ ឈ្មោះថានាគ ព្រោះហេតុទ្រង់មិនធ្វើអំពើអាក្រក់ ។ ឈ្មោះថានាគ ព្រោះហេតុទ្រង់មិនលុះ ។ ឈ្មោះថានាគ ព្រោះហេតុទ្រង់មិនមក ។ បេ ។ ព្រះមានព្រះភាគ ឈ្មោះថានាគ ព្រោះហេតុទ្រង់មិនមក យ៉ាងនេះ ហេតុនោះ (លោកពោលថា) មានកាមចេញហើយ មានព្រៃចេញហើយ ជាព្រះពុទ្ធនាគ ។

(១៨៣) អធិប្បាយពាក្យថា គប្បីពោលមុសា ព្រោះហេតុដូចម្តេចកើត ត្រង់ពាក្យថា ព្រោះហេតុដូចម្តេចកើត គឺ ព្រោះហេតុអ្វី ព្រោះការណ៍អ្វី ព្រោះបច្ច័យអ្វី ហេតុនោះ (លោកពោលថា) ព្រោះហេតុដូចម្តេចកើត ។ ពាក្យថា គប្បីពោលមុសា គឺគប្បីពោលពាក្យមុសា ពោលមុសាវាទ ពោលពាក្យមិនប្រសើរ ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ ទៅក្នុងទីប្រជុំក្តី ទៅក្នុងបរិសទ្យក្តី ទៅក្នុងកណ្តាលពួកញាតិក្តី ទៅក្នុងកណ្តាលរាជត្រកូលក្តី ដែលគេកោះទៅសួរជាសាក្សីថា ម្នាលបុរសដ៏ចម្រើន អ្នកចូរមក អ្នកដឹងហេតុណា ចូរពោលហេតុនោះ

វទេហីតិ អជានំ អាហ ជានាមីតិ ជានំ វា អាហ ន
ជានាមីតិ អបស្សំ វា អាហ បស្សាមីតិ បស្សំ វា
អាហ ន បស្សាមីតិ ឥតិ អត្តហេតុ វា បរហេតុ វា
អាមិសកិញ្ចិក្ខហេតុ វា សម្បជានមុសា ភណតិ
ឥទំ វុច្ចតិ មោសវជ្ជំ ។ អបិច តីហាការេហិ មុសា-
វាទោ ហោតិ បុព្វេវស្ស ហោតិ មុសា ភណិស្សន្តិ
ភណន្តស្ស ហោតិ មុសា ភណាមីតិ ភណិតស្ស
ហោតិ មុសា មយា ភណិតន្តិ ឥមេហិ តីហាកា-
រេហិ មុសាវាទោ ហោតិ ។ អបិច ចតូហាការេ-
ហិ មុសាវាទោ ហោតិ បុព្វេវស្ស ហោតិ មុសា
ភណិស្សន្តិ ។ បេ ។ បញ្ចហាការេហិ ឆហាការេ-
ហិ សត្តហាការេហិ អដ្ឋហាការេហិ មុសាវាទោ
ហោតិ បុព្វេវស្ស ហោតិ មុសា ភណិស្សន្តិ ភ-
ណន្តស្ស ហោតិ មុសា ភណាមីតិ ភណិតស្ស
ហោតិ មុសា មយា ភណិតន្តិ វិនិធាយ ទិដ្ឋឹ វិ-
និធាយ ខន្តឹ វិនិធាយ រុចឹ វិនិធាយ សញ្ញំ វិនិធាយ
ភាវំ ឥមេហិ អដ្ឋហាការេហិ មុសាវាទោ ហោតិ ។

សោឡសមាណវកប្បញ្ហានិគមនិទ្ទេស

កាលមិនដឹង ពោលថាខ្ញុំដឹងក្តី កាលដឹង ពោលថាខ្ញុំមិនដឹងក្តី កាលមិនឃើញ ពោលថាខ្ញុំឃើញក្តី កាលឃើញ ពោលថាខ្ញុំមិនឃើញក្តី ពោលសម្បជានមុសាវាទ ព្រោះហេតុនៃខ្លួនក្តី ព្រោះហេតុនៃបុគ្គលដទៃក្តី ព្រោះហេតុតែសំណូកណាមួយក្តី នេះលោកហៅថា ពាក្យមុសា ។ មួយទៀត ការពោលមុសាដោយអាការ ៣ គឺ មុនដំបូង មុសាវាទរបស់បុគ្គលនោះថា អញនឹងពោលមុសា ១ មុសាវាទរបស់បុគ្គលកំពុងពោលថា អញកំពុងពោលមុសា ១ មុសាវាទរបស់បុគ្គលពោលរួចហើយថា អញពោលមុសាហើយ ១ នេះការពោលមុសា ដោយអាការ ៣ ។ មួយទៀត ការពោលមុសា ដោយអាការ ៤ យ៉ាង គឺ មុនដំបូង មុសាវាទរបស់បុគ្គលនោះថា អញនឹងពោលមុសា ១ ។ បេ ។ ការពោលមុសាដោយអាការ ៥ ដោយអាការ ៦ ដោយអាការ ៧ ដោយអាការ ៨ គឺ មុនដំបូង មុសាវាទរបស់បុគ្គលនោះថា អញនឹងពោលមុសា ១ មុសាវាទរបស់បុគ្គលកំពុងពោលថា អញកំពុងពោលមុសា ១ មុសាវាទរបស់បុគ្គលពោលរួចហើយថា អញពោលមុសាហើយ ១ ពោលបិទបាំងទិដ្ឋិ ១ បិទបាំងខន្តិ ១ បិទបាំងសេចក្តីគាប់ចិត្ត ១ បិទបាំងសញ្ញា ១ បិទបាំងសេចក្តីពិត ១ នេះការពោលមុសាដោយអាការ ៨ ។

កិស្ស ហេតុ មុសា ភណេយ្យ កថេយ្យ ទីបេយ្យ វោហរេយ្យាតិ កិស្ស ហេតុ មុសា ភណេ ។ តេ-នាហ បិង្គិយត្ថេរោ

> បារាយនមនុគាយិស្សំ (ឥច្ចាយស្មា បិង្គិយោ)
> (យថា អទ្ទក្ខិ តថា អក្ខាសិ)
> វិមលោ ភូរិមេធសោ
> និក្កាមោ និព្វនោ នាគោ
> កិស្ស ហេតុ មុសា ភណេតិ ។

(១៤៤) បហីនមលមោហស្ស មានមក្ខប្បហាយិនោ
ហន្ទាហំ កិត្តយិស្សាមិ គិរំ វណ្ណូបសញ្ហិតំ ។

(១៤៥) បហីនមលមោហស្សាតិ មលាតិ រាគោ មលំ ទោសោ មលំ មោហោ មលំ មានោ មលំ ទិដ្ឋិ មលំ កិលេសោ មលំ សព្វទុច្ចរិតំ មលំ ។ មោហោតិ ទុក្ខេ អញ្ញាណំ ។ បេ ។ អវិជ្ជាលង្គី មោហោ អកុសលមូលំ អយំ វុច្ចតិ មោហោ ។

ព្រះអង្គគប្បីពោល និយាយ សំដែង ថ្លែងនូវមុសា ព្រោះហេតុ
ម្តេចបាន ហេតុនោះ (លោកពោលថា) គប្បីពោលមុសា ព្រោះហេតុដូច
ម្តេចកើត ។ ហេតុនោះ បិង្គិយត្ថេរពោលថា

(បិង្គិយមានអាយុ ពោលដូច្នេះថា) ខ្ញុំនឹងប្រៀងតាម
បារាយនៈ ព្រះមានព្រះភាគ ព្រះអង្គមានមន្ទិលគឺកិលេស
ទៅប្រាសហើយ មានប្រាជ្ញាដូចផែនដី មានកាមចេញហើយ
មានព្រៃចេញហើយ ជាព្រះពុទ្ធនាគ (ទ្រង់ឃើញហើយ
យ៉ាងណា ទ្រង់ពោលយ៉ាងនោះ) ទ្រង់គប្បីពោលមុសា
ព្រោះហេតុដូចម្តេចកើត ។

(១៨៨) បើដូច្នោះ ខ្ញុំនឹងសំដែងពាក្យ ដ៏ប្រកបដោយគុណ
របស់ព្រះមានព្រះភាគ ព្រះអង្គលះបង់មន្ទិលនឹងមោហៈ
ហើយ លះបង់មានះនឹងមក្ខៈហើយ ។

(១៨៩) អធិប្បាយពាក្យថា ព្រះអង្គលះបង់មន្ទិលនឹងមោហៈហើយ ត្រង់ពាក្យថា មន្ទិល បានដល់ រាគៈ ឈ្មោះថាមន្ទិល ទោសៈឈ្មោះថាមន្ទិល មោហៈ ឈ្មោះថាមន្ទិល មានះ ឈ្មោះថាមន្ទិល ទិដ្ឋិឈ្មោះថាមន្ទិលកិលេសឈ្មោះថាមន្ទិល ទុច្ចរិតទាំងពួង ឈ្មោះថាមន្ទិល ។ ពាក្យថា មោហៈ គឺ ការមិនដឹងក្នុងកងទុក្ខ ។ បេ ។ បង្គោល គឺអវិជ្ជា សេចក្តីវង្វេង ឫសនៃអកុសល នេះលោកហៅថា មោហៈ ។

មលញ្ច មោហោ ច ពុទ្ធស្ស ភគវតោ បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹអនុប្បាទធម្មា តស្មា ពុទ្ធោ បហីនមលមោហោតិ បហីនមលមោហស្ស ។

(១៤៦) មានមក្ខប្បហាយិនោតិ មានាតិ ឯកវិធេន មានោ យា ចិត្តស្ស ឧណ្ណតិ ។ ទុវិធេន មានោ អត្តុក្កំសនមានោ បរវម្ភនមានោ ។ តិវិធេន មានោ សេយ្យោហមស្មីតិ មានោ សទិសោហមស្មីតិ មានោ ហីនោហមស្មីតិ មានោ ។ ចតុព្វិធេន មានោ លាភេន មានំ ជនេតិ យសេន មានំ ជនេតិ បសំសាយ មានំ ជនេតិ សុខេន មានំ ជនេតិ ។ បញ្ចវិធេន មានោ លាភិម្ហិ មនាបិកានំ រូបានន្តិ មានំ ជនេតិ លាភិម្ហិ មនាបិកានំ សទ្ទានំ គន្ធានំ រសានំ ផោដ្ឋព្វានន្តិ មានំ ជនេតិ ។

## សោឡសមាណវកបញ្ហានិគមនិទ្ទេស

មន្ទិលនឹងមោហៈ ព្រះពុទ្ធមានព្រះភាគបានលះបង់ គាស់រំលើងបុសគល់ ធ្វើឲ្យមានតែទីនៅដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនកើតមាន មិនឲ្យមានកិរិយាកើតតទៅជាធម្មតា ហេតុនោះ ព្រះពុទ្ធឈ្មោះថាមានមន្ទិលនឹងមោហៈលះបង់ហើយ ហេតុនោះ (លោកពោលថា) ព្រះអង្គលះបង់មន្ទិលនឹងមោហៈហើយ ។

(១៨៦) អធិប្បាយពាក្យថា លះបង់មានះនឹងមក្ខៈហើយ ត្រង់ពាក្យថា មានះ សេចក្ដីថា មានះដោយប្រការមួយ បានដល់ការប៉ោងឡើងនៃចិត្ត ។ មានះដោយប្រការ២ គឺ មានះដោយការលើកតំកើងខ្លួន ១ មានះដោយការបន្តុះបង្អាប់អ្នកដទៃ ១ ។ មានះដោយប្រការ ៣ គឺ មានះថាអញជាបុគ្គលប្រសើរ ១ មានះថាអញជាបុគ្គលស្មើ ១ មានះថាអញជាបុគ្គលថោកទាប ១ ។ មានះដោយប្រការ ៤ គឺ បុគ្គលញុំាងមានះឲ្យកើតព្រោះលាភ ១ ញុំាងមានះឲ្យកើតព្រោះយស ១ ញុំាងមានះឲ្យកើតព្រោះសេចក្ដីសរសើរ ១ ញុំាងមានះឲ្យកើតព្រោះសុខ ១ ។ មានះដោយប្រការ ៥ គឺ បុគ្គលញុំាងមានះឲ្យកើតថា អញបានរូបជាទីគាប់ចិត្ត ១ ញុំាងមានះឲ្យកើតថាអញបានសំឡេង ១ ក្លិន ១ រស ១ ផ្សព្វជាទីគាប់ចិត្ត ១ ។

ឆព្វិធេន មានោ ចក្ខុសម្បទាយ មានំ ជនេតិ សោតសម្បទាយ ឃានសម្បទាយ ជិវ្ហាសម្បទាយ កាយសម្បទាយ មនោសម្បទាយ មានំ ជនេតិ ។ សត្តវិធេន មានោ មានោ អតិមានោ មានាតិមានោ ឱមានោ អវមានោ(១) អស្មិមានោ មិច្ឆាមានោ ។ អដ្ឋ-វិធេន មានោ លាភេន មានំ ជនេតិ អលាភេន ឱមានំ ជនេតិ យសេន មានំ ជនេតិ អយសេន ឱមានំ ជនេតិ បសំសាយ មានំ ជនេតិ និន្ទាយ ឱមានំ ជនេតិ សុខេន មានំ ជនេតិ ទុក្ខេន ឱមានំ ជនេតិ ។ នវវិធេន មានោ សេយ្យស្ស សេយ្យោហមស្មីតិ មានោ សេយ្យស្ស សទិសោហ-មស្មីតិ មានោ សេយ្យស្ស ហីនោហមស្មីតិ មានោ

---

១ អដ្ឋកថាយំ អធិមានោតិ ទិស្សតិ ។

មានះដោយប្រការ ៦ គឺ បុគ្គលញ៉ាំងមានះឲ្យកើត ព្រោះការបរិបូណ៌ដោយចក្ខុ ១ ញ៉ាំងមានះឲ្យកើត ព្រោះការបរិបូណ៌ដោយសោតៈ ១ ព្រោះការបរិបូណ៌ដោយឃានៈ ១ ព្រោះការបរិបូណ៌ដោយជិវ្ហា ១ ព្រោះការបរិបូណ៌ដោយកាយ ១ ព្រោះការបរិបូណ៌ដោយមនៈ ១ ។ មានះដោយប្រការ ៧ គឺ ការក្រអឺតក្រអោង ១ ការប្រកាន់គ្រាន់ ១ ការមើលងាយដោយសេចក្ដីប្រកាន់ ១ ការប្រកាន់ទាប ១ ការប្រកាន់ថោក ១ ការប្រកាន់ថាអញមាន ១ ការប្រកាន់ខុស ១ ។ មានះដោយប្រការ ៨ គឺ បុគ្គលញ៉ាំងការក្រអឺតក្រអោងឲ្យកើតព្រោះលាភ ១ ញ៉ាំងការប្រកាន់ទាបឲ្យកើត ព្រោះការមិនមានលាភ ១ ញ៉ាំងការក្រអឺតក្រអោងឲ្យកើតព្រោះយស ១ ញ៉ាំងការប្រកាន់ទាបឲ្យកើតព្រោះការមិនមានយស ១ ញ៉ាំងការក្រអឺតក្រអោងឲ្យកើតព្រោះសេចក្ដីសរសើរ ១ ញ៉ាំងការប្រកាន់ទាបឲ្យកើតព្រោះសេចក្ដីតិះដៀល ១ ញ៉ាំងការក្រអឺតក្រអោងឲ្យកើតព្រោះសុខ ១ ញ៉ាំងការប្រកាន់ទាបឲ្យកើតព្រោះទុក្ខ ១ ។ មានះដោយប្រការ ៩ គឺ បុគ្គលអ្នកខ្ពង់ខ្ពស់មានមានះថា អញខ្ពង់ខ្ពស់ជាងគេ ១ បុគ្គលអ្នកខ្ពង់ខ្ពស់ មានមានះថា អញស្មើ ១ បុគ្គលអ្នកខ្ពង់ខ្ពស់មានមានះថា អញថោកទាប ១

## សោឡសមាណវកប្បញ្ហានិគមនិទ្ទេសោ

សទិសស្ស សេយ្យោហមស្មីតិ មានោ សទិសស្ស សទិសោហមស្មីតិ មានោ សទិសស្ស ហីនោហមស្មីតិ មានោ ហីនស្ស សេយ្យោហមស្មីតិ មានោ ហីនស្ស សទិសោហមស្មីតិ មានោ ហីនស្ស ហីនោហមស្មីតិ មានោ ។ ទសវិធេន មានោ ឥធេកច្ចោ មានំ ជនេតិ ជាតិយា វា គោត្តេន វា កោលបុត្តិយេន វា វណ្ណពោក្ខរតាយ វា ធនេន វា អជ្ឈេនេន វា កម្មាយតនេន វា សិប្បាយតនេន វា វិជ្ជដ្ឋានេន វា សុតេន វា បដិភាណេន វា អញ្ញតរញ្ញតរេន វា វត្ថុនា យោ ឯវរូបោ មានោ មញ្ញនា មញ្ញិតត្តំ ឧណ្ណតិ ឧណ្ណមោ ធជោ សម្បគ្គាហោ កេតុកម្យតា ចិត្តស្ស អយំ វុច្ចតិ មានោ ។ មក្ខាតិ មក្ខោ មក្ខាយនា មក្ខាយិតត្តំ និដ្ឋុរិយកម្មំ អយំ វុច្ចតិ មក្ខោ ។ ពុទ្ធស្ស ភគវតោ មានោ ច មក្ខោ ច បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតិំ អនុប្បាទធម្មា តស្មា ពុទ្ធោ មានមក្ខប្បហាយីតិ មានមក្ខប្បហាយិនោ ។

សោឡសមាណវកប្បញ្ហានិតមនិទ្ទេស

បុគ្គលអ្នកស្មើនឹងគេមានមានះថាអញខ្ពង់ខ្ពស់១ បុគ្គលអ្នកស្មើនឹងគេមានមានះថាអញស្មើ១ បុគ្គលអ្នកស្មើនឹងគេមានមានះថាអញថោកទាប១ បុគ្គលអ្នកថោកទាបមានមានះថាអញខ្ពង់ខ្ពស់១ បុគ្គលអ្នកថោកទាបមានមានះថាអញស្មើ១ បុគ្គលអ្នកថោកទាបមានមានះថាអញថោកទាប១ ៗ មានះដោយប្រការ ១០ គឺ បុគ្គលខ្លះ ក្នុងលោកនេះ ញុំាងមានះឲ្យកើតព្រោះជាតិឬគោត្រឬការកើតជាកូនអ្នកមានត្រកូល ១ ព្រោះភាពជាអ្នកមានរូបល្អ ១ ព្រោះទ្រព្យ ១ ព្រោះការរៀន ១ ព្រោះការងារ ១ ព្រោះសិល្បៈ ១ ព្រោះទីតាំងនៃវិជ្ជា ១ ព្រោះការចេះដឹង ១ ព្រោះសេចក្តីឆ្លៀវឆ្លាស ១ ព្រោះវត្ថុណាមួយ ១ ការមើលងាយ អាការនៃការមើលងាយ ភាពនៃការមើលងាយ ការលើកកំពស់ ការប្រកាន់ខ្ពស់ ការផ្គងចិត្ត ភាពនៃចិត្តប្រាថ្នាដូចទង់ មានសភាពយ៉ាងនេះឯណា នេះលោកហៅថា មានះ ។ ពាក្យថា មក្ខៈ បានដល់សេចក្តីលុបគុណ អាការលុបគុណ ភាពនៃសេចក្តីលុបគុណ អំពើនៃសេចក្តីប្រណៃន នេះលោកហៅថា មក្ខៈ ។ មានះនឹងមក្ខៈ ព្រះពុទ្ធមានព្រះភាគបានលះបង់ គាស់រំលើងឫសគល់ ធ្វើឲ្យមានតែទីនៅដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនមានទីកើត មិនឲ្យមានកិរិយាកើតតទៅជាធម្មតា ហេតុនោះ ព្រះពុទ្ធ ឈ្មោះថាលះបង់មានះនឹងមក្ខៈ ហេតុនោះ (លោកពោលថា) លះបង់មានះនឹងមក្ខៈហើយ ។

(១៤៧) ហន្ទាហំ កិត្តយិស្សាមិ គិរំ វណ្ណូបសញ្ហិតន្តិ ហន្ទាហន្តិ បទសន្ធិ ។បេ។ បទានុបុព្វតាមេតំ ហន្ទាតិ ។ កិត្តយិស្សាមីតិ វណ្ណេន ឧបេតំ សមុបេតំ ឧបាគតំ សមុបាគតំ ឧបបន្នំ សមុបបន្នំ សមន្នាគតំ គិរំ វាចំ ព្យប្បថំ ឧទីរណំ កិត្តយិស្សាមិ ទេសិស្សាមិ បញ្ញបេស្សាមិ បដ្ឋបេស្សាមិ វិវរិស្សាមិ វិភជិស្សាមិ ឧត្តានីករិស្សាមិ បកាសិស្សាមីតិ ហន្ទាហំ កិត្តយិស្សាមិ គិរំ វណ្ណូបសញ្ហិតំ ។ តេនាហ បិង្គិយត្ថេរោ

បហីនមលមោហស្ស មានមក្ខប្បហាយិនោ
ហន្ទាហំ កិត្តយិស្សាមិ គិរំ វណ្ណូបសញ្ហិតន្តិ ។

(១៤៨) តមោនុទោ ពុទ្ធោ សមន្តចក្ខុ
លោកន្តគូ សព្វភវាតិវត្តោ
អនាសវោ សព្វទុក្ខប្បហីនោ
សច្ចវ្ហយោ ព្រហ្មុបាសិតោ មេ ។

(១៨៧) អធិប្បាយពាក្យថា បើដូច្នោះ ខ្ញុំនឹងសំដែងពាក្យប្រកប ដោយគុណ ត្រង់ពាក្យថា បើដូច្នោះខ្ញុំ គឺការតបទ ។ បេ ។ ពាក្យថា បើដូច្នោះខ្ញុំ នុះជាលំដាប់បទ ។ ពាក្យថា សំដែង គឺ នឹងពោល បង្ហាញ ឲ្យដឹងច្បាស់ តាំងផ្តើម បើក វែកញែក ធ្វើឲ្យរាក់ ប្រកាស នូវពាក្យ វាចា គន្លងពាក្យ នឹងសំដី ដែលកប កបព្រម ប្រកប ប្រកបព្រម ចូលដល់ ចូលដល់ព្រម មកដល់ព្រម ដោយគុណ ហេតុនោះ (លោកពោលថា) បើដូច្នោះ ខ្ញុំនឹងសំដែងពាក្យប្រកបដោយគុណ ។ ហេតុនោះ បិង្គិយត្ថេរពោលថា

បើដូច្នោះ ខ្ញុំនឹងសំដែងពាក្យប្រកបដោយគុណ របស់
ព្រះមានព្រះភាគ ទ្រង់លះបង់មន្ទិលនឹងមោហៈហើយ
លះបង់មានះនឹងមក្ខៈហើយ ។

(១៨៨) ព្រះពុទ្ធទ្រង់បន្ទោបង់ងងឹត មានសមន្តចក្ខុ ទ្រង់
ដល់ទីបំផុតលោក ប្រព្រឹត្តកន្លងហើយនូវភពទាំងពួង
មិនមានអាសវៈ ទ្រង់លះបង់ទុក្ខទាំងពួងហើយ មាន
ព្រះនាមដ៏ទៀងទាត់ ខ្ញុំបានចូលទៅគាល់ព្រះមានព្រះ
ភាគប្រសើររួចហើយ ។

## សោឡសមាណវកប្បញ្ហានិគមនិទ្ទេសោ

(១៨៩) តមោនុទោ ពុទ្ធោ សមន្តចក្ខូតិ តមោ-នុទោតិ ភគវា រាគតមំ ទោសតមំ មោហតមំ មា-នតមំ ទិដ្ឋិតមំ កិលេសតមំ ទុច្ចរិតតមំ អន្ធករណំ អចក្ខុករណំ អញ្ញាណករណំ បញ្ញានិរោធិកំ វិឃា-តបក្ខិកំ អនិព្វានសំវត្តនិកំ នុទិ បនុទិ ជហិ វិនោ-ទយិ ព្យន្តីមកាសិ អនភាវង្គមេសីតិ តមោនុទោ ។ ពុទ្ធោតិ យោ សោ ភគវា ។បេ។ សច្ឆិកា បញ្ញត្តិ យទិទំ ពុទ្ធោតិ ។ សមន្តចក្ខូតិ សមន្តចក្ខុ វុច្ចតិ សព្វញ្ញុតញ្ញាណំ ។បេ។ តថាគតោ តេន សមន្ត-ចក្ខូតិ តមោនុទោ ពុទ្ធោ សមន្តចក្ខុ ។

(១៩០) លោកន្តគូ សព្វភវាតិវត្តោតិ លោកាតិ ឯកោ លោកោ ភវលោកោ ។ ទ្វេ លោកា ស-ម្បត្តិ ច ភវលោកោ វិបត្តិ ច ភវលោកោ ។ ត-យោ លោកា តិស្សោ វេទនា ។ ចត្តារោ លោកា ចត្តារោ អាហារា ។ បញ្ច លោកា បញ្ចុបាទាន-ក្ខន្ធា ។ ឆ លោកា ឆ អជ្ឈត្តិកានិ អាយតនានិ ។

## សោឡសមាណវកបញ្ហានិទ្ទេស

(១៨៩) អធិប្បាយពាក្យថា ព្រះពុទ្ធទ្រង់បន្ទោបង់ងងឹត មានសមន្តចក្ខុ ត្រង់ពាក្យថា បន្ទោបង់ងងឹត គឺ ព្រះមានព្រះភាគបានបន្ទោបង់ កំចាត់បង់ លះបង់ បន្សាត់បង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាន នូវងងឹត គឺរាគៈ ងងឹតគឺទោសៈ ងងឹតគឺមោហៈ ងងឹតគឺមានះ ងងឹតគឺទិដ្ឋិ ងងឹតគឺកិលេស ងងឹតគឺទុច្ចរិត ធម្មជាតធ្វើឲ្យងងឹត ធ្វើមិនឲ្យមានចក្ខុ ធ្វើមិនឲ្យមានញាណ រំលត់ប្រាជ្ញា ប្រព្រឹត្តទៅក្នុងពួកនៃសេចក្តីបង្អៀតចង្អល់ មិនប្រព្រឹត្តទៅដើម្បីនិព្វាន ហេតុនោះ (លោកពោលថា) បន្ទោបង់ងងឹត ។ ពាក្យថា ព្រះពុទ្ធ បានដល់ព្រះមានព្រះភាគ ។ បេ ។ បញ្ញត្តិថា ព្រះពុទ្ធ នេះ (កើត) ព្រោះការត្រាស់ដឹង ។ ពាក្យថា សមន្តចក្ខុ សេចក្តីថា សព្វញ្ញុតញ្ញាណ លោកហៅថា សមន្តចក្ខុ ។ បេ ។ ព្រះតថាគត ព្រះនាមថាសមន្តចក្ខុ ដោយហេតុនោះ ហេតុនោះ (លោកពោលថា) ព្រះពុទ្ធទ្រង់បន្ទោបង់ងងឹត មានសមន្តចក្ខុ ។

(១៩០) អធិប្បាយពាក្យថា ទ្រង់ដល់ទីបំផុតលោក ប្រព្រឹត្តកន្លងហើយនូវគតិទាំងពួង ត្រង់ពាក្យថា លោក គឺ លោក ១ បានដល់ភវលោក ។ លោក ២ បានដល់សម្បត្តិភវលោក ១ វិបត្តិភវលោក ១ ។ លោក ៣ បានដល់វេទនា ៣ ។ លោក ៤ បានដល់អាហារ ៤ ។ លោក ៥ បានដល់ឧបាទានក្ខន្ធ ៥ ។ លោក ៦ បានដល់អាយតនៈខាងក្នុង ៦ ។

សត្ត លោកា សត្ត វិញ្ញាណដ្ឋិតិយោ ។ អដ្ឋ លោកា អដ្ឋ លោកធម្មា ។ នវ លោកា នវ សត្តាវាសា ។ ទស លោកា ទស ឧបក្កិលេសា ។ ឯកាទស លោកា ឯកាទស កាមភវា ។ ទ្វាទស លោកា ទ្វាទសាយតនានិ ។ អដ្ឋារស លោកា អដ្ឋារស ធាតុយោ ។ លោកន្តគូតិ ភគវា លោកស្ស អន្តគតោ អន្តប្បត្តោ កោដិគតោ កោដិប្បត្តោ ។ បេ ។ និព្ពានគតោ និព្ពានប្បត្តោ សោ វុដ្ឋវាសោ ចិណ្ណចរណោ ។ បេ ។ ជាតិជរាមរណសំសារោ នត្ថិ តស្ស បុនព្ភវោតិ លោកន្តគូ ។ សព្វភវាតិវត្តោតិ ភវាតិ ទ្វេ ភវា កម្មភវោ ច បដិសន្ធិកោ ច បុនព្ភវោ ។ កតមោ កម្មភវោ ។ បុញ្ញាភិសង្ខារោ អបុញ្ញាភិសង្ខារោ អានេញ្ជាភិសង្ខារោ អយំ កម្មភវោ ។ កតមោ បដិសន្ធិកោ បុនព្ភវោ ។ បដិសន្ធិកា រូបា វេទនា សញ្ញា សង្ខារា វិញ្ញាណំ អយំ បដិសន្ធិកោ បុនព្ភវោ ។ ភគវា កម្មភវញ្ច បដិសន្ធិកញ្ច បុនព្ភវំ អតិវត្តោ អតិក្កន្តោ វីតិវត្តោតិ លោកន្តគូ សព្វភវាតិវត្តោ ។

លោក ៧ បានដល់វិញ្ញាណដ្ឋិតិ ៧ ។ លោក ៨ បានដល់លោកធម៌ ៨ ។ លោក ៩ បានដល់សត្តាវាសៈ ៩ ។ លោក ១០ បានដល់ឧបក្កិលេស ១០ ។ លោក ១១ បានដល់កាមភព ១១ ។ លោក ១២ បានដល់អាយតនៈ ១២ ។ លោក ១៨ បានដល់ធាតុ ១៨ ។ ពាក្យថា ទ្រង់ដល់ទីបំផុតលោក បានសេចក្ដីថា ព្រះមានព្រះភាគទៅកាន់ទីបំផុត ដល់ទីបំផុត ទៅកាន់ទីខាងចុង ដល់ទីខាងចុងនៃលោក ។ បេ ។ ទៅនិព្វាន ដល់និព្វាន ព្រះមានព្រះភាគនោះមានការនៅរួចហើយ មានចរណៈសន្សំហើយ ។ បេ ។ ភពថ្មីគឺការអន្ទោលទៅកាន់ជាតិ ជរា និងមរណៈ របស់ព្រះអង្គមិនមានឡើយ ហេតុនោះ (លោកពោលថា) ទ្រង់ដល់ទីបំផុតលោក ។ ពាក្យថា ភព ក្នុងបទថា ប្រព្រឹត្តកន្លងហើយនូវភពទាំងពួង បានដល់ភព ២ គឺកម្មភព ១ បដិសន្ធិកបុនព្ភព ១ ។ កម្មភព តើដូចម្ដេច ។ បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ អានេញ្ជាភិសង្ខារ នេះឈ្មោះថា កម្មភព ។ បដិសន្ធិកបុនព្ភព តើដូចម្ដេច ។ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលប្រកបដោយបដិសន្ធិ នេះឈ្មោះថាបដិសន្ធិកបុនព្ភព ។ ព្រះមានព្រះភាគបានកន្លង ឈានកន្លង ប្រព្រឹត្តកន្លង នូវកម្មភពនិងបដិសន្ធិកបុនព្ភព ហេតុនោះ (លោកពោលថា) ទ្រង់ដល់ទីបំផុតលោក ប្រព្រឹត្តកន្លងហើយនូវភពទាំងពួង ។

### សោឡសមាណវកបញ្ហានិគមនិទ្ទេសោ

(១៨១) អនាសវោ សព្វទុក្ខប្បហីនោតិ អនាសវាតិ ចត្តារោ អាសវា កាមាសវោ ភវាសវោ ទិដ្ឋាសវោ អវិជ្ជាសវោ ។ តេ អាសវា ពុទ្ធស្ស ភគវតោ បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹអនុប្បាទធម្មា តស្មា ពុទ្ធោ អនាសវោ ។ សព្វទុក្ខប្បហីនោតិ សព្វំ តស្ស បដិសន្ធិកំ ជាតិទុក្ខំ ជរាទុក្ខំ ព្យាធិទុក្ខំ មរណទុក្ខំ សោកបរិទេវទុក្ខទោមនស្សុបាយាសទុក្ខំ ។ បេ ។ ទិដ្ឋិព្យសនទុក្ខំ បហីនំ សមុច្ឆិន្នំ បដិប្បស្សទ្ធំ អភព្វុប្បត្តិកំ ញាណគ្គិនា ទឌ្ឍំ តស្មា ពុទ្ធោ សព្វទុក្ខប្បហីនោ ។

(១៨២) សច្ចវ្ហយោ ព្រហ្មុបាសិតោ មេតិ សច្ចវ្ហយោតិ សច្ចសទិសវ្ហយោ ។ វិបស្សី ភគវា សិខី ភគវា វេស្សភូ ភគវា កកុសន្ធោ ភគវា កោណាគមនោ ភគវា កស្សបោ ភគវា ពុទ្ធា ភគវន្តោ សទិសនាមា សច្ចសទិសវ្ហយា ។

## សោឡសមាណវកបញ្ហានិគមនិទ្ទេស

(១៥១) អធិប្បាយពាក្យថា មិនមានអាសវៈ ទ្រង់លះបង់ទុក្ខទាំងពួងហើយ ត្រង់ពាក្យថា មិនមានអាសវៈ សេចក្ដីថា អាសវៈ៤ គឺកាមាសវៈ១ ភវាសវៈ១ ទិដ្ឋាសវៈ១ អវិជ្ជាសវៈ១ ។ អាសវៈទាំងនោះ ព្រះពុទ្ធមានព្រះភាគបានលះបង់ គាស់រំលើងឫសគល់ ធ្វើឲ្យមានតែទីនៅដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនកើតមាន មិនឲ្យមានកិរិយាកើតតទៅជាធម្មតា ហេតុនោះ ព្រះពុទ្ធឈ្មោះថាមិនមានអាសវៈ ។ ពាក្យថា ទ្រង់លះបង់ទុក្ខទាំងពួងហើយ សេចក្ដីថា ជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខ សោកទុក្ខ បរិទេវទុក្ខ ទោមនស្សុបាយាសទុក្ខ ។ បេ ។ ទិដ្ឋិព្យសនទុក្ខ ទាំងពួង ដែលប្រកបដោយបដិសន្ធិ ព្រះពុទ្ធនោះបានលះបង់ កាត់ផ្ដាច់ រម្ងាប់បង់ ធ្វើមិនឲ្យកើតវិញ បានដុតដោយភ្លើងគឺញាណហើយ ហេតុនោះ ព្រះពុទ្ធ ឈ្មោះថាមានទុក្ខទាំងពួងលះបង់ហើយ ។

(១៥២) ពាក្យថា មានព្រះនាមដ៏ទៀងទាត់ ក្នុងបទថា មានព្រះនាមដ៏ទៀងទាត់ ខ្ញុំបានចូលទៅគាល់ព្រះមានព្រះភាគប្រសើររួចហើយ សេចក្ដីថា ព្រះពុទ្ធ មានព្រះនាមដ៏ទៀងទាត់ដូចគ្នា ។ គឺ ព្រះវិបស្សី ព្រះនាមថាភគវា ព្រះសិខី ព្រះនាមថាភគវា ព្រះវេស្សភូ ព្រះនាមថាភគវា ព្រះកកុសន្ធៈ ព្រះនាមថាភគវា ព្រះកោនាគមនៈ ព្រះនាមថាភគវា ព្រះកស្សបៈ ព្រះនាមថាភគវា ព្រះពុទ្ធដ៏មានព្រះភាគទាំងឡាយ សឹងមានព្រះនាមដូចគ្នា មានព្រះនាមដ៏ទៀងទាត់ស្មើគ្នា ។

ភគវា សក្យមុនិ តេសំ ពុទ្ធានំ ភគវន្តានំ សទិសនា-
មោ សច្ចសទិសវ្ហយោតិ តស្មា ពុទ្ធោ សច្ចវ្ហយោ ។
ព្រហ្មុបាសិតោ មេតិ សោ ភគវា មយា អា-
សិតោ ឧបាសិតោ បយិរុបាសិតោ បរិបុច្ឆិតោ
បរិបញ្ហិតោតិ សច្ចវ្ហយោ ព្រហ្មុបាសិតោ មេ ។
តេនាហ បិង្គិយត្ថេរោ

តមោនុទោ ពុទ្ធោ សមន្តចក្ខុ
លោកន្តគូ សព្វភវាតិវត្តោ
អនាសវោ សព្វទុក្ខប្បហីនោ
សច្ចវ្ហយោ ព្រហ្មុបាសិតោ មេតិ ។

(១៩៣) ទិជោ យថា កុព្វនកំ បហាយ
ពហុប្ផលំ កាននំ អាវសេយ្យ
ឯវមាហំ អប្បទស្សេ បហាយ
មហោទធឹ ហំសរិវជ្ឈបត្តោ ។

ព្រះសក្យមុនីមានព្រះភាគ មានព្រះនាមដូចគ្នា មានព្រះនាមដ៏ទៀងទាត់ ស្មើនឹងព្រះពុទ្ធ មានព្រះភាគទាំងឡាយនោះ ព្រោះហេតុនោះ ព្រះពុទ្ធ ឈ្មោះថាមានព្រះនាមដ៏ទៀងទាត់ ។ ពាក្យថា ខ្ញុំបានចូលទៅគាល់ព្រះមានព្រះភាគប្រសើររួចហើយ គឺព្រះមានព្រះភាគនោះ ខ្ញុំបានចូលទៅ ចូលទៅជិត ចូលទៅអង្គុយជិត សាកសួរ ចោទសួរហើយ ហេតុនោះ (លោកពោលថា) ព្រះមានព្រះភាគ មានព្រះនាមដ៏ទៀងទាត់ ខ្ញុំបានចូលទៅគាល់ព្រះមានព្រះភាគប្រសើររួចហើយ ។ ហេតុនោះ បិង្គិយត្ថេរពោលថា

ព្រះពុទ្ធ ទ្រង់បន្ទោបង់ងងឹត មានសមន្តចក្ខុ ទ្រង់ដល់ទី
បំផុតលោក ប្រព្រឹត្តកន្លងហើយនូវភពទាំងពួង មិនមាន
អាសវៈ ទ្រង់លះបង់ទុក្ខទាំងពួងហើយ មានព្រះនាមដ៏ទៀង
ទាត់ ខ្ញុំបានចូលទៅគាល់ព្រះមានព្រះភាគប្រសើររួចហើយ ។

(១៥៣) (ព្រះបិង្គិយត្ថេរពោលថា) ទិជសត្វ លះបង់ព្រៃតូច
(មានផ្លែតិច) មកនៅអាស្រ័យ នឹងព្រៃធំ មានផ្លែច្រើន
ដូចម្តេចមិញ ខ្ញុំលះបង់បុគ្គលទាំងឡាយ ដែលមានការឃើញ
តិច (មកចូលប្រសព្វនឹងព្រះពុទ្ធទ្រង់មានប្រាជ្ញាច្រើន) ដូច
ហង្សចូលប្រសព្វនូវស្រះ ដែលមានទឹកច្រើន ដូច្នោះឯង ។

សោឡសមាណវកបញ្ហានិគមនិទ្ទេសោ

(១៨៧) ទិជោ យថា កុព្វនកំ បហាយ ពហុប្ផលំ កាននំ អាវសេយ្យាតិ ទិជោ វុច្ចតិ បក្ខី ។ កឹការណា ទិជោ វុច្ចតិ បក្ខី ។ ទ្វិក្ខត្តុំ ជាយតិ ទិជោ មាតុកុច្ឆិម្ហា ច អណ្ឌកោសម្ហា ច តំការណា ទិជោ វុច្ចតិ បក្ខីតិ ទិជោ ។ យថា កុព្វនកំ បហាយាតិ យថា ទិជោ កុព្វនកំ រិត្តវនកំ អប្បភក្ខំ អប្បោទកំ បហាយ ជហិត្វា អតិក្កមិត្វា វីតិវត្តេត្វា អញ្ញំ ពហុប្ផលំ ពហុភក្ខំ ពហុរុក្ខំ(១) មហន្តំ កាននំ វនសណ្ឌំ អធិគច្ឆេយ្យ វិន្ទេយ្យ បដិលភេយ្យ តស្មឹ វនសណ្ឌេ វាសំ កប្បេយ្យាតិ ទិជោ យថា កុព្វនកំ បហាយ ពហុប្ផលំ កាននំ អាវសេយ្យ ។

(១៨៨) ឯវមហំ អប្បទស្សេ បហាយ មហោទធឹ ហំសរិវជ្ឈបត្តោតិ ឯវន្តិ ឱបម្មសម្បដិបាទនំ ។

---

១ ម. ពហុទកំ ។

(១៩៨) ពាក្យថា ទិជសត្វ លះបង់ព្រៃតូច មកនៅអាស្រ័យនឹងព្រៃធំ ដែលមានផ្លែច្រើន ដូចម្តេចមិញ អធិប្បាយថា សត្វស្លាប លោកហៅថា ទិជសត្វ ។ ហេតុអ្វី សត្វស្លាប លោកហៅថា ទិជសត្វ ។ ទិជសត្វតែងកើត ២ លើក គឺ កើតអំពីផ្ទៃមេ ១ លើក អំពីស្រោមស៊ុត ១ លើក ហេតុនោះ សត្វស្លាបទើបលោកហៅថា ទិជសត្វ ហេតុនោះ (លោកពោលថា) ទិជសត្វ ។ ពាក្យថា លះបង់ព្រៃតូច ដូចម្តេចមិញ គឺ ទិជសត្វលះបង់ បោះបង់ កន្ទង់ កន្ទង់បង់ នូវព្រៃតូច ព្រៃស្តើង ដែលមានចំណីតិច មានទឹកតិច ហើយបាន ចួបប្រសព្វ បានចំពោះនូវព្រៃធំ ដទៃ ដែលមានផ្លែច្រើន មានចំណីច្រើន មានឈើច្រើន គឺថា គប្បីសម្រេចការនៅក្នុងដងព្រៃនោះ ដូចម្តេចមិញ ហេតុនោះ (លោកពោលថា) ទិជសត្វលះបង់ព្រៃតូច មកនៅអាស្រ័យនឹងព្រៃធំ ដែលមានផ្លែច្រើន ដូចម្តេចមិញ ។

(១៩៩) អធិប្បាយពាក្យថា ខ្ញុំលះបង់បុគ្គលទាំងឡាយ ដែលមានការឃើញតិច (មកចួបប្រសព្វព្រះពុទ្ធ ទ្រង់មានប្រាជ្ញាច្រើន) ដូចហង្សចួបប្រសព្វ នូវស្រះដែលមានទឹកច្រើន ដូច្នោះឯង ត្រង់ពាក្យថា ដូច្នោះឯង គឺ ជាពាក្យញុំាងសេចក្តីឧបមាឲ្យសម្រេច ។

អប្បទស្សេ បហាយាតិ យោ ច ពាវរី ព្រាហ្មណោ យេ ចញ្ញេ តស្ស អាចរិយា ពុទ្ធំ ភគវន្តំ ឧបាទាយ អប្បទស្សា បរិត្តទស្សា ថោកទស្សា ឱមកទស្សា លាមកទស្សា ជតុក្កទស្សា ។ តេ ព្រាហ្មណា អប្បទស្សេ បរិត្តទស្សេ ថោកទស្សេ ឱមកទស្សេ លាមកទស្សេ ជតុក្កទស្សេ បហាយ បជហិត្វា អតិក្កមិត្វា សមតិក្កមិត្វា ពុទ្ធំ ភគវន្តំ អគ្គទស្សំ សេដ្ឋទស្សំ វិសេដ្ឋទស្សំ ឧត្តមទស្សំ បវរំ អសមំ អសមសមំ អប្បដិភាគំ អប្បដិបុគ្គលំ ទេវាតិទេវំ នរាសភំ បុរិសសីហំ បុរិសនាគំ បុរិសាជញ្ញំ បុរិសនិសភំ បុរិសធោរយ្ហំ ទសពលំ តាទឹ អធិគច្ឆឹ វិន្ទឹ បដិលភឹ ។

ពាក្យថា លះបង់បុគ្គលទាំងឡាយ ដែលមានការឃើញតិច សេចក្តីថា ពាហិរព្រាហ្មណ៍ណា និងពួកជនដទៃណាជាអាចារ្យ របស់ពាហិរព្រាហ្មណ៍នោះ បើប្រៀបផ្ទឹមនឹងព្រះពុទ្ធមានព្រះភាគ ទៅជាអ្នកមានការឃើញតិច មានការឃើញស្តួចស្តើង មានការឃើញថោកថយ មានការឃើញអួនថយ មានការឃើញលាមក មានការឃើញអាក្រក់ ៗ ខ្ញុំលះបង់ បោះបង់ កន្លង កន្លងបង់នូវព្រាហ្មណ៍ទាំងនោះ ដែលមានការឃើញតិច មានការឃើញស្តើងស្តួច មានការឃើញថោកថយ មានការឃើញអួនថយ មានការឃើញលាមក មានការឃើញអាក្រក់ មកចូប ប្រសព្វ បាន ចំពោះនូវព្រះពុទ្ធមានព្រះភាគ ទ្រង់ឃើញដ៏លើស ទ្រង់ឃើញដ៏ប្រសើរ ទ្រង់ឃើញវិសេស ទ្រង់ឃើញឧត្តម ព្រះអង្គជាបុគ្គលប្រសើរ រកបុគ្គលស្មើមិនមាន ព្រះអង្គស្មើដោយព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើ គ្មានបំណែកប្រៀប មិនមានបុគ្គលប្រៀប ទ្រង់ជាទេវតាវិសេស ជាងទេវតា ទ្រង់ជានរាសភៈ ជាបុរិសសីហៈ ជាបុរិសនាគ ជាបុរសអាជានេយ្យ ជាបុរិសនិសភៈ ជាអ្នកនាំទៅនូវធុរៈរបស់បុរស ជាទសពល ជាតាទិបុគ្គល ៗ

### សោឡសមាណវកបញ្ហានិគមនំ ទ្វេសោ

យថាវ ហំសោ មហន្តំ មានុសកតំ វា សរំ អនោតត្តំ វា ទហំ មហាសមុទ្ទំ វា អក្ខោព្ភំ អមិតោទកំ អធិគច្ឆេយ្យ វិន្ទេយ្យ បដិលភេយ្យ ឯវមេវ បិង្គិយោ ព្រាហ្មណោ ពុទ្ធំ ភគវន្តំ អក្ខោព្ភំ អមិតតេជំ បភិន្នញ្ញាណំ វិវដចក្ខុំ បញ្ញាបភេទកុសលំ អធិគតប្បដិសម្ភិទំ ចតុវេសារជ្ជប្បត្តំ សុទ្ធាធិមុត្តំ សេតប្បច្ចត្តំ អទ្វយភាណឹ តាទឹ តថាបដិញ្ញំ អបរិត្តំ មហន្តំ គម្ភីរំ អប្បមេយ្យំ ទុប្បរិយោគាឡ្ហំ ពហុរតនំ សាគរសមំ ឆឡង្គុបេក្ខាយ សមន្នាគតំ អតុលំ វិបុលំ អប្បមេយ្យំ តំ តាទិសំ បវទតមគ្គវាទិនំ សិនេរុមិវ(១) នគានំ គរុឡមិវទិជានំ សីហមិវ មិគានំ

---

១ ម. មេរុមិវ ។

## សោឡសមាណវកបញ្ហានិគមនិទ្ទេស

ដូចហង្ស គប្បីចូល ប្រសព្វ បានចំពោះ នូវស្រះធំដែលមនុស្សកសាង ក្តី អនោតត្តស្រះក្តី មហាសមុទ្រក្តី ដែលមិនកម្រើក មានទឹករាប់មិនអស់ យ៉ាងណា ខ្ញុំឈ្មោះបិង្គិយព្រាហ្មណ៍ បានចួប ប្រសព្វ បានចំពោះនូវ ព្រះពុទ្ធមានព្រះភាគ ព្រះអង្គមិនកម្រើក មានតេជះរាប់មិនបាន មាន ញាណបែកធ្លាយ មានចក្ខុបើកហើយ ព្រះអង្គឆ្លៀវឆ្លាសក្នុងប្រភេទនៃ ប្រាជ្ញា ព្រះអង្គបានបដិសម្ភិទា បានចតុវេសារជ្ជញាណ ទ្រង់មាន ព្រះទ័យចុះស៊ប់ក្នុងផលសមាបត្តិដ៏បរិសុទ្ធ ទ្រង់មានអត្តភាពមិនផ្សេងគ្នា ទ្រង់មិនពោលពីរព្រះឱស្ឋ ទ្រង់មិនញាប់ញ័រ ទ្រង់មានការប្តេជ្ញាទៀង ទ្រង់មិនតូច ទ្រង់ធំ ទ្រង់មានប្រាជ្ញាជ្រៅ ទ្រង់មានប្រាជ្ញាប្រមាណ មិនបាន ទ្រង់មានប្រាជ្ញាមិនអាចអ្នកណាស្ទង់បាន ទ្រង់មានរតនៈ ច្រើន ទ្រង់ស្មើដោយសាគរ ទ្រង់ប្រកបដោយឧបេក្ខា ៦ ទ្រង់មានព្រះ គុណធំទូលាយ ថ្លឹងមិនបាន ប្រមាណមិនត្រូវ ព្រះមានព្រះភាគនោះ ទ្រង់ប្រកបដោយតាទិគុណ ទ្រង់ជាអ្នកពោលដ៏ប្រសើរជាងជនអ្នកពោល ទាំងឡាយ ដូចភ្នំសិនេរុ ប្រសើរជាងភ្នំទាំងឡាយ ឬដូចគ្រុឌ ប្រសើរ ជាងទិជសត្វទាំងឡាយ ឬក៏ដូចសីហៈ ប្រសើរជាងពួកម្រឹគ ពុំនោះសោត

ឧទធិមិវ អក្ខោភំ ជិនបវរំ អធិគច្ឆឹ វិន្ទឹ បដិលភិន្តិ ឯវមាហំ អប្បទស្សេ បហាយ មហោទធឹ ហំសរិវជ្ឈបត្តោ ។ តេនាហ បិង្គិយត្ថេរោ

ទិជោ យថា កុព្វនកំ បហាយ
ពហុប្ផលំ កាននំ អាវសេយ្យ
ឯវមាហំ អប្បទស្សេ បហាយ
មហោទធឹ ហំសរិវជ្ឈបត្តោតិ ។

(១៨៦) យេមេ បុព្វេ វិយាកំសុ (ហុរំ
គោតមសាសនា)

ឥច្ចាសិ ឥតិ ភវិស្សតិ
សព្វំ តំ ឥតិហីតិហំ
សព្វំ តក្កវឌ្ឍនំ ។

ដូចសមុទ្រ ប្រសើរជាងអន្លង់ទឹកទាំងឡាយ ព្រះអង្គជាព្រះជិនស្រី ដ៏ប្រសើរ ក៏យ៉ាងនោះដែរ ហេតុនោះ (លោកពោលថា) ខ្ញុំលះបង់បុគ្គលទាំងឡាយដែលមានការឃើញតិច (មកចួបប្រសព្វព្រះពុទ្ធទ្រង់មានប្រាជ្ញាច្រើន) ដូចហង្សដែលចួបប្រសព្វនូវស្រះ មានទឹកច្រើន ដូច្នោះឯង ។ ហេតុនោះ ព្រះបិង្គិយត្ថេរពោលថា

ទិជសត្វលះបង់ព្រៃតូច (មានផ្លែតិច) មកនៅអាស្រ័យនឹង
ព្រៃធំ មានផ្លែច្រើន ដូចម្តេចមិញ ខ្ញុំលះបង់បុគ្គលទាំង
ឡាយ ដែលមានការឃើញតិច (មកចួបប្រសព្វនឹងព្រះពុទ្ធ
ទ្រង់មានប្រាជ្ញាច្រើន) ដូចហង្សចួបប្រសព្វនូវស្រះ មាន
ទឹកច្រើន ដូច្នោះឯង ។

(១៩៦) ជនទាំងឡាយណា ក្នុងកាលមុន (អំពីសាសនា
នៃព្រះគោតម) ជនទាំងឡាយនោះ បានព្យាករហើយថា
ហេតុមានមកហើយ ដូច្នេះ ៗ នឹងមានតទៅ ដូច្នេះ ៗ
ពាក្យទាំងអស់នោះ (មិនទាន់ប្រាកដទេ) ជាពាក្យជឿស្តាប់
បុគ្គលដទៃ ពាក្យទាំងអស់នោះ ជាពាក្យធ្វើសេចក្តីត្រិះរិះឲ្យ
បម្រើន (ខ្ញុំមិនពេញចិត្តនឹងពាក្យនោះឡើយ) ។

សោឡសមាណវកបញ្ហានិគមនិទ្ទេសោ

(១៤៧) យេ មេ បុព្វេ វិយាកំសូតិ យេ ច ពាវរី ព្រាហ្មណោ យេ ចញ្ញេ តស្ស អាចរិយា តេ សកំ ទិដ្ឋឹ សកំ ខន្តឹ សកំ រុចឹ សកំ លទ្ធឹ សកំ អជ្ឈាសយំ សកំ អធិប្បាយំ ព្យាកំសុ អាចិក្ខឹសុ ទេសយឹសុ បញ្ញបឹសុ បដ្ឋបឹសុ វិវរឹសុ វិភជឹសុ ឧត្តានីមកំសុ បកាសេសុន្តិ យេ មេ បុព្វេ វិយាកំសុ ។

(១៤៨) ហុរំ គោតមសាសនាតិ ហុរំ គោតមសាសនា បរំ គោតមសាសនា បុរេ គោតមសាសនា បឋមតរំ គោតមសាសនា ពុទ្ធសាសនា ជិនសាសនា តថាគតសាសនា ទេវសាសនា អរហន្តសាសនាតិ ហុរំ គោតមសាសនា ។

(១៤៧) ពាក្យថា ជនទាំងឡាយណា . . . ជនទាំងឡាយនោះបានព្យាករហើយ ត្រង់ពាក្យថា ជនទាំងឡាយណា គឺ ពាវរីព្រាហ្មណ៍ណា នឹងពួកជនដទៃណា ជាអាចារ្យរបស់ពាវរីព្រាហ្មណ៍នោះ ព្រាហ្មណ៍ទាំងនោះបានព្យាករ ប្រាប់ សំដែង បញ្ញត្ត តាំងទុក បើក វែកញែក ធ្វើឲ្យងាយ ប្រកាសនូវទិដ្ឋិរបស់ខ្លួន សេចក្ដីគួររបស់ខ្លួន សេចក្ដីគាប់ចិត្តរបស់ខ្លួន លទ្ធិរបស់ខ្លួន អធ្យាស្រ័យរបស់ខ្លួន សេចក្ដីប៉ុនប៉ងរបស់ខ្លួន ហេតុនោះ ( លោកពោលថា ) ជនទាំងឡាយណា . . . ជនទាំងឡាយនោះបានព្យាករហើយ ។

(១៤៨) ពាក្យថា ក្នុងកាលមុនអំពីសាសនានៃព្រះគោតម គឺ ក្នុងកាលមុនអំពីសាសនាព្រះគោតម ដទៃអំពីសាសនាព្រះគោតម ក្នុងកាលមុនដំបូងអំពីសាសនាព្រះគោតម ក្នុងកាលមុនបង្អស់ អំពីសាសនាព្រះគោតម អំពីសាសនាព្រះពុទ្ធ អំពីសាសនាព្រះជិនស្រី អំពីសាសនាព្រះតថាគត អំពីសាសនាព្រះពុទ្ធជាទេវតា អំពីសាសនាអរហន្ត ហេតុនោះ ( លោកពោលថា ) ក្នុងកាលមុន អំពីសាសនានៃព្រះគោតម ។

(១៥៩) ឥច្ឆាសិ ឥតិ ករិស្សតីតិ ឃរំ ការិ អសិ ឃរំ ការិ ករិស្សតីតិ ឥច្ឆាសិ ឥតិ ករិស្សតិ ។

(១៦០) សព្វំ ឥតិហីតិហន្តិ សព្វំ តំ ឥតិ-ហីតិហំ ឥតិកិរាយ បរម្បរាយ បិដកសម្បទាយ តក្កហេតុ នយហេតុ អាការបរិវិតក្កេន ទិដ្ឋិនិជ្ឈាន-ក្ខន្តិយា ន សាមំ សយមភិញ្ញាតំ ន អត្តបច្ចក្ខំ ធម្មំ កថយីស្សតិ សព្វំ ឥតិហីតិហំ ។

(១៦១) សព្វំ តក្កវឌ្ឍនន្តិ សព្វំ តក្កវឌ្ឍនំ វិតក្កវឌ្ឍនំ សង្កប្បវឌ្ឍនំ កាម-វិតក្កវឌ្ឍនំ ព្យាទានវិហឹសាវិតក្កវឌ្ឍនំ ញាតិ-វិតក្កវឌ្ឍនំ ជនបទវិតក្កវឌ្ឍនំ អមរវិតក្កវឌ្ឍនំ

(១៥៩) ពាក្យថា ហេតុមានមកហើយ ដូច្នេះៗ នឹងមានតទៅ ដូច្នេះៗ គឺ ព្ធថា ហេតុយ៉ាងនេះ ធ្លាប់មានមកហើយ ព្ធថា ហេតុយ៉ាងនេះ នឹងមានតទៅខាងមុខ ហេតុនោះ (លោកពោលថា) ហេតុមានហើយ ដូច្នេះៗ នឹងមានតទៅដូច្នេះៗ ។

(១៦០) ពាក្យថា ពាក្យទាំងអស់នោះ ជាពាក្យជឿស្តាប់បុគ្គលដទៃ គឺ ពាក្យទាំងអស់នោះ ជាពាក្យជឿស្តាប់បុគ្គលដទៃ ដោយព្ធដូច្នេះៗ ដោយព្ធត ៗ គ្នា ដោយការផ្សែផ្សេរនឹងក្បួន ដោយហេតុនៃការត្រិះរិះ ដោយហេតុនៃការគ្រេគ្រាន់ ដោយការជញ្ជឹងគិតតាមអាការៈ ដោយការយល់ ការពិនិត្យ នឹងការគិតគូរ គឺថា ជនទាំងនោះសំដែងធម៌ ដែលមិនបានត្រាស់ដឹងចំពោះខ្លួនឯង មិនជាក់ច្បាស់ចំពោះខ្លួនឯង ហេតុនោះ (លោកពោលថា) ពាក្យទាំងអស់នោះ ជាពាក្យជឿស្តាប់បុគ្គលដទៃ ។

(១៦១) ពាក្យថា ពាក្យទាំងអស់នោះ ជាពាក្យធ្វើសេចក្តីត្រិះរិះឲ្យចម្រើន គឺ ពាក្យទាំងអស់នោះ ជាពាក្យធ្វើសេចក្តីត្រិះរិះ ឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះផ្សេង ៗ ឲ្យចម្រើន ធ្វើតម្រិះ ឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះក្នុងកាម ឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះ ក្នុងព្យាបាទនឹងការបៀតបៀនឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះ ក្នុងញាតិឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះ ក្នុងជនបទឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះ ក្នុងការមិនស្លាប់ ឲ្យចម្រើន

បរានុទ្ទយតាបដិសំយុត្តវិតក្កវឌ្ឍនំ លាភសក្ការសិ-
លោកប្បដិសំយុត្តវិតក្កវឌ្ឍនំ អនវញ្ញត្តិប្បដិសំយុត្ត-
វិតក្កវឌ្ឍន្តិ សព្វន្តំ តក្កវឌ្ឍនំ ។ តេនាហ
បិង្គិយត្ថេរោ

យេមេ បុព្វេ វិយាកំសុ (ហុរំ
គោតមសាសនា)
ឥច្ចាសិ ឥតិ ភវិស្សតិ
សព្វន្តំ ឥតិហីតិហំ
សព្វន្តំ តក្កវឌ្ឍន្តិ ។

(១៦២) ឯកោ តមនុទាសីនោ ជុតិមា សោ បភង្ករោ
គោតមោ ភូរិបញ្ញាណោ គោតមោ ភូរិមេធសោ ។

ធ្វើសេចក្តីត្រិះរិះ ដែលប្រកបដោយសេចក្តីអាណិត ចំពោះបុគ្គលដទៃឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះប្រកបដោយលាភសក្ការៈនិងសេចក្តីសរសើរឲ្យចម្រើន ធ្វើសេចក្តីត្រិះរិះ ប្រកបដោយការមិនចង់ឲ្យគេមើលងាយឲ្យចម្រើន ហេតុនោះ (លោកពោលថា) ពាក្យទាំងអស់នោះ ជាពាក្យធ្វើសេចក្តីត្រិះរិះឲ្យចម្រើន ៗ ហេតុនោះ ព្រះបិង្គិយត្ថេរពោលថា

ជនទាំងឡាយណា ក្នុងកាលមុន (អំពីសាសនានៃព្រះគោតម)
ជនទាំងឡាយនោះបានព្យាករហើយថា ហេតុមានមកហើយ
ដូច្នេះ ៗ នឹងមានតទៅដូច្នេះ ៗ ពាក្យទាំងអស់នោះ (មិនទាន់
ប្រាកដទេ) ជាពាក្យជឿស្តាប់បុគ្គលដទៃ ពាក្យទាំងអស់នោះ
ជាពាក្យធ្វើសេចក្តីត្រិះរិះឲ្យចម្រើន (ខ្ញុំមិនពេញចិត្តនឹងពាក្យ
នោះឡើយ) ៗ

(១៦៨) ព្រះគោតមនោះ តែមួយព្រះអង្គឯង ទ្រង់បន្ទោបង់
ងងឹត គង់នៅជាសុខ ទ្រង់មានរស្មីរុងរឿង ទ្រង់ធ្វើពន្លឺ
(ដល់លោក) ព្រះគោតម មានប្រាជ្ញាជាគ្រឿងប្រាកដ
ព្រះគោតម មានប្រាជ្ញាដូចផែនដី ៗ

(១៦៣) ឯកោ តមនុទាសីនោតិ ឯកោតិ ភគវា បព្ពជ្ជាសង្ខាតេន ឯកោ អទុតិយដ្ឋេន ឯកោ តណ្ហាបហានដ្ឋេន ឯកោ ឯកន្តវីតរាគោតិ ឯកោ ឯកន្តវីតទោសោតិ ឯកោ ឯកន្តវីតមោហោតិ ឯកោ ឯកន្តនិក្កិលេសោតិ ឯកោ ឯកាយនមគ្គំ គតោតិ ឯកោ ឯកោ អនុត្តរំ សម្មាសម្ពោធិំ អភិសម្ពុទ្ធោតិ ឯកោ ។

កថំ ភគវា បព្ពជ្ជាសង្ខាតេន ឯកោ ។ ភគវា ទហរោវ សមានោ សុសុកាឡកេសោ ភទ្រេន យោព្វនេន សមន្នាគតោ បឋមេន វយសា អកាមកានំ មាតាបិតូនំ អស្សុមុខានំ រោទន្តានំ វិលបន្តានំ ញាតិសង្ឃំ បហាយ

(១៦៣) អធិប្បាយពាក្យថា តែមួយព្រះអង្គឯង ទ្រង់បន្ទោបង់ ងងឹត គង់នៅជាសុខ ត្រង់ពាក្យថា តែមួយព្រះអង្គឯង គឺ ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ដោយចំណែកនៃបព្វជ្ជា តែមួយព្រះអង្គឯង ដោយសេចក្តីថាមិនមានបុគ្គលជាគម្រប់ពីរ តែមួយព្រះអង្គឯង ដោយសេចក្តីថាលះបង់តណ្ហា តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ប្រាសចាករាគៈដោយចំណែកមួយ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ប្រាសចាកទោសៈដោយចំណែកមួយ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ប្រាសចាកមោហៈ ដោយចំណែកមួយ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់មិនមានកិលេសដោយចំណែកមួយ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ស្តេចទៅកាន់ផ្លូវជាទីទៅនៃបុគ្គលមួយនាក់ តែមួយព្រះអង្គឯង ព្រោះហេតុត្រាស់ដឹង នូវសម្មាសម្ពោធិញ្ញាណ ដ៏ប្រសើរ តែមួយព្រះអង្គ ៗ

ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ដោយចំណែកបព្វជ្ជា តើដូចម្តេច ៗ ព្រះមានព្រះភាគ ទ្រង់នៅក្មេង មានព្រះកេសាខ្មៅស្រិល ប្រកបដោយវ័យដ៏ចម្រើន គឺបឋមវ័យ កាលព្រះមាតានិងព្រះបិតា មិនសព្វព្រះហឫទ័យ (នឹងការចេញបព្វជ្ជា) មានព្រះភ័ក្ត្រដោកដោយទឹកព្រះនេត្រ ទ្រង់ព្រះកន្សែង ពិលាប ទ្រង់ក៏លះបង់ពពួកញាតិ

### សោឡសមាណវកបញ្ហានិគមនិទ្ទេសោ

សព្វំ ឃរាវាសបលិពោធំ ឆិន្ទិត្វា បុត្តទារបលិពោធំ ឆិន្ទិត្វា ញាតិបលិពោធំ ឆិន្ទិត្វា មិត្តាមច្ចបលិពោធំ ឆិន្ទិត្វា កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិត្វា អកិញ្ចនភាវំ ឧបគន្ត្វា ឯកោ ចរតិ វិចរតិ ឥរិយតិ វត្តេតិ ចាលេតិ យបេតិ យាបេតិ ឯវំ ភគវា បព្វជ្ជាសង្ខាតេន ឯកោ ។

កថំ ភគវា អទុតិយដ្ឋេន ឯកោ ។ សោ ឯវំ បព្វជិតោ សមានោ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវតិ អប្បសទ្ទានិ អប្បនិគ្ឃោសានិ វិជនវាតានិ មនុស្សរាហសេយ្យកានិ បដិសល្លានសារុប្បានិ សោ ឯកោ គច្ឆតិ ឯកោ តិដ្ឋតិ ឯកោ និសីទតិ ឯកោ សេយ្យំ កប្បេតិ ឯកោ គាមំ បិណ្ឌាយ បវិសតិ ឯកោ បដិក្កមតិ(១) ឯកោ រហោ និសីទតិ ឯកោ ចង្កមំ អធិដ្ឋាតិ ឯកោ ចរតិ វិចរតិ(២) ឥរិយតិ វត្តេតិ ចាលេតិ យបេតិ យាបេតិ ឯវំ ភគវា អទុតិយដ្ឋេន ឯកោ ។

---

១ ម. ឯកោ អតិក្កមតិ ឯកោ បដិក្កមតិ ។ ២ វិហរតិ ។

កាត់បលិពោធ ក្នុងយកវាសទាំងអស់ កាត់បលិពោធ ក្នុងបុត្រនឹងព្រះជាយា កាត់បលិពោធ ក្នុងញាតិ កាត់បលិពោធ ក្នុងមិត្តនឹងអាមាត្យ ទ្រង់ដាក់ព្រះកេសានឹងព្រះមស្សុ ទ្រង់ប្រដាប់ព្រះពស្ត្រជ្រលក់ទឹកចត់ ស្តេចចេញចាកព្រះពជដំណាក់ ចូលទៅកាន់ផ្នួស ដល់ស៊ីប់នូវភាពជាអ្នកមិនមានកង្វល់ តែមួយព្រះអង្គឯង ទ្រង់ចរ ត្រាច់ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ ហេតុនោះ ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ដោយបំណែកបព្វជ្ជា យ៉ាងនេះ ។

ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ដោយសេចក្តីថាមិនមានបុគ្គលជាគម្រប់ពីរ តើដូចម្តេច ។ ព្រះអង្គទ្រង់ផ្នួសយ៉ាងនេះហើយ ទ្រង់សេពបំពោះព្រៃតូចនឹងព្រៃធំ ជាសេនាសនៈស្ងាត់ មិនមានសំឡេង មិនមានស្គរគឹកកង ប្រាសចាកខ្យល់ដែលកើតអំពីសរីរៈនៃជន ជាសេនាសនៈដ៏ស្ងប់ស្ងាត់របស់មនុស្ស ដ៏សមគួរដល់ការពួនសម្ងំ ព្រះអង្គទ្រង់ពុទ្ធដំណើរ តែមួយអង្គឯង ទ្រង់ឋិត តែមួយអង្គឯង ទ្រង់គង់ តែមួយអង្គឯង ទ្រង់សម្រេចការផ្ទុំ តែមួយអង្គឯង ទ្រង់ចូលទៅបិណ្ឌបាតក្នុងស្រុក តែមួយអង្គឯង ទ្រង់ត្រឡប់មកវិញ តែមួយអង្គឯង ទ្រង់គង់ក្នុងទីរហោស្ថាន តែមួយអង្គឯង ទ្រង់អធិដ្ឋានបង្ក្រម តែមួយអង្គឯង ទ្រង់ចរ ត្រាច់ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ តែមួយអង្គឯង ហេតុនោះ ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ដោយសេចក្តីថាមិនមានបុគ្គលជាគម្រប់ពីរ យ៉ាងនេះ ។

កថំ ភគវា តណ្ហាបហានេន ឯកោ ។ សោ ឯវំ ឯកោ អទុតិយោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ នជ្ជា នេរញ្ជរាយ តីរេ ពោធិរុក្ខមូលេ មហាបធានំ បទហន្តោ មារំ សសេនំ(១) នមុចឹ បមត្តពន្ធុំ វិធមិត្វា តណ្ហំ ជាលិនឹ សរិតំ វិសត្តិកំ បជហិ វិនោទេសិ ព្យន្តឹមកាសិ អនភាវង្គមេសិ ។

តណ្ហាទុតិយោ បុរិសោ ទីឃមទ្ធាន សំសរំ
ឥត្ថភាវញ្ញថាភាវំ សំសារំ នាតិវត្តតិ
ឯវមាទីនវំ ញត្វា តណ្ហា ទុក្ខស្ស សម្ភវំ
វីតតណ្ហោ អនាទានោ សតោ ភិក្ខុ បរិព្វជេតិ ។

ឯវំ ភគវា តណ្ហាបហានេន ឯកោ ។

កថំ ភគវា ឯកន្តវីតរាគោតិ ឯកោ ។ រាគស្ស បហីនត្តា ឯកន្តវីតរាគោតិ ឯកោ ។

១ សសេនំ កណ្ហំ ។

ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ដោយសេចក្ដីថាលះបង់តណ្ហា តើដូចម្ដេច ។ ព្រះអង្គតែមួយព្រះអង្គឯង មិនមានបុគ្គលជាគម្រប់ពីរយ៉ាងនេះហើយ ទ្រង់មិនប្រហែស មានព្យាយាមជាគ្រឿងដុតកម្ដៅកិលេស មានព្រះទ័យបញ្ជូនទៅកាន់ព្រះនិព្វាន ទ្រង់តាំងសេចក្ដីព្យាយាមធំ ទៀបគល់ពោធិព្រឹក្ស ក្បែរឆ្នេរស្ទឹងនេរញ្ជរា ទ្រង់កំចាត់បង់មារព្រមទាំងសេនា ដែលជាអ្នកមិនលះបង់អកុសលធម៌ ជាផៅពង្សនៃបុគ្គលប្រហែស ទ្រង់លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាន នូវតណ្ហាមានបណ្ដាញ ដែលហូរទៅ ផ្សាយទៅ ក្នុងអារម្មណ៍ផ្សេង ៗ ។

បុរសដែលមានតណ្ហាជាគម្រប់ពីរ រមែងអន្ទោលទៅកាន់ភាព
នៃប្រការនេះ នឹងភាពនៃប្រការដទៃ អស់កាលដ៏វែង មិន
កន្លងនូវសង្សារបាន ភិក្ខុអ្នកមានស្មារតី មិនមានសេចក្ដី
ប្រកាន់ ប្រាសចាកតណ្ហា ដឹងទោសនេះហើយ តែង
វៀរចេញ នូវការកើតនៃទុក្ខ ព្រោះតណ្ហា ។

ព្រះមានព្រះភាគតែមួយព្រះអង្គឯង ដោយសេចក្ដីថាលះបង់តណ្ហា យ៉ាងនេះ ។

ព្រះមានព្រះភាគតែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ប្រាសចាករាគៈដោយចំណែកមួយ តើដូចម្ដេច ។ ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ប្រាសចាករាគៈដោយចំណែកមួយ ព្រោះទ្រង់លះរាគៈហើយ ។

សោឡសមាណវកបញ្ហានិគមនិទ្ទេសោ

ទោសស្ស បហីនត្តា ឯកន្តវីតទោសោតិ ឯកោ ។

មោហស្ស បហីនត្តា ឯកន្តវីតមោហោតិ ឯកោ ។

កិលេសានំ បហីនត្តា ឯកន្តនិក្កិលេសោតិ ឯកោ ។

កថំ ភគវា ឯកាយនមគ្គំ គតោតិ ឯកោ ។

ឯកាយនមគ្គោ វុច្ចតិ ចត្តារោ សតិបដ្ឋានា ។ បេ ។

អរិយោ អដ្ឋង្គិកោ មគ្គោ ។

ឯកាយនំ ជាតិក្ខយន្តទស្សី

មគ្គំ បជានាតិ ហិតានុកម្បី

ឯតេន មគ្គេន តរឹសុ បុព្វេ

តរិស្សន្តិ ចេវ តរន្តិ ឱឃន្តិ ។

ឯវំ ភគវា ឯកាយនមគ្គំ គតោតិ ឯកោ ។

ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ប្រាសចាកទោសៈ ដោយចំណែកមួយ ព្រោះទ្រង់លះទោសៈហើយ ។ ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ប្រាសចាកមោហៈដោយចំណែកមួយ ព្រោះទ្រង់លះមោហៈហើយ ។ ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់មិនមានកិលេស ដោយចំណែកមួយ ព្រោះទ្រង់លះកិលេសទាំងឡាយហើយ ។

ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ស្តេចទៅកាន់ផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង តើដូចម្តេច ។ សតិប្បដ្ឋាន ៤ ។ បេ ។ មគ្គដ៏ប្រសើរមានអង្គ ៨ លោកហៅថា ផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង ។

> ព្រះពុទ្ធទ្រង់ឃើញ នូវទីបំផុតនៃធម៌ជាទីអស់ជាតិ ទ្រង់អនុ-
> គ្រោះ នូវប្រយោជន៍ ទ្រង់ជ្រាបច្បាស់នូវផ្លូវ ជាទីទៅនៃ
> បុគ្គលម្នាក់ឯង ចំណែកអ្នកប្រាជ្ញទាំងឡាយ ឆ្លងហើយក្នុង
> អតីត នឹងឆ្លងក្នុងអនាគត កំពុងឆ្លងក្នុងបច្ចុប្បន្ន នូវឱឃៈ
> តាមផ្លូវនេះ ។

ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ស្តេចទៅកាន់ផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង យ៉ាងនេះ ។

កថំ ភគវា ឯកោ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោតិ ឯកោ ។ ពោធិ វុច្ចតិ ចតូសុ មគ្គេសុ ញាណំ បញ្ញា បញ្ញិន្ទ្រិយំ បញ្ញាពលំ ។ បេ ។ ធម្មវិចយសម្ពោជ្ឈង្គោ វីមំសា វិបស្សនា សម្មាទិដ្ឋិ ។ ភគវា តេន ពោធិញាណេន សព្វេ សង្ខារា អនិច្ចាតិ ពុជ្ឈិ ។ បេ ។ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ពុជ្ឈិ ។ អថវា យំ ពុជ្ឈិតព្វំ អនុពុជ្ឈិតព្វំ បដិពុជ្ឈិតព្វំ សម្ពុជ្ឈិតព្វំ អធិគន្តព្វំ ផុសិតព្វំ សច្ឆិកាតព្វំ សព្វន្តំ តេន ពោធិញាណេន ពុជ្ឈិ អនុពុជ្ឈិ បដិពុជ្ឈិ សម្ពុជ្ឈិ អធិគច្ឆិ ផុសេសិ សច្ឆាកាសិ ។ ឯវំ ភគវា ឯកោ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោតិ ឯកោ ។

ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ត្រាស់ដឹងសម្មាសម្ពោធិញ្ញាណដ៏ប្រសើរ តែមួយព្រះអង្គ តើដូចម្តេច ។ ញាណ បញ្ញា បញ្ញិន្ទ្រិយ បញ្ញាពលៈ ។ បេ ។ ធម្មវិចយសម្ពោជ្ឈង្គ វីមំសា វិបស្សនា សម្មាទិដ្ឋិ ក្នុងមគ្គ ៤ លោកហៅថា ពោធិ ។ ដោយសារពោធិញ្ញាណនោះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ដឹងថា សង្ខារទាំងពួងមិនទៀង ។ បេ ។ ត្រាស់ដឹងថា របស់ណានីមួយ មានការកើតឡើងជាធម្មតា របស់ទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា ។ ម្យ៉ាងទៀត ធម្មជាតណា ដែលបណ្ឌិត គប្បីដឹង គប្បីត្រាស់ដឹងតាម គប្បីត្រាស់ដឹងចំពោះ គប្បីត្រាស់ដឹងព្រម គប្បីបាន គប្បីពាល់ត្រូវ គប្បីធ្វើឲ្យជាក់ច្បាស់ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដឹង ត្រាស់ដឹងតាម ត្រាស់ដឹងចំពោះ ត្រាស់ដឹងព្រម បានពាល់ត្រូវ ធ្វើឲ្យជាក់ច្បាស់ នូវធម្មជាតទាំងអស់នោះ ដោយសារពោធិញ្ញាណនោះ ។ ព្រះមានព្រះភាគ តែមួយព្រះអង្គឯង ព្រោះហេតុទ្រង់ត្រាស់ដឹងសម្មាសម្ពោធិញ្ញាណដ៏ប្រសើរ តែមួយព្រះអង្គ យ៉ាងនេះ ។

## សោឡសមាណវកបញ្ហានិគមនិទ្ទេសោ

តមនុទោតិ ភគវា រាគតមំ ទោសតមំ មោហតមំ មានតមំ ទិដ្ឋិតមំ កិលេសតមំ ទុច្ចរិតតមំ អន្ធករណំ អចក្ខុករណំ អញ្ញាណករណំ បញ្ញានិរោធិកំ វិឃាតបក្ខិកំ អនិព្វានសំវត្តនិកំ នុទិ បនុទិ បជហិ វិនោទេសិ ព្យន្តីមកាសិ អនភាវង្គមេសិ ។ អាសីនោតិ និសិន្នោ ភគវា បាសាណកេ ចេតិយេតិ អាសីនោ ។

នគស្ស បស្សេ អាសីនំ មុនឹ ទុក្ខស្ស បារគុំ
សាវកា បយិរុបាសន្តិ តេវិជ្ជា មច្ចុហាយិនោតិ ។

ឯវំ ភគវា អាសីនោ ។ អថវា ភគវា សព្វោស្សុក្កប្បដិប្បស្សទ្ធត្តា(១) អាសីនោ សោ វុដ្ឋវាសោ ចិណ្ណចរណោ ។បេ។ ជាតិជរាមរណសំសារោ នត្ថិ តស្ស បុនព្ភវោតិ ឯវម្បិ ភគវា អាសីនោតិ ឯកោ តមនុទាសីនោ ។

---

១ ម. អប្បោស្សុក្កប្បដិប្បស្សទ្ធត្តា ។

# សោឡសមាណវកបញ្ហានិគមនិទ្ទេស

ពាក្យថា ទ្រង់បន្ទោបង់ងងឹត គឺ ព្រះមានព្រះភាគ ទ្រង់បន្ទោបង់ ទំលាក់ចោល លះបង់ បោះបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាន នូវងងឹតគឺរាគៈ ងងឹតគឺទោសៈ ងងឹតគឺមោហៈ ងងឹតគឺមានះ ងងឹតគឺទិដ្ឋិ ងងឹតគឺកិលេស ងងឹតគឺទុច្ចរិត គ្រឿងធ្វើឲ្យងងឹត ធ្វើមិនឲ្យមានចក្ខុ ធ្វើមិនឲ្យមានការដឹង នាំឲ្យរលត់បញ្ញា ជាចំណែកនៃសេចក្ដីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅដើម្បីនិព្វាន ។ ពាក្យថា ទ្រង់គង់នៅជាសុខ គឺ ព្រះមានព្រះភាគ ទ្រង់គង់ជិតបាសាណកចេតិយ ហេតុនោះឈ្មោះថាទ្រង់គង់នៅជាសុខ ។

ពួកសាវ័កដែលបានវិជ្ជា៣ លះបង់នូវមច្ចុ តែងចូលទៅអង្គុយ
ជិតព្រះមុនិ ទ្រង់ដល់ត្រើយនៃទុក្ខ ទ្រង់គង់នៅក្បែរខាងក្នុំ ។

ហេតុនោះ ព្រះមានព្រះភាគ ឈ្មោះថាទ្រង់គង់នៅជាសុខ យ៉ាងនេះ ។ មួយ៉ាងទៀត ព្រះមានព្រះភាគ ទ្រង់គង់នៅជាសុខ ព្រោះព្រះអង្គគ្របសង្កត់សេចក្ដីខ្វល់ខ្វាយទាំងអស់ ព្រះអង្គមានការនៅ (ក្នុងអរិយវាស) នៅរួចហើយ មានចរណៈសន្សំហើយ ។ បេ ។ ភពថ្មី គឺជាតិ ជរា មរណៈ សង្សារ នៃព្រះអង្គមិនមាន ហេតុនោះ ព្រះមានព្រះភាគ ឈ្មោះថាទ្រង់គង់នៅជាសុខ យ៉ាងនេះឯង ហេតុនោះ (លោកពោលថា) តែមួយព្រះអង្គឯង ទ្រង់បន្ទោបង់ងងឹត គង់នៅជាសុខ ។

(១៦៤) ជុតិមា សោ បភង្ករោតិ ជុតិមាតិ ជុតិមា(១) បណ្ឌិតោ បញ្ញវា ពុទ្ធិមា ញាណី វិភាវី មេធាវី ។ បភង្ករោតិ អាលោកករោ ឱភាសករោ ទីបង្ករោ ឧជ្ជោតករោ បជ្ជោតករោតិ ជុតិមា សោ បភង្ករោ ។

(១៦៥) គោតមោ ភូរិបញ្ញាណោតិ គោតមោ ភូរិបញ្ញាណោ ញាណបញ្ញាណោ បញ្ញាធជោ បញ្ញាកេតុ បញ្ញាធិបតេយ្យោ វិចយពហុលោ បវិចយពហុលោ ឱក្ខាយនពហុលោ សមោក្ខាយនធម្មោ វិភូតវិហារី តច្ចរិតោ តព្ពហុលោ តគ្គរុកោ តន្និន្នោ តប្បោណោ តប្បព្ភារោ តទធិមុត្តោ តទាធិបតេយ្យោ ។

ធជោ រថស្ស បញ្ញាណំ ធូមោ បញ្ញាណមគ្គិនោ

រាជា រដ្ឋស្ស បញ្ញាណំ ភត្តា បញ្ញាណមិត្ថិយាតិ ។

---

១ ម. ជុតិមា មតិមា ។

(១៦៨) ពាក្យថា ព្រះគោតមនោះ ទ្រង់មានរស្មីរុងរឿង ទ្រង់ធ្វើពន្លឺ (ដល់លោក) ត្រង់ពាក្យថា ទ្រង់មានរស្មីរុងរឿង គឺ ទ្រង់មានពន្លឺ ជាបណ្ឌិត មានប្រាជ្ញា មានប្រាជ្ញាជាគ្រឿងត្រាស់ដឹង មានញាណ មានប្រាជ្ញាភ្លឺច្បាស់ មានប្រាជ្ញាជាគ្រឿងទំលាយកិលេស ។ ពាក្យថា ទ្រង់ធ្វើពន្លឺ គឺ ទ្រង់ធ្វើឲ្យឃើញច្បាស់ ទ្រង់ធ្វើពន្លឺ ទ្រង់ធ្វើប្រទីប ទ្រង់ធ្វើរស្មី ទ្រង់ធ្វើពន្លឺសព្វ ហេតុនោះ (លោកពោលថា) ព្រះគោតមនោះ ទ្រង់មានរស្មីរុងរឿង ទ្រង់ធ្វើពន្លឺ (ដល់លោក) ។

(១៦៩) ពាក្យថា ព្រះគោតមមានបញ្ញាជាគ្រឿងប្រាកដ គឺ ព្រះគោតម ទ្រង់មានបញ្ញាជាគ្រឿងប្រាកដ មានញាណជាគ្រឿងប្រាកដ មានប្រាជ្ញាជាទង់ជ័យ មានប្រាជ្ញាជាទង់ មានប្រាជ្ញាជាអធិបតី ច្រើនដោយការពិចារណា ច្រើនដោយការពិចារណាសព្វ ច្រើនដោយការប្រមើលមើល មានការប្រមើលមើលជាធម្មតា ជ្រាបច្បាស់ជាប្រក្រតី ប្រព្រឹត្តដោយប្រាជ្ញានោះ ច្រើនដោយប្រាជ្ញានោះ ធ្ងន់ដោយប្រាជ្ញានោះ ទេរទៅរកប្រាជ្ញានោះ ទោរទៅរកប្រាជ្ញានោះ ឈមទៅរកប្រាជ្ញានោះ បង្អោនទៅរកប្រាជ្ញានោះ យកប្រាជ្ញានោះជាអធិបតី ។

រថមានទង់ជាគ្រឿងប្រាកដ ភ្លើងមានផ្សែងជាគ្រឿងប្រាកដ ដែន
មានស្តេចជាគ្រឿងប្រាកដ ស្ត្រីមានភស្តាជាគ្រឿងប្រាកដ ។

## សោឡសមាណវកបញ្ហានិគមនិទ្ទេសោ

ឯវមេវំ គោតមោ ភូរិបញ្ញាណោ ញាណបញ្ញាណោ បញ្ញាធជោ បញ្ញាកេតុ បញ្ញាធិបតេយ្យោ វិចយពហុលោ បវិចយពហុលោ ឱក្ខាយនពហុលោ សមោក្ខាយនធម្មោ វិភូតវិហារី តច្ចរិតោ តព្ពហុលោ តគ្គរុកោ តន្និន្នោ តប្បោណោ តប្បព្ភារោ តទធិមុត្តោ តទាធិបតេយ្យោតិ គោតមោ ភូរិបញ្ញាណោ ។

(១៦៦) គោតមោ ភូរិមេធសោតិ ភូរិ វុច្ចតិ បឋវី ។ បឋវីសមាយ(១) វិបុលាយ វិត្ថតាយ បញ្ញាយ សមន្នាគតោ ។ មេធា វុច្ចតិ បញ្ញា យា បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ។ ភគវា ឥមាយ មេធាយ បញ្ញាយ ឧបេតោ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ(២) សមន្នាគតោ តស្មា ពុទ្ធោ ភូរិមេធសោតិ(៣)

---

១ ម. តាយ បឋវីសមាយ បញ្ញាយ ។ ២ ម. សម្បន្នោ ។ ៣ ម. សុមេធសោតិ ។

ព្រះគោតម ទ្រង់មានប្រាជ្ញាជាគ្រឿងប្រាកដ មានញាណជាគ្រឿងប្រាកដ មានប្រាជ្ញាជាទង់ជ័យ មានប្រាជ្ញាជាទង់ មានប្រាជ្ញាជាអធិបតី ច្រើនដោយការពិចារណា ច្រើនដោយការពិចារណាសព្វ ច្រើនដោយការប្រមើលមើល មានការប្រមើលមើលជាធម្មតា ជ្រាបច្បាស់ជាប្រក្រតី ប្រព្រឹត្តដោយប្រាជ្ញានោះ ច្រើនដោយប្រាជ្ញានោះ ធ្ងន់ដោយប្រាជ្ញានោះ ទេរទៅរកប្រាជ្ញានោះ ទោរទៅរកប្រាជ្ញានោះ ឈមទៅរកប្រាជ្ញានោះ បង្អោនទៅរកប្រាជ្ញានោះ យកប្រាជ្ញានោះជាអធិបតី យ៉ាងនេះឯង ហេតុនោះ (លោកពោលថា) ព្រះគោតមមានប្រាជ្ញាជាគ្រឿងប្រាកដ ។

(១៦៦) ពាក្យថា ព្រះគោតមទ្រង់មានប្រាជ្ញាដូចផែនដី អធិប្បាយថា ប្រថពី លោកហៅថា ផែនដី ។ ព្រះគោតម ទ្រង់ប្រកបដោយប្រាជ្ញាស្មើដោយប្រថពី ដ៏ធំទូលាយ ។ បញ្ញា លោកហៅថាមេធា បានដល់ ប្រាជ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវ ។ ព្រះមានព្រះភាគ ទ្រង់ប្រកប ប្រកបព្រម ចូលទៅជិតដល់ ចូលទៅជិតដល់ព្រម ដល់ស៊ប់ ដល់ស៊ប់ព្រម រួបរួមដោយមេធាគឺប្រាជ្ញានេះ ហេតុនោះព្រះពុទ្ធ ឈ្មោះថាមានប្រាជ្ញាដូចផែនដី

គោតមោ ភូរិមេធសោ ។ តេនាហ បិង្គិយត្ថេរោ

ឯកោ តមនុទាសីនោ ជុតិមា សោ បភង្ករោ

គោតមោ ភូរិបញ្ញាណោ គោតមោ ភូរិមេធសោតិ ។

(១៦៧) យោ មេ ធម្មមទេសេសិ សន្ទិដ្ឋិកមកាលិកំ

តណ្ហក្ខយមនីតិកំ យស្ស នត្ថិ ឧបមា ក្វចិ ។

(១៦៨) យោ មេ ធម្មមទេសេសីតិ យោតិ

យោ សោ ភគវា សយម្ភូ អនាចរិយកោ បុព្វេ

អននុស្សុតេសុ ធម្មេសុ សាមំ សច្ចានិ អភិសម្ពុជ្ឈិ

តត្ថ ច សព្វញ្ញុតំ បត្តោ ពលេសុ ច វសីភាវំ ។

ហេតុនោះ (លោកពោលថា) ព្រះគោតមទ្រង់មានប្រាជ្ញាដូចផែនដី ។ ហេតុនោះ ព្រះបិង្គិយត្ថេរពោលថា

ព្រះគោតមអង្គនោះ តែមួយព្រះអង្គឯង ទ្រង់បន្ទោបង់ងងឹត គង់នៅជាសុខ ទ្រង់មានរស្មីរុងរឿង ធ្វើពន្លឺ (ដល់លោក) ព្រះគោតមមានប្រាជ្ញា ជាគ្រឿងប្រាកដ ព្រះគោតមមានប្រាជ្ញាដូចផែនដី ។

(១៦៧) ព្រះគោតមអង្គណា ទ្រង់សំដែងធម៌ហើយ ដល់ខ្ញុំ ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល ជាគ្រឿងអស់តណ្ហា មិនមានចង្រៃ ដែលជាធម៌មិនមានឧបមា ក្នុងទីណាមួយ ។

(១៦៨) ពាក្យថា ព្រះគោតមអង្គណា ទ្រង់សំដែងធម៌ដល់ខ្ញុំ ត្រង់ពាក្យថា អង្គណា គឺ ព្រះមានព្រះភាគអង្គណា ទ្រង់កើតឯង មិនមានអាចារ្យ ត្រាស់ដឹងសច្ចៈទាំងឡាយដោយព្រះអង្គឯង ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮមកក្នុងកាលមុន ព្រះអង្គទ្រង់ដល់នូវភាពជាសព្វញ្ញូក្នុងសច្ចៈទាំងនោះផង ទ្រង់ដល់នូវភាពជាអ្នកស្ទាត់ក្នុងពលៈទាំងឡាយផង ។

ធម្មមទេសេសីតិ ធម្មន្តិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ សតិប្បដ្ឋានេ(១) ។ បេ ។ អរិយំ អដ្ឋង្គិកំ មគ្គំ និព្វានញ្ច និព្វានគាមិនិញ្ច បដិបទំ អាចិក្ខិ ទេសេសិ បញ្ញបេសិ បដ្ឋបេសិ វិវរិ វិភជិ ឧត្តានីមកាសិ បកាសេសីតិ យោ មេ ធម្មមទេសេសិ ។

(១៦៩) សន្ទិដ្ឋិកមកាលិកន្តិ សន្ទិដ្ឋិកំ អកាលិកំ ឯហិបស្សិកំ ឱបនយិកំ បច្ចត្តំ វេទិតព្វំ វិញ្ញូហីតិ ឯវំ សន្ទិដ្ឋិកមកាលិកំ ។ អថវា យោ ទិដ្ឋេវ ធម្មេ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ តស្ស មគ្គស្ស អនន្តរា សមនន្តរា អធិគច្ចេវ ផលំ វិន្ទតិ បដិលភតីតិ ឯវម្បិ សន្ទិដ្ឋិកមកាលិកំ ។

---

១ ម. បត្តារោ សតិប្បដ្ឋានេ ។

ពាក្យថា ទ្រង់សំដែងនូវធម៌ ត្រង់ពាក្យថា នូវធម៌ គឺ ទ្រង់ប្រាប់ សំដែង បញ្ញត្ត តាំងទុក បើក វែកញែក ធ្វើឲ្យរាក់ ប្រកាស នូវព្រហ្មចរិយធម៌ មានពីរោះបទដើម ពីរោះបទកណ្ដាល ពីរោះបទចុង ព្រមទាំងអត្ថ ទាំងព្យញ្ជនៈ ដ៏ពេញបរិបូណ៌បរិសុទ្ធទាំងអស់ផង សតិប្បដ្ឋានផង ។ បេ ។ អដ្ឋង្គិកមគ្គដ៏ប្រសើរផង និព្វានផង បដិបទាជាដំណើរទៅកាន់ព្រះនិព្វានផង ហេតុនោះ (លោកពោលថា) ព្រះគោតមអង្គណា ទ្រង់សំដែងនូវធម៌ដល់ខ្ញុំ ។

(១៦៩) ពាក្យថា ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល គឺ ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌គួរដល់ឯហិបស្សវិធី គួរបង្អោនមកទុកក្នុងខ្លួន ជាធម៌ដែលវិញ្ញូជនទាំងឡាយ គប្បីដឹងចំពោះខ្លួន ហេតុនោះ (លោកពោលថា) ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល យ៉ាងនេះ ។ មួយទៀត បុគ្គលណា ចម្រើនអដ្ឋង្គិកមគ្គដ៏ប្រសើរក្នុងបច្ចុប្បន្ន បុគ្គលនោះរមែងជួប បាន បានចំពោះ នូវផលក្នុងលំដាប់ លំដាប់ស្មើនៃមគ្គនោះ ហេតុនោះ (លោកពោលថា) ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល យ៉ាងនេះក៏បាន ។

យថា មនុស្សា កាលិកំ ធនំ ទត្វា អនន្តរា ន លភន្តិ កាលំ អាគមេន្តិ នេវាយំ ធម្មោ ។ យោ និដ្ឋេរ ធម្មោ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ តស្ស មគ្គស្ស អនន្តរា សមនន្តរា អធិគច្ឆតេវ ផលំ វិន្ទតិ បដិលភតិ ន បរត្ថ ន បរលោកេ ឯវំ អកាលិកន្តិ សន្ទិដ្ឋិកមកាលិកំ ។

(១៧០) តណ្ហក្ខយមនីតិកន្តិ តណ្ហាតិ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ តណ្ហក្ខយន្តិ តណ្ហក្ខយំ រាគក្ខយំ ទោសក្ខយំ មោហក្ខយំ គតិក្ខយំ ឧបបត្តិក្ខយំ បដិសន្ធិក្ខយំ ភវក្ខយំ សំសារក្ខយំ វដ្ដក្ខយំ ។ អនីតិកន្តិ ឦតិ វុច្ចន្តិ កិលេសា ច ខន្ធា ច អភិសង្ខារា ច ។ ឦតិប្បហានំ ឦតិវូបសមោ ឦតិប្បដិនិស្សគ្គោ ឦតិប្បដិប្បស្សទ្ធិ អមតំ និព្វានន្តិ តណ្ហក្ខយមនីតិកំ ។

មនុស្សទាំងឡាយឲ្យទ្រព្យ ប្រកបដោយកាល មិនបានផលក្នុងលំដាប់ រមែងរង់ចាំកាលយ៉ាងណា ធម៌នេះមិនមែនយ៉ាងនោះទេ ។ បុគ្គលណា បម្រើនអដ្ឋង្គិកមគ្គដ៏ប្រសើរក្នុងបច្ចុប្បន្ន បុគ្គលនោះ រមែងជួប បាន បាន ចំពោះ នូវផលក្នុងលំដាប់ លំដាប់ស្មើនៃមគ្គនោះ មិនមែនបានក្នុងពេលដទៃ មិនមែនបានក្នុងលោកដទៃទេ ជាធម៌ឲ្យផលមិនរង់ចាំកាលយ៉ាងនេះ ហេតុនោះ (លោកពោលថា) ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល ។

[១៧០] ពាក្យថា ជាគ្រឿងអស់តណ្ហា មិនមានចង្រៃ គ្រង់ពាក្យថា តណ្ហា បានដល់រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ពាក្យថា ជាគ្រឿងអស់តណ្ហា គឺ ជាគ្រឿងអស់តណ្ហា អស់រាគៈ អស់ទោសៈ អស់មោហៈ អស់គតិ អស់ឧប-បត្តិ អស់បដិសន្ធិ អស់ភព អស់សង្សារ អស់វដ្ដៈ ។ ពាក្យថា មិនមានចង្រៃ សេចក្ដីថា កិលេស ខន្ធ និងអភិសង្ខារ លោកហៅថា ចង្រៃ ។ ការលះចង្រៃ ការស្ងប់ចង្រៃ ការរលាស់ចោលចង្រៃ ការគ្រប់សង្កត់ចង្រៃ អមតនិព្វាន ហេតុនោះ (លោកពោលថា) ជាគ្រឿងអស់តណ្ហា មិនមានចង្រៃ ។

## សោឡសមាណវកប្បញ្ហានិគមនិទ្ទេសោ

(១៧១) យស្ស នត្ថិ ឧបមា ក្វចីតិ យស្សាតិ និព្ពានស្ស ។ នត្ថិ ឧបមាតិ ឧបមា នត្ថិ ឧបនិធា នត្ថិ សទិសំ នត្ថិ បដិភាគោ នត្ថិ ន សំវិជ្ជតិ នុបលព្ភតិ ។ ក្វចីតិ ក្វចិ កិម្ហិចិ កត្ថចិ អជ្ឈត្តំ វា ពហិទ្ធា វា អជ្ឈត្តពហិទ្ធា វាតិ យស្ស នត្ថិ ឧបមា ក្វចិ ។ តេនាហ បិង្គិយត្ថេរោ

យោ មេ ធម្មមទេសេសិ សន្ទិដ្ឋិកមកាលិកំ
តណ្ហក្ខយមនីតិកំ យស្ស នត្ថិ ឧបមា ក្វចីតិ ។

(១៧២) កិន្នុ តម្ហា វិប្បវសសិ មុហុត្តមបិ បិង្គិយ
គោតមា ភូរិបញ្ញាណា គោតមា ភូរិមេធសា ។

(១៧១) អធិប្បាយពាក្យថា ដែលជាធម៌មិនមានឧបមាក្នុងទីណាមួយ ត្រង់ពាក្យថា ធម៌ បានដល់ និព្វាន ។ ពាក្យថា មិនមានឧបមា គឺ មិនមានការប្រៀប មិនមានសេចក្តីប្រៀបធៀប មិនមានភាពស្មើគ្នា មិនមាន មិនមានព្រម មិនបាន នូវចំណែកប្រៀប ។ ពាក្យថា ក្នុងទីណាមួយ គឺ ក្នុងទីណាមួយ ក្នុងទីណា ៗ ក្នុងទីមួយ ជាខាងក្នុង ឬខាងក្រៅ ឬទាំងខាងក្នុង ទាំងខាងក្រៅ ហេតុនោះ (លោកពោលថា) ដែលជាធម៌មិនមានឧបមាក្នុងទីណាមួយ ។ ហេតុនោះ ព្រះបិង្គិយត្ថេរពោលថា

ព្រះគោតមអង្គណា ទ្រង់សំដែងធម៌ហើយ ដល់ខ្ញុំ ជាធម៌
ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផល មិនរង់ចាំ
កាល ជាគ្រឿងអស់តណ្ហា មិនមានចង្រៃ ដែលជាធម៌
មិនមានឧបមា ក្នុងទីណាមួយ ។

(១៧២) (ពាវរីព្រាហ្មណ៍សួរថា) បពិត្រព្រះបិង្គិយៈ ចុះ
លោកម្ចាស់ ឃ្លាប់ឃ្លាតអំពីព្រះគោតម ទ្រង់មានប្រាជ្ញាជា
គ្រឿងប្រាកដ អំពីព្រះគោតម មានប្រាជ្ញាដូចផែនដីនោះ
សូម្បីមួយរំពេចដែរឬ ។

(១៧៣) កិន្នុ តម្ហា វិប្បវសសីតិ កិន្នុ តម្ហា តុម្ហា វិប្បវសសិ(១) អបេសិ អបគច្ឆសិ វិនា ហោសីតិ កិន្នុ តម្ហា វិប្បវសសិ ។

(១៧៤) មុហុត្តមបិ បិង្គិយាតិ មុហុត្តម្បិ ខណម្បិ លយម្បិ វស្សម្បិ អត្ថម្បីតិ មុហុត្តមបិ(២) ។ បិង្គិយាតិ ពាវរី តំ នត្តារំ នាមេន អាលបតិ(៣) ។

(១៧៥) គោតមា ភូរិបញ្ញាណាតិ គោតមា ភូរិបញ្ញាណា ញាណបញ្ញាណា បញ្ញាធជា បញ្ញាកេតុម្ហា បញ្ញាធិបតេយ្យម្ហា វិចយពហុលា បវិចយពហុលា ឱក្ខាយនពហុលា សមោក្ខាយនធម្មា វិភូតវិហារិម្ហា តច្ចរិតា តព្ពហុលា តគ្គរុកា តន្និន្នា តប្បោណា តប្បព្ភារា តទធិមុត្តា តទាធិបតេយ្យម្ហាតិ គោតមា ភូរិបញ្ញាណា ។

---

១ ម. កិន្នុ តម្ហា វិប្បវសីតិ កិន្នុ តុម្ហា វិប្បវសិ ។ ២ ម. មុហុត្តមបិ សិង្គិយាតិ មុហុត្តំបិ ខណំបិ លយំបិ វយំបិ អទ្ធំបីតិ មុហុត្តមបិ សិង្គិយ ។ ៣ ម. សិង្គិយាតិ ពាវរី តំ នត្តារំ នាមេន អាលបតីតិ នត្ថិ ។

(១៧៣) ពាក្យថា ចុះលោកម្ចាស់ ធ្លាប់ឃ្លាតអំពីព្រះគោតមនោះដែរឬ គឺ ចុះលោកម្ចាស់ ធ្លាប់ឃ្លាតឃ្លា ឃ្លាតចេញ ថយចេញ វៀរចេញ អំពីព្រះពុទ្ធនោះដែរឬ ហេតុនោះ (ព្រាហ្មណ៍ពោលថា) ចុះលោកម្ចាស់ ធ្លាប់ឃ្លាតអំពីព្រះគោតមនោះដែរឬ ។

(១៧៤) ពាក្យថា បពិត្រព្រះបិង្គិយៈ . . . សូម្បីមួយរំពេច គឺ សូម្បីមួយរំពេច មួយខណៈ មួយស្របក់ មួយចំណែក មួយថ្ងៃ ហេតុនោះ (ព្រាហ្មណ៍ពោលថា) សូម្បីមួយរំពេច ។ ពាក្យថា បពិត្រព្រះបិង្គិយៈ គឺ ពាវរីព្រាហ្មណ៍ ហៅចៅនោះដោយនាម ។

(១៧៥) ពាក្យថា អំពីព្រះគោតម ទ្រង់មានប្រាជ្ញាជាគ្រឿងប្រាកដ គឺ អំពីព្រះគោតមទ្រង់មានប្រាជ្ញាជាគ្រឿងប្រាកដ មានញាណជាគ្រឿងប្រាកដ មានប្រាជ្ញាជាទង់ជ័យ មានប្រាជ្ញាជាទង់ យកប្រាជ្ញាជាអធិបតី ច្រើនដោយការពិចារណា ច្រើនដោយការពិចារណាសព្វ ច្រើនដោយការប្រមើលមើល មានការប្រមើលមើលព្រមជាធម្មតា ជ្រាបច្បាស់ជាប្រក្រតី ប្រព្រឹត្តដោយប្រាជ្ញានោះ ច្រើនដោយប្រាជ្ញានោះ ធ្ងន់ដោយប្រាជ្ញានោះ ទេរទៅរកប្រាជ្ញានោះ ទោរទៅរកប្រាជ្ញានោះ ឈមទៅរកប្រាជ្ញានោះ ឱនទៅរកប្រាជ្ញានោះ យកប្រាជ្ញានោះជាអធិបតី ហេតុនោះ (ព្រាហ្មណ៍ពោលថា) អំពីព្រះគោតម ទ្រង់មានប្រាជ្ញាជាគ្រឿងប្រាកដ ។

សោឡសមាណវកបញ្ហានិគមនំទ្វេសោ

(១៧៦) គោតមា ភូរិមេធសាតិ ភូរិ វុច្ចតិ បឋវី ។ ភគវា តាយ បឋវីសមាយ វិបុលាយ វិត្ថតាយ បញ្ញាយ សមន្នាគតោ ។ មេធា វុច្ចតិ បញ្ញា យា បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ។ ភគវា តាយ មេធាយ បញ្ញាយ ឧបេតោ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ តស្មា ពុទ្ធោ ភូរិមេធសោតិ គោតមា ភូរិមេធសា ។ តេនាហ សោ បារី ព្រាហ្មណោ

កិន្នុ តម្ហា វិប្បវសសិ មុហុត្តមបិ បិង្គិយ
គោតមា ភូរិបញ្ញាណា គោតមា ភូរិមេធសាតិ ។

(១៧៧) យោ តេ ធម្មមទេសេសិ សន្ទិដ្ឋិកមកាលិកំ
តណ្ហក្ខយមនីតិកំ យស្ស នត្ថិ ឧបមា ក្វចិ ។

## សោឡសមាណវកបញ្ហានិគមនិទ្ទេស

(១៧៦) ពាក្យថា អំពីព្រះគោតម មានប្រាជ្ញាដូចផែនដី សេចក្ដីថា ប្រថពី លោកហៅថា ផែនដី ។ ព្រះមានព្រះភាគ ទ្រង់ប្រកបដោយប្រាជ្ញា ស្មើដោយផែនដី ដ៏ធំទូលាយនេះ ។ ប្រាជ្ញា លោកហៅថា មេធា បានដល់ ប្រាជ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវ ។ ព្រះមានព្រះភាគ ប្រកប ប្រកបព្រម ចូលទៅជិតដល់ ចូលទៅជិតដល់ព្រម ដល់ស៊ប់ ដល់ស៊ប់ព្រម រួបរួម ដោយមេធាគឺប្រាជ្ញានេះ ហេតុនោះ ព្រះពុទ្ធ ឈ្មោះថាមានប្រាជ្ញាដូចផែនដី ។ ហេតុនោះ (ព្រាហ្មណ៍ពោលថា) អំពីព្រះគោតម មានប្រាជ្ញាដូចផែនដី ។ ហេតុនោះ ពាវរីព្រាហ្មណ៍នោះពោលថា

បពិត្រព្រះបិង្គិយៈ ចុះលោកម្ចាស់ ឃ្លាតអំពីព្រះគោតម
ទ្រង់មានប្រាជ្ញាជាគ្រឿងប្រាកដ អំពីព្រះគោតម មាន
ប្រាជ្ញាដូចផែនដីនោះ សូម្បីមួយរំពេចដែរឬ ។

(១៧៧) ព្រះគោតមអង្គណា ទ្រង់សំដែងធម៌ដល់លោកម្ចាស់
ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់
ចាំកាល ជាគ្រឿងអស់តណ្ហា មិនមានចង្រៃ ដែលជាធម៌មិន
មានឧបមា ក្នុងទីណាមួយ ។

(១៧៨) យោ តេ ធម្មមទេសេសីតិ យោតិ យោ សោ ភគវា ។បេ។ តត្ថ ច សព្វញ្ញុតំ បត្តោ ពលេសុ ច វសីភាវំ ។ ធម្មមទេសេសីតិ ធម្មំ អាទិកល្យាណំ ។បេ។ និព្វានគាមិនិញ្ច បដិបទំ អាចិក្ខិ ទេសេសិ បញ្ញបេសិ បដ្ឋបេសិ វិវរិ វិភជិ ឧត្តានីមកាសិ បកាសេសីតិ យោ តេ ធម្មមទេសេសិ ។

(១៧៩) សន្ទិដ្ឋិកមកាលិកន្តិ សន្ទិដ្ឋិកំ អកាលិកំ ឯហិបស្សិកំ ឱបនយិកំ បច្ចត្តំ វេទិតព្វំ វិញ្ញូហីតិ ឯវំ សន្ទិដ្ឋិកមកាលិកំ ។ អថវា យោ ឥធេវ ធម្មេ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ តស្ស មគ្គស្ស អនន្តរា សមនន្តរា អធិគច្ឆតេវ ផលំ វិន្ទតិ បដិលភតីតិ ឯវម្បិ សន្ទិដ្ឋិកមកាលិកំ(១) ។

---

១ ម. សន្ទិដ្ឋិកំ អកាលិកន្តិ យថា ។

(១៧៨) ត្រង់ពាក្យថា ព្រះគោតមអង្គណា ទ្រង់សំដែងធម៌ដល់លោកម្ចាស់ ត្រង់ពាក្យថា អង្គណា គឺ ព្រះមានព្រះភាគអង្គណា ។ បេ ។ ទ្រង់ដល់នូវភាពជាសព្វញ្ញូ ក្នុងសព្វៈនោះផង នូវភាពជាអ្នកស្ទាត់ក្នុងពលៈទាំងឡាយផង ។ ពាក្យថា ទ្រង់សំដែងធម៌ ត្រង់ពាក្យថា ធម៌ គឺ ទ្រង់ប្រាប់ សំដែង បញ្ញត្ត តាំងទុក បើក វែកញែក ធ្វើឲ្យរាក់ ប្រកាស នូវព្រហ្មចរិយធម៌ មានពីរោះបទដើម ។ បេ ។ នូវបដិបទាជាដំណើរទៅកាន់ព្រះនិព្វានផង ហេតុនោះ (ព្រាហ្មណ៍ពោលថា) ព្រះគោតមអង្គណា ទ្រង់សំដែងធម៌ដល់លោកម្ចាស់ ។

(១៧៩) ពាក្យថា ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល គឺ ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌គួរដល់ឯហិបស្សវិធី គួរបង្អោនមកទុកក្នុងខ្លួន ជាធម៌ដែលវិញ្ញូជនទាំងឡាយគប្បីដឹងចំពោះខ្លួន ហេតុនោះ (ព្រាហ្មណ៍ពោលថា) ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល យ៉ាងនេះ ។ មួយទៀត បុគ្គលណាចម្រើនអដ្ឋង្គិកមគ្គ ដ៏ប្រសើរក្នុងបច្ចុប្បន្ន បុគ្គលនោះ រមែងចួប បាន បានចំពោះនូវផលក្នុងលំដាប់លំដាប់ស្មើនៃមគ្គនោះ ហេតុនោះ ( ព្រាហ្មណ៍ពោលថា ) ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល យ៉ាងនេះក៏បាន ។

យថា មនុស្សា កាលិកំ ធនំ ទត្វា អនន្តរា ន លភន្តិ កាលំ អាគមេន្តិ នេវាយំ ធម្មោ ។ យោ ទិដ្ឋេវ ធម្មេ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ តស្ស មគ្គស្ស អនន្តរា សមនន្តរា អធិគច្ឆតេវ ផលំ វិន្ទតិ បដិលភតិ ន បរត្ថ ន បរលោកេ ឯវំ អកាលិកន្តិ សន្ទិដ្ឋិកមកាលិកំ ។

(១៨០) តណ្ហក្ខយមនីតិកន្តិ តណ្ហាតិ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ តណ្ហក្ខយន្តិ តណ្ហក្ខយំ រាគក្ខយំ ទោសក្ខយំ មោហក្ខយំ គតិក្ខយំ ឧបបត្តិក្ខយំ បដិសន្ធិក្ខយំ ភវក្ខយំ សំសារក្ខយំ វដ្ដក្ខយំ ។ អនីតិកន្តិ ឦតិ វុច្ចន្តិ កិលេសា ច ខន្ធា ច អភិសង្ខារា ច ។ ឦតិប្បហានំ ឦតិវូបសមោ ឦតិប្បដិនិស្សគ្គោ ឦតិប្បដិប្បស្សទ្ធិ អមតំ និព្វានន្តិ តណ្ហក្ខយមនីតិកំ ។

មនុស្សទាំងឡាយឲ្យទ្រព្យ ប្រកបដោយកាល រមែងមិនបានផល ក្នុងលំដាប់ តែងរង់ចាំកាលយ៉ាងណា ធម៌នេះមិនមែនយ៉ាងនោះទេ ។ បុគ្គលណាចម្រើនអដ្ឋង្គិកមគ្គដ៏ប្រសើរក្នុងបច្ចុប្បន្ន បុគ្គលនោះរមែងជួប បាន បានចំពោះនូវផលក្នុងលំដាប់ លំដាប់ស្មើនៃមគ្គនោះ មិនមែនបានក្នុងពេលដទៃ មិនមែនបានក្នុងលោកដទៃទេ ជាធម៌ឲ្យផលមិនរង់ចាំកាលយ៉ាងនេះ ហេតុនោះ (ព្រាហ្មណ៍ពោលថា) ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល ។

(១៨០) ពាក្យថា ជាគ្រឿងអស់តណ្ហា មិនមានចង្រៃ ត្រង់ពាក្យថា តណ្ហា បានដល់រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ពាក្យថា ជាគ្រឿងអស់តណ្ហា គឺ ជាគ្រឿងអស់តណ្ហា អស់រាគៈ អស់ទោសៈ អស់មោហៈ អស់គតិ អស់ឧបបត្តិ អស់បដិសន្ធិ អស់ភព អស់សង្សារ អស់វដ្តៈ ។ ពាក្យថា មិនមានចង្រៃ សេចក្តីថា កិលេស ខន្ធ និងអភិសង្ខារ លោកហៅថាចង្រៃ ។ ការលះចង្រៃ ការស្ងប់ចង្រៃ ការរលាស់ចោលចង្រៃ ការគ្រប់សង្កត់ចង្រៃ អមតនិព្វាន ហេតុនោះ (ព្រាហ្មណ៍ពោលថា) ជាគ្រឿងអស់តណ្ហា មិនមានចង្រៃ ។

(១៨១) យស្ស នត្ថិ ឧបមា ក្វចីតិ យស្សាតិ និព្វានស្ស ។ នត្ថិ ឧបមាតិ ឧបមា នត្ថិ ឧបនិធា នត្ថិ សទិសំ នត្ថិ បដិភាគោ នត្ថិ ន សំវិជ្ជតិ នុបលព្ភតីតិ នត្ថិ ឧបមា ។ ក្វចីតិ ក្វចិ កិម្ហិចិ កត្ថចិ អជ្ឈត្តំ វា ពហិទ្ធា វា អជ្ឈត្តពហិទ្ធា វាតិ យស្ស នត្ថិ ឧបមា ក្វចិ ។ តេនាហ សោ ពាវរី ព្រាហ្មណោ

យោ មេ ធម្មមទេសេសិ សន្ទិដ្ឋិកមកាលិកំ
តណ្ហាក្ខយមនីតិកំ យស្ស នត្ថិ ឧបមា ក្វចីតិ ។

(១៨២) នាហំ តម្ហា វិប្បវសាមិ មុហុត្តមបិ ព្រាហ្មណ
គោតមា ភូរិបញ្ញាណា គោតមា ភូរិមេធសា ។

(១៨១) ពាក្យថា ដែលជាធម៌មិនមានឧបមា ក្នុងទីណាមួយ គឺពាក្យថា ដែលជាធម៌ បានដល់និព្វាន ។ ពាក្យថា មិនមានឧបមា គឺ មិនមានការប្រៀប មិនមានសេចក្តីប្រៀបធៀប មិនមានភាពស្មើគ្នា មិនមានមិនមានព្រម មិនបាននូវចំណែកប្រៀប ហេតុនោះ (ព្រាហ្មណ៍ពោលថា) មិនមានឧបមា ។ ពាក្យថា ក្នុងទីណាមួយ គឺ ក្នុងទីណាមួយ ក្នុងទីណា ៗ ក្នុងទីនីមួយ ជាខាងក្នុង ឬខាងក្រៅ ឬទាំងខាងក្នុងទាំងខាងក្រៅ ហេតុនោះ (ព្រាហ្មណ៍ពោលថា) ដែលជាធម៌មិនមានឧបមា ក្នុងទីណាមួយ ៗ ហេតុនោះ ពាវរីព្រាហ្មណ៍នោះ ពោលថា

ព្រះគោតមអង្គណា ទ្រង់សំដែងធម៌ដល់លោកម្ចាស់ ជា
ធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំ
កាល ជាគ្រឿងអស់តណ្ហា មិនមានចង្រៃ ដែលជាធម៌
មិនមានឧបមា ក្នុងទីណាមួយ ។

(១៨២) (ព្រះបិង្គិយត្ថេរពោលថា) បពិត្រព្រាហ្មណ៍ អាត្មា
មិនឃ្លាតឃ្លាត អំពីព្រះគោតម ទ្រង់មានប្រាជ្ញាជាគ្រឿង
ប្រាកដ អំពីព្រះគោតម មានប្រាជ្ញាដូចផែនដីនោះ សូម្បី
មួយរំពេចទេ ។

## សោឡសមាណវកបញ្ហានិគមនិទ្ទេសោ

(១៨៣) នាហំ តម្ហា វិប្បវសាមីតិ អហំ តម្ហា ពុទ្ធម្ហា ន វិប្បវសាមិ ន អបេមិ ន អបគច្ឆាមិ ន វិនា ហោមីតិ នាហំ តម្ហា វិប្បវសាមិ ។

(១៨៤) មុហុត្តមបិ ព្រាហ្មណាតិ មុហុត្តម្បិ ខណម្បិ លយម្បិ វស្សម្បិ អទ្ធម្បីតិ មុហុត្តមបិ ។ ព្រាហ្មណាតិ គារវេន មាតុលំ អាលបតិ ។

(១៨៥) គោតមា ភូរិបញ្ញាណាតិ គោតមា ភូរិបញ្ញាណា ញាណបញ្ញាណា បញ្ញាធជា បញ្ញាកេតុម្ហា បញ្ញាធិបតេយ្យម្ហា វិចយពហុលា បវិចយពហុលា ឱក្ខាយនពហុលា សមោក្ខាយនធម្មា វិភូតវិហារិម្ហា តច្ចរិតា តព្ពហុលា តគ្គរុកា តន្និន្នា តប្បោណា តប្បព្ភារា តទធិមុត្តា តទាធិបតេយ្យម្ហាតិ គោតមា ភូរិបញ្ញាណា ។

(១៨៣) ពាក្យថា អាត្មាមិនធ្លាប់ឃ្លាតអំពីព្រះគោតមនោះ គឺ អាត្មាមិនធ្លាប់ឃ្លាតឃ្លា មិនគេចចេញ មិនថយចេញ មិនវៀរចេញ ចាកព្រះពុទ្ធនោះទេ ហេតុនោះ (លោកពោលថា) អាត្មាមិនធ្លាប់ឃ្លាតអំពីព្រះគោតមនោះទេ ។

(១៨៤) ពាក្យថា បពិត្រព្រាហ្មណ៍ ... សូម្បីមួយរំពេច គឺ សូម្បីមួយរំពេច មួយខណៈ មួយស្របក់ មួយចំណែក មួយថ្ងៃ ហេតុនោះ (លោកពោលថា) សូម្បីមួយរំពេច ។ ពាក្យថា បពិត្រព្រាហ្មណ៍ គឺ ព្រះបិង្គិយត្ថេរ ហៅឪពុកធំដោយគោរព ។

(១៨៥) ពាក្យថា អំពីព្រះគោតម ទ្រង់មានប្រាជ្ញាជាគ្រឿងប្រាកដ គឺ អំពីព្រះគោតម ទ្រង់មានប្រាជ្ញាជាគ្រឿងប្រាកដ មានញាណជាគ្រឿងប្រាកដ មានប្រាជ្ញាជាទង់ជ័យ មានប្រាជ្ញាជាទង់ យកប្រាជ្ញាជាអធិបតី ច្រើនដោយការពិចារណា ច្រើនដោយការពិចារណាសព្វ ច្រើនដោយការប្រមើលមើល មានការប្រមើលមើលព្រមជាធម្មតា ជ្រាបច្បាស់ជាប្រក្រតី ប្រព្រឹត្តដោយប្រាជ្ញានោះ ច្រើនដោយប្រាជ្ញានោះ ធ្ងន់ដោយប្រាជ្ញានោះ ទេរទៅរកប្រាជ្ញានោះ ទោរទៅរកប្រាជ្ញានោះ ឈមទៅរកប្រាជ្ញានោះ បង្អោនទៅរកប្រាជ្ញានោះ យកជ្រាជ្ញានោះជាអធិបតី ហេតុនោះ (លោកពោលថា) អំពីព្រះគោតម ទ្រង់មានប្រាជ្ញាជាគ្រឿងប្រាកដ ។

(១៨៦) គោតមា ភូរិមេធសាតិ ភូរិ វុច្ចតិ បឋវី ។ ភគវា ឥមាយ បឋវីសមាយ វិបុលាយ វិត្ថតាយ បញ្ញាយ សមន្នាគតោ ។ មេធា វុច្ចតិ បញ្ញា យា បញ្ញា បជាននា ។បេ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ។ ភគវា ឥមាយ មេធាយ បញ្ញាយ ឧបេតោ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ តស្មា ពុទ្ធោ ភូរិមេធសោតិ គោតមា ភូរិមេធសា ។ តេនាហ បិង្គិយត្ថេរោ

នាហំ តម្ហា វិប្បវសាមិ មុហុត្តមបិ ព្រាហ្មណ
គោតមា ភូរិបញ្ញាណា គោតមា ភូរិមេធសា ។

(១៨៧) យោ មេ ធម្មមទេសេសិ សន្ទិដ្ឋិកមកាលិកំ
តណ្ហក្ខយមនីតិកំ យស្ស នត្ថិ ឧបមា ក្វចិ ។

(១៨៦) ពាក្យថា អំពីព្រះគោតម មានប្រាជ្ញាដូចផែនដី សេចក្តីថា ប្រថពី លោកហៅថា ផែនដី ។ ព្រះមានព្រះភាគ ទ្រង់ប្រកបដោយប្រាជ្ញាស្មើដោយផែនដី ដ៏ធំទូលាយនេះ ។ ប្រាជ្ញា លោកហៅថា មេធា បានដល់ប្រាជ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវ ។ ព្រះមានព្រះភាគទ្រង់ប្រកប ប្រកបព្រម ចូលទៅជិតដល់ ចូលទៅជិតដល់ព្រម ដល់ស៊ប់ ដល់ស៊ប់ព្រម រួបរួម ដោយមេធា គឺប្រាជ្ញានេះ ហេតុនោះ ព្រះពុទ្ធ ឈ្មោះថាមានប្រាជ្ញាដូចផែនដី ហេតុនោះ (លោកពោលថា) អំពីព្រះគោតម មានប្រាជ្ញាដូចផែនដី ។ ហេតុនោះ ព្រះបិង្គិយត្ថេរពោលថា

បពិត្រព្រាហ្មណ៍ អាត្មាមិនធ្លាប់ឃ្លាតអំពីព្រះគោតម ទ្រង់មាន
ប្រាជ្ញាជាគ្រឿងប្រាកដ អំពីព្រះគោតម មានប្រាជ្ញាដូចផែន
ដីនោះ សូម្បីមួយរំពេចទេ ។

(១៨៧) ព្រះគោតម អង្គណា ទ្រង់សំដែងធម៌ដល់អាត្មា ជា
ធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំ
កាល ជាគ្រឿងអស់តណ្ហា មិនមានចង្រៃ ដែលជាធម៌
**មិនមានឧបមា ក្នុងទីណាមួយ ។**

## សោឡសមាណវកបញ្ហានិគមនិទ្ទេសោ

(១៨៨) យោ មេ ធម្មមទេសេសីតិ យោតិ យោ សោ ភគវា សយម្ភូ អនាចរិយកោ បុព្វេ អននុស្សុតេសុ ធម្មេសុ សាមំ សច្ចានិ អភិសម្ពុជ្ឈិ តត្ថ ច សព្វញ្ញុតំ បត្តោ ពលេសុ ច វសីភាវំ ។ ធម្មមទេសេសីតិ ធម្មន្តិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ ចត្តារោ សតិបដ្ឋានេ ចត្តារោ សម្មប្បធានេ ចត្តារោ ឥទ្ធិបាទេ បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គេ អរិយំ អដ្ឋង្គិកំ មគ្គំ និព្វានញ្ច និព្វានគាមិនិញ្ច បដិបទំ អាចិក្ខិ ទេសេសិ បញ្ញបេសិ បដ្ឋបេសិ វិវរិ វិភជិ ឧត្តានីមកាសិ បកាសេសីតិ យោ មេ ធម្មមទេសេសិ ។

(១៨៩) សន្ទិដ្ឋិកមកាលិកន្តិ សន្ទិដ្ឋិកំ អកាលិកំ ឯហិបស្សិកំ ឱបនយិកំ បច្ចត្តំ វេទិតព្វំ វិញ្ញូហីតិ ឯវំ សន្ទិដ្ឋិកមកាលិកំ ។

## សោឡសមាណវកបញ្ហានិគមនិទ្ទេស

(១៨៨) ពាក្យថា ព្រះគោតមអង្គណា ទ្រង់សំដែងធម៌ដល់អាត្មា ត្រង់ពាក្យថា អង្គណា គឺ ព្រះមានព្រះភាគអង្គណា ទ្រង់កើតឯង មិនមានអាចារ្យ ត្រាស់ដឹងសច្ចៈទាំងឡាយដោយព្រះអង្គឯង ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮមកក្នុងកាលមុនផង ទ្រង់ដល់នូវភាពជាសព្វញ្ញូក្នុងសច្ចៈទាំងនោះផង ទ្រង់ដល់នូវភាពជាអ្នកស្ទាត់ក្នុងពលៈទាំងឡាយផង ។ ពាក្យថា ទ្រង់សំដែងធម៌ ត្រង់ពាក្យថា ធម៌ គឺទ្រង់ប្រាប់ សំដែង បញ្ញត្ត តាំងទុក បើក វែកញែក ធ្វើឲ្យរាក់ ប្រកាសនូវព្រហ្មចរិយធម៌ មានពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ព្រមទាំងអត្ថទាំងព្យញ្ជនៈ ដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ នូវសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អដ្ឋង្គិកមគ្គដ៏ប្រសើរ និព្វាន និងបដិបទាជាដំណើរទៅកាន់ព្រះនិព្វាន ហេតុនោះ (លោកពោលថា) ព្រះគោតមអង្គណា ទ្រង់សំដែងធម៌ដល់អាត្មា ។

(១៨៩) ពាក្យថា ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល គឺ ជាធម៌ដែលបុគ្គលគប្បីឃើញច្បាស់ចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌គួរដល់ឯហិបស្សវិធី គួរបង្អោនមកទុកក្នុងខ្លួន ជាធម៌ដែលវិញ្ញូជនគប្បីដឹងចំពោះខ្លួន ហេតុនោះ (លោកពោលថា) ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល យ៉ាងនេះ ។

អថវា យោ ឥធេវ ធម្មំ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ តស្ស មគ្គស្ស អនន្តរា សមនន្តរា អធិគតោវ ផលំ វិន្ទតិ បដិលភតីតិ ឯវម្បិ សន្ទិដ្ឋិកមកាលិកំ ។ យថា មនុស្សា កាលិកំ ធនំ ទត្វា អនន្តរា ន លភន្តិ កាលំ អាគមេន្តិ នេវាយំ ធម្មោ ។ យោ ឥធេវ ធម្មំ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេតិ តស្ស មគ្គស្ស អនន្តរា សមនន្តរា អធិគតោវ ផលំ វិន្ទតិ បដិលភតិ ន បរត្ថ ន បរលោកេ ឯវំ អកាលិកន្តិ សន្ទិដ្ឋិកមកាលិកំ ។

(១៩០) តណ្ហាក្ខយមនីតិកន្តិ តណ្ហាតិ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ តណ្ហាក្ខយន្តិ តណ្ហាក្ខយំ រាគក្ខយំ ទោសក្ខយំ មោហក្ខយំ គតិក្ខយំ ឧបបត្តិក្ខយំ បដិសន្ធិក្ខយំ ភវក្ខយំ សំសារក្ខយំ វដ្ដក្ខយំ ។

មួយទៀត បុគ្គលណាចម្រើនអដ្ឋង្គិកមគ្គដ៏ប្រសើរក្នុងបច្ចុប្បន្ន បុគ្គលនោះរមែងចូប បាន បានចំពោះនូវផលក្នុងលំដាប់ លំដាប់ស្មើ នៃមគ្គនោះ ហេតុនោះ (លោកពោលថា) ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល យ៉ាងនេះក៏បាន ។ មនុស្សទាំងឡាយឲ្យទ្រព្យ ប្រកបដោយកាល មិនបានផលក្នុងលំដាប់ រមែងរង់ចាំកាលយ៉ាងណា ធម៌នេះ មិនមែនយ៉ាងនោះទេ បុគ្គលណាចម្រើនអដ្ឋង្គិកមគ្គដ៏ប្រសើរ ក្នុងបច្ចុប្បន្ន បុគ្គលនោះ រមែងចូប បាន បានចំពោះនូវផលក្នុងលំដាប់ លំដាប់ស្មើនៃមគ្គនោះ មិនមែនបានក្នុងពេលដទៃ មិនមែនបានក្នុងលោកដទៃទេ ជាធម៌ឲ្យផលមិនរង់ចាំកាល យ៉ាងនេះ ហេតុនោះ (លោកពោលថា) ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល ។

(១៩០) អធិប្បាយពាក្យថា ជាគ្រឿងអស់តណ្ហា មិនមានចង្រៃ ត្រង់ពាក្យថា តណ្ហា បានដល់ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ពាក្យថា ជាគ្រឿងអស់តណ្ហា គឺ ជាគ្រឿងអស់ចំណង់ អស់រាគៈ អស់ទោសៈ អស់មោហៈ អស់គតិ អស់ឧបបត្តិ អស់បដិសន្ធិ អស់ភព អស់សង្សារ អស់វដ្តៈ ។

អនីតិកន្តិ ឦតិយោ វុច្ចន្តិ កិលេសា ច ខន្ធា ច អភិ- សង្ខារា ច ។ ឦតិប្បហានំ ឦតិវូបសមំ ឦតិ- ប្បដិនិស្សគ្គំ ឦតិប្បដិប្បស្សទ្ធិំ អមតំ និព្វានន្តិ តណ្ហាក្ខយមនីតិកំ ។

(១៩១) យស្ស នត្ថិ ឧបមា ក្វចីតិ យស្សាតិ និព្វានស្ស ។ នត្ថិ ឧបមាតិ ឧបមា នត្ថិ ឧបនិធា នត្ថិ សទិសំ នត្ថិ បដិភាគោ នត្ថិ ន សំវិជ្ជតិ នុប- លព្ភតីតិ នត្ថិ ឧបមា ។ ក្វចីតិ ក្វចិ កិម្ហិចិ កត្ថចិ អជ្ឈត្តំ វា ពហិទ្ធា វា អជ្ឈត្តពហិទ្ធា វាតិ យស្ស នត្ថិ ឧបមា ក្វចិ ។ តេនាហ បិង្គិយត្ថេរោ

យោ មេ ធម្មមទេសេសិ សន្ទិដ្ឋិកមកាលិកំ
តណ្ហាក្ខយមនីតិកំ យស្ស នត្ថិ ឧបមា ក្វចីតិ ។

ពាក្យថា មិនមានចំណង់ សេចក្ដីថា កិលេស ១៦ នឹងអភិសង្ខារ លោកហៅថា ចំណង់ ៗ ការលះចំណង់ ការស្ងប់ចំណង់ ការរលាស់ចោលចំណង់ ការគ្រប់សង្កត់ចំណង់ អមតនិព្វាន ហេតុនោះ (លោកពោលថា) ជាគ្រឿងអស់តណ្ហា មិនមានចំណង់ ៗ

(១៩១) ពាក្យថា ដែលជាធម៌មិនមានឧបមា ក្នុងទីណាមួយ គ្រង់ពាក្យថា ដែលជាធម៌ បានដល់និព្វាន ៗ ពាក្យថា មិនមានឧបមា គឺមិនមានការប្រៀបផ្ទឹម មិនមានសេចក្ដីប្រៀបធៀប មិនមានភាពស្មើគ្នា មិនមាន មិនមានព្រម មិនបាន នូវចំណែកប្រៀប ហេតុនោះ (លោកពោលថា) មិនមានឧបមា ៗ ពាក្យថា ក្នុងទីណាមួយ គឺ ក្នុងទីណាមួយ ក្នុងទីណា ៗ ក្នុងទីនីមួយ ជាខាងក្នុង ឬខាងក្រៅ ឬទាំងខាងក្នុងទាំងខាងក្រៅ ហេតុនោះ (លោកពោលថា) ដែលជាធម៌មិនមានឧបមា ក្នុងទីណាមួយ ៗ ហេតុនោះ ព្រះបិង្គិយត្ថេរពោលថា

> ព្រះគោតមអង្គណា ទ្រង់សំដែងធម៌ដល់អាត្មា ជាធម៌ដែលបុគ្គលគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផល មិនរង់ចាំកាល ជាគ្រឿងអស់តណ្ហា មិនមានចំណង់ ដែលជាធម៌មិនមានឧបមា ក្នុងទីណាមួយ ៗ

[១៩២] បស្សាមិ នំ មនសា ចក្ខុនា វ
រត្តិន្ទិវំ ព្រាហ្មណ អប្បមត្តោ
នមស្សមានោ វិវសាមិ(១) រត្តឹ
តេនេវ មញ្ញាមិ អវិប្បវាសំ ។

[១៩៣] បស្សាមិ នំ មនសា ចក្ខុនា វាតិ យថា ចក្ខុមា បុរិសោ អាលោកេយ្យ រូបគតានិ បស្សេយ្យ ទក្ខេយ្យ ឱលោកេយ្យ និជ្ឈាយេយ្យ ឧបបរិក្ខេយ្យ ឯវមេវាហំ ពុទ្ធំ ភគវន្តំ មនសា បស្សាមិ ទក្ខាមិ ឱលោកេមិ និជ្ឈាយាមិ ឧប-បរិក្ខាមីតិ បស្សាមិ នំ មនសា ចក្ខុនា វ ។

[១៩៤] រត្តិន្ទិវំ ព្រាហ្មណ អប្បមត្តោតិ រត្តិញ្ច ទិវា ច មនសា(២) ភាវេន្តោ អប្បមត្តោតិ រត្តិន្ទិវំ ព្រាហ្មណ អប្បមត្តោ ។

---

១ ម. វិវសេមិ ។ ២ ម. ពុទ្ធានុស្សតឹ ។

(១៩២) បតិត្រព្រាហ្មណ៍ អាត្មាជាអ្នកមិនប្រហែស តែងឃើញព្រះពុទ្ធនោះ ដោយចិត្ត ហាក់ដូចឃើញដោយភ្នែក ទាំងយប់ទាំងថ្ងៃ អាត្មាតែងនមស្ការ នៅរហូតយប់នឹងថ្ងៃ ទើបអាត្មាសំគាល់ថា ការមិនឃ្លាត ដោយហេតុនោះឯង ។

(១៩៣) ពាក្យថា អាត្មាតែងឃើញព្រះពុទ្ធនោះដោយចិត្ត ហាក់ដូចឃើញដោយភ្នែក គឺ បុរសមានភ្នែកគប្បីមើលមើល គប្បីឃើញ គប្បីចួប គប្បីគន់មើល គប្បីសំឡឹងមើល គប្បីពិចារណាមើល នូវរូបទាំងឡាយ យ៉ាងណា អាត្មាតែងឃើញ ចួប គន់មើល សំឡឹងមើល ពិចារណាមើល នូវព្រះពុទ្ធមានព្រះភាគ ដោយចិត្ត ក៏យ៉ាងនោះដែរ ហេតុនោះ (លោកពោលថា) អាត្មាតែងឃើញព្រះពុទ្ធនោះ ដោយចិត្ត ហាក់ដូចឃើញដោយភ្នែក ។

(១៩៤) ពាក្យថា បតិត្រព្រាហ្មណ៍ អាត្មាជាអ្នកមិនប្រហែសទាំងយប់ទាំងថ្ងៃ គឺ អាត្មាចំរើនដោយចិត្ត ទាំងយប់ទាំងថ្ងៃ ឈ្មោះថាជាអ្នកមិនប្រហែស ហេតុនោះ (លោកពោលថា) បតិត្រព្រាហ្មណ៍ អាត្មាជាអ្នកមិនប្រហែស ទាំងយប់ទាំងថ្ងៃ ។

សោឡសមាណវកបញ្ហានិគមនិទ្ទេសោ

(១៩៥) នមស្សមានោ វិវសាមិ រត្តិន្តិ នមស្ស-មានោតិ កាយេន វា នមស្សមានោ វាចាយ វា នមស្សមានោ ចិត្តេន វា នមស្សមានោ អន្វត្ថប្ប-ដិបត្តិយា វា នមស្សមានោ ធម្មានុធម្មប្បដិបត្តិយា វា នមស្សមានោ សក្ការមានោ គរុការមានោ មានយមានោ បូជយមានោ រត្តិន្ទិវំ វសាមិ វីតិនា-មេមីតិ នមស្សមានោ វិវសាមិ រត្តឹ ។

(១៩៦) តេនេវ មញ្ញាមិ អវិប្បវាសន្តិ តាយ ពុទ្ធានុស្សតិយា ភាវេន្តោ អវិប្បវាសោតិ តំ មញ្ញាមិ អវិប្បវុត្ថោតិ តំ មញ្ញាមិ ជានាមិ ឯវំ អាជានាមិ ឯវំ វិជានាមិ ឯវំ បដិវិជានាមីតិ(១) តេនេវ មញ្ញាមិ អវិប្បវាសំ ។ តេនាហ បិង្គិយត្ថេរោ

បស្សាមិ នំ មនសា ចក្ខុនា វា
រត្តិន្ទិវំ ព្រាហ្មណ អប្បមត្តោ
នមស្សមានោ វិវសាមិ រត្តឹ
តេនេវ មញ្ញាមិ អវិប្បវាសន្តិ ។

១ ម. បដិវិជ្ឈាមីតិ ។

## សោឡសមាណវកបញ្ហានិគមនិទ្ទេស

(១៩៥) ពាក្យថា អាត្មាតែងនមស្ការនៅរហូតយប់នឹងថ្ងៃ ត្រង់ពាក្យថា នមស្ការ គឺ នមស្ការដោយកាយក្តី នមស្ការដោយវាចាក្តី នមស្ការដោយចិត្តក្តី នមស្ការដោយការប្រតិបត្តិ ទៅតាមប្រយោជន៍ក្តី នមស្ការ ធ្វើសក្ការៈ ធ្វើសេចក្តីគោរពរាប់អាន បូជា ដោយការប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ក្តី នៅរហូតយប់នឹងថ្ងៃ គឺ ញុំាងយប់នឹងថ្ងៃឲ្យប្រព្រឹត្តកន្លងទៅ ហេតុនោះ (លោកពោលថា) អាត្មាតែងនមស្ការនៅរហូតយប់នឹងថ្ងៃ ។

(១៩៦) ពាក្យថា ទើបអាត្មាសំគាល់ថា ការមិនឃ្លាតដោយហេតុនោះឯង គឺ អាត្មាកាលអប់រំដោយពុទ្ធានុស្សតិនោះ ទើបសំគាល់នូវអំពើនោះថា ជាការមិនឃ្លាត សំគាល់ គឺដឹង ដឹងយ៉ាងនេះ យល់យ៉ាងនេះ ដឹងច្បាស់យ៉ាងនេះ ដឹងចំពោះយ៉ាងនេះ នូវព្រះពុទ្ធនោះថា ព្រះអង្គមិនធ្លាប់ឃ្លាត ហេតុនោះ (លោកពោលថា) ទើបអាត្មាសំគាល់ថា ការមិនឃ្លាត ដោយហេតុនោះឯង ។ ហេតុនោះ ព្រះបិង្គិយត្ថេរពោលថា

បពិត្រព្រាហ្មណ៍ អាត្មាជាអ្នកមិនប្រហែស តែងឃើញព្រះពុទ្ធ
នោះ ដោយចិត្ត ហាក់ដូចឃើញដោយភ្នែក ទាំងយប់
ទាំងថ្ងៃ អាត្មាតែងនមស្ការ នៅរហូតយប់នឹងថ្ងៃ ទើប
អាត្មាសំគាល់ថាការមិនឃ្លាត ដោយហេតុនោះឯង ។

(១៩៧) សទ្ធា ច បីតិ ច មនោ សតិ ច

នាមេន្តិមេ(១) គោតមសាសនម្ហា

យំ យំ ទិសំ វជតិ ភូរិបញ្ញោ

ស តេន តេនេវ នតោហមស្មិ ។

(១៩៨) សទ្ធា ច បីតិ ច មនោ សតិ ចាតិ សទ្ធាតិ យា ច ភគវន្តំ អារព្ភ សទ្ធា សទ្ទហនា ឱកប្បនា អភិប្បសាទោ សទ្ធា សទ្ធិន្ទ្រិយំ សទ្ធាពលំ ។ បីតីតិ យា ច ភគវន្តំ អារព្ភ បីតិ បាមុជ្ជំ មោទនា បមោទនា វិត្តិ ឱទគ្យំ អត្តមនតា អភិប្បសាទនតា ចិត្តស្ស(២) ។ មនោតិ យញ្ច ភគវន្តំ អារព្ភ ចិត្តំ មនោ មានសំ ហទយំ បណ្ឌរំ មនោ មនាយតនំ មនិន្ទ្រិយំ វិញ្ញាណំ វិញ្ញាណក្ខន្ធោ តជ្ជា មនោវិញ្ញាណធាតុ ។ សតីតិ យា ច ភគវន្តំ អារព្ភ សតិ អនុស្សតិ ។បេ។ សម្មាសតីតិ សទ្ធា ច បីតិ ច មនោ សតិ ច ។

---

១ ម. នាមេន្តិមេ ។ ២ ម. មោទនា អាមោទនា បមោទនា ហាសោ បហាសោ វិត្តិ តុដ្ឋិ ឱទគ្យំ អត្តមនតា ចិត្តស្ស ។

(១៩៧) ធម៌ទាំង ៤ នេះ គឺ សទ្ធា បីតិ មនោ និងសតិ (របស់អាត្មា) តែងមិនឃ្លាតចាកសាសនារបស់ព្រះគោតម ឡើយ ព្រះគោតម ទ្រង់មានប្រាជ្ញាដូចផែនដី ស្តេចទៅកាន់ទិសណា ៗ អាត្មានោះ ក៏ជាអ្នកឱនទៅរកទិសនោះ ៗ ។

(១៩៨) អធិប្បាយពាក្យថា សទ្ធា បីតិ មនោ និងសតិ ត្រង់ពាក្យថា សទ្ធា បានដល់ ជំនឿ ការជឿ ការចុះចិត្ត សេចក្តីជ្រះថ្លាខ្លាំង សទ្ធា សទ្ធិន្ទ្រិយ សទ្ធាពលៈ ប្រារព្ធព្រះមានព្រះភាគ ។ ពាក្យថា បីតិ បានដល់ ការឆ្អែត បាមោជ្ជៈ ការរីករាយ ការរីករាយចំពោះ ការត្រេកអរ ការត្រេកអរសើប ភាពនៃចិត្តរបស់ខ្លួន ភាពនៃចិត្តជ្រះថ្លាក្រៃពេក ប្រារព្ធព្រះមានព្រះភាគ ។ ពាក្យថា មនោ បានដល់ចិត្ត ធម្មជាតសម្រាប់បង្អោនទៅ សេចក្តីប្រាថ្នាក្នុងចិត្ត ហឫទ័យ បណ្ឌរៈ មនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណ-ធាតុ ដែលកើតអំពីវិញ្ញាណក្ខន្ធនោះ ប្រារព្ធព្រះមានព្រះភាគ ។ ពាក្យថា សតិ បានដល់ស្មារតី ការរឭករឿយ ៗ ។ បេ ។ ការរឭកត្រូវ ប្រារព្ធព្រះមានព្រះភាគ ហេតុនោះ (លោកពោលថា) សទ្ធា បីតិ មនោនិងសតិ ។

សោឡសមាណវកបញ្ហានិគមនិទ្ទេសោ

[១៩៩] នាមេន្តិ មេ គោតមសាសនម្ហាតិ ឥមេ ចត្តារោ ធម្មា គោតមសាសនា ពុទ្ធសាសនា ជិនសាសនា តថាគតសាសនា អរហន្តសាសនា នាមេន្តិ នាគច្ឆន្តិ ន វិជហន្តិ ន វិនាសេន្តីតិ នាមេន្តិ មេ គោតមសាសនម្ហា ។

[២០០] យំ យំ ទិសំ វជ្ជតិ ភូរិបញ្ញោតិ យំ យំ ទិសន្តិ បុរត្ថិមំ វា ទិសំ បច្ឆិមំ វា ទិសំ ទក្ខិណំ វា ទិសំ ឧត្តរំ វា ទិសំ វជតិ គច្ឆតិ កមតិ អតិក្កមតិ ។ ភូរិបញ្ញោតិ ភូរិបញ្ញោ មហាបញ្ញោ តិក្ខបញ្ញោ បុថុបញ្ញោ ហាសបញ្ញោ ជវនបញ្ញោ និព្វេធិកបញ្ញោតិ(១) យំ យំ ទិសំ វជ្ជតិ ភូរិបញ្ញោ ។

[២០១] ស តេន តេនេវ នតោ ហមស្មីតិ សោ យេន ពុទ្ធោ តេន តេនេវ នតោ

---

១ ម. និព្វេធិកបញ្ញោ ភូរិ វុច្ចតិ បឋវី តាយ បឋវីសមាយ បញ្ញាយ វិបុលាយ វិត្ថតាយ សមន្នាគតោតិ ទិស្សន្តិ ។

សេចក្ដីសម្រាយសេចក្ដីអធិប្បាយ

(១៩៩) ពាក្យថា ធម៌ទាំង ៤ នេះ តែងមិនឃ្លាតចាកសាសនា របស់ព្រះគោតម គឺ ធម៌ទាំង ៤ នេះ តែងមិនប្រាសចេញ មិនមក មិនលះបង់ មិនវិនាស ចាកសាសនាព្រះគោតម ចាកសាសនាព្រះពុទ្ធ ចាកសាសនាព្រះជិនស្រី ចាកសាសនាព្រះតថាគត ចាកសាសនាព្រះអរហន្ត ហេតុនោះ (លោកពោលថា) ធម៌ទាំង ៤ នេះ តែងមិនប្រាសចាកសាសនា របស់ព្រះគោតម ។

(២០០) ពាក្យថា ទ្រង់មានប្រាជ្ញាដូចផែនដី ស្ដេចទៅកាន់ទិសណា ៗ ត្រង់ពាក្យថា ទិសណា ៗ គឺ ទ្រង់ទៅ ដល់ ឈាន ឈានកន្លង ទៅកាន់ទិសខាងកើតក្ដី ទិសខាងលិចក្ដី ទិសខាងត្បូងក្ដី ទិសខាងជើងក្ដី ។ ពាក្យថា មានប្រាជ្ញាដូចផែនដី គឺ ទ្រង់មានប្រាជ្ញាដូចប្រឹថពី មានប្រាជ្ញាច្រើន មានប្រាជ្ញាមុត មានប្រាជ្ញាក្រាស់ មានប្រាជ្ញារីករាយ មានប្រាជ្ញារហ័ស មានប្រាជ្ញាផូរផង់ ហេតុនោះ (លោកពោលថា) ទ្រង់មានប្រាជ្ញាដូចផែនដី ស្ដេចទៅកាន់ទិសណា ៗ ។

(២០១) ពាក្យថា អាត្មានោះ ជាអ្នកឱនទៅរកទិសនោះ ៗ គឺព្រះពុទ្ធទ្រង់គង់នៅ ក្នុងទិសណា អាត្មានោះ ជាអ្នកឱនទៅរកទិសនោះ

តន្និន្នោ តប្បោណោ តប្បព្ភារោ តទធិមុត្តោ តទា-ធិបតេយ្យោតិ ស តេន តេនេវ នតោហមស្មិ ។ តេនាហ បិង្គិយត្ថេរោ

សទ្ធា ច បីតិ ច មនោ សតិ ច
នាបេន្តិ មេ គោតមសាសនម្ហា
យំ យំ ទិសំ វជតិ ភូរិបញ្ញោ
ស តេន តេនេវ នតោហមស្មីតិ ។

[២០២] ជិណ្ណស្ស មេ ទុព្ពលថាមកស្ស
តេនេវ កាយោ ន បលេតិ តត្ថ
សង្កប្បយន្តាយ វជាមិ និច្ចំ
មនោ ហិ មេ ព្រាហ្មណ តេន យុត្តោ ។

[២០៣] ជិណ្ណស្ស មេ ទុព្ពលថាមកស្សាតិ ជិណ្ណស្សាតិ ជិណ្ណស្ស វុឌ្ឍស្ស មហល្លកស្ស អទ្ធគតស្ស វយោអនុប្បត្តស្សាតិ ជិណ្ណស្ស ។ ទុព្ពលថាមកស្សាតិ ទុព្ពលថាមកស្ស អប្បថាមកស្ស បរិត្តថាមកស្សាតិ ជិណ្ណស្ស មេ ទុព្ពលថាមកស្ស ។

ទេរទៅរកទិសនោះ ទោរទៅរកទិសនោះ ឈមទៅរកទិសនោះ បង្អោន ទៅរកទិសនោះ យកទិសនោះជាអធិបតី ហេតុនោះ (លោកពោលថា) អាត្មានោះ ជាអ្នកឱនទៅរកទិសនោះៗ ។ ហេតុនោះ ព្រះបរិង្គិយ-ត្ថេរពោលថា

ធម៌ទាំង ៤ នេះ គឺ សទ្ធា បីតិ មនោ និងសតិ (របស់អាត្មា) តែងមិនឃ្លាតចាកសាសនា របស់ព្រះគោតមឡើយ ព្រះគោតម ទ្រង់មានប្រាជ្ញាដូចផែនដី ស្តេចទៅកាន់ទិសណា ៗ អាត្មានោះ ក៏ជាអ្នកឱនទៅរកទិសនោះ ៗ ។

[២០២] អាត្មាជាបុគ្គលគ្រាំគ្រា មានកម្លាំងថយហើយ ហេតុនោះ កាយទៅកាន់ទិសនោះ មិនបានទេ តែអាត្មាទៅដោយដំណើរនៃសេចក្តីត្រិះរិះ អស់កាលជានិច្ច បពិត្រព្រាហ្មណ៍ ព្រោះថា ចិត្តរបស់អាត្មា ប្រកបតាមទិសនោះ ។

[២០៣] ពាក្យថា អាត្មាជាបុគ្គលគ្រាំគ្រា មានកម្លាំងថយហើយ ត្រង់ពាក្យថា គ្រាំគ្រា គឺ ចាស់ ចម្រើន មានអាយុច្រើន រស់នៅបានយូរឆ្នាំមកហើយ មានវ័យដល់ហើយតាមលំដាប់ ហេតុនោះ (លោកពោលថា) គ្រាំគ្រា ។ ពាក្យថា មានកម្លាំងថយ គឺ មានកម្លាំងខ្សោយ មានកម្លាំងតិច មានកម្លាំងស្តួចស្តើង ហេតុនោះ (លោកពោលថា) អាត្មាជាបុគ្គលគ្រាំគ្រា មានកម្លាំងថយហើយ ។

## សោឡសមាណវកប្បញ្ហានិគមនិទ្ទេសោ

(២០៤) តេនេវ កាយោ ន បលេតិ តត្ថាតិ កាយោ យេន ពុទ្ធោ តេន ន បលេតិ ន វជតិ ន គច្ឆតិ នាភិក្កមតីតិ តេនេវ កាយោ ន បលេតិ តត្ថ ។

(២០៥) សង្កប្បយត្តាយ វជាមិ និច្ចន្តិ សង្កប្ប-គមនេន វិតក្កគមនេន ញាណគមនេន បញ្ញាគមនេន ពុទ្ធិគមនេន វជាមិ គច្ឆាមិ អភិក្កមាមីតិ ស-ង្កប្បយត្តាយ វជាមិ និច្ចំ ។

(២០៦) មនោ ហិ មេ ព្រាហ្មណ តេន យុត្តោ-តិ មនោតិ យំ ចិត្តំ មនោ មានសំ ហទយំ បណ្ឌរំ មនោ មនាយតនំ មនិន្ទ្រិយំ វិញ្ញាណំ វិញ្ញាណក្ខន្ធោ តជ្ជា មនោវិញ្ញាណធាតុ ។ ព្រាហ្មណ តេន យុត្តោតិ មនោ មម យេន ពុទ្ធោ តេន យុត្តោ សំយុត្តោតិ មនោ ហិ មេ ព្រាហ្មណ តេន យុត្តោ ។

តេនាហ បិង្គិយត្ថេរោ

សោឡសមាណវកបញ្ហានិទ្ទេស

(២០៤) ពាក្យថា កាយទៅក្នុងទិសនោះមិនបានទេ គឺ ព្រះពុទ្ធគង់ក្នុងទិសណា កាយទៅមិនបាន ចេញទៅមិនបាន ដើរទៅមិនបាន ឈានទៅមិនបាន ក្នុងទិសនោះទេ ហេតុនោះ (លោកពោលថា) កាយទៅក្នុងទិសនោះ មិនបានទេ ។

(២០៥) ពាក្យថា តែអាត្មាទៅដោយដំណើរ នៃសេចក្តីត្រិះរិះអស់កាលជានិច្ច គឺ អាត្មាទៅ ដើរទៅ ឈានទៅ ដោយដំណើរនៃតម្រិះ ដោយដំណើរវិតក្កៈ ដោយដំណើរញាណ ដោយដំណើរបញ្ញា ដោយដំណើរប្រាជ្ញាជាគ្រឿងត្រាស់ដឹង ហេតុនោះ (លោកពោលថា) តែអាត្មាទៅដោយដំណើរនៃសេចក្តីត្រិះរិះ អស់កាលជានិច្ច ។

(២០៦) ពាក្យថា បពិត្រព្រាហ្មណ៍ ព្រោះថា ចិត្តរបស់អាត្មាប្រកបតាមទិសនោះ ត្រង់ពាក្យថា ចិត្ត បានដល់គំនិត ធម្មជាតសម្រាប់បង្អោនទៅ សេចក្តីប្រាថ្នាក្នុងចិត្ត ហឫទ័យ បណ្ឌរៈ មនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណក្ខន្ធនោះ ។ ពាក្យថា បពិត្រព្រាហ្មណ៍ ... ប្រកបហើយតាមទិសនោះ គឺ ព្រះពុទ្ធគង់ក្នុងទិសណា ចិត្តរបស់អាត្មាក៏ប្រកប ប្រកបព្រម តាមទិសនោះ ហេតុនោះ (លោកពោលថា) បពិត្រព្រាហ្មណ៍ ព្រោះថា ចិត្តរបស់អាត្មាប្រកបតាមទិសនោះ ។ ហេតុនោះ ព្រះបិង្គិយត្ថេរពោលថា

ជិណ្ណស្ស មេ ទុព្វលថាមកស្ស
តេនេវ កាយោ ន បលេតិ តត្ថ
សង្កប្បយន្តាយ វជាមិ និច្ចំ
មនោ ហិ មេ ព្រាហ្មណ តេន យុត្តោតិ ។

[២០៧] បង្កេ (សយានោ) បរិផន្ទមានោ
ទីបា ទីបំ(១) ឧបល្លវឹ
អថទ្ទសាសឹ សម្ពុទ្ធំ
ឱឃតិណ្ណមនាសវំ ។

[២០៨] បង្កេ សយានោ បរិផន្ទមានោតិ បង្កេ សយានោតិ កាមបង្កេ កាមកទ្ទមេ កាមកិលេសេ កាមពលិសេ កាមបរិឡាហេ កាមបលិពោធេ សេមានោ អវសេមានោ បរិសេមានោតិ បង្កេ សយានោ ។

---

១ ម. ទិសា ទិសំ ។

អាត្មាជាបុគ្គលគ្រាំគ្រា មានកម្លាំងថយហើយ ហេតុនោះ

កាយទៅកាន់ទិសនោះ មិនបានទេ តែអាត្មាទៅដោយ

ដំណើរនៃសេចក្តីត្រិះរិះ អស់កាលជានិច្ច បពិត្រព្រាហ្មណ៍

ព្រោះថា ចិត្តរបស់អាត្មា ប្រកបតាមទិសនោះ ។

(២០៧) អាត្មាដេកកន្ទក់ បម្រះនទៀល ស្ទុះចេញអំពីទី

ពឹង ទៅរកទីពឹង គ្រានោះ អាត្មាបានឃើញព្រះសម្ពុទ្ធ

ទ្រង់ឆ្លងអន្លង់ហើយ ទ្រង់មិនមានអាសវៈទេ ។

(២០៨) អធិប្បាយពាក្យថា ដេកកន្ទក់ បម្រះនទៀល ត្រង់ពាក្យ

ថា ដេកកន្ទក់ គឺ ដេក ដេកស៊ប់ ដេកត្រាំ កន្ទក់គឺកាម កន្ទល្បាប់

គឺកាម កន្ទកិលេសគឺកាម កន្ទសន្ទូចគឺកាម កន្ទសេចក្តីក្តៅក្រហាយ

គឺកាម កន្ទកន្ទួល់គឺកាម ហេតុនោះ (លោកពោលថា) ដេកកន្ទក់ ។

## សោឡសមាណវកប្បញ្ហានិទ្ទេសោ

បរិឌយ្ហមានោតិ តណ្ហាឌយ្ហនាយ ឌយ្ហមានោ ទិដ្ឋិឌយ្ហនាយ ឌយ្ហមានោ កិលេសឌយ្ហនាយ ឌយ្ហមានោ បយោគឌយ្ហនាយ(១) ឌយ្ហមានោ វិបាកឌយ្ហនាយ ឌយ្ហមានោ ទុច្ចរិតឌយ្ហនាយ(២) ឌយ្ហមានោ រត្តោ រាគេន ឌយ្ហមានោ ទុដ្ឋោ ទោសេន ឌយ្ហមានោ មូឡ្ហោ មោហេន ឌយ្ហមានោ វិនិពទ្ធោ មានេន ឌយ្ហមានោ បរាមដ្ឋោ ទិដ្ឋិយា ឌយ្ហមានោ វិក្ខេបគតោ ឧទ្ធច្ចេន ឌយ្ហមានោ អនិដ្ឋង្គតោ វិចិកិច្ឆាយ ឌយ្ហមានោ ថាមគតោ អនុសយេហិ ឌយ្ហមានោ លាភេន ឌយ្ហមានោ អលាភេន ឌយ្ហមានោ យសេន ឌយ្ហមានោ អយសេន ឌយ្ហមានោ និន្ទាយ ឌយ្ហមានោ បសំសាយ ឌយ្ហមានោ សុខេន ឌយ្ហមានោ ទុក្ខេន ឌយ្ហមានោ ជាតិយា ឌយ្ហមានោ ជរាយ ឌយ្ហមានោ ព្យាធិនា

---

១ ម. សំយោគឌយ្ហនាយ ។ ២ ម. មនោទុច្ចរិតឌយ្ហនាយ ។

ពាក្យថា បម្រះនទៀល គឺ បម្រះនទៀល ដោយការបម្រះនទៀលគឺតណ្ហា បម្រះទទៀល ដោយការបម្រះនទៀលគឺទិដ្ឋិ បម្រះនទៀលដោយការបម្រះនទៀលគឺកិលេស បម្រះនទៀល ដោយការបម្រះនទៀលគឺប្រយោគ បម្រះនទៀល ដោយការបម្រះនទៀលគឺវិបាក បម្រះនទៀល ដោយការបម្រះនទៀល គឺទុច្ចរិត ជាអ្នកត្រេកអរ បម្រះនទៀល ដោយរាគៈ ជាអ្នកប្រទូស្ត បម្រះនទៀល ដោយទោសៈ ជាអ្នកវង្វេង បម្រះនទៀលដោយមោហៈ ជាអ្នកជាប់ចំពាក់ បម្រះនទៀលដោយមានះ ជាអ្នកស្ទាបអង្អែល បម្រះនទៀល ដោយទិដ្ឋិ ជាអ្នករវើរវាយ បម្រះនទៀល ដោយឧទ្ធច្ចៈ ជាអ្នកដល់នូវការមិនដាច់ស្រេច បម្រះនទៀល ដោយវិចិកិច្ឆា ជាអ្នកដល់នូវកម្លាំង បម្រះនទៀល ដោយអនុស័យ បម្រះនទៀល ដោយលាភ បម្រះនទៀល ដោយអលាភ បម្រះនទៀលដោយយស បម្រះនទៀល ដោយអយស បម្រះនទៀល ដោយនិន្ទា បម្រះនទៀល ដោយសេចក្ដីសរសើរ បម្រះទទៀលដោយសុខ បម្រះនទៀលដោយទុក្ខ បម្រះនទៀល ដោយជាតិ បម្រះនទៀលដោយជរា បម្រះនទៀលដោយព្យាធិ

ផន្ទមានោ មរណេន ផន្ទមានោ សោកបរិទេវទុក្ខទោ-
មនស្សុបាយាសេហិ ផន្ទមានោ នេរយិកេន ទុក្ខេន
ផន្ទមានោ តិរច្ឆានយោនិកេន ទុក្ខេន ផន្ទមានោ
បិត្តិវិសយិកេន ទុក្ខេន ផន្ទមានោ មានុសកេន
ទុក្ខេន គព្ភោក្កន្តិមូលកេន ទុក្ខេន គព្ភដ្ឋិតិមូលកេន
ទុក្ខេន គព្ភវុដ្ឋានមូលកេន ទុក្ខេន ជាតស្សូបនិពន្ធ-
កេន ទុក្ខេន ជាតស្សបរាធេយ្យកេន ទុក្ខេន អត្តុ-
បក្កមេន ទុក្ខេន បរូបក្កមេន ទុក្ខេន ទុក្ខទុក្ខេន
សង្ខារទុក្ខេន វិបរិណាមទុក្ខេន ចក្ខុរោគេន ទុក្ខេ-
ន សោតរោគេន ទុក្ខេន ឃានរោគេន ទុក្ខេន
ជិវ្ហារោគេន ទុក្ខេន កាយរោគេន ទុក្ខេន សីសរោ-
គេន ទុក្ខេន កណ្ណរោគេន ទុក្ខេន មុខរោគេន
ទុក្ខេន ទន្តរោគេន ទុក្ខេន កាសេន សាសេន
បិនាសេន ឌាហេន ជរេន កុច្ឆិរោគេន មុច្ឆាយ បក្ខ-
ន្ទិកាយ សូលាយ វិសូចិកាយ កុដ្ឋេន គណ្ឌេន
កិលាសេន សោសេន អបមារេន ទទ្ទុយា កណ្ឌុ-
យា កច្ឆុយា រខសាយ វិតច្ឆិកាយ លោហិតេន

បម្រះនទៀលដោយមរណៈ បម្រះនទៀលដោយសេចក្ដីសោក ខ្សឹក ខ្សួល ទុក្ខ ទោមនស្ស សេចក្ដីតានតឹង បម្រះនទៀលដោយទុក្ខក្នុងនរក បម្រះនទៀលដោយទុក្ខក្នុងតិរច្ឆានកំណើត បម្រះនទៀល ដោយទុក្ខ ក្នុងប្រេតវិស័យ បម្រះនទៀល អន្ទះសា ញាប់ញ័រ ញ័ររន្ធត់ ដោយទុក្ខ ជារបស់មនុស្ស ដោយទុក្ខមានការចុះកាន់គភ៌ជាមូល ដោយទុក្ខមានការតាំងនៅក្នុងគភ៌ជាមូល ដោយទុក្ខមានការចេញចាកគភ៌ជាមូល ដោយទុក្ខដែលជាប់ទងនឹងសត្វកើតហើយ ដោយទុក្ខដែលបណ្ដាលអំពីរឿងដទៃនៃសត្វកើតហើយ ដោយទុក្ខព្រោះសេចក្ដីព្យាយាមរបស់ខ្លួន ដោយទុក្ខព្រោះសេចក្ដីព្យាយាមរបស់បុគ្គលដទៃ ដោយទុក្ខទុក្ខ សង្ខារទុក្ខ វិបរិណាមទុក្ខ ចក្ខុរោគទុក្ខ សោតរោគទុក្ខ ឃានរោគទុក្ខ ជិវ្ហារោគទុក្ខ កាយរោគទុក្ខ សីសរោគទុក្ខ កណ្ណរោគទុក្ខ មុខរោគទុក្ខ ទន្តរោគទុក្ខ ដោយទុក្ខព្រោះរោគក្អក ហឺត បុសដួងច្រមុះ ក្ដៅក្រហាយ ស្គាំងស្គម ឈឺពោះ វិលមុខ ធ្លាក់ឈាម ចុកសៀត ចុកផ្ទៃ ឃ្លង់ ពក ស្រែង រឹងរៃ ឆ្កួតជ្រូក ដំណួចពិស រមាស់ កម រោគកើតក្នុងទ្វារដោយក្រចក ឃ្លង់ដេក ឈាម

បិត្តេន មធុមេហេន អំសាយ បិឡកាយ ភគន្ទលាយ(១) បិត្តសមុដ្ឋានេហិ អាពាធេហិ សេម្ហសមុដ្ឋានេហិ អាពាធេហិ វាតសមុដ្ឋានេហិ អាពាធេហិ សន្និបាតិកេហិ អាពាធេហិ ឧតុបរិណាមជេហិ អាពាធេហិ វិសមបរិហារជេហិ អាពាធេហិ ឱបក្កមិកេហិ អាពាធេហិ កម្មវិបាកជេហិ អាពាធេហិ សីតេន ឧណ្ហេន ជិឃច្ឆាយ បិបាសាយ ឧច្ចារេន បស្សាវេន ឌំសមកសវាតាតបសរីសបសម្ផស្សេហិ មាតុមរណេន ទុក្ខេន បិតុមរណេន ទុក្ខេន ភាតុមរណេន ទុក្ខេន ភគិនីមរណេន ទុក្ខេន បុត្តមរណេន ទុក្ខេន ធីតុមរណេន ទុក្ខេន ញាតិព្យសនេន ទុក្ខេន ភោគព្យសនេន ទុក្ខេន រោគព្យសនេន ទុក្ខេន សីលព្យសនេន ទុក្ខេន ទិដ្ឋិព្យសនេន ទុក្ខេន ផន្ទមានោ បរិផន្ទមានោ បវេធមានោ សម្បវេធមានោតិ បង្កេ សយានោ បរិផន្ទមានោ ។

---

១ ម. ភគន្ទលេន បិត្តសមុដ្ឋានេន អាពាធេន ។ល។ ឌំសមកសវាតាតបសរីសបសម្ផស្សេន ទុក្ខេន ។

## សោឡសមាណវកប្បញ្ហានិគមនិទ្ទេស

ប្រមាត់ ប្រមេះ បុសដូងដុះ បូស បុសដូងបាត ព្រោះអាពាធកើតអំពីប្រមាត់ អាពាធកើតអំពីស្លេស្ម អាពាធកើតអំពីខ្យល់ អាពាធកើតអំពីធាតុប្រជុំគ្នា អាពាធកើតអំពីការប្រែប្រួលរដូវ អាពាធកើតអំពីការរក្សាឥរិយាបថមិនស្មើ អាពាធកើតអំពីសេចក្ដីព្យាយាម មានវាយចងជាដើម អាពាធកើតអំពីកម្មវិបាក ព្រោះត្រជាក់ ក្ដៅ ឃ្លាន ស្រេក ឧច្ចារៈ បស្សាវៈ សម្ផស្សរបោម មូស ខ្យល់ កំដៅថ្ងៃ សត្វលូនវារ ដោយទុក្ខព្រោះស្លាប់មាតា ដោយទុក្ខព្រោះស្លាប់បិតា ដោយទុក្ខព្រោះស្លាប់បងប្អូនប្រុស ដោយទុក្ខព្រោះស្លាប់បងប្អូនស្រី ដោយទុក្ខព្រោះស្លាប់កូនប្រុស ដោយទុក្ខព្រោះស្លាប់កូនស្រី ដោយទុក្ខព្រោះវិនាសញាតិ ដោយទុក្ខព្រោះវិនាសភោគសម្បត្តិ ដោយទុក្ខព្រោះវិនាសដោយសាររោគ ដោយទុក្ខ ព្រោះវិនាសសីល ដោយទុក្ខ ព្រោះវិនាសទិដ្ឋិ ហេតុនេះ (លោកពោលថា) ដេកកន្ទក់ បម្រះនទៀល ។

(២០៩) ឥតោ ឥមំ ឧប្បលវន្តិ សត្ថារតោ សត្ថារំ ធម្មក្ខានតោ ធម្មក្ខានំ គណតោ គណំ ទិដ្ឋិយា ទិដ្ឋឹ បដិបទាតោ បដិបទំ មគ្គតោ មគ្គំ ឧបលវឹ សមុប្បលវន្តិ ឥតោ ឥមំ ឧប្បលវឹ ។

(២១០) អជទ្ទសាសឹ សម្ពុទ្ធន្តិ អជាតិ បទសន្ធិ ។ បេ ។ បទានុបុព្វតាមេតំ អជាតិ ។ អទ្ទសាសិន្តិ អទ្ទសំ អទ្ទក្ខឹ អបស្សឹ បដិវិជ្ឈឹ ។ សម្ពុទ្ធន្តិ យោ សោ ភគវា ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ពុទ្ធោតិ អជទ្ទសាសឹ សម្ពុទ្ធំ ។

(២១១) ឱឃតិណ្ណន្តិ ភគវា កាមោឃំ តិណ្ណោ ភវោឃំ តិណ្ណោ ទិដ្ឋោឃំ តិណ្ណោ អវិជ្ជោឃំ តិណ្ណោ ឧត្តិណ្ណោ និត្តិណ្ណោ អតិក្កន្តោ សមតិក្កន្តោ វីតិវត្តោ សោ វុដ្ឋវាសោ ចិណ្ណចរណោ ។ បេ ។

(២០៩) ពាក្យថា ស្ទុះចេញអំពីទីពឹង ទៅរកទីពឹង គឺស្ទុះ ស្ទុះចេញអំពីសាស្តា ទៅរកសាស្តា អំពីអ្នកប្រាប់ធម៌ ទៅរកអ្នកប្រាប់ធម៌ អំពីគណៈ ទៅរកគណៈ អំពីទិដ្ឋិ ទៅរកទិដ្ឋិ អំពីបដិបទា ទៅរកបដិបទា អំពីមគ្គ ទៅរកមគ្គ ហេតុនោះ (លោកពោលថា) ស្ទុះចេញអំពីទីពឹង ទៅរកទីពឹង ។

(២១០) ពាក្យថា គ្រានោះ អាត្មាបានឃើញព្រះសម្ពុទ្ធ ត្រង់ពាក្យថា គ្រានោះ គឺជាការតបទ ។ បេ ។ ពាក្យថា គ្រានោះ ជាលំដាប់នៃបទ ។ ពាក្យថា បានឃើញ គឺ បានឃើញ បានជួប បានប្រសព្វ បានចាក់ធ្លុះ ។ ពាក្យថា ព្រះសម្ពុទ្ធ បានដល់ព្រះមានបុណ្យ ។ បេ ។ បញ្ញត្តិថា ព្រះពុទ្ធ នេះ កើតអំពីការត្រាស់ដឹង ហេតុនោះ (លោកពោលថា) គ្រានោះ អាត្មាបានឃើញព្រះសម្ពុទ្ធ ។

(២១១) ពាក្យថា ទ្រង់ឆ្លងអន្លង់ហើយ គឺ ព្រះមានព្រះភាគទ្រង់ឆ្លងអន្លង់គឺកាម ឆ្លងអន្លង់គឺភព ឆ្លងអន្លង់គឺទិដ្ឋិ ឆ្លង ឆ្លងឡើង ឆ្លងចេញកន្លង កន្លងព្រម ប្រព្រឹត្តកន្លង អន្លង់គឺអវិជ្ជា គឺថា ព្រះអង្គទ្រង់មានការនៅក្នុងអរិយវាស នៅរួចហើយ មានចរណៈសន្សំហើយ ។ បេ ។

ជាតិជរាមរណសំសារោ នត្ថិ តស្ស បុនព្ភវោតិ ឱឃតិណ្ណំ ។ អនាសវន្តិ ចត្តារោ អាសវា កាមាសវោ ភវាសវោ ទិដ្ឋាសវោ អវិជ្ជាសវោ ។ តេ អាសវា ពុទ្ធស្ស ភគវតោ បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា តស្មា ពុទ្ធោ អនាសវោតិ ឱឃតិណ្ណមនាសវំ ។ តេនាហ បិង្គិយត្ថេរោ

បង្កេ (សយានោ) បរិផន្ទមានោ
ទីបា ទីបំ ឧបល្លវឹ
អថទ្ទសាសឹ សម្ពុទ្ធំ
ឱឃតិណ្ណមនាសវន្តិ ។

[២១២] យថា អហូ វក្កលិ មុត្តសទ្ធោ
ភទ្រាវុធោ អាឡវិគោតមោ ច
ឯវមេវ ត្វម្បិ បមុញ្ចស្សុ សទ្ធំ
គមិស្សសិ (ត្វំ) បិង្គិយ មច្ចុធេយ្យស្ស បារំ ។

សោឡសមាណវកបញ្ហានិគមនិទ្ទេស

កពប្ដី គឺ ជាតិ ជរា មរណៈ សង្សារ នៃព្រះអង្គមិនមាន ហេតុនោះ (លោកពោលថា) ទ្រង់ធ្លងអន្លង់ហើយ ។ ពាក្យថា មិនមានអាសវៈ សេចក្ដីថា អាសវៈ ៤ គឺ កាមាសវៈ ភវាសវៈ ទិដ្ឋាសវៈ អវិជ្ជាសវៈ ។ អាសវៈទាំងនោះ ព្រះពុទ្ធមានជោគ ទ្រង់លះបង់ហើយ មានឫសគល់ផ្ដាច់ផ្ដិលហើយ ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើឲ្យដល់នូវការមិនកើតមាន ឲ្យជាធម៌លែងកើតតទៅទៀត ហេតុនោះ ព្រះពុទ្ធឈ្មោះថាមិនមានអាសវៈ ហេតុនោះ (លោកពោលថា) ទ្រង់ធ្លងអន្លង់ហើយ មិនមានអាសវៈ ។ ហេតុនោះ ព្រះបិង្គិយត្ថេរ ពោលថា

អាត្មាដេកក្នុងកក់ បម្រះនទៀល ស្ទុះចេញអំពីទីពឹង ទៅ
រកទីពឹង គ្រានោះ អាត្មាបានឃើញព្រះសម្ពុទ្ធ ព្រះអង្គ
ទ្រង់ធ្លងអន្លង់ហើយ ទ្រង់មិនមានអាសវៈទេ ។

[២១២] (ព្រះមានព្រះភាគត្រាស់ថា) វក្កលិ ភទ្រាវុធ និង
អាឡវិគោតម សុទ្ធតែជាអ្នកមានសទ្ធាបញ្ចេញហើយ យ៉ាង
ណា សូម្បីអ្នកក៏ចូរបញ្ចេញ នូវសទ្ធា យ៉ាងនោះចុះ
ម្នាលបិង្គិយៈ អ្នកនឹងដល់នូវត្រើយ នៃលំនៅរបស់មច្ចុ ។

(២១៣) យថា អហុ វក្កលិ មុត្តសទ្ធោ ភទ្រាវុធោ អាឡវិគោតមោ ចាតិ យថា វក្កលិ មុត្តសទ្ធោ សទ្ធាគរុកោ សទ្ធាបុព្វង្គមោ សទ្ធាធិមុត្តោ សទ្ធាធិបតេយ្យោ អរហត្តប្បត្តោ យថា ភទ្រាវុធោ មុត្តសទ្ធោ សទ្ធាគរុកោ សទ្ធាបុព្វង្គមោ សទ្ធាធិមុត្តោ សទ្ធាធិបតេយ្យោ អរហត្តប្បត្តោ យថា អាឡវិគោតមោ មុត្តសទ្ធោ សទ្ធាគរុកោ សទ្ធាបុព្វង្គមោ សទ្ធាធិមុត្តោ សទ្ធាធិបតេយ្យោ អរហត្តប្បត្តោតិ យថា អហុ វក្កលិ មុត្តសទ្ធោ ភទ្រាវុធោ អាឡវិគោតមោ ច ។

(២១៤) ឯវមេវ ត្វម្បិ បមុញ្ចស្សុ សទ្ធន្តិ ឯវមេវ ត្វំ សទ្ធំ មុញ្ចស្សុ បមុញ្ចស្សុ សម្បមុញ្ចស្សុ អធិមុញ្ចស្សុ ឱកប្បេហិ សព្វេ សង្ខារា អនិច្ចាតិ ។បេ។ យំកិញ្ចិ សមុទយធម្មំ សព្វំ តំ និរោធធម្មន្តិ សទ្ធំ មុញ្ចស្សុ បមុញ្ចស្សុ សម្បមុញ្ចស្សុ អធិមុញ្ចស្សុ ឱកប្បេហីតិ ឯវមេវ ត្វម្បិ បមុញ្ចស្សុ សទ្ធំ ។

(៦១៣) ពាក្យថា វក្កលិ ភទ្រាវុធ នឹងអាឡវិគោតម សុទ្ធតែជាអ្នកមានសទ្ធាបញ្ចេញហើយ យ៉ាងណា អធិប្បាយថា វក្កលិ មានសទ្ធាបញ្ចេញហើយ ជាអ្នកជូនកងសទ្ធា មានសទ្ធាជាប្រធាន មានចិត្តចុះស៊ប់កងសទ្ធា មានសទ្ធាជាអធិបតី បានសម្រេចព្រះអរហត្ត យ៉ាងណា ភទ្រាវុធ មានសទ្ធាបញ្ចេញហើយ ជាអ្នកជូនកងសទ្ធា មានសទ្ធាជាប្រធាន មានចិត្តចុះស៊ប់កងសទ្ធា មានសទ្ធាជាអធិបតី បានសម្រេចព្រះអរហត្ត យ៉ាងណា អាឡវិគោតម មានសទ្ធាបញ្ចេញហើយ ជាអ្នកជូនកងសទ្ធា មានសទ្ធាជាប្រធាន មានចិត្តចុះស៊ប់កងសទ្ធា មានសទ្ធាជាអធិបតី បានសម្រេចព្រះអរហត្ត យ៉ាងណា ហេតុនោះ (ទ្រង់ត្រាស់ថា) វក្កលិ ភទ្រាវុធ នឹងអាឡវិគោតម សុទ្ធតែជាអ្នកមានសទ្ធាបញ្ចេញហើយ យ៉ាងណា ។

(៦១៤) ពាក្យថា សូម្បីអ្នកក៏ចូរបញ្ចេញនូវសទ្ធា យ៉ាងនោះចុះ សេចក្តីថា អ្នកចូរលែង ចូរបញ្ចេញ ចូរបញ្ចេញព្រម ចូរចុះស៊ប់កាន់សទ្ធា គឺចូរជឿថា សង្ខារទាំងពួងមិនទៀង ។ បេ ។ អ្នកចូរលែង ចូរបញ្ចេញ ចូរបញ្ចេញព្រម ចូរចុះស៊ប់កាន់សទ្ធា គឺចូរជឿថា របស់ណាមានការកើតឡើងជាធម្មតា របស់ទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា យ៉ាងនោះដែរ ហេតុនោះ (ទ្រង់ត្រាស់ថា) សូម្បីអ្នកក៏ចូរបញ្ចេញនូវសទ្ធា យ៉ាងនោះចុះ ។

សោឡសមាណវកបញ្ហានិគមនិទ្ទេសោ

(២១៥) គមិស្សសិ (ត្វំ) បិង្គិយ មច្ចុធេយ្យស្ស បារន្តិ មច្ចុធេយ្យា វុច្ចន្តិ កិលេសា ច ខន្ធា ច អភិសង្ខារា ច ។ មច្ចុធេយ្យស្ស បារំ វុច្ចតិ អមតំ និព្វានំ យោ សោ សព្វសង្ខារសមថោ សព្វុបធិប-ដិនិស្សគ្គោ តណ្ហក្ខយោ វិរាគោ និរោធោ និព្វានំ គមិស្សសិ (ត្វំ) បិង្គិយ មច្ចុធេយ្យស្ស បារន្តិ តំ បារំ គមិស្សសិ អធិគមិស្សសិ ផុសិស្សសិ សច្ឆិ-ករិស្សសីតិ គមិស្សសិ (ត្វំ) បិង្គិយ មច្ចុធេយ្យស្ស បារំ ។ តេនាហ ភគវា

យថា អហុ វក្កលិ មុត្តសទ្ធោ
ភទ្រាវុធោ អាឡវិគោតមោ ច
ឯវមេវ ត្វម្បិ បមុញ្ចស្សុ សទ្ធំ
គមិស្សសិ (ត្វំ) បិង្គិយ មច្ចុធេយ្យស្ស បារន្តិ ។

(២១៦) ឯស ភិយ្យោ បសីទាមិ សុត្វាន មុនិនោ វចោ
វិវដច្ឆទោ(១) សម្ពុទ្ធោ អខិលោ បដិភាណវា ។

---

១ ម. វិវដច្ឆទោ ។

(៤១៥) ពាក្យថា ម្នាលបិង្គិយៈ អ្នកនឹងដល់ត្រើយ នៃលំនៅរបស់មច្ចុ សេចក្តីថា កិលេស ខន្ធ និងអភិសង្ខារ លោកហៅថា លំនៅរបស់មច្ចុ ។ អមតនិព្វាន លោកហៅថា ត្រើយនៃលំនៅរបស់មច្ចុ បាន ដល់ការរម្ងាប់សង្ខារទាំងពួង ការលះបង់ឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក សេចក្តីរលត់ និព្វាន ។ ពាក្យថា ម្នាលបិង្គិយៈ អ្នកនឹងដល់ត្រើយ នៃលំនៅរបស់មច្ចុ បានសេចក្តីថា អ្នកនឹងដល់ នឹងបាន នឹងពាល់ត្រូវ នឹងធ្វើឲ្យជាក់ច្បាស់នូវត្រើយ ហេតុនោះ (ទ្រង់ត្រាស់ថា) ម្នាលបិង្គិយៈ អ្នកនឹងដល់ត្រើយ នៃលំនៅរបស់មច្ចុ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

វក្កលិ ភទ្រាវុធ និងអាឡវិគោតម សុទ្ធតែជាអ្នកមាន
សទ្ធាបញ្ចេញហើយ យ៉ាងណា សូម្បីអ្នកក៏ចូរបញ្ចេញ
សទ្ធា យ៉ាងនោះចុះ ម្នាលបិង្គិយៈ អ្នកនឹងដល់ត្រើយ
នៃលំនៅរបស់មច្ចុ ។

(៤១៦) (ព្រះបិង្គិយត្ថេរទូលថា) ខ្ញុំព្រះអង្គនេះជ្រះថ្លាក្រៃពេក
ព្រោះបានស្តាប់ព្រះបន្ទូលនៃព្រះអង្គ ជាព្រះមុនិ ព្រះអង្គ
ទ្រង់មានគ្រឿងបិទ បើកហើយ ព្រះអង្គមិនមានគ្រឿង
រឹងរូស ទ្រង់មានបដិភាណ ។

(២១៧) ឯស ភិយ្យោ បសីទាមីតិ ឯស ភិយ្យោ បសីទាមិ សទ្ទហាមិ អធិមុច្ចាមិ ឱកប្បេមិ សព្វេ សង្ខារា អនិច្ចាតិ ។ បេ ។ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ភិយ្យោ បសីទាមិ សទ្ទហាមិ អធិមុច្ចាមិ ឱកប្បេមីតិ ឯស ភិយ្យោ បសីទាមិ ។

(២១៨) សុត្វាន មុនិនោ វចោតិ មុនីតិ មោនំ វុច្ចតិ ញាណំ យា បញ្ញា បជានានា ។ បេ ។ សង្គជាលមតិច្ច សោ មុនិ ។ សុត្វាន មុនិនោ វចោតិ តុយ្ហំ វចនំ ព្យប្បថំ ទេសនំ អនុសន្ធិំ សុត្វា សុណិត្វា ឧគ្គហេត្វា ឧបធារយិត្វា ឧបលក្ខយិត្វាតិ សុត្វាន មុនិនោ វចោ ។

(២១៩) វិវដ្ដច្ឆទោ សម្ពុទ្ធោតិ ឆទនន្តិ បញ្ច ឆទនានិ តណ្ហាឆទនំ ទិដ្ឋិឆទនំ កិលេសឆទនំ

(៦១៧) ពាក្យថា ខ្ញុំព្រះអង្គនេះជ្រះថ្លាក្រៃពេក គឺ ខ្ញុំព្រះអង្គនេះ ជ្រះថ្លា ជឿ ចុះចិត្តស៊ប់ ជឿមាំក្រៃពេកថា សង្ខារទាំងពួងមិនទៀង ។ បេ ។ ខ្ញុំព្រះអង្គនេះ ជ្រះថ្លា ជឿ ចុះចិត្តស៊ប់ ជឿមាំក្រៃពេកថា របស់ណា មានការកើតឡើងជាធម្មតា របស់នោះ មានការរលត់ទៅវិញជាធម្មតា ហេតុនោះ (លោកពោលថា) ខ្ញុំព្រះអង្គនេះជ្រះថ្លាក្រៃពេក ។

(៦១៨) ពាក្យថា ព្រោះបានស្តាប់ព្រះបន្ទូលនៃព្រះអង្គជាព្រះមុនិ គ្រង់ពាក្យថា មុនិ សេចក្តីថា ញាណ លោកហៅថា មោនៈ បានដល់បញ្ញា ការដឹងច្បាស់ ។ បេ ។ មុនិនោះ កន្លងនូវបណ្តាញគឺកិលេសជាគ្រឿងចំពាក់ ។ ពាក្យថា ព្រោះបានស្តាប់ព្រះបន្ទូលនៃព្រះអង្គជាព្រះមុនិ បានសេចក្តីថា ព្រោះបានស្តាប់ ឮ រៀន ចងចាំទុក កំណត់ទុកនូវព្រះបន្ទូល គន្លងនៃព្រះបន្ទូល ទេសនា អនុសន្ធិ នៃព្រះអង្គ ហេតុនោះ (លោកពោលថា) ព្រោះបានស្តាប់ព្រះបន្ទូល នៃព្រះអង្គជាព្រះមុនិ ។

(៦១៩) ពាក្យថា ព្រះសម្ពុទ្ធទ្រង់មានគ្រឿងបិទបើកហើយ គ្រង់ពាក្យថា គ្រឿងបិទ បានដល់គ្រឿងបិទ ៥ គឺ គ្រឿងបិទគឺតណ្ហា គ្រឿងបិទគឺទិដ្ឋិ គ្រឿងបិទគឺកិលេស គ្រឿងបិទ

ទុច្ចរិតជ្ជរំ អរិដ្ឋជ្ជរំ ។ តានិ ជ្ជរានិ ពុទ្ធស្ស ភគវតោ វន្តានិ វិទ្ធំសិតានិ សមុគ្ឃាតិតានិ បហីនានិ សមុច្ឆិន្នានិ វូបសន្តានិ បដិប្បស្សទ្ធានិ អភព្វុប្បត្តិកានិ ញាណគ្គិនា ទឌ្ឍានិ តស្មា ពុទ្ធោ វិជ្ជរោ ។ ពុទ្ធោតិ យោ សោ ភគវា ។ បេ ។ សច្ឆិកា បញ្ញត្តិ យទិទំ ពុទ្ធោតិ វិជ្ជរោ សម្ពុទ្ធោ ។

(២២០) អខិលោ បដិភាណវាតិ អខិលោតិ រាគោ ខិលោ ទោសោ ខិលោ មោហោ ខិលោ កោធោ ខិលោ ឧបនាហោ ខិលោ ។ បេ ។ សព្វាកុសលាភិសង្ខារា ខិលា ។ តេ ខិលា ពុទ្ធស្ស ភគវតោ បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតិំ អនុប្បាទធម្មា តស្មា ពុទ្ធោ អខិលោ ។

គឺទុច្ចរិត គ្រឿងបិទគឺអវិជ្ជា ។ គ្រឿងបិទទាំងនោះ ព្រះពុទ្ធមានព្រះភាគ ទ្រង់បើក គឺកំចាត់បង់ ដកឡើង លះបង់ ផ្តាច់ផ្តិល រំងាប់ គ្របសង្កត់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ ព្រះពុទ្ធ ឈ្មោះថាមានគ្រឿងបិទបើកហើយ ។ ពាក្យថា ព្រះពុទ្ធ បានដល់ព្រះមានព្រះភាគ ។ បេ ។ បញ្ញត្តិថា ព្រះពុទ្ធ នេះ កើតព្រោះការត្រាស់ដឹង ហេតុនោះ (លោកពោលថា) ព្រះសម្ពុទ្ធទ្រង់មានគ្រឿងបិទបើកហើយ ។

(២២០) អធិប្បាយពាក្យថា ព្រះអង្គមិនមានគ្រឿងរឹងរូស ទ្រង់មានបដិភាណ ត្រង់ពាក្យថា មិនមានគ្រឿងរឹងរូស សេចក្តីថា រាគៈឈ្មោះថាគ្រឿងរឹងរូស ទោសៈ ឈ្មោះថាគ្រឿងរឹងរូស មោហៈ ឈ្មោះថាគ្រឿងរឹងរូស ក្រោធ ឈ្មោះថាគ្រឿងរឹងរូស ការចងគំនុំ ឈ្មោះថាគ្រឿងរឹងរូស ។ បេ ។ អកុសលាភិសង្ខារទាំងអស់ ឈ្មោះថាគ្រឿងរឹងរូស ។ គ្រឿងរឹងរូសទាំងនោះព្រះពុទ្ធមានជោគ ទ្រង់លះបង់ ផ្តាច់ផ្តិលបុសគល់ ធ្វើឲ្យសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនកើតមាន ធ្វើឲ្យជាធម៌លែងកើតតទៅទៀត ហេតុនោះ ព្រះពុទ្ធឈ្មោះថាមិនមានគ្រឿងរឹងរូស ។

បដិភាណវាតិ តយោ បដិភាណវន្តោ បរិយត្តិប្បដិភាណវា ច បរិបុច្ឆាបដិភាណវា ច អធិគមប្បដិភាណវា ច ។

កតមោ បរិយត្តិប្បដិភាណវា ។ ឥធេកច្ចស្ស ពុទ្ធវចនំ បរិយាបុដំ ហោតិ សុត្តំ គេយ្យំ វេយ្យាករណំ គាថា ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លំ តស្ស បរិយត្តឹ និស្សាយ បដិភាតិ អយំ បរិយត្តិប្បដិភាណវា ។

កតមោ បរិបុច្ឆាបដិភាណវា ។ ឥធេកច្ចោ បរិបុច្ឆិតា ហោតិ អត្ថេ ច ញាយេ ច លក្ខណេ ច ការណេ ច ឋានាឋានេ ច តស្ស បរិបុច្ឆំ និស្សាយ បដិភាតិ អយំ បរិបុច្ឆាបដិភាណវា ។

កតមោ អធិគមប្បដិភាណវា ។ ឥធេកច្ចស្ស អធិគតា ហោន្តិ ចត្តារោ សតិប្បដ្ឋានា ចត្តារោ សម្មប្បធានា ចត្តារោ ឥទ្ធិបាទា បញ្ចិន្ទ្រិយានិ បញ្ច ពលានិ

ពាក្យថា ទ្រង់មានបដិភាណ បានដល់បុគ្គលមានបដិភាណ ៣ ពួក គឺ បុគ្គលមានបដិភាណព្រោះបរិយត្តិ១ បុគ្គលមានបដិភាណព្រោះបរិបុច្ឆា ១ បុគ្គលមានបដិភាណព្រោះអធិគមៈ១ ។

បុគ្គលមានបដិភាណព្រោះបរិយត្តិ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ រៀនពុទ្ធវចនៈ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ ពុទ្ធវចនៈនោះ រមែងភ្លឺច្បាស់ដល់បុគ្គលនោះ ព្រោះអាស្រ័យបរិយត្តិ នេះ ឈ្មោះថាបុគ្គលមានបដិភាណព្រោះបរិយត្តិ ។

បុគ្គលមានបដិភាណព្រោះបរិបុច្ឆា តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសាកសួរក្នុងអត្ថ ក្នុងធម៌គួរដឹង ក្នុងលក្ខណៈ ក្នុងហេតុ ក្នុងឋានៈនិងអដ្ឋានៈ សភាវៈមានអត្ថជាដើមនោះ រមែងភ្លឺច្បាស់ដល់បុគ្គលនោះ ព្រោះអាស្រ័យការសាកសួរ នេះ ឈ្មោះថាបុគ្គលមានបដិភាណព្រោះបរិបុច្ឆា ។

បុគ្គលមានបដិភាណព្រោះអធិគមៈ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ត្រាស់ដឹងសតិប្បដ្ឋាន៤ សម្មប្បធាន៤ ឥទ្ធិបាទ៤ ឥន្ទ្រិយ៥ ពលៈ៥

សត្ត ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ ចត្តារោ អរិយមគ្គា ចត្តារិ សាមញ្ញផលានិ ចតស្សោ បដិសម្ភិទាយោ ឆ អភិញ្ញាយោ តស្ស អត្ថញ្ញាតោ ធម្មញ្ញាតោ និរុត្តិញ្ញាតា អត្ថេ ញាតេ អត្ថា បដិភាតិ ធម្មេ ញាតេ ធម្មា បដិភាតិ និរុត្តិយា ញាតាយ និរុត្តិ បដិភាតិ ឥមេសុ តីសុ ញាណំ បដិភាណប្បដិសម្ភិទា ។ ភគវា ឥមាយ បដិសម្ភិទាយ ឧបេតោ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ តស្មា ពុទ្ធោ បដិភាណវា ។ យស្ស បរិយត្តិ នត្ថិ បរិបុច្ឆា នត្ថិ អធិគមោ នត្ថិ កឹ តស្ស បដិភាយិស្សតីតិ អខិលោ បដិភាណវា ។ តេនាហ បិង្គិយត្ថេរោ

ឯវ ភិយ្យោ បសីទាមិ សុត្វាន មុនិនោ វចោ
វិវដច្ឆទោ សម្ពុទ្ធោ អខិលោ បដិភាណវាតិ ។

(២២១) អធិទេវេ អភិញ្ញាយ សព្វំ វេទិ បរោវរំ(១)
បញ្ហានន្តករោ សត្ថា កង្ខីនំ បដិជានតំ ។

១ ម. បរោបរំ ។

ពោជ្ឈង្គ ៧ អដ្ឋង្គិកមគ្គដ៏ប្រសើរ អរិយមគ្គ ៤ សាមញ្ញផល ៤ បដិសម្ភិទា ៤ អភិញ្ញា ៦ បុគ្គលនោះ ដឹងអត្ថ ដឹងធម៌ ដឹងនិរុត្តិ កាលបុគ្គលដឹងអត្ថហើយ អត្ថក៏ភ្លឺច្បាស់ កាលបុគ្គលដឹងធម៌ហើយ ធម៌ក៏ភ្លឺច្បាស់ កាលបុគ្គលដឹងនិរុត្តិហើយ និរុត្តិក៏ភ្លឺច្បាស់ ការដឹងក្នុងធម៌ទាំង ៣ នេះ ឈ្មោះថាបដិភាណប្បដិសម្ភិទា ។ ព្រះមានព្រះភាគ ទ្រង់ប្រកបហើយ ប្រកបព្រម ចូលទៅជិតដល់ ចូលទៅជិតដល់ព្រម ចូលទៅជិតសម្រេច ចូលទៅជិតសម្រេចព្រម រួបរួម ដោយបដិសម្ភិទានេះ ហេតុនោះ ព្រះពុទ្ធ ឈ្មោះថាទ្រង់មានបដិភាណ ។ បុគ្គលណា ពុំមានបរិយត្តិ ពុំមានបរិបុច្ឆា ពុំមានអធិគមៈទេ អ្វីទឹងក៏ភ្លឺច្បាស់ដល់បុគ្គលនោះ ហេតុនោះ (លោកពោលថា) ព្រះអង្គមិនមានគ្រឿងរឹងរូស ទ្រង់មានបដិភាណ ។ ហេតុនោះ ព្រះបិង្គិយត្ថេរ ពោលថា

ខ្ញុំព្រះអង្គនេះជ្រះថ្លាក្រៃពេក ព្រោះបានស្តាប់ព្រះបន្ទូលនៃ
ព្រះអង្គជាព្រះមុនិ ព្រះសម្ពុទ្ធទ្រង់មានគ្រឿងបិទបើកហើយ
ព្រះអង្គមិនមានគ្រឿងរឹងរូស ទ្រង់មានបដិភាណ ។

(២២១) ព្រះសាស្តាទ្រង់ជ្រាបច្បាស់ នូវអធិទេវតាទាំងឡាយ
ទ្រង់ជ្រាបនូវធម្មជាតទាំងអស់ ដែលថោកទាបនឹងប្រសើរ
ទ្រង់ធ្វើទីបំផុត នៃប្រស្នាទាំងឡាយ ដល់ពួកជនអ្នក
សង្ស័យដែលប្តេជ្ញា (ថាអស់សង្ស័យ) ។

(២២២) អធិទេវេ អភិញ្ញាយាតិ ទេវាតិ តយោ ទេវា សម្មុតិទេវា ច ឧបបត្តិទេវា ច វិសុទ្ធិទេវា ច ។

កតមេ សម្មុតិទេវា ។ រាជានោ ច រាជកុមារា ច ទេវិយោ ច ឥមេ សម្មុតិទេវា វុច្ចន្តិ ។

កតមេ ឧបបត្តិទេវា ។ ចាតុម្មហារាជិកា ទេវា តាវតិំសា ទេវា ។ បេ ។ ព្រហ្មកាយិកា ទេវា យេ ច ទេវា តទុត្តរិ(១) ឥមេ ឧបបត្តិទេវា វុច្ចន្តិ ។

កតមេ វិសុទ្ធិទេវា ។ តថាគតសាវកា អរហន្តោ ខីណាសវា យេ ច បច្ចេកសម្ពុទ្ធា ឥមេ វិសុទ្ធិទេវា វុច្ចន្តិ ។

ភគវា សម្មុតិទេវេ អធិទេវាតិ អភិញ្ញាយ ឧបបត្តិទេវេ អធិទេវាតិ អភិញ្ញាយ វិសុទ្ធិទេវេ អធិទេវាតិ អភិញ្ញាយ ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វាតិ អធិទេវេ អភិញ្ញាយ ។

---

១ ម. តទុបរិ ។

(២២២) អធិប្បាយពាក្យថា ទ្រង់ជ្រាបច្បាស់នូវអធិទេវតាទាំងឡាយ ត្រង់ពាក្យថា ទេវតាទាំងឡាយ បានដល់ទេវតា ៣ ពួក គឺ ពួកសម្មតិទេវតា ១ ឧបបត្តិទេវតា ១ វិសុទ្ធិទេវតា ១ ។

សម្មតិទេវតា តើដូចម្តេច ។ ព្រះរាជា ព្រះរាជកុមារ នឹងព្រះរាជទេពី ទាំងនេះ ហៅថា សម្មតិទេវតា ។ ឧបបត្តិទេវតា តើដូចម្តេច ។ ពួកទេវតាជាន់ចាតុម្មហារាជិកៈ ពួកទេវតាជាន់តាវត្តិង្ស ។ បេ ។ ពួកទេវតាជាន់ព្រហ្មកាយិកៈ នឹងពួកទេវតាជាន់ខាងលើអំពីនោះ ទាំងនេះ ហៅថា ឧបបត្តិទេវតា ។

វិសុទ្ធិទេវតា តើដូចម្តេច ។ ព្រះអរហន្តខីណាស្រព ជាសាវ័ករបស់តថាគត នឹងព្រះបច្ចេកសម្ពុទ្ធ ទាំងនេះ ហៅថា វិសុទ្ធិទេវតា ។

ព្រះមានព្រះភាគជ្រាបច្បាស់ នូវសម្មតិទេវតាទាំងឡាយថា ជាអធិទេវតា ទ្រង់ជ្រាបច្បាស់នូវពួកឧបបត្តិទេវតាថា ជាអធិទេវតា ទ្រង់ជ្រាបច្បាស់ ទ្រង់យល់ ទ្រង់ថ្លឹង ទ្រង់ត្រិះរិះ ទ្រង់ជាក់ច្បាស់ ទ្រង់ធ្វើឲ្យប្រាកដ នូវពួកវិសុទ្ធិទេវតាថា ជាអធិទេវតា ហេតុនោះ (លោកពោលថា) ទ្រង់ជ្រាបច្បាស់ នូវអធិទេវតាទាំងឡាយ ។

សោឡសមាណវកបុច្ឆានិគមនិទ្ទេសោ

(២២៣) សព្ពំ វេទិ បរោវរន្តិ ភគវា អត្តនោ ច បរេសញ្ច អធិទេវករេ ធម្មេ វេទិ អញ្ញាសិ អផុសិ បដិវិជ្ឈិ ។ កតមេ អត្តនោ អធិទេវករា ធម្មា ។ សម្មាបដិបទា អនុលោមបដិបទា អបច្ចនីកបដិបទា ធម្មានុធម្មបដិបទា សីលេសុ បរិបូរការិតា ឥន្ទ្រិយេសុ គុត្តទ្វារតា ភោជនេ មត្តញ្ញុតា ជាគរិយានុយោគោ សតិសម្បជញ្ញំ ចត្តារោ សតិបដ្ឋានា ។បេ។ អរិយោ អដ្ឋង្គិកោ មគ្គោ ឥមេ វុច្ចន្តិ អត្តនោ អធិទេវករា ធម្មា ។ កតមេ បរេសំ អធិទេវករា ធម្មា ។ សម្មាបដិបទា ។បេ។ អរិយោ អដ្ឋង្គិកោ មគ្គោ ឥមេ វុច្ចន្តិ បរេសំ អធិទេវករា ធម្មា ។ ឯវំ ភគវា អត្តនោ ច បរេសញ្ច អធិទេវករេ ធម្មេ វេទិ អញ្ញាសិ អផុសិ បដិវិជ្ឈីតិ សព្ពំ វេទិ បរោវរំ ។

## សោឡសមាណវកបញ្ហានិគមនិទ្ទេស

(២២៣) ពាក្យថា ទ្រង់ជ្រាបច្បាស់ធម្មជាតទាំងអស់ ដ៏ថោកទាប នឹងប្រសើរ អធិប្បាយថា ព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់ ទ្រង់យល់ ទ្រង់ប៉ះពាល់ ទ្រង់ចាក់ធ្លុះ នូវពួកធម៌ ដែលធ្វើព្រះអង្គនឹងបុគ្គលដទៃ ឲ្យជាអធិទេវតា ។ ពួកធម៌ដែលធ្វើព្រះអង្គ ឲ្យជាអធិទេវតា តើដូចម្ដេច ។ សេចក្ដីប្រតិបត្តិដោយប្រពៃ សេចក្ដីប្រតិបត្តិបណ្ដោយតាម សេចក្ដីប្រតិ-បត្តិមិនទំនាស់ សេចក្ដីប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ ការធ្វើបំពេញក្នុងសីល ការគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយ ការដឹងប្រមាណក្នុងភោជន ការប្រកបរឿយ ៗ នូវសេចក្ដីភ្ញាក់រឭក សតិសម្បជញ្ញៈ សតិប្បដ្ឋាន ៤ ។ បេ ។ អដ្ឋង្គិកមគ្គដ៏ប្រសើរ ទាំងនេះហៅថា ធម៌ដែលធ្វើព្រះអង្គឲ្យជាអធិទេវតា ។ ធម៌ធ្វើបុគ្គលដទៃឲ្យជាអធិទេវតា តើដូចម្ដេច ។ សេចក្ដីប្រតិបត្តិដោយប្រពៃ ។ បេ ។ អដ្ឋង្គិកមគ្គដ៏ប្រសើរ ទាំងនេះ ហៅថា ធម៌ធ្វើបុគ្គលដទៃឲ្យជាអធិទេវតា ។ ព្រះមានព្រះភាគទ្រង់ជ្រាប ទ្រង់យល់ ទ្រង់ប៉ះពាល់ ទ្រង់ចាក់ធ្លុះ នូវធម៌ដែលធ្វើព្រះអង្គនឹងបុគ្គលដទៃ ឲ្យជាអធិទេវតា ហេតុនោះ (លោកពោលថា) ទ្រង់ជ្រាបធម្មជាតទាំងអស់ដ៏ថោកទាបនឹងប្រសើរ ។

[២២៤] បញ្ញាណន្តកោ សត្ថាតិ ភគវា បារាយ-និកបញ្ញានំ អន្តកោ បរិយន្តកោ បរិច្ឆេទកោ បរិវដុមកោ បរិសបញ្ញានំ(១) អន្តកោ បរិយន្ត-កោ បរិច្ឆេទកោ បរិវដុមកោ បិង្គិយបញ្ញានំ អន្តកោ បរិយន្តកោ បរិច្ឆេទកោ បរិវដុមកោ សក្កបញ្ញានំ អមនុស្សបញ្ញានំ ភិក្ខុបញ្ញានំ ភិក្ខុ-នីបញ្ញានំ ឧបាសកបញ្ញានំ ឧបាសិកាបញ្ញានំ រាជបញ្ញានំ ខត្តិយបញ្ញានំ ព្រាហ្មណបញ្ញានំ វេស្ស-បញ្ញានំ សុទ្ទបញ្ញានំ ព្រហ្មបញ្ញានំ អន្តកោ បរិ-យន្តកោ បរិច្ឆេទកោ បរិវដុមកោតិ បញ្ញាណន្ត-កោ ។ សត្ថាតិ ភគវា សត្ថវាហោ ។ យថា សត្ថវា-ហោ សត្តេ កន្តារំ តារេតិ ចោរកន្តារំ តារេតិ វាឡ-កន្តារំ តារេតិ ទុព្ភិក្ខកន្តារំ តារេតិ និរុទកកន្តារំ តារេតិ ឧត្តារេតិ និត្តារេតិ ខេមន្តភូមឹ សម្បាបេតិ ឯវមេវ

---

១ ម. សភិយបញ្ហានំ ។

(២២៤) ពាក្យថា ព្រះសាស្តា ទ្រង់ធ្វើទីបំផុតនៃប្រស្នា អធិប្បាយថា ព្រះមានព្រះភាគទ្រង់ធ្វើទីបំផុត ធ្វើទីបំផុតជុំវិញ ធ្វើការកំណត់ ធ្វើផ្លូវជុំវិញ នៃបារាយនិកបញ្ហា ទ្រង់ធ្វើទីបំផុត ធ្វើទីបំផុតជុំវិញ ធ្វើការកំណត់ ធ្វើផ្លូវជុំវិញ នៃបរិសបញ្ហា ទ្រង់ធ្វើទីបំផុត ធ្វើទីបំផុតជុំវិញ ធ្វើការកំណត់ ធ្វើផ្លូវជុំវិញ នៃបិង្គិយបញ្ហា ទ្រង់ធ្វើទីបំផុត ធ្វើទីបំផុតជុំវិញ ធ្វើការកំណត់ ធ្វើផ្លូវជុំវិញ នៃសក្កបញ្ហា អមនុស្សបញ្ហា ភិក្ខុបញ្ហា ភិក្ខុនីបញ្ហា ឧបាសកបញ្ហា ឧបាសិកាបញ្ហា រាជបញ្ហា ខត្តិយបញ្ហា ព្រាហ្មណបញ្ហា វេស្សបញ្ហា សុទ្ទបញ្ហា ព្រហ្មបញ្ហា ហេតុនោះ (លោកពោលថា) ទ្រង់ធ្វើនូវទីបំផុតនៃបញ្ហាទាំងឡាយ ។ ពាក្យថា ព្រះសាស្តា បានន័យថា ព្រះមានព្រះភាគ ទ្រង់ជាអ្នកនាំពួក ។ អ្នកនាំពួក ញុំាំងពួកឲ្យឆ្លងផ្លូវលំបាក គឺឲ្យឆ្លងផ្លូវលំបាកគឺចោរ ឲ្យឆ្លងផ្លូវលំបាកគឺសត្វសាហាវ ឲ្យឆ្លងផ្លូវលំបាកគឺទុរ្ភិក្ស ឲ្យឆ្លង ឲ្យឆ្លងឡើង ឲ្យឆ្លងចេញអំពីផ្លូវលំបាកគឺមិនមានទឹក ឲ្យដល់ខេមន្តភូមិ

## សោឡសមាណវកបញ្ហានិគមនិទ្ទេសោ

ភគវា សត្ថវាហោ សត្តេ កន្តារំ តារេតិ ជាតិជរាព្យា-
ធិមរណសោកបរិទេវទុក្ខទោមនស្សុបាយាសកន្តារំ
តារេតិ រាគកន្តារំ តារេតិ ទោសមោហមានទិដ្ឋិកិលេ-
សទុច្ចរិតកន្តារំ តារេតិ រាគគហនំ តារេតិ ទោសគ-
ហនំ តារេតិ មោហគហនំ តារេតិ ទិដ្ឋិកិលេសទុច្ចរិ-
តគហនំ តារេតិ ឧត្តារេតិ និត្តារេតិ ខេមន្តភូមឹ អមតំ
និព្វានំ សម្បាបេតីតិ ឯវំ ភគវា សត្ថវាហោ ។ អថវា
ភគវា នេតា វិនេតា អនុនេតា សញ្ញាបេតា និជ្ឈា-
បេតា បេក្ខេតា បសាទេតាតិ ឯវម្បិ ភគវា សត្ថ-
វាហោ ។ អថវា ភគវា អនុប្បន្នស្ស មគ្គស្ស ឧប្បា-
ទេតា អសញ្ជាតស្ស មគ្គស្ស សញ្ជនេតា អនក្ខាត-
ស្ស មគ្គស្ស អក្ខាតា មគ្គញ្ញូ មគ្គវិទូ មគ្គកោវិ-
ទោ មគ្គានុគា ច បន ឯតរហិ សាវកា វិហរន្តិ
បច្ឆា សមន្នាគតាតិ ឯវម្បិ ភគវា សត្ថវាហោតិ
បជ្ជោតករោ សត្ថា ។

## សោឡសមាណវកប្បញ្ហានិទ្ទេស

យ៉ាងណា ព្រះមានព្រះភាគ ទ្រង់ជាអ្នកនាំពួក ញ៉ាំងសត្វឲ្យឆ្លងផុតលំបាក គឺ ឲ្យឆ្លងផុតលំបាក គឺ ជាតិ ជរា ព្យាធិ មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ និងឧបាយាសៈ ឲ្យឆ្លងផុតលំបាក គឺរាគៈ ឲ្យឆ្លងផុតលំបាក គឺទោសៈ មោហៈ មានៈ ទិដ្ឋិ កិលេស ទុច្ចរិត ឲ្យឆ្លងព្រៃស្បាត គឺរាគៈ ឲ្យឆ្លងព្រៃស្បាត គឺទោសៈ ឲ្យឆ្លងព្រៃស្បាត គឺមោហៈ ឲ្យឆ្លង ឲ្យឆ្លងឡើង ឲ្យឆ្លងចេញអំពីព្រៃស្បាត គឺទិដ្ឋិ កិលេស និងទុច្ចរិត ឲ្យដល់ខេមន្តភូមិ គឺអមតនិព្វាន ក៏យ៉ាងនោះដែរ ហេតុនោះ ព្រះមានព្រះភាគ ឈ្មោះថាជាអ្នកនាំពួក យ៉ាងនេះ ។ មួយទៀត ព្រះមានព្រះភាគ ទ្រង់នាំ ទូន្មាន ទូន្មានរឿយ ៗ ទ្រង់ឲ្យយល់ ឲ្យចូលចិត្ត ឲ្យឃើញ ឲ្យជ្រះថ្លា ហេតុនោះ ព្រះមានព្រះភាគ ឈ្មោះថាជាអ្នកនាំពួក យ៉ាងនេះក៏បាន ។ ឬថា ព្រះមានព្រះភាគទ្រង់ញ៉ាំងមគ្គដែលមិនទាន់កើតឲ្យកើតបាន ញ៉ាំងមគ្គដែលមិនទាន់កកើតឲ្យកកើតបាន ទ្រង់ប្រាប់មគ្គដែលគេមិនទាន់ប្រាប់ ទ្រង់ជ្រាបមគ្គ ទ្រង់ស្គាល់មគ្គ ទ្រង់ឈ្លាសក្នុងមគ្គ ចំណែកខាងពួកសាវ័ក ក្នុងកាលឥឡូវនេះ ជាអ្នកដើរទៅតាមមគ្គ ជាអ្នកប្រកបក្នុងកាលខាងក្រោយ ហេតុនោះ ព្រះមានព្រះភាគ ឈ្មោះថាជាអ្នកនាំពួក យ៉ាងនេះក៏បាន ហេតុនោះ (លោកពោលថា) ព្រះសាស្តា ទ្រង់ធ្វើទីបំផុត នៃប្រស្នាទាំងឡាយ ។

(២២៨) កង្ខីនំ បដិជានតន្តិ សកង្ខា អាគន្ត្វា និក្កង្ខា សម្បជ្ជន្តិ សលេខា អាគន្ត្វា និល្លេខា សម្បជ្ជន្តិ សទ្វេឡ្ហកា អាគន្ត្វា និទ្វេឡ្ហកា សម្បជ្ជន្តិ សវិចិកិច្ឆា អាគន្ត្វា និព្វិចិកិច្ឆា សម្បជ្ជន្តិ សរាគា អាគន្ត្វា វីតរាគា សម្បជ្ជន្តិ សទោសា អាគន្ត្វា វីតទោសា សម្បជ្ជន្តិ សមោហា អាគន្ត្វា វីតមោហា សម្បជ្ជន្តិ សកិលេសា អាគន្ត្វា និក្កិលេសា សម្បជ្ជន្តីតិ កង្ខីនំ បដិជានតំ ។ តេនាហ បិង្គិយត្ថេរោ

អនេជោ អភិញ្ញាយ សត្ថា វេទិ បរោវរំ

បញ្ហានន្តករោ សត្ថា កង្ខីនំ បដិជានតន្តិ ។

(៦៦៩) ពាក្យថា ដល់ពួកជនអ្នកសង្ស័យ ដែលប្ដេជ្ញា (ថាជាអ្នកអស់សង្ស័យ) អធិប្បាយថា ជនទាំងឡាយ ដែលមានសេចក្ដីងឿងឆ្ងល់ មកសម្រេចថា ជាអ្នកមិនមានសេចក្ដីងឿងឆ្ងល់ អ្នកដែលមានចិត្តរសេមរសាម មកសម្រេចថា ជាអ្នកមានចិត្តមិនរសេមរសាម អ្នកដែលមានចិត្តបែកជាពីរ មកសម្រេចថា ជាអ្នកមានចិត្តមិនបែកជាពីរ អ្នកដែលមានសេចក្ដីស្ទាក់ស្ទើរ មកសម្រេចថា ជាអ្នកមិនមានសេចក្ដីស្ទាក់ស្ទើរ អ្នកដែលមានរាគៈ មកសម្រេចថា ជាអ្នកមិនមានរាគៈ អ្នកដែលមានទោសៈ មកសម្រេចថា ជាអ្នកមិនមានទោសៈ អ្នកដែលមានមោហៈ មកសម្រេចថា ជាអ្នកមិនមានមោហៈ អ្នកដែលមានកិលេស មកសម្រេចថា ជាអ្នកមិនមានកិលេស ហេតុនោះ (លោកពោលថា) ដល់ពួកជនអ្នកសង្ស័យ ដែលប្ដេជ្ញា (ថាជាអ្នកអស់សង្ស័យ) ។ ហេតុនោះ ព្រះបិង្គិយត្ថេរពោលថា

ព្រះសាស្ដា ទ្រង់ជ្រាបច្បាស់នូវអធិទេវតាទាំងឡាយ ទ្រង់
ជ្រាបនូវធម្មជាត ទាំងអស់ ដែលថោកទាបនឹងប្រសើរ ទ្រង់
ធ្វើទីបំផុត នៃប្រស្នាទាំងឡាយ ដល់ពួកជនអ្នកសង្ស័យ
ដែលប្ដេជ្ញា (ថាជាអ្នកអស់សង្ស័យ) ។

(២២៦) អសំហិរំ អសង្កុប្បំ យស្ស នត្ថិ ឧបមា ក្វចិ

អទ្ធា គមិស្សាមិ ន មេត្ថ កង្ខា

ឯវំ មំ ធារេហិ អធិមុត្តចិត្តំ ។

(២២៧) អសំហិរំ អសង្កុប្បន្តិ អសំហិរំ វុច្ចតិ អមតំ និព្វានំ យោ សោ សព្វសង្ខារសមថោ សព្វូបធិបដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានំ ។ អសំហិរន្តិ រាគេន ទោសេន មោហេន កោធេន ឧបនាហេន មក្ខេន បឡាសេន ឥស្សាយ មច្ឆរិយេន មាយាយ សាឋេយ្យេន ថម្ភេន សារម្ភេន មានេន អតិមានេន មទេន បមាទេន សព្វកិលេសេហិ សព្វទុច្ចរិតេហិ សព្វបរិឡាហេហិ(១) សព្វសន្តាបេហិ សព្វាកុសលាភិសង្ខារេហិ អសំហារិយំ(២) និច្ចំ ធុវំ សស្សតំ អវិបរិណាមធម្មំ អសំហិរំ ។

---

១ ម. ឯត្ថន្តរេ សព្វាសវេហិ សព្វទរថេហីតិ ទិស្សតិ ។ ២ ម. និព្វានំ ។

(២២៦) ទីណា ដែលកិលេសនាំទៅមិនបាន ដែលមិនកម្រើក មួយទៀត ទីណា ដែលមិនមានឧបមាក្នុងឋានណាមួយ ខ្ញុំនឹងទៅកាន់ទីនោះដោយពិត ខ្ញុំមិនមានសេចក្តីងឿងឆ្ងល់ក្នុងទីនោះទេ សូមព្រះអង្គចាំទុក នូវខ្ញុំព្រះអង្គ ថាជាអ្នកមានចិត្តចុះស៊ប់ហើយ យ៉ាងនេះចុះ ។

(២២៧) ពាក្យថា ទីណា ដែលកិលេសនាំទៅមិនបាន ដែលមិនកម្រើក អធិប្បាយថា អមតនិព្វាន ហៅថា ទីដែលកិលេសនាំទៅមិនបាន បានដល់ការរម្ងាប់សង្ខារទាំងពួង ការរលាស់ចោលឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាករាគៈ សេចក្តីរលត់ទុក្ខ និព្វាន ។ ត្រង់ពាក្យថា ដែលកិលេសនាំទៅមិនបាន គឺ ដែលរាគៈ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ កិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្តីក្តៅក្រហាយទាំងពួង សេចក្តីអន្ទះអន្ទែងទាំងពួង អកុសលាភិសង្ខារទាំងពួង នាំទៅមិនបាន គឺថាជាទីទៀង ទៀងទាត់ ពិតប្រាកដ មិនប្រែប្រួលជាធម្មតា ហេតុនោះ (លោកពោលថា) ដែលកិលេសនាំទៅមិនបាន ។

អសង្កុប្បន្តិ អសង្កុប្បំ វុច្ចតិ អមតំ និព្វានំ យោ សោ សព្វសង្ខារសមថោ សព្វុបធិបដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានំ ។ យស្ស ឧប្បាទោ(១) បញ្ញាយតិ វយោ នត្ថិ តស្ស អញ្ញ-ថត្ត(២) បញ្ញាយតិ និព្វានំ និច្ចំ ធុវំ សស្សតំ អវិបរិណាមធម្មន្តិ អសំហីរំ អសង្កុប្បំ ។

(២២៨) យស្ស នត្ថិ ឧបមា ក្វចីតិ យស្សាតិ និព្វានស្ស ។ នត្ថិ ឧបមាតិ ឧបមា នត្ថិ ឧបនិធា នត្ថិ សទិសំ នត្ថិ បដិភាគោ នត្ថិ ន សំវិជ្ជតិ នុប-លព្ភតីតិ នត្ថិ ឧបមា ។ ក្វចីតិ ក្វចិ កិម្ហិចិ កត្ថ-ចិ អជ្ឈត្តំ វា ពហិទ្ធា វា អជ្ឈត្តពហិទ្ធា វាតិ យស្ស នត្ថិ ឧបមា ក្វចិ ។

---

១ ម. និព្វានស្ស ន ឧប្បាទោ ។ ២ ម. អញ្ញថត្តំ ។

ត្រង់ពាក្យថា មិនកម្រើក សេចក្តីថា អមតនិព្វាន ហៅថា ទីមិនកម្រើក បានដល់ ការរម្ងាប់សង្ខារទាំងពួង ការលះបង់ចោលឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាករាគៈ សេចក្តីរលត់ និព្វាន ។ ការកើតឡើងនៃធម្មជាតណា ប្រាកដ ការវិនាសនៃធម្មជាតណា មិនមាន ការពិតនៃធម្មជាតនោះ ក៏រមែងប្រាកដ គឺថា ព្រះនិព្វាន ទៀង ជាធម្មជាតទៀងទាត់ ពិតប្រាកដ មិនប្រែប្រួលជាធម្មតា ហេតុនោះ (លោកពោលថា) ទីណា ដែលកិលេសនាំទៅមិនបាន ដែលមិនកម្រើក ។

(២២៨) អធិប្បាយពាក្យថា ទីណាដែលមិនមានឧបមាក្នុងឋានណាមួយ ត្រង់ពាក្យថា ទីណា បានដល់និព្វាន ។ ពាក្យថា មិនមានឧបមា គឺមិនមានសេចក្តីប្រៀបផ្ទឹម មិនមានការប្រៀបធៀប មិនមានភាពស្មើគ្នា មិនមាន មិនមានព្រម មិនហ៊ាននូវចំណែកប្រៀប ហេតុនោះ (លោកពោលថា) មិនមានឧបមា ។ ពាក្យថា ក្នុងឋានណាមួយ គឺ ក្នុងទីណាមួយ ក្នុងទីដូចម្តេច ក្នុងទីណា ជាខាងក្នុងឬខាងក្រៅ ឬទាំងខាងក្នុងទាំងខាងក្រៅ ហេតុនោះ (លោកពោលថា) ទីណា ដែលមិនមានឧបមាក្នុងឋានណាមួយ ។

សោឡសមាណវកបញ្ហានិគមនិទ្ទេសោ

(២២៩) អទ្ធា គមិស្សាមិ ន មេត្ថ កង្ខាមិ អទ្ធា គមិស្សាមីតិ អទ្ធា គមិស្សាមិ អធិគមិស្សាមិ ផុស្សយិស្សាមិ សច្ឆិករិស្សាមីតិ អទ្ធា គមិស្សាមិ(១) ។ ន មេត្ថ កង្ខាមិ ឯត្ថ និព្វានេ កង្ខា នត្ថិ វិចិកិច្ឆា នត្ថិ ទ្វេឡ្ហកំ នត្ថិ សំសយោ នត្ថិ ន សំវិជ្ជតិ នុបលព្ភតិ បហីនោ សមុច្ឆិន្នោ វូបសន្តោ បដិប្បស្សទ្ធោ អភព្វុប្បត្តិកោ ញាណគ្គិនា ទឌ្ឍោតិ អទ្ធា គមិស្សាមិ ន មេត្ថ កង្ខា ។

---

១ ម. អទ្ធាតិ ឯកំសវចនំ និស្សំសយវចនំ និក្កង្ខវចនំ អទ្វេជ្ឈវចនំ អទ្វេឡ្ហកវចនំ និយោគវចនំ អបណ្ណកវចនំ អវិរុទ្ធវចនំ អវត្ថាបនវចនមេតំ អទ្ធាតិ គមិស្សាមីតិ គមិស្សាមិ អធិគមិស្សាមិ ផស្សយិស្សាមិ សច្ឆិករិស្សាមីតិ អទ្ធា គមិស្សាមិ ។

## សោឡសមាណវកបញ្ហានិគមនិទ្ទេស

(២៦៩) អធិប្បាយពាក្យថា ខ្ញុំនឹងទៅកាន់ទីនោះដោយពិត ខ្ញុំមិនមានសេចក្តីងឿងឆ្ងល់ក្នុងទីនោះទេ ត្រង់ពាក្យថា ខ្ញុំនឹងទៅដោយពិត គឺ ខ្ញុំនឹងដើរទៅ នឹងបាន នឹងពាល់ត្រូវ នឹងធ្វើឲ្យជាក់ច្បាស់ដោយពិត ហេតុនោះ (លោកពោលថា) ខ្ញុំនឹងទៅដោយពិត ៗ ពាក្យថា ខ្ញុំមិនមានសេចក្តីងឿងឆ្ងល់ក្នុងទីនោះទេ គឺ សេចក្តីងឿងឆ្ងល់មិនមាន ការស្ទាក់ស្ទើរមិនមាន ការគិតបែកជាពីរមិនមាន ការសង្ស័យ មិនមាន មិនមានព្រម មិនកើតមានក្នុងនិព្វាននោះទេ គឺថា ខ្ញុំលះបង់ ផ្តាច់ផ្តិល រម្ងាប់ គ្របសង្កត់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ(លោកពោលថា) ខ្ញុំនឹងទៅកាន់ទីនោះដោយពិត ខ្ញុំមិនមានសេចក្តីងឿងឆ្ងល់ក្នុងទីនោះទេ ៗ

(២៣០) ឯវំ មំ ធារេហិ អធិមុត្តចិត្តន្តិ ឯវំ មំ ធារេហីតិ ឯវំ មំ ឧបលក្ខេហិ ។ អធិមុត្តចិត្តន្តិ និព្វាននិន្នំ និព្វានពោណំ និព្វានបព្ភារំ និព្វានាធិមុត្តំ ឯវំ មំ ធារេហិ អធិមុត្តចិត្តំ ។ តេនាហ បិង្គិយត្ថេរោ

អសំហីរំ អសង្កុប្បំ យស្ស នត្ថិ ឧបមា ក្វចិ

អទ្ធា គមិស្សាមិ ន មេត្ថ កង្ខា

ឯវំ មំ ធារេហិ អធិមុត្តចិត្តន្តិ ។

បារាយនវគ្គោ និដ្ឋិតោ ។

(២៣០) ពាក្យថា សូមព្រះអង្គចាំទុក នូវខ្ញុំព្រះអង្គ ថាជាអ្នកមានចិត្តចុះស៊ប់ហើយយ៉ាងនេះចុះ ត្រង់ពាក្យថា សូមព្រះអង្គចាំទុកនូវខ្ញុំព្រះអង្គយ៉ាងនេះ គឺ សូមព្រះអង្គកំណត់ទុក នូវខ្ញុំព្រះអង្គ យ៉ាងនេះ ។ ពាក្យថា មានចិត្តចុះស៊ប់ហើយ គឺ មានចិត្តទេរទៅរកព្រះនិព្វាន ទោរទៅរកព្រះនិព្វាន ឈមទៅរកព្រះនិព្វាន ឱនទៅរកព្រះនិព្វាន ហេតុនោះ (លោកពោលថា) សូមព្រះអង្គចាំទុក នូវខ្ញុំព្រះអង្គ ថាជាអ្នកមានចិត្តចុះស៊ប់ហើយ យ៉ាងនេះចុះ ។ ហេតុនោះ ព្រះបិង្គិយត្ថេរពោលថា

ទីណា ដែលកិលេសនាំទៅមិនបាន ដែលមិនកម្រើក
មួយទៀត ទីណា ដែលមិនមានឧបមាក្នុងឋានណាមួយ
ខ្ញុំនឹងទៅកាន់ទីនោះដោយពិត ខ្ញុំមិនមានសេចក្តីសង្ស័យក្នុង
ក្នុងទីនោះទេ សូមព្រះអង្គចាំទុក នូវខ្ញុំព្រះអង្គ ថាជាអ្នក
មានចិត្តចុះស៊ប់ហើយ យ៉ាងនេះចុះ ។

ចប់ បារាយនវគ្គ ។

# ខគ្គវិសាណសុត្តនិទ្ទេសោ

(២៣១) សព្វេសុ ភូតេសុ និធាយ ទណ្ឌំ
អហេឋយំ(១) អញ្ញតរម្បិ តេសំ
ន បុត្តមិច្ឆេយ្យ កុតោ សហាយំ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

(២៣២) សព្វេសុ ភូតេសុ និធាយ ទណ្ឌន្តិ សព្វេសូតិ សព្វេន សព្វំ សព្វថា សព្វំ អសេសំ និស្សេសំ បរិយាទាយវចនមេតំ សព្វេសូតិ ។ ភូតេសូតិ ភូតា វុច្ចន្តិ តសា ច ថាវរា ច ។ តសាតិ យេសំ តណ្ហា(២) អប្បហីនា យេសញ្ច ភយភេរវា អប្បហីនា ។ កិំការណា វុច្ចន្តិ តសា ។ តេ តសន្តិ ឧត្តសន្តិ បរិតសន្តិ សន្តាសំ អាបជ្ជន្តិ តំការណា វុច្ចន្តិ តសា ។ ថាវរាតិ យេសំ តណ្ហា បហីនា យេសញ្ច ភយភេរវា បហីនា ។ កិំការណា វុច្ចន្តិ ថាវរា ។ តេ ន តសន្តិ ន ឧត្តសន្តិ ន បរិតសន្តិ ន សន្តាសំ អាបជ្ជន្តិ តំការណា វុច្ចន្តិ ថាវរា ។

---

១ ម. អវិហេឋយំ ។ ២ ម. យេសំ តសិតតណ្ហា ។

# ខគ្គវិសាណសុត្តនិទ្ទេស

[២៣១] (ព្រះបច្ចេកពុទ្ធត្រាស់ថា) បុគ្គលទម្លាក់ចេញនូវអាជ្ញា ចំពោះពួកសត្វទាំងពួង មិនបៀតបៀននូវសត្វទាំងនោះ សូម្បីសត្វណាមួយ គេមិនបង់បាទបុត្រទៅហើយ តើនឹងប្រាថ្នាសំឡាញ់អំពីណាកើត បុគ្គលនោះតែងប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[២៣២] អធិប្បាយពាក្យថា បុគ្គលទម្លាក់ចេញនូវអាជ្ញាចំពោះពួកសត្វទាំងពួង ត្រង់ពាក្យថា ទាំងពួង គឺ គ្រប់ទាំងអស់ សព្វទាំងអស់ មិនសល់ ឥតសល់ ពាក្យថា ទាំងពួង នុ៎ះ ជាពាក្យពោលរួប ។ ពាក្យថា ពួកសត្វ សេចក្តីថា ពួកសត្វតក់ស្លុត នឹងពួកសត្វនឹងនួន ហៅថា ពួកសត្វ ។ ពាក្យថា ពួកសត្វតក់ស្លុត បានខាងពួកសត្វ មិនទាន់លះបង់តណ្ហា នឹងពួកសត្វ មិនទាន់លះបង់ភ័យដែលគួរខ្លាច ។ ដែលលោកពោលថា ពួកសត្វតក់ស្លុត តើព្រោះហេតុដូចម្តេច ។ សត្វទាំងនោះរមែងតក់ស្លុត ញ័រចំប្រប់ ញាប់ញ័រ ដល់នូវសេចក្តីតក់ស្លុត ព្រោះហេតុនោះ លោកពោលថា ពួកសត្វតក់ស្លុត ។ ពាក្យថា ពួកសត្វនឹងនួន បានខាងពួកសត្វ លះបង់តណ្ហាហើយ នឹងពួកសត្វលះបង់ភ័យដែលគួរខ្លាច ។ ដែលលោកពោលថា ពួកសត្វនឹងនួន តើព្រោះហេតុ ដូចម្តេច ។ សត្វទាំងនោះមិនតក់ស្លុត មិនញ័រចំប្រប់ មិនញាប់ញ័រ មិនដល់នូវសេចក្តីតក់ស្លុត ព្រោះហេតុនោះ លោកពោលថា ពួកសត្វនឹងនួន ។

ឧណ្ហាតិ តយោ ឧណ្ហា កាយឧណ្ហា ច វចីឧណ្ហា ច មនោឧណ្ហា ច ។ តិវិធំ កាយទុច្ចរិតំ កាយឧណ្ហា ចតុព្វិធំ វចីទុច្ចរិតំ វចីឧណ្ហា តិវិធំ មនោទុច្ចរិតំ មនោឧណ្ហា ។ សព្ពេសុ ភវេសុ និព្ពាយ ឧណ្ហន្តិ សព្ពេសុ ភវេសុ ឧណ្ហំ និព្ពាយ និទហិត្វា ឱរោបយិត្វា(១) និក្ខិបិត្វា បដិប្បស្សម្ភិត្វាតិ សព្ពេសុ ភវេសុ និព្ពាយ ឧណ្ហំ ។

(២៣៣) អហេឋយំ អញ្ញតរម្បិ តេសន្តិ ឯកមត្តម្បិ(២) សត្តំ បាណិនា វា លេឌ្ឌុនា វា ទណ្ឌេន វា សត្ថេន វា អន្ទុយា(៣) វា រជ្ជុយា វា អវិហេឋយន្តោ សព្ពេបិ សត្តេ បាណិនា វា លេឌ្ឌុនា វា ទណ្ឌេន វា សត្ថេន វា អន្ទុយា វា រជ្ជុយា វា អវិហេឋយន្តោតិ អហេឋយំ អញ្ញតរម្បិ តេសំ ។

---

១ ម. ឱរោបយិត្វា សមោរោបយិត្វា ។ ២ ម. ឯកមេកម្បិ ។ ៣ ម. អទ្ទុយា ។

ពាក្យថា អាជ្ញា បានដល់អាជ្ញា ៣ គឺ អាជ្ញាគឺកាយ ១ អាជ្ញាគឺវាចា ១ អាជ្ញាគឺចិត្ត ១ ។ កាយទុច្ចរិត ៣ ឈ្មោះថាអាជ្ញាគឺកាយ វចីទុច្ចរិត ៤ ឈ្មោះថាអាជ្ញាគឺវាចា មនោទុច្ចរិត ៣ ឈ្មោះថាអាជ្ញាគឺចិត្ត ។ ពាក្យថា បុគ្គលទម្លាក់ចេញ នូវអាជ្ញា ចំពោះពួកសត្វទាំងពួង បានសេចក្តីថា បុគ្គលទម្លាក់ចេញ ដាក់ចេញ បោះបង់ លះបង់ចោល ទម្លាប់ នូវអាជ្ញា ចំពោះពួកសត្វទាំងពួង ហេតុនោះ (លោកពោលថា) បុគ្គលទម្លាក់ចេញនូវអាជ្ញា ចំពោះពួកសត្វទាំងពួង ។

(៦៣៣) ត្រង់ពាក្យថា មិនបៀតបៀននូវសត្វទាំងនោះ សូម្បីសត្វណាមួយ គឺ មិនបៀតបៀននូវសត្វសូម្បីតែមួយ ដោយដៃក្តី ដោយដុំដីក្តី ដោយដំបងក្តី ដោយសស្ត្រាក្តី ដោយពួរក្តី ដោយខ្សែក្តី មិនបៀតបៀននូវពួកសត្វទាំងអស់ ដោយដៃក្តី ដោយដុំដីក្តី ដោយដំបងក្តី ដោយសស្ត្រាក្តី ដោយពួរក្តី ដោយខ្សែក្តី ហេតុនោះ (លោកពោលថា) មិនបៀតបៀននូវសត្វទាំងនោះ សូម្បីសត្វណាមួយ ។

## ខគ្គវិសាណសុត្តនិទ្ទេសោ

[២៣៤] ន បុត្តមិច្ឆេយ្យ កុតោ សហាយន្តិ ជាតិ បដិក្ខេបោ ។ បុត្តាតិ ចត្តារោ បុត្តា អត្រជោ បុត្តោ ខេត្តជោ បុត្តោ ទិន្នកោ បុត្តោ អន្តេវាសិកោ បុត្តោ ។ សហាយន្តិ[១] សហាយា វុច្ចន្តិ យេហិ សហ គមនំ ផាសុ អាគមនំ ផាសុ គមនាគមនំ ផាសុ និសជ្ជំ ផាសុ និបជ្ជំ ផាសុ អាលបនំ ផាសុ សល្លបនំ ផាសុ សមុល្លបនំ ផាសុ ។ ន បុត្តមិច្ឆេយ្យ កុតោ សហាយន្តិ បុត្តម្បិ ន ឥច្ឆេយ្យ ន សាទិយេយ្យ[២] ន បិហាយេយ្យ នាភិជប្បេយ្យ កុតោ មិត្តំ វា សន្ទិដ្ឋំ វា សម្ភត្តំ វា សហាយំ វា ឥច្ឆិស្សតិ សាទិយិស្សតិ បិហាយិស្សតិ អភិជប្បិស្សតីតិ[៣] ន បុត្តមិច្ឆេយ្យ កុតោ សហាយំ ។

---

១ ម. សហាយន្តិ នត្ថិ ។ ២ ម. ន សាទិយេយ្យ ន បត្ថយេយ្យ ។ ៣ ម. ឥច្ឆេយ្យ សាទិយេយ្យ បត្ថយេយ្យ បិហយេយ្យ អភិជប្បេយ្យាតិ ។

## ខគ្គវិសាណសុត្តនិទ្ទេស

(២៣៤) អធិប្បាយពាក្យថា មិនចង់បានបុត្រទៅហើយ តើនឹងប្រាថ្នាសំឡាញ់អំពីណាកើត ត្រង់ពាក្យថា មិន គឺជាពាក្យបដិសេធ ។ ពាក្យថា បុត្រ បានដល់បុត្រ ៤ គឺ បុត្រកើតអំពីខ្លួន១ បុត្រកើតអំពីខេត្រ១ បុត្រដែលគេឲ្យ១ បុត្រគឺសិស្ស១ ។ ពាក្យថា សំឡាញ់ សេចក្តីថា ការទៅសប្បាយ ការមកសប្បាយ ការទៅមកសប្បាយ ការអង្គុយសប្បាយ ការដេកសប្បាយ ការហៅរកសប្បាយ ការនិយាយសប្បាយ ការនិយាយឆ្លើយឆ្លងរកគ្នាសប្បាយ ជាមួយនឹងពួកជនណា ពួកជននោះ លោកហៅថា សំឡាញ់ ។ ពាក្យថា មិនចង់បានបុត្រទៅហើយ តើនឹងប្រាថ្នាសំឡាញ់អំពីណាកើត បានសេចក្តីថា មិនប្រាថ្នា មិនត្រេកអរ មិនស្រឡាញ់ មិនជាប់ចំពាក់ សូម្បីនូវបុត្រទៅហើយ តើនឹងប្រាថ្នា នឹងត្រេកអរ នឹងស្រឡាញ់ នឹងជាប់ចំពាក់ ចំពោះមិត្តក្តី ចំពោះជនដែលធ្លាប់ឃើញគ្នាក្តី ចំពោះមិត្រធ្លាប់បរិភោគរួមគ្នាក្តី ចំពោះសំឡាញ់ក្តី អំពីណាកើត ហេតុនោះ (លោកពោលថា) មិនចង់បានបុត្រទៅហើយ តើនឹងប្រាថ្នាសំឡាញ់អំពីណាកើត ។

(២៣៥) ឯកោ ចរេ ខគ្គវិសាណកប្បោតិ ឯកោតិ សោ បច្ចេកសម្ពុទ្ធោ បព្វជ្ជាសង្ខាតេន ឯកោ អទុតិយដ្ឋេន ឯកោ តណ្ហាបហានដ្ឋេន ឯកោ ឯកន្តវីតរាគោតិ ឯកោ ឯកន្តវីតទោសោតិ ឯកោ ឯកន្តវីតមោហោតិ ឯកោ ឯកន្តនិក្កិលេ-សោតិ ឯកោ ឯកាយនមគ្គំ គតោតិ ឯកោ ឯកោ អនុត្តរំ បច្ចេកសម្ពោធឹ អភិសម្ពុទ្ធោតិ ឯកោ ។

កថំ សោ បច្ចេកសម្ពុទ្ធោ បព្វជ្ជាសង្ខាតេន ឯកោ ។ សោ បច្ចេកសម្ពុទ្ធោ ឃរាវាសបលិពោ-ធំ(១) ឆិន្ទិត្វា បុត្តទារបលិពោធំ ឆិន្ទិត្វា ញាតិបលិ-ពោធំ ឆិន្ទិត្វា សន្និធិបលិពោធំ ឆិន្ទិត្វា កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារ-ស្មា អនគារិយំ បព្វជិត្វា អកិញ្ចនភាវំ ឧបគន្ត្វា ឯកោ ចរតិ វិហរតិ ឥរិយតិ វត្តេតិ បាលេតិ យបេតិ យាបេតីតិ ឯវំ សោ បច្ចេកសម្ពុទ្ធោ បព្វជ្ជាសង្ខាតេន ឯកោ ។

---

១ ម. សព្វឃរាវាសបលិពោធំ ។

(៦៣៩) អធិប្បាយពាក្យថា គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ត្រង់ពាក្យថា ម្នាក់ឯង គឺ ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះចំណែកបព្វជ្ជា ជាបុគ្គលម្នាក់ឯង ព្រោះអត្ថថាមិនមានបុគ្គលជាគំរប់ពីរ ជាបុគ្គលម្នាក់ឯង ព្រោះអត្ថថាលះបង់តណ្ហា ជាបុគ្គលម្នាក់ឯង ព្រោះហេតុប្រាសចាករាគៈដោយដាច់ខាត ជាបុគ្គលម្នាក់ឯង ព្រោះហេតុប្រាសចាកទោសៈដោយដាច់ខាត ជាបុគ្គលម្នាក់ឯង ព្រោះហេតុប្រាសចាកមោហៈដោយដាច់ខាត ជាបុគ្គលម្នាក់ឯង ព្រោះហេតុមិនមានកិលេសដោយដាច់ខាត ជាបុគ្គលម្នាក់ឯង ព្រោះហេតុទៅកាន់ផ្លូវជាទីទៅតែម្នាក់ឯង ជាបុគ្គលម្នាក់ឯង ព្រោះហេតុត្រាស់ដឹងនូវបច្ចេកសម្ពោធិដ៏ប្រសើរ តែម្នាក់ឯង ។

ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថាជាបុគ្គលម្នាក់ឯង ព្រោះចំណែកបព្វជ្ជា តើដូចម្តេច ។ ព្រះបច្ចេកសម្ពុទ្ធនោះ ទ្រង់កាត់បលិពោធក្នុងឃរាវាស កាត់បលិពោធក្នុងបុត្តនិងភរិយា កាត់បលិពោធក្នុងញាតិ កាត់បលិពោធក្នុងការសន្សំ កោរសក់ពុកមាត់និងពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ដល់នូវភាពមិនមានកង្វល់ ជាបុគ្គលម្នាក់ឯង ចរទៅ ត្រាច់ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថាជាបុគ្គលម្នាក់ឯង ព្រោះចំណែកបព្វជ្ជា យ៉ាងនេះ ។

ខគ្គវិសាណសុត្តនិទ្ទេសោ

កថំ សោ បច្ចេកសម្ពុទ្ធោ អទុតិយដ្ឋេន ឯកោ ។ សោ ឯវំ បព្វជិតោ សមានោ ឯកោ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវតិ អប្បសទ្ទានិ អប្បនិគ្ឃោសានិ វិជនវាតានិ មនុស្ស-រាហសេយ្យកានិ បដិសល្លានសារុប្បានិ សោ ឯកោ គច្ឆតិ ឯកោ តិដ្ឋតិ ឯកោ និសីទតិ ឯកោ សេយ្យំ កប្បេតិ ឯកោ គាមំ បិណ្ឌាយ បវិសតិ ឯកោ បដិក្កមតិ ឯកោ រហោ និសីទតិ ឯកោ ចង្កមំ អធិដ្ឋាតិ ឯកោ ចរតិ វិហរតិ ឥរិយតិ វត្តតិ ចាលេតិ យបេតិ យាបេតីតិ ឯវំ សោ បច្ចេកសម្ពុទ្ធោ អទុតិយដ្ឋេន ឯកោ ។

កថំ សោ បច្ចេកសម្ពុទ្ធោ តណ្ហាបហានដ្ឋេន ឯកោ ។ សោ ឯវំ ឯកោ អទុតិយោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ មហាបធានំ បទហន្តោ មារំ សសេនំ នមុចឹ បមត្តពន្ធុំ វិធមិត្វា តណ្ហំ ជាលិនឹ សរិតំ វិសត្តិកំ បជហិ វិនោទេសិ ព្យន្តីម-កាសិ អនភាវង្គមេសិ ។

## ខគ្គវិសាណសុត្តនិទ្ទេស

ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះអត្ថថាមិនមានបុគ្គលជាគំរប់ពីរ តើដូចម្តេច ។ ព្រះបច្ចេកសម្ពុទ្ធនោះ កាលបួសយ៉ាងនេះហើយ ជាបុគ្គលម្នាក់ឯង គប់រកសេនាសនៈ ដ៏ស្ងាត់ គឺព្រៃរបោះ នឹងព្រៃញាតស្បាត ជាទីមិនមានសំឡេង មិនមានសំឡេងគឹកកង ប្រាសចាកខ្យល់ដែលកើតអំពីសរីរៈមនុស្ស ជាទីស្ងាត់កំបាំងរបស់មនុស្ស សមគួរដល់ទីពួនសម្ងំ លោកដើរទៅម្នាក់ឯង ឈរនៅម្នាក់ឯង អង្គុយម្នាក់ឯង សម្រេចសេយ្យាម្នាក់ឯង ចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាតម្នាក់ឯង ត្រឡប់មកវិញម្នាក់ឯង អង្គុយក្នុងទីស្ងាត់ម្នាក់ឯង អធិដ្ឋានចង្ក្រមម្នាក់ឯង ចរ ត្រាច់ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅតែម្នាក់ឯង ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថាជាបុគ្គលម្នាក់ឯង ព្រោះអត្ថថាមិនមានបុគ្គលជាគំរប់ពីរ យ៉ាងនេះ ។

ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះអត្ថថាលះបង់តណ្ហា តើដូចម្តេច ។ ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ឥតមានបុគ្គលជាគំរប់ពីរយ៉ាងនេះហើយ ជាអ្នកមិនប្រហែស មានព្យាយាមដុតកំដៅកិលេស មានចិត្តស្លុង (ទៅកាន់ព្រះនិព្វាន) ផ្គងព្យាយាមធំ កំចាត់បង់មារព្រមទាំងសេនានៃមារ ដែលមិនដោះលែង ជាផៅពង្សនៃបុគ្គលប្រហែស គឺថា លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ញុំាងតណ្ហាដូចជាបណ្តាញ ដែលហូរទៅ ផ្សាយទៅ ឲ្យដល់នូវការមិនកើតមាន ។

តណ្ហាទុតិយោ បុរិសោ ទីឃមទ្ធាន សំសរំ

ឥត្ថភាវញ្ញថាភាវំ សំសារំ នាតិវត្តតិ

ឯវមាទីនវំ ញត្វា តណ្ហំ ទុក្ខស្ស សម្ភវំ

វីតតណ្ហោ អនាទានោ សតោ ភិក្ខុ បរិព្វជេតិ ។

ឯវំ សោ បច្ចេកសម្ពុទ្ធោ តណ្ហាបហានេន ឯកោ ។

កថំ សោ បច្ចេកសម្ពុទ្ធោ ឯកន្តវីតរាគោតិ ឯកោ ។ រាគស្ស បហីនត្តា ឯកន្តវីតរាគោតិ ឯកោ ។ ទោសស្ស បហីនត្តា ឯកន្តវីតទោសោតិ ឯកោ ។ មោហស្ស បហីនត្តា ឯកន្តវីតមោហោតិ ឯកោ ។ កិលេសានំ បហីនត្តា ឯកន្តនិក្កិលេសោតិ ឯកោ ។ ឯវំ សោ បច្ចេកសម្ពុទ្ធោ ឯកន្តវីតរាគោតិ ឯកោ ។

បុរសមានតណ្ហាជាគំរប់ពីរ កាលអន្ទោលទៅអស់កាលដ៏វែង
រមែងមិនកន្លងផុតសង្សារ មានភាពបែបនេះ និងភាពដទៃ
ភិក្ខុអ្នកមានសតិ ប្រាសចាកតណ្ហា មិនមានសេចក្តីប្រកាន់
លុះឃើញទោសយ៉ាងនេះហើយ គួរវៀរនូវតណ្ហា ជាដែន
កើតទុក្ខចេញ ។

ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះអត្ថថាលះបង់តណ្ហា យ៉ាងនេះ ។

ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះហេតុប្រាសចាករាគៈដោយដាច់ខាត តើដូចម្តេច ។ ជាបុគ្គលម្នាក់ឯង ព្រោះហេតុប្រាសចាករាគៈដោយដាច់ខាត ព្រោះលោកលះរាគៈហើយ ។ ជាបុគ្គលម្នាក់ឯង ព្រោះហេតុប្រាសចាកទោសៈដោយដាច់ខាត ព្រោះលោកលះទោសៈហើយ ។ ជាបុគ្គលម្នាក់ឯង ព្រោះហេតុប្រាសចាកមោហៈដោយដាច់ខាត ព្រោះលោកលះមោហៈហើយ ។ ជាបុគ្គលម្នាក់ឯង ព្រោះហេតុមិនមានកិលេសដោយដាច់ខាត ព្រោះលោកលះកិលេសទាំងឡាយហើយ ។ ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះហេតុប្រាសចាករាគៈដោយដាច់ខាត យ៉ាងនេះ ។

## ខគ្គវិសាណសុត្តនិទ្ទេសោ

កថំ សោ បច្ចេកសម្ពុទ្ធោ ឯកាយនមគ្គំ គតោតិ ឯកោ ។ ឯកាយនមគ្គោ វុច្ចតិ ចត្តារោ សតិប្បដ្ឋានា ចត្តារោ សម្មប្បធានា ចត្តារោ ឥទ្ធិ-បាទា បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ ។

ឯកាយនំ ជាតិខយន្តទស្សី
មគ្គំ បជានាតិ ហិតានុកម្បី
ឯតេន មគ្គេន តរឹសុ បុព្វេ
តរិស្សន្តិ ចេវ តរន្តិ ឱឃន្តិ ។

ឯវំ សោ បច្ចេកសម្ពុទ្ធោ ឯកាយនមគ្គំ គតោតិ ឯកោ ។

កថំ សោ បច្ចេកសម្ពុទ្ធោ ឯកោ អនុត្តរំ បច្ចេកសម្ពោធឹ អភិសម្ពុទ្ធោតិ ឯកោ ។ ពោធិ វុច្ចតិ ចតូសុ មគ្គេសុ ញាណំ បញ្ញា បញ្ញិន្ទ្រិយំ បញ្ញាពលំ ធម្មវិចយសម្ពោជ្ឈង្គោ វីមំសា វិបស្សនា សម្មាទិដ្ឋិ ។

ខគ្គវិសាណសុត្តនិទ្ទេស

ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះហេតុទៅកាន់ផ្លូវជាទីទៅម្នាក់ឯង តើដូចម្តេច ។ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ លោកហៅថា ផ្លូវជាទីទៅម្នាក់ឯង ។

បុគ្គលអ្នកឃើញទីបំផុតនៃកិរិយាអស់ជាតិ ជាអ្នកអនុគ្រោះនូវ
ប្រយោជន៍ រមែងដឹងច្បាស់នូវផ្លូវជាទីទៅម្នាក់ឯង ពួកអរិយ-
បុគ្គល បានឆ្លងហើយក្នុងអតីតកាលក្តី នឹងឆ្លងក្នុងអនាគត
ក្តី កំពុងឆ្លងក្នុងបច្ចុប្បន្ននេះក្តី នូវឱឃៈ តាមផ្លូវនេះឯង ។

ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះហេតុទៅកាន់ផ្លូវជាទីទៅម្នាក់ឯង យ៉ាងនេះ ។

ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះហេតុត្រាស់ដឹង នូវបច្ចេកសម្ពោធិដ៏ប្រសើរ តែម្នាក់ឯង តើដូចម្តេច ។ ញាណ បញ្ញា បញ្ញិន្ទ្រិយ បញ្ញាពលៈ ធម្មវិចយសម្ពោជ្ឈង្គ វីមំសា វិបស្សនា សម្មាទិដ្ឋិ ក្នុងមគ្គទាំង ៤ លោកហៅថា ពោធិ ។

សោ បច្ចេកសម្ពុទ្ធោ បច្ចេកពុទ្ធញាណេន សច្ចានិ ពុជ្ឈិ សព្វេ សង្ខារា អនិច្ចាតិ ពុជ្ឈិ សព្វេ សង្ខារា ទុក្ខាតិ ពុជ្ឈិ សព្វេ ធម្មា អនត្តាតិ ពុជ្ឈិ អវិជ្ជា-បច្ចយា សង្ខារាតិ ពុជ្ឈិ សង្ខារបច្ចយា វិញ្ញាណន្តិ ពុជ្ឈិ វិញ្ញាណបច្ចយា នាមរូបន្តិ ពុជ្ឈិ នាមរូប-បច្ចយា សឡាយតនន្តិ ពុជ្ឈិ សឡាយតនបច្ចយា ផស្សោតិ ពុជ្ឈិ ផស្សបច្ចយា វេទនាតិ ពុជ្ឈិ វេទនាបច្ចយា តណ្ហាតិ ពុជ្ឈិ តណ្ហាបច្ចយា ឧបាទានន្តិ ពុជ្ឈិ ឧបាទានបច្ចយា ភវោតិ ពុជ្ឈិ ភវបច្ចយា ជាតីតិ ពុជ្ឈិ ជាតិបច្ចយា ជរាមរណន្តិ ពុជ្ឈិ អវិជ្ជានិរោធា សង្ខារនិរោធោតិ ពុជ្ឈិ

ព្រះបច្ចេកសម្ពុទ្ធនោះ ត្រាស់ដឹងហើយនូវសច្ចៈទាំងឡាយ ដោយបច្ចេកពុទ្ធញាណ ត្រាស់ដឹងហើយថា សង្ខារទាំងពួងមិនទៀង ត្រាស់ដឹងហើយថា សង្ខារទាំងពួងជាទុក្ខ ត្រាស់ដឹងហើយថា ធម៌ទាំងពួងជាអនត្តា ត្រាស់ដឹងហើយថា សង្ខារទាំងឡាយ (កើតមាន) ព្រោះអវិជ្ជាជាបច្ច័យ ត្រាស់ដឹងហើយថា វិញ្ញាណ (កើតមាន) ព្រោះសង្ខារជាបច្ច័យ ត្រាស់ដឹងហើយថា នាមនិងរូប (កើតមាន) ព្រោះវិញ្ញាណជាបច្ច័យ ត្រាស់ដឹងហើយថា អាយតនៈ ៦ (កើតមាន) ព្រោះនាមរូបជាបច្ច័យ ត្រាស់ដឹងហើយថា ផស្សៈ (កើតមាន) ព្រោះអាយតនៈ ៦ ជាបច្ច័យ ត្រាស់ដឹងហើយថា វេទនា (កើតមាន) ព្រោះផស្សៈជាបច្ច័យ ត្រាស់ដឹងហើយថា តណ្ហា (កើតមាន) ព្រោះវេទនាជាបច្ច័យ ត្រាស់ដឹងហើយថា ឧបាទាន (កើតមាន) ព្រោះតណ្ហាជាបច្ច័យ ត្រាស់ដឹងហើយថា ភព (កើតមាន) ព្រោះឧបាទានជាបច្ច័យ ត្រាស់ដឹងហើយថា ជាតិ (កើតមាន) ព្រោះភពជាបច្ច័យ ត្រាស់ដឹងហើយថា ជរានិងមរណៈ (កើតមាន) ព្រោះជាតិជាបច្ច័យ ត្រាស់ដឹងហើយថា ការរលត់សង្ខារ ព្រោះការរលត់ទៅ នៃអវិជ្ជា

សង្ខារនិរោធា វិញ្ញាណនិរោធោតិ ពុជ្ឈិ វិញ្ញាណនិ-
រោធា នាមរូបនិរោធោតិ ពុជ្ឈិ នាមរូបនិរោធា សឡា-
យតននិរោធោតិ ពុជ្ឈិ សឡាយតននិរោធា ផស្សនិ-
រោធោតិ ពុជ្ឈិ ផស្សនិរោធា វេទនានិរោធោតិ ពុជ្ឈិ
វេទនានិរោធា តណ្ហានិរោធោតិ ពុជ្ឈិ តណ្ហានិរោធា
ឧបាទាននិរោធោតិ ពុជ្ឈិ ឧបាទាននិរោធា ភវនិរោ-
ធោតិ ពុជ្ឈិ ភវនិរោធា ជាតិនិរោធោតិ ពុជ្ឈិ
ជាតិនិរោធា ជរាមរណនិរោធោតិ ពុជ្ឈិ ឥទំ ទុក្ខន្តិ
ពុជ្ឈិ អយំ ទុក្ខសមុទយោតិ ពុជ្ឈិ អយំ ទុក្ខនិ-
រោធោតិ ពុជ្ឈិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ
ពុជ្ឈិ ឥមេ អាសវាតិ ពុជ្ឈិ អយំ អាសវសមុទ-
យោតិ ពុជ្ឈិ អយំ អាសវនិរោធោតិ ពុជ្ឈិ អយំ
អាសវនិរោធគាមិនី បដិបទាតិ ពុជ្ឈិ ឥមេ ធម្មា
អភិញ្ញាតព្វាតិ ពុជ្ឈិ ឥមេ ធម្មា បហាតព្វាតិ ពុជ្ឈិ

ត្រាស់ដឹងហើយថា ការរលត់វិញ្ញាណ ព្រោះការរលត់សង្ខារ ត្រាស់ដឹងហើយថា ការរលត់នាមរូប ព្រោះការរលត់វិញ្ញាណ ត្រាស់ដឹងហើយថា ការរលត់អាយតនៈ ៦ ព្រោះការរលត់នាមនឹងរូប ត្រាស់ដឹងហើយថា ការរលត់ផស្សៈ ព្រោះការរលត់អាយតនៈ ៦ ត្រាស់ដឹងហើយថា ការរលត់វេទនា ព្រោះការរលត់ផស្សៈ ត្រាស់ដឹងហើយថា ការរលត់តណ្ហាព្រោះការរលត់វេទនា ត្រាស់ដឹងហើយថា ការរលត់ឧបាទាន ព្រោះការរលត់តណ្ហា ត្រាស់ដឹងហើយថា ការរលត់ភព ព្រោះការរលត់ឧបាទាន ត្រាស់ដឹងហើយថា ការរលត់ជាតិ ព្រោះការរលត់ភព ត្រាស់ដឹងហើយថា ការរលត់ជរាមរណៈ ព្រោះការរលត់ជាតិ ត្រាស់ដឹងហើយថា នេះទុក្ខ ត្រាស់ដឹងហើយថា នេះការកើតទុក្ខ ត្រាស់ដឹងហើយថា នេះការរលត់ទុក្ខ ត្រាស់ដឹងហើយថា នេះបដិបទាជាដំណើរទៅកាន់ការរលត់ទុក្ខ ត្រាស់ដឹងហើយថា ទាំងនេះអាសវៈ ត្រាស់ដឹងហើយថា នេះការកើតអាសវៈ ត្រាស់ដឹងហើយថា នេះការរលត់អាសវៈ ត្រាស់ដឹងហើយថា នេះបដិបទាជាដំណើរទៅកាន់ការរលត់អាសវៈ ត្រាស់ដឹងហើយថា ធម៌ទាំងនេះ គួរដឹងច្បាស់ ត្រាស់ដឹងហើយថា ធម៌ទាំងនេះគួរលះបង់

ឥមេ ធម្មា ភាវេតព្វាតិ ពុជ្ឈតិ ឆន្នំ ផស្សាយតនានំ សមុទយញ្ច អត្ថង្គមញ្ច អាទីនវញ្ច និស្សរណញ្ច ពុជ្ឈតិ បញ្ចន្នំ ឧបាទានក្ខន្ធានំ សមុទយញ្ច អត្ថង្គមញ្ច អាទីនវញ្ច និស្សរណញ្ច ពុជ្ឈតិ ចតុន្នំ មហាភូតានំ សមុទយញ្ច អត្ថង្គមញ្ច អាទីនវញ្ច និស្សរណញ្ច ពុជ្ឈតិ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ពុជ្ឈតិ(១) យំ ពុជ្ឈិតព្វំ អនុពុជ្ឈិតព្វំ សម្ពុជ្ឈិតព្វំ ផុសិតព្វំ សច្ឆិកាតព្វំ សព្វន្តំ តេន បច្ចេកពោធិញាណេន ពុជ្ឈតិ អនុពុជ្ឈតិ សម្ពុជ្ឈតិ ផុសេសិ សច្ឆិកាសីតិ ឯវំ សោ បច្ចេកសម្ពុទ្ធោ ឯកោ អនុត្តរំ បច្ចេកសម្ពោធឹ អភិសម្ពុទ្ធោតិ ឯកោ ។

ចរេតិ អដ្ឋ ចរិយាយោ ឥរិយាបថចរិយា អាយតនចរិយា សតិចរិយា សមាធិចរិយា ញាណចរិយា មគ្គចរិយា បដិបត្តិចរិយា លោកត្ថចរិយា ។ ឥរិយាបថចរិយាតិ ចតូសុ ឥរិយាបថេសុ ។

១ ម. ឯត្ថន្តរេ អធិគតិ ទិស្សតិ ។

ត្រាស់ដឹងហើយថា ធម៌ទាំងនេះគួរចំរើន ត្រាស់ដឹងហើយ នូវការកើតឡើងផង ការវិនាសផង ទោសផង ការរលាស់ចេញនូវផស្សាយតនៈ ៦ ផង ត្រាស់ដឹងហើយនូវការកើតឡើងផង ការវិនាសផង ទោសផង ការរលាស់ចេញនូវឧបាទានក្ខន្ធ ៥ ផង ត្រាស់ដឹងហើយ នូវការកើតឡើងផង ការវិនាសផង ទោសផង ការរលាស់ចេញនូវមហាភូតរូប ៤ ផង ត្រាស់ដឹងហើយថា ធម្មជាតណាមួយ មានការកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា គឺថា ត្រាស់ដឹង ត្រាស់ដឹងតាម ត្រាស់ដឹងឯង ប៉ះពាល់ ធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលត្រូវត្រាស់ដឹង ដែលត្រូវត្រាស់ដឹងតាម ដែលត្រូវត្រាស់ដឹងឯង ដែលត្រូវប៉ះពាល់ ដែលត្រូវធ្វើឲ្យជាក់ច្បាស់ទាំងអស់ ដោយបច្ចេកពោធិញ្ញាណនោះ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះហេតុត្រាស់ដឹងនូវបច្ចេកសម្ពោធិដ៏ប្រសើរ ម្នាក់ឯង យ៉ាងនេះ ។

ពាក្យថា គប្បីប្រព្រឹត្ត បានដល់ការប្រព្រឹត្តិ ៨ គឺ ការប្រព្រឹត្តិឥរិយាបថ ១ ការប្រព្រឹត្តិអាយតនៈ ១ ការប្រព្រឹត្តិសតិ ១ ការប្រព្រឹត្តិសមាធិ ១ ការប្រព្រឹត្តិញាណ ១ ការប្រព្រឹត្តិមគ្គ ១ ការប្រព្រឹត្តិបដិបត្តិ ១ ការប្រព្រឹត្តិជាប្រយោជន៍លោក ១ ។ ពាក្យថា ការប្រព្រឹត្តិឥរិយាបថ បានដល់ ការប្រព្រឹត្តិ ក្នុងឥរិយាបថ ៤ ។

អាយតនចរិយាតិ ឆសុ អជ្ឈត្តិកពាហិរេសុ អាយតនេសុ ។ សតិចរិយាតិ ចតូសុ សតិបដ្ឋានេសុ ។ សមាធិចរិយាតិ ចតូសុ ឈានេសុ ។ ញាណចរិយាតិ ចតូសុ អរិយសច្ចេសុ ។ មគ្គចរិយាតិ ចតូសុ មគ្គេសុ(១) ។ បត្តិចរិយាតិ ចតូសុ សាមញ្ញផលេសុ ។ លោកត្ថចរិយាតិ តថាគតេសុ អរហន្តេសុ សម្មាសម្ពុទ្ធេសុ បទេសតោ បច្ចេកសម្ពុទ្ធេសុ បទេសតោ សាវកេសុ ។ ឥរិយាបថចរិយា ច បណិធិសម្បន្នានំ អាយតនចរិយា ច ឥន្ទ្រិយេសុ គុត្តទ្វារានំ សតិចរិយា ច អប្បមាទវិហារីនំ សមាធិចរិយា ច អធិចិត្តមនុយុត្តានំ ញាណចរិយា ច ពុទ្ធិសម្បន្នានំ មគ្គចរិយា ច សម្មាបដិបន្នានំ បត្តិចរិយា ច អធិគតផលានំ លោកត្ថចរិយា ច តថាគតានំ អរហន្តានំ សម្មាសម្ពុទ្ធានំ បទេសតោ បច្ចេកសម្ពុទ្ធានំ បទេសតោ សាវកានំ ។

---

១ ម. អរិយមគ្គេសុ ។

ពាក្យថា ការប្រព្រឹត្តិអាយតនៈ បានដល់ ការប្រព្រឹត្តិ ក្នុងអាយតនៈ ៦ ទាំងខាងក្នុងទាំងខាងក្រៅ ។ ពាក្យថា ការប្រព្រឹត្តិសតិ បានដល់ការប្រព្រឹត្តិក្នុងសតិប្បដ្ឋាន ៤ ។ ពាក្យថា ការប្រព្រឹត្តិសមាធិ បានដល់ការប្រព្រឹត្តិក្នុងឈាន ៤ ។ ពាក្យថា ការប្រព្រឹត្តិញាណ បានដល់ការប្រព្រឹត្តិក្នុងអរិយសច្ច ៤ ។ ពាក្យថា ការប្រព្រឹត្តិមគ្គ បានដល់ការប្រព្រឹត្តិក្នុងមគ្គ ៤ ។ ពាក្យថា ការប្រព្រឹត្តិបដិបត្តិ បានដល់ការប្រព្រឹត្តិក្នុងសាមញ្ញផល ៤ ។ ពាក្យថា ការប្រព្រឹត្តិជាប្រយោជន៍លោក បានដល់ការប្រព្រឹត្តិមានក្នុងព្រះតថាគតទាំងឡាយ ជាអរហន្តសម្មាសម្ពុទ្ធ ក្នុងព្រះបច្ចេកសម្ពុទ្ធទាំងឡាយ ដោយឯកទេស ក្នុងសាវ័កទាំងឡាយ ដោយឯកទេស ។ ការប្រព្រឹត្តិឥរិយាបថ សម្រាប់ពួកបុគ្គលអ្នកបរិបូណ៌ដោយសេចក្តីកសាង ការប្រ-ព្រឹត្តិអាយតនៈ សម្រាប់បុគ្គលអ្នកមានទ្វារគ្រប់គ្រងក្នុងឥន្ទ្រិយទាំងឡាយ ការប្រព្រឹត្តិសតិ សម្រាប់ពួកបុគ្គលអ្នកមានកិរិយានៅ ដោយសេចក្តីមិនប្រហែស ការប្រព្រឹត្តិសមាធិ សម្រាប់ពួកបុគ្គលអ្នកប្រកបរឿយ ៗ នូវអធិចិត្ត ការប្រព្រឹត្តិញាណ សម្រាប់ពួកបុគ្គលអ្នកបរិបូណ៌ដោយបញ្ញា ការប្រព្រឹត្តិមគ្គ សម្រាប់ពួកបុគ្គលអ្នកប្រតិបត្តិត្រូវ ការប្រព្រឹត្តិបដិបត្តិ សម្រាប់ពួកបុគ្គលអ្នកសម្រេចផល ការប្រព្រឹត្តិជាប្រយោជន៍ សម្រាប់ព្រះតថាគតទាំងឡាយ ជាអរហន្តសម្មាសម្ពុទ្ធ នឹងសម្រាប់ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ ដោយឯកទេស សម្រាប់សាវ័កទាំងឡាយ ដោយឯកទេស ។

ឥមា អដ្ឋ ចរិយាយោ ។ អបរាបិ អដ្ឋ ចរិយាយោ អធិមុច្ចន្តោ សទ្ធាយ ចរតិ បគ្គណ្ហន្តោ វីរិយេន ចរតិ ឧបដ្ឋបេន្តោ សតិយា ចរតិ អវិក្ខេបំ ករោន្តោ សមាធិនា ចរតិ បជានន្តោ បញ្ញាយ ចរតិ វិជានន្តោ វិញ្ញាណេន ចរតិ ឯវំ បដិបន្នស្ស កុសលា ធម្មា អាយាបេន្តីតិ អាយតនចរិយាយ ចរតិ ឯវំ បដិបន្នោ វិសេសមធិគច្ឆតីតិ វិសេសចរិយាយ ចរតិ ឥមា អដ្ឋ ចរិយាយោ ។ អបរាបិ អដ្ឋ ចរិយាយោ ទស្សនចរិយា ច សម្មាទិដ្ឋិយា អភិរោបនចរិយា ច សម្មាសង្កប្បស្ស បរិគ្គហចរិយា ច សម្មាវាចាយ សមុដ្ឋានចរិយា ច សម្មាកម្មន្តស្ស វោទានចរិយា ច សម្មាអាជីវស្ស បគ្គហចរិយា ច សម្មាវាយាមស្ស ឧបដ្ឋានចរិយា ច សម្មាសតិយា អវិក្ខេបចរិយា ច សម្មាសមាធិស្ស ឥមា អដ្ឋ ចរិយាយោ ។

ខគ្គវិសាណកប្បោតិ យថា ខគ្គស្ស នាម វិសាណំ ឯកំ ហោតិ អទុតិយំ ឯវមេវ សោ បច្ចេកសម្ពុទ្ធោ តក្កប្បោ តស្សទិសោ តប្បដិភាគោ ។

នេះការប្រព្រឹត្តិ ៨ ។ ការប្រព្រឹត្តិ ៨ ដោយខ្សែកទៀត គឺ បុគ្គលជឿប្រព្រឹត្តដោយសទ្ធា ១ ប្រឹងប្រព្រឹត្តដោយវីរិយៈ ១ ប្រុងប្រព្រឹត្តដោយសតិ ១ ធ្វើសេចក្តីមិនរាយមាយ ប្រព្រឹត្តដោយសមាធិ ១ ដឹងច្បាស់ ប្រព្រឹត្តដោយបញ្ញា ១ ដឹងវិសេស ប្រព្រឹត្តដោយវិញ្ញាណ ១ បុគ្គលប្រព្រឹត្តដោយការប្រព្រឹត្តិអាយតនៈថា ពួកធម៌ជាកុសល របស់បុគ្គលអ្នកប្រតិបត្តិយ៉ាងនេះ រមែងប្រព្រឹត្តទៅ ១ បុគ្គលប្រព្រឹត្តដោយវិសេសចរិយាថា បុគ្គលប្រតិបត្តិយ៉ាងនេះ រមែងបាននូវគុណវិសេស ១ នេះការប្រព្រឹត្តិ ៨ ។ ការប្រព្រឹត្តិ ៨ ដោយខ្សែកទៀត គឺ ការប្រព្រឹត្តិដោយការឃើញ របស់សម្មាទិដ្ឋិ ១ ការប្រព្រឹត្តិដោយការលើកចិត្ត របស់សម្មាសង្កប្បៈ ១ ការប្រព្រឹត្តិដោយការរក្សា របស់សម្មាវាចា ១ ការប្រព្រឹត្តិដោយការតាំងឡើង របស់សម្មាកម្មន្តៈ ១ ការប្រព្រឹត្តិដោយការផូរផង់ របស់សម្មាអាជីវៈ ១ ការប្រព្រឹត្តិដោយការផ្គង របស់សម្មាវាយាមៈ ១ ការប្រព្រឹត្តិដោយការប្រុង របស់សម្មាសតិ ១ ការប្រព្រឹត្តិដោយការមិនរាយមាយ របស់សម្មាសមាធិ ១ នេះការប្រព្រឹត្តិ ៨ ។

ពាក្យថា ដូចក្អុយរមាស គឺ ក្អុយរមាសមានតែមួយ មិនមានពីរយ៉ាងណា ព្រះបច្ចេកសម្ពុទ្ធនោះ ប្រហែលនឹងក្អុយរមាសនោះ ប្រាកដស្មើដោយក្អុយរមាសនោះ មានការប្រៀបដោយក្អុយរមាសនោះ យ៉ាងនោះ ។

## ខគ្គវិសាណសុត្តនិទ្ទេសោ

យថា អតិលោណំ វុច្ចតិ លោណកប្បោ អតិតិត្តកំ វុច្ចតិ តិត្តកប្បោ អតិមធុរំ វុច្ចតិ មធុកប្បោ អតិឧណ្ហំ វុច្ចតិ អគ្គិកប្បោ អតិសីតលំ វុច្ចតិ ហិមកប្បោ មហាឧទកក្ខន្ធោ វុច្ចតិ សមុទ្ទកប្បោ មហាភិញ្ញាពលប្បត្តោ សាវកោ វុច្ចតិ សត្ថុកប្បោ ឯវំ សោ បច្ចេកសម្ពុទ្ធោ តក្កប្បោ តស្សទិសោ តប្បដិភាគោ ឯកោ អទុតិយោ មុត្តពន្ធនោ សម្មា លោកេ ចរតិ វិចរតិ ឥរិយតិ វត្តតិ បាលេតិ យបេតិ យាបេតីតិ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

សព្វេសុ ភូតេសុ និធាយ ទណ្ឌំ
អហេឋយំ អញ្ញតរម្បិ តេសំ
ន បុត្តមិច្ឆេយ្យ កុតោ សហាយំ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

## ខគ្គវិសាណសុត្តនិទ្ទេស

វត្ថុមានរសប្រៃក្រៃលែង អ្នកផងតែងនិយាយថាដូចអំបិល វត្ថុមានរសល្វីងក្រៃលែង អ្នកផងតែងនិយាយថាដូចម្រះ វត្ថុមានរសផ្អែមក្រៃលែង អ្នកផងតែងនិយាយថា ដូចទឹកឃ្មុំ កំដៅដ៏ក្រៃលែង អ្នកផងតែងនិយាយថា ដូចភ្លើង វត្ថុត្រជាក់ដ៏ក្រៃលែង អ្នកផងតែងនិយាយថា ដូចព្រិល (ឬទឹកកក) ធារនៃទឹកច្រើន អ្នកផងតែងនិយាយថា ដូចសមុទ្រ សាវ័កដែលដល់នូវកំឡាំងអភិញ្ញាដ៏ច្រើន អ្នកផងតែងនិយាយថា ដូចព្រះសាស្តា យ៉ាងណាមិញ ព្រះបច្ចេកសម្ពុទ្ធនោះ ដូចកុយរមាសនោះ ប្រាកដស្មើដោយកុយរមាសនោះ មានការប្រៀបដោយកុយរមាសនោះ ជាបុគ្គលឯក មិនមានបុគ្គលជាគំរប់ពីរ របូតចាកចំណងហើយ តែងចរ ត្រាច់ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ ក្នុងលោកដោយប្រពៃ ក៏យ៉ាងនោះដែរ ព្រោះហេតុនោះ លោកពោលថា គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ៗ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

បុគ្គលទំលាក់ចេញនូវអាជ្ញា ចំពោះពួកសត្វទាំងពួង មិន
បៀតបៀននូវសត្វទាំងនោះ សូម្បីសត្វណាមួយ គេមិន
ចង់បានបុត្តទៅហើយ តើនឹងប្រាថ្នាសំឡាញ់អំពីណាកើត
បុគ្គលនោះគប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ៗ

(២៣៦) សំសគ្គជាតស្ស ភវន្តិ ស្នេហា
ស្នេហន្វយំ ទុក្ខមិទំ បហោតិ
អាទីនវំ ស្នេហជំ បេក្ខមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

(២៣៧) សំសគ្គជាតស្ស ភវន្តិ ស្នេហាតិ សំសគ្គាតិ ទ្វេ សំសគ្គា ទស្សនសំសគ្គោ ច សវនសំសគ្គោ ច ។

កតមោ ទស្សនសំសគ្គោ ។ ឥធេកច្ចោ បស្សតិ ឥត្ថឹ វា កុមារឹ វា អភិរូបំ ទស្សនីយំ បាសាទិកំ បរមាយ វណ្ណបោក្ខរតាយ សមន្នាគតំ ទិស្វា បស្សិត្វា អនុព្យញ្ជនសោ និមិត្តំ គណ្ហាតិ កេសា វា សោភណា មុខំ វា សោភណំ អក្ខិ វា សោភណំ កណ្ណា វា សោភណា នាសា វា សោភណា ឱដ្ឋំ វា សោភណំ ទន្តា វា សោភណា មុខំ វា សោភណំ គីវា វា សោភណា ថនា វា សោភណា ឧរំ វា សោភណំ ឧទរំ វា សោភណំ កដិ វា សោភណា ឩរុ វា សោភណា ជង្ឃា វា សោភណា

(២៣៦) សេចក្តីស្នេហា របស់បុគ្គលអ្នកមានការជាប់ចំពាក់ រមែងមាន សេចក្តីទុក្ខនេះ មានឡើង ព្រោះអាស្រ័យសេចក្តីស្នេហា បុគ្គលកាលសំឡឹងឃើញទោសដែលកើតអំពីសេចក្តីស្នេហា គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(២៣៧) អធិប្បាយពាក្យថា សេចក្តីស្នេហា របស់បុគ្គលអ្នកមានការជាប់ចំពាក់ រមែងមាន ត្រង់ពាក្យថា ការជាប់ចំពាក់ បានដល់ការជាប់ចំពាក់ ២ គឺការជាប់ចំពាក់ដោយការឃើញ ១ ការជាប់ចំពាក់ដោយការស្តាប់ ១ ។

ការជាប់ចំពាក់ ដោយការឃើញ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ឃើញស្ត្រីឬកុមារី ដែលមានរូបល្អ គួរមើលមើលជាទីជ្រះថ្លា ប្រកបដោយសម្បុរល្អក្រៃលែង លុះមើលឃើញហើយក៏កាន់យកនិមិត្ត ដោយអនុព្យញ្ជនៈថា សក់ល្អ មុខល្អ ភ្នែកល្អ ត្រចៀកល្អ ច្រមុះល្អ បបូរមាត់ល្អ ធ្មេញល្អ មាត់ល្អ កល្អ ដោះល្អ ទ្រូងល្អ ពោះល្អ ចង្កេះល្អ ភ្លៅល្អ ជង្គង់ល្អ

ហត្ថា វា សោភណា អង្គុលិយោ វា សោភណា នខា វា សោភណាតិ ទិស្វា បស្សិត្វា អភិនន្ទតិ អភិវទតិ អភិបត្ថេតិ អនុប្បាទេតិ អនុពន្ធតិ រាគពន្ធំ អយំ ទស្សនសំសគ្គោ ។

កតមោ សវនសំសគ្គោ ។ ឥធេកច្ចោ សុណាតិ អមុកស្មឹ គាមេ វា និគមេ វា ឥត្ថី វា កុមារី វា អភិរូបា ទស្សនីយា បាសាទិកា បរមាយ វណ្ណពោក្ខរតាយ សមន្នាគតាតិ សុត្វា សុណិត្វា អភិនន្ទតិ អភិវទតិ អភិបត្ថេតិ អនុប្បាទេតិ អនុពន្ធតិ រាគពន្ធំ អយំ សវនសំសគ្គោ ។

ស្នេហាតិ ទ្វេ ស្នេហា តណ្ហាស្នេហោ ច ទិដ្ឋិស្នេហោ ច ។

កតមោ តណ្ហាស្នេហោ ។ យាវតា តណ្ហាសង្ខាតេន សីមកតំ មរិយាទិកតំ ឱធិកតំ បរិយន្តកតំ បរិគ្គហិតំ មមាយិតំ ឥទំ មមំ ឯតំ មមំ ឯត្តកំ មមំ ឯត្តាវតា មមំ មម រូបា សទ្ទា គន្ធា រសា ផោដ្ឋព្វា អត្ថរណា បាវុរណា ទាសីទាសា

## ១ គុហដ្ឋកសុត្តនិទ្ទេស

ដៃល្អ ម្រាមដៃល្អ ក្រចកល្អ លុះមើលឃើញហើយ រមែងត្រេកអរ សរសើរ ប៉ុនប៉ង ក្រវែលរក ជាប់តាម នូវចំណងគឺរាគៈ នេះការជាប់ចំពាក់ដោយការឃើញ ។

ការជាប់ចំពាក់ដោយការឮ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ឮថា ស្ត្រីឬកុមារី ក្នុងស្រុកក្តី ក្នុងនិគមក្តី ឈ្មោះឯណោះ មានរូបល្អ គួរមើលមើល ជាទីជ្រះថ្លា ប្រកបដោយសម្បុរល្អក្រៃលែង លុះស្តាប់ឮហើយ រមែងត្រេកអរ សរសើរ ប៉ុនប៉ង ក្រវែលរក ជាប់តាម នូវចំណងគឺរាគៈ នេះការជាប់ចំពាក់ដោយការឮ ។

ពាក្យថា សេចក្តីស្នេហា បានដល់សេចក្តីស្នេហា ២ គឺ តណ្ហាស្នេហា ១ ទិដ្ឋិស្នេហា ១ ។

តណ្ហាស្នេហា តើដូចម្តេច ។ អំពើដែលបុគ្គលធ្វើឲ្យមានដែន ធ្វើឲ្យមានខាន់ ធ្វើឲ្យមានជួរ ធ្វើឲ្យមានទីបំផុត ហួងហែង ប្រកាន់ ដោយចំណែកតណ្ហា ទាំងប៉ុន្មានថា នេះ របស់អញ នុ៎ះ របស់អញ វត្ថុប៉ុណ្ណោះរបស់អញ វត្ថុមានប្រមាណប៉ុណ្ណោះរបស់អញ រូប សំឡេង ក្លិន រស ផ្សព្វ កម្រាល ប្រដាប់ស្លៀកពាក់ ខ្ញុំស្រីប្រុស

អជេឡកា កុក្កុដសូករា ហត្ថិគវាស្សវឡវា ខេត្តំ វត្ថុ ហិរញ្ញំ សុវណ្ណំ គាមនិគមរាជធានិយោ រដ្ឋញ្ច ជនបទោ ច កោសោ ច កោដ្ឋាគារញ្ច កេវលម្បិ មហាបថវឹ តណ្ហាវសេន មមាយតិ យាវតា អដ្ឋសតតណ្ហាវិបរីតា អយំ តណ្ហាស្នេហោ ។

កតមោ ទិដ្ឋិស្នេហោ ។ វីសតិវត្ថុកា សក្កាយទិដ្ឋិ ទសវត្ថុកា មិច្ឆាទិដ្ឋិ ទសវត្ថុកា អន្តគ្គាហិកា ទិដ្ឋិ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ទិដ្ឋិគហនំ ទិដ្ឋិកន្តារេ(១) ទិដ្ឋិវិសូកាយិកំ ទិដ្ឋិវិប្ផន្ទិតំ ទិដ្ឋិសញ្ញោជនំ គាហោ បដិគ្គាហោ អភិនិវេសោ បរាមាសោ កុម្មគ្គោ មិច្ឆាបថោ មិច្ឆត្តំ តិត្ថាយតនំ វិបរិយេសគ្គាហោ វិបរីតគ្គាហោ វិបល្លាសគ្គាហោ មិច្ឆាគាហោ អយាថាវកស្មឹ យាថាវកន្តិ គាហោ យាវតា ទ្វាសដ្ឋិ ទិដ្ឋិគតានិ អយំ ទិដ្ឋិស្នេហោ ។

---

១ ម. ទិដ្ឋិកន្តារំ ។

ពពែ ចៀម មាន់ ជ្រូក ដំរី គោ សេះឈ្មោល សេះញី ស្រែ ចម្ការ ប្រាក់ មាស ស្រុក និគម រាជធានី ដែន ជនបទ ជង្រុក ឃ្លាំង របស់អញ ប្រកាន់ នូវមហាប្រឹថពី សូម្បីទាំងអស់ ដោយអំណាចតណ្ហា តណ្ហាវិចរិត ១០៨ ទាំងប៉ុន្មាន នេះតណ្ហាស្នេហា ។

ទិដ្ឋិស្នេហា តើដូចម្តេច ។ សក្កាយទិដ្ឋិមានវត្ថុ ២០ មិច្ឆាទិដ្ឋិ មានវត្ថុ ១០ អន្តគ្គាហិកទិដ្ឋិ មានវត្ថុ ១០ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ការសាំញាំគឺទិដ្ឋិ ផ្លូវលំបាកគឺទិដ្ឋិ គ្រឿងចាក់ដោតគឺទិដ្ឋិ ការអន្ទះសាគឺទិដ្ឋិ គ្រឿងប្រកបទុក្ខគឺទិដ្ឋិ សេចក្តីប្រកាន់ សេចក្តីប្រកាន់ខ្ជាប់ ការជាប់ចំពាក់ ការស្ទាបអង្អែល ផ្លូវអាក្រក់ ផ្លូវខុស សភាពខុស លទ្ធិដូចជាកំពង់ សេចក្តីប្រកាន់ក្នុងការស្វែងរកខុស ការប្រកាន់ឃ្វៀងឃ្វាត ការប្រកាន់ឃ្វាង ការប្រកាន់ខុស ការប្រកាន់ថាពិតក្នុងវត្ថុមិនពិត ទិដ្ឋិ ៦២ ទាំងប៉ុន្មាន នេះទិដ្ឋិស្នេហា ។

## ខគ្គវិសាណសុត្តនិទ្ទេសោ

សំសគ្គជាតស្ស ភវន្តិ ស្នេហាតិ វិបល្លាសប្បច្ចយា ច ទស្សនសវនសំសគ្គប្បច្ចយា ច តណ្ហាស្នេហោ ច ទិដ្ឋិស្នេហោ ច ភវន្តិ ជាយន្តិ សញ្ជាយន្តិ និព្វត្តន្តិ អភិនិព្វត្តន្តិ បាតុភវន្តីតិ សំសគ្គជាតស្ស ភវន្តិ ស្នេហា ។

(២៣៨) ស្នេហន្វយំ ទុក្ខមិទំ បហោតីតិ ស្នេហោតិ ទ្វេ ស្នេហា តណ្ហាស្នេហោ ច ទិដ្ឋិស្នេហោ ច ។បេ។ អយំ តណ្ហាស្នេហោ ។បេ។ អយំ ទិដ្ឋិស្នេហោ ។ ទុក្ខមិទំ បហោតីតិ ឥធេកច្ចោ កាយេន ទុច្ចរិតំ ចរតិ វាចាយ ទុច្ចរិតំ ចរតិ មនសា ទុច្ចរិតំ ចរតិ បាណម្បិ ហនតិ អទិន្នម្បិ អាទិយតិ សន្ធិម្បិ ឆិន្ទតិ វិលោបម្បិ ហរតិ ឯកាគារិកម្បិ ករោតិ បរិបន្ថេបិ តិដ្ឋតិ បរទារម្បិ គច្ឆតិ មុសាបិ ភណតិ ។ តមេនំ គហេត្វា រញ្ញោ ទស្សេន្តិ អយំ ទេវ ចោរោ អាគុចារី ឥមស្ស យំ ឥច្ឆសិ តំ ទណ្ឌំ បណេហីតិ ។ តមេនំ រាជា បរិភាសតិ ។

ខគ្គវិសាណសុត្តនិទ្ទេស

ពាក្យថា សេចក្តីស្នេហា របស់បុគ្គលអ្នកមានការជាប់ចំពាក់ រមែងមាន បានន័យថា តណ្ហាស្នេហាក្តី ទិដ្ឋិស្នេហាក្តី រមែងមាន កើត កើតព្រម លូតលាស់ ចំរើនឡើង កើតប្រាកដឡើង ព្រោះវិប្បល្លាសជាបច្ច័យផង ព្រោះការជាប់ចំពាក់ដោយការមើលឃើញនឹងការព្ទុជាបច្ច័យផង ហេតុនោះ (លោកពោលថា) សេចក្តីស្នេហា របស់បុគ្គលអ្នកមានការជាប់ចំពាក់ រមែងមាន ។

(២៣៨) អធិប្បាយពាក្យថា សេចក្តីទុក្ខនេះ មានឡើងព្រោះអាស្រ័យសេចក្តីស្នេហា ត្រង់ពាក្យថា សេចក្តីស្នេហា បានដល់សេចក្តីស្នេហា ២ យ៉ាង គឺ តណ្ហាស្នេហា ១ ទិដ្ឋិស្នេហា ១ ។ បេ ។ នេះតណ្ហា-ស្នេហា ។ បេ ។ នេះទិដ្ឋិស្នេហា ។ ពាក្យថា សេចក្តីទុក្ខនេះ មានឡើង សេចក្តីថា បុគ្គលពួកខ្លះក្នុងលោកនេះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត សម្លាប់សត្វខ្លះ កាន់យកទ្រព្យដែលគេមិនបានឲ្យខ្លះ កាត់ទី-តខ្លះ ប្លន់ធំខ្លះ ប្លន់តូចខ្លះ ចាំស្កាត់ផ្លូវខ្លះ គប់រកភរិយាបុគ្គលដទៃខ្លះ ពោលពាក្យកុហកខ្លះ ។ ពួករាជបុរស ចាប់បុគ្គលនុ៎ះ ថ្វាយព្រះរាជាថា បពិត្រព្រះសម្មតិទេព ចោរនេះ ប្រព្រឹត្តអាក្រក់ ទ្រង់សព្វព្រះហឫទ័យអាជ្ញាណា សូមទ្រង់ដាក់អាជ្ញានោះដល់ចោរនេះចុះ ។ ព្រះរាជាទ្រង់ជៀលគ្នះចោរនោះ ។

សោ បរិកាសប្បច្ចយាបិ ទុក្ខទោមនស្សំ បដិសំវេទេតិ ។ ឯតំ កយំ ទុក្ខទោមនស្សំ កុតោ ជាតំ ។ តស្ស ស្នេហបច្ចយា ច នន្ទិបច្ចយា ច រាគបច្ចយា ច នន្ទិរាគបច្ចយា ច ជាតំ ។ ឯត្តកេនបិ រាជា ន តុស្សតិ ។ តមេនំ រាជា ពន្ធាបេតិ អន្ទុពន្ធនេន វា រជ្ជុពន្ធនេន វា សង្ខលិកពន្ធនេន វា លតាពន្ធនេន វា បរិក្ខេបពន្ធនេន វា គាមពន្ធនេន វា និគមពន្ធនេន វា នគរពន្ធនេន វា រដ្ឋពន្ធនេន វា ជនបទពន្ធនេន វា អន្តមសោ សាវចនីយម្បិ ករោតិ ន តេ លព្ភា ឥតោ និក្ខមិតុន្តិ ។ សោ ពន្ធនបច្ចយាបិ ទុក្ខទោមនស្សំ បដិសំវេទេតិ ។ ឯតំ កយំ ទុក្ខទោមនស្សំ កុតោ ជាតំ ។ តស្ស ស្នេហបច្ចយា ច នន្ទិបច្ចយា ច រាគបច្ចយា ច នន្ទិរាគបច្ចយា ច ជាតំ ។ ឯត្តកេនបិ រាជា ន តុស្សតិ ។ តមេនំ រាជា តស្ស ធនំ អាហរាបេតិ សតំ វា សហស្សំ វា ។ សោ ធនជានិបច្ចយាបិ ទុក្ខទោមនស្សំ បដិសំវេទេតិ ។

ចោរនោះ រងទុក្ខ ទោមនស្ស ព្រោះការដៀលត្មះជាបច្ច័យ ។ ភ័យ ទុក្ខ ទោមនស្សនុ៎ះ កើតហើយព្រោះអ្វី ។ កើតហើយដល់ចោរនោះ ព្រោះសេចក្តីស្នេហាជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយជាបច្ច័យខ្លះ ព្រោះតម្រេកជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយនឹងតម្រេកជាបច្ច័យខ្លះ ។ បើព្រះរាជាមិនសព្វព្រះហឫទ័យ ដោយហេតុមានប្រមាណប៉ុណ្ណោះទេ ។ ព្រះរាជាញុំាងរាជបុរសឲ្យចងចោរនោះ ដោយចំណងគឺខ្នោះក្តី ដោយចំណងគឺខ្សែក្តី ដោយចំណងគឺច្រវាក់ក្តី ដោយចំណងគឺវល្លិក្តី ដោយចំណងគឺរបងក្តី ដោយចំណងគឺស្រុកក្តី ដោយចំណងគឺនិគមក្តី ដោយចំណងគឺនគរក្តី ដោយចំណងគឺដែនក្តី ដោយចំណងគឺជនបទក្តី ដោយហោចទៅ ព្រះរាជាធ្វើការហាមប្រាម ដោយព្រះបន្ទូលថា អ្នកមិនត្រូវបានចេញអំពីទីនេះទេ ។ ចោរនោះរងទុក្ខទោមនស្ស ព្រោះការចងជាបច្ច័យ ។ ភ័យ ទុក្ខ ទោមនស្សនុ៎ះ កើតហើយព្រោះអ្វី ។ កើតហើយដល់ចោរនោះ ព្រោះសេចក្តីស្នេហាជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយជាបច្ច័យខ្លះ ព្រោះតម្រេកជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយនឹងតម្រេកជាបច្ច័យខ្លះ ។ បើព្រះរាជាមិនសព្វព្រះហឫទ័យ ដោយហេតុត្រឹមប៉ុណ្ណោះទេ ។ ព្រះរាជាទ្រង់ឲ្យរឹបយកទ្រព្យនោះ រាប់រយឬរាប់ពាន់ របស់ចោរនោះ ។ ចោរនោះ ក៏រងទុក្ខទោមនស្ស ព្រោះការសាបសូន្យទ្រព្យជាបច្ច័យ ។

ខគ្គវិសាណសុត្តនិទ្ទេសោ

ឯតំ ភយំ ទុក្ខទោមនស្សំ កុតោ ជាតំ ។ តស្ស
ស្នេហប្បច្ចយា ច ឆន្ទប្បច្ចយា ច រាគប្បច្ចយា ច
ឆន្ទរាគប្បច្ចយា ច ជាតំ ។ ឯត្តកេនបិ រាជា ន
តុស្សតិ ។ រាជា តស្ស វិធា កម្មការណា ការា-
បេតិ កសាហិបិ តាឡេតិ វេត្តេហិបិ តាឡេតិ អឌ្ឍទ-
ណ្ឌកេហិបិ តាឡេតិ ហត្ថម្បិ ឆិន្ទតិ បាទម្បិ ឆិន្ទតិ ហ-
ត្ថបាទម្បិ ឆិន្ទតិ កណ្ណម្បិ ឆិន្ទតិ នាសម្បិ ឆិន្ទតិ ក-
ណ្ណនាសម្បិ ឆិន្ទតិ ពិលង្គថាលិកម្បិ ករោតិ សង្ខ-
មុណ្ឌិកម្បិ ករោតិ រាហុមុខម្បិ ករោតិ ជោតិមាលិ-
កម្បិ ករោតិ ហត្ថប្បជ្ជោតិកម្បិ ករោតិ ឯរកវត្តិ-
កម្បិ ករោតិ ចីរកវាសិកម្បិ ករោតិ ឯណេយ្យកម្បិ
ករោតិ ពលិសមំសិកម្បិ ករោតិ កហាបណិក-
ម្បិ ករោតិ ខារាបតច្ឆិកម្បិ ករោតិ បលិឃបរិវត្តិ-
កម្បិ ករោតិ បលាលបីឋកម្បិ ករោតិ តត្តេនបិ
តេលេន ឱសិញ្ចតិ សុនខេហិបិ ខាទាបេតិ ជីវន្តម្បិ
សូលេ ឧត្តាសេតិ អសិនាបិ សីសំ ឆិន្ទតិ ។ សោ ក-
ម្មការណាប្បច្ចយាបិ ទុក្ខទោមនស្សំ បដិសំវេទេតិ ។

ភ័យ ទុក្ខ ទោមនស្ស+ទុះ កើតហើយព្រោះអ្វី ៗ កើតហើយដល់ចោរនោះ ព្រោះសេចក្តីស្នេហាជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយជាបច្ច័យខ្លះ ព្រោះតម្រេកជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយនឹងតម្រេកជាបច្ច័យខ្លះ ៗ បើព្រះរាជាមិនសព្វព្រះរាជហឫទ័យ ដោយហេតុប៉ុណ្ណេះទេ ៗ ព្រះរាជាក៏ទ្រង់ឲ្យធ្វើកម្មករណ៍ផ្សេង ៗ ដល់ចោរនោះ គឺឲ្យវាយដោយស៊ែខ្លះ ឲ្យវាយដោយរំពាត់ផ្តៅខ្លះ ឲ្យវាយដោយដំបងខ្លីខ្លះ កាត់ដៃខ្លះ កាត់ជើងខ្លះ កាត់ទាំងដៃទាំងជើងខ្លះ កាត់ស្លឹកត្រចៀកខ្លះ កាត់ច្រមុះខ្លះ កាត់ទាំងស្លឹកត្រចៀកទាំងច្រមុះខ្លះ ធ្វើពិលង្គថាលិកកម្មខ្លះ ធ្វើសង្ខមុណ្ឌកកម្មខ្លះ ធ្វើរាហុមុខកម្មខ្លះ ធ្វើជោតិមាលិកកម្មខ្លះ ធ្វើហត្ថប្ប-ជ្ជោតិកកម្មខ្លះ ធ្វើឯរកវត្តិកកម្មខ្លះ ធ្វើចិរវាសិកកម្មខ្លះ ធ្វើឯណេយ្យកកម្មខ្លះ ធ្វើពលិសមំសិកកម្មខ្លះ ធ្វើកហាបណិកកម្មខ្លះ ធ្វើខារាបតច្ឆិកកម្មខ្លះ ធ្វើបលិឃបរិវត្តិកកម្មខ្លះ ធ្វើបលាលបីឋកកម្មខ្លះ ស្រោចដោយប្រេងក្តៅខ្លះ ឲ្យឆ្កែខាំខ្លះ ឲ្យដេកផ្ងាលើឈើអណ្តោតទាំងរស់ខ្លះ កាត់ក្បាលដោយដាវខ្លះ ៗ ចោរនោះក៏រងទុក្ខទោមនស្ស ព្រោះកម្មករណ៍ជាបច្ច័យ ៗ

ឯតំ ភយំ ទុក្ខទោមនស្សំ កុតោ ជាតំ ។ តស្ស ស្នេហប្បច្ចយា ច នន្ទិប្បច្ចយា ច រាគប្បច្ចយា ច នន្ទិរាគប្បច្ចយា ច ជាតំ ។ រាជា ឥមេសំ ចតុន្នំ ទីបានំ ឥស្សរោ ។ សោ សកេន កម្មេន កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ តមេនំ និរយបាលា បញ្ចវិធពន្ធនំ នាម កម្មការណំ ការេន្តិ តត្តំ អយោខិលំ ហត្ថេ គមេន្តិ តត្តំ អយោខិលំ ទុតិយេ ហត្ថេ គមេន្តិ តត្តំ អយោខិលំ បាទេ គមេន្តិ តត្តំ អយោខិលំ ទុតិយេ បាទេ គមេន្តិ តត្តំ អយោខិលំ មជ្ឈេ ឧរស្មឹ គមេន្តិ ។ សោ តត្ថ ទុក្ខា តិព្វា កដុកា វេទនា បដិសំវេទេតិ ន ច តាវ កាលំ ករោតិ យាវ ន តំ បាបកម្មំ ព្យន្តីហោតិ ។ ឯតំ ភយំ ទុក្ខទោមនស្សំ កុតោ ជាតំ ។ តស្ស ស្នេហប្បច្ចយា ច នន្ទិប្បច្ចយា ច រាគប្បច្ចយា ច នន្ទិរាគប្បច្ចយា ច ជាតំ ។ តមេនំ និរយបាលា សំវេសិត្វា កុឋារីហិ តច្ឆន្តិ ។

ភ័យ ទុក្ខ ទោមនស្សនុ៎ះ កើតហើយព្រោះអ្វី ៗ កើតហើយដល់ចោរនោះ ព្រោះសេចក្តីស្នេហាជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយជាបច្ច័យខ្លះ ព្រោះតម្រេកជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយនឹងតម្រេកជាបច្ច័យខ្លះ ៗ ព្រះរាជា ជាឥស្សរៈនៃអាជ្ញាទាំង ៤ នេះ ៗ ចោរនោះលុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើត ឯអបាយ ទុគ្គតិ វិនិបាត នរក ព្រោះកម្មជារបស់ខ្លួន ៗ ពួកនាយនិរយបាល ឲ្យធ្វើកម្មករណ៍ ឈ្មោះបំណង ៥ ប្រការនុ៎ះ គឺ បោះដែកគោលក្តៅត្រង់ដៃ ១ បោះដែកគោលក្តៅត្រង់ដៃទីពីរ ១ បោះដែកគោលក្តៅត្រង់ជើង១ បោះដែកគោលក្តៅត្រង់ជើងទីពីរ១ បោះដែកគោលក្តៅត្រង់កណ្តាលទ្រូង១ ៗ សត្វនោះរងទុក្ខវេទនា ខ្លោចផ្សាដ៏ក្លាខ្លាំង ក្នុងទីនោះ បាបកម្មនោះមិនទាន់អស់ ដរាបណា សត្វនោះក៏មិនទាន់ធ្វើមរណកាល ដរាបនោះ ៗ ភ័យ ទុក្ខ ទោមនស្សនុ៎ះ កើតហើយព្រោះអ្វី ៗ កើតហើយដល់សត្វនោះ ព្រោះសេចក្តីស្នេហាជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយជាបច្ច័យខ្លះ ព្រោះតម្រេកជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយ នឹងតម្រេកជាបច្ច័យខ្លះ ៗ ពួកនាយនិរយ-បាល ញុំាងសត្វនុ៎ះឲ្យដេកសន្ធឹង ហើយចាំងដោយដឹងទាំងឡាយ ៗ

## ទុក្ខវិសោណាសុត្តនិទ្ទេសោ

តមេនំ និរយបាលា ឧទ្ធំបាទំ អធោសិរំ គហេត្វា វាសីហិ តច្ឆន្តិ ។ តមេនំ និរយបាលា រថេ យោជេត្វា អាទិត្តាយ បថវិយា សម្បជ្ជលិតាយ សជោតិភូតាយ សារេន្តិបិ បច្ចាសារេន្តិបិ ។ តមេនំ និរយបាលា មហន្តំ អង្គារបព្វតំ អាទិត្តំ សម្បជ្ជលិតំ សជោតិភូតំ អារោបេន្តិបិ ឱរោបេន្តិបិ ។ តមេនំ និរយបាលា ឧទ្ធំបាទំ អធោសិរំ គហេត្វា តត្តាយ លោហកុម្ភិយា បក្ខិបន្តិ អាទិត្តាយ សម្បជ្ជលិតាយ សជោតិភូតាយ ។ សោ តត្ថ ផេណុទ្ទេហកំ បច្ចតិ ។ សោ តត្ថ ផេណុទ្ទេហកំ បច្ចមានោ សកិម្បិ ឧទ្ធំ គច្ឆតិ សកិម្បិ អធោ គច្ឆតិ សកិម្បិ តិរិយំ គច្ឆតិ ។ សោ តត្ថ ទុក្ខា តិព្វា កដុកា វេទនា បដិសំវេទេតិ ន ច តាវ កាលំ ករោតិ យាវ ន តំ បាបកម្មំ ព្យន្តីហោតិ ។ ឯតំ ភយំ ទុក្ខាទោមនស្សំ កុតោ ជាតំ ។

## ខគ្គវិសាណសុត្តនិទ្ទេស

ពួកនាយនិរយបាលចាប់សត្វនុ៎ះឲ្យមានជើងឡើងលើ មានក្បាលចុះក្រោម ហើយប្រាសដោយកាំបិតទាំងឡាយ ។ ពួកនាយនិរយបាល ទឹមសត្វនុ៎ះក្នុងរថហើយបរទៅខ្លះ បរត្រឡប់មកវិញខ្លះ លើផែនដីដែលភ្លើងឆេះសន្ធោសន្ធៅរន្ទាលប្រាលក្ដៅ ។ ពួកនាយនិរយបាល ឲ្យសត្វនុ៎ះឡើងកាន់ភ្នំរងើកភ្លើងដ៏ធំ ដែលភ្លើងឆេះសន្ធោសន្ធៅ រន្ទាលប្រាលក្ដៅខ្លះ ឲ្យចុះមកវិញខ្លះ ។ ពួកនាយនិរយបាល ចាប់សត្វនុ៎ះឲ្យមានជើងឡើងលើ មានក្បាលចុះក្រោម ហើយបោះទៅក្នុងខ្ទះដែកដ៏ក្ដៅ ដែលភ្លើងឆេះសន្ធោសន្ធៅ រន្ទាលប្រាលក្ដៅ ។ សត្វនោះពុះផុលឡើងដូចពពុះក្នុងខ្ទះនោះ ។ សត្វនោះកាលពុះផុលឡើងដូចពពុះក្នុងខ្ទះនោះ អណ្ដែតឡើងលើម្ដង លិចចុះក្រោមម្ដង ទៅទទឹងម្ដង ។ សត្វនោះរងទុក្ខវេទនាដ៏ក្លាខ្លាំងខ្លោចផ្សាក្នុងខ្ទះនោះ បាបកម្មនោះមិនទាន់អស់ ដរាបណា សត្វនោះក៏មិនទាន់ធ្វើមរណកាល ដរាបនោះ ៗ ភ័យ ទុក្ខ ទោមនស្សនុ៎ះកើតហើយព្រោះអ្វី ៗ

តស្ស ស្នេហប្បច្ចយា ច និទ្ទិប្បច្ចយា ច ភយប្បច្ចយា ច និទ្ទិភគប្បច្ចយា ច ជាតំ ។ តមេនំ និរយបាលា និរយេ បក្ខិបន្តិ ។ សោ ខោ បន មហានិរយោ

ចតុក្កណ្ណោ ចតុទ្វារោ វិភត្តោ ភាគសោ មិតោ
អយោបាការបរិយន្តោ អយសា បដិកុជ្ជិតោ ។
តស្ស អយោមយា ភូមិ ជលិតា តេជសា យុតា
សមន្តា យោជនសតំ ផរិត្វា តិដ្ឋតិ សព្វទា ។
កទរិយា តបនា ឃោរា អច្ចិមន្តោ ទុរាសទា
លោមហំសនរូបា ច ភិស្មា បដិភយា ទុក្ខា ។
បុរត្ថិមាយ ច ភិត្តិយា អច្ចិក្ខន្ធោ សមុដ្ឋិតោ
ឌហន្តោ បាបកម្មន្តេ បច្ឆិមាយ បដិហញ្ញតិ ។
បច្ឆិមាយ ច ភិត្តិយា អច្ចិក្ខន្ធោ សមុដ្ឋិតោ
ឌហន្តោ បាបកម្មន្តេ បុរត្ថិមាយ បដិហញ្ញតិ ។
ទក្ខិណាយ ច ភិត្តិយា អច្ចិក្ខន្ធោ សមុដ្ឋិតោ
ឌហន្តោ បាបកម្មន្តេ ឧត្តរាយ បដិហញ្ញតិ ។

កើតហើយដល់សត្វនោះ ព្រោះសេចក្តីស្នេហាជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយជាបច្ច័យខ្លះ ព្រោះតម្រេកជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយនឹងតម្រេកជាបច្ច័យខ្លះ ៗ ពួកនាយនិរយបាល ក៏បោះសត្វនោះទៅក្នុងនរក ៗ មហានរកនោះសោត

មានជ្រុង ៤ មានទ្វារ ៤ ដែលធម្មតាចែករាប់តាមចំណែក ព័ទ្ធព័ទ្ធដោយកំពែងដែក គ្របដោយបន្ទះដែក ៗ ផ្ទៃមហា-នរកនោះ សុទ្ធដែកច្រាលឆ្អៅ ប្រកបដោយកំដៅ ផ្សាយទៅមួយរយយោជន៍ដោយជុំវិញ សព្វកាល ៗ មហានរកទាំងនោះ មានអណ្តាតភ្លើងអាក្រក់ក្តៅពន្លឹក ពុំគួរគ្រេកអរ មានសភាពគួរព្រឺរោម គួរតក់ស្លុត គួរជាទុក្ខ គួរខ្លាច ៗ គំនរអណ្តាតភ្លើង ដែលតាំងឡើងអំពីជញ្ជាំងខាងកើត ឆាបឆេះសត្វទាំងឡាយដែលមានបាបកម្ម ហើយផ្ទប់ទៅត្រង់ជញ្ជាំងខាងលិច ៗ គំនរអណ្តាតភ្លើង ដែលតាំងឡើងអំពីជញ្ជាំងខាងលិច ឆាបឆេះសត្វទាំងឡាយដែលមានបាបកម្ម ហើយផ្ទប់ទៅត្រង់ជញ្ជាំងខាងកើត ៗ គំនរអណ្តាតភ្លើង ដែលតាំងឡើង អំពីជញ្ជាំងខាងត្បូង ឆាបឆេះសត្វទាំងឡាយដែលមានបាបកម្ម ហើយផ្ទប់ទៅត្រង់ជញ្ជាំងខាងជើង ៗ

ខគ្គវិសាណសុត្តនិទ្ទេសោ

ឧត្តរាយ ច ភិត្តិយា អច្ចិក្ខន្ធោ សមុដ្ឋិតោ
ឌហន្តោ បាបកម្មន្តេ ទក្ខិណាយ បដិហញ្ញតិ ។
ហេដ្ឋិតោ ច សមុដ្ឋិតោ អច្ចិក្ខន្ធោ ភយានកោ
ឌហន្តោ បាបកម្មន្តេ ឆទនម្ហិ បដិហញ្ញតិ ។
ឆទនម្ហា សមុដ្ឋិតោ អច្ចិក្ខន្ធោ ភយានកោ
ឌហន្តោ បាបកម្មន្តេ ភូមិយំ បដិហញ្ញតិ ។
អយោកបាលំ អាទិត្តំ សន្តត្តំ ជលិតំ យថា
ឯវំ អវីចិនិរយោ ហេដ្ឋា ឧបរិ បស្សតោ ។
តត្ថ សត្តា មហាលុទ្ទា មហាកិព្ពិសការិនោ
អច្ចន្តបាបកម្មន្តា បច្ចន្តិ ន ច មិយ្យរេ ។
ជាតវេទសមោ កាយោ តេសំ និរយវាសិនំ
បស្ស កម្មានំ ទឡ្ហត្តំ ន ភស្មា ហោន្តិ នបិ មសិ(១)។
បុរត្ថិមេនបិ ធាវន្តិ តតោ ធាវន្តិ បច្ឆតោ
ឧត្តរេនបិ ធាវន្តិ តតោ ធាវន្តិ ទក្ខិណំ ។

---

១ ម. ន ភស្មំ ហោតិ មំ សិបិ ។

ខគ្គវិសាណសុត្តនិទ្ទេស

គំនរអណ្ដាតភ្លើងដែលតាំងឡើងអំពីជញ្ជាំងខាងជើង ឆាបឆេះសត្វទាំងឡាយដែលមានបាបកម្ម ហើយផ្ទប់ទៅត្រង់ជញ្ជាំងខាងត្បូង ។ គំនរអណ្ដាតភ្លើងគួរខ្លាច តាំងឡើងអំពីខាងក្រោម ឆាបឆេះសត្វទាំងឡាយដែលមានបាបកម្ម ហើយផ្ទប់ទៅទឹងដម្បូល ។ គំនរអណ្ដាតភ្លើងគួរខ្លាច តាំងឡើងអំពីដម្បូល ឆាបឆេះសត្វទាំងឡាយដែលមានបាបកម្ម ហើយផ្ទប់មកទឹងផ្ទៃ ។ អំបែងដែក កំពុងឆេះ ក្ដៅសព្វ រុងរឿងយ៉ាងណា នរកអវិចិ (ក៏ប្រាកដ) ដល់សត្វដែលតាំងនៅខាងក្រោមនឹងខាងលើ យ៉ាងនោះដែរ ។ សត្វទាំងឡាយជាអ្នកអាក្រក់ខ្លាំង ធ្វើអំពើអាក្រក់ច្រើន មានអំពើបាបតែមួយយ៉ាង រមែងឆេះ តែមិនស្លាប់ ក្នុងនរកនោះទេ ។ កាយសត្វនរកទាំងឡាយដែលអាស្រ័យនៅក្នុងនរកនោះ ប្រាកដស្មើដោយភ្លើង អ្នកចូរមើលនូវភាពនៃបាបកម្មដ៏មាំមួនចុះ សត្វទាំងនោះមិនទៅជាផេះ ទាំងមិនទៅជាធ្យូង ។ សត្វនរកទាំងឡាយរមែងស្ទុះទៅតាមទិសខាងកើតខ្លះ ស្ទុះចេញអំពីទិសខាងកើតនោះមកកាន់ទិសខាងលិចខ្លះ ស្ទុះទៅតាមទិសខាងជើងខ្លះ ស្ទុះចេញអំពីទិសខាងជើងនោះ មកកាន់ទិសខាងត្បូងខ្លះ ។

យំ យំ ទិសម្បិ ធាវន្តិ តំ តំ ទ្វារំ បិធិយ្យតិ
អភិនិក្ខមិតាសា តេ សត្តា មោក្ខំ គវេសិនោ ។
ន តេ តតោ និក្ខមិតុំ លភន្តិ កម្មប្បច្ចយា
តេសញ្ច បាបកំ កម្មំ អវិបក្កំ កតំ ពហុន្តិ ។

ឯតំ ភយំ ទុក្ខទោមនស្សំ កុតោ ជាតំ ។ តស្ស ស្នេហប្បច្ចយា ច នន្ទិប្បច្ចយា ច រាគប្បច្ចយា ច នន្ទិរាគប្បច្ចយា ច ជាតំ ។ យានិ ច នេរយិកានិ ទុក្ខានិ យានិ ច តិរច្ឆានយោនិកានិ ទុក្ខានិ យានិ ច បិត្តិវិសយិកានិ ទុក្ខានិ យានិ ច មានុសកានិ ទុក្ខានិ តានិ កុតោ ជាតានិ កុតោ សញ្ជាតានិ កុតោ និព្វត្តានិ កុតោ អភិនិព្វត្តានិ កុតោ បាតុភូតានិ ។ ស្នេហប្បច្ចយា ច នន្ទិប្បច្ចយា ច រាគប្បច្ចយា ច នន្ទិរាគប្បច្ចយា ច ភវន្តិ សម្ភវន្តិ ជាយន្តិ សញ្ជាយន្តិ និព្វត្តន្តិ អភិនិព្វត្តន្តិ បាតុភវន្តីតិ ស្នេហន្វយំ ទុក្ខមិទំ បហោតិ ។

សត្វនរកទាំងនោះ ស្ទុះទៅកាន់ទិសណា ៗ ទ្វារក្នុងទិសនោះៗ ក៏បិទជិតឯង សត្វទាំងនោះ សុទ្ធតែមានសេចក្តីប្រាថ្នាដើម្បីចេញ ស្វែងរកនូវការចេញ ៗ សត្វនរកទាំងនោះ ចេញអំពីនរកនោះមិនបាន ព្រោះកម្មជាបច្ច័យ ព្រោះថាបាបកម្មរបស់សត្វទាំងនោះ មានច្រើនយ៉ាង ដែលខ្លួនធ្វើហើយ ជាកម្មមិនទាន់ទំ ៗ

ភ័យ ទុក្ខ ទោមនស្សនុ៎ះ កើតហើយព្រោះអ្វី ៗ កើតហើយដល់សត្វនោះ ព្រោះសេចក្តីស្នេហាជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយជាបច្ច័យខ្លះ ព្រោះតម្រេកជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយនឹងតម្រេកជាបច្ច័យខ្លះ ៗ ទុក្ខណាមានក្នុងនរកក្តី ទុក្ខណាមានក្នុងកំណើតតិរច្ឆានក្តី ទុក្ខណាមានក្នុងបិត្តិវិស័យក្តី ទុក្ខណាមានក្នុងពួកមនុស្សក្តី ទុក្ខទាំងនោះ កើតហើយព្រោះអ្វី កើតព្រមហើយព្រោះអ្វី ដុះដាលហើយព្រោះអ្វី ចំរើនហើយព្រោះអ្វី កើតប្រាកដហើយព្រោះអ្វី ៗ ទុក្ខទាំងនោះ មាន មានព្រម កើត កើតព្រម ដុះដាល ចំរើន កើតប្រាកដ ព្រោះសេចក្តីស្នេហាជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយជាបច្ច័យខ្លះ ព្រោះតម្រេកជាបច្ច័យខ្លះ ព្រោះសេចក្តីរីករាយនឹងតម្រេកជាបច្ច័យខ្លះ ហេតុនោះ (លោកពោលថា) សេចក្តីទុក្ខនេះ មានឡើង ព្រោះអាស្រ័យសេចក្តីស្នេហា ។

[២៣៩] អាទីនវំ ស្នេហជំ បេក្ខមានោតិ ស្នេហោតិ ទ្វេ ស្នេហា តណ្ហាស្នេហោ ច ទិដ្ឋិស្នេហោ ច ។បេ។ អយំ តណ្ហាស្នេហោ ។បេ។ អយំ ទិដ្ឋិស្នេហោ ។ អាទីនវំ ស្នេហជំ បេក្ខមានោតិ តណ្ហាស្នេហេ ច ទិដ្ឋិស្នេហេ ច អាទីនវំ បេក្ខមានោ(១) ឱលោកយមានោ និជ្ឈាយមានោ ឧបបរិក្ខមានោតិ អាទីនវំ ស្នេហជំ បេក្ខមានោ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

សំសគ្គជាតស្ស ភវន្តិ ស្នេហា
ស្នេហន្វយំ ទុក្ខមិទំ បហោតិ
អាទីនវំ ស្នេហជំ បេក្ខមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

---

១ ម. បេក្ខមានោ ទក្ខមានោ ។

ខគ្គវិសាណសុត្តនិទ្ទេស

(៦៣៩) អធិប្បាយពាក្យថា បុគ្គលកាលសំឡឹងឃើញទោសដែលកើតអំពីសេចក្តីស្នេហា ត្រង់ពាក្យថា សេចក្តីស្នេហា បានដល់សេចក្តីស្នេហា ២ គឺ តណ្ហាស្នេហា ១ ទិដ្ឋិស្នេហា ១ ។ បេ ។ នេះតណ្ហាស្នេហា ។ បេ ។ នេះទិដ្ឋិស្នេហា ។ ពាក្យថា បុគ្គលកាលសំឡឹងឃើញទោសដែលកើតអំពីសេចក្តីស្នេហា បានសេចក្តីថា បុគ្គលកាលសំឡឹងឃើញ រមិលមើល ពិនិត្យមើល ពិចារណាមើល នូវទោសក្នុងតណ្ហាស្នេហាផង ក្នុងទិដ្ឋិស្នេហាផង ហេតុនោះ (លោកពោលថា) បុគ្គលកាលសំឡឹងឃើញទោស ដែលកើតអំពីសេចក្តីស្នេហា ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

សេចក្តីស្នេហា របស់បុគ្គលអ្នកមានការជាប់ចំពាក់ រមែង
មាន សេចក្តីទុក្ខនេះ មានឡើង ព្រោះអាស្រ័យសេចក្តី
ស្នេហា បុគ្គលកាលសំឡឹងឃើញទោស ដែលកើតអំពី
សេចក្តីស្នេហា គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[២៤០] មិត្តេ សុហជ្ជេ អនុកម្បមានោ
ហាបេតិ អត្ថំ បដិពទ្ធចិត្តោ
ឯតំ ភយំ សន្ថវេ បេក្ខមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

[២៤១] មិត្តេ សុហជ្ជេ អនុកម្បមានោ ហាបេតិ អត្ថំ បដិពទ្ធចិត្តោតិ មិត្តាតិ ទ្វេ មិត្តា អាគារិកមិត្តោ ច អនាគារិកមិត្តោ ច ។

កតមោ អាគារិកមិត្តោ ។ ឥធេកច្ចោ ទុទ្ទទំ ទទាតិ ទុច្ចជំ ចជតិ ទុក្ករំ ករោតិ ទុក្ខមំ ខមតិ គុយ្ហមស្ស អាចិក្ខតិ គុយ្ហមស្ស បរិគុយ្ហតិ អាបទាសុ ន វិជហតិ ជីវិតំ ចស្ស អត្ថាយ បរិច្ចត្តំ ហោតិ ខីណេ នាតិមញ្ញតិ អយំ អាគារិកមិត្តោ ។

កតមោ អនាគារិកមិត្តោ(១) ។ ឥធ ភិក្ខុ បិយោ ច ហោតិ មនាបោ ច ហោតិ គរុ ច ភាវនីយោ ច វចនក្ខមោ ច គម្ភីរញ្ច កថំ កត្តា អដ្ឋានេ ច ន និយោជេតិ(២) អធិសីលេ សមាទបេតិ

---

១ ម. បព្វជិតមិត្តោ ។ ២ ម. នោ ច អដ្ឋានេ និយោជេតិ ។

(២៨០) បុគ្គលអ្នកមានចិត្តជាប់ចំពាក់ កាលអនុគ្រោះចំពោះ
មិត្ត នឹងអ្នកមានចិត្តល្អ រមែងញ៉ាំងប្រយោជន៍ ឲ្យវិនាស
បុគ្គលកាលសំឡឹងឃើញភ័យ ក្នុងការស្និទ្ធស្នាលនុ៎ះ គប្បី
ប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(២៨១) អធិប្បាយពាក្យថា បុគ្គលអ្នកមានចិត្តជាប់ចំពាក់ កាលអនុគ្រោះចំពោះមិត្តអ្នកមានចិត្តល្អ រមែងញ៉ាំងប្រយោជន៍ឲ្យវិនាស ត្រង់ពាក្យថា មិត្ត បានដល់មិត្ត ២ គឺ អាគារិកមិត្ត ១ អនាគារិកមិត្ត ១ ។

អាគារិកមិត្ត តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ឲ្យវត្ថុដែលគេឲ្យបានដោយក្រ លះបង់វត្ថុដែលគេលះបង់បានដោយក្រ ធ្វើអំពើដែលគេធ្វើបានដោយក្រ អត់ទ្រាំហេតុដែលគេអត់ទ្រាំបានដោយក្រ ប្រាប់ការកំបាំងដល់មិត្តនោះ លាក់ការកំបាំងរបស់មិត្តនោះ មិនលះបង់គ្នាក្នុងកាលមានអន្តរាយ សូម្បីជីវិតក៏ហ៊ានលះបង់ ដើម្បីប្រយោជន៍ដល់មិត្តនោះ មិនមើលងាយមិត្ត ក្នុងកាលមិត្តអស់ទ្រព្យ នេះអាគារិកមិត្ត ។

អនាគារិកមិត្ត តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ រមែងជាទីស្រឡាញ់ផង ជាទីពេញចិត្តផង គួរគោរពផង គួរអ្នកផងសើបផង អត់ធន់ក្នុងពាក្យពោលផង ធ្វើពាក្យឲ្យជ្រាលជ្រៅផង មិនដឹកនាំក្នុងហេតុមិនគួរផង ដឹកនាំក្នុងអធិសីល ដឹកនាំក្នុងការប្រកបរឿយ ៗ

ចតុន្នំ សតិប្បដ្ឋានានំ ភាវនានុយោគេ សមាទបេតិ ចតុន្នំ សម្មប្បធានានំ ។ បេ ។ ចតុន្នំ ឥទ្ធិបាទានំ បញ្ចន្នំ ឥន្ទ្រិយានំ បញ្ចន្នំ ពលានំ សត្តន្នំ ពោជ្ឈង្គានំ អរិយស្ស អដ្ឋង្គិកស្ស មគ្គស្ស ភាវនានុយោគេ សមាទបេតិ អយំ អនាគារិកមិត្តោ ។

សុហជ្ជា វុច្ចន្តិ យេហិ សហ គមនំ ផាសុ អាគមនំ ផាសុ គមនាគមនំ ផាសុ ឋានំ ផាសុ និស្ស-ជ្ជំ ផាសុ សយនំ ផាសុ អាលបនំ ផាសុ សល្លបនំ ផាសុ ឧល្លបនំ ផាសុ សមុល្លបនំ ផាសុ ។

មិត្តេ សុហជ្ជេ អនុកម្បមានោ ហាបេតិ អត្ថន្តិ មិត្តេ ច សុហជ្ជេ ច សន្ទិដ្ឋេ ច សម្ភត្តេ ច សហាយេ ច អនុកម្បមានោ អនុបេក្ខមានោ អនុគ្គណ្ហមានោ អត្តត្ថម្បិ បរត្ថម្បិ ហាបេតិ ឧភយត្ថម្បិ ហាបេតិ ទិដ្ឋធម្មិកម្បិ អត្ថំ ហាបេតិ សម្បរាយិកម្បិ អត្ថំ ហាបេតិ បរមត្ថម្បិ ហាបេតិ បរិធំសេតិ បរិសជ្ជេតិ អន្តរធាបេតីតិ មិត្តេ សុហជ្ជេ អនុកម្បមានោ ហាបេតិ អត្ថំ ។

នូវការចំរើនសតិប្បដ្ឋាន ៤ ដឹកនាំក្នុងការប្រកបរឿយៗ នូវការចំរើនសម្ម-ប្បធាន ៤ ។ បេ ។ នូវឥទ្ធិបាទ ៤ នូវឥន្ទ្រិយ ៥ នូវពលៈ ៥ នូវពោជ្ឈង្គៈ ៧ នូវអរិយមគ្គមានអង្គ ៨ ផង នេះអនាគារិកមិត្ត ។

ការដើរទៅជាសុខ ការមកជាសុខ ការទៅមកជាសុខ ការឈរជាសុខ ការអង្គុយជាសុខ ការដេកជាសុខ ការហៅរកជាសុខ ការនិយាយរកគ្នាជាសុខ ការនិយាយឆ្លើយឆ្លងគ្នាជាសុខ ការនិយាយស្រុះស្រួលគ្នាជាសុខ ជាមួយនឹងពួកជនណា ពួកជននោះ លោកហៅថា អ្នកមានចិត្តល្អ ។

ពាក្យថា បុគ្គលកាលអនុគ្រោះចំពោះមិត្តនឹងអ្នកមានចិត្តល្អ រមែងញុំាងប្រយោជន៍ឲ្យវិនាស គឺបុគ្គលកាលអនុគ្រោះ ទំនុកបម្រុង ផ្ចុងផ្តើម ចំពោះមិត្តផង ចំពោះអ្នកមានចិត្តល្អផង ចំពោះជនដែលធ្លាប់ឃើញគ្នាផង ចំពោះជនដែលគប់គ្នាស្និទ្ធផង ចំពោះសំឡាញ់ផង រមែងញុំាងប្រយោជន៍ខ្លួន នឹងប្រយោជន៍អ្នកដទៃឲ្យវិនាស ញុំាងប្រយោជន៍ទាំងពីរឲ្យវិនាស ញុំាងប្រយោជន៍បច្ចុប្បន្ន ឲ្យវិនាស ញុំាងប្រយោជន៍បរលោកឲ្យវិនាស ញុំាងប្រយោជន៍ដ៏ក្រៃលែងឲ្យវិនាស ឲ្យខ្ចាត់ខ្ចាយ ឲ្យបាត់បង់ ឲ្យអន្តរ-ធាន ហេតុនោះ (លោកពោលថា) បុគ្គលកាលអនុគ្រោះចំពោះមិត្តនឹងអ្នកមានចិត្តល្អ រមែងញុំាងប្រយោជន៍ឲ្យវិនាស ។

បដិពទ្ធចិត្តោតិ ទ្វីហិ ការណេហិ បដិពទ្ធចិត្តោ ហោតិ អត្តានំ វា នីចំ ឋបេន្តោ បរំ ឧច្ចំ ឋបេន្តោ បដិពទ្ធចិត្តោ ហោតិ អត្តានំ វា ឧច្ចំ ឋបេន្តោ បរំ នីចំ ឋបេន្តោ បដិពទ្ធចិត្តោ ហោតិ ។

កថំ អត្តានំ នីចំ ឋបេន្តោ បរំ ឧច្ចំ ឋបេន្តោ បដិពទ្ធចិត្តោ ហោតិ ។ តុម្ហេ មេ ពហូបការា អហំ តុម្ហេ និស្សាយ លភាមិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ យម្បិ(១) មេ អញ្ញេ ទាតុំ វា កាតុំ វា មញ្ញន្តិ តុម្ហេ និស្សាយ តុម្ហេ សម្បស្សន្តា យម្បិ មេ បោរាណំ មាតាបេត្តិកំ នាមគោត្តំ តម្បិ(២) អន្តរហិតំ តុម្ហេហិ អហំ ញាយាមិ អសុកស្ស កុលុបកោ អសុកាយ កុលុបកោតិ ឯវំ អត្តានំ នីចំ ឋបេន្តោ បរំ ឧច្ចំ ឋបេន្តោ បដិពទ្ធចិត្តោ ហោតិ ។

---

១ ម. យេបិ ។ ២ ម. តម្បិ មេ ។

ពាក្យថា អ្នកមានចិត្តជាប់ចំពាក់ គឺ ជាអ្នកមានចិត្តជាប់ចំពាក់ ដោយហេតុ ២ គឺ ជាអ្នកមានចិត្តជាប់ចំពាក់ តាំងខ្លួនឲ្យទាប តាំងអ្នកដទៃឲ្យខ្ពស់ ឬជាអ្នកមានចិត្តជាប់ចំពាក់ តាំងខ្លួនឲ្យខ្ពស់ តាំងអ្នកដទៃឲ្យទាប ។

បុគ្គលជាអ្នកមានចិត្តជាប់ចំពាក់ តាំងខ្លួនឲ្យទាប តាំងបុគ្គលដទៃឲ្យខ្ពស់ តើដូចម្តេច ។ បុគ្គលនោះពោលថា លោកមានឧបការៈច្រើនដល់ខ្ញុំ ខ្ញុំបានចីវរ បិណ្ឌបាត សេនាសនៈ នឹងថ្នាំគ្រឿងរក្សារោគជាបរិក្ខាររបស់ជីវិត ព្រោះអាស្រ័យលោក ជនទាំងឡាយដទៃ កាលអាស្រ័យលោក ឃើញលោក ទើបសំគាល់ដើម្បីឲ្យ ឬដើម្បីធ្វើវត្តណា ដល់ខ្ញុំក្តី នាមនឹងគោត្រណា ជារបស់មាតាបិតាដែលមានពីមុន របស់ខ្ញុំក្តី សូម្បីវត្តនោះ ទាំងនាមនឹងគោត្រនោះ ក៏បាត់បង់ទៅហើយ (ហេតុនេះ) ខ្ញុំសុំទទួលស្គាល់លោកថា ជាជីតុនរបស់បុរសឯណោះ ជាជីតុនរបស់ស្ត្រីឯណោះ បុគ្គលជាអ្នកមានចិត្តជាប់ចំពាក់ តាំងខ្លួនឲ្យទាប តាំងអ្នកដទៃឲ្យខ្ពស់ យ៉ាងនេះឯង ។

## ខគ្គវិសាណសុត្តនិទ្ទេសោ

កថំ អត្តានំ ឧច្ចំ ឋបេត្វា បរំ នីចំ ឋបេត្វា បដិពទ្ធចិត្តោ ហោតិ ។ អហំ តុម្ហាកំ ពហូបការោ តុម្ហេ មំ អាគម្ម ពុទ្ធំ សរណំ គតា ធម្មំ សរណំ គតា សង្ឃំ សរណំ គតា បាណាតិបាតា បដិវិរតា អទិន្នាទានា បដិវិរតា កាមេសុមិច្ឆាចារា បដិវិរតា មុសាវាទា បដិវិរតា សុរាមេរយមជ្ជបមាទដ្ឋានា បដិវិរតា អហំ តុម្ហាកំ ឧទ្ទេសម្បិ បរិបុច្ឆម្បិ សីលម្បិ ឧបោសថម្បិ អាចិក្ខាមិ នវកម្មំ អធិដ្ឋាមិ អថ ច បន តុម្ហេ មំ បរិច្ចជិត្វា អញ្ញេ សក្ករោថ គរុករោថ មានេថ បូជេថាតិ ឯវំ អត្តានំ ឧច្ចំ ឋបេត្វា បរំ នីចំ ឋបេត្វា បដិពទ្ធចិត្តោ ហោតីតិ មិត្តេ សុហជ្ជេ អនុកម្បមានោ ហាបេតិ អត្ថំ បដិពទ្ធចិត្តោ ។

(២៤៦) ឯតំ ភយំ សន្ថវេ បេក្ខមានោតិ ភយន្តិ ជាតិភយំ ជរាភយំ ព្យាធិភយំ មរណភយំ រាជភយំ ចោរភយំ អគ្គិភយំ ឧទកភយំ អត្តានុវាទភយំ បរានុវាទភយំ ទណ្ឌភយំ ទុគ្គតិភយំ ឩមិភយំ

## ខគ្គវិសាណសុត្តនិទ្ទេស

បុគ្គលជាអ្នកមានចិត្តជាប់ចំពាក់ តាំងខ្លួនឲ្យខ្ពស់ តាំងអ្នកដទៃឲ្យទាប តើដូចម្តេច ។ បុគ្គលនោះពោលថា ខ្ញុំមានឧបការៈច្រើនដល់លោក លោកអាស្រ័យខ្ញុំ ទើបដល់ព្រះពុទ្ធជាទីពឹង ដល់ព្រះធម៌ជាទីពឹង ដល់ព្រះសង្ឃជាទីពឹង វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារៈ វៀរចាកមុសាវាទ វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ ក្នុងទឹកស្រវឹងគឺសុរានិងមេរ័យ ខ្ញុំបានប្រាប់ឧទ្ទេសផង បរិបុច្ឆាផង សីលផង ឧបោសថផង អធិដ្ឋាននវកម្ម ដល់លោក ប៉ុន្តែលោកលះបង់ខ្ញុំ ទៅធ្វើសក្ការៈ គោរព រាប់អាន បូជា ចំពោះបុគ្គលដទៃវិញ បុគ្គលជាអ្នកមានចិត្តជាប់ចំពាក់ តាំងខ្លួនឲ្យខ្ពស់ តាំងអ្នកដទៃឲ្យទាប យ៉ាងនេះឯង ហេតុនោះ (លោកពោលថា) បុគ្គលអ្នកមានចិត្តជាប់ចំពាក់ កាលអនុគ្រោះចំពោះមិត្តនិងអ្នកមានចិត្តល្អ រមែងញុំាងប្រយោជន៍ឲ្យវិនាស ។

(២៤២) អធិប្បាយពាក្យថា បុគ្គលកាលសំឡឹងឃើញភ័យ ក្នុងការសិទ្ធស្នាលនុ៎ះ ត្រង់ពាក្យថា ភ័យ បានដល់ភ័យអំពីជាតិ ភ័យអំពីជរា ភ័យអំពីព្យាធិ ភ័យអំពីមរណៈ ភ័យអំពីព្រះរាជា ភ័យអំពីចោរ ភ័យអំពីភ្លើង ភ័យអំពីទឹក ភ័យអំពីការតិះដៀលខ្លួនឯង ភ័យអំពីការតិះដៀលរបស់បុគ្គលដទៃ ភ័យអំពីអាជ្ញា ភ័យអំពីទុគ្គតិ ភ័យអំពីរលកទឹក

កុម្ភិលភយំ អាវដ្ដភយំ សុសុមារភយំ អាជីវិកាភយំ អសិលោកភយំ បរិសសារជ្ជភយំ(១) ភយានកំ ឆម្ភិតត្តំ លោមហំសោ ចេតសោ ឧព្វេគ្គោ ឧត្រាសោ ។ សន្ថវេតិ ទ្វេ សន្ថវា តណ្ហាសន្ថវោ ច ទិដ្ឋិសន្ថវោ ច ។បេ។ អយំ តណ្ហាសន្ថវោ ។បេ។ អយំ ទិដ្ឋិសន្ថវោ ។ ឯតំ ភយំ សន្ថវេ បេក្ខមានោតិ ឯតំ ភយំ សន្ថវេ បេក្ខមានោ(២) ឱលោកយមានោ និជ្ឈាយមានោ ឧបបរិក្ខមានោតិ ឯតំ ភយំ សន្ថវេ បេក្ខមានោ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

មិត្តេ សុហជ្ជេ អនុកម្បមានោ
ហាបេតិ អត្ថំ បដិពទ្ធចិត្តោ
ឯតំ ភយំ សន្ថវេ បេក្ខមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

---

១ ម. បរិស្សយសារជ្ជភយំ មទនភយំ ។ ២ ម. បេក្ខមានោ ទក្ខមានោ ។

ភ័យអំពីក្រពើ ភ័យអំពីទឹកក្អួច ភ័យអំពីត្រីសាហាវ ភ័យអំពីការរកចិញ្ចឹមជីវិត ភ័យអំពីការមិនសរសើរ ភ័យអំពីសេចក្តីរញោចរញៀមក្នុងបរិស័ទ ហេតុគួរខ្លាច ការញាប់ញ័រ ការព្រឺរោម ការរន្ធត់ចិត្ត ការតក់ស្លុត ។ ពាក្យថា ការស្និទ្ធស្នាល បានដល់សេចក្តីស្និទ្ធស្នាល ២ គឺ សេចក្តីស្និទ្ធស្នាលគឺតណ្ហា ១ សេចក្តីស្និទ្ធស្នាលគឺទិដ្ឋិ ១ ។ បេ ។ នេះសេចក្តីស្និទ្ធស្នាល គឺតណ្ហា ។ បេ ។ នេះ សេចក្តីស្និទ្ធស្នាលគឺទិដ្ឋិ ។ ពាក្យថា បុគ្គល កាលសំឡឹងឃើញភ័យ ក្នុងសេចក្តីស្និទ្ធស្នាលនុ៎ះ បានសេចក្តីថា បុគ្គលកាលសំឡឹងឃើញ ក្រឡេកមើល ពិនិត្យមើល ពិចារណាមើល នូវភ័យក្នុងសេចក្តីស្និទ្ធស្នាលនុ៎ះ ហេតុនោះ (លោកពោលថា) បុគ្គលកាលសំឡឹងឃើញភ័យ ក្នុងសេចក្តីស្និទ្ធស្នាលនុ៎ះ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

បុគ្គលអ្នកមានចិត្តជាប់ចំពាក់ កាលអនុគ្រោះចំពោះ
មិត្តនិងអ្នកមានចិត្តល្អ រមែងញុំាងប្រយោជន៍ឲ្យវិនាស
បុគ្គលកាលសំឡឹងឃើញភ័យ ក្នុងការស្និទ្ធស្នាលនុ៎ះ
គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

ខគ្គវិសាណសុត្តនិទ្ទេសោ

(២៤៣) វំសោ វិសាលោវ យថា វិសត្តោ
បុត្តេសុ ទារេសុ ច យា អបេក្ខា
វំសក្កឡីរោវ(១) អសជ្ជមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

(២៥៤) វំសោ វិសាលោវ យថា វិសត្តោតិ វំសោ វុច្ចតិ វេឡុគុម្ពោ ។ យថា វេឡុគុម្ពស្មឹ កណ្ដកា ជដិតា សំសិព្វិតា វិសត្តា លគ្គា(២) លគ្គិតា បលិពទ្ធា ឯវមេវ វិសត្តិកា វុច្ចតិ តណ្ហា យោ រាគោ សារាគោ អនុនយោ អនុរោធោ នន្ទិ នន្ទិរាគោ ចិត្តស្ស សារាគោ ឥច្ឆា មុច្ឆា អជ្ឈោសានំ គេធោ បលិគេធោ សង្គោ បង្កោ ឯជា មាយា ជនិកា សញ្ជននី សិព្វិនី ជាលិនី សរិតា វិសត្តិកា សោត្តំ វិសតា អាយូហនី ទុតិយា បណិធិ ភវនេត្តិ វនំ វនថោ សន្ថវោ សិនេហោ អបេក្ខា បដិពទ្ធា អាសា អាសីសនា អាសីសិតត្តំ

---

១ ម. វំសេកឡីរោវ ។ ២ ម. យថា វេឡុគុម្ពស្មឹ បោរាណកា វំសា សត្តា វិសត្តា អសត្តា លគ្គា ។

ខគ្គវិសាណសុត្តនិទ្ទេស

(៤៤៣) អាល័យណា ក្នុងពួកបុត្តនិងប្រពន្ធ អាល័យនោះ តាក់ស្រែះ ដូចឫស្សី មានមែកសាំងញ៉ាំង បុគ្គលមិនជាប់ចំពាក់ ដូចទំពាំងឫស្សី គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(៤៤៤) ពាក្យថា អាល័យនោះ តាក់ស្រែះ ដូចឫស្សីមានមែកសាំងញ៉ាំង អធិប្បាយថា គុម្ពឫស្សី ហៅថា ឫស្សី ។ បន្ទាក្នុងគុម្ពឫស្សី សាំញ៉ាំ តាក់ស្រែះ តាក់តណ្ដាញ់ ប្រទាក់គ្នា ធ្លាក់គ្នា ជាប់គ្នា យ៉ាងណាមិញ តណ្ហា លោកពោលថា វិសត្តិកា ក៏យ៉ាងនោះដែរ គឺបានខាងតម្រេក តម្រេកខ្លាំង សេចក្ដីត្រេកអរ សេចក្ដីស្រើបស្រាល សេចក្ដីរីករាយ សេចក្ដីត្រេកត្រអាល តម្រេកខ្លាំងនៃចិត្ត ការចង់បាន ការជ្រប់ចិត្ត ការងប់ចិត្ត ការប្រាថ្នា ការប្រាថ្នាខ្លាំង ការជាប់នៅ កិលេសដូចភក់ ការញាប់ញ័រ កិលេសជាតិជាគ្រឿងបិទបាំងទោស កិលេសជាតិនាំឲ្យកើត ញុំាងទុក្ខឲ្យកើត ជាគ្រឿងដេរភ្ជាប់ ដូចជាបណ្ដាញ ជាទីហូរទៅ ជាគ្រឿងតាក់ស្រែះ ដូចជាខ្សែ ផ្សាយទៅ ជាគ្រឿងប្រមូលមក ជាគំរប់ពីរ (របស់សត្វ) ជាគ្រឿងតំកល់ទុក ជាគ្រឿងនាំទៅកាន់ភព ដូចជាព្រៃតូច ព្រៃធំ សេចក្ដីស្និទ្ធស្នាល សេចក្ដីស្នេហា ការអាល័យ ការជាប់ចំពោះ ចំណង់ ការប៉ុនប៉ង ភាពនៃសេចក្ដីប៉ុនប៉ង

រូបាសា សទ្ទាសា គន្ធាសា រសាសា ផោដ្ឋព្វាសា លាភាសា ធនាសា បុត្តាសា ជីវិតាសា ជប្បា បជប្បា អភិជប្បា ជប្បាយនា ជប្បិតត្តំ លោលុប្បា លោលុប្បាយនា លោលុប្បិតត្តំ បុច្ចញ្ចិកតា(១) អសាធុកម្យតា អធម្មរាគោ វិសមរាគោ វិសមលោភោ និកន្តិ និកាមនា បត្ថនា បិហនា សម្បត្ថនា កាមតណ្ហា ភវតណ្ហា វិភវតណ្ហា រូបតណ្ហា អរូបតណ្ហា និរោធតណ្ហា រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ឱឃោ យោគោ គន្ថោ ឧបាទានំ អាវរណំ នីវរណំ ឆទនំ ពន្ធនំ ឧបក្កិលេសោ អនុសយោ បរិយុដ្ឋានំ លតា វេវិច្ឆំ ទុក្ខមូលំ ទុក្ខនិទានំ ទុក្ខប្បភវោ មារបាសោ មារពលិសំ មារវិសយោ មារនិវាសោ មារពន្ធនំ តណ្ហានទី តណ្ហាជាលំ តណ្ហាគទ្ទុលំ តណ្ហាសមុទ្ទោ អភិជ្ឈា លោភោ អកុសលមូលំ ។

---

១ ម. បុច្ឆញ្ជិកតា ។

ការប៉ុនប៉ងរូប ការប៉ុនប៉ងសំឡេង ការប៉ុនប៉ងក្លិន ការប៉ុនប៉ងរស ការប៉ុនប៉ងផ្សព្វ ការប៉ុនប៉ងលាភ ការប៉ុនប៉ងទ្រព្យ ការប៉ុនប៉ងបុត្ត ការប៉ុនប៉ងជីវិត ការជាប់ចិត្ត ការជាប់ចិត្តទួទៅ ការជាប់ចិត្តខ្លាំង អាការជាទីជាប់ចិត្ត ភាពនៃការជាប់ចិត្ត ការរវះរវាម អាការជាទីរវះរវាម ភាពនៃចិត្តរវះរវាម ការធ្វើឲ្យញាប់ញ័រ ការធ្វើមិនប្រពៃ តម្រេកមិនត្រូវតាមធម៌ តម្រេកមិនពេះល្មម លោភមិនល្មម ការស្រឡាញ់ ការកួចកាន់ ការប្រាថ្នា ការពេញចិត្ត ការប្រាថ្នាខ្លាំង ការអន្ទះសាក្នុងកាម ការអន្ទះសាក្នុងភព ការអន្ទះសាក្នុងវិភព ការអន្ទះសាក្នុងរូប ការអន្ទះសាក្នុងអរូប ការអន្ទះសាក្នុងនិរោធ ការអន្ទះសាក្នុងរូប ការអន្ទះសាក្នុងសំឡេង ការអន្ទះសាក្នុងក្លិន ការអន្ទះសាក្នុងរស ការអន្ទះសាក្នុងផ្សព្វ ការអន្ទះសាក្នុងធម្មារម្មណ៍ កិលេសដូចជាជំនន់ ជាគ្រឿងប្រកបទុក ជាគ្រឿងរួបរឹត ជាគ្រឿងថ្ពក់ ជាគ្រឿងពាំង ជាគ្រឿងហាម ជាគ្រឿងប្រក់ ជាគ្រឿងចង គ្រឿងសៅហ្មង ជាគ្រឿងដេកនៅរឿយៗ ជាគ្រឿងស្អាក់ វល្លិគឺតណ្ហា សេចក្តីប្រាថ្នាផ្សេងៗ ឫសគល់នៃទុក្ខ ហេតុនៃទុក្ខ ដែនផ្តើមកើតទុក្ខ អន្ទាក់មារ សន្ទូចមារ វិស័យមារ លំនៅមារ ចំណងមារ ស្ទឹងគឺតណ្ហា បណ្តាញគឺតណ្ហា ដងដោយគឺតណ្ហា សមុទ្រគឺតណ្ហា អភិជ្ឈា លោភៈ អកុសលមូល ។

## ខគ្គវិសាណសុត្តនិទ្ទេសោ

វិសត្តិកាតិ កេនដ្ឋេន វិសត្តិកា ។ វិសតាតិ វិសត្តិកា ។ វិសាលាតិ វិសត្តិកា ។ វិសដាតិ វិសត្តិកា(១) ។ វិសក្កតីតិ វិសត្តិកា ។ វិសំហរតីតិ វិសត្តិកា ។ វិសំវាទិកាតិ វិសត្តិកា ។ វិសមូលាតិ វិសត្តិកា ។ វិសផលាតិ វិសត្តិកា ។ វិសបរិភោគាតិ វិសត្តិកា ។ វិសាលា វា បន សា តណ្ហា រូបេ សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ កុលេ គណេ អាវាសេ លាភេ យសេ បសំសាយ សុខេ ចីវរេ បិណ្ឌបាតេ សេនាសនេ គិលានប្បច្ចយភេសជ្ជបរិក្ខារេ កាមធាតុយា រូបធាតុយា អរូបធាតុយា កាមភវេ រូបភវេ អរូបភវេ សញ្ញាភវេ អសញ្ញាភវេ នេវសញ្ញានាសញ្ញាភវេ ឯកវោការភវេ ចតុវោការភវេ បញ្ចវោការភវេ អតីតានាគតបច្ចុប្បន្នេ ទិដ្ឋសុតមុតវិញ្ញាតព្វេសុ ធម្មេសុ វិសដា វិត្ថតាតិ វិសត្តិកាតិ វំសោ វិសាលោវ យថា វិសត្តោ ។

១ ម. ឯត្ថន្តរេ វិសតាតិ វិសត្តិកាតិ ទិស្សតិ ។

## ខគ្គវិសាណសុត្តនិទ្ទេស

សំនួរត្រង់ពាក្យថា វិសត្តិកា ចុះកិលេសជាតិ ឈ្មោះថាវិសត្តិកា តើដោយសេចក្តីដូចម្តេច ។ ឈ្មោះថាវិសត្តិកា ព្រោះហេតុផ្សាយទៅ ។ ឈ្មោះថាវិសត្តិកា ព្រោះហេតុធំទូលាយ ។ ឈ្មោះថាវិសត្តិកា ព្រោះហេតុជ្រួតជ្រាប ។ ឈ្មោះថាវិសត្តិកា ព្រោះហេតុអត់ធន់ ។ ឈ្មោះថាវិសត្តិកា ព្រោះហេតុនាំខុស ។ ឈ្មោះថាវិសត្តិកា ព្រោះហេតុពោលខុស ។ ឈ្មោះថាវិសត្តិកា ព្រោះហេតុមានឫសគល់ជាពិស ។ ឈ្មោះថាវិសត្តិកា ព្រោះហេតុមានផ្លែជាពិស ។ ឈ្មោះថាវិសត្តិកា ព្រោះហេតុមានការបរិភោគជាពិស ។ មួយទៀត ឈ្មោះថាវិសត្តិកា ព្រោះហេតុតណ្ហា ដ៏ធំទូលាយ ផ្សាយ លាតទៅ ក្នុងរូប សំឡេង ក្លិន រស ផ្សព្វ ត្រកូល គណៈ អាវាស លាភ យស សេចក្តីសរសើរ សេចក្តីសុខ ចីវរ បិណ្ឌបាត សេនាសនៈ នឹងថ្នាំគ្រឿងរក្សាពេគជាបរិវាររបស់ជីវិត ក្នុងកាមធាតុ រូបធាតុ អរូបធាតុ កាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯកវោការភព ចតុវោការភព បញ្ចវោការភព ក្នុងអតីត អនាគត បច្ចុប្បន្ន ក្នុងអារម្មណ៍ទាំងឡាយដែលឃើញ ឮ ប៉ះពាល់ ដឹងច្បាស់ ហេតុនោះ (លោកពោលថា) អាល័យនោះ ជាក់ស្រែះ ដូចឫស្សី មានមែកសាងញ៉ាង ។

(២៨៥) បុត្តេសុ ទារេសុ ច យា អបេក្ខាតិ បុត្តាតិ ចត្តារោ បុត្តា អត្រជោ បុត្តោ ខេត្រជោ បុត្តោ ទិន្នកោ បុត្តោ អន្តេវាសិកោ បុត្តោ ។ ទារា វុច្ចតិ ភរិយា ។ អបេក្ខា វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។បេ។ អភិជ្ឈា លោភោ អកុសលមូលន្តិ បុត្តេសុ ទារេសុ ច យា អបេក្ខា ។

(២៨៦) វំសក្កឡីរោវ អសជ្ជមានោតិ វំសោ វុច្ចតិ វេឡុគុម្ពោ ។ យថា វេឡុគុម្ពម្ហិ តរុណាកឡីរា(១) អសត្តា អលគ្គា អបលិវេដ្ឋិតា(២) អបលិពទ្ធា និក្ខន្តា និស្សដ្ឋា វិប្បមុត្តា ឯវមេវ ទ្វេ សជ្ជនា តណ្ហាសជ្ជនា ច ទិដ្ឋិសជ្ជនា ច ។បេ។ អយំ តណ្ហាសជ្ជនា ។បេ។ អយំ ទិដ្ឋិសជ្ជនា ។ តស្ស បច្ចេកសម្ពុទ្ធស្ស តណ្ហាសជ្ជនា បហីនា ទិដ្ឋិសជ្ជនា បដិនិស្សដ្ឋា តណ្ហាសជ្ជនាយ បហីនត្តា ទិដ្ឋិសជ្ជនាយ បដិនិស្សដ្ឋត្តា សោ បច្ចេកសម្ពុទ្ធោ រូបេ ន សជ្ជតិ សទ្ទេ ន សជ្ជតិ គន្ធេ ន សជ្ជតិ រសេ ន សជ្ជតិ ផោដ្ឋព្វេ ន សជ្ជតិ

---

១ ម. តរុណកា កឡីរកា ។ ២ ម. អគធិតា ។

(៤៤៥) ពាក្យថា អាល័យណា ក្នុងពួកបុត្តនឹងប្រពន្ធ ត្រង់ពាក្យថា បុត្ត បានដល់បុត្ត ៤ ពួក គឺ បុត្តកើតអំពីខ្លួន ១ បុត្តកើតក្នុងខែត្រ ១ បុត្តដែលគេឲ្យ ១ បុត្តគឺសិស្ស ១ ។ ភរិយា ហៅថា ប្រពន្ធ ។ តណ្ហា ហៅថា អាល័យ បានខាងតម្រេក តម្រេកខ្លាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ហេតុនោះ (លោកពោលថា) អាល័យណា ក្នុងពួកបុត្តនឹងប្រពន្ធ ។

(៤៤៦) ពាក្យថា បុគ្គលមិនជាប់ចំពាក់ ដូចទំពាំងឫស្សី អធិប្បាយថា គុម្ពឫស្សី ហៅថា ឫស្សី ។ ទំពាំងដ៏ខ្ចី ក្នុងគុម្ពឫស្សី មិនជាប់ មិនចំពាក់ មិនព័ទ្ធព័ន្ធ មិនបាក់កណ្តាញ់ គឺចេញ រលាស់ផុតស្រឡះហើយ យ៉ាងណាមិញ ការចំពាក់ ២ គឺ ការចំពាក់គឺតណ្ហា ១ ការចំពាក់គឺទិដ្ឋិ ១ ក៏យ៉ាងនោះដែរ ។ បេ ។ នេះ ការចំពាក់គឺតណ្ហា ។ បេ ។ នេះការចំពាក់គឺទិដ្ឋិ ។ ព្រះបច្ចេកសម្ពុទ្ធនោះ លះការចំពាក់គឺតណ្ហា រលាស់ចោលការចំពាក់គឺទិដ្ឋិហើយ ព្រោះលះការចំពាក់គឺតណ្ហា ព្រោះរលាស់ចោលការចំពាក់គឺទិដ្ឋិ ព្រះបច្ចេកសម្ពុទ្ធនោះ ទើបមិនជាប់ក្នុងរូប មិនជាប់ក្នុងសំឡេង មិនជាប់ក្នុងក្លិន មិនជាប់ក្នុងរស មិនជាប់ក្នុងផ្សព្វ

កុលេ គណេ អាវាសេ លាភេ យសេ បសំសាយ សុខេ ចីវរេ បិណ្ឌបាតេ សេនាសនេ គិលានប្បច្ចយភេសជ្ជបរិក្ខារេ កាមធាតុយា រូបធាតុយា អរូបធាតុយា កាមភវេ រូបភវេ អរូបភវេ សញ្ញាភវេ អសញ្ញាភវេ នេវសញ្ញានាសញ្ញាភវេ ឯកវោការភវេ ចតុវោការភវេ បញ្ចវោការភវេ អតីតានាគតប្បច្ចុប្បន្នេ ទិដ្ឋសុតមុតវិញ្ញាតព្វេសុ ធម្មេសុ ន សជ្ជតិ ន គយ្ហតិ(១) ន ពជ្ឈតិ ន បលិពជ្ឈតិ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសំយុត្តោ វិមរិយាទិកតេន ចេតសា វិហរតីតិ វំសកឡីរោវ អសជ្ជមានោ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

វំសោ វិសាលោវ យថា វិសត្តោ
បុត្តេសុ ទារេសុ ច យា អបេក្ខា
វំសកឡីរោវ អសជ្ជមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

---

១ ម. ន គណ្ហាតិ ។

## ខគ្គវិសាណសុត្តនិទ្ទេស

មិនជាប់ មិនប្រកាន់ មិនចង មិនជាប់ស្អិត ក្នុងត្រកូល គណៈ អាវាស លាភ យស សេចក្ដីសរសើរ សេចក្ដីសុខ ចីវរ បិណ្ឌបាត សេនាសនៈ និងថ្នាំគ្រឿងរក្សាពេលជាបរិក្ខាររបស់ជីវិត ក្នុងកាមធាតុ រូបធាតុ អរូបធាតុ កាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯកវោការភព ចតុវោការភព បញ្ចវោការភព ក្នុងអតីត អនាគត បច្ចុប្បន្ន ក្នុងអារម្មណ៍ទាំងឡាយដែលឃើញ ឮ ប៉ះពាល់ ដឹងច្បាស់ គឺលោកចេញ រលាស់ ផុតស្រឡះ ប្រាសចេញ មានចិត្តប្រាសចាកសេចក្ដីសល់វល់ ហេតុនោះ (លោកពោលថា) បុគ្គលមិនជាប់ចំពាក់ ដូចទំពាំងឫស្សី ៗ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ៗ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

អាល័យណា ក្នុងពួកបុត្តនិងប្រពន្ធ អាល័យនោះ
ចាក់ស្រែះ ដូចឫស្សី មានមែកសាំងញ៉ាំង
បុគ្គលមិនជាប់ចំពាក់ ដូចទំពាំងឫស្សី គប្បីប្រព្រឹត្ត
ម្នាក់ឯង ដូចកុយរមាស ៗ

(៤៤៧) មិគោ អរញ្ញម្ហិ យថា អពទ្ធោ
យេនិច្ឆកំ គច្ឆតិ គោចរាយ
វិញ្ញូ នរោ សេរិត បេក្ខមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

(៤៤៨) មិគោ អរញ្ញម្ហិ យថា អពទ្ធោ យេនិច្ឆកំ គច្ឆតិ គោចរាយាតិ មិគោតិ ទ្វេ មិគា ឯណិមិគោ ច សរភមិគោ ច ។ យថា អារញ្ញកោ មិគោ អរញ្ញេ វសមានោ វិស្សត្ថោ គច្ឆតិ វិស្សត្ថោ តិដ្ឋតិ វិស្សត្ថោ និសីទតិ វិស្សត្ថោ សេយ្យំ កប្បេតិ ។

វុត្តំ ហេតំ ភគវតា សេយ្យថាបិ ភិក្ខវេ អារញ្ញកោ មិគោ អរញ្ញេ បវនេ ចរមានោ វិស្សត្ថោ គច្ឆតិ វិស្សត្ថោ តិដ្ឋតិ វិស្សត្ថោ និសីទតិ វិស្សត្ថោ សេយ្យំ កប្បេតិ

(២៤៧) ម្រឹគក្នុងព្រៃ ជាសត្វមិនជាប់ចំណង ទៅរកចំណី តាមប្រាថ្នាបាន យ៉ាងណា វិញ្ញូជន កាលសំឡឹងឃើញសេរីភាព(១) គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស យ៉ាងនោះ ។

(២៤៨) អធិប្បាយពាក្យថា ម្រឹគក្នុងព្រៃ ជាសត្វមិនជាប់ចំណង ទៅរកចំណី តាមប្រាថ្នាបាន យ៉ាងណា ត្រង់ពាក្យថា ម្រឹគ បានដល់ម្រឹគ ២ ពួកគឺ ឯណិម្រឹគ ១ សរភម្រឹគ ១ ។ ម្រឹគព្រៃកាលនៅក្នុងព្រៃ រមែងដើរទៅឥតរង្កៀស ឈប់ឥតរង្កៀស អង្គុយឥតរង្កៀស សម្រេចការដេកឥតរង្កៀស យ៉ាងណាមិញ ។

សមដូចពាក្យ ដែលព្រះមានព្រះភាគទ្រង់ត្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ ម្រឹគព្រៃកាលត្រាច់ទៅក្នុងព្រៃរហោះ ព្រៃស្បាត រមែងដើរទៅឥតរង្កៀស ឈប់ឥតរង្កៀស អង្គុយឥតរង្កៀស សម្រេចការដេកឥតរង្កៀស

---

១ ការប្រព្រឹត្តិតាមសេចក្តីប្រាថ្នារបស់ខ្លួន មិនជាប់ទាក់ទងនឹងបុគ្គលដទៃ ។ អដ្ឋកថា ។

តំ កិស្ស ហេតុ អឆាទាបកតោ ភិក្ខវេ លុទ្ទស្ស ឯវមេវ ខោ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អន្ធមកាសិ មារំ អបទំ វធិត្វា មារចក្ខុអទស្សនំ គតោ ទាបិមតោ បុនចបរំ ភិក្ខវេ ភិក្ខុ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អន្ធមកាសិ មារំ អបទំ វធិត្វា មារចក្ខុអទស្សនំ គតោ ទាបិមតោ បុនចបរំ ភិក្ខវេ ភិក្ខុ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ

ដំណើរនោះព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា ម្រឹគនោះទៅកន្លែងមិនមែនជាគន្លងរបស់ព្រាន យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកធម៌ទាំងឡាយ ជាអកុសលហើយ ចូលបឋមជ្ឈាន ប្រកបដោយវិតក្កៈនិងវិចារៈ មានបីតិនិងសុខៈដែលកើតអំពីវិវេក ក៏យ៉ាងនោះដែរ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតពោលថា បានធ្វើមារឲ្យងងឹត សម្លាប់មារមិនឲ្យមានជានជើង ដល់នូវការមិនចួបប្រទះដោយភ្នែកមារ របស់មារលាមក ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុចូលទុតិយជ្ឈាន ជាទីផូរផង់ ប្រព្រឹត្តក្នុងសន្តាន មានសេចក្តីជ្រះថ្លាគឺសទ្ធា មានសភាពជាធម្មជាតខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខៈដែលកើតអំពីសមាធិ គឺបឋមជ្ឈាន ព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតពោលថា បានធ្វើមារឲ្យងងឹត សម្លាប់មារមិនឲ្យមានជានជើង ដល់នូវការមិនចួបប្រទះដោយភ្នែកមារ របស់មារលាមក ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកព្រងើយកន្តើយ មានសតិនិងការដឹងច្បាស់ សោយសុខដោយនាមកាយ ព្រោះសាយនៃបីតិ ព្រះអរិយៈទាំងឡាយ តែងសរសើរបុគ្គលដែលបានតតិយជ្ឈាននោះឯង ថាជាបុគ្គលមានចិត្តព្រងើយកន្តើយ មានស្មារតី មានការនៅជាសុខ ភិក្ខុចូលតតិយជ្ឈាននោះ ម្នាល

អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អន្ធមកាសិ មារំ
អបទំ វធិត្វា មារចក្ខុអទស្សនំ គតោ បាបិមតោ
បុនចបរំ ភិក្ខវេ ភិក្ខុ សុខស្ស ច បហានា
ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមន-
ស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធិំ
ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ អយំ វុច្ចតិ
ភិក្ខវេ ភិក្ខុ អន្ធមកាសិ មារំ អបទំ វធិត្វា
មារចក្ខុអទស្សនំ គតោ បាបិមតោ បុនចបរំ
ភិក្ខវេ ភិក្ខុ សព្វសោ រូបសញ្ញានំ សមតិក្កមា
បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមន-
សិការា អនន្តោ អាកាសោតិ អាកាសានញ្ចា-
យតនំ ឧបសម្បជ្ជ វិហរតិ អយំ វុច្ចតិ ភិក្ខវេ
ភិក្ខុ អន្ធមកាសិ មារំ អបទំ វធិត្វា មារចក្ខុអ-
ទស្សនំ គតោ បាបិមតោ បុនចបរំ ភិក្ខវេ ភិក្ខុ
សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ
វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ

ភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតពោលថា បានធ្វើមារឲ្យងងឹត សម្លាប់មារ មិនឲ្យមានដានជើង ដល់នូវការមិនចួបប្រទះដោយភ្នែកមារ របស់មារលាមក ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុចូលចតុត្ថជ្ឈាន ឥតទុក្ខឥតសុខ មានសតិដ៏បរិសុទ្ធដោយឧបេក្ខា ព្រោះលះបង់សុខផង លះបង់ទុក្ខផង ព្រោះដល់នូវការវិនាសនៃសោមនស្សនឹងទោមនស្សក្នុងកាលមុនផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតពោលថា បានធ្វើមារឲ្យងងឹត សម្លាប់មារមិនឲ្យមានដានជើង ដល់នូវការមិនចួបប្រទះដោយភ្នែកមារ របស់មារលាមក ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រោះកន្លងរូបសញ្ញា ព្រោះវិនាសនៃបដិឃសញ្ញា ព្រោះមិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ដោយប្រការទាំងពួង ភិក្ខុចូលអាកាសានញ្ចាយតនៈ (ដោយបរិកម្ម) ថា អាកាសមិនមានទីបំផុត ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតពោលថា បានធ្វើមារឲ្យងងឹត សម្លាប់មារមិនឲ្យមានដានជើង ដល់នូវការមិនចួបប្រទះដោយភ្នែកមារ របស់មារលាមក ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រោះកន្លងអាកាសានញ្ចាយតនៈ ដោយប្រការទាំងពួង ហើយចូលវិញ្ញាណញ្ចាយតនៈ (ដោយបរិកម្ម) ថា វិញ្ញាណ មិនមានទីបំផុត

## ខគ្គវិសាណសុត្តនិទ្ទេសោ

សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ
កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ
សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម សន្តមេតំ
បណីតមេតន្តិ នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ
វិហរតិ សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិ-
ក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ
បញ្ញាយ ចស្ស ទិស្វា អាសវា បរិក្ខីណា ហោន្តិ
អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អន្ធមកាសិ មារំ អបទំ
វធិត្វា មារចក្ខុអទស្សនំ គតោ បាបិមតោ តិណ្ណោ
លោកេ វិសត្តិកំ សោ វិស្សត្ថោ គច្ឆតិ វិស្សត្ថោ
តិដ្ឋតិ វិស្សត្ថោ និសីទតិ វិស្សត្ថោ សេយ្យំ
កប្បេតិ តំ កិស្ស ហេតុ អនាបាថគតោ ភិក្ខវេ
បាបិមតោតិ ។ មិគោ អរញ្ញម្ហិ យថា អពន្ធោ
យេនិច្ឆកំ គច្ឆតិ គោចរាយ ។

## ខគ្គវិសាណសុត្តនិទ្ទេស

ព្រោះកន្លងវិញ្ញាណញ្ចាយតនៈ ដោយប្រការទាំងពួង ភិក្ខុចូលអាកិញ្ចញ្ញាយតនៈ (ដោយបរិកម្ម) ថា វត្ថុតិចតួចមិនមាន ព្រោះកន្លងអាកិញ្ចញ្ញាយតនៈ ដោយប្រការទាំងពួង ហើយចូលនេវសញ្ញានាសញ្ញាយតនៈ (ដោយបរិកម្ម) ថា ធម្មជាតនុ៎ះ ជាគុណដ៏ស្ងប់ ធម្មជាតនុ៎ះ ជាគុណដ៏ឧត្តម ព្រោះកន្លងនេវសញ្ញានាសញ្ញាយតនៈ ដោយប្រការទាំងពួង ហើយចូលសញ្ញាវេទយិតនិរោធ ទាំងអាសវៈទាំងឡាយ របស់ភិក្ខុនោះក៏អស់ ព្រោះឃើញដោយបញ្ញា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះតថាគតពោលថា បានធ្វើមារឲ្យងងឹត សម្លាប់មារមិនឲ្យមានដានជើង ដល់នូវការមិនចួបប្រទះដោយភ្នែកមារ របស់មារលាមក បានឆ្លងតណ្ហា ឈ្មោះវិសត្តិកាក្នុងលោក ភិក្ខុនោះរមែងដើរទៅឥតរង្កៀស ឈរឥតរង្កៀស អង្គុយឥតរង្កៀស សម្រេចការដេកឥតរង្កៀស ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ (ព្រោះថា) ភិក្ខុនោះនៅក្នុងទីមិនមែនជាគន្លងនៃមារដ៏លាមក ហេតុនោះ (លោកពោលថា) ម្រឹគក្នុងព្រៃ ជាសត្វមិនជាប់ចំណង ទៅរកចំណី តាមប្រាថ្នាបាន យ៉ាងណា ។

(២៤៩) វិញ្ញូ នរោ សេវិត បេក្ខមានោតិ វិញ្ញូតិ វិញ្ញូ បណ្ឌិតោ បញ្ញវា ពុទ្ធិមា ញាណី វិភាវី មេធាវី ។ នរោតិ សត្តោ មាណវោ បោសោ បុគ្គលោ ជីវោ ជាគុ(១) ជន្តុ ឥន្ទគូ(២) មនុជោ ។ សេវីតិ ទ្វេ សេវី ធម្មោបិ សេវី បុគ្គលោបិ សេវី ។

កតមោ ធម្មោ សេវី ។ ចត្តារោ សតិប្បដ្ឋានា ចត្តារោ សម្មប្បធានា ចត្តារោ ឥទ្ធិបាទា បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ ។ អយំ ធម្មោ សេវី ។

កតមោ បុគ្គលោ សេវី ។ យោ ឥមិនា សេវិនា ធម្មេន សមន្នាគតោ សោ វុច្ចតិ បុគ្គលោ សេវី ។

វិញ្ញូ នរោ សេវិត បេក្ខមានោតិ វិញ្ញូ នរោ សេវិតំ ធម្មំ បេក្ខមានោ ឱលោកយមានោ និជ្ឈាយមានោ ឧបបរិក្ខមានោតិ វិញ្ញូ នរោ សេវិត បេក្ខមានោ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

១ ម. ជគុ ។ ២ ម, ហិន្ទគុ ។

(២៤៩) អធិប្បាយពាក្យថា វិញ្ញូជន កាលសំឡឹងឃើញសេរីភាព ត្រង់ពាក្យថា វិញ្ញូជន គឺបុគ្គលអ្នកដឹង ជាបណ្ឌិត មានបញ្ញា មានយោបល់ មានញាណ មានបញ្ញាឈ្វេងយល់ មានបញ្ញាធ្លុះធ្លាយ ។ ពាក្យថា ជន បានដល់សត្វ មាណព បុរស បុគ្គល សត្វមានជីវៈ សត្វមានជាតិ សត្វមានជក សត្វទៅដោយឥន្ទ្រិយ សត្វកើតអំពីមនុស្ស ។ ពាក្យថា សេរី បានដល់សេរី ២ គឺ ធម៌សេរី ១ បុគ្គលសេរី ១ ។

ធម៌សេរី តើដូចម្តេច ។ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ ។ នេះធម៌សេរី ។

បុគ្គលសេរី តើដូចម្តេច ។ បុគ្គលណា ប្រកបដោយធម៌សេរីនេះ បុគ្គលនោះ លោកហៅថា បុគ្គលសេរី ។

ពាក្យថា វិញ្ញូជន កាលសំឡឹងឃើញសេរីភាព បានសេចក្តីថា វិញ្ញូជន កាលរំពឹងមើល គន់មើល ពិនិត្យមើល ពិចារណាមើល នូវធម៌គឺសេរីភាព ហេតុនោះ (លោកពោលថា) វិញ្ញូជន កាលសំឡឹងឃើញសេរីភាព ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

ខគ្គវិសាណសុត្តនិទ្ទេសោ

មិគោ អរញ្ញម្ហិ យថា អពទ្ធោ
យេនិច្ឆកំ គច្ឆតិ គោចរាយ
វិញ្ញូ នរោ សេរិតំ បេក្ខមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

(២៨០) អាមន្តនា ហោតិ សហាយមជ្ឈេ
វាសេ ឋានេ គមនេ ចារិកាយ
អនភិជ្ឈិតំ សេរិតំ បេក្ខមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

(២៨១) អាមន្តនា ហោតិ សហាយមជ្ឈេ វាសេ ឋានេ គមនេ ចារិកាយាតិ សហាយា វុច្ចន្តិ យេហិ សហ គមនំ ផាសុ អាគមនំ ផាសុ គមនាគមនំ ផាសុ ឋានំ ផាសុ និសជ្ជនំ ផាសុ សយនំ ផាសុ អាលបនំ ផាសុ សល្លបនំ ផាសុ ឧល្លបនំ ផាសុ សមុល្លបនំ ផាសុ ។ អាមន្តនា ហោតិ សហាយមជ្ឈេ វាសេ ឋានេ គមនេ ចារិកាយាតិ សហាយមជ្ឈេ វាសេបិ ឋានេបិ គមនេបិ ចារិកាយបិ អត្តត្ថមន្តនា បរត្ថមន្តនា ឧភយត្ថមន្តនា

ខគ្គវិសាណសុត្តនិទ្ទេស

ម្រឹគក្នុងព្រៃ ជាសត្វមិនជាប់ចំណង ទៅរកចំណី
តាមប្រាថ្នាបាន យ៉ាងណា វិញ្ញូជន កាលសំឡឹង
ឃើញសេរីភាព គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស
យ៉ាងនោះ ។

(២៥០) ការប្រឹក្សា ក្នុងលំនៅ ក្នុងទី (បំរើ) ក្នុងការ
ដើរ ក្នុងចារិក រមែងមាន ក្នុងកណ្តាលសំឡាញ់
បុគ្គលកាលសំឡឹងឃើញសេរីភាព ដែលបុគ្គលពាល
មិនប្រាថ្នា គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(២៥១) ពាក្យថា ការប្រឹក្សាក្នុងលំនៅ ក្នុងទី(បំរើ) ក្នុងការដើរ ក្នុងចារិក រមែងមាន ក្នុងកណ្តាលសំឡាញ់ សេចក្តីថា ការដើរទៅជាសុខ ការមកជាសុខ ការទៅមកជាសុខ ការឈរជាសុខ ការអង្គុយជាសុខ ការដេកជាសុខ ការហៅរកជាសុខ ការចរចាជាសុខ ការឆ្លើយឆ្លងរកគ្នាជាសុខ ការនិយាយស្រស់ស្រាយជាសុខ ជាមួយនឹងពួកជនណា ពួកជននោះ លោកហៅថា សំឡាញ់ ។ ពាក្យថា ការប្រឹក្សា ក្នុងលំនៅ ក្នុងទី (បំរើ) ក្នុងការដើរ ក្នុងចារិក រមែងមាន ក្នុងកណ្តាលនៃសំឡាញ់ បានសេចក្តីថា ការប្រឹក្សាអំពីប្រយោជន៍ របស់ខ្លួន ការប្រឹក្សាអំពីប្រយោជន៍ របស់បុគ្គលដទៃ ការប្រឹក្សាអំពីប្រយោជន៍ទាំងពីរ

ទិដ្ឋធម្មិកត្ថមន្តនា សម្បរាយិកត្ថមន្តនា បរមត្ថមន្តនាតិ អាមន្តនា ហោតិ សហាយមជ្ឈេ វាសេ ឋានេ គមនេ ចារិកាយ ។

(២៨២) អនភិជ្ឈិតំ សេរិតំ បេក្ខមានោតិ អនភិជ្ឈិតំ ឯតំ វត្ថុ ពាលានំ អសប្បុរិសានំ តិត្ថិយានំ តិត្ថិយសាវកានំ យទិទំ ភណ្ឌុកាសាយវត្ថវសនតា អភិជ្ឈិតំ ឯតំ វត្ថុ បណ្ឌិតានំ សប្បុរិសានំ ពុទ្ធសាវកានំ បច្ចេកពុទ្ធានំ យទិទំ ភណ្ឌុកាសាយវត្ថវសនតា ។ សេរិតំ ទ្វេ សេរី ធម្មោបិ សេរី បុគ្គលោបិ សេរី ។ កតមោ ធម្មោ សេរី ។ ចត្តារោ សតិបដ្ឋានា ។បេ។ អរិយោ អដ្ឋង្គិកោ មគ្គោ អយំ ធម្មោ សេរី ។ កតមោ បុគ្គលោ សេរី ។ យោ ឥមិនា សេរិនា ធម្មេន សមន្នាគតោ សោ វុច្ចតិ បុគ្គលោ សេរី ។ អនភិជ្ឈិតំ សេរិតំ បេក្ខមានោតិ សេរិតំ បេក្ខមានោ ឱលោកយមានោ

ការប្រឹក្សាអំពីប្រយោជន៍បច្ចុប្បន្ន ការប្រឹក្សាអំពីប្រយោជន៍បរលោក ការប្រឹក្សាអំពីប្រយោជន៍ដ៏ក្រៃលែង គឺ ព្រះនិព្វាន កង្វល់នៅក្តី កង្វល់ (បំរើ) ក្តី កង្វល់ការដើរក្តី កង្វល់ចារិកក្តី (រមែងមាន) កង្វល់កណ្តាលសំឡាញ់ ហេតុនោះ (លោកពោលថា) ការប្រឹក្សា កង្វល់នៅ កង្វល់ (បំរើ) កង្វល់ការដើរ កង្វល់ចារិក រមែងមាន កង្វល់កណ្តាលសំឡាញ់ ។

(២៩២) ពាក្យថា បុគ្គលកាលសំឡឹងឃើញសេរីភាព ដែលបុគ្គលពាលមិនប្រាថ្នា អធិប្បាយថា វត្ថុដែលពួកជនពាល ជាអសប្បុរស ជាពួកតិរ្ថិយ ជាពួកសាវ័កនៃតិរ្ថិយ មិនប្រាថ្នា គឺការកោរសក់ពុកមាត់នឹងការស្លៀកដណ្តប់សំពត់កាសាយៈ វត្ថុដែលពួកបណ្ឌិត ជាសប្បុរស ជាពួកសាវ័កព្រះពុទ្ធនឹងព្រះបច្ចេកពុទ្ធទាំងឡាយ ប្រាថ្នាហើយ គឺការកោរសក់ពុកមាត់នឹងការស្លៀកដណ្តប់សំពត់កាសាយៈ ។ ពាក្យថា សេរី បានដល់សេរី ២ គឺ ធម៌សេរី ១ បុគ្គលសេរី ១ ។ ធម៌សេរី តើដូចម្តេច ។ សតិប្បដ្ឋាន ៤ ។ បេ ។ អរិយមគ្គប្រកបដោយអង្គ ៨ នេះ ធម៌សេរី ។ បុគ្គលសេរី តើដូចម្តេច ។ បុគ្គលណាប្រកបដោយធម៌សេរីនេះ បុគ្គលនោះ លោកហៅថា បុគ្គលសេរី ។ ពាក្យថា បុគ្គលកាលសំឡឹងឃើញសេរីភាព ដែលបុគ្គលពាលមិនប្រាថ្នា បានសេចក្តីថា បុគ្គលកាលសំឡឹងឃើញ គន់មើល ពិនិត្យ

## ខគ្គវិសាណសុត្តនិទ្ទេសោ

និជ្ឈាយមានោ ឧបបរិក្ខមានោតិ អនភិជ្ឈិតំ សេវិតំ បេក្ខមានោ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

អាមន្តនា ហោតិ សហាយមជ្ឈេ
វាសេ ឋានេ គមនេ ចារិកាយ
អនភិជ្ឈិតំ សេវិតំ បេក្ខមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

(២៨៣) ខិឌ្ឌា រតី ហោតិ សហាយមជ្ឈេ
បុត្តេសុ ច វិបុលំ ហោតិ បេមំ
បិយវិប្បយោគំ វិជិគុច្ឆមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

(២៨៤) ខិឌ្ឌា រតី ហោតិ សហាយមជ្ឈេតិ ខិឌ្ឌាតិ ទ្វេ ខិឌ្ឌា កាយិកា ច ខិឌ្ឌា វាចសិកា ច ខិឌ្ឌា ។

ខគ្គវិសាណសុត្តនិទ្ទេស

មើល ពិចារណាមើល នូវសេរីភាព ហេតុនោះ (លោកពោលថា) បុគ្គលកាលសំឡឹងឃើញសេរីភាព ដែលបុគ្គលពាលមិនប្រាថ្នា ៗ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ៗ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

ការប្រឹក្សា ក្នុងលំនៅ ក្នុងទី (បំរើ) ក្នុងការដើរ
ក្នុងចារិក រមែងមាន ក្នុងកណ្តាលសំឡាញ់ បុគ្គល
កាលសំឡឹងឃើញសេរីភាព ដែលបុគ្គលពាលមិន
ប្រាថ្នា គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ៗ

(២៥៣) ល្បែង តម្រេក រមែងមាន ក្នុងកណ្តាលសំឡាញ់
តាំងសេចក្តីស្រឡាញ់ ដ៏ធំទូលាយ រមែងមាន ក្នុង
ពួកបុត្ត បុគ្គលកាលធុញទ្រាន់ ចំពោះការព្រាត់ប្រាស
ចាកអារម្មណ៍ ជាទីស្រឡាញ់ គប្បីប្រព្រឹត្តម្នាក់ឯង
ដូចកុយរមាស ៗ

(២៥៤) អធិប្បាយពាក្យថា ល្បែង តម្រេក រមែងមាន ក្នុងកណ្តាលសំឡាញ់ ត្រង់ពាក្យថា ល្បែង បានដល់ល្បែង ២ គឺ ល្បែងខាងផ្លូវកាយ ១ ល្បែងខាងផ្លូវវាចា ១ ៗ

កតមា កាយិកា វិញ្ញត្តិ ។ ហត្ថីហិបិ កីឡន្តិ អស្សេហិបិ កីឡន្តិ រថេហិបិ កីឡន្តិ ធនូហិបិ កីឡន្តិ អដ្ឋបទេហិបិ កីឡន្តិ ទសបទេហិបិ កីឡន្តិ អាកាសេហិបិ កីឡន្តិ បរិហារបថេហិបិ កីឡន្តិ សន្តិកាយបិ កីឡន្តិ ខលិកាយបិ កីឡន្តិ ឃដិកាយបិ កីឡន្តិ សលាកហត្ថេនបិ កីឡន្តិ អក្ខេនបិ កីឡន្តិ បង្គចីរេនបិ កីឡន្តិ វង្កកេនបិ កីឡន្តិ មោក្ខចិកាយបិ កីឡន្តិ ចិង្គុលកេនបិ កីឡន្តិ បត្តាឡ្ហកេនបិ កីឡន្តិ រថកេនបិ កីឡន្តិ ធនុកេនបិ កីឡន្តិ អក្ខរិកាយបិ កីឡន្តិ មនេសិកាយបិ កីឡន្តិ យថាវជ្ជេនបិ កីឡន្តិ អយំ កាយិកា វិញ្ញត្តិ ។

កតមា វាចសិកា វិញ្ញត្តិ ។ មុខភេរិយំ មុខាឡម្ពរំ មុខទេណ្ឌិមកំ មុខវលិមកំ មុខភេរុឡកំ មុខទទ្ទរិកំ នាដកំ លាសំ(១) គីតំ ទវកម្មំ អយំ វាចសិកា វិញ្ញត្តិ ។

---

១ ម. មុខភេរិកំ មុខាលម្ពរំ មុខទិន្ទិមកំ មុខបលិមកំ មុខភេរកំ មុខទទ្ទរិកំ នាដកំ លាបំ ។

ល្បែងខាងផ្លូវកាយ តើដូចម្តេច ។ ពួកជនរមែងលេងដោយដំរីខ្លះ លេងសេះខ្លះ លេងរថខ្លះ លេងធ្នូខ្លះ លេងបត្រង្គមានក្រឡាប្រាំបីខ្លះ[១] លេងល្បែងមានក្រឡាដប់ខ្លះ[២] លេងបត្រង្គក្នុងអាកាសខ្លះ[៣] លេងផ្លូវកងដែលគួរកងខ្លះ[៤] លេងផ្កាត់គ្រាប់មានគ្រាប់គ្រួសជាដើមខ្លះ លេងបាស្កាក្នុងលានសម្រាប់លេងខ្លះ លេងហ៊ឹងខ្លះ លេងរលាស់ទឹកល័ខឲ្យទាយរូបខ្លះ លេងអង្គុញខ្លះ លេងផ្លុំប៉ីស្លឹកខ្លះ លេងនង្គ័លតូចខ្លះ លេងល្បែងដាំដូងខ្លះ លេងកង្ហារខ្លះ លេងរល់ខ្សច់ខ្លះ លេងរទេះតូចខ្លះ លេងធ្នូតូចខ្លះ លេងសរសេរអក្សរពេញដ៏អាកាសឲ្យទាយខ្លះ លេងទាយចិត្ត (ស្តេចចង់) ខ្លះ លេងកំផ្លែងត្រាប់គេខ្លះ នេះល្បែងខាងផ្លូវកាយ ។

ល្បែងខាងផ្លូវវាចា តើដូចម្តេច ។ ការលេងវាយស្គរដោយមាត់ ការធ្វើសំឡេងស្គរដែលជាប់ដោយមាត់ ការយកមាត់ធ្វើត្រាប់សំឡេងស្គរ ការហួច ការពោលសំឡេងដូចជាសំឡេងស្គរដោយមាត់ ការបង្រៀនរាំ ការច្រៀងបញ្ចើត ការច្រៀង ការធ្វើឲ្យសើច នេះល្បែងខាងផ្លូវវាចា ។

---

១ ល្បែងបាស្កា ។ ២ ល្បែងក្រឡាដប់នេះ គឺល្បែងបាយខ្ញុំ ។ ៣ បត្រង្គគ្មានក្តារ លេងជាតែមាត់ទទេ ។ ៤ ល្បែងបិទពួន ។ អដ្ឋកថា ។

ខគ្គវិសាណសុត្តនិទ្ទេសោ

រតីតិ អនុក្កណ្ឋិតាវចនមេតំ(១) រតីតិ ។ សហាយមជ្ឈេតិ(២) សហាយា វុច្ចន្តិ យេហិ សហា គមនំ ផាសុ អាគមនំ ផាសុ គមនាគមនំ ផាសុ ឋានំ ផាសុ និសជ្ជនំ ផាសុ សយនំ ផាសុ អាលបនំ ផាសុ សល្លបនំ ផាសុ ឧល្លបនំ ផាសុ សមុល្លបនំ ផាសុ ។ ខិឌ្ឌា រតី ហោតិ សហាយមជ្ឈេតិ ខិឌ្ឌា ច រតិ ច សហាយមជ្ឈេ ហោតីតិ ខិឌ្ឌា រតី ហោតិ សហាយមជ្ឈេ ។

(២៨៨) បុត្តេសុ ច វិបុលំ ហោតិ បេមន្តិ បុត្តាតិ ចត្តារោ បុត្តា អត្រជោ បុត្តោ ខេត្រជោ បុត្តោ ទិន្នកោ បុត្តោ អន្តេវាសិកោ បុត្តោ ។ បុត្តេសុ ច វិបុលំ ហោតិ បេមន្តិ បុត្តេសុ ច អធិមត្តំ ហោតិ បេមន្តិ បុត្តេសុ ច វិបុលំ ហោតិ បេមំ ។

---

១ ម. អនុក្កណ្ឋិតាធិវចនមេតំ ។ ២ ម. អយំ បាឋោ នត្ថិ ។

ខគ្គវិសាណសុត្តនិទ្ទេស

សេចក្តីនៃពាក្យថា តម្រេក គឺពាក្យថា តម្រេក នុ៎ះ ជាឈ្មោះនៃសេចក្តីមិនរផ្សុក ៗ ពាក្យថា ក្នុងកណ្តាលសំឡាញ់ គឺ ការដើរទៅជាសុខ ការមកជាសុខ ការទៅមកជាសុខ ការឈរជាសុខ ការអង្គុយជាសុខ ការដេកជាសុខ ការហៅគេជាសុខ ការបរហាជាសុខ ការឆ្លើយឆ្លងគេគ្នាជាសុខ ការនិយាយស្រស់ស្រាយជាសុខ ជាមួយពួកជនណា ពួកជននោះ លោកហៅថា សំឡាញ់ ៗ ពាក្យថា ល្បែង តម្រេក (រមែងមាន) ក្នុងកណ្តាលសំឡាញ់ គឺ ល្បែងផង តម្រេកផង រមែងមាន ក្នុងកណ្តាលសំឡាញ់ ហេតុនោះ (លោកពោលថា) ល្បែង តម្រេក រមែងមាន ក្នុងកណ្តាលសំឡាញ់ ៗ

(២៥៥) អធិប្បាយពាក្យថា សេចក្តីស្រឡាញ់ ដ៏ធំទូលាយ រមែងមាន ក្នុងពួកបុត្ត ត្រង់ពាក្យថា បុត្ត បានដល់បុត្ត ៤ ពួក គឺ បុត្តកើតអំពីខ្លួន ១ បុត្តកើតក្នុងខែត្រ ១ បុត្តដែលគេឲ្យ ១ បុត្រគឺសិស្ស ១ ៗ ពាក្យថា សេចក្តីស្រឡាញ់ ដ៏ធំទូលាយ រមែងមាន ក្នុងពួកបុត្ត គឺ សេចក្តីស្រឡាញ់ដ៏ក្រៃលែង រមែងមានក្នុងពួកបុត្ត ហេតុនោះ (លោកពោលថា) ទាំងសេចក្តីស្រឡាញ់ដ៏ធំទូលាយ រមែងមានក្នុងពួកបុត្ត ៗ

(២៨៦) បិយវិប្បយោគំ វិជិគុច្ឆមានោតិ ទ្វេ បិយា សត្តា ច បិយា សង្ខារា ច បិយា ។

កតមេ សត្តា បិយា ។ ឥធ យស្ស តេ ហោន្តិ អត្ថកាមា ហិតកាមា ផាសុកាមា យោគក្ខេមកាមា មាតា វា បិតា វា ភាតា វា ភគិនី វា បុត្តា វា ធីតា វា មិត្តា វា អមច្ចា វា ញាតិ វា សាលោហិតា វា ឥមេ សត្តា បិយា ។

កតមេ សង្ខារា បិយា ។ មនាបិកា រូបា មនាបិកា សទ្ទា មនាបិកា គន្ធា មនាបិកា រសា មនាបិកា ផោដ្ឋព្វា ឥមេ សង្ខារា បិយា ។

បិយវិប្បយោគំ វិជិគុច្ឆមានោតិ បិយវិប្បយោគំ វិជិគុច្ឆមានោ អដ្ដិយមានោ ហរាយមានោតិ បិយវិប្បយោគំ វិជិគុច្ឆមានោ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

(២៥៦) ពាក្យថា បុគ្គលកាលធុញទ្រាន់ ចំពោះការព្រាត់ប្រាស ចាកអារម្មណ៍ជាទីស្រឡាញ់ អធិប្បាយថា អារម្មណ៍ជាទីស្រឡាញ់ មាន ២ គឺ ពួកសត្វជាទីស្រឡាញ់ ១ ពួកសង្ខារជាទីស្រឡាញ់ ១ ។

ពួកសត្វជាទីស្រឡាញ់ តើដូចម្តេច ។ ពួកជនណា ក្នុងលោកនេះ ទោះជាមាតាក្តី បិតាក្តី បងប្អូនប្រុសក្តី បងប្អូនស្រីក្តី បុត្តក្តី ធីតាក្តី មិត្តក្តី អាមាត្យក្តី ញាតិក្តី សាលោហិតក្តី ជាអ្នកប្រាថ្នាសេចក្តីចំរើន ប្រាថ្នាប្រយោជន៍ ប្រាថ្នាសេចក្តីសុខ ប្រាថ្នាការក្សេមចាកយោគៈរបស់ជននោះ នេះពួកសត្វជាទីស្រឡាញ់ ។

ពួកសង្ខារជាទីស្រឡាញ់ តើដូចម្តេច ។ រូបជាទីពេញចិត្ត សំឡេងជាទីពេញចិត្ត ក្លិនជាទីពេញចិត្ត រសជាទីពេញចិត្ត ផ្សព្វជាទីពេញចិត្ត នេះពួកសង្ខារជាទីស្រឡាញ់ ។

ពាក្យថា បុគ្គលកាលធុញទ្រាន់ ចំពោះការព្រាត់ប្រាស ចាកអារម្មណ៍ជាទីស្រឡាញ់ បានសេចក្តីថា បុគ្គលកាលធុញទ្រាន់ នឿយណាយ ខ្ពើមរអើម ចំពោះការព្រាត់ប្រាស ចាកអារម្មណ៍ ជាទីស្រឡាញ់ ហេតុនោះ (លោកពោលថា) បុគ្គលកាលធុញទ្រាន់ ចំពោះការព្រាត់ប្រាស ចាកអារម្មណ៍ជាទីស្រឡាញ់ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

ខិឌ្ឌា រតី ហោតិ សហាយមជ្ឈេ
បុត្តេសុ ច វិបុលំ ហោតិ បេមំ
បិយវិប្បយោគំ វិជិគុច្ឆមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

(២៤៧) ចាតុទ្ទិសោ អប្បដិឃោ ច ហោតិ
សន្តុស្សមានោ ឥតរីតរេន
បរិស្សយានំ សហិតា អឆម្ភី
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

(២៤៨) ចាតុទ្ទិសោ អប្បដិឃោ ច ហោតីតិ ចាតុទ្ទិសោតិ សោ បច្ចេកសម្ពុទ្ធោ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហរតិ

ខគ្គវិសាណសុត្តនិទ្ទេស

ល្បែង តម្រេក រមែងមាន ក្នុងកណ្តាលសំឡាញ់ ទាំងសេចក្តីស្រឡាញ់ ដ៏ធំទូលាយ រមែងមាន ក្នុងពួកបុត្ត បុគ្គលកាលធុញទ្រាន់ ចំពោះការព្រាត់ប្រាស ចាកអារម្មណ៍ជាទីស្រឡាញ់ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(២៥៧) បុគ្គលមានកិរិយាទៅជាសុខ ក្នុងទិស ៤ ទាំងមិនមានសេចក្តីថ្នាំងថ្នាក់ចិត្ត សន្តោសដោយបច្ច័យតាមមានតាមបាន ជាអ្នកអត់ធ្មត់ ចំពោះអន្តរាយទាំងឡាយ ជាអ្នកមិនតក់ស្លុត គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(២៥៨) អធិប្បាយពាក្យថា បុគ្គលមានកិរិយាទៅជាសុខក្នុងទិស ៤ ទាំងមិនមានសេចក្តីថ្នាំងថ្នាក់ចិត្ត ត្រង់ពាក្យថា មានកិរិយាទៅជាសុខ សេចក្តីថា ព្រះបច្ចេកសម្ពុទ្ធនោះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា មានចិត្តប្រកបដោយមេត្តា ដ៏ធំទូលាយ ដល់នូវសេចក្តីប្រសើរ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកដែលមានសត្វទាំងអស់ ក្នុងទិសខាងលើ ទិសខាងក្រោម ទិសទទឹង

ករុណាសហគតេន ចេតសា មុទិតាសហគតេន ចេតសា ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហរតិ ។ ចាតុទ្ទិសោ អប្បដិឃោ ច ហោតីតិ មេត្តាយ ការិតត្តា យេ បុរត្ថិមាយ ទិសាយ សត្តា តេ អប្បដិកុលា ហោន្តិ យេ បច្ឆិមាយ ទិសាយ សត្តា តេ អប្បដិកុលា ហោន្តិ យេ ឧត្តរាយ ទិសាយ សត្តា តេ អប្បដិកុលា ហោន្តិ យេ ទក្ខិណាយ ទិសាយ សត្តា តេ អប្បដិកុលា ហោន្តិ យេ បុរត្ថិមាយ អនុទិសាយ សត្តា តេ អប្បដិកុលា ហោន្តិ យេ បច្ឆិមាយ អនុទិសាយ សត្តា តេ អប្បដិកុលា ហោន្តិ យេ ឧត្តរាយ អនុទិសាយ សត្តា តេ អប្បដិកុលា ហោន្តិ

ព្រោះយកខ្លួនទៅប្រៀបផ្ទឹម ក្នុងសត្វទាំងអស់ ក្នុងទិសទាំងអស់ ហើយសម្រេចសម្រាន្តនៅ ដោយប្រការដូច្នេះ មានចិត្តប្រកបដោយករុណា មានចិត្តប្រកបដោយមុទិតា មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា មានចិត្តប្រកបដោយឧបេក្ខាដ៏ធំទូលាយ ដល់នូវសេចក្តីប្រសើរ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់ លោកដែលមានសត្វទាំងអស់ ក្នុងទិសខាងលើ ទិសខាងក្រោម ទិសទទឹង ព្រោះយកខ្លួនទៅប្រៀបផ្ទឹម ក្នុងសត្វទាំងអស់ ក្នុងទិសទាំងអស់ ហើយសម្រេចសម្រាន្តនៅ ដោយប្រការដូច្នេះ ។ ពាក្យថា បុគ្គលមានកិរិយានៅជាសុខក្នុងទិស ៤ ទាំងមិនមានសេចក្តីថាំងថាក់ចិត្ត បានសេចក្តីថា ព្រោះបានចំរើនមេត្តា (ទើបយល់ថា) ពួកសត្វណា ក្នុងទិសខាងកើត ពួកសត្វនោះមិនគួរខ្ពើម ពួកសត្វណា ក្នុងទិសខាងលិច ពួកសត្វនោះមិនគួរខ្ពើម ពួកសត្វណា ក្នុងទិសខាងត្បូង ពួកសត្វនោះមិនគួរខ្ពើម ពួកសត្វណា ក្នុងទិសខាងជើង ពួកសត្វនោះមិនគួរខ្ពើម ពួកសត្វណា ក្នុងទិសអាគ្នេយ៍ ពួកសត្វនោះមិនគួរខ្ពើម ពួកសត្វណា ក្នុងទិសពាយ័ព្យ ពួកសត្វនោះមិនគួរខ្ពើម ពួកសត្វណា ក្នុងទិសនិរតី ពួកសត្វនោះ មិនគួរខ្ពើម

យេ ឧត្តរាយ អនុទិសាយ សត្តា តេ អប្បដិកុលា ហោន្តិ យេ ហេដ្ឋិមាយ ទិសាយ សត្តា តេ អប្បដិកុលា ហោន្តិ យេ ឧបរិមាយ ទិសាយ សត្តា តេ អប្បដិកុលា ហោន្តិ យេ ទិសាសុ វិទិសាសុ សត្តា តេ អប្បដិកុលា ហោន្តិ ករុណាយ ភាវិតត្តា មុទិតាយ ភាវិតត្តា ឧបេក្ខាយ ភាវិតត្តា យេ បុរត្ថិមាយ ទិសាយ សត្តា តេ អប្បដិកុលា ហោន្តិ ។ បេ ។ យេ ទិសាសុ វិទិសាសុ សត្តា តេ អប្បដិកុលា ហោន្តីតិ ចាតុទ្ទិសោ អប្បដិឃោ ច ហោតិ ។

(២៤៩) សន្តុស្សមានោ ឥតរីតរេនាតិ សោ បច្ចេកសម្ពុទ្ធោ សន្តុដ្ឋោ ហោតិ ឥតរីតរេន ចីវរេន ឥតរីតរចីវរសន្តុដ្ឋិយា ច វណ្ណវាទី ន ច ចីវរហេតុ អនេសនំ អប្បដិរូបំ អាបជ្ជតិ អលទ្ធា ច(១) ចីវរំ ន បរិតស្សតិ(២) លទ្ធា ច ចីវរំ អគធិតោ អមុច្ឆិតោ អនជ្ឈាបន្នោ អាទីនវទស្សាវី និស្សរណបញ្ញោ

---

១ ម. ចសទ្ទោ នត្ថិ ។ ២ ម. បរិយេសតិ ។

ពួកសត្វណា ក្នុងទិសឦសាន ពួកសត្វនោះ មិនគួរខ្ពើម ពួកសត្វណា ក្នុងទិសខាងក្រោម ពួកសត្វនោះ មិនគួរខ្ពើម ពួកសត្វណា ក្នុងទិសខាងលើ ពួកសត្វនោះមិនគួរខ្ពើម ពួកសត្វណា ក្នុងទិសធំ ក្នុងទិសតូចទាំងឡាយ ពួកសត្វនោះមិនគួរខ្ពើម ព្រោះបានចំរើនករុណា ព្រោះបានចំរើនមុទិតា ព្រោះបានចំរើនឧបេក្ខា (ទើបយល់ថា) ពួកសត្វណា ក្នុងទិសខាងកើត ពួកសត្វនោះ មិនគួរខ្ពើម ។ បេ ។ ពួកសត្វណា ក្នុងទិសធំ ក្នុងទិសតូចទាំងឡាយ ពួកសត្វនោះមិនគួរខ្ពើម ហេតុនោះ (លោកពោលថា) បុគ្គលមានកិរិយានៅជាសុខ ក្នុងទិស ៤ ទាំងមិនមានសេចក្តីថ្នាំងថ្នាក់ចិត្ត ។

(២៥៩) ពាក្យថា សន្តោសដោយបច្ច័យ តាមមានតាមបាន អធិប្បាយថា ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលសន្តោសដោយចីវរ តាមមានតាមបានផង ថ្លែងគុណសន្តោសដោយចីវរ តាមមានតាមបានផង មិនដល់នូវអនេសនៈ ដែលមិនសមគួរ ព្រោះហេតុតែចីវរផង មិនបានចីវរ ក៏មិនតក់ស្លុតផង បានចីវរហើយ ក៏មិនជក់ចិត្ត មិនឈ្លក់ចិត្ត មិនងប់ចិត្ត ឃើញទោស មានប្រាជ្ញាជាគ្រឿងរលាស់

បរិភុញ្ជតិ តាយ ច(១) បន ឥតរីតរចីវរសន្តុដ្ឋិយា នេវត្តានុក្កំសេតិ ន បរំ វម្ភេតិ យោ ហិ តត្ថ ទក្ខោ អនលសោ សម្បជានោ បដិស្សតោ អយំ វុច្ចតិ បច្ចេកសម្ពុទ្ធោ បោរាណេ អគ្គញ្ញេ អរិយវំសេ ឋិតោ ។ សន្តុដ្ឋោ ហោតិ ឥតរីតរេន បិណ្ឌបាតេន ឥតរីតរបិណ្ឌបាតសន្តុដ្ឋិយា ច វណ្ណវាទី ន ច បិណ្ឌបាតហេតុ អនេសនំ អប្បដិរូបំ អាបជ្ជតិ អលទ្ធា ច បិណ្ឌបាតំ ន បរិតស្សតិ លទ្ធា ច បិណ្ឌបាតំ អគធិតោ អមុច្ឆិតោ អនជ្ឈាបន្នោ អាទីនវទស្សាវី និស្សរណបញ្ញោ ភុញ្ជតិ តាយ ច បន ឥតរីតរបិណ្ឌបាតសន្តុដ្ឋិយា នេវត្តានុក្កំសេតិ ន បរំ វម្ភេតិ យោ ហិ តត្ថ ទក្ខោ អនលសោ សម្បជានោ បដិស្សតោ អយំ វុច្ចតិ បច្ចេកសម្ពុទ្ធោ បោរាណេ អគ្គញ្ញេ អរិយវំសេ ឋិតោ ។ សន្តុដ្ឋោ ហោតិ ឥតរីតរេន សេនាសនេន

---

១ ម. ច សទ្ទោ នត្ថិ ។

ប្រើប្រាស់ផង មួយទៀត មិនលើកតំកើងខ្លួន មិនបង្អាប់បុគ្គលដទៃ ព្រោះតែសេចក្តីសន្តោសដោយចីវរ តាមមានតាមបាននោះ ដ្បិតថាព្រះបច្ចេកសម្ពុទ្ធណា រត់វៃ មិនខ្ជិល ដឹងខ្លួន មានស្មារតីស៊ប់សួនក្នុងការសន្តោសដោយចីវរ តាមមានតាមបាននោះ ព្រះបច្ចេកសម្ពុទ្ធនេះ លោកពោលថា អ្នកឋិតនៅក្នុងអរិយវង្ស មានក្នុងកាលមុន ដែលពួកបណ្ឌិតគួរស្គាល់ថាប្រសើរ ។ ជាបុគ្គលសន្តោសដោយបិណ្ឌបាត តាមមានតាមបានផង ថ្លែងគុណសន្តោសដោយបិណ្ឌបាត តាមមានតាមបានផង មិនដល់នូវអនេសនៈ ដែលមិនសមគួរ ព្រោះហេតុតែបិណ្ឌបាតផង មិនបានបិណ្ឌបាតក៏មិនតក់ស្លុតផង បានបិណ្ឌបាតហើយក៏មិនជក់ចិត្ត មិនឈ្លក់ចិត្ត មិនងប់ចិត្ត ឃើញទោស មានប្រាជ្ញាជាគ្រឿងរលាស់ ប្រើប្រាស់ផង មួយទៀត មិនលើកតំកើងខ្លួន មិនបង្អាប់បុគ្គលដទៃ ព្រោះតែការសន្តោស ដោយបិណ្ឌបាត តាមមានតាមបាននោះ ដ្បិតថាព្រះបច្ចេកសម្ពុទ្ធណា រត់វៃ មិនខ្ជិល ដឹងខ្លួន មានស្មារតីស៊ប់សួន ក្នុងការសន្តោសដោយបិណ្ឌបាត តាមមានតាមបាននោះ ព្រះបច្ចេកសម្ពុទ្ធនេះ លោកពោលថា អ្នកឋិតនៅក្នុងអរិយវង្ស មានក្នុងកាលមុន ដែលពួកបណ្ឌិតគួរស្គាល់ថាប្រសើរ ។ ជាបុគ្គលសន្តោសដោយសេនាសនៈ

ខគ្គវិសាណសុត្តនិទ្ទេសោ

ឥតរីតរសេនាសនសន្តុដ្ឋិយា ច វណ្ណវាទី ន ច សេនាសនហេតុ អនេសនំ អប្បដិរូបំ អាបជ្ជតិ អលទ្ធា ច សេនាសនំ ន បរិតស្សតិ លទ្ធា ច សេនាសនំ អគធិតោ អមុច្ឆិតោ អនជ្ឈោបន្នោ អាទីនវទស្សាវី និស្សរណបញ្ញោ បរិភុញ្ជតិ តាយ ច បន ឥតរីតរសេនាសនសន្តុដ្ឋិយា នេវត្តានុក្កំសេតិ ន បរំ វម្ភេតិ យោ ហិ តត្ថ ទក្ខោ អនលសោ សម្បជានោ បដិស្សតោ អយំ វុច្ចតិ ភិក្ខុ បោរាណេ អគ្គញ្ញេ អរិយវំសេ ឋិតោ ។ សន្តុដ្ឋោ ហោតិ ឥតរីតរេន គិលានបច្ចយភេសជ្ជបរិក្ខារេន ឥតរីតរគិលានបច្ចយភេសជ្ជបរិក្ខារសន្តុដ្ឋិយា ច វណ្ណវាទី ន ច គិលានបច្ចយភេសជ្ជបរិក្ខារហេតុ អនេសនំ អប្បដិរូបំ អាបជ្ជតិ អលទ្ធា ច គិលានបច្ចយភេសជ្ជបរិក្ខារំ ន បរិតស្សតិ លទ្ធា ច គិលានបច្ចយភេសជ្ជបរិក្ខារំ អគធិតោ អមុច្ឆិតោ អនជ្ឈោបន្នោ អាទីនវទស្សាវី និស្សរណបញ្ញោ បរិភុញ្ជតិ

ខគ្គវិសាណសុត្តនិទ្ទេស

តាមមានតាមបានផង ថ្លែងគុណសន្តោសដោយសេនាសនៈ តាមមានតាមបានផង មិនដល់នូវអនេសនៈ ដែលមិនសមគួរ ព្រោះហេតុតែសេនាសនៈផង មិនបានសេនាសនៈ ក៏មិនតក់ស្លុតផង បានសេនាសនៈហើយក៏មិនជក់ចិត្ត មិនឈ្លក់ចិត្ត មិនងប់ចិត្ត ឃើញទោស មានប្រាជ្ញាជាគ្រឿងរលាស់ ប្រើប្រាស់ផង មួយទៀត មិនលើកតំកើងខ្លួន មិនបន្អាប់បុគ្គលដទៃ ព្រោះតែការសន្តោសដោយសេនាសនៈ តាមមានតាមបាននោះ ដ្បិតថា ព្រះបច្ចេកសម្ពុទ្ធណា វាងវៃ មិនខ្ជិល ដឹងខ្លួន មានស្មារតីស៊ប់សួន ក្នុងការសន្តោសដោយសេនាសនៈ តាមមានតាមបាននោះ ព្រះបច្ចេកសម្ពុទ្ធនេះ លោកពោលថា អ្នកឋិតនៅក្នុងអរិយវង្ស មានក្នុងកាលមុន ដែលពួកបណ្ឌិតគួរស្គាល់ថាប្រសើរ ៗ ជាបុគ្គលសន្តោសដោយគិលានប្បច្ច័យភេសជ្ជបរិក្ខារ តាមមានតាមបានផង ថ្លែងគុណសន្តោសដោយគិលានប្បច្ច័យភេសជ្ជបរិក្ខារ តាមមានតាមបានផង មិនដល់នូវអនេសនៈ ដែលមិនសមគួរ ព្រោះហេតុតែគិលានប្បច្ច័យភេសជ្ជបរិក្ខារ មិនបានគិលានប្បច្ច័យភេសជ្ជបរិក្ខារ ក៏មិនតក់ស្លុតផង បានគិលានប្បច្ច័យភេសជ្ជបរិក្ខារហើយ ក៏មិនជក់ចិត្ត មិនឈ្លក់ចិត្ត មិនងប់ចិត្ត ឃើញទោស មានប្រាជ្ញាជាគ្រឿងរលាស់ ប្រើប្រាស់ផង

តាយ ច បន ឥតរីតរគិលានប្បច្ចយភេសជ្ជបរិក្ខារសន្តុដ្ឋិយា នេវត្តានុក្កំសេតិ ន បរំ វម្ភេតិ យោ ហិ តត្ថ ទក្ខោ អនលសោ សម្បជានោ បដិស្សតោ អយំ វុច្ចតិ បច្ចេកសម្ពុទ្ធោ បោរាណេ អគ្គញ្ញេ អរិយវំសេ ឋិតោតិ សន្តុស្សមានោ ឥតរីតរេន ។

(២៦០) បរិស្សយានំ សហិតា អឆម្ភីតិ បរិស្សយាតិ ទ្វេ បរិស្សយា បាកដបរិស្សយា ច បដិច្ឆន្នបរិស្សយា ច ។

កតមេ បាកដបរិស្សយា ។ សីហា ព្យគ្ឃា ទីបិ អច្ឆតរច្ឆា កោកា គោមហិសា ហត្ថី អហិ វិច្ឆិកា សតបទី ចោរា វា អស្សុ មាណវា វា កតកម្មា វា អកតកម្មា វា ចក្ខុរោគោ សោតរោគោ ឃានរោគោ ជិវ្ហារោគោ កាយរោគោ សីសរោគោ កណ្ណរោគោ មុខរោគោ ទន្តរោគោ កាសោ សាសោ បិនាសោ ឌាហោ ជរោ កុច្ឆិរោគោ មុច្ឆា បក្ខន្ទិកា សុលា វិសូចិកា កុដ្ឋំ គណ្ឌោ កិលាសោ សោសោ អបមារោ ទទ្ទុ កណ្ឌុ

មួយទៀត មិនលើកតំកើងខ្លួន មិនបង្អាប់បុគ្គលដទៃទេ ព្រោះតែការសន្តោសដោយគិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមានតាមបាននោះ ដ្បិតថា ព្រះបច្ចេកសម្ពុទ្ធណា វាងវៃ មិនខ្ជិល ដឹងខ្លួន មានស្មារតីស៊ប់ស្ងួន ក្នុងការសន្តោសដោយគិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមានតាមបាននោះ ព្រះបច្ចេកសម្ពុទ្ធនេះ លោកពោលថា ឋិតនៅក្នុងអរិយវង្ស ក្នុងកាលមុន ដែលពួកបណ្ឌិតស្គាល់ថាប្រសើរ ។ ហេតុនោះ (លោកពោលថា) សន្តោសដោយបច្ច័យ តាមមានតាមបាន ។

(២៦០) អធិប្បាយពាក្យថា ជាអ្នកអត់ធ្មត់ ចំពោះអន្តរាយទាំងឡាយ ជាអ្នកមិនតក់ស្លុត ត្រង់ពាក្យថា អន្តរាយ បានដល់អន្តរាយ ២ គឺអន្តរាយប្រាកដ ១ អន្តរាយកំបាំង ១ ។ អន្តរាយប្រាកដ តើដូចម្តេច ។ ពួកសីហៈ ពួកខ្លាធំ ខ្លាដំបង ពួកខ្លាឃ្មុំ នឹងខ្លារខិន ពួកឆ្កែព្រៃ ពួកគោនឹងក្របី ពួកដំរី ពស់ ខ្លួយ ក្អែប ឬពួកមាណព ជាចោរធ្វើកម្មហើយ ឬមិនទាន់ធ្វើកម្មហើយ ឬរោគក្នុងភ្នែក រោគត្រចៀក រោគច្រមុះ រោគអណ្តាត រោគកាយ រោគក្បាល រោគស្លឹកត្រចៀក រោគមាត់ រោគធ្មេញ ក្អក ហឺត រោគខាងក្រៅច្រមុះ រោគក្តៅ រោគគ្រាំគ្រា រោគពោះ ខ្យល់ចាប់ ធ្លាក់ឈាម ចុកសៀត រាករូស ឃ្លង់ បូស ស្រែង រេចង៍ ឆ្កួតជ្រូក ដំនួចពីស រមាស់

## ខគ្គវិសាណសុត្តនិទ្ទេសោ

កច្ឆុ រខសា វិតច្ឆិកា លោហិតំ បិត្តំ មធុមេហោ អំសា បិឡកា ភគន្ទលា បិត្តសមុដ្ឋានា អាពាធា សេម្ហសមុដ្ឋានា អាពាធា វាតសមុដ្ឋានា អាពាធា សន្និបាតិកា អាពាធា ឧតុបរិណាមជា អាពាធា វិសមបរិហារជា អាពាធា ឱបក្កមិកា អាពាធា កម្មវិបាកជា អាពាធា សីតំ ឧណ្ហំ ជិឃច្ឆា បិបាសា ឧច្ចារោ បស្សាវោ ឌំសមកសវាតាតបសិរឹសបសម្ផស្សា ឥតិ វា ឥមេ វុច្ចន្តិ បាកដបរិស្សយា ។

កតមេ បដិច្ឆន្នបរិស្សយា ។ កាយទុច្ចរិតំ វចីទុច្ចរិតំ មនោទុច្ចរិតំ កាមច្ឆន្ទនីវរណំ ព្យាបាទនីវរណំ ថីនមិទ្ធនីវរណំ ឧទ្ធច្ចកុក្កុច្ចនីវរណំ វិចិកិច្ឆានីវរណំ រាគោ ទោសោ មោហោ កោធោ ឧបនាហោ មក្ខោ បឡាសោ ឥស្សា មច្ឆរិយំ មាយា សាឋេយ្យំ ថម្ភោ សារម្ភោ មានោ អតិមានោ មទោ បមាទោ សព្វេ កិលេសា សព្វេ ទុច្ចរិតា សព្វេ ទរថា សព្វេ បរិឡាហា សព្វេ សន្តាបា សព្វាកុសលាភិសង្ខារា ឥមេ វុច្ចន្តិ បដិច្ឆន្នបរិស្សយា ។

## ខគ្គវិសាណសុត្តនិទ្ទេស

កម រោគក្លាយអំពីក្របក ឃ្លង់ដែក ឈាម ប្រមាត់ ទឹកមូត្រផ្អែម ឫសដូង ដុះ រលកកែវ ឫសដូងបាត ពួកអាពាធកើតអំពីប្រមាត់ ពួកអាពាធ កើតអំពីស្លេស្ម ពួកអាពាធកើត អំពីខ្យល់ ពួកអាពាធកើត អំពីប្រជុំនៃ ប្រមាត់ស្លេស្មនឹងខ្យល់ ពួកអាពាធកើតអំពីការប្រែប្រួលរដូវ ពួកអាពាធ កើតអំពីការប្រើឥរិយាបថមិនស្មើ ពួកអាពាធកើតអំពីព្យាយាម (មានការ សំឡាប់ចាប់ចងជាដើម) ពួកអាពាធកើត អំពីវិបាករបស់កម្ម ត្រជាក់ ក្តៅ ឃ្លាន ស្រេក ឧច្ចារៈ បស្សាវៈ ពួកសម្ផស្សនៃរបោម មូស ខ្យល់ កំដៅថ្ងៃ នឹងសត្វលូន ទាំងនេះ លោកហៅថា អន្តរាយប្រាកដ ។

អន្តរាយកំបាំង តើដូចម្តេច ។ កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ច-រិត កាមច្ឆន្ទនីវរណៈ ព្យាបាទនីវរណៈ ថីនមិទ្ធនីវរណៈ ឧទ្ធច្ចកុ-ក្កុច្ចនីវរណៈ វិចិកិច្ឆានីវរណៈ រាគៈ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ ពួកកិលេសទាំងពួង ទុច្ចរិតទាំងពួង សេចក្តីក្រវល់ក្រវាយទាំងពួង សេចក្តីក្រហល់ក្រហាយ ទាំងពួង សេចក្តីក្តៅក្រហាយទាំងពួង អកុសលាភិសង្ខារទាំងពួង ទាំង នេះ លោកហៅថា អន្តរាយកំបាំង ។

បរិស្សយាតិ កេនដ្ឋេន បរិស្សយា ។ បរិសហ-ន្តីតិ បរិស្សយា ។ បរិហានាយ សំវត្តន្តីតិ បរិស្ស-យា ។ តត្រាសយាតិ បរិស្សយា ។

កថំ បរិសហន្តីតិ បរិស្សយា ។ តេ បរិស្សយា តំ បុគ្គលំ សហន្តិ បរិសហន្តិ អភិភវន្តិ អជ្ឈោត្ថរន្តិ បរិយាទិយន្តិ បីឡេន្តិ ឯវំ បរិសហន្តីតិ បរិស្សយា ។

កថំ បរិហានាយ សំវត្តន្តីតិ បរិស្សយា ។ តេ បរិស្សយា កុសលានំ ធម្មានំ អន្តរាយាយ បរិហា-នាយ សំវត្តន្តិ ។ កតមេសំ កុសលានំ ធម្មានំ ។ សម្មាបដិបទាយ អនុលោមបដិបទាយ អបច្ចនីក-បដិបទាយ អន្វត្ថបដិបទាយ ធម្មានុធម្មបដិបទាយ សីលេសុ បរិបូរិការិតាយ ឥន្ទ្រិយេសុ គុត្តទ្វារតាយ ភោជនេ មត្តញ្ញុតាយ ជាគរិយានុយោគស្ស សតិ-សម្បជញ្ញស្ស ចតុន្នំ សតិបដ្ឋានានំ ភាវនានុយោ-គស្ស ចតុន្នំ សម្មប្បធានានំ ចតុន្នំ ឥទ្ធិបាទានំ

សំនួរត្រង់ពាក្យថា ពួកអន្តរាយ ចុះអន្តរាយ តើដោយសេចក្តីដូចម្តេច ។ ឈ្មោះថាអន្តរាយ ព្រោះហេតុបង្រ្គប ។ ឈ្មោះថាអន្តរាយ ព្រោះហេតុប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យ ។ ឈ្មោះថាអន្តរាយ ព្រោះហេតុអាស្រ័យក្នុងសរីរៈនោះ ។

ចុះឈ្មោះថាអន្តរាយ ព្រោះហេតុបង្រ្គប តើដូចម្តេច ។ ពួកអន្តរាយនោះ សង្រ្គប បង្រ្គប គ្របសង្កត់ រួបរឹត សង្កត់សង្កិន បៀតបៀននូវបុគ្គលនោះ ឈ្មោះថាអន្តរាយ ព្រោះហេតុបង្រ្គប យ៉ាងនេះឯង ។

ចុះឈ្មោះថាអន្តរាយ ព្រោះហេតុប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យ តើដូចម្តេច ។ ពួកអន្តរាយនោះ ប្រព្រឹត្តទៅព្រម ដើម្បីសេចក្តីអន្តរាយ ដើម្បីសេចក្តីសាបសូន្យ នូវពួកធម៌ជាកុសល ។ ពួកធម៌ជាកុសល តើដូចម្តេចខ្លះ ។ សម្មាបដិបទា អនុលោមប្បដិបទា អបច្ចនីកប្បដិបទា អន្វត្ថប្បដិបទា ធម្មានុធម្មប្បដិបទា ការធ្វើឲ្យពេញលេញក្នុងសីលទាំងឡាយ ការគ្រប់គ្រងទ្វារក្នុងឥន្រ្ទិយទាំងឡាយ ការដឹងប្រមាណក្នុងភោជន ការប្រកបរឿយៗនូវសេចក្តីភ្ញាក់រឭក សតិនិងសម្បជញ្ញៈ ការប្រកបរឿយ ៗ នូវការចំរើនសតិប្បដ្ឋាន ៤ ការប្រកបរឿយ ៗ នូវកិរិយាចំរើនសម្មប្បធាន ៤ ឥទ្ធិបាទ ៤

បញ្ចន្នំ ឥន្ទ្រិយានំ បញ្ចន្នំ ពលានំ សត្តន្នំ ពោជ្ឈង្គានំ អរិយស្ស អដ្ឋង្គិកស្ស មគ្គស្ស ភាវនានុយោគស្ស ឥមេសំ កុសលានំ ធម្មានំ អន្តរាយាយ បរិយាទាយ សំវត្តន្តិ ឯវំ បរិយាទាយ សំវត្តន្តីតិ បរិស្សយា ។

កថំ តត្រាសយាតិ បរិស្សយា ។ តត្ថ តេ បាបកា អកុសលា ធម្មា ឧប្បជ្ជន្តិ អត្តភាវសន្និស្សយា ។ យថា ពិលេ ពិលាសយា បាណា សយន្តិ ទកេ ទកាសយា បាណា សយន្តិ វនេ វនាសយា បាណា សយន្តិ រុក្ខេ រុក្ខាសយា បាណា សយន្តិ ឯវមេវ តត្ថ តេ បាបកា អកុសលា ធម្មា ឧប្បជ្ជន្តិ អត្តភាវសន្និស្សយា ឯវម្បិ តត្រាសយាតិ បរិស្សយា ។

## ខគ្គវិសាណសុត្តនិទ្ទេស

ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គ ប្រកបដោយអង្គ ៨ ពួកអន្តរាយនោះ ប្រព្រឹត្តទៅព្រម ដើម្បីសេចក្តីអន្តរាយ ដើម្បីសេចក្តីសាបសូន្យ នូវពួកធម៌ជាកុសលទាំងនេះ ឈ្មោះថាអន្តរាយ ព្រោះហេតុប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យ យ៉ាងនេះឯង ។

ចុះឈ្មោះថាអន្តរាយ ព្រោះហេតុអាស្រ័យក្នុងសរីរៈនោះ តើដូចម្តេច ។ ពួកធម៌ជាអកុសល ដ៏អាក្រក់ទាំងនុ៎ះ អាស្រ័យព្រមនូវអត្តភាព រមែងកើត ក្នុងអត្តភាពនោះ ។ ពួកពិលាសយសត្វ (សត្វនៅក្នុងរន្ធ) តែងដេកក្នុងរន្ធ ពួកឧទកាសយសត្វ (សត្វនៅក្នុងទឹក) តែងដេកក្នុងទឹក ពួកវនាសយសត្វ (សត្វនៅក្នុងព្រៃ) តែងដេកក្នុងព្រៃ ពួករុក្ខាសយសត្វ (សត្វនៅលើឈើ) តែងដេកលើឈើ យ៉ាងណា ពួកធម៌ជាអកុសល ដ៏អាក្រក់ទាំងនុ៎ះ អាស្រ័យព្រមនូវអត្តភាព រមែងកើតក្នុងអត្តភាពនោះ យ៉ាងនោះដែរ ឈ្មោះថាអន្តរាយ ព្រោះហេតុអាស្រ័យក្នុងសរីរៈនោះ យ៉ាងនេះក៏មាន ។

វុត្តំ ហេតំ(១) ភគវតា សាន្តេវាសិកោ ភិក្ខវេ ភិក្ខុ សាចរិយកោ ទុក្ខំ ន ផាសុ វិហរតិ កថញ្ច ភិក្ខវេ ភិក្ខុ សាន្តេវាសិកោ សាចរិយោ ទុក្ខំ ន ផាសុ វិហរតិ ឥធ ភិក្ខវេ ភិក្ខុនោ ចក្ខុនា រូបំ ទិស្វា ឧប្បជ្ជន្តិ យេ បាបកា អកុសលា ធម្មា សរសង្កប្បា សញ្ញោជនីយា ត្យាស្ស អន្តោ វសន្តិ អន្វាស្សវន្តិ(២) បាបកា អកុសលា ធម្មាតិ តស្មា សាន្តេវាសិកោតិ វុច្ចតិ តេ នំ សមុទាចរន្តិ បាប-កា អកុសលា ធម្មាតិ តស្មា សាចរិយោតិ វុច្ចតិ បុនចបរំ ភិក្ខវេ ភិក្ខុនោ សោតេន សទ្ទំ សុត្វា ឃានេន គន្ធំ ឃាយិត្វា ជិវ្ហាយ រសំ សាយិត្វា កាយេន ផោដ្ឋព្វំ ផុសិត្វា មនសា ធម្មំ វិញ្ញាយ ឧប្បជ្ជន្តិ យេ បាបកា អកុសលា ធម្មា សរសង្កប្បា សញ្ញោជនីយា ត្យាស្ស អន្តោ វសន្តិ អន្វាស្សវន្តិ បាបកា អកុសលា ធម្មាតិ

១ ម. វុត្តញ្ហេតំ ។ ២ ម. អន្វាយ វសត្តិ ។

សម្ដេចព្រះមានព្រះភាគ បានត្រាស់ព្រះតម្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅរួមដោយសិស្ស អ្នកនៅរួមដោយអាចារ្យ តែងនៅជាទុក្ខមិនសប្បាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅរួមដោយសិស្ស អ្នកនៅរួមដោយអាចារ្យ តែងនៅជាទុក្ខមិនសប្បាយ តើដូចម្ដេច ម្នាលភិក្ខុទាំងឡាយ ពួកធម៌ជាអកុសល ដ៏អាក្រក់ណា គឺសេចក្ដីត្រិះរិះដែលកើតដោយអំណាច នៃការរឭកតទៅ (កន្លងអារម្មណ៍ផ្សេងៗ) ជាគ្រឿងទំនុកបម្រុងដល់សំយោជនៈ របស់ភិក្ខុក្នុងសាសនានេះ កើតឡើងព្រោះឃើញរូបដោយចក្ខុ ពួកធម៌ជាអកុសលដ៏អាក្រក់នោះ នៅខាងក្នុងសន្ដាននៃភិក្ខុនោះ ជាប់ជិតប្រកិតតាមភិក្ខុនោះ ព្រោះហេតុនោះ ភិក្ខុនោះ តថាគតហៅថា អ្នកនៅរួមដោយសិស្ស ពួកធម៌ជាអកុសល ដ៏អាក្រក់នោះ រមែងប្រើភិក្ខុនោះ ព្រោះហេតុនោះ ភិក្ខុនោះ តថាគតហៅថា អ្នកនៅរួមដោយអាចារ្យ ម្នាលភិក្ខុទាំងឡាយ មួយទៀត ពួកធម៌ជាអកុសលដ៏អាក្រក់ណា គឺសេចក្ដីត្រិះរិះដែលកើតដោយអំណាច នៃការរឭកតទៅ ជាគ្រឿងទំនុកបម្រុងដល់សំយោជនៈ របស់ភិក្ខុ កើតឡើង ព្រោះឮសំឡេងដោយត្រចៀក ធុំក្លិនដោយច្រមុះ ត្រេកដញ្ញក់រសដោយអណ្ដាត ពាល់ត្រូវផ្សព្វដោយកាយ ដឹងធម្មារម្មណ៍ដោយចិត្ត ពួកធម៌ជាអកុសលដ៏អាក្រក់នោះ នៅខាងក្នុងសន្ដាននៃភិក្ខុនោះ ជាប់ជិតប្រកិតតាមភិក្ខុនោះ

តស្មា សាន្តេវាសិកោតិ វុច្ចតិ តេ នំ សមុទាចរន្តិ បាបកា អកុសលា ធម្មាតិ តស្មា សាចរិយោតិ វុច្ចតិ ឯវំ ខោ ភិក្ខវេ ភិក្ខុ សាន្តេវាសិកោ សាចរិយោ ទុក្ខំ ន ផាសុ វិហរតីតិ ។ ឯវម្បិ តត្រាសយាតិ បរិស្សយោ ។

វុត្តំ ហេតំ ភគវតា តយោមេ ភិក្ខវេ អន្តរាមលា អន្តរាអមិត្តា អន្តរាសបត្តា អន្តរាវធកា អន្តរាបច្ចត្ថិកា កតមេ តយោ លោភោ ភិក្ខវេ អន្តរាមលំ អន្តរាអមិត្តោ អន្តរាសបត្តោ អន្តរាវធកោ អន្តរាបច្ចត្ថិកោ ទោសោ ភិក្ខវេ ។បេ។ មោហោ ភិក្ខវេ អន្តរាមលំ អន្តរាអមិត្តោ អន្តរាសបត្តោ អន្តរាវធកោ អន្តរាបច្ចត្ថិកោ ឥមេ ខោ ភិក្ខវេ តយោ អន្តរាមលា អន្តរាអមិត្តា អន្តរាសបត្តា អន្តរាវធកា អន្តរាបច្ចត្ថិកាតិ ។

ខគ្គវិសាណសុត្តនិទ្ទេស

ព្រោះហេតុនោះ ភិក្ខុនោះ តថាគតហៅថា អ្នកនៅរួមដោយសិស្ស ពួកធម៌ជាអកុសល ដ៏អាក្រក់នោះ រមែងប្រើភិក្ខុនោះ ព្រោះហេតុនោះ ភិក្ខុនោះ តថាគតហៅថា អ្នកនៅរួមដោយអាចារ្យ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅរួមដោយសិស្ស អ្នកនៅរួមដោយអាចារ្យ តែងនៅជាទុក្ខមិនសប្បាយ យ៉ាងនេះឯង ។ ឈ្មោះថាអន្តរាយ ព្រោះហេតុអាស្រ័យក្នុងសរីរៈនោះ យ៉ាងនេះក៏មាន ។

មួយទៀត ព្រះមានព្រះភាគបានត្រាស់ព្រះតម្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ អកុសលធម៌ ៣ នេះ ជាមន្ទិលខាងក្នុង ជាអមិត្រខាងក្នុង ជាសត្រូវខាងក្នុង ជាពេជ្ឈឃាតខាងក្នុង ជាខ្មាំងខាងក្នុង អកុសលធម៌៣ តើដូចម្តេចខ្លះ ម្នាលភិក្ខុទាំងឡាយ លោភៈ ជាមន្ទិលខាងក្នុង ជាអមិត្រខាងក្នុង ជាសត្រូវខាងក្នុង ជាពេជ្ឈឃាតខាងក្នុង ជាខ្មាំងខាងក្នុង ម្នាលភិក្ខុទាំងឡាយ ទោសៈ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មោហៈ ជាមន្ទិលខាងក្នុង ជាអមិត្រខាងក្នុង ជាសត្រូវខាងក្នុង ជាពេជ្ឈឃាតខាងក្នុង ជាខ្មាំងខាងក្នុង ម្នាលភិក្ខុទាំងឡាយ អកុសលធម៌ ៣ នេះឯង ជាមន្ទិលខាងក្នុង ជាអមិត្រខាងក្នុង ជាសត្រូវខាងក្នុង ជាពេជ្ឈឃាតខាងក្នុង ជាខ្មាំងខាងក្នុង ។

អនត្ថជននោ លោភោ លោភោ ចិត្តប្បកោបនោ
ភយមន្តរតោ ជាតំ តំ ជនោ នាវពុជ្ឈតិ
លុទ្ធោ អត្ថំ ន ជានាតិ លុទ្ធោ ធម្មំ ន បស្សតិ
អន្ធតមំ តទា ហោតិ យំ លោភោ សហតេ នរំ
អនត្ថជននោ ទោសោ ទោសោ ចិត្តប្បកោបនោ
ភយមន្តរតោ ជាតំ តំ ជនោ នាវពុជ្ឈតិ
ទុដ្ឋោ អត្ថំ ន ជានាតិ ទុដ្ឋោ ធម្មំ ន បស្សតិ
អន្ធតមំ តទា ហោតិ យំ ទោសោ សហតេ នរំ
អនត្ថជននោ មោហោ មោហោ ចិត្តប្បកោបនោ
ភយមន្តរតោ ជាតំ តំ ជនោ នាវពុជ្ឈតិ
មូឡ្ហោ អត្ថំ ន ជានាតិ មូឡ្ហោ ធម្មំ ន បស្សតិ
អន្ធតមំ តទា ហោតិ យំ មោហោ សហតេ នរន្តិ ។

ឯវម្បិ តត្រាសយាតិ បរិស្សយា ។

លោភៈ ឲ្យកើតវិនាស លោភៈឲ្យចិត្តរំជួល ភ័យកើតខាងក្នុង អ្នកផងមិនយល់ភ័យនោះ ជនលោភមិនស្គាល់អត្ថ ជនលោភមិនឃើញធម៌ សេចក្តីងងឹតឈឹង តែងមានក្នុងកាលដែលលោភៈគ្របសង្កត់នរៈនោះ ទោសៈឲ្យកើតវិនាស ទោសៈឲ្យចិត្តរំជួល ភ័យកើតខាងក្នុង អ្នកផងមិនយល់ភ័យនោះ ជនប្រទុស្តមិនស្គាល់អត្ថ ជនប្រទុស្តមិនឃើញធម៌ សេចក្តីងងឹតឈឹង តែងមានក្នុងកាលដែលទោសៈគ្របសង្កត់នរៈនោះ មោហៈឲ្យកើតវិនាស មោហៈឲ្យចិត្តរំជួល ភ័យកើតខាងក្នុង អ្នកផងមិនយល់ភ័យនោះ ជនវង្វេងមិនស្គាល់អត្ថ ជនវង្វេងមិនឃើញធម៌ សេចក្តីងងឹតឈឹង តែងមាន ក្នុងកាលដែលមោហៈគ្របសង្កត់នរៈនោះ ៗ

ឈ្មោះថាអន្តរាយ ព្រោះហេតុអាស្រ័យក្នុងសរីរៈនោះ យ៉ាងនេះក៏មាន ៗ

## ខគ្គវិសាណសុត្តនិទ្ទេសោ

វុត្តំ ហេតំ ភគវតា តយោ ខោ មហារាជ បរិស្សយធម្មា អជ្ឈត្តំ ឧប្បជ្ជមានា ឧប្បជ្ជន្តិ អហិតាយ ទុក្ខាយ អផាសុវិហារាយ កតមេ តយោ លោភោ ខោ មហារាជ បរិស្សយធម្មោ អជ្ឈត្តំ ឧប្បជ្ជមានោ ឧប្បជ្ជតិ អហិតាយ ទុក្ខាយ អផាសុវិហារាយ ទោសោ ខោ មហារាជ ។បេ។ មោហោ ខោ មហារាជ បរិស្សយធម្មោ អជ្ឈត្តំ ឧប្បជ្ជមានោ ឧប្បជ្ជតិ អហិតាយ ទុក្ខាយ អផាសុវិហារាយ ឥមេ ខោ មហារាជ តយោ បរិស្សយធម្មា អជ្ឈត្តំ ឧប្បជ្ជមានា ឧប្បជ្ជន្តិ អហិតាយ ទុក្ខាយ អផាសុវិហារាយាតិ ។

លោភោ ទោសោ ច មោហោ ច
បុរិសំ បាបចេតសំ
ហឹសន្តិ អត្តសម្ភូតា
តចសារំវ សម្ផលន្តិ ។

ឯវម្បិ តត្រាសយាតិ បរិស្សយា ។

ខគ្គវិសាណសុត្តនិទ្ទេស

មួយទៀត ព្រះមានព្រះភាគបានត្រាស់ព្រះតម្រាស់នេះថា បពិត្រមហាពជ អកុសលធម៌ ៣ ជាធម៌អន្តរាយ កាលកើតខាងក្នុង កើតឡើងដើម្បីមិនជាគុណ ដើម្បីការលំបាក ដើម្បីការនៅមិនស្រួល អកុសល-ធម៌៣តើដូចម្តេចខ្លះ បពិត្រមហាពជ លោភៈ ជាធម៌អន្តរាយ កាលកើតខាងក្នុង កើតឡើងដើម្បីមិនជាគុណ ដើម្បីការលំបាក ដើម្បីការនៅមិនស្រួល បពិត្រមហាពជ ទោសៈ ។ បេ ។ បពិត្រមហាពជ មោហៈ ជាធម៌អន្តរាយ កាលកើតខាងក្នុង កើតឡើងដើម្បីមិនជាគុណ ដើម្បីការលំបាក ដើម្បីការនៅមិនស្រួល បពិត្រមហាពជ អកុសលធម៌ ៣ នេះឯង ជាធម៌អន្តរាយ កាលកើតខាងក្នុង កើតឡើងដើម្បីមិនជាគុណ ដើម្បីការលំបាក ដើម្បីការនៅមិនស្រួល ។

លោភៈ ទោសៈ នឹងមោហៈ កើតពីខ្លួន រមែង
សម្លាប់បុរស ដែលមានចិត្តបាប ដូចផ្លែឫស្សី
ដែលសម្លាប់ដើមរបស់ខ្លួន ។

ឈ្មោះថាអន្តរាយ ព្រោះហេតុអាស្រ័យក្នុងសរីរៈនោះ យ៉ាងនេះក៏មាន ។

វុត្តំ ហេតំ ភគវតា

រាគោ ទោសោ ច មោហោ ច ឥតោនិទានា
អរតី រតិ លោមហំសោ ឥតោជា
ឥតោ សមុដ្ឋាយ មនោវិតក្កា
កុមារកា ធង្កមិវោស្សជ្ជន្តីតិ ។

ឯវម្បិ តត្រាសយាតិ បរិស្សយា ។

បរិស្សយានំ សហិតាតិ បរិស្សយេ សហិតា អកណិតា(១) អជ្ឈោត្ថរិតា បីឡិតា ឃាតិតាតិ បរិស្សយានំ សហិតា ។ អច្ឆម្ភីតិ សោ បច្ចេកសម្ពុទ្ធោ អភីរុ អច្ឆម្ភី អនុត្រាសី អបលាយី បហីនភយភេរវោ វិគតលោមហំសោ វិហរតីតិ បរិស្សយានំ សហិតា អច្ឆម្ភី ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

---

១ ម. អាកណិតា ។

មួយទៀត ព្រះមានព្រះភាគបានត្រាស់ព្រះតម្រាស់នេះថា

រាគៈ ទោសៈ នឹងមោហៈ មានអត្តភាពនេះជាហេតុ
សេចក្តីមិនត្រេកអរ សេចក្តីត្រេកអរ នឹងសេចក្តីព្រឺ
ព្រួចរោម កើតហើយអំពីអត្តភាពនេះ សេចក្តីត្រិះរិះ
ក្នុងចិត្តទាំងឡាយ ដាលឡើងអំពីអត្តភាពនេះ ហើយ
លែងចិត្ត ដូចជាពួកក្មេងលែងក្អែក ។

ឈ្មោះថាអត្តភាព ព្រោះហេតុអាស្រ័យក្នុងសរីរៈនោះ យ៉ាងនេះក៏មាន ។

ពាក្យថា ជាអ្នកអត់ធ្មត់ ចំពោះអន្តរាយទាំងឡាយ គឺ ជាអ្នកអត់ធ្មត់ មិនដក់ចិត្ត រួបរឹត បៀតបៀន នូវពួកអន្តរាយ ហេតុនោះ (លោកពោលថា) ជាអ្នកអត់ធ្មត់ចំពោះអន្តរាយទាំងឡាយ ។ ពាក្យថា ជាអ្នកមិនតក់ស្លុត គឺព្រះបច្ចេកសម្ពុទ្ធនោះ មិនខ្លាច មិនតក់ស្លុត មិនរន្ធត់ មិនរត់ លះបង់សេចក្តីខ្លាច នឹងសេចក្តីញ័រចំប្រប់ហើយ ប្រាសចាកសេចក្តីព្រឺព្រួចរោម ហេតុនោះ (លោកពោលថា) ជាអ្នកអត់ធ្មត់ ចំពោះអន្តរាយទាំងឡាយ ជាអ្នកមិនតក់ស្លុត ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

ខគ្គវិសាណសុត្តនិទ្ទេសោ

ចាតុទ្ទិសោ អប្បដិឃោ ច ហោតិ
សន្តុស្សមានោ ឥតរីតរេន
បរិស្សយានំ សហិតា អឆម្ភី
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

(២៦១) ទុស្សង្គហា បព្វជិតាបិ ឯកេ
អថោ គហដ្ឋា ឃរមាវសន្តា
អប្បោស្សុក្កោ បរបុត្តេសុ ហុត្វា
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

(២៦២) ទុស្សង្គហា បព្វជិតាបិ ឯកេតិ ឯកេច្ចេ បព្វជិតាបិ និស្សយេបិ ទិយ្យមានេ ឧទ្ទេសេបិ ទិយ្យមានេ បរិបុច្ឆាយបិ ទិយ្យមានាយ ចីវរេបិ ទិយ្យមានេ បត្តេបិ ទិយ្យមានេ លោហថាលកេបិ ទិយ្យមានេ ធម្មករកេបិ ទិយ្យមានេ បរិស្សាវនេបិ ទិយ្យមានេ កុញ្ចិកាយបិ ទិយ្យមានាយ ឧបាហនេបិ ទិយ្យមានេ កាយពន្ធនេបិ ទិយ្យមានេ ន សុណន្តិ ន សោតំ ឱទហន្តិ ន អញ្ញាចិត្តំ ឧបដ្ឋបេន្តិ អនស្សវា អវចនករា បដិលោមវុត្តិនោ អញ្ញេនេវ មុខំ ករោន្តីតិ ទុស្សង្គហា បព្វជិតាបិ ឯកេ ។

ខគ្គវិសាណសុត្តនិទ្ទេស

បុគ្គលមានកិរិយានៅ ជាសុខ ក្នុងទិស ៤ ទាំងមិន មានសេចក្តីថ្នាំងថ្នាក់ចិត្ត សន្តោសដោយបច្ច័យ តាមមានតាមបាន ជាអ្នកអត់ធ្មត់ ចំពោះអន្តរាយទាំងឡាយ ជាអ្នកមិនតក់ស្លុត គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(២៦១) ពួកបព្វជិតខ្លះ នឹងពួកគ្រហស្ថ ដែលនៅគ្រប់គ្រងផ្ទះខ្លះ គេសង្គ្រោះបានដោយកម្រ បុគ្គលជាអ្នកមិនខ្វល់ខ្វាយ ក្នុងពួកបុត្តនៃអ្នកដទៃទេ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(២៦២) ពាក្យថា ពួកបព្វជិតខ្លះ គេសង្គ្រោះបានដោយកម្រ អធិប្បាយថា ពួកបព្វជិតខ្លះ ក្នុងលោកនេះ កាលបើគេឲ្យនិស្ស័យក្តី ឲ្យឧទ្ទេសក្តី ឲ្យបរិបុច្ឆាក្តី ឲ្យចីវរក្តី ឲ្យបាត្រក្តី ឲ្យផ្តិលលោហៈក្តី ឲ្យធម្មក្រកក្តី ឲ្យតម្រងទឹកក្តី ឲ្យកូនសោក្តី ឲ្យស្បែកជើងក្តី ឲ្យវត្តពន្ធន៍បង្កេះក្តី តែងមិនស្តាប់ មិនផ្ទៀងត្រចៀក មិនតាំងចិត្តបង់ដឹង ជាអ្នកមិនព្រមស្តាប់ មិនធ្វើតាមពាក្យ ប្រព្រឹត្តប្រាស បែរមុខទៅកាន់ទីដទៃ ហេតុនោះ (លោកពោលថា) ពួកបព្វជិតខ្លះ គេសង្គ្រោះបានដោយកម្រ ។

(២៦៣) អថោ គហដ្ឋា ឃរមាវសន្តាតិ សន្តេ-កច្ចេ គហដ្ឋាបិ ហត្ថិម្បិ និយ្យាមេន រថម្បិ ខេត្តម្បិ វត្ថុម្បិ ហិរញ្ញម្បិ សុវណ្ណម្បិ និយ្យាមេន គាមេបិ និគមេបិ ជនបទេបិ និយ្យាមេន ន សុណន្តិ ន សោតំ ឱទហន្តិ ន អញ្ញា ចិត្តំ ឧបដ្ឋបេន្តិ អនស្សវា អវចនករា បដិលោមវុត្តិនោ អញ្ញេនេវ មុខំ ករោន្តីតិ អថោ គហដ្ឋា ឃរមាវសន្តា ។

(២៦៤) អប្បោស្សុក្កោ បរបុត្តេសុ ហុត្វាតិ អត្តានំ ឋបេត្វា សព្វេ ឥមស្មឹ អត្ថេ បុត្តា ។ អប្បោស្សុក្កោ បរបុត្តេសុ ហុត្វាតិ អប្បោស្សុក្កោ ហុត្វា អព្យាវដោ ហុត្វា អនបេក្ខោ ហុត្វាតិ អប្បោ-ស្សុក្កោ បរបុត្តេសុ ហុត្វា ។ ឯកោ ចរេ ខគ្គវិសា-ណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

ទុស្សង្គហា បព្វជិតាបិ ឯកេ
អថោ គហដ្ឋា ឃរមាវសន្តា
អប្បោស្សុក្កោ បរបុត្តេសុ ហុត្វា
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

(២៦៣) ពាក្យថា ពួកគ្រហស្ថ ដែលនៅគ្រប់គ្រងផ្ទះខ្លះ គឺ ពួកគ្រហស្ថខ្លះ ក្នុងលោកនេះ កាលបើគេឲ្យដំរីក្តី ឲ្យរថក្តី ស្រែក្តី ចម្ការក្តី ប្រាក់ក្តី មាសក្តី ឲ្យស្រុកក្តី ក្រុងក្តី ខេត្តក្តី តែងមិនស្តាប់ មិនផ្ទៀងត្រចៀក មិនតាំងចិត្តចង់ដឹង ជាអ្នកមិនព្រមស្តាប់ មិនធ្វើតាមពាក្យ ប្រព្រឹត្តប្រាស បែរមុខទៅកាន់ទីដទៃ ហេតុនោះ (លោកពោលថា) ពួកគ្រហស្ថដែលនៅគ្រប់គ្រងផ្ទះខ្លះ ។

(២៦៤) ពាក្យថា បុគ្គលជាអ្នកមិនខ្វល់ខ្វាយក្នុងពួកបុត្តនៃអ្នកដទៃ គឺ បុគ្គលទាំងអស់ លើកលែងតែខ្លួនចេញ លោកពោលក្នុងអត្ថនេះ ។ ពាក្យថា បុគ្គលជាអ្នកមិនខ្វល់ខ្វាយ ក្នុងពួកបុត្តនៃអ្នកដទៃ បានសេចក្តីថា បុគ្គលជាអ្នកមិនខ្វល់ខ្វាយ ជាអ្នកមិនក្រវើន ជាអ្នកមិនអាឡោះអាល័យ ហេតុនោះ (លោកពោលថា) បុគ្គលជាអ្នកមិនខ្វល់ខ្វាយ ក្នុងពួកបុត្តនៃអ្នកដទៃ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

> ពួកបព្វជិតខ្លះ នឹងពួកគ្រហស្ថ ដែលនៅគ្រប់គ្រងផ្ទះ
> ខ្លះ គេសង្គ្រោះបានដោយកម្រ បុគ្គលជាអ្នកមិនខ្វល់
> ខ្វាយ ក្នុងពួកបុត្តនៃអ្នកដទៃទេ គប្បីប្រព្រឹត្តម្នាក់ឯង
> ដូចកុយរមាស ។

ខគ្គវិសាណសុត្តនិទ្ទេសោ

(២៦៥) ឱហារយិត្វា គិហិព្យញ្ជនានិ
សញ្ឆិន្នបត្តោ យថា កោវិឡារោ
ឆេត្វាន វីរោ(១) គិហិពន្ធនានិ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

(២៦៦) ឱហារយិត្វា គិហិព្យញ្ជនានីតិ គិហិព្យញ្ជនានិ វុច្ចន្តិ កេសា ច មស្សុ ច មាលា ច គន្ធំ ច វិលេបនំ ច អាភរណំ ច បិលន្ធនំ ច វត្ថញ្ច បារុបនញ្ច វេឋនញ្ច ឧច្ឆាទនញ្ច បរិមទ្ទនញ្ច នហាបនំ សម្ពាហនំ អាទាសំ អញ្ជនំ មាលាវិលេបនំ មុខចុណ្ណកំ មុខលេបំ ហត្ថពន្ធំ សិខាពន្ធំ ទណ្ឌំ នាឡិកំ ខគ្គំ ឆត្តំ ឧបាហនា ឧណ្ហិសំ មណិ វាលវីជនី ឱទាតានិ វត្ថានិ ទីឃរស្សានិ(២) ឥតិ វា ។ ឱហារយិត្វា គិហិព្យញ្ជនានីតិ ឱហារេត្វា និក្ខិបិត្វា បដិសម្ភយិត្វាតិ ឱហារយិត្វា គិហិព្យញ្ជនានិ ។

---

១ ម. ធីរោ ។ ២ ម. ទីឃទសានិ ។

## ១ត្តវិសោណកវុត្តនិទ្ទេស

(២៦៥) វីរបុរស លះបង់វត្ថុទាំងឡាយជាគ្រឿងប្រាកដ
របស់គ្រហស្ថ កាត់ចំណង របស់គ្រហស្ថទាំងឡាយ
ដូចរលួសផ្អុង ដែលជម្រុះស្លឹក គប្បីប្រព្រឹត្តម្នាក់
ឯង ដូចកុយរមាស ។

(២៦៦) ពាក្យថា លះបង់វត្ថុទាំងឡាយជាគ្រឿងប្រាកដ របស់គ្រហស្ថ សេចក្ដីថា សក់ ពុកមាត់ពុកចង្កា កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប គ្រឿងអាភរណៈ គ្រឿងប្រដាប់ សំពត់ គ្រឿងដណ្ដប់ ឈ្នួតក្បាល គ្រឿងដុសខាត់ ការគក់រឹតទួត ការផ្ងូត ការគក់ច្របាច់ កញ្ចក់ ប្រដាប់សម្រាប់បន្តក់ កម្រងផ្កា និងគ្រឿងលាប ស្រឡាប គ្រឿងលំអិតសម្រាប់ប្រស់មុខ គ្រឿងសម្រាប់លុបលាបមុខ គ្រឿងចងដៃ គ្រឿងចងដុក ដំបង បំពង់ថ្នាំ ព្រះខ័ន ឆ័ត្រ ស្បែកជើង ក្បាំងមុខ ស្នៀតសក់ ស៊ែ សំពត់សវែងនឹងខ្លី លោកហៅថា វត្ថុជាគ្រឿងប្រាកដ របស់គ្រហស្ថ ។ ពាក្យថា លះបង់វត្ថុទាំងឡាយ ជាគ្រឿងប្រាកដរបស់គ្រហស្ថ គឺ ទំលាក់ចោល ដាក់ចោល ជម្រុះចោល ហេតុនោះ (លោកពោលថា) លះបង់វត្ថុទាំងឡាយ ជាគ្រឿងប្រាកដរបស់គ្រហស្ថ ។

(២៦៧) សញ្ឆិន្នបត្តោ យថា កោវិឡារោតិ យថា កោវិឡារស្ស បត្តានិ សីណានិ ឆិន្នានិ បតិតានិ ឯវមេវ តស្ស បច្ចេកសម្ពុទ្ធស្ស គិហិព្យញ្ជនានិ ឆិន្នានិ បតិតានីតិ សញ្ឆិន្នបត្តោ យថា កោវិឡារោ ។

(២៦៨) ឆេត្វាន វីរោ គិហិពន្ធនានីតិ វីរិយវាតិ វីរោ ។ បហូតិ វីរោ ។ វិសវីតិ វីរោ ។ អលមត្តោតិ វីរោ ។ សូរោតិ វីរោ ។ វិក្កន្តោ អភីរុ អច្ឆម្ភី អនុត្រាសី អបលាយី បហីនភយភេរវោ វិគតលោមហំសោតិ វីរោ ។

អារតោ ឥធេវ សព្វបាបកេហិ
និរយទុក្ខមតិច្ច វីរិយវាសោ
សោ វីរិយវា បធានវា
វីរោ តាទិ វុច្ចតេ តថត្តា ។

(២៦៧) ពាក្យថា ដូចល្បួសម្ពុន ដែលជម្រុះស្លឹក សេចក្តីថា ស្លឹកទាំងឡាយ របស់ល្បួសម្ពុន ដែលរបេះ ដាច់ ជ្រុះ យ៉ាងណា វត្ថុទាំងឡាយ ជាគ្រឿងប្រាកដរបស់គ្រហស្ថ នៃព្រះបច្ចេកសម្ពុទ្ធនោះ ក៏ដាច់ជ្រុះ យ៉ាងនោះដែរ ហេតុនោះ (លោកពោលថា) ដូចល្បួសម្ពុន ដែលជម្រុះស្លឹក ។

(២៦៨) ពាក្យថា វីរបុរស កាត់ចំណងរបស់គ្រហស្ថទាំងឡាយ អធិប្បាយថា ឈ្មោះថាវីរបុរស ព្រោះហេតុមានសេចក្តីព្យាយាម ។ ឈ្មោះថាវីរបុរស ព្រោះហេតុជាអ្នកអាច ។ ឈ្មោះថាវីរបុរស ព្រោះហេតុញុំាងសេចក្តីព្យាយាមឲ្យកើត ។ ឈ្មោះថាវីរបុរស ព្រោះហេតុមានចិត្តអង់អាច ។ ឈ្មោះថាវីរបុរស ព្រោះហេតុជាអ្នកហ៊ាន ។ ឈ្មោះថាវីរបុរស ព្រោះហេតុជាអ្នកមោះមុត មិនខ្លាច មិនរន្ធត់ មិនស្រឡាំងកាំង មិនរត់ លះបង់សេចក្តីខ្លាចនឹងសេចក្តីញរ័ចំប្រប់ហើយ ប្រាសចាកសេចក្តីព្រឺរោម ។

ព្រះខីណាស្រព វៀរចាកបាបទាំងពួង កន្លងលោកនេះឯង មានការព្យាយាមជាលំនៅ កន្លងទុក្ខក្នុងនរក
លោកមានព្យាយាម មានសេចក្តីប្រឹងប្រែង ជាអ្នកនឹងធឹង មានសភាពដូច្នោះ ទើបលោកហៅថា វីរបុរស ។

គិហិពន្ធនានិ វុច្ចន្តិ បុត្តា ច ទាសីទាសា ច អជេឡកា ច កុក្កុដសូករា ច ហត្ថិគវស្សវឡវា ច ខេត្តញ្ច វត្ថុ ច ហិរញ្ញញ្ច សុវណ្ណញ្ច គាមនិគមរាជធានិយោ ច រដ្ឋញ្ច ជនបទោ ច កោសោ ច កោដ្ឋាគារញ្ច យញ្ចិញ្ចិ រជនីយវត្ថុ ។ ឆេត្វាន វីរោ គិហិពន្ធនានីតិ សោ បច្ចេកសម្ពុទ្ធោ វីរោ គិហិពន្ធនានិ ឆិន្ទិត្វា សមុច្ឆិន្ទិត្វា ជហិត្វា វិនោទេត្វា ព្យន្តីករិត្វា អនភាវង្គមេត្វាតិ ឆេត្វាន វីរោ គិហិពន្ធនានិ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

ឱរោបយិត្វា គិហិព្យញ្ជនានិ
សញ្ឆិន្នបត្តោ យថា កោវិឡារោ
ឆេត្វាន វីរោ គិហិពន្ធនានិ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

## ខគ្គវិសាណសុត្តនិទ្ទេស

ពួកកូន ខ្ញុំស្រី នឹងខ្ញុំប្រុស ពពែ និងចៀម មាន់ នឹងជ្រូក ដំរី គោ សេះឈ្មោល សេះញី ស្រែ ចម្ការ ប្រាក់ មាស ស្រុក និគម រាជធានី ដែន ជនបទ បន្ទាយ ឃ្លាំង នឹងវត្ថុជាទីត្រេកត្រអាលណាមួយ លោកហៅថា បំណងរបស់គ្រហស្ថ ។ ពាក្យថា វីរបុរសកាត់បំណង របស់គ្រហស្ថទាំងឡាយ បានសេចក្ដីថា ព្រះបច្ចេកសម្ពុទ្ធនោះ ជាវីរបុរស កាត់ ក្របែល លះ បន្ទោបង់ ធ្វើឲ្យវិនាសនូវបំណងរបស់គ្រហស្ថទាំងឡាយ ធ្វើឲ្យដល់នូវកិរិយាលែងកើត ហេតុនោះ (លោកពោលថា) វីរបុរស កាត់បំណងរបស់គ្រហស្ថទាំងឡាយ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

វីរបុរស លះបង់វត្ថុទាំងឡាយ ជាគ្រឿងប្រាកដ
របស់គ្រហស្ថ កាត់បំណងរបស់គ្រហស្ថទាំងឡាយ
ដូចរលួសផ្អុង ដែលជម្រុះស្លឹក គប្បីប្រព្រឹត្តម្នាក់
ឯង ដូចកុយរមាស ។

(២៦៩) សចេ លភេថ និបកំ សហាយំ
សទ្ធិំចរំ សាធុវិហារិ ធីរំ
អភិភុយ្យ សព្វានិ បរិស្សយានិ
ចរេយ្យ តេនត្តមនោ សតិមា ។

(២៧០) សចេ លភេថ និបកំ សហាយន្តិ សចេ និបកំ បណ្ឌិតំ បញ្ញវន្តំ ពុទ្ធិមន្តំ ញាណឹ វិភាវឹ មេធាវឹ សហាយំ លភេយ្យ បដិលភេយ្យ អធិគច្ឆេយ្យ វិន្ទេយ្យាតិ សចេ លភេថ និបកំ សហាយំ ។

(២៧១) សទ្ធិំចរំ សាធុវិហារិ ធីរន្តិ សទ្ធិំចរន្តិ ឯកតោ ចរំ ។ សាធុវិហារិន្តិ បឋមេនបិ ឈានេន សាធុវិហារឹ ទុតិយេនបិ ឈានេន តតិយេនបិ ឈានេន ចតុត្ថេនបិ ឈានេន សាធុវិហារឹ មេត្តាយបិ ចេតោវិមុត្តិយា សាធុវិហារឹ ករុណាយបិ មុទិតាយបិ ឧបេក្ខាយបិ ចេតោវិមុត្តិយា សាធុវិហារឹ

(២៦៩) បើបុគ្គល បានសំឡាញ់ មានប្រាជ្ញាចាស់ទុំ
ជាអ្នកប្រព្រឹត្តត្រូវគ្នា មានការនៅប្រពៃ ជាអ្នកប្រាជ្ញ
អាចគ្របសង្កត់អន្តរាយទាំងពួងបាន គប្បីមានស្មារតី
មានចិត្តត្រេកអរ ប្រព្រឹត្តនៅជាមួយសំឡាញ់នោះចុះ ។

(២៧០) ពាក្យថា បើបុគ្គលបានសំឡាញ់ មានប្រាជ្ញាចាស់ទុំ គឺ បើបុគ្គលគប្បីបាន គប្បីជួប គប្បីប្រទះ គប្បីពើបពះ នូវសំឡាញ់ មានប្រាជ្ញាចាស់ទុំ ជាបណ្ឌិត ជាបញ្ញាវន្ត មានសេចក្ដីវៃ មានសេចក្ដីដឹង មានសេចក្ដីយល់ច្បាស់ មានប្រាជ្ញាជាគ្រឿងទម្លាយកិលេស ហេតុនោះ (លោកពោលថា) បើ បុគ្គលបានសំឡាញ់ មានប្រាជ្ញា ។

(២៧១) អធិប្បាយពាក្យថា ជាអ្នកប្រព្រឹត្តត្រូវគ្នា មានការនៅប្រពៃ ជាអ្នកប្រាជ្ញ ត្រង់ពាក្យថា ជាអ្នកប្រព្រឹត្តត្រូវគ្នា គឺ ប្រព្រឹត្តក្នុងមុខការជាមួយគ្នា ។ ពាក្យថា មានការនៅប្រពៃ គឺ មានការនៅដ៏ប្រពៃ ដោយបឋមជ្ឈានក៏បាន មានការនៅដ៏ប្រពៃ ដោយទុតិយជ្ឈានក៏បាន ដោយតតិយជ្ឈានក៏បាន ដោយចតុត្ថជ្ឈានក៏បាន មានការនៅដ៏ប្រពៃ ដោយចេតោវិមុត្តិគឺមេត្តាក៏បាន មានការនៅដ៏ប្រពៃដោយចេតោវិមុត្តិ គឺករុណាក៏បាន មុទិតាក៏បាន ឧបេក្ខាក៏បាន មានការ

## ខគ្គវិសាណសុត្តនិទ្ទេសោ

អាកាសានញ្ចាយតនសមាបត្តិយាបិ សាធុវិហារី វិញ្ញាណញ្ចាយតនសមាបត្តិយាបិ អាកិញ្ចញ្ញាយតនសមាបត្តិយាបិ នេវសញ្ញានាសញ្ញាយតនសមាបត្តិយាបិ សាធុវិហារី និរោធសមាបត្តិយាបិ សាធុវិហារី ផលសមាបត្តិយាបិ សាធុវិហារី ។ ធីរន្តិ ធីរំ បណ្ឌិតំ បញ្ញវន្តំ ពុទ្ធិមន្តំ ញាណឹ វិភាវឹ មេធាវិន្តិ សទ្ធឹចរំ សាធុវិហារិ ធីរំ ។

(២៧២) អភិភុយ្យ សហានិ បរិស្សយានីតិ បរិស្សយាតិ ទ្វេ បរិស្សយា បាកដបរិស្សយា ច បដិច្ឆន្នបរិស្សយា ច ។បេ។ ឥមេ វុច្ចន្តិ បាកដបរិស្សយា ។បេ។ ឥមេ វុច្ចន្តិ បដិច្ឆន្នបរិស្សយា ។ អភិភុយ្យ សហានិ បរិស្សយានីតិ សហានិ បរិស្សយានិ អភិភុយ្យ អភិភវិត្វា អជ្ឈោត្ថរិត្វា បរិយាទយិត្វាតិ អភិភុយ្យ សហានិ បរិស្សយានិ ។

នៅដ៏ប្រពៃ ដោយអាកាសានញ្ចាយតនសមាបត្តិក៏បាន មានការនៅដ៏ប្រពៃ ដោយវិញ្ញាណញ្ចាយតនសមាបត្តិក៏បាន ដោយអាកិញ្ចញ្ញាយតនសមាបត្តិក៏បាន ដោយនេវសញ្ញានាសញ្ញាយតនសមាបត្តិក៏បាន មានការនៅដ៏ប្រពៃ ដោយនិរោធសមាបត្តិក៏បាន មានការនៅដ៏ប្រពៃ ដោយផលសមាបត្តិក៏បាន ។ ពាក្យថា ជាអ្នកប្រាជ្ញ គឺជាអ្នកមានប្រាជ្ញា ជាបណ្ឌិត ជាបញ្ញាវន្ត មានសេចក្ដីចេះ មានសេចក្ដីដឹង មានសេចក្ដីយល់ច្បាស់ មានប្រាជ្ញាជាគ្រឿងទំលាយកិលេស ហេតុនោះ (លោកពោលថា) ជាអ្នកប្រព្រឹត្តត្រូវគ្នា មានការនៅប្រពៃ ជាអ្នកប្រាជ្ញ ។

(២៧២) អធិប្បាយពាក្យថា គ្របសង្កត់អន្តរាយទាំងពួង ត្រង់ពាក្យថា អន្តរាយ បានដល់ អន្តរាយ ២ គឺ អន្តរាយប្រាកដ ១ អន្តរាយកំបាំង១ ។បេ។ ទាំងនេះ ហៅថា អន្តរាយប្រាកដ ។បេ។ ទាំងនេះហៅថា អន្តរាយកំបាំង ។ ពាក្យថា គ្របសង្កត់អន្តរាយទាំងពួង បានសេចក្ដីថា គ្រប គ្របសង្កត់ បង្ក្រប រួបរឹត នូវពួកអន្តរាយទាំងពួង ហេតុនោះ (លោកពោលថា) គ្របសង្កត់អន្តរាយទាំងពួង ។

(២៧៣) ចរេយ្យ តេនត្តមនោ សតិមាតិ សោ បច្ចេកសម្ពុទ្ធោ តេន និបកេន បណ្ឌិតេន បញ្ញវន្តេន ពុទ្ធិមន្តេន ញាណិនា វិភាវិនា មេធាវិនា សហាយេន សទ្ធិំ អត្តមនោ តុដ្ឋមនោ ហដ្ឋមនោ បហដ្ឋមនោ ឧទគ្គមនោ បមុទិតមនោ ចរេយ្យ វិចរេយ្យ(១) ឥរិយេយ្យ វត្តេយ្យ បាលេយ្យ យបេយ្យ យាបេយ្យាតិ ចរេយ្យ តេនត្តមនោ ។ សតិមាតិ សោ បច្ចេកសម្ពុទ្ធោ សតិមា ហោតិ បរមេន សតិនេបកេន សមន្នាគតោ ចិរកតំបិ ចិរភាសិតំបិ សរិតា អនុស្សរិតាតិ ចរេយ្យ តេនត្តមនោ សតិមា ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

---

១ ម. វិហរេយ្យ ។

(២៧៣) ពាក្យថា គប្បីមានស្មារតី មានចិត្តត្រេកអរ ប្រព្រឹត្តទៅជាមួយសំឡាញ់នោះចុះ អធិប្បាយថា ព្រះបច្ចេកសម្ពុទ្ធនោះ មានចិត្តត្រេកអរ មានចិត្តសប្បាយ មានចិត្តរីករាយ មានចិត្តស្រស់ស្រាយ មានចិត្តអណ្តែត មានចិត្តពព្រាយ គប្បីត្រាច់ទៅ គប្បីត្រាច់ទៅផ្សេងៗ ទៅប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ ជាមួយនឹងសំឡាញ់ ជាអ្នកមានប្រាជ្ញាចាស់ទុំ ជាបណ្ឌិត ជាបញ្ញាវន្ត មានសេចក្តីបេះ មានសេចក្តីដឹង មានសេចក្តីយល់ច្បាស់ មានប្រាជ្ញាជាគ្រឿងទម្លាយកិលេសនោះ ហេតុនោះ (លោកពោលថា) គប្បីមានចិត្តត្រេកអរ ប្រព្រឹត្តទៅ ជាមួយសំឡាញ់នោះចុះ ។ ពាក្យថា មានស្មារតី គឺព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលមានស្មារតី ប្រកបដោយស្មារតីនឹងប្រាជ្ញាដ៏ក្រៃលែង រឭក រឭកឃើញនូវអំពើដែលលោកធ្វើយូរមកហើយផង នូវពាក្យដែលលោកពោលយូរមកហើយផង ហេតុដូច្នោះ (លោកពោលថា) គប្បីមានស្មារតី មានចិត្តត្រេកអរ ប្រព្រឹត្តទៅជាមួយសំឡាញ់នោះចុះ ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

ខគ្គវិសាណសុត្តនិទ្ទេសោ

ស ចេ លភេថ និបកំ សហាយំ

សទ្ធិំចរំ សាធុវិហារិ ធីរំ

អភិភុយ្យ សព្វានិ បរិស្សយានិ

ចរេយ្យ តេនត្តមនោ សតិមាតិ ។

(២៧៨) នោ ចេ លភេថ និបកំ សហាយំ

សទ្ធិំចរំ សាធុវិហារិ ធីរំ

រាជាវ រដ្ឋំ វិជិតំ បហាយ

ឯកោ ចរេ ខគ្គវិសាណកប្បោ ។

(២៧៩) នោ ចេ លភេថ និបកំ សហាយន្តិ នោ ចេ និបកំ បណ្ឌិតំ បញ្ញវន្តំ ពុទ្ធិមន្តំ ញាណី វិភាវី មេធាវី សហាយំ លភេយ្យ បដិលភេយ្យ អធិគច្ឆេយ្យ វិន្ទេយ្យាតិ នោ ចេ លភេថ និបកំ សហាយំ ។

## ខគ្គវិសាណសុត្តនិទ្ទេស

បើបុគ្គលបានសំឡាញ់ មានប្រាជ្ញាចាស់ទុំ ជាអ្នកប្រព្រឹត្តត្រូវគ្នា មានការនៅប្រពៃ ជាអ្នកប្រាជ្ញ អាចគ្របសង្កត់អន្តរាយទាំងពួងបាន គប្បីមានស្មារតី មានចិត្តត្រេកអរ ប្រព្រឹត្តនៅជាមួយសំឡាញ់នោះចុះ ។

(២៧៨) បើបុគ្គលរកមិនបានសំឡាញ់ មានប្រាជ្ញាចាស់ទុំ ជាអ្នកប្រព្រឹត្តត្រូវគ្នា មានការនៅប្រពៃ ជាអ្នកប្រាជ្ញទេ គប្បីប្រព្រឹត្តម្នាក់ឯង ដូចព្រះរាជាលះបង់ដែនដែលទ្រង់ឈ្នះហើយ ឬដូចកុយរមាស ។

(២៧៩) ពាក្យថា បើបុគ្គលរកមិនបានសំឡាញ់មានប្រាជ្ញាចាស់ទុំ គឺ បើបុគ្គលរកមិនបាន មិនចួប មិនប្រទះ មិនតើបពះ នូវសំឡាញ់ដែលមានប្រាជ្ញាចាស់ទុំ ជាបណ្ឌិត ជាបញ្ញវន្ត មានសេចក្តីចេះ មានសេចក្តីដឹង មានសេចក្តីយល់ច្បាស់ មានប្រាជ្ញាជាគ្រឿងទម្លាយកិលេស ហេតុនោះ (លោកពោលថា) បើបុគ្គលរកមិនបានសំឡាញ់មានប្រាជ្ញាចាស់ទុំ ។

(២៧៦) សទ្ធឹចរំ សាធុវិហារិ ធីរន្តិ សទ្ធឹចរន្តិ ឯកតោ ចរំ ។ សាធុវិហារិន្តិ បឋមេនបិ ឈានេន សាធុវិហារី ។បេ។ និរោធសមាបត្តិយាបិ សាធុវិហារី ផលសមាបត្តិយាបិ សាធុវិហារី ។ ធីរន្តិ ធីរំ បណ្ឌិតំ បញ្ញវន្តំ ពុទ្ធិមន្តំ ញាណឹ វិភាវី មេធាវិន្តិ សទ្ធឹចរំ សាធុវិហារិ ធីរំ ។

(២៧៧) រាជាវ រដ្ឋំ វិជិតំ បហាយាតិ រាជា ខត្តិយោ មុទ្ធាភិសិត្តោ វិជិតសង្គាមោ និហតបច្ចាមិត្តោ លទ្ធាធិប្បាយោ បរិបុណ្ណកោដ្ឋាគារោ រដ្ឋញ្ច ជនបទញ្ច កោដ្ឋាគារញ្ច បហូតហិរញ្ញសុវណ្ណំ នគរញ្ច បរិច្ចជិត្វា កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិត្វា អកិញ្ចនភាវំ ឧបគន្ត្វា ឯកោ ចរតិ វិចរតិ ឥរិយតិ វត្តេតិ បាលេតិ យបេតិ យាបេតិ ឯវំ បច្ចេកសម្ពុទ្ធោបិ សព្វំ ឃរាវាសបលិពោធំ ឆិន្ទិត្វា

(២៧៦) អធិប្បាយពាក្យថា ជាអ្នកប្រព្រឹត្តត្រូវគ្នា មានការនៅប្រពៃ ជាអ្នកប្រាជ្ញ ត្រង់ពាក្យថា ជាអ្នកប្រព្រឹត្តត្រូវគ្នា គឺជាអ្នកប្រព្រឹត្តក្នុងមុខការជាមួយគ្នា ។ ពាក្យថា មានការនៅប្រពៃ គឺមានការនៅប្រពៃ ដោយបឋមជ្ឈានក៏បាន ។ បេ ។ មានការនៅប្រពៃ ដោយនិរោធសមាបត្តិក៏បាន មានការនៅប្រពៃ ដោយផលសមាបត្តិក៏បាន ។ ពាក្យថា ជាអ្នកប្រាជ្ញ គឺជាអ្នកមានប្រាជ្ញា ជាបណ្ឌិត ជាបញ្ញវន្ត មានសេចក្តីចេះ មានសេចក្តីដឹង មានសេចក្តីយល់ច្បាស់ មានប្រាជ្ញាជាគ្រឿងទម្លាយកិលេស ហេតុនោះ (លោកពោលថា) ជាអ្នកប្រព្រឹត្តត្រូវគ្នា មានការនៅប្រពៃ ជាអ្នកប្រាជ្ញ ។

(២៧៧) ពាក្យថា ដូចព្រះរាជាលះបង់ដែន ដែលទ្រង់ឈ្នះហើយ អធិប្បាយថា ព្រះរាជាជាក្សត្រិយ៍ ដែលបានមុទ្ធាភិសេក បានឈ្នះសង្គ្រាម បានកំចាត់បច្ចាមិត្រ បានសម្រេចតាមព្រះបំណងហើយ មានឃ្លាំងបរិបូណ៌ ទ្រង់លះបង់ដែនផង ជនបទផង ឃ្លាំងដាក់ប្រាក់នឹងមាសច្រើនផង នគរផង ហើយកោរព្រះកេសនឹងព្រះមស្សុ ទ្រង់កាសាយពស្ត្រ ចេញចាកដំណាក់ ហើយទ្រង់ព្រះផ្នួស ដល់នូវភាពមិនមានកង្វល់ ត្រាច់ត្រាច់ទៅផ្សេងៗ ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ មួយអង្គឯង (យ៉ាងណា) ឯព្រះបច្ចេកសម្ពុទ្ធ កាត់សេចក្តីកង្វល់ក្នុងឃរាវាសទាំងអស់

## ខគ្គវិសាណសុត្តនិទ្ទេសោ

បុត្តទារបលិពោធំ ឆិន្ទិត្វា ញាតិបលិពោធំ ឆិន្ទិត្វា មិត្តាមច្ចបលិពោធំ ឆិន្ទិត្វា កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិត្វា អកិញ្ចនភាវំ ឧបគន្ត្វា ឯកោ ចរតិ វិចរតិ ឥរិយតិ វត្តតិ បាលេតិ យបេតិ យាបេតីតិ រាជាវ រដ្ឋំ វិជិតំ បហាយ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

នោ ចេ លភេថ និបកំ សហាយំ
សទ្ធិំចរំ សាធុវិហារិ ធីរំ
រាជាវ រដ្ឋំ វិជិតំ បហាយ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

(២៧៨) អទ្ធា បសំសាម សហាយសម្បទំ
សេដ្ឋា សមា សេវិតព្វា សហាយា
ឯតេ អលទ្ធា អនវជ្ជភោជី
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

## ខគ្គវិសាណសុត្តនិទ្ទេស

កាត់សេចក្តីកង្វល់ក្នុងកូននឹងប្រពន្ធ កាត់សេចក្តីកង្វល់ក្នុងញាតិ កាត់សេចក្តីកង្វល់ក្នុងមិត្តនឹងអាមាត្យ កោរសក់ពុកមាត់ពុកចង្កា ស្លៀកដណ្តប់កាសាយពស្ត្រ ចេញចាកគេហដ្ឋាន ហើយដល់នូវភាពមិនមានកង្វល់ ត្រាច់ ត្រាច់ទៅផ្សេងៗ ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅតែម្នាក់ឯង ក៏យ៉ាងនោះ ហេតុនោះ (លោកពោលថា) ដូចព្រះរាជាលះបង់ដែន ដែលទ្រង់ឈ្នះហើយ ៗ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ៗ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

បើបុគ្គលរកមិនបានសំឡាញ់ មានប្រាជ្ញាចាស់ទុំ ជា
អ្នកប្រព្រឹត្តត្រូវគ្នា មានការនៅប្រពៃ ជាអ្នកប្រាជ្ញទេ
គប្បីប្រព្រឹត្តម្នាក់ឯង ដូចព្រះរាជាលះបង់ដែន ដែល
ទ្រង់ឈ្នះហើយ ឬដូចកុយរមាស ៗ

(២៧៨) តាមពិត យើងសរសើរនូវការបរិបូណ៌ដោយ
សំឡាញ់ហើយ តែបុគ្គលគួរគប់រកសំឡាញ់ មាន
គុណប្រសើរជាងខ្លួន នឹងសំឡាញ់មានគុណស្មើនឹង
ខ្លួន បើរកមិនបានសំឡាញ់ទាំងនុ៎ះទេ គប្បីជាអ្នក
បរិភោគភោជនមិនមានទោស ហើយប្រព្រឹត្តម្នាក់ឯង
ដូចកុយរមាស ៗ

[២៧៩] អទ្ធា បសំសាម សហាយសម្បទន្តិ អទ្ធាតិ ឯកំសវចនំ និស្សំសយវចនំ និក្កង្ខវចនំ អទ្វេជ្ឈវចនំ អទ្វេឡ្ហកវចនំ និយោគវចនំ អបណ្ណកវចនំ អវត្ថាបនវចនមេតំ អទ្ធាតិ ។ សហាយសម្បទន្តិ សហាយសម្បទា វុច្ចតិ យោ សោ សហាយោ អសេក្ខេន សីលក្ខន្ធេន សមន្នាគតោ ហោតិ អសេក្ខេន សមាធិក្ខន្ធេន អសេក្ខេន បញ្ញាក្ខន្ធេន អសេក្ខេន វិមុត្តិក្ខន្ធេន អសេក្ខេន វិមុត្តិញាណទស្សនក្ខន្ធេន សមន្នាគតោ ហោតិ ។ អទ្ធា បសំសាម សហាយសម្បទន្តិ សហាយសម្បទំ បសំសាម ថោមេម កិត្តេម វណ្ណេមាតិ អទ្ធា បសំសាម សហាយសម្បទំ ។

[២៨០] សេដ្ឋា សមា សេវិតព្វា សហាយាតិ សេដ្ឋា ហោន្តិ សហាយា សីលេន សមាធិនា បញ្ញាយ វិមុត្តិយា វិមុត្តិញាណទស្សនេន សមា ហោន្តិ

(២៧៩) អធិប្បាយពាក្យថា តាមពិត យើងសរសើរនូវការបរិបូណ៌ ដោយសំឡាញ់ហើយ ត្រង់ពាក្យថា តាមពិត គឺ ជាពាក្យពោលដោយ បំណែកមួយ ជាពាក្យពោលដោយឥតមានសង្ស័យ ជាពាក្យពោល ដោយឥតងឿងឆ្ងល់ ជាពាក្យមិនបែកជាពីរ ជាពាក្យមិនព្រែកជាពីរ ជា ពាក្យប្រកបអស់ដើង ជាពាក្យមិនខុស ពាក្យថា តាមពិត នុ៎ះ ជាពាក្យ កំណត់ ៗ ពាក្យថា ការបរិបូណ៌ដោយសំឡាញ់ សេចក្តីថា ដែលហៅ ថា ការបរិបូណ៌ដោយសំឡាញ់ បានដល់សំឡាញ់ ប្រកបដោយ អសេក្ខសីលក្ខន្ធ ប្រកបដោយអសេក្ខសមាធិក្ខន្ធ ដោយអសេក្ខបញ្ញាខន្ធ ដោយអសេក្ខវិមុត្តិក្ខន្ធ ដោយអសេក្ខវិមុត្តិញាណទស្សនក្ខន្ធ ៗ ពាក្យ ថា តាមពិត យើងសរសើរនូវការបរិបូណ៌ ដោយសំឡាញ់ហើយ គឺ យើងសរសើរ ស្ងើច កោត ថ្លែងគុណ នូវការបរិបូណ៌ដោយសំឡាញ់ ហេតុនោះ (លោកពោលថា) តាមពិត យើងសរសើរនូវការបរិបូណ៌ ដោយសំឡាញ់ហើយ ៗ

(២៨០) ពាក្យថា បុគ្គលគួរគប់រកសំឡាញ់ មានគុណប្រសើរ ជាងខ្លួន នឹងសំឡាញ់មានគុណស្មើនឹងខ្លួន អធិប្បាយថា សំឡាញ់ជា បុគ្គលប្រសើរជាងដោយសីល សមាធិ បញ្ញា វិមុត្តិ វិមុត្តិញាណទស្សនៈ

## ខគ្គវិសាណសុត្តនិទ្ទេសោ

សហាយា សីលេន សមាធិនា បញ្ញាយ វិមុត្តិយា វិមុត្តិញាណទស្សនេន សេដ្ឋោ វា សហាយា សមោ វា សហាយា សេវិតព្វោ ភជិតព្វោ បយិរុបាសិតព្វោ បរិបុច្ឆិតព្វោ បរិបញ្ហិតព្វោតិ សេដ្ឋោ សមោ សេវិតព្វោ សហាយា ។

(២៨១) ឯកេ អលទ្ធា អនវជ្ជភោជីតិ អត្ថិ បុគ្គលោ សាវជ្ជភោជី អត្ថិ បុគ្គលោ អនវជ្ជភោជី ។

កតមោ ច បុគ្គលោ សាវជ្ជភោជី ។ ឥធេកច្ចោ បុគ្គលោ កុហនាយ លបនាយ នេមិត្តកតាយ និប្បេសិកតាយ លាភេន លាភំ និជិគីសនតាយ ទារុទានេន វេឡុទានេន បត្តទានេន បុប្ផទានេន(១) សិនានទានេន ចុណ្ណទានេន មត្តិកទានេន ទន្តកដ្ឋទានេន មុខោទកទានេន ចាដុកម្យតាយ មុគ្គសូបតាយ ចារិភដ្យតាយ បរបិដ្ឋិមំសិកតាយ វត្ថុវិជ្ជាយ តិរច្ឆានវិជ្ជាយ អង្គវិជ្ជាយ នក្ខត្តវិជ្ជាយ ទូតគមនេន បហីនគមនេន

១ ម. បុប្ផទានេន ផលទានេន ។

ខគ្គវិសាណសុត្តនិទ្ទេស

សំឡាញ់ ជាបុគ្គលស្មើដោយសីល សមាធិ បញ្ញា វិមុត្តិ វិមុត្តិញាណទស្សនៈ បុគ្គលត្រូវសេពគប់ ត្រូវគប់រក ត្រូវចូលទៅអង្គុយជិត ត្រូវសាកសួរ ត្រូវដេញដោល នូវសំឡាញ់មានគុណប្រសើរជាងខ្លួន ឬសំឡាញ់មានគុណស្មើនឹងខ្លួន ហេតុនោះ (លោកពោលថា) បុគ្គលគួរគប់រកសំឡាញ់មានគុណប្រសើរជាងខ្លួននឹងសំឡាញ់មានគុណស្មើនឹងខ្លួន ។

[២៨១] ពាក្យថា បើរកមិនបានសំឡាញ់ ទាំងនុ៎ះទេ គប្បីជាអ្នកបរិភោគភោជនមិនមានទោស អធិប្បាយថា បុគ្គលបរិភោគភោជនប្រកបដោយទោសក៏មាន បុគ្គលបរិភោគភោជនមិនមានទោសក៏មាន ។

ចុះបុគ្គលបរិភោគភោជន ប្រកបដោយទោស តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ បាន ចួប ប្រទះ ពើបពះ ប្រសព្វ ដោយអធម៌មិនរាបទាបហើយចិញ្ចឹមជីវិត គឺដោយកិរិយាបំភាន់ កិរិយាសួរព៉ាវ កិរិយាបញ្ឆិតបញ្ឆៀង កលល្បិច កិរិយាស្វែងលាភដោយលាភ ដោយការឲ្យឈើ ឲ្យឫស្សី ឲ្យស្លឹកឈើ ឲ្យផ្កាឈើ ឲ្យគ្រឿងសម្រាប់ងូត ឲ្យលំអិត ឲ្យដីស្អិត ឲ្យឈើស្ទន់ ឲ្យទឹកសម្រាប់លុបមុខ ដោយការបន្ទាបខ្លួនចំពោះត្រកូល ដោយសំដីដូចជាសំម្លសណ្តែកបាយ ដោយការបី-ពបញ្ជិះសេះកូនត្រកូល ដោយការស៊ីសាច់ខ្នងគេ ដោយវត្ថុវិជ្ជា តិរច្ឆានវិជ្ជា អង្គវិជ្ជា នក្ខត្តវិជ្ជា ដោយធ្វើទូតេយ្យកម្ម ហើយទៅ ដោយការទៅកាន់ទីដែលគេប្រើទៅ

ជង្ឃប្បេសនីយេន វេជ្ជកម្មេន ទូតកម្មេន បិណ្ឌប-
ដិបិណ្ឌកេន ទានានុប្បទានេន អធម្មេន វិសមេន
លទ្ធា លភិត្វា បដិលភិត្វា អធិគន្ត្វា វិន្ទិត្វា ជីវិកំ(១)
កប្បេតិ អយំ វុច្ចតិ បុគ្គលោ សាវជ្ជភោជី ។

កតមោ ច បុគ្គលោ អនវជ្ជភោជី ។ ឥធេក-
ច្ចោ បុគ្គលោ ន កុហនាយ ន លបនាយ ន
នេមិត្តកតាយ ន និប្បេសិកតាយ ន លាភេន
លាភំ និជិគីសនតាយ ន ទារុទានេន ន វេឡុទានេន
ន បត្តទានេន ន បុប្ផទានេន(២) ន សិនានទានេន
ន ចុណ្ណទានេន ន មត្តិកទានេន ន ទន្តកដ្ឋទានេន
ន មុខោទកទានេន ន ចាតុកម្យតាយ ន មុគ្គ-
សូបតាយ ន បារិភដ្យតាយ ន បរបិដ្ឋិមំសិកតាយ
ន វត្ថុវិជ្ជាយ ន តិរច្ឆានវិជ្ជាយ ន អង្គវិជ្ជាយ ន
នក្ខត្តវិជ្ជាយ ន ទូតគមនេន ន បហិណគមនេន ន
ជង្ឃប្បេសនីយេន ន វេជ្ជកម្មេន ន ទូតកម្មេន ន

១ ម. ជីវិតំ ។ ២ ម. ន បុប្ផទានេន ន ផលទានេន ។

ដោយការបម្រើគេដោយស្មង ដោយវេជ្ជកម្ម ទូតកម្ម ដោយដុំបាយតប ដុំបាយ ដោយការឲ្យវត្ថុដែលគេឲ្យដល់ខ្លួនវិញ នេះ លោកហៅថា បុគ្គល បរិភោគភោជនប្រកបដោយទោស ។

ចុះបុគ្គលបរិភោគភោជន មិនមានទោស តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ បាន ចួប ប្រទះ ពើបពះ ប្រសព្វ ដោយធម៌ដ៏ពបទាប ហើយចិញ្ចឹមជីវិត គឺ មិនមែនដោយការបំភាន់ មិនមែនដោយការរួសរ៉ាវ មិនមែនដោយការបញ្ឆិតបញ្ឆៀង មិនមែនដោយកលល្បិច មិនមែនដោយការស្វែងលាភដោយលាភ មិនមែនដោយការឲ្យឈើ មិនមែន ដោយការឲ្យឫស្សី មិនមែនដោយការឲ្យស្លឹកឈើ មិនមែនដោយការឲ្យផ្កាឈើ មិនមែន ដោយការឲ្យគ្រឿងសម្រាប់ងូត មិនមែនដោយការឲ្យលំអិត មិនមែនដោយការឲ្យដីស្អិត មិនមែនដោយការឲ្យឈើស្ទន់ មិនមែន ដោយការឲ្យទឹកសម្រាប់លប់មុខ មិនមែនដោយការបន្ទន់បន្ទាបខ្លួនចំពោះត្រកូល មិនមែន ដោយសំដីដូចសំឡសណ្តែកបាយ មិនមែនដោយការបី-ពបញ្ជិះសេះកូនត្រកូល មិនមែនដោយការស៊ីសាច់ខ្នងគេ មិនមែនដោយវត្ថុវិជ្ជា មិនមែនដោយតិរច្ឆានវិជ្ជា មិនមែនដោយអង្គវិជ្ជា មិនមែនដោយនក្ខត្តវិជ្ជា មិនមែនដោយទូតេយ្យ-កម្មហើយទៅ មិនមែនដោយកិរិយាទៅកាន់ទីដែលគេបញ្ជូនទៅ មិនមែនដោយការបម្រើគេដោយស្មង មិនមែនដោយវេជ្ជកម្ម មិនមែនដោយទូតកម្ម

បិណ្ឌប្បដិបិណ្ឌកេន ន ទានានុប្បទានេន ធម្មេន សមេន លទ្ធា លភិត្វា បដិលភិត្វា អធិគន្ត្វា វិន្ទិត្វា ជីវិកំ កប្បេតិ អយំ វុច្ចតិ បុគ្គលោ អនវជ្ជភោជី ។

ឯតេ អលទ្ធា អនវជ្ជភោជីតិ ឯតេ អលទ្ធា អលភិត្វា អប្បដិលភិត្វា អនធិគន្ត្វា អវិន្ទិត្វាតិ ឯតេ អលទ្ធា អនវជ្ជភោជី ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

អទ្ធា បសំសាម សហាយសម្បទំ
សេដ្ឋា សមា សេវិតព្វា សហាយា
ឯតេ អលទ្ធា អនវជ្ជភោជី
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

(២៨២) ទិស្វា សុវណ្ណស្ស បភស្សរានិ
កម្មារបុត្តេន សុនិដ្ឋិតានិ
សង្ឃដ្ដយន្តានិ ទុវេ ភុជស្មឹ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

វគ្គវិសាណសុត្តនិទ្ទេស

មិនមែនដោយដុំបាយតបដុំបាយ មិនមែនដោយការឲ្យនូវវត្ថុដែលគេឲ្យដល់ខ្លួនវិញ នេះលោកហៅថា បុគ្គលបរិភោគភោជនមិនមានទោស ។

ពាក្យថា បើរកមិនបានសំឡាញ់ទាំងនុ៎ះទេ គប្បីជាអ្នកបរិភោគភោជនមិនមានទោស គឺ មិនបាន មិនជួប មិនប្រទះ មិនពើបពះ មិនប្រសព្វនូវសំឡាញ់នុ៎ះ ហេតុនោះ (លោកពោលថា) បើរកមិនបានសំឡាញ់ទាំងនុ៎ះទេ គប្បីជាអ្នកបរិភោគភោជនមិនមានទោស ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

តាមពិត យើងសរសើរ នូវការបរិបូណ៌ដោយសំឡាញ់
ហើយ តែបុគ្គលគួរគប់រកសំឡាញ់មានគុណប្រសើរ
ជាងខ្លួន នឹងសំឡាញ់មានគុណស្មើនឹងខ្លួន បើរកមិន
បានសំឡាញ់ទាំងនុ៎ះទេ គប្បីជាអ្នកបរិភោគភោជនមិន
មានទោស ហើយប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(២៨២) បុគ្គលឃើញកងមាសទាំងពីរ ដ៏ភ្លឺផ្លេកៗ ដែល
កម្មារបុត្ត ធ្វើសម្រេចល្អហើយ ទង្គិចគ្នា ឰដ៏ដៃ គប្បី
ប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(២៨៣) ទិស្វា សុវណ្ណស្ស បភស្សរានីតិ ទិស្វា បស្សិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា ។ សុវណ្ណស្សាតិ ជាតរូបស្ស ។ បភស្សរានីតិ បរិសុទ្ធានិ បរិយោទាតានីតិ ទិស្វា សុវណ្ណស្ស បភស្សរានិ ។

(២៨៤) កម្មារបុត្តេន សុនិដ្ឋិតានីតិ កម្មារបុត្តោ វុច្ចតិ សុវណ្ណការោ ។ កម្មារបុត្តេន សុនិដ្ឋិតានីតិ កម្មារបុត្តេន សុនិដ្ឋិតានិ សុកតានិ សុបរិកម្មានីតិ កម្មារបុត្តេន សុនិដ្ឋិតានិ ។

(២៨៥) សង្ឃដ្ដយន្តានិ ទុវេ ភុជស្មិន្តិ ភុជោ វុច្ចតិ ហត្ថោ ។ យថា ឯកស្មឹ ហត្ថេ ទ្វេ នុវរានិ ឃដេន្តិ ឯវមេវ សត្តា តណ្ហាវសេន ឃដេន្តិ តិរច្ឆានយោនិយំ ឃដេន្តិ បេត្តិវិសយេ ឃដេន្តិ មនុស្សលោកេ ឃដេន្តិ ទេវលោកេ ឃដេន្តិ គតិយា គតឹ ឧបបត្តិយា ឧបបត្តឹ បដិសន្ធិយា បដិសន្ធឹ ភវេន ភវំ សំសារេន សំសារំ វដ្ដេន វដ្ដំ

(២៨៣) ពាក្យថា ឃើញកនមាស ដ៏ភ្លឺផ្លេក ៗ គឺ ឃើញ មើល សម្លឹង ត្រួត បញ្ចាក់ ធ្វើឲ្យច្បាស់ ។ ពាក្យថា មាស គឺ ជាតរូប ។ ពាក្យថា ភ្លឺផ្លេក ៗ គឺស្អាត ផូរផង់ ហេតុនោះ (លោកពោលថា) ឃើញ កនមាស ដ៏ភ្លឺផ្លេក ៗ ។

(២៨៤) ពាក្យថា ដែលកម្មារបុត្តធ្វើសម្រេចល្អហើយ សេចក្តីថា ជាងមាស លោកហៅថា កម្មារបុត្ត ។ ពាក្យថា ដែលកម្មារបុត្ត ធ្វើសម្រេចល្អហើយ បានសេចក្តីថា ដែលកម្មារបុត្តឲ្យសម្រេចល្អហើយ ធ្វើល្អហើយ មានការសម្រិតសម្រាំងល្អហើយ ហេតុនោះ (លោកពោល ថា) ដែលកម្មារបុត្តធ្វើសម្រេចល្អហើយ ។

(២៨៥) ពាក្យថា កនមាសទាំងពីរ ដែលទង្គិចគ្នា ឰដ៏ដៃ អធិប្បាយ ថា ហត្ថ លោកហៅថា ដៃ ។ កនមាសទាំងពីរ ឰដ៏ដៃមួយ ទង្គិចគ្នា យ៉ាងណា ពួកសត្វតែងទង្គិច ដោយអំណាចតណ្ហា គឺទង្គិចក្នុងកំណើត តិរច្ឆាន ទង្គិចក្នុងបិត្តិវិស័យ ទង្គិចក្នុងមនុស្សលោក ទង្គិចក្នុងទេវលោក គឺថា ទង្គិច ត្រាច់ នៅ ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ កាន់ គតិ ដោយគតិ កាន់ឧបបត្តិ ដោយឧបបត្តិ កាន់បដិសន្ធិ ដោយបដិសន្ធិ កាន់ភព ដោយភព កាន់សង្សារ ដោយសង្សារ កាន់វដ្ដៈ ដោយវដ្ដៈ

ឃដេន្តិ ចរន្តិ វិហរន្តិ ឥរិយន្តិ វត្តេន្តិ បាលេន្តិ យបេន្តិ យាបេន្តីតិ សង្ឃដ្ដយន្តានិ ទុវេ ភុជស្មឹ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

និស្សាយ សុវណ្ណស្ស បភស្សរានិ
កម្មារបុត្តេន សុនិដ្ឋិតានិ
សង្ឃដ្ដយន្តានិ ទុវេ ភុជស្មឹ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

(២៨៦) ឯវំ ទុតិយេន សហា មមស្ស
វាចាភិលាបោ អភិសជ្ជនា វា
ឯតំ ភយំ អាយតិំ បេក្ខមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

(២៨៧) ឯវំ ទុតិយេន សហា មមស្សាតិ តណ្ហាទុតិយេន ។ តណ្ហាទុតិយោ វា ហោតិ បុគ្គលទុតិយោ វា ។ កថំ តណ្ហាទុតិយោ ហោតិ ។ តណ្ហាតិ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ យស្សេសា តណ្ហា អប្បហីនា សោ វុច្ចតិ តណ្ហាទុតិយោ ។

ហេតុនោះ (លោកពោលថា) កងមាសទាំងពីរ ដែលទង្គិចគ្នា ឮដំដៃ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

បុគ្គលឃើញ កងមាសទាំងពីរ ដ៏ភ្លឺផ្លេកៗ ដែល
កម្មារបុត្ត ធ្វើសម្រេចល្អហើយ ទង្គិចគ្នា ឮដំដៃ
គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(២៨៦) ការរួសរាយ ដោយវាចាក្តី ការជាប់ចំពាក់ក្តី
ជាមួយនឹងបុគ្គលជាគម្រប់ពីរ របស់អញ យ៉ាងនេះ
បុគ្គលកាលសំឡឹងឃើញភ័យនុ៎ះ ក្នុងអនាគត គប្បី
ប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(២៨៧) អធិប្បាយពាក្យថា ជាមួយនឹងបុគ្គលជាគម្រប់ពីរ របស់អញ យ៉ាងនេះ គឺ បុគ្គល មានតណ្ហាជាគម្រប់ពីរ ។ បុគ្គលមានតណ្ហាជាគម្រប់ពីរក៏មាន មានបុគ្គលជាគម្រប់ពីរក៏មាន ។ បុគ្គលមានតណ្ហាជាគម្រប់ពីរ តើដូចម្តេច ។ ពាក្យថា តណ្ហា បានដល់រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ បុគ្គលណាមិនបានលះបង់តណ្ហានេះ បុគ្គលនោះ លោកហៅថា មានតណ្ហាជាគម្រប់ពីរ ។

តណ្ហាទុតិយោ បុរិសោ ទីឃមទ្ធាន សំសរំ

ឥត្ថភាវញ្ញថាភាវំ សំសារំ នាតិវត្តតិ(១) ។

ឯវំ តណ្ហាទុតិយោ ហោតិ ។ កថំ បុគ្គលទុតិយោ ហោតិ ។ ឥធេកច្ចោ ន អត្តហេតុ ន ការណាហេតុ ឧទ្ធតោ អវូបសន្តចិត្តោ ឯកស្ស វា ទុតិយោ ហោតិ ទ្វិន្នំ វា តតិយោ ហោតិ តិណ្ណំ វា ចតុត្ថោ ហោតិ តត្ថ ពហុំ សម្ផប្បលាបំ លបតិ សេយ្យថីទំ រាជកថំ ចោរកថំ មហាមត្តកថំ សេនាកថំ ភយកថំ យុទ្ធកថំ អន្នកថំ បានកថំ វត្ថកថំ មាលាកថំ ញាតិកថំ យានកថំ គាមកថំ និគមកថំ នគរកថំ ជនបទកថំ ឥត្ថីកថំ បុរិសកថំ សូរកថំ វិសិខាកថំ កុម្ភដ្ឋានកថំ លោកក្ខាយិកំ សមុទ្ទក្ខាយិកំ ឥតិភវាភវកថំ ឥតិ វា កថេតិ ឯវំ បុគ្គលទុតិយោ ហោតីតិ ឯវំ ទុតិយេន សហា មមស្ស ។

---

១ ម. នាតិវត្តតីតិ ។

បុរស មានតណ្ហាជាគម្រប់ពីរ តែងអន្ទោលទៅអស់
កាលយូរ មិនប្រព្រឹត្តកន្លង នូវសង្សារដែលមានភាព
នេះនឹងភាពដទៃបានទេ ។

បុគ្គលមានតណ្ហាជាគម្រប់ពីរ យ៉ាងនេះឯង ។ បុគ្គលមានបុគ្គលគម្រប់ពីរ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ពាយមាយ មានចិត្តមិនស្ងប់រំងាប់ មិនមែនព្រោះហេតុខ្លួន មិនមែនព្រោះហេតុដំណើរទេ ជាគម្រប់ពីរនឹងបុគ្គលមួយនាក់ក៏មាន ជាគម្រប់បី នឹងបុគ្គលពីរនាក់ក៏មាន ជាគម្រប់បួន នឹងបុគ្គលបីនាក់ក៏មាន និយាយសម្ផប្បលាបៈ ច្រើនក្នុងទីនោះ គឺ និយាយរាជកថា ចោរកថា មហាមត្តកថា សេនាកថា ភយកថា យុទ្ធកថា អន្នកថា បានកថា វត្ថកថា មាលាកថា ញាតិកថា យានកថា គាមកថា និគមកថា នគរកថា ជនបទកថា ឥត្ថីកថា បុរិសកថា សូរកថា វិសិខាកថា កុម្ភដ្ឋានកថា លោកក្ខាយិកកថា សមុទ្ទក្ខាយិកកថា ឥតិភវាភវកថា ដូច្នេះៗ ខ្លះ បុគ្គល មានបុគ្គលជាគម្រប់ពីរ យ៉ាងនេះឯង ហេតុនោះ (លោកពោលថា) ជាមួយនឹងបុគ្គលជាគម្រប់ពីរ របស់អញ យ៉ាងនេះ ។

## ខគ្គវិសាណសុត្តនិទ្ទេសោ

(២៨៨) វាចាភិលាបោ អភិសជ្ជនា វាតិ វាចាភិលាបោ វុច្ចតិ ពាត្តឹស តិរច្ឆានកថា សេយ្យថីទំ រាជកថា ចោរកថា ។ បេ ។ ឥតិភវាភវកថា ឥតិ វា ។ អភិសជ្ជនាតិ ទ្វេ សជ្ជនា តណ្ហាសជ្ជនា ច ទិដ្ឋិសជ្ជនា ច ។ បេ ។ អយំ តណ្ហាសជ្ជនា ។ បេ ។ អយំ ទិដ្ឋិសជ្ជនាតិ វាចាភិលាបោ អភិសជ្ជនា វា ។

(២៨៩) ឯតំ ភយំ អាយតឹ បេក្ខមានោតិ ភយន្តិ ជាតិភយំ ជរាភយំ ព្យាធិភយំ មរណភយំ រាជភយំ ចោរភយំ អគ្គិភយំ ឧទកភយំ អត្តានុវាទភយំ បរានុវាទភយំ ទណ្ឌភយំ ទុគ្គតិភយំ ឩមិភយំ កុម្ភីលភយំ អាវដ្ដភយំ សុំសុការភយំ(១) អាជីវិកាភយំ អសិលោកភយំ បរិសសារជ្ជភយំ(២) ភយានកំ ឆម្ភិតត្តំ លោមហំសោ ចេតសោ ឧព្វេគោ ឧត្រាសោ ។ ឯតំ ភយំ អាយតឹ បេក្ខមានោតិ

---

១ ម. សុសុមារភយំ ។ ២ ម. បរិសារជ្ជភយំ មទនភយំ ។

## ខគ្គវិសាណសុត្តនិទ្ទេស

(២៨៨) ពាក្យថា ការប្រសព្វដោយវាចាក្តី ការជាប់ចំពាក់ក្តី អធិប្បាយថា ការប្រសព្វដោយវាចា លោកសំដៅយកតិរច្ឆានកថា ៣២ គឺ រាជកថា ចោរកថា ។ បេ ។ ឥតិភវាភវកថា ដូច្នេះៗ ខ្លះ ។ ពាក្យថា ការជាប់ចំពាក់ បានដល់ការជាប់ចំពាក់ ២ គឺ ការជាប់ចំពាក់គឺតណ្ហា ១ ការជាប់ចំពាក់គឺទិដ្ឋិ ១ ។ បេ ។ នេះ ការជាប់ចំពាក់គឺតណ្ហា ។ បេ ។ នេះ ការជាប់ចំពាក់គឺទិដ្ឋិ ហេតុនោះ (លោកពោលថា) ការប្រសព្វដោយវាចាក្តី ការជាប់ចំពាក់ក្តី ។

(២៨៩) អធិប្បាយពាក្យថា បុគ្គលកាលសំឡឹងឃើញភ័យនុ៎ះ ក្នុងអនាគត ត្រង់ពាក្យថា ភ័យ បានដល់ភ័យអំពីជាតិ ភ័យអំពីជរា ភ័យអំពីព្យាធិ ភ័យអំពីមរណៈ ភ័យអំពីព្រះរាជា ភ័យអំពីចោរ ភ័យអំពីភ្លើង ភ័យអំពីទឹក ភ័យអំពីការតិះដៀលរបស់ខ្លួន ភ័យអំពីការតិះដៀលរបស់បុគ្គលដទៃ ភ័យអំពីអាជ្ញា ភ័យអំពីទុគ្គតិ ភ័យអំពីរលក ភ័យអំពីក្រពើ ភ័យអំពីកន្ទ្រង់ទឹកវិល ភ័យអំពីឆ្លាម ភ័យអំពីការចិញ្ចឹមជីវិត ភ័យអំពីដំណៀល ភ័យអំពីការញញើតបរិស័ទ អារម្មណ៍គួរស្បើម សេចក្តីរន្ធត់ សេចក្តីព្រឺរោម សេចក្តីតក់ស្លុតចិត្ត សេចក្តីស្រឡាំងកាំងចិត្ត ។ ពាក្យថា បុគ្គលកាលសំឡឹងឃើញភ័យនុ៎ះ ក្នុងអនាគត

ឯតំ ភយំ អាយតឹ បេក្ខមានោ ទក្ខមានោ ឱ-
លោកយមានោ និជ្ឈាយមានោ ឧបបរិក្ខមានោតិ
ឯតំ ភយំ អាយតឹ បេក្ខមានោ ។ ឯកោ ចរេ
ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកស-
ម្ពុទ្ធោ

ឯវំ ទុតីយេន សហា មមស្ស
វាចាភិលាបោ អភិសជ្ជនា វា
ឯតំ ភយំ អាយតឹ បេក្ខមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

(២៩០) កាមា ហិ ចិត្រា មធុរា មនោរមា
វិរូបរូបេន មថេន្តិ ចិត្តំ
អាទីនវំ កាមគុណេសុ ទិស្វា
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

(២៩១) កាមា ហិ ចិត្រា មធុរា មនោរមាតិ
កាមាតិ ឧទ្ទានតោ ទ្វេ កាមា វត្ថុកាមា ច កិលេ-
សកាមា ច ។បេ។ ឥមេ វុច្ចន្តិ វត្ថុកាមា ។បេ។

សេចក្តីថា បុគ្គលកាលសំឡឹងឃើញ មើល រមិលមើល ពិនិត្យ ផ្ចង់នូវភ័យទុក្ខក្នុងអនាគត ហេតុនោះ (លោកពោលថា) បុគ្គលកាលសំឡឹងឃើញភ័យទុក្ខ ក្នុងអនាគត ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

ការរួសរាយ ដោយភាពក្តី ការជាប់ចំពាក់ក្តី ជាមួយនឹងបុគ្គលជាគម្រប់ពីរ របស់អញ យ៉ាងនេះ បុគ្គលកាលសំឡឹងឃើញភ័យទុក្ខ ក្នុងអនាគត គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[២៩០] ពិតណាស់ កាមទាំងឡាយដ៏វិចិត្រ មានរសឆ្ងាញ់ ជាទីត្រេកអរនៃចិត្ត តែងញាំញីចិត្ត ដោយសភាពនៃរូបផ្សេង ៗ បុគ្គលឃើញទោស ក្នុងកាមគុណទាំងឡាយហើយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

[២៩១] អធិប្បាយពាក្យថា ពិតណាស់ កាមទាំងឡាយដ៏វិចិត្រ មានរសឆ្ងាញ់ ជាទីត្រេកអរនៃចិត្ត ត្រង់ពាក្យថា កាម តាមឧទ្ទាន កាមមាន ២ គឺ វត្ថុកាម ១ កិលេសកាម ១ ។ បេ ។ ទាំងនេះហៅថា វត្ថុកាម

ឥមេ វុច្ចន្តិ កិលេសកាមា ។ ចិត្រាតិ នានា
វណ្ណា រូបា នានាវណ្ណា សទ្ទា នានាវណ្ណា គន្ធា នានា-
វណ្ណា រសា នានាវណ្ណា ផោដ្ឋព្វា ។ មធុរាតិ វុត្តញ្ហេតំ
ភគវតា បញ្ចិមេ ភិក្ខវេ កាមគុណា កតមេ
បញ្ច ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា
បិយរូបា កាមូបសញ្ហិតា រជនីយា សោតវិញ្ញេយ្យា
សទ្ទា ឃានវិញ្ញេយ្យា គន្ធា ជិវ្ហាវិញ្ញេយ្យា រសា
កាយវិញ្ញេយ្យា ផោដ្ឋព្វា ឥដ្ឋា កន្តា មនាបា
បិយរូបា កាមូបសញ្ហិតា រជនីយា ឥមេ ខោ ភិក្ខវេ
បញ្ច កាមគុណា យំ ខោ ភិក្ខវេ ឥមេ បញ្ច
កាមគុណេ បដិច្ច ឧប្បជ្ជតិ សុខំ សោមន-
ស្សំ ឥទំ វុច្ចតិ កាមសុខំ មិឡ្ហសុខំ បុថុជ្ជន-
សុខំ អនរិយសុខំ ន សេវិតព្វំ ន ភាវេតព្វំ ន
ពហុលីកាតព្វំ ភាយិតព្វំ ឯតស្ស
សុខស្សាតិ វទាមីតិ កាមា ហិ ចិត្រា មធុរា ។

ៗ បេ ៗ ទាំងនេះហៅថា កិលេសកាម ។ ពាក្យថា ដ៏វិចិត្រ គឺរូបមានបែបផ្សេងៗ សំឡេងមានបែបផ្សេងៗ ក្លិនមានបែបផ្សេងៗ រសមានបែបផ្សេងៗ ផោដ្ឋព្វៈមានបែបផ្សេងៗ ។ ពាក្យថា មានរសឆ្ងាញ់ សេចក្តីថា មែនពិត ព្រះមានព្រះភាគបានត្រាស់ព្រះតម្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ កាមគុណនេះ មាន ៥ កាមគុណ ៥ គឺអ្វីខ្លះ គឺ រូបដែលត្រូវដឹងដោយចក្ខុ ជាទីប្រាថ្នា ជាទីស្រឡាញ់ ជាទីគាប់ចិត្ត មានភាពជាទីស្រឡាញ់ ប្រកបដោយកាម គួរឲ្យត្រេកត្រអាល ១ សំឡេងដែលត្រូវដឹងដោយសោតៈ ១ ក្លិនដែលត្រូវដឹងដោយឃានៈ ១ រសដែលត្រូវដឹងដោយជិវ្ហា ១ ផោដ្ឋព្វៈ ដែលត្រូវដឹងដោយកាយ ជាទីប្រាថ្នា ជាទីស្រឡាញ់ ជាទីគាប់ចិត្ត មានភាពជាទីស្រឡាញ់ ប្រកបដោយកាម គួរឲ្យត្រេកត្រអាល ១ ម្នាលភិក្ខុទាំងឡាយ នេះឯង កាមគុណ ៥ ម្នាលភិក្ខុទាំងឡាយ សុខ សោមនស្សណា កើតឡើងព្រោះអាស្រ័យកាមគុណ ៥ នេះ សុខ សោមនស្សនេះ តថាគតហៅថា សុខក្នុងកាម សុខដូចលាមក សុខរបស់បុថុជ្ជន សុខមិនប្រសើរ តថាគតពោលថា បុគ្គលមិនគួរសេព មិនគួរគប់ មិនគួរបម្រើន មិនគួរធ្វើឲ្យរឿយ ៗ បុគ្គលគួរខ្លាចសុខនុ៎ះ ហេតុនោះ (លោកពោលថា) ពិតណាស់ កាមទាំងឡាយ ដ៏វិចិត្រ មានរសឆ្ងាញ់ ៗ

មនោរមាតិ មនោតិ យំ ចិត្តំ មនោ មានសំ ហទយំ បណ្ឌរំ មនោ មនាយតនំ មនិន្ទ្រិយំ វិញ្ញាណំ វិញ្ញាណក្ខន្ធោ តជ្ជា មនោវិញ្ញាណធាតុ ។

(២៩២) វិរូបរូបេន មថេន្តិ ចិត្តន្តិ នានាវណ្ណេហិ រូបេហិ ។បេ។ នានាវណ្ណេហិ ផោដ្ឋព្វេហិ ចិត្តំ មថេន្តិ តាសេន្តិ(១) ហាបេន្តិ បហាបេន្តីតិ វិរូបរូបេន មថេន្តិ ចិត្តំ ។

(២៩៣) អាទីនវំ កាមគុណេសុ ទិស្វាតិ វុត្តំ ហេតំ ភគវតា កោ ច ភិក្ខវេ កាមានំ អាទីនវោ ឥធ ភិក្ខវេ កុលបុត្តោ យេន សិប្បដ្ឋានេន ជីវិកំ កប្បេតិ យទិ មុទ្ទាយ យទិ គណនាយ យទិ សង្ខាយ យទិ កសិយា យទិ វណិជ្ជាយ យទិ គោរក្ខេន យទិ ឥស្សត្ថេន យទិ រាជបោរិសេន យទិ សិប្បាយតនេន សីតស្ស បុរក្ខតោ ឧណ្ហស្ស បុរក្ខតោ ឌំសមកសវាតាតបសិរឹសបសម្ផស្សេហិ រិស្សមានោ ខុប្បិបាសាយ មិយ្យមានោ(២)

១ ម. តោសេន្តិ ។ ២ ម. បិឡ្យមានោ ។

ពាក្យថា ជាទីត្រេកអរនៃចិត្ត ត្រង់ពាក្យថា ចិត្ត បានដល់ ចិត្ត មនៈ មានសៈ ហទយៈ បណ្ឌរៈ មនៈ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណក្ខន្ធនោះ ។

(២៩២) ពាក្យថា តែងញាំញីចិត្ត ដោយសភាពនៃរូបផ្សេងៗ គឺ តែងញាំញី ញាំងចិត្តឲ្យតក់ស្លុត ឲ្យសាបសូន្យ ឲ្យសាបរលាបដោយរូបទាំងឡាយ មានបែបផ្សេងៗ ។ បេ ។ ដោយផោដ្ឋព្វៈទាំងឡាយ មានបែបផ្សេងៗ ហេតុនោះ (លោកពោលថា) តែងញាំញីចិត្ត ដោយសភាពនៃរូបផ្សេងៗ ។

(២៩៣) ពាក្យថា បុគ្គលឃើញទោស ក្នុងកាមគុណទាំងឡាយ អធិប្បាយថា មែនពិត ព្រះមានព្រះភាគ បានត្រាស់ព្រះតម្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ ទោសរបស់កាមទាំងឡាយ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ កុលបុត្រក្នុងលោកនេះ ចិញ្ចឹមជីវិត ដោយថ្នាក់នៃសិប្បៈណា គឺ ការរាប់ដោយដៃទទេក្តី ការរាប់មិនដាច់ក្តី ការរាប់បូកក្តី ការភ្ជួររាស់ក្តី ជំនួញក្តី ការរក្សាគោក្តី ការកាន់អាវុធបម្រើក្តី ភាពជារាជបុរសក្តី សិប្បៈ មានហត្ថសិប្បៈជាដើមក្តី ជាអ្នកត្រូវត្រជាក់បៀតបៀន ត្រូវកម្តៅបៀតបៀន ប៉ះ ទង្គិច ទង្គក ដោយសម្ផស្ស នៃរបោម មូស ខ្យល់ កម្តៅថ្ងៃ និងសត្វលូន ស្លាប់ដោយគម្លាននឹងសម្រេក

## ខគ្គវិសាណសុត្តនិទ្ទេសោ

អយំ ភិក្ខវេ កាមានំ អាទីនវោ សន្ទិដ្ឋិកោ ទុក្ខ-
ក្ខន្ធោ កាមហេតុ កាមនិទានំ កាមាធិករណំ
កាមានមេវ ហេតុ តស្ស ចេ ភិក្ខវេ កុលបុត្តស្ស
ឯវំ ឧដ្ឋហតោ ឃដតោ វាយមតោ តេ ភោគា នា-
ភិនិប្ផជ្ជន្តិ សោ សោចតិ កិលមតិ បរិទេវតិ ឧរត្តា-
ឡឹ កន្ទតិ សម្មោហំ អាបជ្ជតិ មោឃំ វត មេ ឧ-
ដ្ឋានំ អផលោ វត មេ វាយាមោតិ អយម្បិ ភិក្ខវេ
កាមានំ អាទីនវោ សន្ទិដ្ឋិកោ ទុក្ខក្ខន្ធោ កាម-
ហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ
ហេតុ តស្ស ចេ ភិក្ខវេ កុលបុត្តស្ស ឯវំ ឧដ្ឋហ-
តោ ឃដតោ វាយមតោ តេ ភោគា អភិនិប្ផជ្ជន្តិ
សោ តេសំ ភោគានំ អារក្ខាធិករណំ ទុក្ខំ ទោមន-
ស្សំ បដិសំវេទេតិ កិន្តិ មេ ភោគេ នេវ រាជានោ
ហរេយ្យុំ ន ចោរា ហរេយ្យុំ ន អគ្គិ ឌហេយ្យ ន
ឧទកំ វហេយ្យ ន អប្បិយា ទាយាទា ហរេយ្យុន្តិ

ខគ្គវិសាណសុត្តនិទ្ទេស

ម្នាលភិក្ខុទាំងឡាយ នេះទោសរបស់កាមទាំងឡាយ ដែលគេត្រូវឃើញផ្ទាល់ខ្លួន ជាកងទុក្ខ (កើតឡើង) ព្រោះកាមជាហេតុ ព្រោះកាមជាដើមចម ព្រោះកាមជាដើមទង ព្រោះហេតុនៃកាមទាំងឡាយតែម្យ៉ាង ម្នាលភិក្ខុទាំងឡាយ បើកាលកុលបុត្រនោះ ខំខ្នះ ប្រឹងប្រែង ព្យាយាមយ៉ាងម្ល៉េះហើយ ភោគៈទាំងនោះ មិនសម្រេចទេ កុលបុត្រនោះ តែងក្រៀមក្រំ លំបាក ខ្សឹកខ្សួល កន្ទក់កន្ទេញ គក់ទ្រូង ដល់នូវសេចក្តីវង្វេងថា ការប្រឹងប្រែងរបស់អញ ឥតអំពើហើយតើ សេចក្តីព្យាយាមរបស់អញ មិនមានផលហើយតើ ម្នាលភិក្ខុទាំងឡាយ នេះទោសរបស់កាមទាំងឡាយ ដែលគេត្រូវឃើញផ្ទាល់ខ្លួន ជាកងទុក្ខ (កើតឡើង) ព្រោះកាមជាហេតុ ព្រោះកាមជាដើមចម ព្រោះកាមជាដើមទង ព្រោះហេតុនៃកាមទាំងឡាយតែម្យ៉ាង ម្នាលភិក្ខុទាំងឡាយ បើកាលកុលបុត្រនោះ ខំខ្នះ ប្រឹងប្រែង ព្យាយាមយ៉ាងម្ល៉េះហើយ ភោគៈទាងនោះ សម្រេច កុលបុត្រនោះ ក៏គង់រងទុក្ខនឹងទោមនស្ស ដែលមានការហួងហែងភោគៈទាំងនោះជាហេតុថា ធ្វើដូចម្តេច កុំឲ្យព្រះរាជានាំយកទៅបាន កុំឲ្យចោរនាំយកទៅបាន កុំឲ្យភ្លើងឆេះ កុំឲ្យទឹកនាំយកទៅបាន កុំឲ្យពួកជនជាទាយាទមិនជាទីស្រឡាញ់នាំយកទៅបាន នូវភោគៈទាំងឡាយរបស់អញ

តស្ស ឯវំ អារក្ខតោ គោបយតោ តេ ភោគេ
រាជានោ វា ហរន្តិ ចោរា វា ហរន្តិ អគ្គិ វា
ឌហតិ ឧទកំ វា វហតិ អប្បិយា ទាយាទា វា
ហរន្តិ សោ សោចតិ ។បេ។ សម្មោហំ អាប-
ជ្ជតិ យម្បិ មេ អហោសិ តម្បិ មេ នត្ថីតិ
អយម្បិ ភិក្ខវេ កាមានំ អាទីនវោ សន្ទិដ្ឋិកោ
ទុក្ខក្ខន្ធោ កាមហេតុ កាមនិទានំ កាមាធិករ-
ណំ កាមានមេវ ហេតុ ។ បុន ចបរំ ភិក្ខវេ
កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ
ហេតុ រាជានោបិ រាជូហិ វិវទន្តិ ខត្តិយាបិ ខត្តិយេ-
ហិ វិវទន្តិ ព្រាហ្មណាបិ ព្រាហ្មណេហិ វិវទន្តិ គហ-
បតីបិ គហបតីហិ វិវទន្តិ មាតាបិ បុត្តេន វិវទតិ
បុត្តោបិ មាតរា វិវទតិ បិតាបិ បុត្តេន វិវទតិ បុត្តោ-
បិ បិតរា វិវទតិ ភាតាបិ ភគិនិយា វិវទតិ ភគិនីបិ
ភាតរា វិវទតិ សហាយោបិ សហាយេន វិវទតិ តេ
តត្ថ កលហវិវាទាបន្នា អញ្ញមញ្ញំ បាណីហិបិ ឧប-
ក្កមន្តិ លេឌ្ឌូហិបិ ឧបក្កមន្តិ ទណ្ឌេហិបិ ឧបក្កមន្តិ

កាលបើកុលបុត្រនោះ ហួងហែង គ្រប់គ្រង យ៉ាងម៉្លេះហើយ ព្រះរាជាទាំងឡាយនាំយកទៅក្តី ចោរទាំងឡាយនាំយកទៅក្តី ភ្លើងឆេះក្តី ទឹកនាំទៅក្តី ពួកជនជាទាយាទមិនជាទីស្រឡាញ់នាំយកទៅក្តី នូវភោគៈទាំងឡាយនោះ កុលបុត្រនោះ តែងក្រៀមក្រំ ។ បេ ។ ដល់នូវសេចក្តីងើងង៉ោងថា ទ្រព្យណា របស់អញមានហើយ អញមិនមានទ្រព្យនោះវិញ ម្នាលភិក្ខុទាំងឡាយ នេះទោសរបស់កាមទាំងឡាយ ដែលគេត្រូវឃើញផ្ទាល់ខ្លួន ជាកងទុក្ខ (កើតឡើង) ព្រោះកាមជាហេតុ ព្រោះកាមជាដើមចម ព្រោះកាមជាដើមទង ព្រោះហេតុនៃកាមទាំងឡាយតែម្យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រោះកាមជាហេតុ ព្រោះកាមជាដើមចម ព្រោះកាមជាដើមទង ព្រោះហេតុនៃកាមទាំងឡាយតែម្យ៉ាង ពួកព្រះរាជាក៏វិវាទដោយពួកព្រះរាជា ពួកក្សត្រិយ៍ក៏វិវាទដោយពួកក្សត្រិយ៍ ពួកព្រាហ្មណ៍ក៏វិវាទដោយពួកព្រាហ្មណ៍ ពួកគហបតីក៏វិវាទដោយពួកគហបតី មាតាក៏វិវាទដោយបុត្រ បុត្រក៏វិវាទដោយមាតា បិតាក៏វិវាទដោយបុត្រ បុត្រក៏វិវាទដោយបិតា បងប្អូនប្រុសក៏វិវាទដោយបងប្អូនស្រី បងប្អូនស្រីក៏វិវាទដោយបងប្អូនប្រុស សំឡាញ់ក៏វិវាទដោយសំឡាញ់ ពួកជននោះដល់នូវជម្លោះ និងការវិវាទ ក្នុងទីនោះ ប្រហារគ្នាដោយដៃខ្លះ

ខគ្គវិសាណសុត្តនិទ្ទេសោ

សត្ថេហិបិ ឧបក្កមន្តិ តេ តត្ថ មរណម្បិ និគច្ឆន្តិ[១] មរណមត្តម្បិ ទុក្ខំ អយម្បិ ភិក្ខវេ កាមានំ អាទីនវោ សន្ទិដ្ឋិកោ ទុក្ខក្ខន្ធោ កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ ហេតុ ។ បុន ចបរំ ភិក្ខវេ កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ ហេតុ អសិចម្មំ គហេត្វា ធនុកលាបំ សន្នយ្ហិត្វា ឧភតោវិយូឡ្ហំ[២] សង្គាមំ បក្ខន្ទន្តិ ឧសូសុបិ ខិប្បមានេសុ សត្តីសុបិ ខិប្បមានាសុ អសីសុបិ វិជ្ជោតលន្តេសុ[៣] តេ តត្ថ ឧសូហិបិ វិជ្ឈន្តិ សត្តីហិបិ វិជ្ឈន្តិ អសិនាបិ សីសំ ឆិន្ទន្តិ តេ តត្ថ មរណម្បិ និគច្ឆន្តិ មរណមត្តម្បិ ទុក្ខំ អយម្បិ ភិក្ខវេ កាមានំ អាទីនវោ សន្ទិដ្ឋិកោ ទុក្ខក្ខន្ធោ កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ ហេតុ ។

---

១ ម. គច្ឆន្តិ ។ ២ ម. ឧភតោវិយូឡ្ហំ ។ ៣ ម. វិជ្ជោតន្តេសុ ។

ប្រហារគ្នាដោយដុំដីខ្លះ ប្រហារគ្នាដោយដំបងខ្លះ ប្រហារគ្នាដោយសស្ត្រាខ្លះ ពួកជននោះ ដល់នូវសេចក្តីស្លាប់ខ្លះ ដល់នូវទុក្ខស្មើស្លាប់ខ្លះ ព្រោះតែការប្រហារគ្នានោះ ម្នាលភិក្ខុទាំងឡាយ នេះទោសរបស់កាមទាំងឡាយ ដែលគេត្រូវឃើញផ្ទាល់ខ្លួន ជាកងទុក្ខ (កើតឡើង) ព្រោះកាមជាហេតុ ព្រោះកាមជាដើមចម ព្រោះកាមជាដើមទង ព្រោះហេតុនៃកាមទាំងឡាយតែម្យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រោះកាមជាហេតុ ព្រោះកាមជាដើមចម ព្រោះកាមជាដើមទង ព្រោះហេតុនៃកាមទាំងឡាយតែម្យ៉ាង ជនទាំងឡាយក៏កាន់ដាវនឹងខែល សៀតធ្នូនឹងបំពង់ព្រួញ ហើយរុកពនគ្គានទៅកាន់សង្គ្រាម ដែលពពាក់ពពូនទាំងសងខាង កាលបើព្រួញទាំងឡាយ ដែលគេបាញ់ទៅខ្លះ លំពែងទាំងឡាយដែលគេពួយទៅខ្លះ ដាវទាំងឡាយដែលគេគ្រវីគ្រវាត់ខ្លះ ជនទាំងនោះបាញ់ដោយព្រួញទាំងឡាយ ក្នុងសង្គ្រាមនោះខ្លះ ចាក់ដោយលំពែងទាំងឡាយខ្លះ កាត់ក្បាលដោយដាវខ្លះ ជនទាំងនោះ ដល់នូវសេចក្តីស្លាប់ខ្លះ ដល់នូវទុក្ខស្មើស្លាប់ខ្លះ ក្នុងសង្គ្រាមនោះ ម្នាលភិក្ខុទាំងឡាយ នេះទោសរបស់កាមទាំងឡាយ ដែលគេត្រូវឃើញផ្ទាល់ខ្លួន ជាកងទុក្ខ (កើតឡើង) ព្រោះកាមជាហេតុ ព្រោះកាមជាដើមចម ព្រោះកាមជាដើមទង ព្រោះហេតុនៃកាមទាំងឡាយតែម្យ៉ាង ។

បុន ចបរំ ភិក្ខវេ កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ ហេតុ អសិម្បិ គហេត្វា ធនុកលាបំ សន្នយ្ហិត្វា អទ្ធាវលេបនា ឧបការិយោ បក្ខន្ទន្តិ ឧសូសុបិ ខិប្បមានេសុ សត្តីសុបិ ខិប្បមានាសុ អសីសុបិ វិជ្ជោតលន្តេសុ តេ តត្ថ ឧសូហិបិ វិជ្ឈន្តិ សត្តិហិបិ វិជ្ឈន្តិ ឆកណដិយាបិ(១) ឱសិញ្ចន្តិ អភិវគ្គេន ឱមទ្ទន្តិ អសិនាបិ សីសំ ឆិន្ទន្តិ តេ តត្ថ មរណម្បិ និគច្ឆន្តិ មរណមត្តម្បិ ទុក្ខំ អយម្បិ ភិក្ខវេ កាមានំ អាទីនវោ សន្ទិដ្ឋិកោ ទុក្ខក្ខន្ធោ កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ ហេតុ ។ បុន ចបរំ ភិក្ខវេ កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ ហេតុ សន្ធិម្បិ ឆិន្ទន្តិ និល្លោបម្បិ ហរន្តិ ឯកាគារិកម្បិ ករោន្តិ បរិបន្ថេបិ តិដ្ឋន្តិ បរទារម្បិ គច្ឆន្តិ តមេនំ រាជានោ គហេត្វា វិវិធា កម្មករណា ការេន្តិ កសាហិបិ តាឡេន្តិ វេត្តេហិបិ តាឡេន្តិ

---

១ ម. ឆកកាឱយាបិ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រោះកាមជាហេតុ ព្រោះកាមជាដើមចម ព្រោះកាមជាដើមទង ព្រោះហេតុនៃកាមទាំងឡាយតែម្យ៉ាង ជនទាំងឡាយក៏កាន់ដាវនឹងខែល សៀតធ្នូនឹងបំពង់ព្រួញ រុករានគង្គានទៅកាន់ជើងកំ-ពែង មានបឹមដែលបូកដោយបាយអ កាលបើព្រួញទាំងឡាយដែលគេបាញ់ទៅខ្លះ លំពែងទាំងឡាយដែលគេពួយទៅខ្លះ ដាវទាំងឡាយដែលគេគ្រវីគ្រវាត់ខ្លះ ជនទាំងនោះបាញ់ដោយព្រួញទាំងឡាយ ក្នុងសង្គ្រាមនោះខ្លះ ចាក់ដោយលំពែងទាំងឡាយខ្លះ ស្រោចចុះដោយអាចម៍គោកំពុងពុះខ្លះ ប្រំដោយអាវុធមានធ្មេញ ៧ ខ្លះ កាត់ក្បាលដោយដាវខ្លះ ជនទាំងនោះដល់នូវសេចក្តីស្លាប់ខ្លះ ដល់នូវទុក្ខស្មើស្លាប់ខ្លះ ក្នុងសង្គ្រាមនោះ ម្នាលភិក្ខុទាំងឡាយ នេះទោសរបស់កាមទាំងឡាយ ដែលគេត្រូវឃើញផ្ទាល់ខ្លួន ជាកងទុក្ខ (កើតឡើង) ព្រោះកាមជាហេតុ ព្រោះកាមជាដើមចម ព្រោះកាមជាដើមទង ព្រោះហេតុនៃកាមតែម្យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រោះកាមជាហេតុ ព្រោះកាមជាដើមចម ព្រោះកាមជាដើមទង ព្រោះហេតុនៃកាមតែម្យ៉ាង ជនទាំងឡាយកាត់ទី-តផ្ទះខ្លះ ប្លន់ធំខ្លះ ធ្វើនូវការប្លន់ផ្ទះមួយខ្លះ ឈរស្កាត់ផ្លូវខ្លះ គប់រកប្រពន្ធគេខ្លះ ព្រះរាជាទាំងឡាយ ប្រើឲ្យចាប់ជននោះ ហើយឲ្យធ្វើកម្មករណ៍ផ្សេងៗ គឺឲ្យវាយដោយសែតីទាំងឡាយខ្លះ ឲ្យវាយដោយរំពាត់ផ្តៅទាំងឡាយខ្លះ

## ខគ្គវិសាណសុត្តនិទ្ទេសោ

អឌ្ឍទណ្ឌកេហិបិ តាឡេន្តិ ហត្ថម្បិ ឆិន្ទន្តិ បាទម្បិ ឆិន្ទន្តិ ។ បេ ។ អសិនាបិ សីសំ ឆិន្ទន្តិ តេ តត្ថ មរណម្បិ និគច្ឆន្តិ មរណមត្តម្បិ ទុក្ខំ អយម្បិ ភិក្ខវេ កាមានំ អាទីនវោ សន្ទិដ្ឋិកោ ទុក្ខក្ខន្ធោ កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ ហេតុ ។ បុន ចបរំ ភិក្ខវេ កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ ហេតុ កាយេន ទុច្ចរិតំ ចរន្តិ វាចាយ ទុច្ចរិតំ ចរន្តិ មនសា ទុច្ចរិតំ ចរន្តិ តេ កាយេន ទុច្ចរិតំ ចរិត្វា វាចាយ ទុច្ចរិតំ ចរិត្វា មនសា ទុច្ចរិតំ ចរិត្វា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ អយម្បិ ភិក្ខវេ កាមានំ អាទីនវោ សម្បរាយិកោ ទុក្ខក្ខន្ធោ កាមហេតុ កាមនិទានំ កាមាធិករណំ កាមានមេវ ហេតូតិ ។

## ខគ្គវិសាណសុត្តនិទ្ទេស

ឲ្យដំដោយអន្ទង់ទាំងឡាយខ្លះ ឲ្យកាត់ដៃខ្លះ ឲ្យកាត់ជើងខ្លះ ។ បេ ។ ឲ្យកាត់ក្បាលដោយដាវខ្លះ ជនទាំងនោះ ដល់នូវសេចក្តីស្លាប់ខ្លះ ដល់នូវទុក្ខស្មើរស្លាប់ខ្លះ ព្រោះតែដំណើរនោះ ម្នាលភិក្ខុទាំងឡាយ នេះទោសរបស់កាមទាំងឡាយ ដែលគេត្រូវឃើញផ្ទាល់ខ្លួន ជាកងទុក្ខ (កើតឡើង) ព្រោះកាមជាហេតុ ព្រោះកាមជាដើមចម ព្រោះកាមជាដើមទង ព្រោះហេតុនៃកាមទាំងឡាយតែម្យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ព្រោះកាមជាហេតុ ព្រោះកាមជាដើមចម ព្រោះកាមជាដើមទង ព្រោះហេតុនៃកាមទាំងឡាយតែម្យ៉ាង ជនទាំងឡាយប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ជនទាំងនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងទុគ្គតិ វិនិបាត នរក ម្នាលភិក្ខុទាំងឡាយ នេះទោសរបស់កាមទាំងឡាយ ដែលត្រូវឃើញក្នុងលោកខាងនាយ ជាកងទុក្ខ (កើតឡើង) ព្រោះកាមជាហេតុ ព្រោះកាមជាដើមចម ព្រោះកាមជាដើមទង ព្រោះហេតុនៃកាមទាំងឡាយតែម្យ៉ាង ។

អាទីនវំ កាមគុណេសុ ទិស្វាតិ កាមគុណេសុ អាទីនវំ ទិស្វា បស្សិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វាតិ អាទីនវំ កាមគុណេសុ ទិស្វា ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

កាមា ហិ ចិត្រា មធុរា មនោរមា
វិរូបរូបេន មថេន្តិ ចិត្តំ
អាទីនវំ កាមគុណេសុ ទិស្វា
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

(២៩៦) ឦតី ច គណ្ឌោ ច ឧបទ្ទវោ ច
រោគោ ច សល្លញ្ច ភយញ្ច មេតំ
ឯតំ ភយំ កាមគុណេសុ ទិស្វា
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

(២៩៧) ឦតី ច គណ្ឌោ ច ឧបទ្ទវោ ច
រោគោ ច សល្លញ្ច ភយញ្ច មេតន្តិ វុត្តញ្ហេតំ ភគវតា ភយន្តិ ភិក្ខវេ កាមានមេតំ អធិវចនំ ទុក្ខន្តិ

ពាក្យថា បុគ្គលឃើញទោស ក្នុងកាមគុណទាំងឡាយ បានសេចក្តីថា ឃើញ មើល ថ្លឹង ត្រួត បញ្ជាក់ ធ្វើឲ្យជាក់ នូវទោសក្នុងកាមគុណទាំងឡាយ ហេតុនោះ (លោកពោលថា) បុគ្គលឃើញទោស ក្នុងកាមគុណទាំងឡាយ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

ពិតណាស់ កាមទាំងឡាយ ដ៏វិចិត្រ មានរសឆ្ងាញ់
ជាទីត្រេកអរនៃចិត្ត តែងញាំញីចិត្ត ដោយសភាពនៃ
រូបផ្សេង បុគ្គលឃើញទោស ក្នុងកាមគុណទាំងឡាយ
ហើយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(២៩៨) បុគ្គលឃើញភ័យនុ៎ះ ក្នុងកាមគុណទាំងឡាយថា
នេះជាចង្រៃ ជាបូស ជាឧបទ្រព ជារោគ ជាព្រួញ
នឹងជាភ័យ របស់អញហើយ គប្បីប្រព្រឹត្តម្នាក់ឯង
ដូចកុយរមាស ។

(២៩៩) ពាក្យថា នេះជាចង្រៃ ជាបូស ជាឧបទ្រព ជារោគ ជាព្រួញ នឹងជាភ័យរបស់អញ អធិប្បាយថា ព្រះមានព្រះភាគបានត្រាស់ព្រះតម្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភ័យ នេះជាឈ្មោះនៃកាមទាំងឡាយ

## ខគ្គវិសាណសុត្តនិទ្ទេសោ

ភិក្ខវេ កាមានមេតំ អធិវចនំ រោគោតិ ភិក្ខវេ កាមានមេតំ អធិវចនំ គណ្ឌោតិ ភិក្ខវេ កាមានមេតំ អធិវចនំ លគ្គន្តិ(១) ភិក្ខវេ កាមានមេតំ អធិវចនំ សត្តោតិ(២) ភិក្ខវេ កាមានមេតំ អធិវចនំ បង្កោតិ ភិក្ខវេ កាមានមេតំ អធិវចនំ គព្ភោតិ ភិក្ខវេ កាមានមេតំ អធិវចនំ យស្មា(៣) ច ភិក្ខវេ ភយន្តិ កាមានមេតំ អធិវចនំ កាមរាគរត្តាយំ ភិក្ខវេ ឆន្ទរាគវិនិពន្ធោ ទិដ្ឋធម្មិកាបិ ភយា ន បរិមុច្ចតិ សម្បរាយិកាបិ ភយា ន បរិមុច្ចតិ តស្មា ភយន្តិ កាមានមេតំ អធិវចនំ យស្មា ច ភិក្ខវេ ទុក្ខន្តិ រោគោតិ គណ្ឌោតិ លគ្គន្តិ សត្តោតិ បង្កោតិ គព្ភោតិ កាមានមេតំ អធិវចនំ កាមរាគរត្តាយំ ភិក្ខវេ ឆន្ទរាគវិនិពន្ធោ ទិដ្ឋធម្មិកាបិ គព្ភា ន បរិមុច្ចតិ សម្បរាយិកាបិ គព្ភា ន បរិមុច្ចតិ តស្មា គព្ភោតិ កាមានមេតំ អធិវចនន្តិ ។

---

១ ម. សល្លន្តិ ។ ២ ម. សង្គោតិ ។ ៣ ម. កស្មា ។

ខគ្គវិសាណសុត្តនិទ្ទេស

ម្នាលភិក្ខុទាំងឡាយ ពាក្យថា ទុក្ខ នេះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ពាក្យថា រោគ នេះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ពាក្យថា បូស នេះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ការស្ទក់ នេះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភាវៈជាប់ នេះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភក់ នេះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ពាក្យថា គភ៌ នេះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែពាក្យថា ភ័យ នេះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ បានជាសត្វអ្នកត្រេកត្រអាលដោយកាមរាគនេះ ជាប់ចំពាក់ដោយឆន្ទរាគ ទើបមិនរួចចាកភ័យ ដែលមានក្នុងបច្ចុប្បន្នផង មិនរួចចាកភ័យដែលមានក្នុងបរលោកផង ព្រោះហេតុនោះ ពាក្យថា ភ័យ នេះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែពាក្យថា ទុក្ខ ថារោគ ថាបូស ថាការស្ទក់ ថាភាវៈជាប់ ថាភក់ ថាគភ៌ នេះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ បានជាសត្វអ្នកត្រេកត្រអាលដោយកាមរាគនេះ ជាប់ចំពាក់ដោយឆន្ទរាគ ទើបមិនរួចចាកគភ៌ ដែលមានក្នុងបច្ចុប្បន្នផង មិនរួចចាកគភ៌ដែលមានក្នុងបរលោកផង ព្រោះហេតុនោះ ពាក្យថា គភ៌ នេះ ជាឈ្មោះនៃកាមទាំងឡាយ ។

ភយញ្ច ទុក្ខញ្ច រោគោ ច  សល្លោ បង្កោ ច ទុភយំ
ឯតេ កាមា បវុច្ចន្តិ  យត្ថ សត្តោ បុថុជ្ជនោ
ឱតិណ្ណោ សាតរូបេន  គព្ភាយ ច និគច្ឆតិ ។
យតោ ច ភិក្ខវេ ភិក្ខុ  ឈានញ្ច ន រិញ្ចតិ
សោមំ បលិបថំ ទុគ្គំ  អតិក្កម្ម តថាវិធំ
បជំ ជាតិជរូបេតំ  ផន្ទមានំ(១) អវេក្ខតីតិ ។

ឦតី ច គណ្ឌោ ច ឧបទ្ទវោ ច រោគោ ច សល្លញ្ច ភយញ្ច មេតំ ។

(២៩៦) ឯតំ ភយំ កាមគុណេសុ ទិស្វាតិ ឯតំ ភយំ កាមគុណេសុ ទិស្វា បស្សិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វាតិ ឯតំ ភយំ កាមគុណេសុ ទិស្វា ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

១ ម. ពន្ទមានំ ។

> បុថុជ្ជន ជាប់ក្នុងកាមទាំងឡាយណា កាមទាំងឡាយនុ៎ះ ព្រះមានព្រះភាគត្រាស់ហៅថា ភ័យផង ទុក្ខផង រោគផង ភារៈជាប់ផង ភក់ផង ធម្មជាតិទាំងពីរគឺ ការថ្ពក់ផង គភ៌ផង ជាសត្វត្រូវរាគៈមានសភាពធ្ងាញ់ សម្រុតហើយ តែងទៅកាន់គភ៌ ៗ ម្នាលភិក្ខុទាំងឡាយ លុះណាតែភិក្ខុ មិនលះបង់ឈាន ទើបភិក្ខុនោះកន្លងផុត មានភក់ គឺកាមនេះ ជាជង្ហក មានបែបដូច្នោះ ហើយសំឡឹងមើល នូវពួកសត្វដែលប្រកបដោយជាតិនិងជរា កំពុងញញាក់ញញ័រ ៗ

ហេតុនោះ (លោកពោលថា) នេះជាចង្រៃ ជាបូស ជាឧបទ្រព ជារោគ ជាព្រួញ និងជាភ័យ របស់អញ ៗ

(៤៩៦) ពាក្យថា បុគ្គលឃើញភ័យនុ៎ះ ក្នុងកាមគុណទាំងឡាយ គឺឃើញ មើល ថ្លឹង ត្រួត បញ្ជាក់ ធ្វើឲ្យច្បាស់ នូវភ័យនុ៎ះ ក្នុងកាមគុណទាំងឡាយ ហេតុនោះ (លោកពោលថា) បុគ្គលឃើញភ័យនុ៎ះ ក្នុងកាមគុណទាំងឡាយ ៗ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ៗ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

ខគ្គវិសាណសុត្តនិទ្ទេសោ

ឦតី ច គណ្ឌោ ច ឧបទ្ទវោ ច
រោគោ ច សល្លញ្ច ភយញ្ច មេតំ
ឯតំ ភយំ កាមគុណេសុ ទិស្វា
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

(២៩៧) សីតញ្ច ឧណ្ហញ្ច ខុទំ បិបាស
វាតាតបេ ឌំសសរីសបេ ច
សព្វានិបេតានិ អភិសំភវិត្វា
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

(២៩៨) សីតញ្ច ឧណ្ហញ្ច ខុទំ បិបាសន្តិ ទ្វីហិ ការណេហិ សីតំ ហោតិ អព្ភន្តរធាតុបកោបវសេន វា សីតំ ហោតិ ពហិទ្ធាឧតុវសេន វា សីតំ ហោតិ ។ ឧណ្ហន្តិ ទ្វីហិ ការណេហិ ឧណ្ហំ ហោតិ អព្ភន្តរធាតុបកោបវសេន វា ឧណ្ហំ ហោតិ ពហិទ្ធាឧតុវសេន វា ឧណ្ហំ ហោតិ ។ ខុទា វុច្ចតិ ឆាតកោ ។ បិបាសា វុច្ចតិ ឧទកាម្យតិ សីតញ្ច ឧណ្ហញ្ច ខុទំ បិបាសំ ។

ខគ្គវិសាណសុត្តនិទ្ទេស

បុគ្គលឃើញភ័យនុ៎ះ ក្នុងកាមគុណទាំងឡាយថា នេះ
ជាចង្រៃ ជាបូស ជាឧបទ្រព ជារោគ ជាព្រួញ
នឹងជាភ័យ របស់អញហើយ គប្បីប្រព្រឹត្តម្នាក់ឯង
ដូចកុយរមាស ។

(២៩៧) បុគ្គលគ្របសង្កត់ នូវធម្មជាតទាំងអស់នុ៎ះ គឺ
ត្រជាក់ កម្ដៅ គម្លាន សម្រេក ខ្យល់នឹងកម្ដៅ
ថ្ងៃ របោមនឹងសត្វលូនហើយ គប្បីប្រព្រឹត្តម្នាក់ឯង
ដូចកុយរមាស ។

(២៩៨) ពាក្យថា ត្រជាក់ កម្ដៅ គម្លាន សម្រេក សេចក្ដីថា ត្រជាក់ ដោយហេតុ ២ គឺ ត្រជាក់ដោយអំណាចកម្រើកធាតុខាងក្នុង ឬត្រជាក់ដោយអំណាចរដូវខាងក្រៅ ។ ពាក្យថា កម្ដៅ បានដល់ កម្ដៅដោយហេតុ ២ គឺ កម្ដៅដោយអំណាចកម្រើកធាតុខាងក្នុង ឬ កម្ដៅដោយអំណាចរដូវខាងក្រៅ ។ ដែលហៅថា គម្លាន បានដល់ សេចក្ដីឃ្លាន ។ ដែលហៅថា សម្រេក បានដល់ ការស្រេកទឹក ហេតុនោះ (លោកពោលថា) ត្រជាក់ កម្ដៅ គម្លាន សម្រេក ។

[២៩៩] វាតាតបេ ឌំសសិរឹសបេ ចាតិ វាតាតិ បុរត្ថិមា វាតា បច្ឆិមា វាតា ឧត្តរា វាតា ទក្ខិណា វាតា សរជា វាតា សីតា វាតា ឧណ្ហា វាតា បរិត្តា វាតា អធិមត្តា វាតា វេរម្ភវាតា សុបណ្ណវាតា តាលបណ្ណវាតា វិធូបនវាតា ។ អាតបោ វុច្ចតិ សុរិយសន្តាបោ ។ ឌំសា វុច្ចន្តិ បិង្គលមក្ខិកា ។ សិរឹសបា វុច្ចន្តិ អហីតិ វាតាតបេ ឌំសសិរឹសបេ ច ។

[៣០០] សព្វានិ បេតានិ អភិសំភវិត្វាតិ អភិភវិត្វា អជ្ឈោត្ថរិត្វា បរិយាទិយិត្វា មទ្ទិត្វាតិ សព្វានិ បេតានិ អភិសំភវិត្វា ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

សីតញ្ច ឧណ្ហញ្ច ខុទំ បិបាសំ
វាតាតបេ ឌំសសិរឹសបេ ច
សព្វានិ បេតានិ អភិសំភវិត្វា
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

(២៩៩) ពាក្យថា ខ្យល់ទិសកម្តៅថ្ងៃ របោមទីសត្វលូន គឺ ពាក្យថា ខ្យល់ គឺ ខ្យល់ខាងកើត ខ្យល់ខាងលិច ខ្យល់ខាងជើង ខ្យល់ខាងត្បូង ខ្យល់មានធូលី ខ្យល់ត្រជាក់ ខ្យល់ក្តៅ ខ្យល់រំភើយ ខ្យល់យ៉ាងខ្លាំង ខ្យល់កំបុតត្បូង ខ្យល់គ្រុឌ ខ្យល់ស្លឹកត្នោត ខ្យល់ផ្លិត ។ ដែលហៅថា កម្តៅថ្ងៃ បានដល់ កម្តៅព្រះអាទិត្យ ។ ដែលហៅថា របោម បានដល់ ពួកមក្ខិកាលឿង ។ ដែលហៅថា សត្វលូន បានដល់ពួកសត្វពស់ ហេតុនោះ (លោកពោលថា) ខ្យល់ទិសកម្តៅថ្ងៃ របោមទីសត្វលូន ។

(៣០០) ពាក្យថា បុគ្គលគ្របសង្កត់ នូវធម្មជាតទាំងអស់នុះ គឺ គ្របសង្កត់ បង្ក្រាប សង្កត់សង្កិន ញាំញី ហេតុនោះ (លោកពោលថា) បុគ្គលគ្របសង្កត់ នូវធម្មជាតទាំងអស់នុះ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

បុគ្គលគ្របសង្កត់ នូវធម្មជាតទាំងអស់នុះ គឺត្រជាក់
ក្តៅ ឃ្លាន ស្រេក ខ្យល់ទិសកម្តៅថ្ងៃ របោមទីស
សត្វលូនហើយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

## ខគ្គវិសាណសុត្តនិទ្ទេសោ

(៣០១) នាគោវ យូថានិ វិវជ្ជយិត្វា
សញ្ជាតខន្ធោ បទុមី ឧឡារោ
យថាភិរន្តំ វិហរេ អរញ្ញេ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

(៣០២) នាគោវ យូថានិ វិវជ្ជយិត្វាតិ នាគោ វុច្ចតិ ហត្ថិនាគោ ។ បច្ចេកសម្ពុទ្ធោបិ នាគោ ។ កិំការណា បច្ចេកសម្ពុទ្ធោ នាគោ ។ អាគុំ ន ករោតីតិ នាគោ ។ ន គច្ឆតីតិ នាគោ ។ ន អាគច្ឆតីតិ នាគោ ។

កថំ សោ បច្ចេកសម្ពុទ្ធោ អាគុំ ន ករោតីតិ នាគោ ។ អាគូ វុច្ចន្តិ បាបកា អកុសលា ធម្មា សង្កិលេសិកា បោនោព្ភវិកា សទរា ទុក្ខវិបាកា អាយតីជាតិជរាមរណីយា ។

## ខគ្គវិសាណសុត្តនិទ្ទេស

(៣០១) បុគ្គលដូចនាគ មានខន្ធកើតព្រមហើយ មាន
សម្បុរដូចផ្កាឈូក ជាសត្វខ្ពង់ខ្ពស់ គេចចាកហ្វូង
ហើយនៅក្នុងព្រៃតាមសប្បាយ គប្បីប្រព្រឹត្តម្នាក់
ឯង ដូចកុយរមាស ។

(៣០២) ពាក្យថា ដូចនាគ គេចចាកហ្វូង អធិប្បាយថា ដំរីដ៏ប្រសើរ លោកហៅថា នាគ ។ ព្រះបច្ចេកសម្ពុទ្ធ ក៏ឈ្មោះនាគដែរ ។ ព្រះបច្ចេកសម្ពុទ្ធ ឈ្មោះថា នាគ ព្រោះហេតុអ្វី ។ ឈ្មោះថានាគ ព្រោះហេតុមិនធ្វើអំពើអាក្រក់ ។ ឈ្មោះថានាគ ព្រោះហេតុមិនលុះ ។ ឈ្មោះថានាគ ព្រោះហេតុមិនមក ។

ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថានាគ ព្រោះហេតុមិនធ្វើអំពើអាក្រក់ តើដូចម្ដេច ។ ធម៌ទាំងឡាយ ជាអកុសល ដ៏លាមក ប្រកបដោយសេចក្ដីសៅហ្មង នាំសត្វឲ្យកើតក្នុងភពថ្មី ប្រកបដោយសេចក្ដីក្រវល់ក្រវាយ មានទុក្ខជាវិបាក ជាទីតាំងនៃជាតិជរានឹងមរណៈតទៅ លោកហៅថា អំពើអាក្រក់ ។

អាគុំ ន ករោតិ កិញ្ចិ លោកេ
សព្វសំយោគេ វិសជ្ជ ពន្ធនានិ
សព្វត្ថ ន សជ្ជតិ វិប្បមុត្តោ
នាគោ តាទិ បវុច្ចតេ តថត្តា ។

ឯវំ សោ បច្ចេកសម្ពុទ្ធោ អាគុំ ន ករោតីតិ នាគោ ។

កថំ សោ បច្ចេកសម្ពុទ្ធោ ន គច្ឆតីតិ នាគោ ។ សោ បច្ចេកសម្ពុទ្ធោ ន ឆន្ទាគតឹ គច្ឆតិ ន ទោសាគតឹ គច្ឆតិ ន មោហាគតឹ គច្ឆតិ ន ភយាគតឹ គច្ឆតិ ន រាគវសេន គច្ឆតិ ន ទោសវសេន គច្ឆតិ ន មោហវសេន គច្ឆតិ ន មានវសេន គច្ឆតិ ន ទិដ្ឋិវសេន គច្ឆតិ ន ឧទ្ធច្ចវសេន គច្ឆតិ ន វិចិកិច្ឆាវសេន គច្ឆតិ ន អនុសយវសេន គច្ឆតិ ន វគ្គេហិ ធម្មេហិ យាយតិ និយ្យតិ វុយ្ហតិ សំហរីយតិ ឯវំ សោ បច្ចេកសម្ពុទ្ធោ ន គច្ឆតីតិ នាគោ ។

កថំ បច្ចេកសម្ពុទ្ធោ ន អាគច្ឆតីតិ នាគោ ។

ព្រះបច្ចេកសម្ពុទ្ធ មិនធ្វើអំពើអាក្រក់តិចតួចក្នុងលោក
លះបង់កិលេស ជាគ្រឿងប្រកបទាំងពួង និងចំណង
ទាំងឡាយ ផុតស្រឡះ មិនជាប់ចំពាក់ក្នុងអារម្មណ៍
ទាំងពួង មិនរំកើបដោយលោកធម៌ លោកហៅថា នាគ
ព្រោះទ្រង់គុណប្រាកដដូច្នោះ ។

ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថានាគ ព្រោះហេតុមិនធ្វើនូវអំពើអាក្រក់ យ៉ាងនេះឯង ។

ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថា នាគ ព្រោះហេតុមិនលុះ តើដូចម្តេច ។ ព្រះបច្ចេកសម្ពុទ្ធនោះ មិនលុះឆន្ទាគតិ មិនលុះទោសាគតិ មិនលុះមោហាគតិ មិនលុះភយាគតិ មិនលុះដោយអំណាចរាគៈ មិនលុះដោយអំណាចទោសៈ មិនលុះដោយអំណាចមោហៈ មិនលុះដោយអំណាចមានះ មិនលុះដោយអំណាចទិដ្ឋិ មិនលុះដោយអំណាចឧទ្ធច្ចៈ មិនលុះ ដោយអំណាចវិចិកិច្ឆា មិនលុះដោយអំណាចអនុស័យ មិនត្រូវធម៌ជាពួកនាំទៅ ដឹកទៅ បន្សាត់ទៅ កួចទៅ ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថានាគ ព្រោះហេតុមិនលុះ យ៉ាងនេះឯង ។

ព្រះបច្ចេកសម្ពុទ្ធ ឈ្មោះថានាគ ព្រោះហេតុមិនមក តើដូចម្តេច ។

## ខគ្គវិសាណសុត្តនិទ្ទេសោ

សោតាបត្តិមគ្គេន យេ កិលេសា បហីនា តេ
កិលេសេ ន បុនេតិ ន បច្ចេតិ ន បច្ចាគច្ឆតិ
សកទាគាមិមគ្គេន អនាគាមិមគ្គេន អរហត្តមគ្គេន
យេ កិលេសា បហីនា តេ កិលេសេ ន បុនេតិ
ន បច្ចេតិ ន បច្ចាគច្ឆតិ ឯវំ សោ បច្ចេកសម្ពុទ្ធោ
ន អាគច្ឆតីតិ នាគោ ។ នាគោវ យូថានិ វិវជ្ជយិ-
ត្វាតិ យថា សោ ហត្ថិនាគោ យូថានិ វិវជ្ជេត្វា
បរិវជ្ជេត្វា អភិនិវជ្ជេត្វា ឯកោវ អរញ្ញេ វនមជ្ឈស្ស
អជ្ឈោគាហេត្វា ចរតិ វិចរតិ ឥរិយតិ វត្តតិ បាលេតិ
យបេតិ យាបេតិ បច្ចេកសម្ពុទ្ធោបិ គណំ វជ្ជេត្វា
បរិវជ្ជេត្វា អភិវជ្ជេត្វា ឯកោ ចរេ ខគ្គវិសាណកប្បោ
អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវតិ អប្ប-
សទ្ទានិ អប្បនិគ្ឃោសានិ វិជនវាតានិ មនុស្សរាហសេ-
យ្យកានិ បដិសល្លានសារុប្បានិ សោ ឯកោ គច្ឆតិ
ឯកោ តិដ្ឋតិ ឯកោ និសីទតិ ឯកោ សេយ្យំ កប្បេតិ

## ខគ្គវិសាណសុត្តនិទ្ទេស

កិលេសទាំងឡាយណា ដែលលោកលះបង់ហើយ ដោយសោតាបត្តិមគ្គ លោកមិនមក មិនត្រឡប់មក មិនវិលមក រកកិលេសទាំងនោះទៀត កិលេសទាំងឡាយណា ដែលលោកលះបង់ហើយ ដោយសកទាគាមិមគ្គ អនាគាមិមគ្គ អរហត្តមគ្គ លោកមិនមក មិនត្រឡប់មក មិនវិលមករកកិលេសទាំងនោះទៀត ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថានាគ ព្រោះហេតុមិនមក យ៉ាងនេះឯង ។ ពាក្យថា ដូចនាគ គេចចាកហ្វូង បានសេចក្តីថា ដំរីដ៏ប្រសើរនោះ វៀរលែង ចៀសវាង វៀរស្រឡះនូវហ្វូងទាំងឡាយ ចូលទៅនៅកណ្តាលព្រៃក្នុងអរញ្ញប្រទេស ចរ ត្រាច់ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ តែម្នាក់ឯង យ៉ាងណា ចំណែកព្រះបច្ចេកសម្ពុទ្ធ ក៏វៀរលែង ចៀសវាង វៀរស្រឡះនូវពួក ប្រព្រឹត្តនៅតែមួយអង្គឯង ដូចកុយរមាស ទ្រង់គប់រកព្រៃតូចនឹងព្រៃធំ ជាសេនាសនៈដ៏ស្ងាត់ មិនមានសម្លេង មិនមានសូរគឹកកង ប្រាសចាកខ្យល់ ដែលកើតអំពីសរីរៈនៃជន ជាសេនាសនៈដ៏ស្ងាត់ចាកមនុស្ស សមគួរដល់ការពួនសម្ងំ ព្រះបច្ចេកសម្ពុទ្ធនោះ និមន្តទៅតែមួយអង្គឯង ឈរតែមួយអង្គឯង គង់នៅតែមួយអង្គឯង សម្រេចការសិងតែមួយអង្គឯង

ឯកោ គាមំ បិណ្ឌាយ បវិសតិ ឯកោ បដិក្កមតិ ឯកោ រហោ និសីទតិ ឯកោ ចង្កមំ អធិដ្ឋាតិ ឯកោ ចរតិ វិហរតិ ឥរិយតិ វត្តតិ បាលេតិ យបេតិ យាបេតីតិ នាគោវ យូថានិ វិវជ្ជយិត្វា ។

(៣០៣) សញ្ជាតខន្ធោ បទុមី ឧឡារោតិ យថា សោ ហត្ថិនាគោ សញ្ជាតក្ខន្ធោ សត្តរតនោ វា ហោតិ អដ្ឋរតនោ វា បច្ចេកសម្ពុទ្ធោបិ សញ្ជា-តក្ខន្ធោ អសេក្ខេន សីលក្ខន្ធេន អសេក្ខេន សមាធិក្ខន្ធេន អសេក្ខេន បញ្ញាខន្ធេន អសេក្ខេន វិមុត្តិក្ខន្ធេន អសេក្ខេន វិមុត្តិញ្ញាណទស្សនក្ខន្ធេន ។ យថា សោ ហត្ថិនាគោ បទុមី បច្ចេកសម្ពុទ្ធោបិ សត្តហិ ពោជ្ឈង្គបុប្ផេហិ បទុមី សតិសម្ពោជ្ឈង្គបុប្ផេន ធម្មវិចយសម្ពោជ្ឈង្គបុប្ផេន វីរិយសម្ពោជ្ឈង្គបុប្ផេន បី-តិសម្ពោជ្ឈង្គបុប្ផេន បស្សទ្ធិសម្ពោជ្ឈង្គបុប្ផេន សមាធិ-សម្ពោជ្ឈង្គបុប្ផេន ឧបេក្ខាសម្ពោជ្ឈង្គបុប្ផេន ។ យថា សោ ហត្ថិនាគោ ឧឡារោ ថាមេន ពលេន ជវេន

ចូលទៅបិណ្ឌបាតក្នុងស្រុកតែមួយអង្គឯង ត្រឡប់មកវិញតែមួយអង្គឯង គង់ក្នុងទីស្ងាត់តែមួយអង្គឯង អធិដ្ឋានបង្រ្កមតែមួយអង្គឯង ចរ ត្រាច់ ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ តែមួយអង្គឯង (ក៏យ៉ាងនោះដែរ) ហេតុនោះ (លោកពោលថា) ដូចនាគ គេចចាកហ្វូង ។

(៣០៣) ពាក្យថា មានខន្ធកើតព្រមហើយ មានសម្បុរដូចផ្កាឈូក ជាសត្វខ្ពង់ខ្ពស់ អធិប្បាយថា ដំរីដ៏ប្រសើរនោះ មានខន្ធកើតព្រមហើយ ជាដំរី ៧ ហត្ថ ឬ ៨ ហត្ថ យ៉ាងណា ឯព្រះបច្ចេកសម្ពុទ្ធ ក៏មានខន្ធកើតព្រមហើយ ដោយអសេក្ខសីលក្ខន្ធ អសេក្ខសមាធិក្ខន្ធ អសេក្ខ-បញ្ញាខន្ធ អសេក្ខវិមុត្តិក្ខន្ធ អសេក្ខវិមុត្តិញាណទស្សនក្ខន្ធ ក៏យ៉ាងនោះ ។ ដំរីដ៏ប្រសើរនោះ មានផ្កាឈូក យ៉ាងណា ឯព្រះបច្ចេកសម្ពុទ្ធ ឈ្មោះថាមានផ្កាឈូក ដោយផ្កាគឺពោជ្ឈង្គ ៧ គឺ ដោយផ្កាគឺសតិសម្ពោ-ជ្ឈង្គ ១ ផ្កាគឺធម្មវិចយសម្ពោជ្ឈង្គ ១ ផ្កាគឺវីរិយសម្ពោជ្ឈង្គ ១ ផ្កាគឺបីតិ-សម្ពោជ្ឈង្គ ១ ផ្កាគឺបស្សទ្ធិសម្ពោជ្ឈង្គ ១ ផ្កាគឺសមាធិសម្ពោជ្ឈង្គ ១ ផ្កាគឺឧបេក្ខាសម្ពោជ្ឈង្គ ១ (យ៉ាងនោះដែរ) ។ ដំរី ដ៏ប្រសើរនោះ ជាសត្វលើសលុប ដោយកម្លាំងកាយ កម្លាំងចិត្ត សន្ទុះ

សព្វេន បច្ចេកសម្ពុទ្ធោបិ ឧឡារោ សីលេន សមាធិនា បញ្ញាយ វិមុត្តិយា វិមុត្តិញាណទស្សនេនាតិ សញ្ជាតខគ្គោ បទុមំ ឧឡារោ ។

(៣០៤) យថាភិរន្តំ វិហារេ អរញ្ញេតិ យថា សោ ហត្ថិនាគោ យថាភិរន្តំ អរញ្ញេ វិហរតិ បច្ចេកសម្ពុទ្ធោបិ យថាភិរន្តំ អរញ្ញេ វិហរតិ បឋមេនបិ ឈានេន យថាភិរន្តំ អរញ្ញេ វិហរតិ ទុតិយេនបិ តតិយេនបិ ចតុត្ថេនបិ ឈានេន យថាភិរន្តំ អរញ្ញេ វិហរតិ មេត្តាយបិ ចេតោវិមុត្តិយា យថាភិរន្តំ អរញ្ញេ វិហរតិ ករុណាយបិ មុទិតាយបិ ឧបេក្ខាយបិ ចេតោវិមុត្តិយា យថាភិរន្តំ អរញ្ញេ វិហរតិ អាកាសានញ្ចាយតនសមាបត្តិយាបិ យថាភិរន្តំ អរញ្ញេ វិហរតិ វិញ្ញាណញ្ចាយតនសមាបត្តិយាបិ អាកិញ្ចញ្ញាយតនសមាបត្តិយាបិ នេវសញ្ញានាសញ្ញាយតនសមាបត្តិយាបិ ផលសមាបត្តិយាបិ យថាភិរន្តំ អរញ្ញេ វិហរតីតិ យថាភិរន្តំ វិហារេ អរញ្ញេ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

នឹងសេចក្តីក្លៀវក្លា យ៉ាងណា ឯព្រះបច្ចេកសម្ពុទ្ធ ក៏ជាបុគ្គលលើសលុបដោយសីល សមាធិ បញ្ញា វិមុត្តិ នឹងវិមុត្តិញាណទស្សនៈ (យ៉ាងនោះដែរ) ហេតុនោះ (លោកពោលថា) មានខន្ធកើតព្រមហើយ មានសម្បុរដូចផ្កាឈូក ជាសត្វខ្ពង់ខ្ពស់ ។

(៣០៤) ពាក្យថា នៅក្នុងព្រៃតាមសប្បាយ សេចក្តីថា ដំរីដ៏ប្រសើរនោះ នៅក្នុងព្រៃតាមសប្បាយ យ៉ាងណា ឯព្រះបច្ចេកសម្ពុទ្ធ ក៏នៅក្នុងព្រៃតាមសប្បាយ ( យ៉ាងនោះដែរ ) គឺនៅក្នុងព្រៃតាមសប្បាយ ដោយបឋមជ្ឈានខ្លះ នៅក្នុងព្រៃតាមសប្បាយ ដោយទុតិយជ្ឈានខ្លះ តតិយជ្ឈានខ្លះ ចតុត្ថជ្ឈានខ្លះ នៅក្នុងព្រៃតាមសប្បាយ ដោយមេត្តា-ចេតោវិមុត្តិខ្លះ នៅក្នុងព្រៃតាមសប្បាយ ដោយករុណាចេតោវិមុត្តិខ្លះ មុទិតាចេតោវិមុត្តិខ្លះ ឧបេក្ខាចេតោវិមុត្តិខ្លះ នៅក្នុងព្រៃតាមសប្បាយ ដោយអាកាសានញ្ចាយតនសមាបត្តិខ្លះ នៅក្នុងព្រៃតាមសប្បាយ ដោយវិញ្ញាណញ្ចាយតនសមាបត្តិខ្លះ ដោយអាកិញ្ចញ្ញាយតនសមាបត្តិខ្លះ ដោយនេវសញ្ញានាសញ្ញាយតនសមាបត្តិខ្លះ ដោយផលសមាបត្តិខ្លះ ហេតុនោះ (លោកពោលថា) នៅក្នុងព្រៃតាមសប្បាយ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

នាគោវ យូថានិ វិវជ្ជយិត្វា

សញ្ជាតខន្ធោ បទុមី ឧឡារោ

យថាភិរន្តំ វិហរេ អរញ្ញេ

ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

(៣០៥) អដ្ឋាន តំ សង្គណិការតស្ស

យំ ផុស្សយេ សាមយិកំ វិមុត្តឹ

អាទិច្ចពន្ធុស្ស វចោ និសម្ម

ឯកោ ចរេ ខគ្គវិសាណកប្បោ ។

(៣០៦) អដ្ឋាន តំ សង្គណិការតស្ស យំ ផុស្សយេ សាមយិកំ វិមុត្តិន្តិ វុត្តំ ហេតំ ភគវតា យាវតានន្ទ ភិក្ខុ សង្គណិការាមោ សង្គណិការ-តោ សង្គណិការាមតំ អនុយុត្តោ គណារាមោ

បុគ្គលដែលដូចនាគ មានខ្លួនកើតព្រមហើយ មាន
សម្បុរដូចផ្កាឈូក ជាសត្វខ្ពង់ខ្ពស់ គេបរិភោគហ្វូង
ហើយនៅក្នុងព្រៃតាមសប្បាយ គប្បីប្រព្រឹត្តម្នាក់ឯង
ដូចកុយរមាស ។

(៣០៥) បុគ្គលគប្បីបានសាមយិកវិមុត្តិ(១) ដោយហេតុណា
ហេតុនោះ មិនមែនជាទីតាំង នៃបុគ្គលអ្នកត្រេកអរក្នុងពួកទេ បុគ្គលពិចារណាពាក្យ នៃព្រះពុទ្ធ ជាព្រះអាទិច្ចពន្ធុហើយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(៣០៦) ពាក្យថា បុគ្គល គប្បីបានសាមយិកវិមុត្តិ ដោយហេតុណា ហេតុនោះ មិនមែនជាទីតាំង នៃបុគ្គលអ្នកត្រេកអរក្នុងពួកទេ អធិប្បាយថា មែនពិត ព្រះមានព្រះភាគ បានត្រាស់ព្រះពុទ្ធដីកានេះថា ម្នាលអានន្ទ ភិក្ខុមានការនៅច្រឡូកច្រឡំដោយពួកជាទីត្រេកអរ ត្រេកអរក្នុងការនៅច្រឡូកច្រឡំដោយពួក ប្រកបរឿយ ៗ នូវសេចក្តីត្រេកអរ ក្នុងការនៅច្រឡូកច្រឡំដោយពួក មានពួកជាទីត្រេកអរ

១ វិមុត្តិប្រព្រឹត្តទៅតាមសម័យ គឺ វិមុត្តិជាលោកិយ ។

គណារតោ គណសម្មុទិតោ គណារាមតំ អនុយុត្តោ
យន្តំ នេក្ខម្មសុខំ បវិវេកសុខំ ឧបសមសុខំ
សម្ពោធិសុខំ តស្ស សុខស្ស និកាមលាភី ភវិស្សតិ
អកិច្ឆលាភី អកសិរលាភីតិ នេតំ ឋានំ វិជ្ជតិ ។
យោ ច ខោ សោ អានន្ទ ភិក្ខុ ឯកោ គណស្មា
វូបកដ្ឋោ វិហរតិ តស្សេតំ ភិក្ខុនោ បាដិកង្ខំ យន្តំ
នេក្ខម្មសុខំ បវិវេកសុខំ ឧបសមសុខំ សម្ពោធិ-
សុខំ តស្ស សុខស្ស និកាមលាភី ភវិស្សតិ អកិច្ឆ-
លាភី អកសិរលាភីតិ ឋានមេតំ វិជ្ជតិ ។ យាវតា-
នន្ទ ភិក្ខុ សង្គណិការាមោ សង្គណិការតោ សង្គ-
ណិការាមតំ អនុយុត្តោ គណារាមោ គណារតោ
គណសម្មុទិតោ គណារាមតំ អនុយុត្តោ សាមយិកំ
វា ចេតោវិមុត្តឹ ឧបសម្បជ្ជ វិហរិស្សតិ អសាម-
យិកំ វា អកុប្បន្តិ នេតំ ឋានំ វិជ្ជតិ ។

ត្រេកអរក្នុងពួក ពេះពយក្នុងពួក ប្រកបរឿយៗ នូវសេចក្តីត្រេកអរក្នុងពួក ជាកំណត់ សេចក្តីសុខក្នុងការចេញបួស សេចក្តីសុខក្នុងការស្ងាត់ សេចក្តីសុខក្នុងការស្ងប់ សេចក្តីសុខក្នុងការត្រាស់ដឹង ណា (ភិក្ខុនោះ) នឹងជាអ្នកបានតាមប្រាថ្នា បានដោយមិនក្រ បានដោយមិនលំបាក នូវសេចក្តីសុខនោះ ហេតុការណ៍បែបនេះ មិនមានទេ ។ ម្នាលអានន្ទ លុះតែភិក្ខុណា ចៀសចេញចាកពួក ហើយនៅតែម្នាក់ឯង សេចក្តីសុខនុះ ទើបមានប្រាកដដល់ភិក្ខុនោះ គឺថា សេចក្តីសុខក្នុងការចេញបួស សេចក្តីសុខក្នុងការស្ងាត់ សេចក្តីសុខក្នុងការស្ងប់ សេចក្តីសុខក្នុងការត្រាស់ដឹងណា (ភិក្ខុនោះ) នឹងជាអ្នកបានតាមប្រាថ្នា បានដោយមិនក្រ បានដោយមិនលំបាក នូវសេចក្តីសុខនោះ ហេតុការណ៍បែបនេះ ទើបមាន ។ ម្នាលអានន្ទ ភិក្ខុមានការនៅច្រឡូកច្រឡំដោយពួកជាទីត្រេកអរ ត្រេកអរក្នុងការនៅច្រឡូកច្រឡំដោយពួក ប្រកបរឿយ ៗ នូវសេចក្តីត្រេកអរក្នុងការនៅច្រឡូកច្រឡំដោយពួក មានពួកជាទីត្រេកអរ ត្រេកអរក្នុងពួក ពេះពយក្នុងពួក ប្រកបរឿយៗនូវសេចក្តីត្រេកអរក្នុងពួក ជាកំណត់ (ភិក្ខុនោះ) នឹងបានសាមយិកចេតោវិមុត្តិ (ចេតោវិមុត្តិជាលោកិយ) ឬអសាមយិក-អកុប្បធម៌ (មគ្គជាលោកុត្តរៈ) ហេតុការណ៍បែបនេះ មិនមានទេ ។

យោ ច ខោ សោ អានន្ទ ភិក្ខុ ឯកោ គណស្មា វូបកដ្ឋោ វិហរតិ តស្សេតំ ភិក្ខុនោ បាដិកង្ខំ សាមយិកំ វា ចេតោវិមុត្តិំ ឧបសម្បជ្ជ វិហរិស្សតិ អសាមយិកំ វា អកុប្បន្តិ ឋានមេតំ វិជ្ជតីតិ អដ្ឋាន តំ សង្គណិការតស្ស យំ ផុស្សេយ្យ សាមយិកំ វិមុត្តិំ ។

(៣០៧) អាទិច្ចពន្ធុស្ស វចោ និសម្មាតិ អាទិច្ចោ វុច្ចតិ សុរិយោ ។ សោ គោតមោ គោត្តេន បច្ចេកសម្ពុទ្ធោបិ គោតមោ គោត្តេន សោ បច្ចេកសម្ពុទ្ធោបិ សុរិយស្ស គោត្តញាតកោ(១) គោត្តពន្ធុ តស្មា បច្ចេកសម្ពុទ្ធោ អាទិច្ចពន្ធុ ។ អាទិច្ចពន្ធុស្ស វចោ និសម្មាតិ អាទិច្ចពន្ធុស្ស វចនំ ព្យបថំ ទេសនំ អនុសន្ធិំ សុត្វា សុណិត្វា ឧគ្គហេត្វា ឧបធារយិត្វា ឧបលក្ខយិត្វាតិ អាទិច្ចពន្ធុស្ស វចោ និសម្ម ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

---

១ ម. អយំ បាឋោ នត្ថិ ។

ម្នាលអានន្ទ លុះតែភិក្ខុណា ចៀសចេញចាកពួក ហើយនៅតែម្នាក់ឯង សេចក្ដីសុខនោះ ទើបមានប្រាកដដល់ភិក្ខុនោះ គឺថា (ភិក្ខុនោះ) នឹងបានសាមយិកចេតោវិមុត្តិ ឬអសាមយិកអកុប្បធម៌ ហេតុការណ៍បែបនេះ ទើបមាន ហេតុនោះ (លោកពោលថា) បុគ្គលគប្បីបានសាមយិកវិមុត្តិ ដោយហេតុណា ហេតុនោះ មិនមែនជាទីតាំងនៃបុគ្គល អ្នកត្រេកអរកងពួកទេ ។

(៣០៧) ពាក្យថា បុគ្គលពិចារណាពាក្យនៃព្រះពុទ្ធ ជាព្រះអាទិច្ចពន្ធុ សេចក្ដីថា ព្រះអាទិត្យ លោកហៅថា អាទិច្ចៈ ។ ព្រះអាទិត្យនោះជាគោតមដោយគោត្ត ចំណែកព្រះបច្ចេកសម្ពុទ្ធ ក៏ជាគោតមដោយគោត្ត ព្រះបច្ចេកសម្ពុទ្ធនោះ ជាញាតិដោយគោត្ត ជាផៅពង្សដោយគោត្តនៃព្រះអាទិត្យ ព្រោះហេតុនោះ ព្រះបច្ចេកសម្ពុទ្ធ ឈ្មោះថា ព្រះអាទិច្ចពន្ធុ ។ ពាក្យថា បុគ្គលពិចារណាពាក្យនៃព្រះពុទ្ធ ជាព្រះអាទិច្ចពន្ធុ បានសេចក្ដីថា បុគ្គលបានស្ដាប់ ឮ រៀន ចាំទុក កំណត់នូវពាក្យ គន្ថពាក្យ ទេសនា អនុសន្ធិ នៃព្រះពុទ្ធជាព្រះអាទិច្ចពន្ធុ ហេតុនោះ (លោកពោលថា) បុគ្គលពិចារណាពាក្យនៃព្រះពុទ្ធ ជាព្រះអាទិច្ចពន្ធុ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

ខគ្គវិសាណសុត្តនិទ្ទេសោ

អដ្ឋាន តំ សង្គណិការតស្ស
យំ ផុស្សយេ សាមយិកំ វិមុត្តឹ
អាទិច្ចពន្ធុស្ស វចោ និសម្ម
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

(៣០៨) ទិដ្ឋីវិសូកានិ ឧបាតិវត្តោ
បត្តោ និយាមំ បដិលទ្ធមគ្គោ
ឧប្បន្នញាណោម្ហិ អនញ្ញនេយ្យោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

(៣០៩) ទិដ្ឋីវិសូកានិ ឧបាតិវត្តោតិ ទិដ្ឋិវិសូកានិ វុច្ចន្តិ វីសតិវត្ថុកា សក្កាយទិដ្ឋី ។ ឥធ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្មស្ស អកោវិទោ អរិយធម្មេ អវិនីតោ សប្បុរិសានំ អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិសធម្មេ អវិនីតោ រូបំ អត្តតោ សមនុបស្សតិ រូបវន្តំ វា អត្តានំ អត្តនិ វា រូបំ រូបស្មឹ វា អត្តានំ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ អត្តតោ សមនុបស្សតិ

ខគ្គវិសាណសុត្តនិទ្ទេស

បុគ្គលគប្បីបានសាមយិកវិមុត្តិ ដោយហេតុណា ហេតុនោះ មិនមែនជាទីតាំងនៃបុគ្គលអ្នកត្រេកអរក្នុងពួកទេ បុគ្គលពិចារណាពាក្យ នៃព្រះពុទ្ធ ជាព្រះអាទិច្ចពន្ធុ ហើយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(៣០៨) បុគ្គលប្រព្រឹត្តកន្លង នូវបម្រួងគឺទិដ្ឋិទាំងឡាយ បានសម្រេចធម៌ដ៏ទៀងទាត់ បានចំពោះនូវមគ្គ មិនមានបុគ្គលដទៃណែនាំ (ព្រោះដឹងថា) អាត្មាអញមានញាណកើតហើយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(៣០៩) ពាក្យថា បុគ្គលប្រព្រឹត្តកន្លង នូវបម្រួងគឺទិដ្ឋិទាំងឡាយ សេចក្តីថា សក្កាយទិដ្ឋិមានវត្ថុ ២០ ហៅថា បម្រួងគឺទិដ្ឋិ ។ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនឃើញនូវពួកព្រះអរិយៈ មិនឈ្លាសក្នុងអរិយធម៌ មិនបានទូន្មានខ្លួនក្នុងអរិយធម៌ មិនឃើញពួកសប្បុរស មិនឈ្លាសក្នុងសប្បុរិសធម៌ មិនបានទូន្មានខ្លួនក្នុងសប្បុរិសធម៌ រមែងពិចារណាឃើញរូបថាខ្លួន នូវខ្លួនថាមានរូបខ្លះ នូវរូបក្នុងខ្លួនខ្លះ នូវខ្លួនក្នុងរូបខ្លះ ពិចារណាឃើញនូវវេទនា សញ្ញា សង្ខារ វិញ្ញាណថាខ្លួន

វិញ្ញាណវត្ថុំ វា អត្តានំ អត្តនិ វា វិញ្ញាណំ វិញ្ញាណស្មឹ វា អត្តានំ យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ទិដ្ឋិគហនំ ទិដ្ឋិកន្តារោ ទិដ្ឋិវិសូកាយិកំ ទិដ្ឋិវិប្ផន្ទិតំ ទិដ្ឋិសំយោជនំ គាហោ បដិគ្គាហោ(១) អភិនិវេសោ បរាមាសោ កុម្មគ្គោ មិច្ឆាបថោ មិច្ឆត្តំ តិត្ថាយតនំ វិបរិយេសគ្គាហោ វិបរីតគ្គាហោ វិបល្លាសគ្គាហោ មិច្ឆាគាហោ អយាថាវកស្មឹ យាថាវកន្តិ គាហោ យាវតា ទ្វាសដ្ឋី ទិដ្ឋិគតានិ ឥមានិ ទិដ្ឋិវិសូកានិ(២) ។ ឧបាតិវត្តោតិ ទិដ្ឋិវិសូកានិ ឧបាតិវត្តោ អតិក្កន្តោ សមតិក្កន្តោ(៣) វីតិវត្តោតិ ទិដ្ឋីវិសូកានិ ឧបាតិវត្តោ ។

[៣១០] បត្តោ និយាមំ បដិលទ្ធមគ្គោតិ និយាមា វុច្ចន្តិ ចត្តារោ មគ្គា អរិយោ អដ្ឋង្គិកោ មគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។

---

១ ម. បតិដ្ឋាហោ ។ ២ ម. អយំ ទិដ្ឋិវិសូកា ។ ៣ ម. ទិដ្ឋីវិសូកានិ ឧបាតិវត្តោតិ ទិដ្ឋិវិសូកានិ ឧបាតិវត្តោ អតិក្កន្តោ សមតិក្កន្តោ ។

នូវខន្ធថា មានវិញ្ញាណខ្លះ នូវវិញ្ញាណក្នុងខន្ធខ្លះ នូវខន្ធក្នុងវិញ្ញាណខ្លះ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ព្រៃស្បាតគឺទិដ្ឋិ ផ្លូវដាច់ស្រយាលគឺទិដ្ឋិ បម្រួងគឺទិដ្ឋិ សេចក្តីញាប់ញ័រគឺទិដ្ឋិ បំណងគឺទិដ្ឋិ ការប្រកាន់ ការប្រកាន់ខ្ជាប់ ការប្រកាន់មាំ ការស្ទាបអង្អែល ផ្លូវខុស គន្លងខុស សេចក្តីខុស លទ្ធិដូចជាកំពង់ សេចក្តីប្រកាន់ដោយការស្វែងរកខុស ការប្រកាន់វិបរីត ការប្រកាន់វិបល្លាស ការប្រកាន់ខុស ការប្រកាន់ថាពិត ក្នុងរបស់ដែលមិនពិត ទិដ្ឋិ ៦២ ទាំងប៉ុន្មាន មានសភាពយ៉ាងនេះ ឯណា នេះ ឈ្មោះថាបម្រួងគឺទិដ្ឋិ ។ ពាក្យថា ប្រព្រឹត្តកន្លង គឺ ប្រព្រឹត្តរំលង ឈានកន្លង ឈានរំលង ប្រព្រឹត្តកន្លង នូវបម្រួងគឺទិដ្ឋិទាំងឡាយ ហេតុនោះ (លោកពោលថា) បុគ្គលប្រព្រឹត្តកន្លង នូវបម្រួងគឺទិដ្ឋិទាំងឡាយ ។

(៣១០) ពាក្យថា បានសម្រេចធម៌ដ៏ទៀងទាត់ បានចំពោះនូវមគ្គ សេចក្តីថា មគ្គ ៤ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ គឺសម្មាទិដ្ឋិ ១ សម្មាសង្កប្បៈ ១ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ សម្មាវាយាមៈ ១ សម្មាសតិ ១ សម្មាសមាធិ ១ លោកហៅថា ធម៌ដ៏ទៀង ។

ចតូហិ អរិយមគ្គេហិ សមន្នាគតោ សម្បត្តោ អធិគ-តោ ផុសិតោ សច្ឆិកតោតិ បត្តោ និយាមំ ។ បដិ-លទ្ធមគ្គោតិ លទ្ធមគ្គោ បដិលទ្ធមគ្គោ អធិគតមគ្គោ ផុសិតមគ្គោតិ បត្តោ និយាមំ បដិលទ្ធមគ្គោ ។

(៣១១) ឧប្បន្នញាណោម្ហិ អនញ្ញនេយ្យោតិ តស្ស បច្ចេកសម្ពុទ្ធស្ស ញាណំ ឧប្បន្នំ សមុប្បន្នំ និព្វត្តំ អភិនិព្វត្តំ បាតុភូតំ សព្វេ សង្ខារា អនិច្ចាតិ ញាណំ ឧប្បន្នំ សមុប្បន្នំ និព្វត្តំ អភិនិព្វត្តំ បាតុភូ-តំ សព្វេ សង្ខារា ទុក្ខាតិ ។ បេ ។ យង្កិញ្ចិ សមុ-ទយធម្មំ សព្វន្តំ និរោធធម្មន្តិ ញាណំ ឧប្បន្នំ សមុ-ប្បន្នំ និព្វត្តំ អភិនិព្វត្តំ បាតុភូតន្តិ ឧប្បន្នញាណោ-ម្ហិ ។ អនញ្ញនេយ្យោតិ សោ បច្ចេកសម្ពុទ្ធោ ន បរ-នេយ្យោ ន បរបត្តិយោ ន បរប្បច្ចយោ ន បរប្បដិ-ពទ្ធគូ យថាភូតំ ជានាតិ បស្សតិ អសម្មូឡ្ហោ សម្ប-ជានោ បដិស្សតោ សព្វេ សង្ខារា អនិច្ចាតិ ។ បេ ។

ខគ្គវិសាណសុត្តនិទ្ទេស

បុគ្គលប្រកប សម្រេច បាន ប៉ះពាល់ ធ្វើឲ្យជាក់ច្បាស់ដោយអរិយមគ្គទាំង ៤ ហេតុនោះ (លោកពោលថា) បានសម្រេចធម៌ដ៏ទៀងទាត់ ។ ពាក្យថា បានចំពោះនូវមគ្គ គឺបានមគ្គ បានចំពោះមគ្គ បានសម្រេចមគ្គ បានប៉ះពាល់មគ្គ ហេតុនោះ (លោកពោលថា) បានសម្រេចធម៌ដ៏ទៀងទាត់ បានចំពោះនូវមគ្គ ។

(៣១១) ពាក្យថា មិនមានបុគ្គលដទៃ ណែនាំ (ព្រោះដឹងថា) អាត្មាអញមានញាណកើតហើយ អធិប្បាយថា ព្រះបច្ចេកសម្ពុទ្ធនោះ មានញាណកើតឡើង កើតឡើងព្រម កើត កើតចំពោះ កើតប្រាកដ គឺ មានញាណកើតឡើង កើតឡើងព្រម កើត កើតចំពោះ កើតប្រាកដថា សង្ខារទាំងពួងមិនទៀង ថា សង្ខារទាំងពួងជាទុក្ខ ។ បេ ។ មានញាណកើតឡើង កើតឡើងព្រម កើត កើតចំពោះ កើតប្រាកដថា របស់ណាមួយ មានការកើតឡើងជាធម្មតា របស់ទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា ហេតុនោះ (លោកពោលថា) អាត្មាអញមានញាណកើតហើយ ។ ពាក្យថា មិនមានបុគ្គលដទៃ ណែនាំ គឺ ព្រះបច្ចេកសម្ពុទ្ធនោះ មិនមានបុគ្គលដទៃណែនាំ មិនមានបុគ្គលដទៃឲ្យជឿ មិនមានបុគ្គលដទៃជាទីអាង មិនដល់នូវការជាប់ចំពាក់ដោយបុគ្គលដទៃ រមែងដឹង ឃើញតាមពិត ជាបុគ្គលមិនវង្វេង ជាអ្នកដឹងច្បាស់ មានស្មារតីប្រុងជានិច្ចថា សង្ខារទាំងពួងមិនទៀង ។ បេ ។

យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ន
បរនេយ្យោ ន បរបត្តិយោ ន បរប្បច្ចយោ ន
បរប្បដិពទ្ធគូ យថាភូតំ ជានាតិ បស្សតិ អសម្មូឡ្ហោ
សម្បជានោ បដិស្សតោតិ ឧប្បន្នញាណោម្ហិ អនញ្ញ-
នេយ្យោ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។
តេនាហ សោ បច្ចេកសម្ពុទ្ធោ

ទិដ្ឋីវិសូកានិ ឧបាតិវត្តោ
បត្តោ និយាមំ បដិលទ្ធមគ្គោ
ឧប្បន្នញាណោម្ហិ អនញ្ញនេយ្យោ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

(៣១២) និល្លោលុបោ និក្កុហោ និប្បិបាសោ
និម្មក្ខោ និទ្ធន្តកសាវមោហោ
និរាសសោ សព្វលោកេ ភវិត្វា
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

មិនមានបុគ្គលដទៃណែនាំ មិនមានបុគ្គលដទៃឲ្យជឿ មិនមានបុគ្គលដទៃជាទីអាង មិនដល់នូវការជាប់ចំពាក់ដោយបុគ្គលដទៃ រមែងដឹង ឃើញតាមពិត ជាបុគ្គលមិនវង្វេង ជាអ្នកដឹងច្បាស់ មានស្មារតីប្រុងជានិច្ច ថារបស់ណាមួយ មានការកើតឡើងជាធម្មតា របស់ទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា ហេតុនោះ (លោកពោលថា) មិនមានបុគ្គលដទៃណែនាំ (ព្រោះដឹងថា) អាត្មាអញមានញាណកើតហើយ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

បុគ្គលប្រព្រឹត្តកន្លង នូវចម្រូងគឺទិដ្ឋិទាំងឡាយ បាន
សម្រេចធម៌ដ៏ទៀងទាត់ បានបំពោះនូវមគ្គ មិនមាន
បុគ្គលដទៃណែនាំ (ព្រោះដឹងថា) អាត្មាអញមានញាណ
កើតហើយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(៣១២) បុគ្គលអ្នកមិនលោភ អ្នកមិនកុហក អ្នកមិន
មានការស្រេកឃ្លាន អ្នកមិនមានការលុបគុណគេ មាន
ទឹកចត់នឹងមោហៈកំចាត់ចេញហើយ មិនមានសេចក្តី
ប្រាថ្នា ក្នុងលោកទាំងមូល គប្បីប្រព្រឹត្ត ម្នាក់ឯង
ដូចកុយរមាស ។

## ខគ្គវិសាណសុត្តនិទ្ទេសោ

(៣១៣) និល្លោលុបោ និក្កុហោ និប្បិបាសោតិ លោលុប្បា វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។បេ។ អភិជ្ឈា លោភោ អកុសលមូលំ ។ សា លោលុប្បា តណ្ហា តស្ស បច្ចេកសម្ពុទ្ធស្ស បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹអនុប្បាទធម្មា តស្មា បច្ចេកសម្ពុទ្ធោ និល្លោលុបោ ។ និក្កុហោតិ តីណិ កុហនវត្ថូនិ បច្ចយបដិសេវនសង្ខាតំ កុហនវត្ថុ ឥរិយាបថសង្ខាតំ កុហនវត្ថុ សាមន្តជប្បនសង្ខាតំ កុហនវត្ថុ ។

កតមំ បច្ចយបដិសេវនសង្ខាតំ កុហនវត្ថុ ។ ឥធ គហបតិកា ភិក្ខុំ និមន្តេន្តិ ចីវរបិណ្ឌបាតសេនាសនគិលានបច្ចយភេសជ្ជបរិក្ខារេហិ ។ សោ បាបិច្ឆោ ឥច្ឆាបកតោ អត្ថិកោ ចីវរបិណ្ឌបាតសេនាសនគិលានបច្ចយភេសជ្ជបរិក្ខារានំ ភិយ្យោកម្យតំ ឧបាទាយ ចីវរំ បច្ចក្ខាតិ បិណ្ឌបាតំ បច្ចក្ខាតិ សេនាសនំ បច្ចក្ខាតិ គិលានបច្ចយភេសជ្ជបរិក្ខារំ បច្ចក្ខាតិ ។

## ខគ្គវិសាណសុត្តនិទ្ទេស

(៣១៣) ពាក្យថា បុគ្គលអ្នកមិនលោភ អ្នកមិនកុហក អ្នកមិនមានការស្រេកឃ្លាន អធិប្បាយថា តណ្ហា ហៅថា សេចក្ដីលោភ បានដល់តម្រេក តម្រេកខ្លាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ តណ្ហាគឺសេចក្ដីលោភនោះ ព្រះបច្ចេកសម្ពុទ្ធនោះ បានលះបង់ គាស់រំលើងឫស ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនកើតមាន ឲ្យជាធម៌លែងកើតឡើងតទៅទៀត ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថាអ្នកមិនមានលោភ ។ ពាក្យថា អ្នកមិនកុហក សេចក្ដីថា កុហនវត្ថុ មាន ៣ គឺកុហនវត្ថុប៉ែកខាងការសេពបច្ច័យ ១ កុហនវត្ថុប៉ែកខាងឥរិយាបថ ១ កុហនវត្ថុប៉ែកខាងការខ្សឹប ១ ។

កុហនវត្ថុ ប៉ែកខាងការសេពបច្ច័យ តើដូចម្ដេច ។

ពួកគហបតី ក្នុងសាសនានេះ និមន្តភិក្ខុដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ។ ភិក្ខុនោះ ជាអ្នកមានសេចក្ដីប្រាថ្នាលាមក ត្រូវសេចក្ដីប្រាថ្នាគ្របសង្កត់ មានសេចក្ដីត្រូវការដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ អាស្រ័យសេចក្ដីប្រាថ្នាខ្លាំង ក៏ពោលឃាត់ចីវរ ពោលឃាត់បិណ្ឌបាត ពោលឃាត់សេនាសនៈ ពោលឃាត់គិលានប្បច្ចយភេសជ្ជបរិក្ខារ ។

សោ ឯវមាហ កឹ សមណស្ស មហគ្ឃេន ចីវរេន ឯតំ សារុប្បំ យំ សមណោ សុសានា វា សង្ការកូដា វា បាបណិកា វា នន្តកានិ ឧច្ចិនិត្វា សង្ឃាដឹ កត្វា(១) ធារេយ្យ កឹ សមណស្ស មហគ្ឃេន បិណ្ឌបាតេន ឯតំ សារុប្បំ យំ សមណោ ឧញ្ឆាចរិយាយ បិណ្ឌិយាលោបេន ជីវិតំ កប្បេយ្យ កឹ សមណស្ស មហគ្ឃេន សេនាសនេន ឯតំ សារុប្បំ យំ សមណោ រុក្ខមូលិកោ វា អស្ស អព្ភោកាសិកោ វា កឹ សមណស្ស មហគ្ឃេន គិលានប្បច្ចយភេសជ្ជបរិក្ខារេន ឯតំ សារុប្បំ យំ សមណោ បូតិមុត្តេន វា ហរីដកីខណ្ឌេន វា ឱសធំ ករេយ្យាតិ តទុបាទាយ លូខំ ចីវរំ ធារេតិ លូខំ បិណ្ឌបាតំ ភុញ្ជតិ លូខំ សេនាសនំ បដិសេវតិ លូខំ គិលានប្បច្ចយភេសជ្ជបរិក្ខារំ បដិសេវតិ ។ តមេនំ គហបតិកា ឯវំ ជានន្តិ អយំ សមណោ អប្បិច្ឆោ សន្តុដ្ឋោ បវិវិត្តោ អសំសដ្ឋោ

---

១ ម. សង្ឃាដិកំ ករិត្វា ។

ភិក្ខុនោះ បាននិយាយយ៉ាងនេះថា សមណៈមានប្រយោជន៍អ្វី ដោយចីវរ ដែលមានថ្លៃច្រើន ឯអំពើដ៏សមគួរនុ៎ះ ត្រង់សមណៈរើសកំណាត់សំពត់ អំពីព្រៃស្មសាន អំពីគំនរសម្រាម ឬអំពីពានផ្សារ ធ្វើជាសង្ឃាដិហើយទ្រទ្រង់ សមណៈមានប្រយោជន៍អ្វី ដោយបិណ្ឌបាតដែលមានថ្លៃច្រើន ឯអំពើដ៏សមគួរនុ៎ះ ត្រង់សមណៈចិញ្ចឹមជីវិតដោយពំនូតអាហារដោយការដើរស្វែង សមណៈមានប្រយោជន៍អ្វី ដោយសេនាសនៈដែលមានថ្លៃច្រើន ឯអំពើដ៏សមគួរនុ៎ះ ត្រង់សមណៈគួរជាអ្នកនៅជិតគល់ឈើ ឬនៅក្នុងទីវាល សមណៈមានប្រយោជន៍អ្វី ដោយគិលានប្បច្ចយភេសជ្ជបរិក្ខារ ដែលមានថ្លៃច្រើន ឯអំពើដ៏សមគួរនុ៎ះ ត្រង់សមណៈធ្វើថ្នាំដោយទឹកមូត្រគោ ឬដោយចំណិតផ្លែសម៉ ភិក្ខុអាស្រ័យដំណើរនោះ ក៏ទ្រទ្រង់ចីវរសៅហ្មង បរិភោគបិណ្ឌបាតសៅហ្មង ប្រើប្រាស់សេនាសនៈសៅហ្មង សេពគិលានប្បច្ចយភេសជ្ជបរិក្ខារសៅហ្មង ៗ ពួកគហបតី ដឹងនូវភិក្ខុនោះយ៉ាងនេះថា សមណៈនេះ ជាអ្នកប្រាថ្នាតិច ជាអ្នកសន្តោស ជាអ្នកស្ងប់ស្ងាត់ ជាអ្នកមិនច្រឡូកច្រឡំ (ដោយពួក)

ខគ្គវិសាណសុត្តនិទ្ទេសោ

អារទ្ធវីរិយោ ឧត្តភោតិ ភិយ្យោ និមន្តេន្តិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេហិ ។

សោ ឯវមាហ តិណ្ណំ សម្មុខីភាវា សទ្ធោ កុលបុត្តោ ពហុំ បុញ្ញំ បសវតិ សទ្ធាយ សម្មុខីភាវា សទ្ធោ កុលបុត្តោ ពហុំ បុញ្ញំ បសវតិ ទេយ្យធម្មស្ស សម្មុខីភាវា សទ្ធោ កុលបុត្តោ ពហុំ បុញ្ញំ បសវតិ ទក្ខិណេយ្យានំ សម្មុខីភាវា សទ្ធោ កុលបុត្តោ ពហុំ បុញ្ញំ បសវតិ តុម្ហាកញ្ចាយំ សទ្ធា អត្ថិ ទេយ្យធម្មោ ច សំវិជ្ជតិ អហញ្ច បដិគ្គាហកោ សចាហំ ន បដិគ្គហេស្សាមិ ឯវំ តុម្ហេ បុញ្ញេន បរិហាយិស្សថ ន មយ្ហំ ឥមិនា អត្ថោ អបិច តុម្ហាកញ្ញេវ អនុកម្បាយ បដិគ្គណ្ហាមីតិ តទុបាទាយ ពហុម្បិ ចីវរំ បដិគ្គណ្ហាតិ ពហុម្បិ បិណ្ឌបាតំ បដិគ្គណ្ហាតិ ពហុម្បិ សេនាសនំ បដិគ្គណ្ហាតិ ពហុម្បិ គិលានប្បច្ចយភេសជ្ជបរិក្ខារំ បដិគ្គណ្ហាតិ ។ យា ឯវរូបា ភាកុដិកា ភាកុដិយំ កុហនា កុហាយនា កុហិតត្តំ ឥទំ វុច្ចតិ បច្ចយប្បដិសេវនសង្ខាតំ កុហនវត្ថុ ។

ប្រារព្ធព្យាយាម ពោលពាក្យជាគ្រឿងកំចាត់បង់កិលេស ក៏តែតែនិមន្ត ដោយចីវរ បិណ្ឌបាត សេនាសនៈនឹងគិលានប្បច្ចយភេសជ្ជបរិក្ខារ ។

ភិក្ខុនោះ បាននិយាយយ៉ាងនេះថា កុលបុត្រអ្នកមានសទ្ធា បានបុណ្យ ច្រើនព្រោះធម៌ ៣ មានចំពោះមុខ គឺ កុលបុត្រអ្នកមានសទ្ធា បានបុណ្យច្រើន ព្រោះមានសទ្ធាចំពោះមុខ ១ កុលបុត្រអ្នកមានសទ្ធា បានបុណ្យច្រើន ព្រោះមានទេយ្យធម៌ចំពោះមុខ ១ កុលបុត្តអ្នកមានសទ្ធា បានបុណ្យច្រើន ព្រោះពួកទក្ខិណេយ្យបុគ្គលមានចំពោះមុខ ១ (ឥឡូវ) សទ្ធានេះ របស់អ្នកទាំងឡាយក៏មានផង ទេយ្យធម៌ក៏មានផង ទាំងអាត្មាក៏ជាអ្នកទទួលស្រាប់ បើអាត្មាមិនទទួលទេ អ្នកទាំងឡាយនឹងសាបសូន្យ ចាកបុណ្យយ៉ាងនេះ មិនខាន អាត្មាមិនមានសេចក្តីត្រូវការដោយទេយ្យធម៌នេះទេ ប៉ុន្តែអាត្មាទទួលដើម្បីអនុគ្រោះ ដល់អ្នកទាំងឡាយប៉ុណ្ណោះ (ភិក្ខុ) អាស្រ័យដំណើរនោះ ក៏ទទួលចីវរយ៉ាងច្រើនផង ទទួលបិណ្ឌបាតយ៉ាងច្រើនផង ទទួលសេនាសនៈយ៉ាងច្រើនផង ទទួលគិលានប្បច្ចយភេសជ្ជបរិក្ខារ យ៉ាងច្រើនផង ។ អាការធ្វើមុខស្រពោន ភាពនៃការធ្វើមុខស្រពោន ការកុហក អាការនៃកុហក ភាពនៃកុហក មានសភាពយ៉ាងនេះ ឯណា នេះលោកហៅថា កុហនវត្ថុ ប៉ែកខាងការសេពបច្ច័យ ។

កតមំ ឥរិយាបថសង្ខាតំ កុហនវត្ថុ ។ ឥធេកច្ចោ បាបិច្ឆោ ឥច្ឆាបកតោ សម្ភាវនាធិប្បាយោ ឯវំ មំ ជនោ សម្ភាវេស្សតីតិ គមនំ សណ្ឋាបេតិ ឋានំ សណ្ឋាបេតិ និសជ្ជំ សណ្ឋាបេតិ សេយ្យំ សណ្ឋាបេតិ បណិធាយ គច្ឆតិ បណិធាយ តិដ្ឋតិ បណិធាយ និសីទតិ បណិធាយ សេយ្យំ កប្បេតិ សមាហិតោ វិយ គច្ឆតិ សមាហិតោ វិយ តិដ្ឋតិ សមាហិតោ វិយ និសីទតិ សមាហិតោ វិយ សេយ្យំ កប្បេតិ អាបាថកជ្ឈាយីវ ហោតិ ។ យា ឯវរូបា ឥរិយាបថស្ស អាឋបនា ឋបនា សណ្ឋាបនា ភាកុដិកា ភាកុដិយំ កុហនា កុហាយនា កុហាយិតត្តំ ឥទំ ឥរិយាបថសង្ខាតំ កុហនវត្ថុ ។

កុហនវត្ថុ ប៉ែកខាងឥរិយាបថ តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនា នេះ មានសេចក្តីប្រាថ្នាលាមក ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ មានបំណងនូវការសរសើរថា អ្នកផងនឹងសរសើរអញយ៉ាងនេះ ក៏រៀបចំដំណើរ រៀបចំដំហរ រៀបចំបង្គុយ រៀបចំដំណេក រៀបរឹកដើរ រៀបរឹកឈរ រៀបរឹកអង្គុយ រៀបរឹកសម្រេចការដេក ដើរដូចជាមានចិត្តតម្កល់មាំ ឈរដូចជាមានចិត្តតម្កល់មាំ អង្គុយដូចជាមានចិត្តតម្កល់មាំ សម្រេចការដេកដូចជាមានចិត្តតម្កល់មាំ ហាក់ដូចជាចូលឈានក្នុងទីចំពោះមុខ (នៃអ្នកផង) ។ ការតាំងក្នុងខាងដើម ការតាំងទុក ការរៀបចំឥរិយាបថ អាការធ្វើមុខស្រពោន ភាពនៃការធ្វើមុខស្រពោន ការកុហក អាការនៃកុហក ភាពនៃកុហក មានសភាពយ៉ាងនេះ ឯណា នេះហៅថា កុហនវត្ថុ ប៉ែកខាងឥរិយាបថ ។

## ខគ្គវិសាណសុត្តនិទ្ទេសោ

កថំ សាមន្តជប្បនសង្ខាតំ កុហនវត្ថុ ។ ឥធេកច្ចោ បាបិច្ឆោ ឥច្ឆាបកតោ សម្ភាវនាធិប្បាយោ ឯវំ មំ ជនោ សម្ភាវេស្សតីតិ អរិយធម្មសន្និស្សិតំ វាចំ ភាសតិ យោ ឯវរូបំ ចីវរំ ធារេតិ សោ សមណោ មហេសក្ខោតិ ភណតិ ។ យោ ឯវរូបំ បត្តំ ធារេតិ លោហថាលកំ ធារេតិ ធម្មករកំ ធារេតិ បរិស្សាវនំ ធារេតិ កុញ្ចិកំ ធារេតិ ឧបាហនំ ធារេតិ កាយពន្ធនំ ធារេតិ អាយោគពន្ធនំ ធារេតិ សោ សមណោ មហេសក្ខោតិ ភណតិ ។ យស្ស ឯវរូបោ ឧបជ្ឈាយោ សោ សមណោ មហេសក្ខោតិ ភណតិ ។ យស្ស ឯវរូបោ អាចរិយោ សមានុបជ្ឈាយកា សមានាចរិយកា មិត្តា សន្ទិដ្ឋា សម្ភត្តា សហាយា សោ សមណោ មហេសក្ខោតិ ភណតិ ។ យោ ឯវរូបេ វិហារេ វសតិ សោ សមណោ មហេសក្ខោតិ ភណតិ ។

# ខគ្គវិសាណសុត្តនិទ្ទេស

កុហនវត្ថុ ប៉ែកខាងការខ្សឹប តើដូចម្តេច ៗ ភិក្ខុខ្លះក្នុងសាសនា នេះ មានសេចក្តីប្រាថ្នាលាមក ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ មាន បំណងនូវការសរសើរថា អ្នកផងនឹងសរសើរអញយ៉ាងនេះ ក៏ពោល វាចាផ្តួលទៅរកអរិយធម៌ គឺពោលថា សមណៈណា ទ្រទ្រង់ចីវរមាន សភាពយ៉ាងនេះ សមណៈនោះ មានសក្តិធំ ៗ ពោលថា សមណៈ ណា ទ្រទ្រង់បាត្រ ទ្រទ្រង់ផ្តិលលោហៈ ទ្រទ្រង់ធម្មក្រក ទ្រទ្រង់សំពត់ តម្រងទឹក ទ្រទ្រង់កូនសោ ទ្រទ្រង់ស្បែកជើង ទ្រទ្រង់វត្ថពន្ធន៍ចង្កេះ ទ្រទ្រង់សំពត់អាយោគពន្ធន៍ មានសភាពយ៉ាងនេះ ៗ សមណៈនោះ មានសក្តិធំ ៗ ពោលថា ឧបជ្ឈាយ៍នៃសមណៈណា មានសភាពយ៉ាង នេះ សមណៈនោះមានសក្តិធំ ៗ ពោលថា សមណៈណា មានអាចារ្យ មានពួកភិក្ខុដែលមានឧបជ្ឈាយ៍ស្មើគ្នា មានពួកភិក្ខុដែលមានអាចារ្យស្មើគ្នា មានមិត្ត មានមិត្តស្មាក់ស្មើរ មានមិត្តស៊ប់សួន មានសំឡាញ់ មាន សភាពយ៉ាងនេះៗ សមណៈនោះ មានសក្តិធំ ៗ ពោលថា សមណៈ ណា នៅក្នុងវិហារ មានសភាពយ៉ាងនេះ សមណៈនោះមានសក្តិធំ ៗ

យោ ឯវរូបេ អឌ្ឍយោគេ វសតិ(១) ហម្មិយេ វសតិ គុហាយំ វសតិ(២) កុដិយា វសតិ កូដាគារេ វសតិ អដ្ដេ វសតិ មាឡេ វសតិ ឧទ្ទណ្ឌេ វសតិ ឧបដ្ឋានសាលាយំ វសតិ មណ្ឌបេ វសតិ រុក្ខមូលេ វសតិ សោ សមណោ មហាសក្កោតិ ភណតិ ។ អថវា កោរជិកកោរជិកោ ភាកុដិកភាកុដិកោ កុហកុហោ លបលបោ មុខសម្ភាវិតោ អយំ សមណោ ឥមាសំ ឯវរូបានំ សន្តានំ វិហារសមាបត្តីនំ លាភីតិ តាទិសំ គម្ភីរំ គូឡ្ហំ និបុណំ បដិច្ឆន្នំ លោកុត្តរសុញ្ញតាបដិសញ្ញុត្តំ កថំ កថេតិ ។ យា ឯវរូបា ភាកុដិកា ភាកុដិយំ កុហនា កុហាយនា កុហាយិតត្តំ ឥទំ សាមន្តជប្បនសង្ខាតំ កុហនវត្ថុ ។

---

១ ម. ឯត្ថន្តរេ បាសាទេ វសតីតិ ទិស្សតិ ។ ២ ម. ឯត្ថន្តរេ លេណេ វសតីតិ ទិស្សតិ ។

ពោលថា សមណៈណា នៅក្នុងអឡ្សយោគ (បង្ហា) នៅក្នុងប្រាសាទ មានកំពូល នៅក្នុងគុហា នៅក្នុងខ្ទម នៅក្នុងផ្ទះកំពូល នៅក្នុងប៉ម នៅក្នុងពេងមូល នៅក្នុងថែវ នៅក្នុងឧបដ្ឋានសាលា នៅក្នុងមណ្ឌប (ផាំ) នៅក្បែរគល់ឈើ មានសភាពយ៉ាងនេះ ៗ សមណៈនោះ មានសក្តិធំ ៗ ម្យ៉ាងទៀត ភិក្ខុជាអ្នកស្រគត់ស្រគំពេក មានមុខស្រពាប់ស្រពោនពេក ជាអ្នកកុហកពេក ជាអ្នករួសរាយពេក ដែលត្រូវគេសរសើរ ដោយអំណាចមាត់ (របស់ខ្លួន) ថា សមណៈនេះ ជាអ្នកបាននូវវិហារសមាបត្តិទាំងនេះ ជាគុណដ៏ស្ងប់ស្ងាត់ មានសភាពយ៉ាងនេះ តែងពោលពាក្យប្រាកដដូច្នោះ ជាពាក្យជ្រាលជ្រៅ លំបាកយល់ ដ៏ល្អិត កំបិទកំបាំង ជាវាចាប្រកបដោយលោកុត្តរធម៌ នឹងសុញ្ញត-និព្វាន ៗ អាការធ្វើមុខស្រពោន ភាពនៃការធ្វើមុខស្រពោន ការកុហក អាការនៃកុហក ភាពនៃកុហក មានសភាពយ៉ាងនេះ ឯណានេះហៅថា កុហនវត្ថុ ប៉ែកខាងការខ្សឹប ៗ

តស្ស បច្ចេកសម្ពុទ្ធស្ស ឥមានិ តីណិ កុហន-វត្ថូនិ បហីនានិ សមុច្ឆិន្នានិ វូបសន្តានិ បដិប្បស្សទ្ធានិ អភព្វុប្បត្តិកានិ ញាណគ្គិនា ទឌ្ឍានិ តស្មា សោ បច្ចេកសម្ពុទ្ធោ និក្កុហោ ។ និប្បិបាសោតិ បិបាសា វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។បេ។ អភិជ្ឈា លោភោ អកុសលមូលំ ។ សា បិបាសា តណ្ហា តស្ស បច្ចេកសម្ពុទ្ធស្ស បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា តស្មា សោ បច្ចេកសម្ពុទ្ធោ និប្បិបាសោតិ និល្លោលុបោ និក្កុហោ និប្បិបាសោ ។

## ខគ្គវិសាណសុត្តនិទ្ទេស

កុហនវត្ថុទាំង ៣ នេះ ព្រះបច្ចេកសម្ពុទ្ធនោះ បានលះបង់ ផ្តាច់ ផ្តិល រម្ងាប់ គ្រប់សង្កត់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតដោយភ្លើងគឺញាណហើយ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថាអ្នកមិនកុហក ។ ពាក្យថា អ្នកមិនមានការស្រេកឃ្លាន សេចក្តីថា តណ្ហា លោកហៅថា ការស្រេកឃ្លាន បានដល់តម្រេក តម្រេកខ្លាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ តណ្ហាគឺការស្រេកឃ្លាននោះ ព្រះបច្ចេកសម្ពុទ្ធនោះ បានលះបង់ គាស់ឫសគល់ ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនកើតមាន ឲ្យជាធម៌លែងកើតតទៅទៀត ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថាអ្នកមិនមានការស្រេកឃ្លាន ហេតុនោះ (លោកពោលថា) បុគ្គលអ្នកមិនលោភ អ្នកមិនកុហក អ្នកមិនមានការស្រេកឃ្លាន ។

[៣១៤] និម្មក្ខោ និទ្ធន្តកសាវមោហោតិ ម-ក្ខោតិ យោ មក្ខោ មក្ខាយនា មក្ខាយិតត្តំ និដ្ឋុ-រិយំ និដ្ឋុរិយកម្មំ ។ កសាវាតិ រាគោ កសាវោ ទោសោ កសាវោ មោហោ កសាវោ កោធោ ឧបនាហោ មក្ខោ បឡាសោ ។ បេ ។ សព្វាកុស-លាភិសង្ខារា កសាវា ។ មោហោតិ ទុក្ខេ អញ្ញា-ណំ ទុក្ខសមុទយេ អញ្ញាណំ ទុក្ខនិរោធេ អញ្ញាណំ ទុក្ខនិរោធគាមិនិយា បដិបទាយ អញ្ញាណំ បុព្វន្តេ អញ្ញាណំ អបរន្តេ អញ្ញាណំ បុព្វន្តាបរន្តេ អញ្ញាណំ ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណំ យំ ឯវរូបំ អញ្ញាណំ អទស្សនំ អនភិសមយោ អន-នុពោធោ អសម្ពោធោ អប្បដិវេធោ អសង្គាហនា អប-រិយោគាហនា អសមបេក្ខនា អបច្ចវេក្ខនា អបច្ចក្ខ-កម្មំ ទុម្មេជ្ឈំ ពាល្យំ អសម្បជញ្ញំ មោហោ សម្មោហោ

(៣១៤) អធិប្បាយពាក្យថា អ្នកមិនមានការលុបគុណគេ មានទឹកចត់នឹងមោហៈកំចាត់ចេញហើយ ត្រង់ពាក្យថា ការលុបគុណ បានខាងការបំបាត់គុណ អាការៈនៃការលុបគុណ ភាពនៃការលុបគុណ សេចក្តីប្រណៃន កម្មគឺសេចក្តីប្រណៃន ។ ពាក្យថា ទឹកចត់ សំដៅយកកពកៈ ឈ្មោះថាទឹកចត់ ទោសៈ ឈ្មោះថាទឹកចត់ មោហៈ ឈ្មោះថាទឹកចត់ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ។ បេ ។ អកុសលាភិសង្ខារទាំងអស់ ឈ្មោះថាទឹកចត់ ។ ពាក្យថា មោហៈ បានដល់ការមិនដឹងក្នុងទុក្ខ ការមិនដឹងក្នុងទុក្ខសមុទ័យ ការមិនដឹងក្នុងទុក្ខនិរោធ ការមិនដឹងក្នុងទុក្ខនិរោធគាមិនីបដិបទា ការមិនដឹងក្នុងចំណែកខន្ធមុន ការមិនដឹងក្នុងចំណែកខន្ធក្រោយ ការមិនដឹងក្នុងចំណែកខន្ធមុននឹងចំណែកខន្ធក្រោយ ការមិនដឹងក្នុងធម៌ទាំងឡាយ ដែលអាស្រ័យគ្នាកើតឡើង ព្រោះធម៌នេះជាបច្ច័យ គឺ ដែលជា ការមិនដឹង ការមិនឃើញ ការមិនយល់ច្បាស់ ការមិនត្រាស់ដឹងតាម ការមិនត្រាស់ដឹងព្រម ការមិនចាក់ធ្លុះ ការមិនកាន់យក (ដោយសាមញ្ញលក្ខណៈ) ការមិនចុះកាន់ (សាមញ្ញលក្ខណៈ) ការមិនសំឡឹងស្មើ ការមិនពិចារណា អំពើមិនជាក់ច្បាស់ សន្តានចិត្តអាក្រក់ ភាពជាបុគ្គលល្ងង់ ការមិនដឹងខ្លួន ការវង្វេង ការវង្វេងសព្វ

អវិជ្ជោឃោ អវិជ្ជាយោគោ អវិជ្ជានុសយោ អវិជ្ជាបរិយុដ្ឋានំ អវិជ្ជាជាលំ(១) អវិជ្ជាលង្គី មោហោ អកុសលមូលំ ។ តស្ស បច្ចេកសម្ពុទ្ធស្ស មក្ខោ ច កសាវោ ច មោហោ ច វន្តា(២) និទ្ធន្តា បហីនា សមុច្ឆិន្នា វូបសន្តា បដិប្បស្សទ្ធា អភព្វុប្បត្តិកា ញាណគ្គិនា ទឌ្ឍា តស្មា សោ បច្ចេកសម្ពុទ្ធោ និម្មក្ខោ និទ្ធន្តកសាវមោហោ ។

(៣១៥) និរាសសោ សព្វលោកេ ភវិត្វាតិ អាសា វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។បេ។ អភិជ្ឈា លោភោ អកុសលមូលំ ។ សព្វលោកេតិ សព្វអបាយលោកេ សព្វមនុស្សលោកេ សព្វទេវលោកេ សព្វខន្ធលោកេ សព្វធាតុលោកេ សព្វអាយតនលោកេ ។ និរាសសោ សព្វលោកេ ភវិត្វាតិ សព្វលោកេ និរាសសោ ភវិត្វា និត្តណ្ហោ ភវិត្វា និប្បិបាសោ ភវិត្វាតិ និរាសសោ សព្វលោកេ ភវិត្វា ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។

---

១ ម. អយំ បាឋោ នត្ថិ ។ ២ ម. វត្តា សំវន្តា ។

អន្ធការគឺអវិជ្ជា យោគៈគឺអវិជ្ជា អនុស័យគឺអវិជ្ជា កិលេសជាគ្រឿងគ្របសង្កត់ចិត្តគឺអវិជ្ជា បណ្តាញគឺអវិជ្ជា សន្ទះទ្វារធំគឺអវិជ្ជា មោហៈ អកុសលមូល មានសភាពយ៉ាងនេះ ។ ការលុបគុណ ទឹកចត់ នឹងមោហៈ ព្រះបច្ចេកសម្ពុទ្ធនោះ បានខ្ជាក់ចោល កំចាត់ចោល លះបង់ កាត់ផ្តាច់ រម្ងាប់ គ្របសង្កត់ ធ្វើមិនគួរឲ្យកើតឡើងបាន ដុតបំផ្លាញដោយភ្លើងគឺញាណ ព្រោះហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថាអ្នកមិនមានការលុបគុណគេ មានទឹកចត់នឹងមោហៈកំចាត់ចេញហើយ ។

(៣១៥) ពាក្យថា មិនមានសេចក្តីប្រាថ្នា ក្នុងលោកទាំងមូល សេចក្តីថា តណ្ហា លោកហៅថា សេចក្តីប្រាថ្នា បានខាងតម្រេក តម្រេកខ្លាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ ពាក្យថា ក្នុងលោកទាំងមូល គឺ ក្នុងអបាយលោកទាំងមូល មនុស្សលោកទាំងមូល ទេវលោកទាំងមូល ខន្ធលោកទាំងមូល ធាតុលោកទាំងមូល អាយតនលោកទាំងមូល ។ ពាក្យថា មិនមានសេចក្តីប្រាថ្នាក្នុងលោកទាំងមូល បានសេចក្តីថា ជាអ្នកមិនមានសេចក្តីប្រាថ្នា មិនមានតណ្ហា មិនមានសេចក្តីស្រេកឃ្លានក្នុងលោកទាំងមូល ហេតុនោះ (លោកពោលថា) មិនមានសេចក្តីប្រាថ្នាក្នុងលោកទាំងមូល ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

តេនាហ សោ បច្ចេកសម្ពុទ្ធោ

និល្លោលុបោ និក្កុហោ និប្បិបាសោ
និម្មក្ខោ និទ្ធន្តកសាវមោហោ
និរាសសោ សព្វលោកេ ភវិត្វា
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

(៣១៦) បាបំ សហាយំ បរិវជ្ជយេថ
អនត្ថទស្សឹ វិសមេ និវិដ្ឋំ
សយំ ន សេវេ បសុតំ បមត្តំ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

(៣១៧) បាបំ សហាយំ បរិវជ្ជយេថាតិ បាប-សហាយោ វុច្ចតិ យោ សោ សហាយោ ទសវត្ថុ-កាយ មិច្ឆាទិដ្ឋិយា សមន្នាគតោ នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ នត្ថិ ហុតំ នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ នត្ថិ អយំ លោកោ នត្ថិ បរោ លោកោ នត្ថិ មាតា នត្ថិ បិតា នត្ថិ សត្តា ឱបបាតិកា នត្ថិ

ព្រោះហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

បុគ្គលអ្នកមិនលោភ អ្នកមិនកុហក អ្នកមិនមានការ
ស្រេកឃ្លាន អ្នកមិនមានការលុបគុណគេ មានទឹកចត់
នឹងមោហៈកំចាត់ចេញហើយ មិនមានសេចក្តីប្រាថ្នាក្នុង
លោកទាំងមូល គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(៣១៦) បុគ្គល គួរបៀសវាង នូវសំឡាញ់អាក្រក់ អ្នក
ឃើញនូវអំពើមិនមានប្រយោជន៍ អ្នកតាំងនៅក្នុងអំពើ
មិនស្មើ មិនគួរសេពគប់នូវបុគ្គលអ្នកខ្វល់ខ្វាយ អ្នក
ធ្វេសប្រហែស ដោយខ្លួនឯង គប្បីប្រព្រឹត្តម្នាក់ឯង
ដូចកុយរមាស ។

(៣១៧) ពាក្យថា បុគ្គលគួរបៀសវាង នូវសំឡាញ់អាក្រក់ សេចក្តីថា ដែលហៅថា សំឡាញ់អាក្រក់ បានដល់សំឡាញ់ដែលប្រកប ដោយមិច្ឆាទិដ្ឋិ មានវត្ថុ ១០ យ៉ាងថា ទានដែលគេឲ្យមិនមានផល បូជាធំមិនមានផល បូជាតូចមិនមានផល ផលវិបាកនៃកម្ម ដែលបុគ្គលធ្វើល្អធ្វើអាក្រក់ មិនមាន លោកនេះមិនមាន លោកដទៃមិនមាន មាតាមិនមានគុណ បិតាមិនមានគុណ ពួកសត្វជាឧបបាតិកៈមិនមាន

លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិប-ន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អ-ភិញ្ញា សច្ឆិកត្វា បវេទេន្តិ អយំ បាបសហាយោ ។ បាបំ សហាយំ បរិវជ្ជយេថាតិ បាបំ សហាយំ បរិវជ្ជយេថ វិវជ្ជេយ្យ បរិវជ្ជេយ្យាតិ បាបំ សហាយំ បរិវជ្ជយេថ ។

(៣១៨) អនត្ថទស្សឹ វិសមេ និវិដ្ឋន្តិ អនត្ថ-ទស្សី វុច្ចតិ យោ សោ សហាយោ ទសវត្ថុកាយ មិច្ឆាទិដ្ឋិយា សមន្នាគតោ នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ ។បេ។ យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តិ អយំ អនត្ថទស្សី ។

ពួកសមណព្រាហ្មណ៍ក្នុងលោក ដែលប្រព្រឹត្តត្រឹមត្រូវ ប្រតិបត្តិត្រឹមត្រូវ បានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាយ៉ាងខ្ពង់ខ្ពស់ចំពោះខ្លួន ហើយប្រកាសនូវលោកនេះ នឹងលោកខាងមុខ មិនមាន សំឡាញ់បែបនេះ ឈ្មោះថាសំឡាញ់អាក្រក់ ។ ពាក្យថា បុគ្គលគួរចៀសវាង នូវសំឡាញ់អាក្រក់ បានសេចក្តីថា បុគ្គលគួរចៀសវាង គួរវៀរលែង គួរគេចវាង នូវសំឡាញ់អាក្រក់ ហេតុនោះ (លោកពោលថា) បុគ្គលគួរចៀសវាងនូវសំឡាញ់អាក្រក់ ។

(៣១៨) ពាក្យថា អ្នកឃើញនូវអំពើមិនមានប្រយោជន៍ អ្នកតាំងនៅក្នុងអំពើមិនស្មើ សេចក្តីថា ដែលហៅថា អ្នកឃើញនូវអំពើមិនមានប្រយោជន៍ បានខាងសំឡាញ់ ដែលប្រកបដោយមិច្ឆាទិដ្ឋិ មានវត្ថុ ១០ យ៉ាងថា ទានដែលគេឲ្យ មិនមានផល បូជាធំ មិនមានផល ។ បេ ។ ដែលបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាយ៉ាងខ្ពង់ខ្ពស់ចំពោះខ្លួន ហើយប្រកាសនូវលោកនេះ នឹងលោកខាងមុខ មិនមាន សំឡាញ់បែបនេះ ឈ្មោះថា សំឡាញ់អ្នកឃើញ នូវអំពើមិនមានប្រយោជន៍ ។

វិសមេ និវិដ្ឋន្តិ វិសមេ កាយកម្មេ និវិដ្ឋំ វិសមេ វចីកម្មេ និវិដ្ឋំ វិសមេ មនោកម្មេ និវិដ្ឋំ វិសមេ បាណាតិបាតេ និវិដ្ឋំ វិសមេ អទិន្នាទានេ និវិដ្ឋំ វិសមេ កាមេសុមិច្ឆាចារេ និវិដ្ឋំ វិសមេ មុសាវាទេ និវិដ្ឋំ វិសមាយ បិសុណាយ វាចាយ និវិដ្ឋំ វិសមាយ ផរុសាយ វាចាយ និវិដ្ឋំ វិសមេ សម្ផប្បលាបេ និវិដ្ឋំ វិសមាយ អភិជ្ឈាយ និវិដ្ឋំ វិសមេ ព្យាបាទេ និវិដ្ឋំ វិសមាយ មិច្ឆាទិដ្ឋិយា និវិដ្ឋំ វិសមេសុ សង្ខារេសុ និវិដ្ឋំ វិសមេសុ បញ្ចសុ កាមគុណេសុ និវិដ្ឋំ សត្តំ អល្លីនំ ឧបគតំ អជ្ឈោសិតំ អធិមុត្តន្តិ អនត្តនស្សី វិសមេ និវិដ្ឋំ ។

ពាក្យថា អ្នកតាំងនៅក្នុងអំពើមិនស្មើ សេចក្តីថា អ្នកតាំងនៅក្នុងកាយកម្មមិនស្មើ តាំងនៅក្នុងវចីកម្មមិនស្មើ តាំងនៅក្នុងមនោកម្មមិនស្មើ គឺថា តាំងនៅក្នុងកម្មមិនស្មើ គឺបាណាតិបាត តាំងនៅក្នុងកម្មមិនស្មើគឺអទិន្នាទាន តាំងនៅក្នុងកម្មមិនស្មើ គឺកាមេសុមិច្ឆាចារ តាំងនៅក្នុងកម្មមិនស្មើ គឺ មុសាវាទ តាំងនៅក្នុងកម្មមិនស្មើ គឺបិសុណវាចា តាំងនៅក្នុងកម្មមិនស្មើ គឺផរុសវាចា តាំងនៅក្នុងកម្មមិនស្មើ គឺសម្ផប្បលាបៈ តាំងនៅក្នុងកម្មមិនស្មើ គឺអភិជ្ឈា តាំងនៅក្នុងកម្មមិនស្មើ គឺព្យាបាទ តាំងនៅក្នុងកម្មមិនស្មើ គឺមិច្ឆាទិដ្ឋិ តាំងនៅក្នុងកម្មទាំងឡាយមិនស្មើ គឺសង្ខារ តាំងនៅ ជាប់ ជាប់ស្អិត ចូលទៅដល់ស៊ប់ លិចចុះ ចុះចិត្តស៊ប់ ក្នុងកម្មមិនស្មើ គឺ កាមគុណ ៥ ហេតុនោះ (លោកពោលថា) អ្នកឃើញ នូវអំពើមិនមានប្រយោជន៍ អ្នកតាំងនៅក្នុងអំពើមិនស្មើ ។

ខគ្គវិសាណសុត្តនិទ្ទេសោ

(៣១៩) សយំ ន សេវេ បសុតំ បមត្តន្តិ បសុតន្តិ យោបិ កាមេ ឯសតិ គវេសតិ បរិយេសតិ តច្ចរិតោ តព្ពហុលោ តគ្គរុកោ តន្និន្នោ តប្បោណោ តប្បព្ភារោ តទធិមុត្តោ តទាធិបតេយ្យោ សោបិ កាមបសុតោ ។ យោបិ តណ្ហាវសេន រូបេ បរិយេសតិ យោបិ តណ្ហាវសេន រូបេ បដិលភតិ យោបិ តណ្ហាវសេន រូបេ បរិភុញ្ជតិ សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ បរិភុញ្ជតិ តច្ចរិតោ តព្ពហុលោ តគ្គរុកោ តន្និន្នោ តប្បោណោ តប្បព្ភារោ តទធិមុត្តោ តទាធិបតេយ្យោ សោបិ កាមបសុតោ ។

## ខគ្គវិសាណសុត្តនិទ្ទេស

(៣១៩) អធិប្បាយពាក្យថា មិនត្រូវសេពគប់ នូវបុគ្គលអ្នកខ្វល់ខ្វាយ អ្នកធ្វេសប្រហែស ដោយខ្លួនឯង ត្រង់ពាក្យថា បុគ្គលអ្នកខ្វល់ខ្វាយ សេចក្តីថា បុគ្គលណា ដើររក ស្វែងរក ស្វះស្វែងរក នូវកាមទាំងឡាយ ជាអ្នកប្រព្រឹត្តកាមនោះ ច្រើនដោយកាមនោះ ធ្ងន់ក្នុងកាមនោះ ទេរទៅរកកាមនោះ ទោរទៅរកកាមនោះ ឈមទៅរកកាមនោះ ចុះចិត្តស៊ប់ក្នុងកាមនោះ យកកាមនោះជាអធិបតី បុគ្គលនោះឯង ឈ្មោះថាអ្នកខ្វល់ខ្វាយក្នុងកាម ។ បុគ្គលណាស្វះស្វែងរករូបទាំងឡាយ ដោយអំណាចតណ្ហាក្តី បុគ្គលណា បានរូបទាំងឡាយ ដោយអំណាចតណ្ហាក្តី បុគ្គលណា ប្រើប្រាស់រូបទាំងឡាយ ដោយអំណាចតណ្ហាក្តី ប្រើប្រាស់សម្លេង ក្លិន រស និងផោដ្ឋព្វៈ ដោយអំណាចតណ្ហាក្តី ជាអ្នកប្រព្រឹត្តអារម្មណ៍នោះ ច្រើនដោយអារម្មណ៍នោះ ធ្ងន់ក្នុងអារម្មណ៍នោះ ទេរទៅរកអារម្មណ៍នោះ ទោរទៅរកអារម្មណ៍នោះ ឈមទៅរកអារម្មណ៍នោះ ចុះចិត្តស៊ប់ក្នុងអារម្មណ៍នោះ យកអារម្មណ៍នោះជាអធិបតី បុគ្គលនោះឯង ក៏ឈ្មោះថាអ្នកខ្វល់ខ្វាយក្នុងកាមដែរ ។

បមត្តន្តិ បមាទោ វត្តព្វោ ។ កាយទុច្ចរិតេ វា វចីទុច្ចរិតេ វា មនោទុច្ចរិតេ វា បញ្ចសុ វា កាមគុណេសុ ចិត្តស្ស វោស្សគ្គោ វោស្សគ្គានុប្បទានំ កុសលានំ វា ធម្មានំ ភាវនាយ អសក្កច្ចកិរិយតា អសាតច្ចកិរិយតា អនដ្ឋិតកិរិយតា ឱលីនវុត្តិតា និក្ខិត្តច្ឆន្ទតា និក្ខិត្តធុរតា អនាសេវនា អភាវនា អពហុលីកម្មំ អនធិដ្ឋានំ អននុយោគោ យោ ឯវរូបោ បមាទោ បមជ្ជនា បមជ្ជិតត្តំ អយំ វុច្ចតិ បមាទោ ។ សយំ ន សេវេ បសុតំ បមត្តន្តិ បសុតញ្ច ន សេវេយ្យ បមត្តញ្ច ន សេវេយ្យ ន និសេវេយ្យ ន សំសេវេយ្យ ន បដិសេវេយ្យ ន អាចរេយ្យ ន សមាចរេយ្យ ន សមាទាយ វត្តេយ្យាតិ សយំ ន សេវេ បសុតំ បមត្តំ ។ ឯសោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

ពាក្យថា អ្នកធ្វេសប្រហែស គឺសេចក្តីធ្វេសប្រហែស ខ្ញុំគប្បីពោលដូចតទៅនេះ ។ ការបណ្តោយចិត្ត ការផ្តល់កម្លាំងដល់ការបណ្តោយចិត្ត ក្នុងកាយទុច្ចរិត ក្នុងវចីទុច្ចរិត ក្នុងមនោទុច្ចរិត ក្នុងកាមគុណទាំង ៥ ក្តី ពុំនោះសោត ការមិនធ្វើដោយផ្ចិតផ្ចង់ ការមិនធ្វើរឿយៗ ការមិនធ្វើឲ្យឋិតថេរ កិរិយាប្រព្រឹត្តរួញរា ការដាក់សេចក្តីប្រាថ្នា ការដាក់ធុរៈ ការមិនសេពគប់ ការមិនចម្រើន ការមិនធ្វើឲ្យច្រើន ការមិនអធិដ្ឋាន ការមិនប្រកបរឿយៗ ក្នុងការចម្រើននូវធម៌ទាំងឡាយជាកុសល សេចក្តីប្រហែស សេចក្តីធ្វេសប្រហែស ភាពនៃសេចក្តីធ្វេសប្រហែស មានសភាពយ៉ាងនេះឯណា នេះលោកហៅថា សេចក្តីធ្វេសប្រហែស ។ ពាក្យថា មិនគួរសេពគប់ នូវបុគ្គលអ្នកខ្ជិលខ្ជាយ អ្នកធ្វេសប្រហែស ដោយខ្លួនឯង បានសេចក្តីថា មិនគួរសេព នូវបុគ្គលអ្នកខ្ជិលខ្ជាយផង មិនគួរសេព មិនគួរគប់រក មិនគួរភប់រក មិនគួរភប់អាន មិនគួរប្រព្រឹត្តអើពើ មិនគួរប្រព្រឹត្តរួម មិនគួរប្រព្រឹត្តសមាទាន នូវបុគ្គលអ្នកធ្វេសប្រហែសផង ហេតុនោះ (លោកពោលថា) មិនគួរសេពគប់ នូវបុគ្គលអ្នកខ្ជិលខ្ជាយ អ្នកធ្វេសប្រហែស ដោយខ្លួនឯង ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ព្រោះហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

## ខគ្គវិសាណសុត្តនិទ្ទេសោ

បាបំ សហាយំ បរិវជ្ជយេថ
អនត្ថទស្សឹ វិសមេ និវិដ្ឋំ
សយំ ន សេវេ បសុតំ បមត្តំ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

(៣២០) ពហុស្សុតំ ធម្មធរំ ភជេថ
មិត្តំ ឧឡារំ បដិភាណវន្តំ
អញ្ញាយ អត្ថានិ វិនេយ្យ កង្ខំ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

(៣២១) ពហុស្សុតំ ធម្មធរំ ភជេថាតិ ពហុស្សុតន្តិ ពហុស្សុតោ សុតធរោ សុតសន្និចយោ យេ តេ ធម្មា អាទិកល្យាណា មជ្ឈេកល្យាណា បរិយោសានកល្យាណា សាត្ថា សព្យញ្ជនា កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ តថារូបស្ស ធម្មា ពហុស្សុតា ហោន្តិ ធតា វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា ។

## ខគ្គវិសាណសុត្តនិទ្ទេស

បុគ្គលគួរបៀសវាង នូវសំឡាញ់អាក្រក់ អ្នកឃើញនូវ
អំពើមិនមានប្រយោជន៍ អ្នកតាំងនៅក្នុងអំពើមិនស្មើ
មិនគួរសេពគប់ នូវបុគ្គលអ្នកខ្វល់ខ្វាយ អ្នកធ្វេស
ប្រហែស ដោយខ្លួនឯង គប្បីប្រព្រឹត្តម្នាក់ឯង ដូច
កុយរមាស ។

(៣២០) បុគ្គលគួរគប់រកជនជាពហុស្សូត អ្នកទ្រទ្រង់ធម៌
ជាមិត្តដ៏ខ្ពង់ខ្ពស់ មានបដិភាណ បុគ្គលបានដឹងច្បាស់
នូវប្រយោជន៍ទាំងឡាយហើយ គួរកំចាត់ នូវសេចក្តី
សង្ស័យ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(៣២១) អធិប្បាយពាក្យថា បុគ្គលគួរគប់រកជន ជាពហុស្សូត អ្នកទ្រទ្រង់ធម៌ ត្រង់ពាក្យថា ជនជាពហុស្សូត គឺ ជនអ្នកចេះដឹងច្រើន អ្នកចងចាំនូវសូត្រ សន្សំទុកនូវសូត្រ គឺថា ធម៌ទាំងឡាយណា មាន លំអបទដើម លំអបទកណ្តាល លំអបទចុង ព្រមទាំងអត្ថនិងព្យញ្ជនៈ ប្រកាសនូវព្រហ្មចរិយៈ ដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ធម៌ទាំងឡាយមានសភាពដូច្នោះ ជននោះបានស្តាប់ច្រើន បានទ្រទ្រង់ បានចាំស្ទាត់រត់មាត់ បានពិនិត្យមើលដោយចិត្ត បានចាក់ធ្លុះប្រពៃដោយសេចក្តីយល់ ។

ធម្មធរន្តិ ធម្មំ ធារេន្តិ សុត្តំ គេយ្យំ វេយ្យាករណំ គាថា ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លំ ។ ពហុស្សុតំ ធម្មធរំ ភជេថាតិ ពហុស្សុតញ្ច ធម្មធរញ្ច មិត្តំ ភជេយ្យ សេវេយ្យ និសេវេយ្យ សំសេវេយ្យ បដិសេវេយ្យាតិ ពហុស្សុតំ ធម្មធរំ ភជេថ ។

(៣៦៦) មិត្តំ ឧឡារំ បដិភាណវន្តន្តិ ឧឡារោ ហោតិ មិត្តោ សីលេន សមាធិនា បញ្ញាយ វិមុត្តិយា វិមុត្តិញាណទស្សនេន ។ បដិភាណវន្តន្តិ តយោ បដិភាណវន្តោ បរិយត្តិបដិភាណវា បរិបុច្ឆាបដិភាណវា អធិគមបដិភាណវា ។

កតមោ បរិយត្តិបដិភាណវា ។ ឥធេកច្ចស្ស ពុទ្ធវចនំ បរិយាបុដំ ហោតិ សុត្តំ គេយ្យំ វេយ្យាករណំ គាថា ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លំ តស្ស បរិយត្តិំ និស្សាយ បដិភាតិ អយំ បរិយត្តិបដិភាណវា ។

ពាក្យថា អ្នកទ្រទ្រង់ធម៌ សេចក្តីថា អ្នកទ្រទ្រង់នូវធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ ។ ពាក្យថា បុគ្គលគួរគប់រកជនជាពហុស្សូត អ្នកទ្រទ្រង់ធម៌ បានសេចក្តីថា បុគ្គលគួរគប់រក គួរសេព គួរភប់រក គួរភប់អាន គួរសេពចំពោះ នូវមិត្តជាពហុស្សូតផង អ្នកទ្រទ្រង់ធម៌ផង ហេតុនោះ (លោកពោលថា) បុគ្គលគួរគប់រកជនជាពហុស្សូត អ្នកទ្រទ្រង់ធម៌ ។

(៣២២) ពាក្យថា ជាមិត្តដ៏ខ្ពង់ខ្ពស់ មានបដិភាណ អធិប្បាយថា ជនជាមិត្តដ៏ខ្ពង់ខ្ពស់ ដោយសីល សមាធិ បញ្ញា វិមុត្តិ វិមុត្តិញាណទស្សនៈ ។ ពាក្យថា មានបដិភាណ គឺជនមានបដិភាណ ៣ ពួក គឺមានបដិភាណក្នុងបរិយត្តិ ១ មានបដិភាណក្នុងបរិបុច្ឆា ១ មានបដិភាណក្នុងអធិគមៈ ១ ។

ជនអ្នកមានបដិភាណក្នុងបរិយត្តិ តើដូចម្តេច ។ ជនខ្លះក្នុងសាសនានេះ បានរៀននូវពុទ្ធវចនៈ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ (ពុទ្ធវចនៈនោះ) រមែងភ្លឺច្បាស់ដល់ជននោះ ព្រោះអាស្រ័យបរិយត្តិ នេះឈ្មោះថាអ្នកមានបដិភាណក្នុងបរិយត្តិ ។

### ខគ្គវិសាណសុត្តនិទ្ទេសោ

កតមោ បរិបុច្ឆាបដិភាណវា ។ ឥធេកច្ចោ បរិបុច្ឆិតោ ហោតិ អត្ថេ ច ញាយេ ច លក្ខណេ ច ការណេ ច ឋានាឋានេ ច តស្ស បរិបុច្ឆំ និស្សាយ បដិភាតិ អយំ បរិបុច្ឆាបដិភាណវា ។

កតមោ អធិគមប្បដិភាណវា ។ ឥធេកច្ចស្ស អធិគតា ហោន្តិ ចត្តារោ សតិប្បដ្ឋានា ចត្តារោ សម្មប្បធានា ចត្តារោ ឥទ្ធិបាទា បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ ចត្តារោ អរិយមគ្គា ចត្តារិ សាមញ្ញផលានិ ចតស្សោ បដិសម្ភិទាយោ ឆឡភិញ្ញាយោ ។ តស្ស អត្ថោ ញាតោ ធម្មោ ញាតោ និរុត្តិ ញាតា ។ អត្ថេ ញាតេ អត្ថោ បដិភាតិ(១) ធម្មេ ញាតេ ធម្មោ បដិភាតិ(២) និរុត្តិយា ញាតាយ និរុត្តិ បដិភាតិ(៣) ។ ឥមេសុ តីសុ ញាណំ បដិភាណប្បដិសម្ភិទា ។

---

១ ២ ៣ ម. បដិភាយតិ ។

## ខគ្គវិសាណសុត្តនិទ្ទេស

ជនអ្នកមានបដិភាណ ក្នុងបរិបុច្ឆា តើដូចម្តេច ។ ជនខ្លះក្នុងសាសនានេះ ជាអ្នកសាកសួរក្នុងអត្ថ ក្នុងធម៌ដែលគួរដឹង ក្នុងលក្ខណៈ ក្នុងហេតុ ក្នុងឋានៈនិងអដ្ឋានៈ (សភាវៈមានអត្ថជាដើម) រមែងភ្លឺច្បាស់ដល់ជននោះ ព្រោះអាស្រ័យការសាកសួរ នេះ ឈ្មោះថាអ្នកមានបដិភាណក្នុងបរិបុច្ឆា ។

ជនអ្នកមានបដិភាណ ក្នុងអធិគមៈ តើដូចម្តេច ។ ជនខ្លះក្នុងសាសនានេះ បានត្រាស់ដឹងនូវសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គដ៏ប្រសើរ ប្រកបដោយអង្គ ៨ អរិយមគ្គ ៤ សាមញ្ញផល ៤ បដិសម្ភិទា ៤ អភិញ្ញា ៦ ។ បុគ្គលនោះ បានដឹងអត្ថ ដឹងធម៌ ដឹងនិរុត្តិ ។ កាលបើដឹងអត្ថហើយ អត្ថ រមែងច្បាស់ប្រាកដ កាលបើដឹងធម៌ហើយ ធម៌រមែងច្បាស់ប្រាកដ កាលបើដឹងនិរុត្តិហើយ និរុត្តិរមែងច្បាស់ប្រាកដ ។ ការដឹងក្នុងបដិភាណទាំង ៣ នេះ ឈ្មោះថាបដិភាណប្បដិសម្ភិទា ។

សោ បច្ចេកសម្ពុទ្ធោ ឥមាយ បដិភាណប្បដិសម្ភិទាយ ឧបេតោ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ តស្មា បច្ចេកសម្ពុទ្ធោ បដិភាណវា ។ យស្ស បរិយត្តិ នត្ថិ បរិបុច្ឆា នត្ថិ អធិគមោ នត្ថិ កឹ តស្ស បដិភាយិស្សតីតិ មុត្តិំ ឧឡារំ បដិភាណវន្តំ ។

(៣២៣) អញ្ញាយ អត្ថានិ វិនេយ្យ កង្ខំ អត្តត្ថំ អញ្ញាយ បរត្ថំ អញ្ញាយ ឧភយត្ថំ អញ្ញាយ ទិដ្ឋធម្មិកត្ថំ អញ្ញាយ សម្បរាយិកត្ថំ អញ្ញាយ(១) អភិញ្ញាយ ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វា កង្ខំ វិនេយ្យ បដិវិនេយ្យ បជហេយ្យ វិនោទេយ្យ ព្យន្តីករេយ្យ អនភាវង្គមេយ្យាតិ អញ្ញាយ អត្ថានិ វិនេយ្យ កង្ខំ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

១ ម. ឯត្ថន្តរេ បរមត្ថំ អញ្ញាយាតិ ទិស្សតិ ។

ព្រះបច្ចេកសម្ពុទ្ធនោះ ប្រកប ប្រកបព្រម ចូលទៅជិត ចូលទៅជិតព្រម ចូលទៅដល់ ចូលទៅដល់ព្រម ប្រកបព្រមដោយបដិភាណប្បដិសម្ភិទានេះ ព្រោះហេតុនោះ ព្រះបច្ចេកសម្ពុទ្ធ ឈ្មោះថាមានបដិភាណ ។ បុគ្គលណា មិនមានបរិយត្តិ មិនមានបរិបុច្ឆា មិនមានអធិគមៈ ធម្មជាតអ្វី នឹងច្បាស់ប្រាកដ ដល់បុគ្គលនោះបាន ហេតុនោះ (លោកពោលថា) ជាមិត្តដ៏ខ្ពង់ខ្ពស់ មានបដិភាណ ។

(៣២៣) ពាក្យថា បុគ្គលបានដឹងច្បាស់នូវប្រយោជន៍ទាំងឡាយហើយ គួរកំចាត់នូវសេចក្តីសង្ស័យ សេចក្តីថា បុគ្គលដឹងនូវប្រយោជន៍ខ្លួន ដឹងនូវប្រយោជន៍ជនដទៃ ដឹងនូវប្រយោជន៍ទាំងពីរ ដឹងនូវប្រយោជន៍បច្ចុប្បន្ន ដឹង ដឹងច្បាស់ ស្គាល់ ថ្លឹង ត្រិះរិះ ធ្វើឲ្យច្បាស់ ធ្វើឲ្យប្រាកដនូវប្រយោជន៍ក្នុងលោកខាងមុខហើយ គួរកំចាត់ បំបាត់ចេញ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាន នូវសេចក្តីសង្ស័យ ហេតុនោះ (លោកពោលថា) បុគ្គលបានដឹងច្បាស់នូវប្រយោជន៍ទាំងឡាយហើយ គួរកំចាត់នូវសេចក្តីសង្ស័យ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

ខគ្គវិសាណសុត្តនិទ្ទេសោ

ពហុស្សុតំ ធម្មធរំ ភជេថ

មិត្តំ ឧឡារំ បដិភាណវន្តំ

អញ្ញាយ អត្ថានិ វិនេយ្យ កង្ខំ

ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

(៣២៤) ខិឌ្ឌា រតី កាមសុខញ្ច លោកេ

អនលង្ករិត្វា អនបេក្ខមានោ

វិភូសដ្ឋានា វិរតោ សច្ចវាទី

ឯកោ ចរេ ខគ្គវិសាណកប្បោ ។

(៣២៥) ខិឌ្ឌា រតី កាមសុខញ្ច លោកេតិ ខិឌ្ឌាតិ ទ្វេ ខិឌ្ឌា កាយិកា ច ខិឌ្ឌា វាចសិកា ច ខិឌ្ឌា ។បេ។ អយំ កាយិកា ខិឌ្ឌា ។បេ។ អយំ វាចសិកា ខិឌ្ឌា ។

ខគ្គវិសាណសុត្តនិទ្ទេស

បុគ្គលគួរគប់រកជនជាពហុស្សូត អ្នកទ្រទ្រង់ធម៌ ជា
មិត្តដ៏ខ្ពង់ខ្ពស់ មានបដិភាណ បុគ្គលបានដឹងច្បាស់នូវ
ប្រយោជន៍ទាំងឡាយហើយ គួរកំចាត់ នូវសេចក្តី
សង្ស័យ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(៣២៨) បុគ្គលមិនអើពើ មិនអាឡោះអាល័យនូវល្បែង
នូវសេចក្តីត្រេកអរ នឹងកាមសុខក្នុងលោក ជាអ្នកវៀរ
ចាកគ្រឿងស្អិតស្អាង អ្នកពោលពាក្យពិត គប្បីប្រព្រឹត្ត
ម្នាក់ឯង ដូចកុយរមាស ។

(៣២៩) អធិប្បាយពាក្យថា នូវល្បែង នូវសេចក្តីត្រេកអរ នឹងកាមសុខក្នុងលោក ត្រង់ពាក្យថា ល្បែង បានដល់ល្បែង ២ យ៉ាង គឺ ល្បែងប្រកបដោយកាយ ១ ល្បែងប្រកបដោយវាចា ១ ។ បេ ។ នេះ ល្បែងប្រកបដោយកាយ ។ បេ ។ នេះ ល្បែងប្រកបដោយវាចា ។

រតីតិ អនុក្កណ្ឋិតាធិវចនមេតំ រតីតិ ។ កាម-សុខន្តិ វុត្តញ្ហេតំ ភគវតា បញ្ចិមេ ភិក្ខវេ កាមគុណា កតមេ បញ្ច ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមុបសញ្ហិតា រជនីយា សោតវិញ្ញេយ្យា សទ្ទា ឃានវិញ្ញេយ្យា គន្ធា ជិវ្ហាវិញ្ញេយ្យា រសា កាយវិញ្ញេយ្យា ផោដ្ឋព្វា ឥដ្ឋា កន្តា មនាបា បិយរូបា កាមុបសញ្ហិតា រជនីយា ឥមេ ខោ ភិក្ខវេ បញ្ច កាមគុណា យំ ខោ ភិក្ខវេ ឥមេ បញ្ច កាមគុណេ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ ឥទំ វុច្ចតិ កាមសុខន្តិ កាមសុខញ្ច ។ លោកេតិ មនុស្ស-លោកេតិ ខិឌ្ឌា រតី កាមសុខញ្ច លោកេ ។

ពាក្យថា សេចក្ដីត្រេកអរ ចំពោះពាក្យថា សេចក្ដីត្រេកអរ នេះ ជាឈ្មោះនៃសេចក្ដីមិនអផ្សុក ។ ពាក្យថា កាមសុខ សេចក្ដីថា មែនពិត ព្រះមានព្រះភាគ បានត្រាស់ព្រះពុទ្ធដីកានេះថា ម្នាលភិក្ខុទាំងឡាយ កាមគុណនេះ មាន ៥ កាមគុណ ៥ តើដូចម្ដេច រូប ដែលគប្បីដឹងដោយភ្នែក ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយសេចក្ដីប្រាថ្នា ជាទីតាំងនៃសេចក្ដីត្រេកអរ សំឡេង ដែលគប្បីដឹងដោយត្រចៀក ក្លិន ដែលគប្បីដឹងដោយច្រមុះ រស ដែលគប្បីដឹងដោយអណ្ដាត ផោដ្ឋព្វៈ ដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយសេចក្ដីប្រាថ្នា ជាទីតាំងនៃសេចក្ដីត្រេកអរ ម្នាលភិក្ខុទាំងឡាយ នេះឯង កាមគុណ ៥ ម្នាលភិក្ខុទាំងឡាយ សេចក្ដីសុខ សោមនស្សណា កើតឡើងព្រោះអាស្រ័យកាមគុណ ៥ នេះ សេចក្ដីសុខ សោមនស្សនេះ តថាគតហៅថា កាមសុខ ហេតុនោះ (លោកពោលថា) កាមសុខ ។ ពាក្យថា ក្នុងលោក គឺ ក្នុងមនុស្សលោក ហេតុនោះ (លោកពោលថា) នូវល្បែង នូវសេចក្ដីត្រេកអរ នឹងកាមសុខ ក្នុងលោក ។

ខគ្គវិសាណសុត្តនិទ្ទេសោ

(៣៦៦) អនលង្ករិត្វា អនបេក្ខមានោតិ ខិឌ្ឌញ្ច រតិញ្ច កាមសុខញ្ច លោកេ អនលង្ករិត្វា អនបេក្ខោ ហុត្វា បជហិត្វា វិនោទេត្វា ព្យន្តីករិត្វា អនភាវង្គមេត្វាតិ អនលង្ករិត្វា អនបេក្ខមានោ ។

(៣៦៧) វិភូសនដ្ឋានា វិរតោ សច្ចវាទីតិ វិភូសាតិ ទ្វេ វិភូសា អត្ថិ អាគារិកវិភូសា អត្ថិ អនាគារិកវិភូសា ។

កតមា អាគារិកវិភូសា ។ កេសា ច មស្សុ ច មាលា ច គន្ធា ច វិលេបនញ្ច អាភរណញ្ច បិលន្ធនញ្ច វត្ថញ្ច បសាធនញ្ច វេឋនញ្ច ឧច្ឆាទនំ បរិមទ្ទនំ នហាបនំ សម្ពាហនំ អាទាសំ អញ្ជនំ មាលាវិលេបនំ មុខចុណ្ណកំ មុខលេបនំ ហត្ថពន្ធំ សិខាពន្ធំ ទណ្ឌំ នាឡិកំ ខគ្គំ ឆត្តំ ឧបាហនា(១) ឧណ្ហីសំ ភលវិជ្ជនី(២) ឱទាតានិ វត្ថានិ ទីឃទសានិ ឥតិ វា អយំ អាគារិកវិភូសា ។

១ ម. ចិត្រុបាហនា ។ ២ ម. មណិភិឡុពិជ្ជនី ។

ខគ្គវិសាណសុត្តនិទ្ទេស

(៣៦៦) ពាក្យថា មិនអើពើ មិនអាឡោះអាល័យ សេចក្តីថា មិនអើពើ មិនអាឡោះអាល័យ គឺថាលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាន នូវល្បែងផង នូវសេចក្តីត្រេកអរផង នូវកាម-សុខផង ក្នុងលោក ហេតុនោះ (លោកពោលថា) មិនអើពើ មិនអាឡោះអាល័យ ។

(៣៦៧) អធិប្បាយពាក្យថា ជាអ្នកវៀរចាកគ្រឿងស្អិតស្អាង អ្នកពោលពាក្យពិត ត្រង់ពាក្យថា គ្រឿងស្អិតស្អាង សំដៅយក គ្រឿងស្អិតស្អាង ២ យ៉ាង គឺ គ្រឿងស្អិតស្អាងសម្រាប់គ្រហស្ថក៏មាន គ្រឿងស្អិតស្អាងសម្រាប់បព្វជិតក៏មាន ។

គ្រឿងស្អិតស្អាងសម្រាប់គ្រហស្ថ តើដូចម្តេច ។ សក់ ពុកមាត់ ពុកចង្កា ផ្កាកម្រង គ្រឿងក្រអូប គ្រឿងស្រឡាប គ្រឿងអាភរណៈ គ្រឿងប្រដាប់ សំពត់ គ្រឿងសំអាង ឆ្ពត គ្រឿងអប់ ការប្រហាប់រឹត ការផ្ងូតទឹក ការគក់ប្រហាប់ កញ្ចក់ គ្រឿងបន្តក់ កម្រងផ្កា គ្រឿងលាប លំអិតសម្រាប់ប្រស់មុខ វត្ថុសម្រាប់លាបមុខ គ្រឿងប្រដាប់ដៃ ប្រដាប់ផ្ពងសក់ ដំបង បំពង់ថ្នាំ ព្រះខ័ន ឆ័ត្រ ស្បែកជើង ក្បាំងមុខ ស៊ែ សំពត់ស វែងខ្លះ ខ្លីខ្លះ នេះគ្រឿងស្អិតស្អាងសម្រាប់គ្រហស្ថ ។

កតមា អនាគារិកវិភូសា(១) ។ ចីវរមណ្ឌនា បត្តមណ្ឌនា សេនាសនមណ្ឌនា ឥមស្ស វា បូតិកាយស្ស ពាហិរកានំ វា បរិក្ខារានំ មណ្ឌនា វិភូសនា កេឡនា បរិកេឡនា គេធិកតា គេធិកត្តំ ចបលនា(២) ចាបល្យំ អយំ អនាគារិកវិភូសា ។

សច្ចវាទីតិ សោ បច្ចេកសម្ពុទ្ធោ សច្ចវាទី សច្ចសន្ធោ ថេតោ បច្ចយិកោ អវិសំវាទកោ លោកស្ស វិភូសនដ្ឋានា អារតោ បដិវិរតោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរតីតិ វិភូសនដ្ឋានា វិរតោ សច្ចវាទី ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

ខិឌ្ឌា រតី កាមសុខញ្ច លោកេ
អនលង្ករិត្វា អនបេក្ខមានោ
វិភូសនដ្ឋានា វិរតោ សច្ចវាទី
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

---

១ ម. បព្វជិតស្ស វិភូសា ។ ២ ម. កេឡិតតា គេធិតា គេធិតត្តំ ចបលតា ។

គ្រឿងស្អិតស្អាងសម្រាប់បព្វជិត តើដូចម្តេច ។ គ្រឿងប្រដាប់ចីវរ គ្រឿងប្រដាប់បាត្រ គ្រឿងប្រដាប់សេនាសនៈ ការប្រដាប់ ការស្អិតស្អាង ការលេង ការលេងសព្វ ការជាប់ចិត្ត សេចក្តីជាប់ចិត្ត ការតាក់តែង សេចក្តីតាក់តែង នូវកាយស្អុយនេះ ឬនូវបរិក្ខារខាងក្រៅ នេះគ្រឿងស្អិតស្អាងសម្រាប់បព្វជិត ។

ពាក្យថា អ្នកពោលពាក្យពិត សេចក្តីថា ព្រះបច្ចេកសម្ពុទ្ធនោះ ជាអ្នកពោលពាក្យពិត តពាក្យពិត មានសំដីទៀង មានសំដីគួរជឿ មិនបោកប្រាសសត្វលោក គឺជាអ្នកនៅឆ្ងាយ វៀរស្រឡះ ឃ្លាតចេញ រលាស់ចេញ ផុតស្រឡះ ប្រាសចេញ ចាកគ្រឿងស្អិតស្អាង នៅដោយចិត្តដែលប្រាសចាកដែនគឺកិលេស ហេតុនោះ (លោកពោលថា) ជាអ្នកវៀរចាកគ្រឿងស្អិតស្អាង អ្នកពោលនូវពាក្យពិត ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ព្រោះហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

បុគ្គលមិនអើពើ មិនអាឡោះអាល័យនូវល្បែង នូវ
សេចក្តីត្រេកអរ នឹងកាមសុខក្នុងលោក ជាអ្នកវៀរ
ចាកគ្រឿងស្អិតស្អាង អ្នកពោលពាក្យពិត គប្បី
ប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

ខគ្គវិសាណសុត្តនិទ្ទេសោ

(៣២៨) បុត្តញ្ច ទារំ បិតរញ្ច មាតរំ
ធនានិ ធញ្ញានិ ច ពន្ធវានិ
ហិត្វាន(១) កាមានិ យថោធិកានិ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

(៣២៩) បុត្តញ្ច ទារំ បិតរញ្ច មាតរន្តិ បុត្តាតិ ចត្តារោ បុត្តា អត្រជោ បុត្តោ ខេត្តជោ បុត្តោ ទិន្នកោ បុត្តោ អន្តេវាសិកោ បុត្តោ ។ ទារា វុច្ចន្តិ ភរិយាយោ ។ បិតាតិ យោ សោ ជនកោ ។ មាតាតិ យា សា ជនិកាតិ បុត្តញ្ច ទារំ បិតរញ្ច មាតរំ ។

(៣៣០) ធនានិ ធញ្ញានិ ច ពន្ធវានីតិ ធនានិ វុច្ចន្តិ(២) មុត្តា មណិ វេឡុរិយោ សង្ខោ សិលា បវាឡំ រជតំ ជាតរូបំ លោហិតង្គោ មសារគល្លោ ។ ធញ្ញានិ វុច្ចន្តិ បុព្វណ្ណំ អបរណ្ណំ ។ បុព្វណ្ណំ នាម សាលិ វីហិ យវោ គោធុមោ កង្គុ វរកោ កុទ្រូសកោ ។ អបរណ្ណំ នាម សូបេយ្យំ ។

---

១ ម. ជហិត្វាន ។ ២ ម. ឯត្ថន្តរេ ហិរញ្ញំ សុវណ្ណន្តិ ទិស្សតិ ។

## ខគ្គវិសាណសុត្តនិទ្ទេស

(៣២៨) បុគ្គលលះបង់ នូវបុត្ត ប្រពន្ធ បិតា មាតា ទ្រព្យ ស្រូវ ផៅពង្ស នឹងកាមទាំងឡាយ តាមថ្នាក់ តាមជាន់ហើយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(៣២៩) ពាក្យថា បុត្ត ប្រពន្ធ បិតា មាតា ត្រង់ពាក្យថា បុត្ត បានដល់បុត្ត ៤ ពួក គឺ បុត្តកើតអំពីខ្លួន ១ បុត្តកើតក្នុងខេត្ត ១ បុត្តដែលគេឲ្យ ១ បុត្តគឺកូនសិស្ស ១ ។ ភរិយាទាំងឡាយ ហៅថា ប្រពន្ធ ។ ពាក្យថា បិតា បានដល់ បុរសអ្នកបង្កើតកូន ។ ពាក្យថា មាតា បានដល់ស្ត្រីអ្នកបង្កើតកូន ហេតុនោះ (លោកពោលថា) បុត្ត ប្រពន្ធ បិតា មាតា ។

(៣៣០) ពាក្យថា ទ្រព្យ ស្រូវ ផៅពង្ស គឺ កែវមុត្តា កែវមណី កែវពៃទូរ្យ សង្ខ ថ្ម កែវប្រពាឡ ប្រាក់ មាស កែវទទឹម កែវមរកត ហៅថា ទ្រព្យ ។ បុព្វណ្ណជាត(១) អបរណ្ណជាត(២) ហៅថា ស្រូវ ។ ស្រូវខ្សាយស ស្រូវខ្សាយក្រហម ស្រូវដំណើប ស្រងែ ស្ពៅ ស្កួយ គៃលលក ឈ្មោះថាបុព្វណ្ណជាត ។ គ្រឿងសម្ល ឈ្មោះថាអបរណ្ណជាត ។

---

១ វត្ថុដែលត្រូវបរិភោគមុន ។ ២ វត្ថុដែលត្រូវបរិភោគក្រោយ ។

ពន្ធវានីតិ ចត្តារោ ពន្ធវា ញាតិពន្ធវាបិ ពន្ធវា គោត្ត-ពន្ធវាបិ ពន្ធវា មិត្តពន្ធវាបិ ពន្ធវា សិប្បពន្ធវាបិ ពន្ធវាតិ ធនានិ ធញ្ញានិ ច ពន្ធវានិ ។

(៣៣១) ហិត្វាន កាមានិ យថោធិកានីតិ កាមាតិ ឧទ្ទានតោ ទ្វេ កាមា វត្ថុកាមា ច កិលេសកាមា ច ។ បេ ។ ឥមេ វុច្ចន្តិ វត្ថុកាមា ។ បេ ។ ឥមេ វុច្ចន្តិ កិលេសកាមា ។ ហិត្វាន កាមានីតិ វត្ថុកាមេ បរិជានិត្វា កិលេសកាមេ បហាយ បជហិត្វា វិនោទេត្វា ព្យន្តីករិត្វា អនភាវង្គមេត្វាតិ ហិត្វាន កាមានិ ។ យថោធិកានីតិ សោតាបត្តិមគ្គេន យេ កិលេសា បហីនា តេ កិលេសេន បុនេតិ ន បច្ចេតិ ន បច្ចាគច្ឆតិ សកទាគាមិមគ្គេន

ពាក្យថា ផៅពង្ស បានដល់ផៅពង្ស ៤ ពួក គឺ បុគ្គលជាប់ដោយញាតិ ឈ្មោះថាផៅពង្ស ១ បុគ្គលជាប់ដោយគោត្រ ឈ្មោះថាផៅពង្ស ១ បុគ្គលជាប់ដោយមិត្ត ឈ្មោះថាផៅពង្ស ១ បុគ្គលជាប់ដោយសិល្បៈ ឈ្មោះថាផៅពង្ស ១ ហេតុនោះ (លោកពោលថា) ទ្រព្យ ស្រូវ ផៅពង្ស ។

(៣៣១) អធិប្បាយពាក្យថា លះបង់កាមទាំងឡាយ តាមថ្នាក់តាមជាន់ ត្រង់ពាក្យថា កាម តាមឧទ្ទាន កាមមាន ២ គឺវត្ថុកាម ១ កិលេសកាម ១ ។ បេ ។ ទាំងនេះហៅថា វត្ថុកាម ។ បេ ។ ទាំងនេះហៅថា កិលេសកាម ។ ពាក្យថា លះបង់កាមទាំងឡាយ គឺ កំណត់ដឹងនូវវត្ថុកាម ហើយលះបង់ ផ្តាច់បង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាន នូវកិលេសកាម ហេតុនោះ (លោកពោលថា) លះបង់កាមទាំងឡាយ ។ ពាក្យថា តាមថ្នាក់តាមជាន់ គឺ កិលេសទាំងឡាយណា ដែលព្រះបច្ចេកសម្ពុទ្ធលះបង់ហើយ ដោយសោតាបត្តិមគ្គ លោកមិនមក មិនវិលមក មិនត្រឡប់មក កាន់កិលេសទាំងនោះទេ កិលេសទាំងឡាយណា ដែលលោកលះបង់ហើយ ដោយសកទាគាមិមគ្គ

យេ កិលេសា បហីនា អនាគាមិមគ្គេន យេ កិលេសា បហីនា អរហត្តមគ្គេន យេ កិលេសា បហីនា តេ កិលេសេ ន បុនេតិ ន បច្ចេតិ ន បច្ចាគច្ឆតីតិ ហិត្វាន កាមានិ យថោធិកានិ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

បុត្តញ្ច ទារំ បិតរញ្ច មាតរំ
ធនានិ ធញ្ញានិ ច ពន្ធវានិ
ហិត្វាន កាមានិ យថោធិកានិ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

(៣៣២) សង្គោ ឯសោ បរិត្តមេត្ថ សោខ្យំ
អប្បស្សាទោ ទុក្ខមេត្ថ ភិយ្យោ
គឡោ(១) ឯសោ ឥតិ ញត្វា មតិមា
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

---

១ ម. គណ្ឌោ ។

កិលេសទាំងឡាយណា ដែលលោកលះបង់ហើយ ដោយអនាគាមិមគ្គ កិលេសទាំងឡាយណា ដែលលោកលះបង់ហើយ ដោយអរហត្តមគ្គ លោកមិនមក មិនវិលមក មិនត្រឡប់មក កាន់កិលេសទាំងនោះទេ ហេតុនោះ (លោកពោលថា) លះបង់នូវកាមទាំងឡាយ តាមថ្នាក់តាមជាន់ ៗ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ៗ ព្រោះហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

បុគ្គលលះបង់ នូវបុត្ត ប្រពន្ធ បិតា មាតា ទ្រព្យ
ស្រូវ ផៅពង្ស នឹងកាមទាំងឡាយ តាមថ្នាក់តាម
ជាន់ហើយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ៗ

(៣៣២) កាមគុណនេះ ជាគ្រឿងចំពាក់ សេចក្តីសុខក្នុង
កាមគុណនេះ មានប្រមាណតិច កាមគុណនេះមាន
សេចក្តីត្រេកអរតិច សេចក្តីទុក្ខក្នុងកាមគុណនេះ មាន
ច្រើនក្រៃលែង កាមគុណនេះជាពក បុគ្គលអ្នកមាន
ប្រាជ្ញាបានដឹងដូច្នេះហើយ គប្បីប្រព្រឹត្តម្នាក់ឯង ដូច
កុយរមាស ៗ

(៣៣៣) សង្គោ ឯសោ បរិត្តមេត្ថ សោខ្យន្តិ សង្គោតិ វា ពឡិសន្តិ វា អាមិសន្តិ វា លគ្គនន្តិ វា បលិពោធោតិ វា បញ្ចន្នេតំ កាមគុណានំ អធិវចនំ ។ បរិត្តមេត្ថ សោខ្យន្តិ វុត្តញ្ហេតំ ភគវតា បញ្ចិមេ ភិក្ខវេ កាមគុណា កតមេ បញ្ច ចក្ខុវិ-ញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូ-បសញ្ហិតា រជនីយា សោតវិញ្ញេយ្យា សទ្ទា ឃាន-វិញ្ញេយ្យា គន្ធា ជិវ្ហាវិញ្ញេយ្យា រសា កាយវិញ្ញេយ្យា ផោដ្ឋព្វា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបស-ញ្ហិតា រជនីយា ឥមេ ខោ ភិក្ខវេ បញ្ច កាមគុណា

(៣៣៣) អធិប្បាយពាក្យថា កាមគុណនេះ ជាគ្រឿងបំពាក់ សេចក្តីសុខក្នុងកាមនេះ មានប្រមាណតិច ពាក្យថា គ្រឿងបំពាក់ក្តី ថាសន្ទូចក្តី ថានុយក្តី ថាគ្រឿងថ្ពក់ក្តី ថាកង្វល់ក្តី នេះជាឈ្មោះនៃកាមគុណទាំង ៥ ។ ពាក្យថា សេចក្តីសុខ ក្នុងកាមនេះ មានប្រមាណតិច សេចក្តីថា មែនពិត ព្រះមានព្រះភាគ បានត្រាស់ព្រះពុទ្ធដីកានេះថា ម្នាលភិក្ខុទាំងឡាយ កាមគុណនេះ មាន ៥ កាមគុណ ៥ តើដូចម្តេច រូប ដែលគប្បីដឹងដោយភ្នែក ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយសេចក្តីប្រាថ្នា ជាទីតាំងនៃសេចក្តីត្រេកអរ សំឡេង ដែលគប្បីដឹង ដោយត្រចៀក ក្លិន ដែលគប្បីដឹងដោយច្រមុះ រស ដែលគប្បីដឹង ដោយអណ្តាត ផ្សព្វ ដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយសេចក្តីប្រាថ្នា ជាទីតាំងនៃសេចក្តីត្រេកអរ ម្នាលភិក្ខុទាំងឡាយ ទាំងនេះឯង កាមគុណ ៥

ខគ្គវិសាណសុត្តនិទ្ទេសោ

យំ ខោ ភិក្ខវេ ឥមេ បញ្ច កាមគុណេ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ ឥទំ វុច្ចតិ កាមសុខំ អប្បកំ ឯតំ សុខំ(១) ឱមកំ ឯតំ សុខំ លាមកំ ឯតំ សុខំ ទុក្ខំ(២) ឯតំ សុខន្តិ សង្គោ ឯសោ បរិត្តមេត្ថ សោខ្យំ ។

[៣៣៤] អប្បស្សាទោ ទុក្ខមេត្ថ ភិយ្យោតិ អប្បស្សាទា កាមា វុត្តា ភគវតា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោ ។ អដ្ឋិកង្កលូបមា កាមា វុត្តា ភគវតា ។ មំសបេសូបមា កាមា វុត្តា ភគវតា ។ តិណុក្កូបមា កាមា វុត្តា ភគវតា ។ អង្គារកាសូបមា កាមា វុត្តា ភគវតា ។ សុបិនកូបមា កាមា វុត្តា ភគវតា ។ យាចិតកូបមា កាមា វុត្តា ភគវតា ។ រុក្ខផលូបមា កាមា វុត្តា ភគវតា ។

---

១ ម. ឯត្ថន្តរេ បរិត្តកំ ឯតំ សុខំ ហោមកំ ឯតំ សុខន្តិ ទិស្សន្តិ ។ ២ ម. ឆតុក្កំ ។

ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខ សោមនស្សណា កើតឡើង ព្រោះអាស្រ័យកាមគុណ ៥ នេះ សេចក្តីសុខ សោមនស្សនេះ តថាគតហៅថា កាមសុខ សេចក្តីសុខនេះ មានប្រមាណតិច សេចក្តីសុខនេះ ថោកទាប សេចក្តីសុខនេះ លាមក សេចក្តីសុខនេះ នាំមកនូវទុក្ខ ហេតុនោះ (លោកពោលថា) កាមគុណនេះ ជាគ្រឿងបំពាក់ សេចក្តីសុខក្នុងកាមនេះ មានប្រមាណតិច ។

(៣៣៤) ពាក្យថា កាមគុណនេះ មានសេចក្តីត្រេកអរតិច សេចក្តីទុក្ខក្នុងកាមគុណនេះ មានច្រើនក្រៃលែង អធិប្បាយថា កាមទាំងឡាយ ព្រះមានព្រះភាគត្រាស់ថា មានសេចក្តីត្រេកអរតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះមានច្រើនក្រៃលែង ។ កាមទាំងឡាយ ព្រះមានព្រះភាគត្រាស់ថា មានឧបមាដោយពន្លឹង ។ កាមទាំងឡាយ ព្រះមានព្រះភាគត្រាស់ថា មានឧបមាដោយដុំសាច់ ។ កាមទាំងឡាយ ព្រះមានព្រះភាគត្រាស់ថា មានឧបមាដោយគប់ភ្លើង ។ កាមទាំងឡាយ ព្រះមានព្រះភាគត្រាស់ថា មានឧបមាដោយរណ្តៅរងើកភ្លើង ។ កាមទាំងឡាយ ព្រះមានព្រះភាគត្រាស់ថា មានឧបមាដោយការយល់សប្ត ។ កាមទាំងឡាយ ព្រះមានព្រះភាគត្រាស់ថា មានឧបមាដោយរបស់ខ្ចីគេ ។ កាមទាំងឡាយព្រះមានព្រះភាគត្រាស់ថា មានឧបមាដោយផ្លែឈើ ។

អសិសូលូបមា កាមា វុត្តា ភគវតា ។ សត្តិសូលូ-
បមា កាមា វុត្តា ភគវតា ។ សប្បសិរូបមា
កាមា វុត្តា ភគវតា ពហុទុក្ខា ពហូបាយាសា
អាទីនវោ ឯត្ថ ភិយ្យោតិ អប្បស្សាទោ ទុក្ខ-
មេត្ថ ភិយ្យោ ។

(៣៣៨) កណ្ហា ឯសោ ឥតិ ញត្វា មតិមាតិ
កណ្ហាតិ វា ពឡិសន្តិ វា អាមិសន្តិ វា លគ្គនន្តិ វា
បលិពោធោតិ វា បញ្ចន្នេតំ(១) កាមគុណានំ អធិវ-
ចនំ ។ ឥតីតិ បទសន្ធិ បទសំសគ្គោ បទបារិបូរិ
អក្ខរសមវាយោ ព្យញ្ជនសិលិដ្ឋតា បទានុបុព្វតាមេតំ
ឥតីតិ ។ កណ្ហា ឯសោ ឥតិ ញត្វា មតិមាតិ មតិមា
បណ្ឌិតោ បញ្ញវា ពុទ្ធិមា ញាណី វិភាវី មេធាវី

---

១ បញ្ចន្នមេតំ ឥតិ មម មតិ ។

កាមទាំងឡាយ ព្រះមានព្រះភាគត្រាស់ថា មានឧបមាដោយកាំបិតនឹងជ្រញ់ ។ កាមទាំងឡាយ ព្រះមានព្រះភាគត្រាស់ថា មានឧបមាដោយចុងលំពែង ។ កាមទាំងឡាយ ព្រះមានព្រះភាគត្រាស់ថា មានឧបមាដោយក្បាលពស់ កាមទាំងឡាយមានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះ មានច្រើនក្រៃលែង ហេតុនោះ (លោកពោលថា) កាមមានសេចក្តីត្រេកអរតិច ទុក្ខក្នុងកាមនេះ មានច្រើនក្រៃលែង ។

(៣៣៥) អធិប្បាយពាក្យថា កាមគុណនេះជាពក បុគ្គលអ្នកមានប្រាជ្ញាដឹងដូច្នេះហើយ ពាក្យថា ពកក្តី ថាសន្ទូបក្តី ថានុយក្តី ថាកន្ទល់ក្តី នេះជាឈ្មោះនៃកាមគុណ ៥ ។ ពាក្យថា ដូច្នេះ ជាតំណបទ ជាពាក្យភ្ជាប់បទ ជាពាក្យបំពេញបទ ជាពាក្យប្រជុំអក្ខរៈ ជាពាក្យសម្រួលព្យញ្ជនៈ ពាក្យថា ដូច្នេះ នេះ ជាលំដាប់បទ ។ ពាក្យថា កាមគុណនេះ ជាពក បុគ្គលអ្នកមានប្រាជ្ញាដឹងដូច្នេះហើយ បានសេចក្តីថា គឺបុគ្គលអ្នកមានគំនិត ជាបណ្ឌិត មានប្រាជ្ញា មានការត្រាស់ដឹង មានញាណ មានប្រាជ្ញាភ្លឺច្បាស់ មានប្រាជ្ញាជាគ្រឿងទំលាយ

### ខគ្គវិសាណសុត្តនិទ្ទេសោ

គណ្ឌោតិ ញត្វា ពឡិសន្តិ ញត្វា អាមិសន្តិ ញត្វា លគ្គនន្តិ ញត្វា បលិពោធោតិ ញត្វា ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា វិភូតំ កត្វាតិ គណ្ឌោ ឯសោ ឥតិ ញត្វា មតិមា ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

សង្គោ ឯសោ បរិត្តមេត្ថ សោខ្យំ
អប្បស្សាទោ ទុក្ខមេត្ថ ភិយ្យោ
គណ្ឌោ ឯសោ ឥតិ ញត្វា មតិមា
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

(៣៣៦) សន្ទាលយិត្វាន សញ្ញោជនានិ
ជាលំវ ភេត្វា សលិលម្ពុចារី
អគ្គីវ ទឌ្ឍំ អនិវត្តមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

ខគ្គវិសាណសុត្តនិទ្ទេស

នូវកិលេស ដឹងថាជាពក ដឹងថាជាសន្ទូច ដឹងថាជាទុយ ដឹងថាជាគ្រឿងជាប់ ដឹង យល់ ថ្លឹង ត្រិះរិះ ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដ ថាជាកន្លល់ ហេតុនោះ (លោកពោលថា) កាម-គុណនេះ ជាពក បុគ្គលអ្នកមានប្រាជ្ញា ដឹងដូច្នេះហើយ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

កាមគុណនេះ ជាគ្រឿងជំពាក់ សេចក្តីសុខ ក្នុង
កាមគុណនេះ មានប្រមាណតិច កាមគុណនេះមាន
សេចក្តីត្រេកអរតិច សេចក្តីទុក្ខ ក្នុងកាមគុណនេះ
មានច្រើនក្រៃលែង កាមគុណនេះជាពក បុគ្គលអ្នក
មានប្រាជ្ញា ដឹងដូច្នេះហើយ គប្បីប្រព្រឹត្តម្នាក់ឯង ដូច
កុយរមាស ។

(៣៣៦) បុគ្គលទំលាយនូវសំយោជនៈទាំងឡាយ ដូច
សត្វត្រាច់ទៅក្នុងទឹក ដែលទំលាយនូវបណ្តាញ គេ
មិនត្រឡប់មក (រកសំយោជនៈវិញ) ដូចភ្លើងឆេះ
(មិនត្រឡប់វិលវិញ) គប្បីប្រព្រឹត្តម្នាក់ឯង ដូច
កុយរមាស ។

(៣៣៧) សន្ទាលយិត្វាន សញ្ញោជនានីតិ ទស សញ្ញោជនានិ កាមរាគសញ្ញោជនំ បដិឃសញ្ញោជនំ មានសញ្ញោជនំ ទិដ្ឋិសញ្ញោជនំ វិចិកិច្ឆាសញ្ញោជនំ សីលព្វតបរាមាសសញ្ញោជនំ ភវរាគសញ្ញោជនំ ឥស្សាសញ្ញោជនំ មច្ឆរិយសញ្ញោជនំ អវិជ្ជាសញ្ញោជនំ ។ សន្ទាលយិត្វាន សញ្ញោជនានីតិ ទស សញ្ញោជនានិ ទាលយិត្វា សន្ទាលយិត្វា បជហិត្វា វិនោទេត្វា ព្យន្តីករិត្វា អនភាវង្គមេត្វាតិ សន្ទាលយិត្វាន សញ្ញោជនានិ ។

(៣៣៨) ជាលំវ ភេត្វា សលិលម្ពុចារីតិ ជាលំ វុច្ចតិ សុត្តជាលំ ។ សលិលំ វុច្ចតិ ឧទកំ ។ អម្ពុចារី វុច្ចតិ មច្ឆោ ។ ជាលំ ភិន្ទិត្វា សំភិន្ទិត្វា ទាលយិត្វា(១) បទាលយិត្វា សម្បទាលយិត្វា ចរតិ វិចរតិ ឥរិយតិ វត្តតិ បាលេតិ យបេតិ យាបេតិ ។

---

១ ម. ផាលយិត្វា ។

(៣៣៧) ពាក្យថា ទំលាយនូវសំយោជនៈទាំងឡាយ បានដល់សំយោជនៈទាំង ១០ គឺកាមរាគសំយោជនៈ បដិឃសំយោជនៈ មានសំយោជនៈ ទិដ្ឋិសំយោជនៈ វិចិកិច្ឆាសំយោជនៈ សីលព្វតបរាមាសសំយោជនៈ ភវរាគសំយោជនៈ ឥស្សាសំយោជនៈ មច្ឆរិយសំយោជនៈ អវិជ្ជាសំយោជនៈ ។ ពាក្យថា ទំលាយនូវសំយោជនៈទាំងឡាយ គឺទំលាយ ទំលាយចោល លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាន នូវសំយោជនៈទាំង ១០ ហេតុនោះ (លោកពោលថា) ទំលាយនូវសំយោជនៈទាំងឡាយ ។

(៣៣៨) ពាក្យថា ដូចសត្វត្រាច់ទៅក្នុងទឹក ដែលទំលាយនូវបណ្ដាញ អធិប្បាយថា សំណាញ់ដែលត្បាញដោយអំបោះ ហៅថា បណ្ដាញ ។ ទុទកៈ ហៅថា ទឹក ។ ត្រី ហៅថា សត្វត្រាច់ទៅក្នុងទឹក ។ ត្រីទំលាយ ទំលុះ ហែក ប្រឹងទំលាយ ប្រឹងទំលុះ នូវសំណាញ់ ហើយចរ ត្រាច់ ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ ។

ខគ្គវិសាណសុត្តនិទ្ទេសោ

ឯវមេវ ទ្វេ ជាលា តណ្ហាជាលញ្ច ទិដ្ឋិជាលញ្ច ។ បេ ។ ឥទំ តណ្ហាជាលំ ។ បេ ។ ឥទំ ទិដ្ឋិជាលំ ។ តស្ស បច្ចេកសម្ពុទ្ធស្ស តណ្ហាជាលំ បហីនំ ទិដ្ឋិជាលំ បដិនិស្សដ្ឋំ ។ តណ្ហាជាលស្ស បហីនត្តា ទិដ្ឋិជាលស្ស បដិនិស្សដ្ឋត្តា សោ បច្ចេកសម្ពុទ្ធោ រូបេ ន សជ្ជតិ សទ្ទេ ន សជ្ជតិ គន្ធេ ន សជ្ជតិ ។ បេ ។ ទិដ្ឋសុតមុតវិញ្ញាតព្វេសុ ធម្មេសុ ន សជ្ជតិ ន គយ្ហតិ ន ពជ្ឈតិ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរតីតិ ជាលំវ ភេត្វា សលិលម្ពុចារី ។

## ខគ្គវិសាណសុត្តនិទ្ទេស

បណ្ដាញមាន ២ គឺ បណ្ដាញគឺតណ្ហា ១ បណ្ដាញគឺទិដ្ឋិ ១ ។ បេ ។ នេះ បណ្ដាញគឺតណ្ហា ។ បេ ។ នេះបណ្ដាញគឺទិដ្ឋិ ។ ព្រះបច្ចេកសម្ពុទ្ធនោះ លះបង់នូវបណ្ដាញគឺតណ្ហា បានរលាស់ចោលនូវបណ្ដាញគឺទិដ្ឋិ ដូចត្រីទំលាយសំណាញ់យ៉ាងនោះឯង ។ ព្រោះលះបង់ នូវបណ្ដាញគឺតណ្ហា ព្រោះរលាស់ចោល នូវបណ្ដាញគឺទិដ្ឋិហើយ ទើបព្រះបច្ចេក-សម្ពុទ្ធនោះ មិនជាប់ក្នុងរូប មិនជាប់ក្នុងសំឡេង មិនជាប់ក្នុងក្លិន ។ បេ ។ មិនជាប់ មិនក្ពួចកាន់ មិនចំពាក់ក្នុងធម្មារម្មណ៍ ដែលឃើញ ឮ ប៉ះពាល់ ដឹងច្បាស់ គឺជាលោកឃ្លាតចេញ រលាស់ចេញ ផុតស្រឡះ មិនប្រកប នៅដោយចិត្តដែលប្រាសចាកដែន គឺកិលេស ហេតុនោះ (លោកពោលថា) ដូចសត្វត្រាច់ទៅក្នុងទឹក ដែលទំលាយនូវបណ្ដាញ ។

(៣៣៩) អគ្គីវ ទឌ្ឍំ អនិវត្តមានោតិ យថា អគ្គិ តិណកដ្ឋុបាទានំ ទហន្តោ គច្ឆតិ អនិវត្តន្តោ ឯវមេវ តស្ស បច្ចេកសម្ពុទ្ធស្ស សោតាបត្តិមគ្គេន យេ កិលេសា បហីនា តេ កិលេសេ ន បុនេតិ ន បច្ចេតិ ន បច្ចាគច្ឆតិ សកទាគាមិមគ្គេន យេ កិលេសា បហីនា អនាគាមិមគ្គេន យេ កិលេសា បហីនា អរហត្តមគ្គេន យេ កិលេសា បហីនា តេ កិលេសេ ន បុនេតិ ន បច្ចេតិ ន បច្ចាគច្ឆតីតិ អគ្គីវ ទឌ្ឍំ អនិវត្តមានោ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

សន្ទាលយិត្វាន សំយោជនានិ
ជាលំវ ភេត្វា សលិលម្ពុចារី
អគ្គីវ ទឌ្ឍំ អនិវត្តមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

(៣៣៩) ពាក្យថា មិនត្រឡប់មក (រកសំយោជនៈវិញ) ដូចភ្លើងឆេះ (មិនត្រឡប់វិលវិញ) អធិប្បាយថា ភ្លើងកាលឆេះនូវចំណីភ្លើង គឺស្មៅនិងឧស កាលទៅ មិនវិលត្រឡប់វិញ យ៉ាងណា ព្រះបច្ចេកសម្ពុទ្ធនោះ លះបង់កិលេសទាំងឡាយណា ដោយសោតាបត្តិមគ្គហើយ លោកមិនមក មិនវិលមក មិនត្រឡប់មករកកិលេសទាំងនោះទេ លោកលះបង់កិលេសទាំងឡាយណា ដោយសកទាគាមិមគ្គ លះបង់កិលេសទាំងឡាយណា ដោយអនាគាមិមគ្គ លះបង់កិលេសទាំងឡាយណា ដោយអរហត្តមគ្គ លោកមិនមក មិនវិលមក មិនត្រឡប់មករកកិលេសទាំងនោះទេ ក៏យ៉ាងនោះដែរ ហេតុនោះ (លោកពោលថា) ដូចភ្លើងឆេះ (មិនត្រឡប់វិលវិញ) ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

បុគ្គលទំលាយនូវសំយោជនៈទាំងឡាយ ដូចសត្វត្រាច់
ទៅក្នុងទឹក ដែលទំលាយនូវបណ្តាញ មិនត្រឡប់មក
(រកសំយោជនៈវិញ) ដូចភ្លើងឆេះ (មិនត្រឡប់វិលវិញ)
គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

## ខគ្គវិសាណសុត្តនិទ្ទេសោ

[៣៤០] ឱក្ខិត្តចក្ខុ ន ច បាទលោលោ
គុត្តិន្ទ្រិយោ រក្ខិតមានសានោ
អនវស្សុតោ អបរិឌយ្ហមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

[៣៤១] ឱក្ខិត្តចក្ខុ ន ច បាទលោលោតិ កថំ ខិត្តចក្ខុ ហោតិ ។ ឥធេកច្ចោ ចក្ខុលោលោ ចក្ខុលោលិយេន សមន្នាគតោ ហោតិ អទិដ្ឋំ ទក្ខិតព្វំ ទិដ្ឋំ សមតិក្កមិតព្វន្តិ អារាមេន អារាមំ ឧយ្យានេន ឧយ្យានំ គាមេន គាមំ និគមេន និគមំ នគរេន នគរំ រដ្ឋេន រដ្ឋំ ជនបទេន ជនបទំ ទីឃចារិកំ អន្វត្ថចារិកំ អនុយុត្តោ ហោតិ រូបទស្សនាយ ឯវំ ខិត្តចក្ខុ ហោតិ ។

ខគ្គវិសាណសុត្តនិទ្ទេស

(៣៤០) ភិក្ខុមានចក្ខុដាក់ចុះ ជាអ្នកមិនរពឹសជើង ជាអ្នកគ្រប់គ្រងឥន្ទ្រិយ រក្សាចិត្តទុក មានចិត្តមិនទទឹក មិនក្តៅក្រហាយ (ដោយកិលេស) គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(៣៤១) អធិប្បាយពាក្យថា ភិក្ខុមានចក្ខុដាក់ចុះ ជាអ្នកមិនរពឹសជើង សំនួរថា ភិក្ខុមានចក្ខុពោះទៅ តើដូចម្តេច ។ ភិក្ខុខ្លះក្នុងសាសនានេះ ជាអ្នករពឹសក្អែក ប្រកបដោយការរពឹសក្អែក ដោយគិតថា អាត្មាអញគប្បីឃើញ នូវរបស់ដែលមិនធ្លាប់ឃើញ គប្បីរំលងចោល នូវរបស់ ដែលធ្លាប់ឃើញហើយ ជាអ្នកប្រកបរឿយៗ នូវការត្រាច់ទៅឆ្ងាយ ៗ នូវការត្រាច់ទៅរឿយៗ ដើម្បីឃើញរូប គឺចេញអំពីអារាមទៅអារាម ចេញអំពីឧទ្យានទៅឧទ្យាន ចេញអំពីស្រុកទៅស្រុក ចេញអំពីនិគមទៅនិគម ចេញអំពីនគរទៅនគរ ចេញអំពីដែនទៅដែន ចេញអំពីជនបទទៅជនបទ ភិក្ខុជាអ្នកមានចក្ខុពោះទៅ យ៉ាងនេះឯង ។

អថវា ភិក្ខុ អន្តរឃរំ បវិដ្ឋោ វីថឹ បដិបន្នោ អសំវុតោ គច្ឆតិ ហត្ថឹ ឱលោន្តោ អស្សំ ឱលោកេន្តោ រថំ ឱលោកេន្តោ បត្តឹ ឱលោកេន្តោ កុមារកេ ឱលោកេន្តោ កុមារិកាយោ ឱលោកេន្តោ ឥត្ថិយោ ឱលោកេន្តោ បុរិសេ ឱលោកេន្តោ អន្តរាបណំ ឱលោកេន្តោ ឃរមុខានិ ឱលោកេន្តោ ឧទ្ធំ ឱលោកេន្តោ អធោ ឱលោកេន្តោ ទិសាវិទិសំ បេក្ខមានោ គច្ឆតិ ឯវម្បិ ខិត្តចក្ខុ ហោតិ ។ អថវា ចក្ខុនា រូបំ ទិស្វា និមិត្តគ្គាហី ហោតិ អនុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ ន បដិបជ្ជតិ ន រក្ខតិ ចក្ខុន្ទ្រិយំ ន ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ ឯវម្បិ ខិត្តចក្ខុ ហោតិ ។

មួយទៀត ភិក្ខុចូលទៅកាន់ចន្លោះផ្ទះ ដើរទៅកាន់ថ្នល់ មិនសង្រួមដើរទៅ ក្រឡេកមើលដំរី ក្រឡេកមើលសេះ ក្រឡេកមើលរថ ក្រឡេកមើលពលថ្មើរជើង ក្រឡេកមើលពួកក្មេងប្រុស ក្រឡេកមើលពួកក្មេងស្រី ក្រឡេកមើលពួកស្រី ក្រឡេកមើលពួកបុរស ក្រឡេកមើលរានផ្សារ ក្រឡេកមើលមុខផ្ទះ ក្រឡេកមើលលើ ក្រឡេកមើលក្រោម ក្រឡេកមើលកន្លងទិសតូចនិងទិសធំ ដើរទៅ ភិក្ខុជាអ្នកមានចក្ខុលោភទៅ យ៉ាងនេះខ្លះ ។ មួយទៀត ភិក្ខុឃើញនូវរូបដោយភ្នែក ជាអ្នកកាន់យកនូវនិមិត្ត កាន់យកនូវអនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្សដែលជាអកុសលធម៌លាមក គប្បីជាប់តាមភិក្ខុដែលមិនសង្រួម នូវចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនបានសង្រួមនូវចក្ខុន្ទ្រិយណា មិនប្រតិបត្តិដើម្បីសង្រួមនូវចក្ខុន្ទ្រិយនោះ មិនរក្សានូវចក្ខុន្ទ្រិយ មិនដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ភិក្ខុជាអ្នកមានចក្ខុលោភទៅ យ៉ាងនេះខ្លះ ។

## ខគ្គវិសាណសុត្តនិទ្ទេសោ

យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបំ វិសូកទស្សនំ អនុយុត្តា វិហរន្តិ សេយ្យថីទំ នច្ចំ គីតំ វាទិតំ បេក្ខំ អក្ខានំ បាណិស្សរំ វេតាឡំ កុម្ភថូណំ សោភណករកំ ចណ្ឌាលំ វំសំ ធោវនំ ហត្ថិយុទ្ធំ អស្សយុទ្ធំ មហិសយុទ្ធំ ឧសភយុទ្ធំ មេណ្ឌយុទ្ធំ កុក្កុដយុទ្ធំ ទណ្ឌយុទ្ធំ មុដ្ឋិយុទ្ធំ និព្ពុទ្ធំ ឧយ្យោធិកំ ពលគ្គំ សេនាព្យូហំ អនីកទស្សនំ ឥតិ វា ឯវរូបំ វិសូកទស្សនំ អនុយុត្តោ ហោតិ ឯវម្បិ ខិត្តចក្ខុ ហោតិ ។

កថំ ឱក្ខិត្តចក្ខុ ហោតិ ។ ឥធ ភិក្ខុ ន ចក្ខុលោលោ ចក្ខុលោលិយេន សមន្នាគតោ ហោតិ អទិដ្ឋំ ទក្ខិតព្ពំ ទិដ្ឋំ សមតិក្កមិតព្ពន្តិ ន អារាមេន អារាមំ ន ឧយ្យានេន ឧយ្យានំ ន គាមេន គាមំ

មួយវិញទៀត សមណព្រាហ្មណ៍ ដ៏ចំរើនពួកខ្លះ បរិភោគភោជន ដែលគេឲ្យដោយសទ្ធាហើយ សមណព្រាហ្មណ៍ទាំងនោះ តែងប្រកប រឿយៗ នូវការមើលរបស់ដែលជាសត្រូវ មានសភាពយ៉ាងនេះ គឺរបាំ ចម្រៀង ប្រគំ មហោស្រព ការនិយាយ (រឿងស្តេចការតៈនឹងព្រះរាម ជាដើម) គង រគាំង ស្គរមានជ្រុង ៤ រូបគំនូរ ល្បែងដុំដែក ល្បែងព៉ាវ ល្បែងលាងឆ្អឹង ប្រជល់ដំរី ប្រខាំសេះ ប្រជល់ក្របី ប្រជល់គោ ប្រជល់កែះ ប្រជល់មាន់ គុណដំបង ប្រដាល់ ចម្បាប់ ទីសម្រាប់ ច្បាំង ទីសម្រាប់រៀបពល ទីនៅសេនា ទីត្រួតកងទ័ព ភិក្ខុជាអ្នក ប្រកបរឿយ ៗ នូវការមើលរបស់ដែលជាសត្រូវ មានសភាពយ៉ាងនេះ ដូច្នេះៗខ្លះ ភិក្ខុជាអ្នកមានចក្ខុបោះទៅ យ៉ាងនេះខ្លះ ។

ភិក្ខុជាអ្នកមានចក្ខុដាក់ចុះ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ មិនមែនជាអ្នករពឹសក្អែក មិនមែនប្រកបដោយការរពឹសក្អែក ដោយ គិតថា អាត្មាអញគប្បីឃើញរបស់ដែលមិនដែលឃើញ គប្បីដើររំលង របស់ដែលបានឃើញហើយ ដូច្នេះទេ ជាអ្នកមិនប្រកបនូវការត្រាច់ទៅ ឆ្ងាយៗនូវការត្រាច់ទៅរឿយៗ ដើម្បីឃើញរូបទេ គឺមិនចេញអំពីអារាម ទៅអារាម មិនចេញអំពីឧទ្យានទៅឧទ្យាន មិនចេញអំពីស្រុកទៅស្រុក

ន និគមេន និគមំ ន នគរេន នគរំ ន រដ្ឋេន រដ្ឋំ ន ជនបទេន ជនបទំ ន ទីឃចារិកំ អន្វត្ថ-ចារិកំ អនុយុត្តោ ហោតិ រូបទស្សនាយ ឃរម្បិ ឱក្ខិត្តចក្ខុ ហោតិ ។ អថវា ភិក្ខុ អន្តរឃរំ បវិដ្ឋោ វីថឹ បដិបន្នោ សំវុតោ គច្ឆតិ ន ហត្ថឹ ឱលោកេន្តោ ន អស្សំ ឱលោកេន្តោ ន រថំ ឱលោកេន្តោ ន បត្តឹ ឱលោកេន្តោ ន កុមារកេ ឱលោកេន្តោ ន កុមារិកាយោ ឱលោកេន្តោ ន ឥត្ថិយោ ឱលោ-កេន្តោ ន បុរិសេ ឱលោកេន្តោ ន អន្តរាបណំ ឱលោកេន្តោ ន ឃរមុខានិ ឱលោកេន្តោ ន ឧទ្ធំ ឱលោកេន្តោ ន អធោ ឱលោកេន្តោ ន ទិសាវិទិសំ បេក្ខមានោ គច្ឆតិ ឃរម្បិ ឱក្ខិត្តចក្ខុ ហោតិ ។

មិនចេញអំពីនិគមទៅនិគម មិនចេញអំពីនគរទៅនគរ មិនចេញអំពីដែនទៅដែន មិនចេញអំពីជនបទទៅជនបទ ភិក្ខុជាអ្នកមានចក្ខុដាក់ចុះ យ៉ាងនេះខ្លះ ។ មួយទៀត ភិក្ខុចូលទៅកាន់ចន្លោះផ្ទះ ដើរទៅតាមថ្នល់ ជាអ្នកសង្រួមដើរទៅ មិនក្រឡេកមើលដំរី មិនក្រឡេកមើលសេះ មិនក្រឡេកមើលរថ មិនក្រឡេកមើលពលថ្មើរជើង មិនក្រឡេកមើលពួកក្មេងប្រុស មិនក្រឡេកមើលពួកក្មេងស្រី មិនក្រឡេកមើលពួកស្រី មិនក្រឡេកមើលពួកប្រុស មិនក្រឡេកមើលពនផ្សារ មិនក្រឡេកមើលមុខផ្ទះ មិនក្រឡេកមើលលើ មិនក្រឡេកមើលក្រោម មិនមៀងមើលក្នុងទិសតូចនឹងទិសធំ ដើរទៅ ភិក្ខុជាអ្នកមានចក្ខុដាក់ចុះ យ៉ាងនេះខ្លះ ។

ខគ្គវិសាណសុត្តនិទ្ទេសោ

អថវា ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ ឯវម្បិ ឱក្ខិត្តចក្ខុ ហោតិ ។ យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបំ វិសូកទស្សនំ អនុយុត្តា វិហរន្តិ សេយ្យថីទំ នច្ចំ គីតំ វាទិតំ ។ បេ ។ អនីកទស្សនំ ឥតិ វា ឯវរូបា វិសូកទស្សនានុយោគា បដិវិរតោ ហោតិ ឯវម្បិ ឱក្ខិត្តចក្ខុ ហោតិ ។

មួយទៀត ភិក្ខុឃើញរូបដោយភ្នែក តែជាអ្នកមិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្ស ដែលជាអកុសលធម៌ដ៏លាមក គប្បីជាប់តាមភិក្ខុដែលមិនសង្រួម នូវចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួមនូវចក្ខុន្ទ្រិយណា មិនប្រតិបត្តិដើម្បីសង្រួម នូវចក្ខុន្ទ្រិយនោះ រក្សានូវចក្ខុន្ទ្រិយ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ភិក្ខុជាអ្នកមានចក្ខុដាក់ចុះ យ៉ាងនេះខ្លះ ។ មួយវិញទៀត សមណព្រាហ្មណ៍ ដ៏ចំរើនពួកខ្លះបរិភោគភោជនដែលគេឲ្យដោយសទ្ធាហើយ សមណព្រាហ្មណ៍ទាំងនោះមិនប្រកបរឿយ ៗ នូវការមើលនូវល្បែង ដែលជាសត្រូវ មានសភាពយ៉ាងនេះ គឺរបាំ ចម្រៀង ប្រគំ ។បេ។ ទីសម្រាប់ត្រួតកងទ័ព ជាអ្នកវៀរចាកការប្រកបរឿយ ៗ នូវការមើលល្បែង ដែលជាសត្រូវ មានសភាពយ៉ាងនេះ ដូច្នេះៗ ភិក្ខុជាអ្នកមានចក្ខុដាក់ចុះ យ៉ាងនេះខ្លះ ។

ន ច បាទលោលោតិ កថំ បាទលោលោ ហោតិ ។ ឥធេកច្ចោ បាទលោលោ បាទលោលិយេន សមន្នាគតោ ហោតិ អារាមេន អារាមំ ឧយ្យានេន ឧយ្យានំ គាមេន គាមំ និគមេន និគមំ នគរេន នគរំ រដ្ឋេន រដ្ឋំ ជនបទេន ជនបទំ ទីឃចារិកំ អនវត្ថចារិកំ អនុយុត្តោ ហោតិ ឯវម្បិ បាទលោលោ ហោតិ ។ អថវា ភិក្ខុ អន្តោសង្ឃារាមេ បាទលោលិយេន សមន្នាគតោ ហោតិ ន អត្ថហេតុ ន ការណហេតុ ឧទ្ធតោ អវូបសន្តចិត្តោ បរិវេណតោ បរិវេណំ គច្ឆតិ វិហារតោ វិហារំ គច្ឆតិ អឌ្ឍយោគតោ អឌ្ឍយោគំ គច្ឆតិ បាសាទតោ បាសាទំ គច្ឆតិ ហម្មិយតោ ហម្មិយំ គច្ឆតិ គុហតោ គុហំ គច្ឆតិ លេណតោ លេណំ គច្ឆតិ កុដិយា កុដឹ គច្ឆតិ កូដាគារតោ កូដាគារំ គច្ឆតិ

អធិប្បាយពាក្យថា ជាអ្នកមិនរពឹសដើរ សំនួរថា ភិក្ខុជាអ្នករពឹសដើរ តើដូចម្តេច ។ ភិក្ខុខ្លះ ក្នុងសាសនានេះ ជាអ្នករពឹសដើរ ប្រកបដោយការរពឹសដើរ ជាអ្នកប្រកបរឿយៗ នូវការត្រាច់ទៅឆ្ងាយៗ នូវការត្រាច់ទៅរឿយៗ គឺចេញអំពីអារាមទៅអារាម ចេញអំពីឧទ្យានទៅឧទ្យាន ចេញអំពីស្រុកទៅស្រុក ចេញអំពីនិគមទៅនិគម ចេញអំពីនគរទៅនគរ ចេញអំពីដែនទៅដែន ចេញអំពីជនបទទៅជនបទ ភិក្ខុជាអ្នករពឹសដើរ យ៉ាងនេះខ្លះ ។ មួយយ៉ាងទៀត ភិក្ខុជាអ្នកប្រកបដោយការរពឹសដើរ តែខាងក្នុងអារាមរបស់សង្ឃ ជាអ្នកមានចិត្តលោភលន់ មានចិត្តមិនស្ងប់ មិនមែនព្រោះហេតុប្រយោជន៍ មិនមែនព្រោះហេតុដំណើរអ្វីទេ ចេញអំពីបរិវេណទៅបរិវេណ ចេញអំពីវិហារទៅវិហារ ចេញអំពីអឌ្ឍយោគ ទៅអឌ្ឍយោគ ចេញអំពីប្រាសាទទៅប្រាសាទ ចេញអំពីប្រាសាទត្រដិល ទៅប្រាសាទត្រដិល ចេញអំពីគុហាទៅគុហា ចេញអំពីលេណដ្ឋាន ទៅលេណដ្ឋាន ចេញអំពីខ្ទមទៅខ្ទម ចេញអំពីផ្ទះកំពូលទៅផ្ទះកំពូល

ខគ្គវិសាណសុត្តនិទ្ទេសោ

អដ្ដតោ អដ្ដំ គច្ឆតិ មាឡតោ មាឡំ គច្ឆតិ ឧទ្ទណ្ឌតោ ឧទ្ទណ្ឌំ គច្ឆតិ ឧទ្ទោសិតតោ ឧទ្ទោសិតំ គច្ឆតិ ឧបដ្ឋានសាលតោ ឧបដ្ឋានសាលំ គច្ឆតិ មណ្ឌបតោ មណ្ឌបំ គច្ឆតិ រុក្ខមូលតោ រុក្ខមូលំ គច្ឆតិ យត្ថ វា បន ភិក្ខូ និសីទន្តិ វា គច្ឆន្តិ វា តត្ថ ឯកស្ស វា ទុតិយោ ហោតិ ទ្វិន្នំ វា តតិយោ ហោតិ តិណ្ណំ វា ចតុត្ថោ ហោតិ តត្ថ ពហុំ សម្ផប្បលាបំ សល្លបតិ សេយ្យថីទំ រាជកថំ ចោរកថំ ។ បេ ។ ឥតិភវាភវកថំ ឥតិ វា ករេសិ ឯវម្បិ ឋានលោលោ ហោតិ ។ ន ច ឋានលោលោតិ សោ បច្ចេកសម្ពុទ្ធោ ឋានលោលិយា អារតោ វិរតោ បដិវិរតោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសំយុត្តោ វិមរិយាទិក-តេន ចេតសា វិហរតិ បដិសល្លានារាមោ ហោតិ

## ខគ្គវិសាណសុត្តនិទ្ទេស

ចេញអំពីប៉មទៅប៉ម ចេញអំពីរោងមូលទៅរោងមូល ចេញអំពីរោងដោលទៅរោងដោល ចេញអំពីឃ្លាំងរបស់ទៅឃ្លាំងរបស់ ចេញអំពីឧបដ្ឋានសា-លាទៅឧបដ្ឋានសាលា ចេញអំពីមណ្ឌបទៅមណ្ឌប ចេញអំពីគល់ឈើទៅគល់ឈើ បើពុំនោះទេ ពួកភិក្ខុអង្គុយឬដើរទៅក្នុងទីណា (ភិក្ខុនោះ) ជាគម្រប់ពីរនឹងភិក្ខុមួយរូបខ្លះ ជាគម្រប់បីនឹងភិក្ខុពីររូបខ្លះ ជាគម្រប់បួននឹងភិក្ខុបីរូបខ្លះ ក្នុងទីទាំងនោះ និយាយពាក្យឥតប្រយោជន៍ច្រើន ក្នុងទីនោះ គឺនិយាយ រាជកថា ចោរកថា ។ បេ ។ ឥតិភវាភវកថា ដូច្នេះៗ ភិក្ខុជាអ្នកព្រឹសដើន យ៉ាងនេះខ្លះ ។ ពាក្យថា ជាអ្នកមិនព្រឹសដើន សេចក្តីថា ព្រះបច្ចេកសម្ពុទ្ធនោះ នៅឆ្ងាយ វៀរ វៀរលែង ចេញ រលាស់ចេញ រួចផុត ប្រាសចេញ ចាកការព្រឹសដោយដើន មានព្រះទ័យមិនសល់វល់ មានការសម្ងំនៅ ក្នុងកម្មដ្ឋានជាទីត្រេកអរ

បដិសល្លានរតោ អជ្ឈត្តំ ចេតោសមថមនុយុត្តោ អនិរាកតជ្ឈានោ វិបស្សនាយ សមន្នាគតោ ព្រូហេតា សុញ្ញាគារានំ ឈាយី ឈានរតោ ឯកត្តមនុយុត្តោ សទត្ថគរុកោតិ ឱក្ខិត្តចក្ខុ ន ច បាទលោលោ ។

(៣៤២) គុត្តិន្ទ្រិយោតិ(១) សោ បច្ចេកសម្ពុទ្ធោ ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ សោតេន សទ្ទំ សុត្វា ឃានេន គន្ធំ ឃាយិត្វា ជិវ្ហាយ រសំ សាយិត្វា កាយេន ផោដ្ឋព្វំ ផុសិត្វា មនសា ធម្មំ វិញ្ញាយ

---

១ ម. គុត្តិន្ទ្រិយោ រក្ខិតមានសានោតិ គុត្តិន្ទ្រិយោតិ ។

ត្រេកអរក្នុងការសម្ងំ ប្រកបរឿយៗ នូវការស្ងប់ចិត្តក្នុងខាងក្នុង មិនឃ្លាតចាកឈាន ប្រកបដោយវិបស្សនា ចម្រើនសុញ្ញាគារដ្ឋាន ជាអ្នកមានឈាន ត្រេកអរក្នុងឈាន ប្រកបរឿយៗ នូវភាពនៃខ្លួនជាបុគ្គលម្នាក់ឯង ជាអ្នកធ្ងន់ក្នុងប្រយោជន៍របស់ខ្លួន ហេតុនោះ (លោកពោលថា) មានចក្ខុដាក់ចុះ ទាំងមិនរពឹសជើង ។

(៣៤២) ពាក្យថា អ្នកគ្រប់គ្រងឥន្ទ្រិយ អធិប្បាយថា ព្រះបច្ចេកសម្ពុទ្ធនោះ ឃើញរូបដោយភ្នែក មិនកាន់យកនិមិត្ត មិនកាន់យកអនុព្យញ្ជនៈ ពួកអកុសលធម៌ដ៏លាមក គឺ អភិជ្ឈានិងទោមនស្ស គប្បីជាប់តាមបុគ្គលមិនសង្រួមចក្ខុន្ទ្រិយនោះ ព្រោះហេតុមិនសង្រួមនូវចក្ខុន្ទ្រិយណា លោកប្រតិបត្តិដើម្បីសង្រួមចក្ខុន្ទ្រិយនោះ រក្សាចក្ខុន្ទ្រិយ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ឮសំឡេងដោយត្រចៀក ធុំក្លិនដោយច្រមុះ ទទួលរសដោយអណ្តាត ពាល់ត្រូវផោដ្ឋព្វៈដោយកាយ ដឹងធម្មារម្មណ៍ដោយចិត្ត

ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ មនិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ មនិន្ទ្រិយំ មនិន្ទ្រិយេ សំវរំ អាបជ្ជតីតិ គុត្តិន្ទ្រិយោ ។ រក្ខិតមានសានោតិ គោបិតមានសានោ រក្ខិតចិត្តោតិ គុត្តិន្ទ្រិយោ រក្ខិតមានសានោ ។

(៣៦៣) អនវស្សុតោ អបរិឌយ្ហមានោតិ អនវស្សុតោតិ វុត្តញ្ហេតំ អាយស្មតា មហាមោគ្គល្លានេន អវស្សុតបរិយាយញ្ច វោ អាវុសោ ទេសិស្សាមិ អនវស្សុតបរិយាយញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវមាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ មហាមោគ្គល្លានស្ស បច្ចស្សោសុំ ។

វគ្គវិសាណាសុត្តនិទ្ទេស

មិនកាន់យកនិមិត្ត មិនកាន់យកអនុព្យញ្ជនៈ ពួកអកុសលធម៌ ដ៏លាមក គឺអភិជ្ឈានឹងទោមនស្ស គប្បីជាប់តាមបុគ្គលអ្នកមិនសង្រួមមនិន្ទ្រិយនោះ ព្រោះហេតុមិនសង្រួមមនិន្ទ្រិយណា លោកប្រតិបត្តិដើម្បីសង្រួមមនិន្ទ្រិយនោះ រក្សានូវមនិន្ទ្រិយ ដល់នូវការសង្រួម ក្នុងមនិន្ទ្រិយ ហេតុនោះ (លោកពោលថា) ជាអ្នកគ្រប់គ្រងឥន្ទ្រិយ ។ ពាក្យថា រក្សាចិត្ត គឺគ្រប់គ្រងចិត្ត ថែទាំចិត្ត ហេតុនោះ (លោកពោលថា) ជាអ្នកគ្រប់គ្រងឥន្ទ្រិយ រក្សាចិត្ត ។

[៣៤៣] អធិប្បាយពាក្យថា មានចិត្តមិនទទឹក មិនពេលពល (ដោយកិលេស) ត្រង់ពាក្យថា មានចិត្តមិនទទឹក សេចក្តីថា ព្រះមហាមោគ្គល្លាន មានអាយុ បានពោលពាក្យនេះថា ម្នាលលោកមានអាយុ ខ្ញុំនឹងសំដែង នូវបរិយាយនៃបុគ្គលមានចិត្តទទឹកផង នូវបរិយាយនៃបុគ្គលមានចិត្តមិនទទឹកផង ចំពោះអ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់នូវបរិយាយនោះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ ខ្ញុំនឹងសំដែង ។ ភិក្ខុទាំងនោះ ទទួលស្តាប់ព្រះមហាមោគ្គល្លានមានអាយុថា អើ អាវុសោ ។

អាយស្មា មហាមោគ្គល្លានោ ឯតទវោច កថញ្ចាវុសោ អវស្សុតោ ហោតិ ឥធាវុសោ ភិក្ខុ ចក្ខុនា រូបំ ទិស្វា បិយរូបេ រូបេ អធិមុច្ចតិ អប្បិយរូបេ រូបេ ព្យាបជ្ជតិ អនុបដ្ឋិតកាយស្សតិ ច វិហរតិ បរិត្តចេតសោ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ នប្បជានាតិ យត្ថស្ស តេ ឧប្បន្នា បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ សោតេន សទ្ទំ សុត្វា ឃានេន គន្ធំ ឃាយិត្វា ជិវ្ហាយ រសំ សាយិត្វា កាយេន ផោដ្ឋព្វំ ផុសិត្វា មនសា ធម្មំ វិញ្ញាយ បិយរូបេ ធម្មេ អធិមុច្ចតិ អប្បិយរូបេ ធម្មេ ព្យាបជ្ជតិ អនុបដ្ឋិតកាយស្សតិ ច វិហរតិ បរិត្តចេតសោ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ នប្បជានាតិ យត្ថស្ស តេ ឧប្បន្នា បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ អយំ វុច្ចតាវុសោ ភិក្ខុ អវស្សុតោ ចក្ខុវិញ្ញេយ្យេសុ រូបេសុ អវស្សុតោ សោតវិញ្ញេយ្យេសុ សទ្ទេសុ ។ បេ ។

ព្រះមហាមោគ្គល្លានមានអាយុ បានពោលពាក្យនេះថា ម្នាលអាវុសោ បុគ្គលមានចិត្តទទឹក តើដូចម្តេច ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយភ្នែកហើយ ងប់ក្នុងរូបមានសភាពជាទីស្រឡាញ់ ស្អប់ក្នុងរូបមានសភាពមិនជាទីស្រឡាញ់ មិនប្រុងសតិក្នុងកាយ មានចិត្តស្តួចស្តើងផង អកុសលធម៌ដ៏លាមកទាំងនោះ កើតឡើងដល់បុគ្គលនោះហើយរលត់ទៅវិញ មិនសេសសល់ ក្នុងវិមុត្តិណា ក៏មិនដឹងច្បាស់នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិនោះតាមពិតផង ឮសំឡេងដោយត្រចៀក ធុំក្លិនដោយច្រមុះ ទទួលរសដោយអណ្តាត ពាល់ត្រូវសម្ផស្សដោយកាយ ដឹងធម្មារម្មណ៍ដោយចិត្តហើយ ងប់ក្នុងធម្មារម្មណ៍ មានសភាពជាទីស្រឡាញ់ ស្អប់ធម្មារម្មណ៍ ដែលមានសភាពមិនជាទីស្រឡាញ់ មិនប្រុងសតិក្នុងកាយ មានចិត្តស្តួចស្តើងផង អកុសលធម៌ដ៏លាមកទាំងនោះ កើតឡើងដល់បុគ្គលនោះ ហើយរលត់ទៅវិញមិនសេសសល់ ក្នុងវិមុត្តិណា ក៏មិនដឹងច្បាស់ នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិនោះតាមពិតផង ម្នាលអាវុសោ ភិក្ខុនេះ គេហៅថា អ្នកមានចិត្តទទឹក ក្នុងរូបដែលគប្បីដឹងដោយភ្នែក អ្នកមានចិត្តទទឹក ក្នុងសំឡេងដែលគប្បីដឹងដោយត្រចៀក ។ បេ ។

## ខគ្គវិសាណសុត្តនិទ្ទេសោ

អវស្សុតោ មនោវិញ្ញេយ្យេសុ ធម្មេសុ ឯវំវិហារឹ អា-
វុសោ ភិក្ខុំ ចក្ខុតោ ចេបិ នំ មារោ ឧបសង្កមតិ
លភេថេវ មារោ ឱតារំ លភតិ មារោ អារម្មណំ
សោតតោ ចេបិ នំ ។បេ។ មនតោ ចេបិ នំ
មារោ ឧបសង្កមតិ លភេថេវ មារោ ឱតារំ លភតិ
មារោ អារម្មណំ សេយ្យថាបិ អាវុសោ នឡាគារំ វា
តិណាគារំ វា សុក្ខំ កោឡាបំ តេរោវស្សិកំ(១) បុរត្ថិ-
មាយ ចេបិ នំ ទិសាយ បុរិសោ អាទិត្តាយ តិណុ-
ក្កាយ ឧបសង្កមេយ្យ លភេថេវ អគ្គិ ឱតារំ លភតិ
អគ្គិ អារម្មណំ បច្ឆិមាយ ចេបិ នំ ទិសាយ ឧត្តរា-
យ ចេបិ នំ ទិសាយ ទក្ខិណាយ ចេបិ នំ ទិសា-
យ ហេដ្ឋិមតោ ចេបិ នំ ឧបរិតោ ចេបិ នំ យតោកុ-
តោ ចេបិ នំ បុរិសោ អាទិត្តាយ តិណុក្កាយ ឧបស-
ង្កមេយ្យ លភេថេវ អគ្គិ ឱតារំ លភតិ អគ្គិ អារម្មណំ
ឯវមេវ ខោ អាវុសោ ឯវំវិហារឹ ភិក្ខុំ ចក្ខុតោ ចេបិ
នំ មារោ ឧបសង្កមតិ លភេថេវ មារោ ឱតារំ
លភតិ មារោ អារម្មណំ សោតតោ ចេបិ នំ ។បេ។

---

១ ម. តេរោវស្សិកន្តិ យុត្តតរំ ។

អ្នកមានចិត្តទទឹក ក្នុងធម្មារម្មណ៍ ដែលគប្បីដឹងដោយចិត្ត ម្នាលអាវុសោ ភិក្ខុមានកិរិយានៅយ៉ាងនេះ ប្រសិនបើ មារចូលទៅជិតភិក្ខុនោះ តាមទ្វារភ្នែក មារគង់បាននូវឱកាស មារគង់បាននូវអារម្មណ៍ ប្រសិនបើ (មារចូលទៅ) ជិតភិក្ខុនោះ តាមទ្វារត្រចៀក ។ បេ ។ ប្រសិនបើ មារចូលទៅជិតភិក្ខុនោះ តាមទ្វារចិត្ត មារគង់បាននូវឱកាស មារគង់បាននូវអារម្មណ៍ ម្នាលអាវុសោ ដូចផ្ទះបបុសក្តី ផ្ទះស្មៅក្តី ជាអាគារស្ងួត ពុក កន្លងយូរឆ្នាំ ប្រសិនបើ បុរសកាន់គប់ស្មៅ ដែលភ្លើងឆេះទៅជិតផ្ទះនោះ ពីទិសខាងកើត ភ្លើងតែងបាននូវឱកាស ភ្លើងតែងបាននូវអារម្មណ៍ ប្រសិនបើ (ទៅ) ជិតផ្ទះនោះ ពីទិសខាងលិច ប្រសិនបើ (ទៅ) ជិតផ្ទះនោះ ពីទិសខាងជើង ប្រសិនបើ (ទៅ) ជិត ផ្ទះនោះ ពីទិសខាងត្បូង ប្រសិនបើ (ទៅ) ជិតផ្ទះនោះ ពីខាងក្រោម ប្រសិនបើ (ទៅ) ជិតផ្ទះនោះពីខាងលើ ប្រសិនបើ បុរសកាន់គប់ស្មៅដែលភ្លើងឆេះ ទៅជិតផ្ទះនោះ ពីទិសខាងណាក៏ដោយ ភ្លើងតែងបាននូវឱកាស ភ្លើងតែងបាននូវអារម្មណ៍ មានឧបមាយ៉ាងណាមិញ ម្នាលអាវុសោ ភិក្ខុមានកិរិយានៅយ៉ាងនេះ ប្រសិនបើ មារចូលទៅជិតភិក្ខុនោះតាមទ្វារភ្នែក មារគង់បាននូវឱកាស មារគង់បាននូវអារម្មណ៍ ប្រសិនបើ (មារចូលទៅ) ជិតភិក្ខុនោះ តាមទ្វារត្រចៀក ។ បេ ។

មនតោ ចេបិ នំ មារោ ឧបសង្កមតិ លភតេវ មា-
រោ ឱតារំ លភតិ មារោ អារម្មណំ ឯវំវិហារិញ្ចាវុ-
សោ ភិក្ខុំ រូបា អភិភវិំសុ ន ភិក្ខុ រូបេ អភិភវិ
សទ្ទា ភិក្ខុំ អភិភវិំសុ ន ភិក្ខុ សទ្ទេ អភិភវិ គន្ធា
ភិក្ខុំ អភិភវិំសុ ន ភិក្ខុ គន្ធេ អភិភវិ រសា ភិក្ខុំ
អភិភវិំសុ ន ភិក្ខុ រសេ អភិភវិ ផោដ្ឋព្វា ភិក្ខុំ
អភិភវិំសុ ន ភិក្ខុ ផោដ្ឋព្វេ អភិភវិ ធម្មា ភិក្ខុំ
អភិភវិំសុ ន ភិក្ខុ ធម្មេ អភិភវិ អយំ វុច្ចតាវុសោ
ភិក្ខុ រូបាភិភូតោ សទ្ទាភិភូតោ គន្ធាភិភូតោ
រសាភិភូតោ ផោដ្ឋព្វាភិភូតោ អភិភូតោ តេហិ
កិលេសេហិ ន អភិភូ ហិ សោ បាបកេ
អកុសលេ ធម្មេ សង្កិលេសិកេ ពោនោព្ភវិកេ
សទរេ ទុក្ខវិបាកេ អាយតឹជាតិជរាមរណីយេ
ឯវំ ខោ អាវុសោ អវស្សុតោ ហោតិ ។

ប្រសិនបើមារចូលទៅជិតភិក្ខុនោះ តាមទ្វារចិត្ត មារតែងបាននូវឱកាស មារតែងបាន នូវអារម្មណ៍ មានឧបមេយ្យដូច្នោះឯង ម្នាលអាវុសោ រូបគ្របសង្កត់ភិក្ខុ អ្នកមានកិរិយានៅយ៉ាងនេះ ភិក្ខុមិនគ្របសង្កត់រូបបានឡើយ សំឡេងគ្របសង្កត់ភិក្ខុ ភិក្ខុមិនគ្របសង្កត់សំឡេងបានឡើយ ក្លិនគ្របសង្កត់ភិក្ខុ ភិក្ខុមិនគ្របសង្កត់ក្លិនបានឡើយ រសគ្របសង្កត់ភិក្ខុ ភិក្ខុមិនគ្របសង្កត់រសបានឡើយ ផ្សព្វគ្របសង្កត់ភិក្ខុ ភិក្ខុមិនគ្របសង្កត់ផ្សព្វបានឡើយ ធម្មារម្មណ៍គ្របសង្កត់ភិក្ខុ ភិក្ខុមិនគ្របសង្កត់ធម្មារម្មណ៍បានឡើយ ម្នាលអាវុសោ ភិក្ខុនេះ គេហៅថា អ្នកត្រូវរូបគ្របសង្កត់ អ្នកត្រូវសំឡេងគ្របសង្កត់ អ្នកត្រូវក្លិនគ្របសង្កត់ អ្នកត្រូវរសគ្របសង្កត់ អ្នកត្រូវផ្សព្វគ្របសង្កត់ អ្នកត្រូវពួកកិលេសទាំងនោះ គ្របសង្កត់ ព្រោះថា ភិក្ខុនោះ មិនបានគ្របសង្កត់នូវពួកអកុសលធម៌ដ៏លាមក ដែលប្រកបដោយសេចក្តីសៅហ្មង នាំទៅកើតក្នុងភពថ្មីទៀត ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានទុក្ខជាផល មានជាតិជរានឹងមរណៈតទៅខាងមុខទៀតទេ ម្នាលអាវុសោ ភិក្ខុមានចិត្តទទឹក យ៉ាងនេះឯង ។

## ខគ្គវិសាណសុត្តនិទ្ទេសោ

កថញ្ចាវុសោ អនវស្សុតោ ហោតិ។ ឥធាវុសោ ភិក្ខុ ចក្ខុនា រូបំ ទិស្វា បិយរូបេ រូបេ នាធិមុច្ចតិ អប្បិយរូបេ រូបេ ន ព្យាបជ្ជតិ ឧបដ្ឋិតកាយស្សតិ ច វិហរតិ អប្បមាណចេតសោ តញ្ច ចេតោវិមុត្តិំ បញ្ញាវិមុត្តិំ យថាភូតំ បជានាតិ យត្ថស្ស តេ ឧប្បន្នា បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ សោតេន សទ្ទំ សុត្វា ។បេ។ មនសា ធម្មំ វិញ្ញាយ បិយរូបេ ធម្មេ នាធិមុច្ចតិ អប្បិយរូបេ ធម្មេ ន ព្យាបជ្ជតិ ឧបដ្ឋិតកាយស្សតិ ច វិហរតិ អប្បមាណចេតសោ តញ្ច ចេតោវិមុត្តិំ បញ្ញាវិមុត្តិំ យថាភូតំ បជានាតិ យត្ថស្ស តេ ឧប្បន្នា បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ អយំ វុច្ចតាវុសោ ភិក្ខុ អនវស្សុតោ ចក្ខុវិញ្ញេយ្យេសុ រូបេសុ អនវស្សុតោ សោតវិញ្ញេយ្យេសុ សទ្ទេសុ ។បេ។ អនវស្សុតោ មនោវិញ្ញេយ្យេសុ ធម្មេសុ ឯវំវិហារី ចាវុសោ ភិក្ខុ ចក្ខុតោ ចេបិ នំ មារោ ឧបសង្កមតិ

## ខគ្គវិសាណសុត្តនិទ្ទេស

ម្នាលអាវុសោ ភិក្ខុមានចិត្តមិនទទឹក តើដូចម្តេច ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយភ្នែក មិនជាប់ក្នុងរូបមានសភាពជាទីស្រឡាញ់ មិនស្អប់រូប មិនជាទីស្រឡាញ់ ប្រុងសតិក្នុងកាយ មានចិត្តប្រមាណមិនបានផង អកុសលធម៌ដ៏លាមកទាំងនោះ កើតឡើងដល់បុគ្គលនោះហើយ រលត់ទៅមិនមានសេសសល់ ក្នុងវិមុត្តិណា ក៏ដឹងច្បាស់នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិនោះ តាមពិតផង ឮសំឡេងដោយត្រចៀក ។ បេ ។ ដឹងធម្មារម្មណ៍ដោយចិត្ត មិនជាប់ក្នុងធម្មារម្មណ៍មានសភាពជាទីស្រឡាញ់ មិនស្អប់ធម្មារម្មណ៍ មានសភាពមិនជាទីស្រឡាញ់ ប្រុងសតិក្នុងកាយ មានចិត្តប្រមាណមិនបានផង អកុសលធម៌ដ៏លាមកទាំងនោះ កើតឡើងដល់បុគ្គលនោះហើយ រលត់ទៅមិនមានសេសសល់ក្នុងវិមុត្តិណា ក៏ដឹងច្បាស់នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិនោះ តាមពិតផង ម្នាលអាវុសោ ភិក្ខុនេះ គេហៅថា អ្នកមានចិត្តមិនទទឹក ក្នុងរូប ដែលគប្បីដឹងដោយភ្នែក អ្នកមានចិត្តមិនទទឹក ក្នុងសំឡេង ដែលគប្បីដឹងដោយត្រចៀក ។ បេ ។ អ្នកមានចិត្តមិនទទឹក ក្នុងធម្មារម្មណ៍ ដែលគប្បីដឹងដោយចិត្ត ម្នាលអាវុសោ ភិក្ខុមានកិរិយានៅយ៉ាងនេះ ប្រសិនបើ មារចូលទៅជិតភិក្ខុនោះ តាមទ្វារភ្នែក

នេវ លភតិ មារោ ឱតារំ ន លភតិ មារោ អារម្មណំ សោតតោ ចេបិ នំ ។ បេ ។ មនតោ ចេបិ នំ មារោ ឧបសង្កមតិ នេវ លភតិ មារោ ឱតារំ ន លភតិ មារោ អារម្មណំ សេយ្យថាបិ អាវុសោ កូដាគារសាលា វា សន្ធាគារសាលា វា ពហលមត្តិកា អល្លាវលេបនា បុរត្ថិមាយ ចេបិ នំ ទិសាយ បុរិសោ អាទិត្តាយ តិណុក្កាយ ឧបសង្កមេយ្យ នេវ លភតិ អគ្គិ ឱតារំ ន លភតិ អគ្គិ អារម្មណំ បច្ឆិមាយ ចេបិ នំ ទិសាយ ឧត្តរាយ ចេបិ នំ ទិសាយ ទក្ខិណាយ ចេបិ នំ ទិសាយ ហេដ្ឋិមតោ ចេបិ នំ ឧបរិតោ ចេបិ នំ យតោ កុតោ ចេបិ នំ បុរិសោ អាទិត្តាយ តិណុក្កាយ ឧបសង្កមេយ្យ នេវ លភតិ អគ្គិ ឱតារំ ន លភតិ អគ្គិ អារម្មណំ ឯវមេវ ខោ អាវុសោ ឯវំវិហារី ភិក្ខុ ចក្ខុតោ ចេបិ នំ មារោ ឧបសង្កមតិ នេវ លភតិ មារោ ឱតារំ ន លភតិ មារោ អារម្មណំ សោតតោ ចេបិ នំ ។ បេ ។

មារមិនបាននូវឱកាស មារមិនបាននូវអារម្មណ៍ ប្រសិនបើមារ (ចូលទៅ) ជិតភិក្ខុនោះ តាមទ្វារត្រចៀក ។ បេ ។ ប្រសិនបើមារចូលទៅជិតភិក្ខុនោះ តាមទ្វារចិត្ត មារមិនបាននូវឱកាស មារមិនបាននូវអារម្មណ៍ ម្នាលអាវុសោ ប្រៀបដូចកូដាគារសាលាក្តី សណ្ឋាគារសាលាក្តី ដែលបូកដោយដីដ៏ក្រាស់ លាបដោយអាចម៍គោស្រស់ ប្រសិនបើ បុរសកាន់គប់ស្មៅដែលភ្លើងឆេះ ទៅជិតសាលានោះពីទិសខាងកើត ភ្លើងមិនបាននូវឱកាស ភ្លើងមិនបាននូវអារម្មណ៍ ប្រសិនបើ ទៅជិតសាលានោះពីទិសខាងលិច ប្រសិនបើ ទៅជិតសាលានោះ ពីទិសខាងជើង ប្រសិនបើ ទៅជិតសាលានោះពីទិសខាងត្បូង ប្រសិនបើ ទៅជិតសាលានោះពីខាងក្រោម ប្រសិនបើ ទៅជិតសាលានោះពីខាងលើ ប្រសិនបើ បុរសកាន់គប់ស្មៅ ដែលភ្លើងឆេះ ទៅជិតសាលានោះពីទិសខាងណាក៏ដោយ ភ្លើងមិនបាននូវឱកាស ភ្លើងមិនបាននូវអារម្មណ៍ មានឧបមាយ៉ាងណាមិញ ម្នាលអាវុសោ ភិក្ខុមានកិរិយានៅយ៉ាងនេះ ប្រសិនបើមារចូលទៅជិតភិក្ខុនោះតាមទ្វារភ្នែក មារមិនបាននូវឱកាស មារមិនបាននូវអារម្មណ៍ ប្រសិនបើ (ចូលទៅ) ជិតភិក្ខុនោះតាមទ្វារត្រចៀក ។ បេ ។

### ខគ្គវិសាណសុត្តនិទ្ទេសោ

មនតោ ចេបិ នំ មារោ ឧបសង្កមតិ នេវ លភតិ មារោ ឱតារំ ន លភតិ មារោ អារម្មណំ ឯវំវិហារិញ្ចាវុសោ ភិក្ខុំ ន រូបា អភិភវឹសុ ភិក្ខុ រូបេ អភិភវិ ន សទ្ទា ភិក្ខុំ អភិភវឹសុ ភិក្ខុ សទ្ទេ អភិភវិ ។បេ។ ន ធម្មា ភិក្ខុំ អភិភវឹសុ ភិក្ខុ ធម្មេ អភិភវិ អយំ វុច្ចតាវុសោ ភិក្ខុ រូបាភិភូ សទ្ទាភិភូ គន្ធាភិភូ រសាភិភូ ផោដ្ឋព្ពាភិភូ ធម្មាភិភូ អនភិភូតោ តេហិ កិលេសេហិ អភិភូ ហិ សោ បាបកេ អកុសលេ ធម្មេ សង្កិលេសិកេ បោនោភវិកេ សទរេ ទុក្ខវិបាកេ អាយតឹជាតិជរាមរណីយេ ឯវំ ខោ អាវុសោ អនវស្សុតោ ហោតីតិ អនវស្សុតោ ។ អបរិឌយ្ហមានោតិ រាគគ្គិនា អបរិឌយ្ហមានោ ទោសគ្គិនា អបរិឌយ្ហមានោ មោហគ្គិនា អបរិឌយ្ហមានោតិ(១) អនវស្សុតោ អបរិឌយ្ហមានោ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

---

១ ម. អបរិឌយ្ហមានោតិ រាគជេន បរិឡាហេន អបរិឌយ្ហមានោ ទោសជេន បរិឡាហេន អបរិឌយ្ហមានោ មោហជេន បរិឡាហេន អបរិឌយ្ហមានោតិ ។

## ខគ្គវិសាណសុត្តនិទ្ទេស

ប្រសិនបើ មារចូលទៅជិតភិក្ខុនោះតាមទ្វារចិត្ត មារមិនបាននូវឱកាស មារមិនបាននូវអារម្មណ៍ មានឧបមេយ្យដូច្នោះឯង ម្នាលអាវុសោ រូបមិនគ្រប់សង្កត់ភិក្ខុ ដែលមានកិរិយានៅយ៉ាងនេះ ភិក្ខុគ្រប់សង្កត់រូប សំឡេងមិនគ្រប់សង្កត់ភិក្ខុ ភិក្ខុគ្រប់សង្កត់សំឡេង ។ បេ ។ ធម្មារម្មណ៍មិនគ្រប់សង្កត់ភិក្ខុ ភិក្ខុគ្រប់សង្កត់ធម្មារម្មណ៍ ម្នាលអាវុសោ ភិក្ខុនេះ គេហៅថា អ្នកគ្រប់សង្កត់រូប អ្នកគ្រប់សង្កត់សំឡេង អ្នកគ្រប់សង្កត់ក្លិន អ្នកគ្រប់សង្កត់រស អ្នកគ្រប់សង្កត់ផោដ្ឋព្វៈ អ្នកគ្រប់សង្កត់ធម្មារម្មណ៍ អ្នកមិនត្រូវពួកកិលេសទាំងនោះ គ្រប់សង្កត់ទេ ព្រោះថា ភិក្ខុនោះគ្រប់សង្កត់ពួកអកុសលធម៌ដ៏លាមក ដែលប្រកបដោយសេចក្តីសៅហ្មង នាំឲ្យកើតក្នុងភពថ្មី ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានទុក្ខជាផល ជាទីតាំងនៃជាតិជរានិងមរណៈតទៅ ម្នាលអាវុសោ ភិក្ខុមានចិត្តមិនទទឹក យ៉ាងនេះឯង ហេតុនោះ (លោកពោលថា) មានចិត្តមិនទទឹក ។ ពាក្យថា មិនពេលពល គឺ មិនក្តៅក្រហាយដោយភ្លើងរាគៈ មិនក្តៅក្រហាយដោយភ្លើងទោសៈ មិនក្តៅក្រហាយដោយភ្លើងមោហៈ ហេតុនោះ (លោកពោលថា) មានចិត្តមិនទទឹក មិនពេលពល (ដោយកិលេស) ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

ឱក្ខិត្តចក្ខុ ន ច បាទលោលោ
គុត្តិន្ទ្រិយោ រក្ខិតមានសានោ
អនវស្សុតោ អបរិឌយ្ហមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

(៣៤៤) ឱហារយិត្វា គិហិព្យញ្ជនានិ
សញ្ឆន្នបត្តោ យថា បារិឆត្តោ
កាសាយវត្ថោ អភិនិក្ខមិត្វា
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

(៣៤៥) ឱហារយិត្វា គិហិព្យញ្ជនានីតិ គិហិព្យញ្ជនានិ វុច្ចន្តិ កេសា ច មស្សុ ច ។ បេ ។ ទីឃរស្សានិ ឥតិ វា ។ ឱហារយិត្វា គិហិព្យញ្ជនានីតិ គិហិព្យញ្ជនានិ ឱរោបយិត្វា សមោរោបយិត្វា(១) បដិប្បស្សម្ភិត្វាតិ ឱហារយិត្វា គិហិព្យញ្ជនានិ ។

---

១ ម. ឯត្ថន្តរេ និក្ខិបិត្វាតិ ទិស្សតិ ។

ភិក្ខុមានចក្ខុដាក់ចុះ ជាអ្នកមិនរពឹសជើង អ្នកគ្រប់គ្រងឥន្ទ្រិយ រក្សាចិត្ត មានចិត្តមិនទទឹក មិនពេលពល (ដោយកិលេស) គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(៣៤៤) បុគ្គលលះបង់ នូវវត្ថុជាគ្រឿងប្រាកដនៃគ្រហស្ថ ចេញទៅបួស ស្លៀកដណ្តប់សំពត់កាសាយៈ ដូចដើមបារិច្ឆត្តព្រឹក្ស មានស្លឹកដ៏ខាប់ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(៣៤៥) ពាក្យថា បុគ្គលលះបង់ នូវវត្ថុជាគ្រឿងប្រាកដនៃគ្រហស្ថ អធិប្បាយថា សក់ ពុកមាត់ ពុកចង្កា ។ បេ ។ សំពត់វែង នឹងខ្លី ហៅថា វត្ថុជាគ្រឿងប្រាកដនៃគ្រហស្ថ ។ ពាក្យថា បុគ្គលលះបង់នូវវត្ថុជាគ្រឿងប្រាកដនៃគ្រហស្ថ គឺ ដាក់ចុះ ដាក់ស្រឡះ លះបង់ នូវវត្ថុជាគ្រឿងប្រាកដនៃគ្រហស្ថ ហេតុនោះ (លោកពោលថា) បុគ្គលលះបង់នូវវត្ថុជាគ្រឿងប្រាកដនៃគ្រហស្ថ ។

## ខគ្គវិសាណសុត្តនិទ្ទេសោ

(៣៤៦) សញ្ឆិន្នបត្តោ យថា បារិឆត្តោតិ យថា បារិឆត្តកោ កោវិឡារោ ពហលបត្តបលាសោ សណ្ឌច្ឆាយោ(១) ឯវមេវ សោ បច្ចេកសម្ពុទ្ធោ បរិបុណ្ណបត្តចីវរធរោតិ សញ្ឆិន្នបត្តោ យថា បារិឆត្តោ ។

(៣៤៧) កាសាយវត្ថោ អភិនិក្ខមិត្វាតិ សោ បច្ចេកសម្ពុទ្ធោ សព្វំ ឃរាវាសបលិពោធំ ឆិន្ទិត្វា បុត្តទារបលិពោធំ ឆិន្ទិត្វា ញាតិបលិពោធំ ឆិន្ទិត្វា(២) សន្និធិបលិពោធំ ឆិន្ទិត្វា កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិត្វា អកិញ្ចនភាវំ ឧបគន្ត្វា ឯកោ ចរតិ វិហរតិ ឥរិយតិ វត្តេតិ បាលេតិ យបេតិ យាបេតីតិ កាសាយវត្ថោ អភិនិក្ខមិត្វា ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

---

១ ម. កោវិឡារោ ច សាខបត្តបលាសោ សណ្ឌច្ឆាយោ ។ ២ ម. ឯត្ថន្តរេ មិត្តាមច្ចបលិពោធំ ឆិន្ទិត្វាតិ ទិស្សតិ ។

## ខគ្គវិសាណសុត្តនិទ្ទេស

(៣៤៦) ពាក្យថា ដូចដើមបារិច្ឆត្តព្រឹក្ស មានស្លឹកដ៏ខ្នាប់ គឺ ព្រះបច្ចេកសម្ពុទ្ធនោះ ទ្រទ្រង់នូវបាត្រនិងចីវរដ៏បរិបូណ៌ ដូចដើមបារិច្ឆត្តព្រឹក្ស គឺដើមរលួសផ្អុង មានស្លឹកនិងត្រួយដ៏ក្រាស់ មានម្លប់ត្រឈៃ ហេតុនោះ (លោកពោលថា) ដូចដើមបារិច្ឆត្តព្រឹក្ស មានស្លឹកដ៏ខ្នាប់ ។

(៣៤៧) ពាក្យថា ចេញទៅបួស ស្លៀកដណ្ដប់សំពត់កាសាយៈ អធិប្បាយថា ព្រះបច្ចេកសម្ពុទ្ធនោះ កាត់កង្វល់ក្នុងឃរាវាសទាំងពួង កាត់កង្វល់ក្នុងបុត្រនិងភរិយា កាត់កង្វល់ក្នុងញាតិ កាត់កង្វល់ក្នុងការសន្សំ កោរសក់ ពុកមាត់ពុកចង្កា ទ្រទ្រង់នូវសំពត់កាសាយៈ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ដល់នូវភាពជាអ្នកមិនមានកង្វល់ ចរ ត្រាច់ទៅ ប្រព្រឹត្ត វត្ត យាត្រា ឲ្យយាត្រាទៅតែម្នាក់ឯង ហេតុនោះ (លោកពោលថា) ចេញទៅបួស ស្លៀកដណ្ដប់សំពត់កាសាយៈ ។ គប្បីប្រព្រឹត្ត ម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះពោលថា

ឱហារយិត្វា គិហិព្យញ្ជនានិ
សញ្ឆិន្នបត្តោ យថា បារិឆត្តោ
កាសាយវត្ថោ អភិនិក្ខមិត្វា
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

[៣៤៨] រសេសុ គេធំ អករំ អលោលោ
អនញ្ញបោសី សបទានចារី
កុលេ កុលេ អប្បដិពទ្ធចិត្តោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

[៣៤៩] រសេសុ គេធំ អករំ អលោលោតិ រសេសូតិ មូលរសោ ខន្ធរសោ តចរសោ បត្តរសោ បុប្ផរសោ ផលរសោ អម្ពិលំ មធុរំ តិត្តកំ កដុកំ លោណិកំ ខារិកំ លម្ពិលំ កសាវោ សាទុ អសាទុ សីតំ ឧណ្ហំ ។ សន្តិ លោកេ(១) សមណព្រាហ្មណា រសគិទ្ធា តេ ជិវ្ហគ្គេន រសេ(២) បរិយេសន្តា អាហិណ្ឌន្តិ ។

---

១ ម. សន្តេកេ ។ ២ ម. រសគ្គានិ ។

បុគ្គលលះបង់នូវវត្ថុជាគ្រឿងប្រាកដនៃគ្រហស្ថ ចេញ
ទៅបួស ស្លៀកដណ្តប់សំពត់កាសាយៈ ដូចដើម
បារិច្ឆត្តព្រឹក្ស មានស្លឹកដ៏ខាប់ គប្បីប្រព្រឹត្តម្នាក់ឯង
ដូចកុយរមាស ។

(៣៤៨) បុគ្គលមិនធ្វើនូវចំណង់ក្នុងរសទាំងឡាយ ជា
អ្នកមិនរពឹស មិនចិញ្ចឹមបុគ្គលដទៃ ត្រាច់ទៅតាម
លំដាប់ត្រកូល មិនមានចិត្តជាប់ក្នុងត្រកូល ក្នុងត្រកូល
គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(៣៤៩) អធិប្បាយពាក្យថា មិនធ្វើនូវចំណង់ក្នុងរសទាំងឡាយ
ជាអ្នកមិនរពឹស ត្រង់ពាក្យថា រសទាំងឡាយ បានដល់រសមើម រស
ដើម រសសំបក រសស្លឹក រសផ្កា រសផ្លែ ជូរ ផ្អែម ល្វីង ហឹរ
ប្រៃ ខារ ជូរចត់ ចត់ ឆ្ងាញ់ មិនឆ្ងាញ់ ត្រជាក់ ក្តៅ ។
មាន ពួកសមណព្រាហ្មណ៍ ក្នុងលោក ជាអ្នកលោភក្នុងរស សមណ-
ព្រាហ្មណ៍ទាំងនោះ រមែងដើរស្វែងរកនូវរស ព្រោះចុងអណ្តាត ។

## ខគ្គវិសាណសុត្តនិទ្ទេសោ

អម្ពិលំ លភិត្វា អនម្ពិលំ បរិយេសន្តិ អនម្ពិលំ លភិត្វា អម្ពិលំ បរិយេសន្តិ ។ មធុរំ លភិត្វា អមធុរំ បរិយេសន្តិ អមធុរំ លភិត្វា មធុរំ បរិយេសន្តិ ។ តិត្តកំ លភិត្វា អតិត្តកំ បរិយេសន្តិ អតិត្តកំ លភិត្វា តិត្តកំ បរិយេសន្តិ ។ កដុកំ លភិត្វា អកដុកំ បរិយេសន្តិ អកដុកំ លភិត្វា កដុកំ បរិយេសន្តិ ។ លោណិកំ លភិត្វា អលោណិកំ បរិយេសន្តិ អលោណិកំ លភិត្វា លោណិកំ បរិយេសន្តិ ។ ខារិកំ លភិត្វា អខារិកំ បរិយេសន្តិ អខារិកំ លភិត្វា ខារិកំ បរិយេសន្តិ ។ លម្ពិលំ លភិត្វា កសាវំ បរិយេសន្តិ កសាវំ លភិត្វា លម្ពិលំ បរិយេសន្តិ ។ សាទុំ លភិត្វា អសាទុំ បរិយេសន្តិ អសាទុំ លភិត្វា សាទុំ បរិយេសន្តិ ។ សីតំ លភិត្វា ឧណ្ហំ បរិយេសន្តិ ឧណ្ហំ លភិត្វា សីតំ បរិយេសន្តិ ។

ខគ្គវិសាណសុត្តនិទ្ទេស

បានរសជូរហើយ ស្វែងរករសមិនជូរ បានរសមិនជូរហើយ ស្វែងរករសជូរ ៗ បានរសផ្អែមហើយ ស្វែងរករសមិនផ្អែម បានរសមិនផ្អែមហើយ ស្វែងរករសផ្អែម ៗ បានរសល្វីងហើយ ស្វែងរករសមិនល្វីង បានរសមិនល្វីងហើយ ស្វែងរករសល្វីង ៗ បានរសហឹរហើយ ស្វែងរករសមិនហឹរ បានរសមិនហឹរហើយ ស្វែងរករសហឹរ ៗ បានរសប្រៃហើយ ស្វែងរករសមិនប្រៃ បានរសមិនប្រៃហើយ ស្វែងរករសប្រៃ ៗ បានរសខារហើយ ស្វែងរករសមិនខារ បានរសមិនខារហើយ ស្វែងរករសខារ ៗ បានរសជូរចត់ហើយ ស្វែងរករសចត់ បានរសចត់ហើយ ស្វែងរករសជូរចត់ ៗ បានរសឆ្ងាញ់ហើយ ស្វែងរករសមិនឆ្ងាញ់ បានរសមិនឆ្ងាញ់ហើយ ស្វែងរករសឆ្ងាញ់ ៗ បានត្រជាក់ហើយ ស្វែងរកក្ដៅ បានក្ដៅហើយ ស្វែងរកត្រជាក់ ៗ

តេ យំ យំ លភន្តិ តេន តេន ច តុស្សន្តិ អបរាបរំ បរិយេសន្តិ រសេសុ រត្តា គិទ្ធា គធិតា មុច្ឆិតា អជ្ឈោសន្នា លគ្គា លគ្គិតា បលិពុទ្ធា ។ សា រសតណ្ហា តស្ស បច្ចេកសម្ពុទ្ធស្ស បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា តស្មា សោ បច្ចេកសម្ពុទ្ធោ បដិសង្ខា យោនិសោ អាហារំ អាហារេតិ នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសូបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ ។

ពួកសមណព្រាហ្មណ៍ទាំងនោះ បានរសណា ៗ រមែងមិនសន្តោសដោយរសនោះ ៗ ទេ នៅតែស្វែងរករសផ្សេង ៗ ទៀត ជាអ្នកត្រេកអរជាប់ចិត្ត ជ្រប់ចិត្ត លង់ចិត្ត ងប់ចិត្ត ស្អិត ទាក់ បំពាក់ ក្នុងរសទាំងឡាយ ៗ បំណង់ក្នុងរសនោះ ព្រះបច្ចេកសម្ពុទ្ធនោះ លះបង់ គាស់រំលើងឫសគល់ ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនកើតមាន ឲ្យជាធម៌លែងកើតតទៅទៀត ព្រោះហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពិចារណាដោយឧបាយនៃប្រាជ្ញាហើយ ទើបឆាន់នូវអាហារ មិនមែនដើម្បីលេង មិនមែនដើម្បីស្រវឹង មិនមែនដើម្បីប្រដាប់ មិនមែនដើម្បីស្អិតស្អាងទេ គ្រាន់តែដើម្បីឲ្យតាំងនៅនៃកាយនេះតែប៉ុណ្ណោះ ដើម្បីញុំាងឥរិយាបថឲ្យប្រព្រឹត្តទៅ ដើម្បីបំបាត់នូវសេចក្តីលំបាក ដើម្បីអនុគ្រោះដល់ព្រហ្មចរិយៈ (ឆាន់ដោយគិត) ថា អាត្មាអញនឹងបំបាត់បង់នូវវេទនាចាស់ផង មិនឲ្យវេទនាថ្មីកើតឡើងផង ការប្រព្រឹត្តទៅផង ការមិនមានទោសផង ការនៅជាសុខផង នឹងមានដល់អាត្មាអញ ដោយឧបាយនេះ ៗ

## ខគ្គវិសាណសុត្តនិទ្ទេសោ

យថា វណំ អាលិម្បេយ្យ យាវទេវ រោបនត្ថាយ យថា វា សត្ថោ អក្ខំ អព្ភញ្ជេយ្យ យាវទេវ ភារស្ស និត្ថរណត្ថាយ យថា វា បុត្តមំសំ អាហារេយ្យ យាវ-ទេវ កន្តារស្ស និត្ថរណត្ថាយ ឯវមេវ សោ បច្ចេក-សម្ពុទ្ធោ បដិសង្ខា យោនិសោ អាហារំ អាហារេតិ នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូស-នាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យា-បនាយ វិហឹសុបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បា-ទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ ។ រសតណ្ហាយ អារតោ វិរតោ បដិវិរតោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសំយុត្តោ វិមរិយាទិកតេន ចេតសា វិហរតីតិ រសេសុ គេធំ អករំ ។ អលោលោតិ លោលាតិ វា លោលុប្បាតិ វា វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។

## ខគ្គវិសាណសុត្តនិទ្ទេស

ដូចបុគ្គលលាបដំបៅ គ្រាន់តែនឹងឲ្យដុះសាច់ ឬដូចពួកអ្នករទេះលាបភ្លៅរទេះ គ្រាន់តែនឹងដឹកនូវរបស់ធ្ងន់ ឬក៏ដូចបុគ្គលស៊ីសាច់កូន គ្រាន់តែនឹងឆ្លងផុតកន្តារៈ ព្រះបច្ចេកសម្ពុទ្ធនោះក៏ដូច្នោះដែរ លោកពិចារណាដោយឧបាយនៃប្រាជ្ញាហើយឆាន់នូវអាហារ មិនមែនដើម្បីលេង មិនមែនដើម្បីស្រវឹង មិនមែនដើម្បីប្រដាប់ មិនមែនដើម្បីស្អិតស្អាងទេ គ្រាន់តែដើម្បីឲ្យតាំងនៅនៃកាយនេះ ដើម្បីញុំាងឥរិយាបថឲ្យប្រព្រឹត្តទៅ ដើម្បីបំបាត់នូវសេចក្តីលំបាក ដើម្បីអនុគ្រោះដល់ព្រហ្មចរិយៈ (ឆាន់ដោយគិត) ថាអាត្មាអញនឹងបំបាត់បង់នូវវេទនាចាស់ផង មិនឲ្យវេទនាថ្មីកើតឡើងផង ការប្រព្រឹត្តិទៅផង ការមិនមានទោសផង ការនៅជាសុខផង នឹងមានដល់អាត្មាអញ ដោយឧបាយនេះ ៗ ជាអ្នកឆ្ងាយ វៀរ វៀរលែង ចេញ ដោះចេញ រួចផុត ប្រាសចេញ ចាកបំណង់ក្នុងរស មានចិត្តមិនសល់វល់ ហេតុនោះ (លោកពោលថា) មិនធ្វើនូវបំណង់ក្នុងរសទាំងឡាយ ៗ

ពាក្យថា មិនរពឹស សេចក្តីថា តណ្ហា លោកហៅថា ការរពឹសផង ហៅថា សេចក្តីប្រាថ្នាក្រៃពេកផង បានខាងតម្រេក តម្រេកខ្លាំង ៗ បេ ៗ

អភិជ្ឈា លោភោ អកុសលមូលំ ។ សា លោលា លោលុប្បា តណ្ហា តស្ស បច្ចេកសម្ពុទ្ធស្ស បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ-អនុប្បាទធម្មា តស្មា បច្ចេកសម្ពុទ្ធោ អលោលោតិ រសេសុ គេធំ អករំ អលោលោ ។

(៣៩០) អនញ្ញបោសី សបទានចារីតិ អនញ្ញ-បោសីតិ សោ បច្ចេកសម្ពុទ្ធោ អត្តានញ្ញេវ បោ-សេតិ ន បរន្តិ ។

អនញ្ញបោសិមញ្ញាតំ សារេសុ សុបតិដ្ឋិតំ
ខីណាសវំ វន្តទោសំ តមហំ ព្រូមិ ព្រាហ្មណន្តិ ។

អនញ្ញបោសី ។ សបទានចារីតិ សោ បច្ចេកសម្ពុទ្ធោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ គាមំ វា និគមំ វា បិណ្ឌាយ បវិសតិ រក្ខិតេនេវ កាយេន រក្ខិ-តាយ វាចាយ រក្ខិតេន ចិត្តេន ឧបដ្ឋិតាយ សតិយា

អភិជ្ឈា លោភៈ អកុសលមូល ។ តណ្ហា គឺ ការរើស នឹងសេចក្តីប្រាថ្នាក្រៃពេកនោះ ព្រះបច្ចេកសម្ពុទ្ធនោះ លះបង់ គាស់រំលើងឫសគល់ ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ឲ្យដល់នូវការមិនកើតមាន ឲ្យជាធម៌លែងកើតតទៅទៀត ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធឈ្មោះថាជាអ្នកមិនរើស ហេតុនោះ (លោកពោលថា) មិនធ្វើនូវចំណង់ក្នុងរស ជាអ្នកមិនរើស ។

(៣៩០) អធិប្បាយពាក្យថា មិនចិញ្ចឹមបុគ្គលដទៃ ត្រាច់ទៅតាមលំដាប់ប្រក ត្រង់ពាក្យថា មិនចិញ្ចឹមបុគ្គលដទៃ គឺ ព្រះបច្ចេកសម្ពុទ្ធនោះចិញ្ចឹមតែព្រះអង្គឯង មិនចិញ្ចឹមបុគ្គលដទៃទេ ។

តថាគតហៅបុគ្គល ដែលមិនចិញ្ចឹមបុគ្គលដទៃ ជាអ្នក
ត្រាស់ដឹង តាំងនៅស៊ប់ក្នុងសារធម៌ទាំងឡាយ អស់
អាសវៈ ខ្ជាក់ចោលនូវទោស ថាជាព្រាហ្មណ៍ ។

ហេតុនោះ (លោកពោលថា) មិនចិញ្ចឹមបុគ្គលដទៃ ។ ពាក្យថា ត្រាច់ទៅតាមលំដាប់ប្រក គឺ ព្រះបច្ចេកសម្ពុទ្ធនោះ ទ្រង់ស្បង់ប្រដាប់បាត្រនឹងចីវរក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ស្រុកឬនិគម ដើម្បីបិណ្ឌបាត មានកាយរក្សាហើយ មានវាចារក្សាហើយ មានចិត្តរក្សាហើយ មានសតិ

ខគ្គវិសាណសុត្តនិទ្ទេសោ

សំវុតេហិ ឥន្ទ្រិយេហិ ឱក្ខិត្តចក្ខុ ឥរិយាបថសម្បន្នោ កុលា កុលំ អភិក្កមន្តោ បិណ្ឌាយ ចរតីតិ អនញ្ញបោសី សបទានចារី ។

(៣៥១) កុលេ កុលេ អប្បដិពទ្ធចិត្តោតិ ទ្វីហិ ការណេហិ បដិពទ្ធចិត្តោ ហោតិ អត្តានំ វា នីចំ ឋបេន្តោ បរំ ឧច្ចំ ឋបេន្តោ បដិពទ្ធចិត្តោ ហោតិ អត្តានំ វា ឧច្ចំ ឋបេន្តោ បរំ នីចំ ឋបេន្តោ បដិពទ្ធចិត្តោ ហោតិ ។

កថំ អត្តានំ នីចំ ឋបេន្តោ បរំ ឧច្ចំ ឋបេន្តោ បដិពទ្ធចិត្តោ ហោតិ ។ តុម្ហេ មេ ពហូបការា អហំ តុម្ហេ និស្សាយ លភាមិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ

ប្រុងហើយ មានឥន្ទ្រិយសង្រួមហើយ មានចក្ខុដាក់ចុះហើយ បរិបូណ៌ដោយឥរិយាបថ ចេញអំពីត្រកូលទៅកាន់ត្រកូល ត្រាច់ទៅដើម្បីបិណ្ឌបាត ហេតុនោះ (លោកពោលថា) មិនចិញ្ចឹមបុគ្គលដទៃ ត្រាច់ទៅតាមលំដាប់ត្រក ។

(៣៩១) ពាក្យថា មិនមានចិត្តជាប់ ក្នុងត្រកូល ក្នុងត្រកូល អធិប្បាយថា ភិក្ខុដែលមានចិត្តជាប់ចំពាក់ ដោយហេតុ ២ យ៉ាង គឺភិក្ខុបន្ទាបខ្លួនឯងឲ្យទាប លើកអ្នកដទៃឲ្យខ្ពស់ ឈ្មោះថាអ្នកមានចិត្តជាប់ចំពាក់ ឬភិក្ខុលើកខ្លួនឯងឲ្យខ្ពស់ បន្ទាបអ្នកដទៃឲ្យទាប ឈ្មោះថាអ្នកមានចិត្តជាប់ចំពាក់ ។

ភិក្ខុបន្ទាបខ្លួនឯងឲ្យទាប លើកអ្នកដទៃឲ្យខ្ពស់ ឈ្មោះថាអ្នកមានចិត្តជាប់ចំពាក់ តើដូចម្តេច ។ ភិក្ខុនោះ ពោលយ៉ាងនេះថា លោកមានឧបការៈច្រើន ដល់ខ្ញុំ ខ្ញុំអាស្រ័យលោក ទើបបាននូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារ

យស្ស មេ អញ្ញោ ធាតុំ វា កាតុំ វា មញ្ញន្តិ តុម្ហេ និស្សាយ តុម្ហេ សម្បស្សន្តា យស្ស មេ ភោគានំ អាតាបេត្តិកំ ធាមតោត្តិ តស្ស មេ អន្តរហិតំ តុម្ហាកំ អហំ ញាយាមិ អសុកស្ស កុលុបកោ អសុកាយ កុលុបកោតិ ឯវំ អត្តានំ នីចំ ឋបេត្វា បរំ ឧច្ចំ ឋបេត្វា បដិពទ្ធចិត្តោ ហោតិ ។

កថំ អត្តានំ ឧច្ចំ ឋបេត្វា បរំ នីចំ ឋបេត្វា បដិពទ្ធចិត្តោ ហោតិ ។ អហំ តុម្ហាកំ ពហូបការោ តុម្ហេ មំ អាគម្ម ពុទ្ធំ សរណំ គតា ធម្មំ សរណំ គតា សង្ឃំ សរណំ គតា បាណាតិបាតា បដិវិរតា អទិន្នាទានា បដិវិរតា កាមេសុ មិច្ឆាចារា បដិវិរតា មុសាវាទា បដិវិរតា សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតា តុម្ហាកំ ឧទ្ទេសំ ទេមិ បរិបុច្ឆំ ទេមិ ឧបោសថំ អក្ខាមិ នវកម្មំ អធិដ្ឋាមិ អថ ច បន តុម្ហេ មំ បរិច្ចជិត្វា អញ្ញេ សក្ករោថ គរុករោថ មានេថ បូជេថាតិ ឯវំ អត្តានំ ឧច្ចំ ឋបេត្វា បរំ នីចំ ឋបេត្វា បដិពទ្ធចិត្តោ ហោតិ ។

ព្រោះពួកជនដទៃ អាស្រ័យនូវលោក ស្គាល់លោក ទើបសំគាល់នឹងឲ្យ នឹងធ្វើដល់ខ្ញុំ សូម្បីនាមនឹងគោត្រណា ពីដើម របស់មាតាបិតានៃខ្ញុំ នាមនឹងគោត្ររបស់ខ្ញុំនោះ បាត់បង់ទៅហើយ ខ្ញុំដែលគេស្គាល់ថា ជាដីតុននៃឧបាសកឯណោះ ជាដីតុននៃឧបាសិកាឯណោះ ដោយសារតែលោក ភិក្ខុបន្ទាប់ខ្លួនឯងឲ្យទាប លើកអ្នកដទៃឲ្យខ្ពស់ ឈ្មោះថាអ្នកមានចិត្តជាប់ចំពាក់ យ៉ាងនេះឯង ។

ភិក្ខុលើកខ្លួនឯងឲ្យខ្ពស់ បន្ទាប់អ្នកដទៃឲ្យទាប ឈ្មោះថាអ្នកមានចិត្តជាប់ចំពាក់ តើដូចម្តេច ។ ភិក្ខុពោលយ៉ាងនេះថា ខ្ញុំមានឧបការៈច្រើនដល់ពួកអ្នក ពួកអ្នកអាស្រ័យខ្ញុំ ទើបបានដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ជាទីពឹង ដល់នូវព្រះសង្ឃជាទីពឹង វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ខ្ញុំឲ្យឧទ្ទេស ខ្ញុំឲ្យបរិបុច្ឆា ខ្ញុំប្រាប់ឧបោសថ ខ្ញុំអធិដ្ឋាននវកម្ម ដល់លោក លុះមកខាងក្រោយ លោកលះចោលខ្ញុំ ហើយទៅធ្វើសក្ការៈ ធ្វើការគោរព រាប់អាន បូជាអ្នកដទៃវិញ ភិក្ខុលើកខ្លួនឯងឲ្យខ្ពស់ បន្ទាប់អ្នកដទៃឲ្យទាប ឈ្មោះថាអ្នកមានចិត្តជាប់ចំពាក់ យ៉ាងនេះឯង ។

## ខគ្គវិសាណសុត្តនិទ្ទេសោ

កុលេ កុលេ អប្បដិពទ្ធចិត្តោតិ សោ បច្ចេកសម្ពុទ្ធោ កុលបលិពោធេន អប្បដិពទ្ធចិត្តោ ហោតិ គណបលិពោធេន អប្បដិពទ្ធចិត្តោ ហោតិ អាវាសបលិពោធេន អប្បដិពទ្ធចិត្តោ ហោតិ ចីវរបលិពោធេន អប្បដិពទ្ធចិត្តោ ហោតិ បិណ្ឌបាតបលិពោធេន អប្បដិពទ្ធចិត្តោ ហោតិ សេនាសនបលិពោធេន អប្បដិពទ្ធចិត្តោ ហោតិ គិលានប្បច្ចយភេសជ្ជបរិក្ខារបលិពោធេន អប្បដិពទ្ធចិត្តោ ហោតីតិ កុលេ កុលេ អប្បដិពទ្ធចិត្តោ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

រសេសុ គេធំ អការំ អលោលោ
អនញ្ញបោសី សបទានចារី
កុលេ កុលេ អប្បដិពទ្ធចិត្តោ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

## ខគ្គវិសាណសុត្តនិទ្ទេស

ពាក្យថា មិនមានចិត្តជាប់ ក្នុងត្រកូល ក្នុងត្រកូល បានសេចក្តីថា ព្រះបច្ចេកសម្ពុទ្ធនោះ មិនមានចិត្តជាប់ចំពាក់ដោយកង្វល់ក្នុងត្រកូល មិនមានចិត្តជាប់ចំពាក់ដោយកង្វល់ក្នុងគណៈ មិនមានចិត្តជាប់ចំពាក់ដោយកង្វល់ក្នុងអាវាស មិនមានចិត្តជាប់ចំពាក់ដោយកង្វល់ក្នុងចីវរ មិនមានចិត្តជាប់ចំពាក់ដោយកង្វល់ក្នុងបិណ្ឌបាត មិនមានចិត្តជាប់ចំពាក់ដោយកង្វល់ក្នុងសេនាសនៈ មិនមានចិត្តជាប់ចំពាក់ដោយកង្វល់ក្នុងគិលានប្បច្ចយភេ-សជ្ជបរិក្ខារ ហេតុនោះ (លោកពោលថា) មិនមានចិត្តជាប់ចំពាក់ក្នុងត្រកូល ក្នុងត្រកូល ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

> បុគ្គលមិនធ្វើនូវបំណង់ ក្នុងរសទាំងឡាយ ជាអ្នកមិន
> រើស មិនចិញ្ចឹមបុគ្គលដទៃ ត្រាច់ទៅតាមលំដាប់ច្រក
> មិនមានចិត្តជាប់ ក្នុងត្រកូល ក្នុងត្រកូល គប្បី
> ប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(៣៥២) បហាយ បញ្ចាវរណានិ ចេតសោ
ឧបក្កិលេសេ ព្យបនុជ្ជ សព្វេ
អនិស្សិតោ ឆេត្វា សិនេហទោសំ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

(៣៥៣) បហាយ បញ្ចាវរណានិ ចេតសោតិ សោ បច្ចេកសម្ពុទ្ធោ កាមច្ឆន្ទនីវរណំ បហាយ បជហិត្វា វិនោទេត្វា ព្យន្តីការិត្វា អនភាវង្គមេត្វា ព្យាបាទនីវរណំ ថីនមិទ្ធនីវរណំ ឧទ្ធច្ចកុក្កុច្ចនីវរណំ វិចិកិច្ឆានីវរណំ បហាយ បជហិត្វា វិនោទេត្វា ព្យន្តីការិត្វា អនភាវង្គមេត្វា វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតីតិ បហាយ បញ្ចាវរណានិ ចេតសោ ។

(៣៥២) បុគ្គលលះបង់ នូវរបាំងរបស់ចិត្ត ៥ បន្ទោបង់នូវឧបក្កិលេសទាំងពួង ជាអ្នកមិនអាស្រ័យ កាត់បង់នូវសេចក្ដីស្នេហានឹងទោសៈ គប្បីប្រព្រឹត្តម្នាក់ឯងដូចកុយរមាស ។

(៣៥៣) ពាក្យថា លះបង់នូវរបាំងរបស់ចិត្ត៥ គឺព្រះបច្ចេកសម្ពុទ្ធនោះ លះ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាន នូវកាមច្ឆន្ទនីវរណៈ លះ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាន នូវព្យាបាទនីវរណៈ ថីនមិទ្ធនីវរណៈ ឧទ្ធច្ចកុក្កុច្ចនីវរណៈ វិចិកិច្ឆានីវរណៈ ជាអ្នកស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កៈនឹងវិចារៈ មានបីតិនិងសុខៈ កើតអំពីសេចក្ដីស្ងាត់ ហេតុនោះ (លោកពោលថា) លះបង់នូវរបាំងរបស់ចិត្ត ៥ ។

ខគ្គវិសាណសុត្តនិទ្ទេសោ

(៣៨៤) ឧបក្កិលេសេ ព្យបនុជ្ជ សព្វេតិ រាគោ ចិត្តស្ស ឧបក្កិលេសោ ទោសោ ចិត្តស្ស ឧបក្កិលេសោ មោហោ ចិត្តស្ស ឧបក្កិលេសោ កោធោ ឧបនាហោ ។ បេ ។ សព្វាកុសលាភិសង្ខារ ចិត្តស្ស ឧបក្កិលេសា ។ ឧបក្កិលេសេ ព្យបនុជ្ជ សព្វេតិ ចិត្តស្ស សព្វេ ឧបក្កិលេសេ ព្យបនុជ្ជ បនុទិត្វា បជហិត្វា វិនោទេត្វា ព្យន្តីករិត្វា អនភាវង្គមេត្វាតិ ឧបក្កិលេសេ ព្យបនុជ្ជ សព្វេ ។

(៣៨៥) អនិស្សិតោ ឆេត្វា ស្នេហទោសន្តិ អនិស្សិតោតិ ទ្វេ និស្សយា តណ្ហានិស្សយោ ច ទិដ្ឋិនិស្សយោ ច ។ បេ ។ អយំ តណ្ហានិស្សយោ ។ បេ ។ អយំ ទិដ្ឋិនិស្សយោ ។ ស្នេហោតិ ទ្វេ ស្នេហា តណ្ហាស្នេហោ ច ទិដ្ឋិស្នេហោ ច ។ បេ ។ អយំ តណ្ហាស្នេហោ ។ បេ ។ អយំ ទិដ្ឋិស្នេហោ ។

(៣៩៨) ពាក្យថា បន្ទោបង់នូវឧបក្កិលេសទាំងពួង សេចក្ដីថា រាគៈជាឧបក្កិលេសរបស់ចិត្ត ទោសៈជាឧបក្កិលេសរបស់ចិត្ត មោហៈជាឧបក្កិលេសរបស់ចិត្ត កោធៈ ឧបនាហៈ ។ បេ ។ អកុសលាភិសង្ខារទាំងពួង ជាឧបក្កិលេសរបស់ចិត្ត ។ ពាក្យថា បន្ទោបង់នូវឧបក្កិលេសទាំងពួង គឺ បន្ទោ បន្ទោបង់ បន្ទាត់បង់ លះបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាន នូវឧបក្កិលេសទាំងពួងនៃចិត្ត ហេតុនោះ (លោកពោលថា) បន្ទោបង់នូវឧបក្កិលេសទាំងពួង ។

(៣៩៩) អធិប្បាយពាក្យថា ជាអ្នកមិនអាស្រ័យ កាត់បង់នូវសេចក្ដីស្នេហា និងទោសៈ ត្រង់ពាក្យថា ជាអ្នកមិនអាស្រ័យ សេចក្ដីថា ការអាស្រ័យមាន ២ គឺ ការអាស្រ័យគឺតណ្ហា ១ ការអាស្រ័យគឺទិដ្ឋិ ១ ។ បេ ។ នេះការអាស្រ័យគឺតណ្ហា ។ បេ ។ នេះការអាស្រ័យគឺទិដ្ឋិ ។ ពាក្យថា សេចក្ដីស្នេហា បានដល់ស្នេហា ២ គឺ តណ្ហាស្នេហា ១ ទិដ្ឋិស្នេហា ១ ។ បេ ។ នេះតណ្ហាស្នេហា ។ បេ ។ នេះ ទិដ្ឋិស្នេហា ។

ទោសោតិ យោ ចិត្តស្ស អាឃាតោ បដិឃាតោ បដិឃោ បដិវិរោធោ កោបោ បកោបោ សម្បកោបោ ទោសោ បទោសោ សម្បទោសោ ចិត្តស្ស ព្យាបត្តិ មនោបទោសោ កោធោ កុជ្ឈនា កុជ្ឈិតត្តំ ទោសោ ទុស្សនា ទុស្សិតត្តំ ព្យាបត្តិ ព្យាបជ្ជនា ព្យាបជ្ជិតត្តំ វិរោធោ បដិវិរោធោ ចណ្ឌិក្កំ អសុរោបោ អនត្តមនតា ចិត្តស្ស ។ អនិស្សិតោ ឆេត្វា ស្នេហទោសន្តិ សោ បច្ចេកសម្ពុទ្ធោ តណ្ហាស្នេហញ្ច ទិដ្ឋិស្នេហញ្ច ទោសញ្ច ឆេត្វា ឧច្ឆេត្វា សមុច្ឆេត្វា បជហិត្វា វិនោទេត្វា ព្យន្តីករិត្វា អនភាវង្គមេត្វា ចក្ខុំ អនិស្សិតោ សោតំ អនិស្សិតោ ។ បេ ។ ទិដ្ឋសុតមុតវិញ្ញាតព្វេ ធម្មេ អនិស្សិតោ អនល្លីនោ អនុបគតោ អនជ្ឈោសិតោ អនធិមុត្តោ និក្ខន្តោ និស្សដោ វិប្បមុត្តោ វិសញ្ញុត្តោ វិមរិយាទិកតេន ចេតសា វិហរតីតិ អនិស្សិតោ ឆេត្វា ស្នេហទោសំ ។

ពាក្យថា ទោសៈ បានដល់ការអាឃាត គំនុំ ការថ្នាំងថ្នាក់ ការអាក់អន់ ការក្រោធ ការក្រោធខ្លាំង ការកម្រើក ការប្រទូស្ត ការប្រទូស្តខ្លាំង ការក្តៅក្រហាយនៃចិត្ត សេចក្តីចង្អៀតចង្អល់នៃចិត្ត សេចក្តីប្រទូស្តនៃចិត្ត សេចក្តីក្រោធ អាការនៃសេចក្តីក្រោធ ភាពនៃសេចក្តីក្រោធ សេចក្តីប្រទូស្ត អាការនៃសេចក្តីប្រទូស្ត ភាពនៃសេចក្តីប្រទូស្ត សេចក្តីចង្អៀតចង្អល់ អាការនៃសេចក្តីចង្អៀតចង្អល់ ភាពនៃសេចក្តីចង្អៀតចង្អល់ សេចក្តីខឹង ការថ្នាំងថ្នាក់ ការច ការពោលពាក្យមិនពីរោះ ភាពនៃចិត្តមិនត្រេកអរ ។ ពាក្យថា ជាអ្នកមិនអាស្រ័យ កាត់បង់នូវសេចក្តីស្នេហា និងទោសៈ បានសេចក្តីថា ព្រះបច្ចេកសម្ពុទ្ធនោះ កាត់ កាត់ផ្តាច់ កាត់ចោល លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាន នូវតណ្ហាស្នេហា ទិដ្ឋិស្នេហា និងទោសៈ មិនអាស្រ័យនូវចក្ខុ មិនអាស្រ័យនូវសោតៈ ។ បេ ។ មិនអាស្រ័យ មិនផ្តេកផ្តិត មិនប្រកប មិនជាប់ចិត្ត មិនចុះចិត្តស៊ប់ ចាកចេញ ដោះចេញ រួចស្រឡះ មិនប្រកប នូវធម្មារម្មណ៍ ដែលគប្បីឃើញ ឮ ប៉ះពាល់ ឬដឹង មានចិត្តមិនសល់វល់ ហេតុនោះ (លោកពោលថា) ជាអ្នកមិនអាស្រ័យ កាត់បង់នូវសេចក្តីស្នេហានិងទោសៈ ។

## ខគ្គវិសាណសុត្តនិទ្ទេសោ

ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ
បច្ចេកសម្ពុទ្ធោ

បហាយ បញ្ចាវរណានិ ចេតសោ
ឧបក្កិលេសេ ព្យបនុជ្ជ សព្វេ
អនិស្សិតោ ឆេត្វា ស្នេហទោសំ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

(៣៨៦) វិបិដ្ឋិកត្វាន សុខំ ទុក្ខញ្ច
បុព្វេវ ច សោមនស្សទោមនស្សំ
លទ្ធានុបេក្ខំ សមថំ វិសុទ្ធំ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

(៣៨៧) វិបិដ្ឋិកត្វាន សុខំ ទុក្ខញ្ច បុព្វេវ ច សោមនស្សទោមនស្សន្តិ សោ បច្ចេកសម្ពុទ្ធោ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតីតិ វិបិដ្ឋិកត្វាន សុខំ ទុក្ខញ្ច បុព្វេវ ច សោមនស្សទោមនស្សានំ ។

គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

> បុគ្គលលះបង់ នូវរបាំងរបស់ចិត្ត ៥ បន្ទោបង់នូវឧបក្កិលេសទាំងពួង ជាអ្នកមិនអាស្រ័យ កាត់បង់នូវសេចក្តីស្នេហានិងទោសៈ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។
>
> (៣៥៦) បុគ្គលធ្វើឲ្យនៅពីខាងក្រោយខ្នង នូវសុខ ទុក្ខ សោមនស្សនិងទោមនស្សក្នុងកាលមុន បាននូវឧបេក្ខា និងសមថៈដ៏បរិសុទ្ធ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(៣៥៧) ពាក្យថា បុគ្គលធ្វើឲ្យនៅពីខាងក្រោយខ្នង នូវសុខ ទុក្ខ សោមនស្សនិងទោមនស្ស ក្នុងកាលមុន សេចក្តីថា ព្រោះលះសុខផង លះទុក្ខផង ធ្វើនូវសោមនស្សនិងទោមនស្សក្នុងកាលមុន ឲ្យវិនាសផង ព្រះបច្ចេកសម្ពុទ្ធនោះ ចូលចតុត្ថជ្ឈាន ឥតទុក្ខឥតសុខ មានសេចក្តីបរិសុទ្ធិ ដោយឧបេក្ខានិងសតិ ហេតុនោះ (លោកពោលថា) ធ្វើឲ្យនៅពីខាងក្រោយខ្នង នូវសុខ ទុក្ខ សោមនស្សនិងទោមនស្សក្នុងកាលមុន ។

(៣៨៨) លទ្ធានុបេក្ខំ សមថំ វិសុទ្ធន្តិ ឧបេក្ខាតិ យា ចតុត្ថជ្ឈានេ ឧបេក្ខា ឧបេក្ខនា អជ្ឈុបេក្ខនា ចិត្តស្ស បស្សទ្ធតា មជ្ឈត្តតា ចិត្តស្ស ។ សមថោតិ យា ចិត្តស្ស ឋិតិ សណ្ឋិតិ អវដ្ឋិតិ អវិសាហារោ អវិក្ខេបោ អវិសាហដមានសតា សមថោ សមាធិន្ទ្រិយំ សមាធិពលំ សម្មាសមាធិ ។ ចតុត្ថជ្ឈានេ ឧបេក្ខា ច សមថោ ច សុទ្ធា ហោន្តិ វិសុទ្ធា បរិយោទាតា អនង្គណា វិគតូបក្កិលេសា មុទុភូតា កម្មនិយា ឋិតា អានេញ្ជប្បត្តា ។ លទ្ធានុបេក្ខំ សមថំ វិសុទ្ធន្តិ ចតុត្ថជ្ឈានេ ឧបេក្ខញ្ច សមថញ្ច លទ្ធាន លភិត្វា លទ្ធានុបេក្ខំ សមថំ វិសុទ្ធំ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

> វិបិដ្ឋិកត្វាន សុខំ ទុក្ខញ្ច
> បុព្វេវ ច សោមនស្សទោមនស្សំ
> លទ្ធានុបេក្ខំ សមថំ វិសុទ្ធំ
> ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

(៣៩៨) អធិប្បាយពាក្យថា បាននូវឧបេក្ខានិងសមថៈដ៏បរិសុទ្ធ ត្រង់ពាក្យថា ឧបេក្ខា បានដល់ការព្រងើយ អាការនៃការព្រងើយ ការព្រងើយកន្តើយ ភាពនៃចិត្តស្ងប់ ភាពនៃចិត្តតាំងនៅជាកណ្តាល ក្នុងចតុត្ថជ្ឈាន ។ ពាក្យថា សមថៈ បានដល់ការតាំងនៅ ការតាំងនៅព្រម ការតាំងនៅខ្ជាប់ ការមិនរសេមរសាម ការមិនរាយមាយ ភាពមិនអណ្តែតអណ្តូង នៃចិត្ត សមថៈ សមាធិន្ទ្រិយ សមាធិពលៈ សម្មាសមាធិ ។ ឧបេក្ខានិងសមថៈ ក្នុងចតុត្ថជ្ឈាន ជាសភាវៈ បរិសុទ្ធ ស្អាត ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស ជាសភាពទន់ភ្លន់ គួរដល់កម្ម នឹងនួន ដល់នូវការមិនញាប់ញ័រ ។ ពាក្យថា បាននូវឧបេក្ខានិងសមថៈដ៏បរិសុទ្ធ បានសេចក្តីថា បាន បានហើយ នូវឧបេក្ខានិងសមថៈ ក្នុងចតុត្ថជ្ឈាន ហេតុនោះ (លោកពោលថា) បាន នូវឧបេក្ខានិងសមថៈដ៏បរិសុទ្ធ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

បុគ្គលធ្វើឲ្យនៅពីខាងក្រោយខ្នង នូវសុខ ទុក្ខ
សោមនស្សនឹងទោមនស្សក្នុងកាលមុន បាននូវ
ឧបេក្ខានិងសមថៈដ៏បរិសុទ្ធ គប្បីប្រព្រឹត្តម្នាក់ឯង
ដូចកុយរមាស ។

ខគ្គវិសាណសុត្តនិទ្ទេសោ

(៣៨៩) អារទ្ធវីរិយោ បរមត្ថបត្តិយា
អលីនចិត្តោ អកុសីតវុត្តិ
ទឡ្ហនិក្កមោ ថាមពលូបបន្នោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

(៣៦០) អារទ្ធវីរិយោ បរមត្ថបត្តិយាតិ បរមត្ថំ វុច្ចតិ អមតំ និព្វានំ យោ សោ សព្វសង្ខារសមថោ សព្វូបធិបដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានំ ។ បរមត្ថស្ស បត្តិយា លាភាយ បដិលាភាយ អធិគមាយ ផុសនាយ សច្ឆិកិរិយាយ អារទ្ធវីរិយោ វិហរតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ សម្បទាយ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសូតិ អារទ្ធវីរិយោ បរមត្ថបត្តិយា ។

## ខគ្គវិសាណសុត្តនិទ្ទេស

(៣៥៩) បុគ្គល ប្រារព្ធព្យាយាម ដើម្បីសម្រេចនូវ
ប្រយោជន៍ដ៏ឧត្តម មានចិត្តមិនរួញរា ជាអ្នកប្រព្រឹត្ត
មិនខ្ជិល មានព្យាយាមមាំ បរិបូណ៌ដោយកំឡាំងចិត្ត
នឹងកំឡាំងកាយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(៣៦០) ពាក្យថា ប្រារព្ធព្យាយាម ដើម្បីសម្រេចនូវប្រយោជន៍ដ៏ឧត្តម សេចក្ដីថា អមតនិព្វាន ហៅថា ប្រយោជន៍ដ៏ឧត្តម បានដល់ការរំងាប់សង្ខារទាំងពួង ការលះបង់នូវឧបធិទាំងពួង ការអស់តណ្ហា ការអស់តម្រេក ការរលត់ និព្វាន ។ បុគ្គលជាអ្នកប្រារព្ធព្យាយាម ក្នុងការលះអកុសលធម៌ ក្នុងការបំពេញកុសលធម៌ដើម្បីការដល់ ការបាន ការបានបំពោះ ការត្រាស់ដឹង ការពាល់ត្រូវ ការធ្វើឲ្យជាក់ច្បាស់ នូវប្រយោជន៍ដ៏ឧត្តម គឺជាអ្នកមានកំឡាំងចិត្ត មានសេចក្ដីប្រឹងប្រែងមាំ មិនដាក់ធុរៈ ក្នុងកុសលធម៌ទាំងឡាយ ហេតុនោះ (លោកពោលថា) ប្រារព្ធព្យាយាម ដើម្បីសម្រេច នូវប្រយោជន៍ដ៏ឧត្តម ។

(៣៦១) អលីនចិត្តោ អកុសីតវុត្តីតិ សោ បច្ចេកសម្ពុទ្ធោ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាបារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតីតិ ឯវំ អលីនចិត្តោ អកុសីតវុត្តិ ។ អថវា កាមំ តចោ ច ន្ហារុ ច អដ្ឋិ ច អវសិស្សតុ សុស្សតុ សរីរេ មំសលោហិតំ យន្តំ បុរិសថាមេន បុរិសវីរិយេន

(៣៦១) ពាក្យថា មានចិត្តមិនរួញរា ជាអ្នកប្រព្រឹត្ត មិនខ្ជិល អធិប្បាយថា ព្រះបច្ចេកសម្ពុទ្ធនោះញុំាងឆន្ទៈឲ្យកើត ព្យាយាម ប្រារព្ធនូវសេចក្តីព្យាយាម ផ្គងចិត្ត តាំងចិត្ត ដើម្បីញុំាងអកុសលធម៌ដ៏លាមកដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបាន ញុំាងឆន្ទៈឲ្យកើត ព្យាយាម ប្រារព្ធនូវសេចក្តីព្យាយាម ផ្គងចិត្ត តាំងចិត្ត ដើម្បីលះនូវអកុសលធម៌ដ៏លាមកដែលកើតឡើងហើយ ញុំាងឆន្ទៈឲ្យកើត ព្យាយាម ប្រារព្ធនូវសេចក្តីព្យាយាម ផ្គងចិត្ត តាំងចិត្ត ដើម្បីញុំាងកុសលធម៌ដែលមិនទាន់កើត ឲ្យកើតឡើង ញុំាងឆន្ទៈឲ្យកើត ព្យាយាម ប្រារព្ធនូវសេចក្តីព្យាយាម ផ្គងចិត្ត តាំងចិត្ត ដើម្បីញុំាងកុសលធម៌ដែលកើតឡើងហើយឲ្យឋិតថេរ មិនឲ្យសាបសូន្យ ឲ្យចំរើនក្រៃលែង ឲ្យទូលំទូលាយ ឲ្យពេញលេញដោយភាវនា ហេតុនោះ (លោកពោលថា) មានចិត្តមិនរួញរា ជាអ្នកប្រព្រឹត្ត មិនខ្ជិល យ៉ាងនេះ ។ មួយទៀត បុគ្គលផ្គងចិត្ត តាំងចិត្តថា ចង់សល់នៅតែស្បែក សរសៃនឹងឆ្អឹង ក៏ដោយចុះ ចង់សាច់និងឈាមក្នុងសរីរៈ រីងស្ងួតទៅក៏ដោយចុះ គុណជាតណា ដែលបុគ្គលគប្បីសម្រេចដោយកំឡាំងចិត្តរបស់បុរស ដោយកំឡាំងកាយរបស់បុរស

## ខគ្គវិសាណសុត្តនិទ្ទេសោ

បុរិសវីរិយេន បុរិសបរក្កមេន បត្តព្វំ ន តំ អបា-បុណិត្វា វីរិយស្ស ឋានំ ករិស្សតីតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឃវម្បិ អលីនចិត្តោ អកុសីតវុត្តិ ។ ន តាវាហំ ឥមំ បល្លង្កំ ភិន្ទិស្សាមិ យាវ មេ ន អនុ-បាទាយ អាសវេហិ ចិត្តំ វិមុច្ចិស្សតីតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឃវម្បិ អលីនចិត្តោ អកុសីតវុត្តិ ។

នាសិស្សំ ន បិវិស្សាមិ វិហារតោ ន និក្ខមី(១)

នបិ បស្សំ និបាតេស្សំ តណ្ហាសល្លេ អនូហតេតិ

ចិត្តំ បគ្គណ្ហាតិ បទហតិ ឃវម្បិ អលីនចិត្តោ អកុសីតវុត្តិ ។ ន តាវាហំ ឥមម្ហា អាសនា វុដ្ឋហិស្សាមិ យាវ មេ ន អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចិស្សតីតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឃវម្បិ អលីនចិត្តោ អកុសីតវុត្តិ ។

---

១ ម. និក្ខមេ ។

## ខគ្គវិសាណសុត្តនិទ្ទេស

ដោយសេចក្តីព្យាយាមរបស់បុរស ដោយសេចក្តីប្រឹងប្រែងរបស់បុរស បើអាត្មាមិនទាន់សម្រេច នូវគុណជាតនោះទេ នឹងមិនបញ្ឈប់នូវព្យាយាមឡើយ បុគ្គលមានចិត្តមិនរួញរា ជាអ្នកប្រព្រឹត្តមិនខ្ជិល ដោយវិធីយ៉ាងនេះក៏មាន ។ បុគ្គលផ្គងចិត្ត តាំងចិត្តថា ចិត្តរបស់អាត្មាអញ មិនទាន់រួចចាកអាសវៈ ព្រោះមិនប្រកាន់មាំ ដរាបណា អាត្មាអញនឹងមិនទំលាយភ្នែនដរាបនោះ បុគ្គលមានចិត្តមិនរួញរា ជាអ្នកប្រព្រឹត្តមិនខ្ជិល ដោយវិធីយ៉ាងនេះក៏មាន ។ បុគ្គលផ្គងចិត្ត តាំងចិត្តថា

កាលបើសរគឺតណ្ហា មិនទាន់ដកចេញទេ អាត្មាអញ
នឹងមិនស៊ី នឹងមិនផឹក នឹងមិនចេញអំពីវិហារ ទាំង
នឹងមិនដាក់នូវបង្អៀង (ទម្រេត) ឡើយ ។

បុគ្គល មានចិត្តមិនរួញរា ជាអ្នកប្រព្រឹត្តមិនខ្ជិល ដោយវិធីយ៉ាងនេះក៏មាន ។ បុគ្គលផ្គងចិត្ត តាំងចិត្តថា បើចិត្តរបស់អាត្មាអញ នឹងមិនទាន់រួច ចាកអាសវៈ ព្រោះមិនប្រកាន់មាំ ដរាបណា អាត្មាអញនឹងមិនក្រោក ចាកអាសនៈនេះ ដរាបនោះ បុគ្គលមានចិត្តមិនរួញរា ជាអ្នកប្រព្រឹត្តមិនខ្ជិល ដោយវិធីយ៉ាងនេះ ក៏មាន ។

ន តាវាហំ ឥមម្ហា ចង្កមា ឱរោហិស្សាមិ វិហារា
និក្ខមិស្សាមិ អឌ្ឍយោគា និក្ខមិស្សាមិ បាសាទា
និក្ខមិស្សាមិ ហម្មិយា និក្ខមិស្សាមិ គុហាយ និ-
ក្ខមិស្សាមិ លេណា និក្ខមិស្សាមិ កុដិយា និក្ខ-
មិស្សាមិ កូដាគារា និក្ខមិស្សាមិ អដ្ដា និក្ខមិ-
ស្សាមិ មាឡា និក្ខមិស្សាមិ ឧទ្ទណ្ឌា និក្ខមិស្សាមិ
ឧបដ្ឋានសាលាយ និក្ខមិស្សាមិ មណ្ឌបា និក្ខ-
មិស្សាមិ រុក្ខមូលា និក្ខមិស្សាមិ យាវ មេ ន
អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចិស្សតីតិ ចិត្តំ
បគ្គណ្ហាតិ បទហតិ ឯវម្បិ អលីនចិត្តោ អកុសីត-
វុត្តិ ។ ឥមស្មឹ យេវ បុព្វណ្ហសមយេ អរិយធម្មំ អា-
ហរិស្សាមិ សមាហរិស្សាម អធិគច្ឆិស្សាមិ ផុសយិ-
ស្សាមិ សច្ឆិករិស្សាមីតិ ចិត្តំ បគ្គណ្ហាតិ បទហតិ
ឯវម្បិ អលីនចិត្តោ អកុសីតវុត្តិ ។ ឥមស្មឹ យេវ
មជ្ឈន្តិកសមយេ សាយណ្ហសមយេ បុរេភត្តំ

បុគ្គលផ្គងចិត្ត តាំងចិត្តថា អាត្មាអញនឹងមិនចុះអំពីទីចង្ក្រមនេះ មិនចេញអំពីវិហារនេះ មិនចេញអំពីអឌ្ឍយោគនេះ មិនចេញអំពីប្រាសាទនេះ មិនចេញអំពីប្រាសាទមានជ្រុង ៤ នេះ មិនចេញអំពីគុហានេះ មិនចេញអំពីគុកនេះ មិនចេញអំពីកុដិនេះ មិនចេញអំពីផ្ទះមានកំពូលនេះ មិនចេញអំពីប៉មនេះ មិនចេញអំពីរោងនេះ មិនចេញអំពីរោងដោលនេះ មិនចេញអំពីឧបដ្ឋានសាលានេះ មិនចេញអំពីបណ្ឌបនេះ មិនចេញអំពីគល់ឈើនេះ បើចិត្តរបស់អាត្មាអញមិនទាន់រួចចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ បុគ្គលមានចិត្តមិនរួញរា ជាអ្នកប្រព្រឹត្តមិនខ្ជិល ដោយវិធីយ៉ាងនេះក៏មាន ។ បុគ្គលផ្គងចិត្ត តាំងចិត្តថា អាត្មាអញនឹងនាំមក នឹងប្រមូលមក នឹងត្រាស់ដឹង នឹងពាល់ត្រូវ នឹងធ្វើឲ្យជាក់ច្បាស់ នូវអរិយធម៌ ឲ្យទាន់ក្នុងបុព្វណ្ហសម័យនេះ បុគ្គលមានចិត្តមិនរួញរា ជាអ្នកប្រព្រឹត្តមិនខ្ជិល ដោយវិធីយ៉ាងនេះក៏មាន ។ បុគ្គលផ្គងចិត្ត តាំងចិត្តថា អាត្មាអញនឹងនាំមក នឹងប្រមូលមក នឹងត្រាស់ដឹង នឹងពាល់ត្រូវ នឹងធ្វើឲ្យជាក់ច្បាស់ នូវអរិយធម៌ ឲ្យទាន់ក្នុងវេលាថ្ងៃត្រង់នេះ ក្នុងវេលាថ្ងៃរសៀលនេះ ក្នុងវេលាមុនភត្តនេះ

## ខគ្គវិសាណសុត្តនិទ្ទេសោ

បច្ឆាភត្តំ បុរិមយាមេ មជ្ឈិមយាមេ បច្ឆិមយាមេ កាឡេ ជុណ្ហេ វស្សេ ហេមន្តេ គិម្ហេ បុរិមេ វយោ-ខន្ធេ មជ្ឈិមេ វយោខន្ធេ បច្ឆិមេ វយោខន្ធេ អរិ-យធម្មំ អាហារិស្សាមិ សមាហារិស្សាមិ អធិគច្ឆិស្សាមិ ផុសយិស្សាមិ សច្ឆិករិស្សាមីតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឋវម្សិ អលីនចិត្តោ អកុសីតវុត្តិ ។

(៣៨២) ទឡ្ហនិក្កមោ ថាមពលូបបន្នោតិ ទឡ្ហ-និក្កមោតិ សោ បច្ចេកសម្ពុទ្ធោ ទឡ្ហសមាទានោ អហោសិ កុសលេសុ ធម្មេសុ អវដ្ឋិតសមាទានោ កាយសុចរិតេ វចីសុចរិតេ មនោសុចរិតេ ទានសំ-វិភាគេ សីលសមាទានេ ឧបោសថុបវាសេ មត្តេ-យ្យតាយ បេត្តេយ្យតាយ សាមញ្ញតាយ ព្រហ្មញ្ញ-តាយ កុលេ ជេដ្ឋាបចាយិកាយ អញ្ញតរញ្ញត-រេសុ អធិកុសលេសុ ធម្មេសូតិ ទឡ្ហនិក្កមោ ។

ក្នុងវេលាក្រោយភត្តនេះ ក្នុងបឋមយាមនេះ ក្នុងមជ្ឈិមយាមនេះ ក្នុងបច្ឆិមយាមនេះ ក្នុងរនោចនេះ ក្នុងខ្នើតនេះ ក្នុងវស្សានរដូវនេះ ក្នុងហេមន្តរដូវនេះ ក្នុងគិម្ហរដូវនេះ ក្នុងចំណែកបឋមវ័យនេះ ក្នុងចំណែកមជ្ឈិមវ័យនេះ ក្នុងចំណែកបច្ឆិមវ័យនេះ បុគ្គលមានចិត្តមិនរួញរា ជាអ្នកប្រព្រឹត្តមិនខ្ជិល ដោយវិធីយ៉ាងនេះក៏មាន ។

(៣៦២) អធិប្បាយពាក្យថា មានព្យាយាមមាំ បរិបូណ៌ដោយកំឡាំងចិត្តនិងកំឡាំងកាយ ត្រង់ពាក្យថា មានព្យាយាមមាំ សេចក្តីថា ព្រះបច្ចេកសម្ពុទ្ធនោះ ជាអ្នកមានការសមាទានមាំ ក្នុងពួកកុសលធម៌ មានការសមាទានខ្ជាប់ខ្ជួន ក្នុងកាយសុចរិត ក្នុងវចីសុចរិត ក្នុងមនោ-សុចរិត ក្នុងការចែករលែក ក្នុងការសមាទានសីល ក្នុងការរក្សាឧបោសថ ក្នុងភាពជាអ្នកគោរពមាតា ក្នុងភាពជាអ្នកគោរពបិតា ក្នុងភាពជាអ្នកគោរពសមណៈ ក្នុងភាពជាអ្នកគោរពព្រាហ្មណ៍ ក្នុងសេចក្តីគោរពបុគ្គលជាច្បងក្នុងត្រកូល ក្នុងធម៌ទាំងឡាយជាអធិកុសលណាមួយ ហេតុនោះ (លោកពោលថា) មានព្យាយាមមាំ ។

ថាមពលូបបន្នោតិ សោ បច្ចេកសម្ពុទ្ធោ ថាមេន ច ពលេន ច វីរិយេន ច បរក្កមេន ច ឧបេតោ ហោតិ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោតិ ទឡ្ហនិក្កមោ ថាមពលូបបន្នោ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

អារទ្ធវីរិយោ បរមត្ថបត្តិយា
អលីនចិត្តោ អកុសីតវុត្តិ
ទឡ្ហនិក្កមោ ថាមពលូបបន្នោ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

(៣៦៣) បដិសល្លានំ ឈានមរិញ្ចមានោ
ធម្មេសុ និច្ចំ អនុធម្មចារី
អាទីនវំ សម្មសិតា ភវេសុ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

ពាក្យថា បរិបូណ៌ដោយកម្លាំងចិត្តនឹងកម្លាំងកាយ បានសេចក្តីថា ព្រះបច្ចេកសម្ពុទ្ធនោះ ដល់ ដល់ព្រម មកជិត មកជិតព្រម ចូលដល់ ចូលដល់ព្រម ប្រកបដោយកម្លាំងចិត្តផង កម្លាំងកាយផង ព្យាយាមផង សេចក្តីប្រឹងប្រែងផង ហេតុនោះ (លោកពោលថា) មានព្យាយាមមាំ បរិបូណ៌ដោយកម្លាំងចិត្តនឹងកម្លាំងកាយ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

បុគ្គលប្រារព្ធព្យាយាម ដើម្បីសម្រេចនូវប្រយោជន៍
ដ៏ឧត្តម មានចិត្តមិនរួញរា ជាអ្នកប្រព្រឹត្តមិនខ្ជិល
មានព្យាយាមមាំ បរិបូណ៌ដោយកម្លាំងចិត្តនឹងកម្លាំង
កាយ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(៣៦៣) បុគ្គលមិនលះបង់ នូវការសម្ងំផង នូវឈានផង
ជាអ្នកប្រព្រឹត្តធម៌បន្ទាប់បន្សំ ក្នុងធម៌ទាំងឡាយ អស់
កាលជានិច្ច ពិចារណាឃើញទោសក្នុងភពទាំងឡាយ
គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

## ខគ្គវិសាណសុត្តនិទ្ទេសោ

[៣៦៤] បដិសល្លានំ ឈានមរិញ្ចមានោតិ សោ បច្ចេកសម្ពុទ្ធោ បដិសល្លានារាមោ ហោតិ បដិសល្លានរតោ អជ្ឈត្តំ ចេតោសមថមនុយុត្តោ អនិរាកតជ្ឈានោ ឈានមរិញ្ចតិ(១) អនុប្បន្នស្ស វា បឋមស្ស ឈានស្ស ឧប្បាទាយ យុត្តោ បយុត្តោ សំយុត្តោ អាយុត្តោ សមាយុត្តោ អនុប្បន្នស្ស វា ទុតិយស្ស ឈានស្ស អនុប្បន្នស្ស វា តតិយស្ស ឈានស្ស អនុប្បន្នស្ស វា ចតុត្ថស្ស ឈានស្ស ឧប្បាទាយ យុត្តោ បយុត្តោ សំយុត្តោ អាយុត្តោ សមាយុត្តោតិ ឯវំ ឈានមរិញ្ចតិ ។ អថវា ឧប្បន្នំ វា បឋមំ ឈានំ អាសេវតិ ភាវេតិ ពហុលីករោតិ ឧប្បន្នំ វា ទុតិយំ ឈានំ ឧប្បន្នំ វា តតិយំ ឈានំ ឧប្បន្នំ វា ចតុត្ថំ ឈានំ អាសេវតិ ភាវេតិ ពហុលីករោតីតិ ឯវម្បិ ឈានមរិញ្ចតីតិ បដិសល្លានំ ឈានមរិញ្ចមានោ ។

---

១ ម. អនិរាកតជ្ឈានោ វិបស្សនាយ សមន្នាគតោ ព្រូហេតា សុញ្ញាគារំ ឈាយី ឈានរតោ ឯកតមនុយុត្តោ សទត្ថគរុកោតិ បដិសល្លានំ ។ ឈានមរិញ្ចមានោតិ សោ បច្ចេកសម្ពុទ្ធោ ទ្វីហិ ការណេហិ ឈានំ នរិញ្ចតីតិ ទិស្សន្តិ ។

## ខគ្គវិសាណសុត្តនិទ្ទេស

(៣៦៤) ពាក្យថា មិនលះបង់ នូវការសម្ងំផង នូវឈានផង អធិប្បាយថា ព្រះបច្ចេកសម្ពុទ្ធនោះ ជាអ្នកមានការសម្ងំជាទីត្រេកអរ ត្រេកអរក្នុងការសម្ងំ ប្រកបរឿយៗនូវចេតោសមថៈខាងក្នុង មិនធ្វើឈានឲ្យរបូតចុះ មិនលះបង់ឈាន ប្រកប ប្រកបរឿយៗ ប្រកបព្រម ប្រកបមិនដាច់ ប្រកបមិនដាច់ព្រម ដើម្បីធ្វើបឋមជ្ឈានដែលមិនទាន់កើតឲ្យកើតឡើង ឬប្រកប ប្រកបរឿយ ៗ ប្រកបព្រម ប្រកបមិនដាច់ ប្រកបមិនដាច់ព្រម ដើម្បីធ្វើទុតិយជ្ឈានដែលមិនទាន់កើត ឬតតិយជ្ឈានដែលមិនទាន់កើត ឬក៏ចតុត្ថជ្ឈានដែលមិនទាន់កើត ឲ្យកើតឡើង ហេតុនោះ ឈ្មោះថាមិនលះបង់នូវឈាន យ៉ាងនេះឯង ។ មួយទៀត ព្រះបច្ចេកសម្ពុទ្ធ សេព ចម្រើន ធ្វើឲ្យច្រើន នូវបឋមជ្ឈាន ដែលកើតឡើងហើយ ឬសេព ចម្រើន ធ្វើឲ្យច្រើន នូវទុតិយជ្ឈានដែលកើតឡើងហើយ ឬតតិយជ្ឈានដែលកើតឡើងហើយ ឬចតុត្ថជ្ឈានដែលកើតឡើងហើយ ហេតុនោះ ឈ្មោះថា មិនលះបង់នូវឈាន យ៉ាងនេះក៏មាន ហេតុនោះ (លោកពោលថា) មិនលះបង់ នូវការសម្ងំផង នូវឈានផង ។

(៣៦៥) ធម្មេសុ និច្ចំ អនុធម្មចារីតិ ធម្មា វុច្ចន្តិ ចត្តារោ សតិបដ្ឋានា ។ បេ ។ អរិយោ អដ្ឋង្គិកោ មគ្គោ ។ កតមោ អនុធម្មោ ។ សម្មាបដិបទា អនុលោមបដិបទា អបច្ចនីកបដិបទា អន្វត្ថបដិបទា ធម្មានុធម្មបដិបទា សីលេសុ បរិបូរការិតា ឥន្ទ្រិយេសុ គុត្តទ្វារតា ភោជនេ មត្តញ្ញុតា ជាគរិយានុយោគោ សតិសម្បជញ្ញំ ឥមេ វុច្ចន្តិ អនុធម្មា ។ ធម្មេសុ និច្ចំ អនុធម្មចារីតិ ធម្មេសុ និច្ចកាលំ(១) សតតំ សមិតំ អព្វោកិណ្ណំ(២) បោខានុបោខំ ឧទកុម្មិជាតំ អវីចិ(៣) សន្តតិ សហិតំ ផុសិតំ បុរេភត្តំ បច្ឆាភត្តំ បុរិមយាមេ មជ្ឈិមយាមេ បច្ឆិមយាមេ កាឡេ ជុណ្ហេ វស្សេ ហេមន្តេ គិម្ហេ បុរិមេ វយោខន្ធេ មជ្ឈិមេ វយោខន្ធេ បច្ឆិមេ វយោខន្ធេ ចរតិ វិហរតិ ឥរិយតិ វត្តេតិ បាលេតិ យបេតិ យាបេតីតិ ធម្មេសុ និច្ចំ អនុធម្មចារី ។

---

១ ម. ឯត្ថន្តរេ ធុវកាលន្តិ ទិស្សតិ ។ ២ ម. អកោកិណ្ណំ ។ ៣ ម. ឧទកុម្មិកជាតំ អវីចិ ។

សុត្តន្តបិដក ខុទ្ទកនិកាយ ចូឡនិទ្ទេស

(៣៦៥) ពាក្យថា ជាអ្នកប្រព្រឹត្តធម៌បន្ទាប់បន្សំ ក្នុងធម៌ទាំងឡាយអស់កាលជានិច្ច អធិប្បាយថា សតិប្បដ្ឋាន ៤ ។បេ។ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ហៅថា ធម៌ ។ ធម៌បន្ទាប់បន្សំ តើដូចម្តេច ។ ការប្រតិបត្តិត្រូវ ការប្រតិបត្តិជាអនុលោម ការប្រតិបត្តិមិនមានទំនាស់ ការប្រតិបត្តិគួរតាមប្រយោជន៍ ការប្រតិបត្តិនូវធម៌តាមធម៌ ការបំពេញក្នុងសីលទាំងឡាយ ការគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយ ការស្គាល់ប្រមាណក្នុងភោជន ការប្រកបរឿយ ៗ នូវសេចក្តីភ្ញាក់រឭក សតិនិងសម្បជញ្ញៈ ទាំងនេះហៅថា ធម៌បន្ទាប់បន្សំ ។ ពាក្យថា ជាអ្នកប្រព្រឹត្តធម៌បន្ទាប់សន្សំ ក្នុងធម៌ទាំងឡាយ អស់កាលជានិច្ច បានសេចក្តីថា បរ គ្រាច់ ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ ក្នុងធម៌ទាំងឡាយ អស់កាលជានិច្ច រឿយ ៗ ជាប់ត មិនដាច់ ញយ ៗ មិនល្ហោះ ជាប់មិនដាច់ ជាប់ត ជិតស្និទ្ធ វេលាមុនកត្ត វេលាក្រោយកត្ត បុរិមយាម មជ្ឈិមយាម បច្ឆិមយាម រនោច ខ្នើត វស្សានរដូវ ហេមន្តរដូវ គិម្ហរដូវ ចំណែកបុរិមវ័យ ចំណែកមជ្ឈិមវ័យ ចំណែកបច្ឆិមវ័យ ហេតុនោះ (លោកពោលថា) ជាអ្នកប្រព្រឹត្តធម៌ បន្ទាប់បន្សំ ក្នុងធម៌ទាំងឡាយ អស់កាលជានិច្ច ។

## ខគ្គវិសាណសុត្តនិទ្ទេសោ

(៣៦៦) អាទីនវំ សម្មសិតា ភវេសូតិ សព្វេ សង្ខារា អនិច្ចាតិ អាទីនវំ សម្មសិតា ភវេសុ សព្វេ សង្ខារា ទុក្ខាតិ សព្វេ ធម្មា អនត្តាតិ ។ បេ ។ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ អាទីនវំ សម្មសិតា ភវេសូតិ អាទីនវំ សម្មសិតា ភវេសុ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

បដិសល្លានំ ឈានមរិញ្ចមានោ
ធម្មេសុ និច្ចំ អនុធម្មចារី
អាទីនវំ សម្មសិតា ភវេសុ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

(៣៦៧) តណ្ហក្ខយំ បត្ថយំ អប្បមត្តោ
អនេឡមូគោ សុតវា សតិមា
សង្ខាតធម្មោ និយតោ បធានវា
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

## ខគ្គវិសាណសុត្តនិទ្ទេស

(៣៦៦) ពាក្យថា ពិចារណាឃើញទោស ក្នុងកពទាំងឡាយ គឺ ពិចារណាឃើញនូវទោសក្នុងកពថា សង្ខារទាំងពួងមិនទៀង ថា សង្ខារទាំងពួងជាទុក្ខ ថា ធម៌ទាំងពួងជាអនត្តា ។ បេ ។ ពិចារណាឃើញទោសក្នុងកពថា ធម្មជាតណាមួយមានការកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា ហេតុនោះ (លោកពោលថា) ពិចារណាឃើញទោសក្នុងកពទាំងឡាយ ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

បុគ្គលមិនលះបង់ នូវការសម្ងំផង នូវឈានផង ជាអ្នក
ប្រព្រឹត្តធម៌បន្ទាប់បន្សំ ក្នុងធម៌ទាំងឡាយ អស់កាល
ជានិច្ច ពិចារណាឃើញទោស ក្នុងកពទាំងឡាយ
គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(៣៦៧) បុគ្គលកាលប្រាថ្នានូវការអស់តណ្ហា ជាអ្នកមិន
ប្រមាទ មិនល្ងង់ខ្លៅ ជាអ្នកចេះដឹង មានស្មារតី
មានធម៌ពិចារណាហើយ ជាអ្នកទៀងទាត់ មាន
ព្យាយាម គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(៣៦៨) តណ្ហាក្ខយំ បត្ថយំ អប្បមត្តោតិ តណ្ហាតិ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ តណ្ហាក្ខយំ បត្ថយន្តិ រាគក្ខយំ ទោសក្ខយំ មោហក្ខយំ គតិក្ខយំ ឧបបត្តិក្ខយំ បដិសន្ធិក្ខយំ ភវក្ខយំ[១] សំសារក្ខយំ វដ្ដក្ខយំ ឥច្ឆន្តោ[២] បត្ថយន្តោ អភិជប្បន្តោតិ តណ្ហាក្ខយំ បត្ថយំ ។ អប្បមត្តោតិ សោ បច្ចេកសម្ពុទ្ធោ សក្កច្ចការី សាតច្ចការី ។បេ។ អប្បមត្តោ កុសលេសុ ធម្មេសូតិ តណ្ហាក្ខយំ បត្ថយំ អប្បមត្តោ ។

(៣៦៩) អនេលមូគោ សុតវា សតិមាតិ អនេលមូគោតិ សោ បច្ចេកសម្ពុទ្ធោ បណ្ឌិតោ បញ្ញវា ពុទ្ធិមា ញាណី វិភាវី មេធាវីតិ អនេលមូគោ ។

---

១ ម. អាសវក្ខយំ ។ ២ ម. ឯត្ថន្តរេ សាទិយន្តោ បិហយន្តោតិ ទិស្សតិ ។

## សុត្តន្តបិដក ខុទ្ទកនិកាយ ចូឡនិទ្ទេស

(៣៦៨) អធិប្បាយពាក្យថា កាលប្រាថ្នានូវការអស់តណ្ហា ជាអ្នកមិនប្រហែស ត្រង់ពាក្យថា តណ្ហា បានដល់រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ។ ពាក្យថា កាលប្រាថ្នានូវការអស់តណ្ហា គឺកាលប្រាថ្នា ប៉ុនប៉ង ផ្គងបំណង នូវការអស់រាគៈ ការអស់ទោសៈ ការអស់មោហៈ ការអស់គតិ ការអស់ឧបបត្តិ ការអស់បដិសន្ធិ ការអស់ភព ការអស់សង្សារ ការអស់វដ្តៈ ហេតុនោះ (លោកពោលថា) កាលប្រាថ្នានូវការអស់តណ្ហា ។ ពាក្យថា ជាអ្នកមិនប្រហែស គឺព្រះបច្ចេកសម្ពុទ្ធនោះ ជាអ្នកធ្វើសេចក្តីគោរព ។បេ។ ជាអ្នកមិនប្រហែសក្នុងកុសលធម៌ទាំងឡាយ ហេតុនោះ (លោកពោលថា) កាលប្រាថ្នានូវការអស់តណ្ហា ជាអ្នកមិនប្រហែស ។

(៣៦៩) អធិប្បាយពាក្យថា មិនល្ងង់ខ្លៅ ជាអ្នកចេះដឹង មានស្មារតី ត្រង់ពាក្យថា មិនល្ងង់ខ្លៅ គឺព្រះបច្ចេកសម្ពុទ្ធនោះ ជាបណ្ឌិត មានប្រាជ្ញា មានការត្រាស់ដឹង មានញាណ មានការភ្លឺស្វាង មានប្រាជ្ញាជាគ្រឿងទម្លាយកិលេស ហេតុនោះ (លោកពោលថា) មិនល្ងង់ខ្លៅ ។

សុតវាតិ សោ បច្ចេកសម្ពុទ្ធោ ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ យេ តេ ធម្មា អាទិកល្យាណា មជ្ឈេកល្យាណា បរិយោសានកល្យាណា សាត្ថា សព្យញ្ជនា កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ តថារូបាស្ស ធម្មា ពហុស្សុតា ហោន្តិ ធតា វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធាតិ សុតវា ។ សតិមាតិ សោ បច្ចេកសម្ពុទ្ធោ សតិមា ហោតិ បរមេន សតិនេបក្កេន សមន្នាគតោ ចិរកតម្បិ ចិរភាសិតម្បិ សរិតាតិ អនេលមូគោ សុតវា សតិមា ។

(៣៧០) សង្ខាតធម្មោ និយតោ បធានវាតិ សង្ខាតធម្មោ វុច្ចតិ ញាណំ យា បញ្ញា បជាននា ។បេ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ។

## ខគ្គវិសាណសុត្តនិទ្ទេស

ពាក្យថា ជាអ្នកចេះដឹង គឺព្រះបច្ចេកសម្ពុទ្ធនោះ ជាពហុស្សូត ទ្រទ្រង់នូវបំណេះ សន្សំនូវបំណេះ ពួកធម៌ណាដែលល្អខាងដើម ល្អកណ្ដាល ល្អទីបំផុត ប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈ ប្រកាសនូវព្រហ្មចរិយធម៌ ដ៏បរិសុទ្ធ បរិបូណ៌ ពេញលេញ ពួកធម៌មានសភាពដូច្នោះ គឺព្រះបច្ចេកសម្ពុទ្ធនោះ បានចេះចាំច្រើន បានទ្រទ្រង់ទុក ចាំស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ ចាក់ធ្លុះដោយទិដ្ឋិ ហេតុនោះ (លោកពោលថា) ជាអ្នកចេះដឹង ។ ពាក្យថា មានស្មារតី គឺព្រះបច្ចេកសម្ពុទ្ធនោះ មានស្មារតី ប្រកបដោយសតិនិងប្រាជ្ញាជាគ្រឿងរក្សាខ្លួនដ៏ក្រៃលែង ជាអ្នករឭកឃើញនូវអំពើដែលធ្វើយូរហើយផង នូវសំដីដែលពោលយូរហើយផង ហេតុនោះ (លោកពោលថា) មិនល្ងង់ខ្លៅ ជាអ្នកចេះដឹង មានស្មារតី ។

(៣៧០) ពាក្យថា មានធម៌ពិចារណាហើយ ជាអ្នកទៀងទាត់ មានព្យាយាម អធិប្បាយថា ញាណ លោកហៅថាធម៌ដែលពិចារណាហើយ បានដល់ បញ្ញា ការដឹងច្បាស់ ។ បេ ។ ការមិនវង្វេង ការពិចារណានូវធម៌ ការយល់ត្រូវ ។

សង្ខាតធម្មោតិ សោ បច្ចេកសម្ពុទ្ធោ សង្ខាតធម្មោ ញាតធម្មោ តុលិតធម្មោ តីរិតធម្មោ វិភូតធម្មោ វិភាវិតធម្មោ សព្វេ សង្ខារា អនិច្ចាតិ ។ បេ ។ យង្កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ សង្ខាតធម្មោ ញាតធម្មោ តុលិតធម្មោ តីរិតធម្មោ វិភូតធម្មោ វិភាវិតធម្មោ ។ អថវា តស្ស បច្ចេកសម្ពុទ្ធស្ស ខន្ធា សង្ខាតា(១) ធាតុយោ សង្ខាតា អាយតនានិ សង្ខាតានិ គតិយោ សង្ខាតា ឧបបត្តិយោ សង្ខាតា បដិសន្ធិយោ សង្ខាតា ភវា សង្ខាតា សំសារា សង្ខាតា វដ្ដា សង្ខាតា ។ អថវា បច្ចេកសម្ពុទ្ធោ ខន្ធបរិយន្តេ ឋិតោ ធាតុបរិយន្តេ ឋិតោ អាយតនបរិយន្តេ ឋិតោ គតិបរិយន្តេ ឋិតោ ឧបបត្តិបរិយន្តេ ឋិតោ បដិសន្ធិបរិយន្តេ ឋិតោ ភវបរិយន្តេ ឋិតោ សំសារបរិយន្តេ ឋិតោ វដ្ដបរិយន្តេ ឋិតោ សង្ខារបរិយន្តេ ឋិតោ អន្តិមភវេ ឋិតោ អន្តិមទេហធរោ បច្ចេកសម្ពុទ្ធោ ។

---

១ ម. សង្ខាតា ។

ពាក្យថា មានធម៌ពិចារណាហើយ គឺព្រះបច្ចេកសម្ពុទ្ធនោះ មានធម៌ពិចារណាហើយ មានធម៌ដឹងហើយ មានធម៌ថ្លឹងហើយ មានធម៌ត្រិះរិះហើយ មានធម៌ច្បាស់ហើយ មានធម៌ធ្វើឲ្យកើតប្រាកដហើយថា សង្ខារទាំងពួងមិនទៀង ។ បេ ។ មានធម៌ពិចារណាហើយ មានធម៌ដឹងហើយ មានធម៌ថ្លឹងហើយ មានធម៌ត្រិះរិះហើយ មានធម៌ច្បាស់ហើយ មានធម៌ធ្វើឲ្យកើតប្រាកដហើយថា ធម្មជាតណាមួយមានការកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា ។ មួយទៀត ព្រះបច្ចេកសម្ពុទ្ធនោះ បានពិចារណាខន្ធ ពិចារណាធាតុ ពិចារណាអាយតនៈ ពិចារណាគតិ ពិចារណាឧបបត្តិ ពិចារណាបដិសន្ធិ ពិចារណាភព ពិចារណាសង្សារ ពិចារណាវដ្ដៈ ។ មួយទៀត ព្រះបច្ចេកសម្ពុទ្ធឋិតនៅក្នុងទីបំផុតនៃខន្ធ ឋិតនៅក្នុងទីបំផុតនៃធាតុ ឋិតនៅក្នុងទីបំផុតនៃអាយតនៈ ឋិតនៅក្នុងទីបំផុតនៃគតិ ឋិតនៅក្នុងទីបំផុតនៃឧបបត្តិ ឋិតនៅក្នុងទីបំផុតនៃបដិសន្ធិ ឋិតនៅក្នុងទីបំផុតនៃភព ឋិតនៅក្នុងទីបំផុតនៃសង្សារ ឋិតនៅក្នុងទីបំផុតនៃវដ្ដៈ ឋិតនៅក្នុងទីបំផុតនៃសង្ខារ ឋិតនៅក្នុងភពជាទីបំផុត ព្រះបច្ចេកសម្ពុទ្ធទ្រទ្រង់នូវរាងកាយជាទីបំផុត ។

## ខគ្គវិសាណសុត្តនិទ្ទេសោ

យស្សាយំ បច្ឆិមកោ ភវោ ចរិមោយំ សមុស្សយោ
ជាតិជរាមរណសំសារោ នត្ថិ តស្ស បុនព្ភវោតិ
សង្ខាតធម្មោ ។ និយតោតិ និយាមា វុច្ចន្តិ ចត្តា-
រោ អរិយមគ្គា ។ ចតូហិ អរិយមគ្គេហិ សមន្នាគ-
តោ និយតោ អរិយមគ្គេហិ និយាមំ បត្តោ សម្ប-
ត្តោ ផុសិតោ សច្ឆិកតោតិ និយតោ ។ បធា-
នវាតិ បធានំ វុច្ចតិ វីរិយំ យោ ចេតសោ វីរិយា-
រម្ភោ និក្កមោ បរក្កមោ ឧយ្យាមោ ឧស្សាហោ ឧស្សោឡ្ហី
ថាមោ ធិតិ អសិថិលបរក្កមោ អនិក្ខិត្តច្ឆន្ទតា អនិ-
ក្ខិត្តធុរតា ធុរសម្បគ្គាហោ វីរិយំ វីរិយិន្ទ្រិយំ វីរិយព-
លំ សម្មាវាយាមោ ។ សោ បច្ចេកសម្ពុទ្ធោ ឥមិនា
បធានេន ឧបេតោ សមុបេតោ ឧបាគតោ សមុបា-
គតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ តស្មា
សោ បច្ចេកសម្ពុទ្ធោ បធានវាតិ សង្ខាតធម្មោ និយ-
តោ បធានវា ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។

ខគ្គវិសាណសុត្តនិទ្ទេស

ភពនេះ ជាខាងក្រោយ រាងកាយនេះ ជាខាងក្រោយ
របស់បុគ្គលណា ការអន្ទោលទៅកាន់ជាតិ ជរា មរណៈ
គឺភពថ្មី របស់បុគ្គលនោះ មិនមានឡើយ

ហេតុនោះ (លោកពោលថា) មានធម៌ពិចារណាហើយ ៗ ពាក្យថា ជាអ្នកទៀនទាត់ សេចក្តីថា អរិយមគ្គ ៤ ហៅថា ការទៀនទាត់ ៗ បុគ្គលប្រកបដោយអរិយមគ្គ ៤ ឈ្មោះថាជាអ្នកទៀនទាត់ គឺជាអ្នកដល់ ដល់ព្រម ពាល់ត្រូវ ធ្វើឲ្យជាក់ច្បាស់ នូវការទៀនទាត់ ដោយអរិយមគ្គទាំងឡាយ ហេតុនោះ (លោកពោលថា) ជាអ្នកទៀនទាត់ ៗ ពាក្យថា មានព្យាយាម សេចក្តីថា សេចក្តីប្រឹងប្រែង ហៅថា សេចក្តីព្យាយាម បានដល់ ការប្រារព្ធព្យាយាមនៃចិត្ត ការប្រឹងប្រែង ការខ្នះខ្នែង ការឧស្សាហ៍ ការខ្មីឃ្មាត ការសង្វាត ការសង្វាតមាំ ការមិនបន្ធូរបន្ថយព្យាយាម ការមិនដាក់បំណង ការមិនទម្លាក់ធុរៈ ការផ្គងនូវធុរៈ វីរិយៈ វីរិយិន្ទ្រិយ វីរិយពលៈ សម្មាវាយាមៈ ៗ ព្រះបច្ចេកសម្ពុទ្ធនោះ ដល់ ដល់ព្រម មកជិត មកជិតព្រម ចូលទៅដល់ ចូលទៅដល់ព្រម ប្រកបដោយសេចក្តីព្យាយាមនេះ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថាមានព្យាយាម ហេតុនោះ (លោកពោលថា) មានធម៌ពិចារណាហើយ ជាអ្នកទៀនទាត់ មានព្យាយាម ៗ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ៗ

តេនាហ សោ បច្ចេកសម្ពុទ្ធោ

តណ្ហក្ខយំ បត្ថយំ អប្បមត្តោ
អនេលមូគោ សុតវា សតិមា
សង្ខាតធម្មោ និយតោ បធានវា
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

(៣៧១) សីហោវ សទ្ទេសុ អសន្តសន្តោ
វាតោវ ជាលម្ហិ អសជ្ជមានោ
បទុមំវ តោយេន អលិម្បមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

(៣៧២) សីហោវ សទ្ទេសុ អសន្តសន្តោតិ យថា សីហោ មិគរាជា សទ្ទេសុ អសន្តាសី អបរិសន្តាសី អនុត្រាសី អនុព្វិគ្គោ អនុស្សុកី(១) អនុត្រាសោ អភិរុ អច្ឆម្ភី អនុត្រាសី អបលាយី បច្ចេកសម្ពុទ្ធោបិ សទ្ទេសុ អសន្តាសី អបរិសន្តាសី អនុត្រាសី អនុព្វិគ្គោ អនុស្សុកី អនុត្រាសោ អភិរុ អច្ឆម្ភី អនុត្រាសី អបលាយី បហីនភយភេរវោ វិគតលោមហំសោ វិហរតីតិ សីហោវ សទ្ទេសុ អសន្តសន្តោ ។

---

១ ម. អនុស្សុក្កី ។

ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

បុគ្គលប្រាថ្នា នូវការអស់តណ្ហា ជាអ្នកមិនប្រហែស
មិនល្ងង់ខ្លៅ ជាអ្នកចេះដឹង មានស្មារតី មានធម៌
ពិចារណាហើយ ជាអ្នកទៀងទាត់ មានព្យាយាម
គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(៣៧១) បុគ្គលអ្នកមិនតក់ស្លុត ព្រោះសំឡេងទាំងឡាយ
ដូចសីហៈ មិនជាប់ក្នុងជាលដូចខ្យល់ មិនទទឹកដោយ
ទឹកដូចឈូក គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(៣៧២) ពាក្យថា បុគ្គលមិនតក់ស្លុត ព្រោះសំឡេងទាំងឡាយដូចសីហៈ អធិប្បាយថា សីហៈជាស្តេចម្រឹគ មិនតក់ស្លុត មិនរន្ធត់ មិនញាប់ញ័រ មិនភ្ញាក់ផ្អើល មិនព្រឺព្រួច មិនរំភើប មិនខ្លាច មិនកិតភ័យ មិនស្ញប់ស្ញែង មិនរត់ ព្រោះសំឡេងទាំងឡាយ យ៉ាងណាមិញ ឯព្រះបច្ចេកសម្ពុទ្ធក៏មិនតក់ស្លុត មិនរន្ធត់ មិនញាប់ញ័រ មិនភ្ញាក់ផ្អើល មិនព្រឺព្រួច មិនរំភើប មិនខ្លាច មិនកិតភ័យ មិនស្ញប់ស្ញែង មិនរត់ លះភ័យគួរខ្លាច មិនព្រឺរោម ព្រោះសំឡេងទាំងឡាយ ក៏យ៉ាងនោះដែរ ហេតុនោះ (លោកពោលថា) បុគ្គលមិនតក់ស្លុត ព្រោះសំឡេងទាំងឡាយ ដូចសីហៈ ។

## ខគ្គវិសាណសុត្តនិទ្ទេសោ

(៣៧៣) វាតោវ ជាលម្ហិ អសជ្ជមានោតិ វាតោតិ បុរត្ថិមា វាតា បច្ឆិមា វាតា ឧត្តរា វាតា ទក្ខិណា វាតា សរជា វាតា សីតា វាតា ឧណ្ហា វាតា បរិត្តា វាតា អធិមត្តា វាតា កាឡវាតា វេរម្ភវាតា បក្ខវាតា សុបណ្ណវាតា តាលបណ្ណវាតា វិធូបនវាតា ។ ជាលំ វុច្ចតិ សុត្តជាលំ ។ យថា វាតោ ជាលម្ហិ ន សជ្ជតិ ន គណ្ហាតិ ន ពជ្ឈតិ ន បលិពជ្ឈតិ ឯវមេវ ទ្វេ ជាលា តណ្ហាជាលញ្ច ទិដ្ឋិជាលញ្ច ។ បេ ។ ឥទំ តណ្ហាជាលំ ។ បេ ។ ឥទំ ទិដ្ឋិជាលំ តស្ស បច្ចេកសម្ពុទ្ធស្ស តណ្ហាជាលំ បហីនំ ទិដ្ឋិជាលំ បដិនិស្សដ្ឋំ តណ្ហាជាលស្ស បហីនត្តា ទិដ្ឋិជាលស្ស បដិនិស្សដ្ឋត្តា សោ បច្ចេកសម្ពុទ្ធោ រូបេ ន សជ្ជតិ សទ្ទេ ន សជ្ជតិ ។ បេ ។ ទិដ្ឋសុតមុតវិញ្ញាតព្វេសុ ធម្មេសុ ន សជ្ជតិ ន គណ្ហាតិ ន ពជ្ឈតិ ន បលិពជ្ឈតិ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសំយុត្តោ វិមរិយាទិកតេន ចេតសា វិហរតីតិ វាតោវ ជាលម្ហិ អសជ្ជមានោ ។

## ខគ្គវិសាណសុត្តនិទ្ទេស

(៣៧៣) អធិប្បាយពាក្យថា មិនជាប់ក្នុងជាលដូចខ្យល់ ត្រង់ពាក្យថា ខ្យល់ បានដល់ ខ្យល់ខាងកើត ខ្យល់ខាងលិច ខ្យល់ខាងជើង ខ្យល់ខាងត្បូង ខ្យល់មានធូលី ខ្យល់ត្រជាក់ ខ្យល់ក្តៅ ខ្យល់តិច ខ្យល់ច្រើន ខ្យល់កើតតាមកាល ខ្យល់ព្យុះ ខ្យល់ស្លាបសត្វ ខ្យល់គ្រុឌ ខ្យល់ផ្លឹតស្លឹកត្នោត ខ្យល់កើតអំពីការបក់ ។ បណ្តាញធ្វើអំពីអំបោះ ហៅថា ជាល ។ ខ្យល់មិនជាប់ បុគ្គលចាប់មិនបាន មិនទើសទាក់ មិនជាប់ចំពាក់ក្នុងជាល យ៉ាងណាមិញ ជាលមាន ២ យ៉ាង គឺ ជាលគឺតណ្ហា ១ ជាលគឺទិដ្ឋិ ១ ។ បេ ។ នេះជាលគឺតណ្ហា ។ បេ ។ នេះជាលគឺទិដ្ឋិ ព្រះបច្ចេកសម្ពុទ្ធនោះ លះចោលនូវជាលគឺតណ្ហា រលាស់ចោលនូវជាលគឺទិដ្ឋិ ព្រោះតែលះចោលនូវជាលគឺតណ្ហា ព្រោះតែរលាស់ចោលនូវជាលគឺទិដ្ឋិ ព្រះបច្ចេកសម្ពុទ្ធនោះ ទើបមិនជាប់ក្នុងរូប មិនជាប់ក្នុងសំឡេង ។ បេ ។ មិនជាប់ មិនកាន់យក មិនទើសទាក់ មិនជាប់ចំពាក់ក្នុងធម្មារម្មណ៍ ដែលឃើញ ឮ ប៉ះពាល់ប្ដឹង គឺលោកឆាកចេញ ដោះចេញ រួចស្រឡះ មិនប្រកបមានចិត្តមិនសល់វល់ ក៏យ៉ាងនោះឯង ហេតុនោះ (លោកពោលថា) មិនជាប់ក្នុងជាល ដូចខ្យល់ ។

[៣៧៤] បទុមំវ តោយេន អលិម្បមានោតិ បទុមំ វុច្ចតិ បទុមបុប្ផំ ។ តោយំ វុច្ចតិ ឧទកំ ។ យថា បទុមបុប្ផំ តោយេន ន លិម្បតិ អលិត្តំ អនុបលិត្តំ ឯវមេវ ទ្វេ លេបា តណ្ហាលេបោ ច ទិដ្ឋិលេបោ ច ។បេ។ អយំ តណ្ហាលេបោ ។បេ។ អយំ ទិដ្ឋិលេបោ តស្ស បច្ចេកសម្ពុទ្ធស្ស តណ្ហាលេបោ បហីនោ ទិដ្ឋិលេបោ បដិនិស្សដ្ឋោ តណ្ហាលេបស្ស បហីនត្តា ទិដ្ឋិលេបស្ស បដិនិស្សដ្ឋត្តា សោ បច្ចេកសម្ពុទ្ធោ រូបេ ន លិម្បតិ សទ្ទេ ន លិម្បតិ ។បេ។ ទិដ្ឋសុតមុតវិញ្ញាតព្វេសុ ធម្មេសុ ន លិម្បតិ នុបលិម្បតិ អលិត្តោ អនុបលិត្តោ និក្ខន្តោ និស្សដ្ឋោ វិប្បមុត្តោ វិសំយុត្តោ វិមរិយាទិកតេន ចេតសា វិហរតីតិ បទុមំវ តោយេន អលិម្បមានោ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

(៣៧៤) ពាក្យថា មិនទទឹកដោយទឹក ដូចឈូក អធិប្បាយថា ផ្កាឈូក ហៅថា ឈូក ។ ឧទក: ហៅថា ទឹក ។ ផ្កាឈូកមិនជាប់ មិនប្រឡាក់ មិនជិតជាមដោយទឹក យ៉ាងណាមិញ គ្រឿងប្រឡាក់ ពីរយ៉ាង គឺ គ្រឿងប្រឡាក់គឺតណ្ហា១ គ្រឿងប្រឡាក់ គឺទិដ្ឋិ១ ។ បេ ។ នេះគ្រឿងប្រឡាក់គឺតណ្ហា ។ បេ ។ នេះគ្រឿងប្រឡាក់ គឺទិដ្ឋិ ព្រះបច្ចេកសម្ពុទ្ធនោះ លះបង់នូវគ្រឿងប្រឡាក់គឺតណ្ហា រលាស់ចោលនូវគ្រឿងប្រឡាក់គឺទិដ្ឋិ ព្រោះតែលះបង់នូវគ្រឿងប្រឡាក់គឺតណ្ហា ព្រោះតែរលាស់ចោល នូវគ្រឿងប្រឡាក់គឺទិដ្ឋិ ព្រះបច្ចេកសម្ពុទ្ធនោះ ទើបមិនប្រឡាក់ក្នុងរូប មិនប្រឡាក់ក្នុងសំឡេង ។ បេ ។ មិនជាប់ មិនជាប់ស្អិតក្នុងធម្មារម្មណ៍ដែលឃើញ ឮ ប៉ះពាល់ឬដឹង គឺថាលោកមិនប្រឡាក់ មិនជិតជាម ល៉ាកចេញ ដោះចេញ រួចស្រឡះ មិនប្រកប មានចិត្តមិនសល់វល់ ក៏យ៉ាងនោះដែរ ហេតុនោះ (លោកពោលថា) មិនទទឹកដោយទឹក ដូចឈូក ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

ខគ្គវិសាណសុត្តនិទ្ទេសោ

សីហោវ សទ្ទេសុ អសន្តសន្តោ

វាតោវ ជាលម្ហិ អសជ្ជមានោ

បទុមំវ តោយេន អលិប្បមានោ

ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

(៣៧៥) សីហោ យថា ទាឋពលី បសយ្ហ

រាជា មិគានំ អភិភុយ្យចារី

សេវេថ បន្តានិ សេនាសនានិ

ឯកោ ចរេ ខគ្គវិសាណកប្បោ ។

(៣៧៦) សីហោ យថា ទាឋពលី បសយ្ហ រាជា មិគានំ អភិភុយ្យចារីតិ យថា សីហោ មិគរាជា ទាឋពលី ទាឋាវុធោ សព្វេ តិរច្ឆានគតេ បាណេ អភិភុយ្យ អភិភវិត្វា អជ្ឈោត្ថរិត្វា បរិយាទិយិត្វា មទ្ទិត្វា ចរតិ វិចរតិ ឥរិយតិ វត្តតិ បាលេតិ យបេ-តិ យាបេតិ ឯវមេវ បច្ចេកសម្ពុទ្ធោបិ បញ្ញាពលី

ខគ្គវិសាណសុត្តនិទ្ទេស

បុគ្គលមិនតក់ស្លុត ព្រោះសំឡេងទាំងឡាយ ដូចសីហៈ មិនជាប់ក្នុងជាល ដូចខ្យល់ មិនទទឹកដោយទឹក ដូចឈូក គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(៣៧៥) សីហៈជាស្តេចម្រឹគ មានចង្កូមជាកម្លាំង ប្រព្រឹត្តគ្របសង្កត់ កំហែង នូវសត្វទាំងឡាយ យ៉ាងណា បុគ្គលសេពសេនាសនៈ ដ៏ស្ងាត់ ក៏យ៉ាងនោះ គប្បីប្រព្រឹត្តទៅម្នាក់ឯង ដូចកុយរមាស ។

(៣៧៦) ពាក្យថា សីហៈជាស្តេចម្រឹគ មានចង្កូមជាកម្លាំង ប្រព្រឹត្តគ្របសង្កត់ កំហែង យ៉ាងណា អធិប្បាយថា សីហៈជាស្តេចម្រឹគ មានចង្កូមជាកម្លាំង មានចង្កូមជាអាវុធ គម្រាម កំហែង គ្របសង្កត់ កាច់កិនញាំញី នូវសត្វតិរច្ឆានទាំងពួង ចរ ត្រាច់ ទៅ ប្រព្រឹត្ត រក្សា យាត្រាឲ្យយាត្រាទៅ យ៉ាងណាមិញ ឯព្រះបច្ចេកសម្ពុទ្ធ មានបញ្ញាជាកម្លាំង

បញ្ញាវុធោ សព្វប្បាណភូតេ បញ្ញាយ អភិភុយ្យ អភិភវិត្វា អជ្ឈោត្ថរិត្វា បរិយាទិយិត្វា មទ្ទិត្វា ចរតិ វិចរតិ ឥរិយតិ វត្តតិ បាលេតិ យបេតិ យាបេតីតិ សីហោ យថា ទាឋពលី បសយ្ហ រាជា មិគានំ អភិភុយ្យចារី ។

(៣៧៧) សេវេថ បន្តានិ សេនាសនានីតិ យថា សីហោ មិគរាជា អរញ្ញវនបត្ថានិ អជ្ឈោគាហេត្វា ចរតិ វិចរតិ ឥរិយតិ វត្តតិ បាលេតិ យបេតិ យាបេតិ ឯវមេវ បច្ចេកសម្ពុទ្ធោបិ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវតិ អប្បសទ្ទានិ អប្បនិគ្ឃោសានិ វិជនវាតានិ មនុស្សរាហសេយ្យកានិ បដិសល្លានសារុប្បានិ ។ សោ ឯកោ គច្ឆតិ ឯកោ តិដ្ឋតិ ឯកោ និសីទតិ ឯកោ សេយ្យំ កប្បេតិ ឯកោ គាមំ បិណ្ឌាយ បវិសតិ ឯកោ បដិក្កមតិ ឯកោ រហោ និសីទតិ

មានបញ្ញាជាអាវុធ គម្រាម កំហែង គ្របសង្កត់ កាច់កិន ញាំញី នូវសត្វទាំងពួងដោយបញ្ញា ហើយចរ ត្រាច់ ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ ក៏យ៉ាងនោះដែរ ហេតុនោះ (លោកពោលថា) សីហៈជាស្តេចម្រឹគ មានចង្កូមជាកម្លាំង ប្រព្រឹត្តគ្របសង្កត់ កំហែង យ៉ាងណា ។

(៣៧៧) ពាក្យថា សេពនូវសេនាសនៈដ៏ស្ងាត់ អធិប្បាយថា សីហៈជាស្តេចម្រឹគ ចូលកាន់ព្រៃតូចព្រៃធំ ហើយចរ ត្រាច់ ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ យ៉ាងណា ឯព្រះបច្ចេកសម្ពុទ្ធ ក៏សេពព្រៃតូចព្រៃធំ ជាសេនាសនៈដ៏ស្ងាត់ មិនមានសំឡេង មិនមានស្វូរគឹកកង ប្រាសចាកខ្យល់ដែលកើតអំពីសរីរៈរបស់ជន ជាទីស្ងាត់របស់មនុស្ស គួរដល់ការពួនសម្ងំ យ៉ាងនោះដែរ ។ ព្រះបច្ចេកសម្ពុទ្ធនោះ ដើរម្នាក់ឯង ឈរម្នាក់ឯង អង្គុយម្នាក់ឯង សិងម្នាក់ឯង ចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាតម្នាក់ឯង ត្រឡប់មកវិញម្នាក់ឯង គង់នៅក្នុងទីស្ងាត់ម្នាក់ឯង

ឯកោ ចង្កមំ អធិដ្ឋាតិ ឯកោ ចរតិ វិចរតិ ឥរិយតិ វត្តតិ បាលេតិ យបេតិ យាបេតីតិ សេវេថ បន្តានិ សេនាសនានិ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

សីហោ យថា ទាឋពលី បសយ្ហ
រាជា មិគានំ អភិភុយ្យចារី
សេវេថ បន្តានិ សេនាសនានិ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

(៣៧៨) មេត្តំ ឧបេក្ខំ ករុណំ វិមុត្តឹ
អាសេវមានោ មុទិតញ្ច កាលេ
សព្វេន លោកេន អវិរុជ្ឈមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

(៣៧៩) មេត្តំ ឧបេក្ខំ ករុណំ វិមុត្តឹ អាសេវមានោ មុទិតញ្ច កាលេតិ សោ បច្ចេកសម្ពុទ្ធោ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ

## ខគ្គវិសាណសុត្តនិទ្ទេស

អធិដ្ឋានបក្រ្កមម្នាក់ឯង បរ ត្រាច់ ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ ម្នាក់ឯង ហេតុនោះ (លោកពោលថា) សេពនូវសេនាសនៈដ៏ស្ងាត់ ៗ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ៗ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

សីហៈជាស្តេចម្រឹគ មានបង្កួមជាកម្លាំង ប្រព្រឹត្តគ្រប
សង្កត់ កំហែង នូវសត្វទាំងឡាយ យ៉ាងណា បុគ្គល
សេពសេនាសនៈដ៏ស្ងាត់ ក៏យ៉ាងនោះ គប្បីប្រព្រឹត្ត
ម្នាក់ឯង ដូចកុយរមាស ៗ

(៣៧៨) បុគ្គលកាលសេពនូវវិមុត្តិ គឺ មេត្តា ឧបេក្ខា
ករុណានឹងមុទិតាក្នុងកាលគួរ តែងត្រូវសត្វលោកទាំង
ពួងមិនស្អប់ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ៗ

(៣៧៩) ពាក្យថា កាលសេពនូវវិមុត្តិ គឺមេត្តា ឧបេក្ខា ករុណានឹងមុទិតាក្នុងកាលគួរ អធិប្បាយថា ព្រះបច្ចេកសម្ពុទ្ធនោះ មានចិត្តប្រកបដោយមេត្តាផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ដូចគ្នា ទិសទី ៣ ដូចគ្នា ទិសទី ៤ ដូចគ្នា

ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ករុណាសហគតេន ចេតសា មុទិតាសហគតេន ចេតសា ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតីតិ មេត្តំ ឧបេក្ខំ ករុណំ វិមុត្តឹ អាសេវមានោ មុទិតញ្ច កាលេ ។

(៣៨០) សព្វេន លោកេន អវិរុជ្ឈមានោតិ មេត្តាទីនំ ភាវិតត្តា យេ បុរត្ថិមាយ ទិសាយ សត្តា តេ អប្បដិកុលា ហោន្តិ យេ បច្ឆិមាយ ទិសាយ សត្តា យេ ឧត្តរាយ ទិសាយ សត្តា

មានចិត្តប្រកបដោយមេត្តា ដ៏ធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកទាំងមូល ក្នុងទិសខាងលើ ទិសខាងក្រោម និងទិសទទឹង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទីទាំងពួង ដោយប្រការដូច្នេះ មានចិត្តប្រកបដោយករុណា មានចិត្តប្រកបដោយមុទិតា មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ដូចគ្នា ទិសទី ៣ ដូចគ្នា ទិសទី ៤ ដូចគ្នា មានចិត្តប្រកបដោយឧបេក្ខា ដ៏ធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកទាំងមូល ក្នុងទិសខាងលើ ទិសខាងក្រោម និងទិសទទឹង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទីទាំងពួង ដោយប្រការដូច្នេះ ហេតុនោះ (លោកពោលថា) កាលសេពនូវវិមុត្តិ គឺមេត្តា ឧបេក្ខា ករុណា និងមុទិតា ក្នុងកាលគួរ ។

(៣៨០) ពាក្យថា តែងត្រូវសត្វលោកទាំងពួងមិនស្អប់ អធិប្បាយថា ព្រោះព្រះបច្ចេកសម្ពុទ្ធនោះ ចម្រើនហើយនូវព្រហ្មវិហារ មានមេត្តាជាដើម ពួកសត្វណាក្នុងទិសខាងកើត ពួកសត្វទាំងនោះ រមែងមិនស្អប់ ពួកសត្វណា ក្នុងទិសខាងលិច ពួកសត្វណា ក្នុងទិសខាងជើង

## ខគ្គវិសាណសុត្តនិទ្ទេសោ

យេ ទក្ខិណាយ ទិសាយ សត្តា យេ បុរត្ថិមាយ អនុទិសាយ សត្តា យេ បច្ឆិមាយ អនុទិសាយ សត្តា យេ ឧត្តរាយ អនុទិសាយ សត្តា យេ ទក្ខិណាយ អនុទិសាយ សត្តា យេ អធោកមាយ ទិសាយ សត្តា យេ ឧបរិមាយ ទិសាយ សត្តា យេ ទសសុ ទិសាសុ វិទិសាសុ សត្តា តេ អប្បដិកុលា ហោន្តិ ។ សព្វេន លោកេន អវិរុជ្ឈមានោតិ សព្វេន សត្តលោកេន អវិរុជ្ឈមានោ អប្បដិវិរុជ្ឈមានោ អឃដ្ដិយមានោ អប្បដិហញ្ញមានោតិ សព្វេន លោកេន អវិរុជ្ឈមានោ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

មេត្តំ ឧបេក្ខំ ករុណំ វិមុត្តឹ
អាសេវមានោ មុទិតញ្ច កាលេ
សព្វេន លោកេន អវិរុជ្ឈមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

## ខគ្គវិសាណសុត្តនិទ្ទេស

ពួកសត្វណា ក្នុងទិសខាងត្បូង ពួកសត្វណា ក្នុងទិសអគ្នេយ៍ ពួកសត្វណា ក្នុងទិសពាយព្យ ពួកសត្វណា ក្នុងទិសឦសាន ពួកសត្វណា ក្នុងទិសនិរតី ពួកសត្វណា ក្នុងទិសខាងក្រោម ពួកសត្វណា ក្នុងទិសខាងលើ ពួកសត្វណា ក្នុងទិសតូចទិសធំទាំង ១០ ពួកសត្វទាំងនោះ រមែងមិនស្អប់ ៗ ពាក្យថា តែងត្រូវសត្វលោកទាំងពួងមិនស្អប់ បានសេចក្ដីថា សត្វលោកទាំងពួងមិនទោមនស្ស មិនអាក់អន់ មិនថ្នាំងថ្នាក់ មិនខ្ញំងខ្ញប់ ហេតុនោះ (លោកពោលថា) តែងត្រូវសត្វលោកទាំងពួងមិនស្អប់ ៗ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ៗ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

បុគ្គលកាលសេពនូវវិមុត្តិ គឺ មេត្តា ឧបេក្ខា ករុណា
និងមុទិតា ក្នុងកាលគួរ តែងត្រូវសត្វលោកទាំង
ពួងមិនស្អប់ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ៗ

(៣៨១) រាគញ្ច ទោសញ្ច បហាយ មោហំ
សន្ទាលយិត្វាន សញ្ញោជនានិ
អសន្តសំ ជីវិតសង្ខយម្ហិ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

(៣៨២) រាគញ្ច ទោសញ្ច បហាយ មោហន្តិ រាគន្តិ យោ រាគោ សារាគោ ។បេ។ អភិជ្ឈា លោភោ អកុសលមូលំ ។ ទោសន្តិ យោ ចិត្តស្ស អាឃាតោ ។បេ។ ចណ្ឌិក្កំ អស្សុរោបោ អនត្តមនតា ចិត្តស្ស ។ មោហោតិ ទុក្ខេ អញ្ញាណំ ។បេ។ អវិជ្ជាលង្គី មោហោ អកុសលមូលំ ។ រាគញ្ច ទោសញ្ច បហាយ មោហន្តិ សោ បច្ចេកសម្ពុទ្ធោ រាគញ្ច ទោសញ្ច មោហញ្ច បហាយ បជហិត្វា វិនោទេត្វា ព្យន្តីករិត្វា អនភាវង្គមេត្វាតិ រាគញ្ច ទោសញ្ច បហាយ មោហំ ។

(៣៨១) បុគ្គលលះរាគៈ ទោសៈ និងមោហៈ ទំលាយនូវ
សញ្ញោជនៈទាំងឡាយ មិនតក់ស្លុត ក្នុងការអស់ជីវិត
គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(៣៨២) អធិប្បាយពាក្យថា លះរាគៈ ទោសៈ និងមោហៈ ត្រង់ពាក្យថា រាគៈ បានដល់ការត្រេកអរ ការត្រេកអរខ្លាំង ។ បេ ។ អភិជ្ឈា លោភៈ អកុសលមូល ។ ពាក្យថា ទោសៈ បានដល់ការគុំគួននៃចិត្ត ។ បេ ។ ចិត្តកាច ការពោលពាក្យមិនពីរោះ ភាពនៃចិត្តមិនត្រេកអរ ។ ពាក្យថា មោហៈ បានដល់ការមិនដឹងទុក្ខ ។ បេ ។ សន្ទះគឺអវិជ្ជា មោហៈ អកុសលមូល ។ ពាក្យថា លះរាគៈ ទោសៈ និងមោហៈ បានសេចក្តីថា ព្រះបច្ចេកសម្ពុទ្ធនោះ លះ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាន នូវរាគៈ ទោសៈ និងមោហៈ ហេតុនោះ (លោកពោលថា) លះរាគៈ ទោសៈ និងមោហៈ ។

## ខគ្គវិសាណសុត្តនិទ្ទេសោ

(៣៨៣) សន្ទាលយិត្វាន សញ្ញោជនានីតិ ទស សញ្ញោជនានិ កាមរាគសញ្ញោជនំ បដិឃសញ្ញោជនំ ។ បេ ។ អវិជ្ជាសញ្ញោជនំ ។ សន្ទាលយិត្វាន សញ្ញោជនានីតិ សញ្ញោជនានិ សន្ទាលយិត្វាន បទាលយិត្វាន សម្បទាលយិត្វាន បជហិត្វាន វិនោទេត្វាន ព្យន្តីករិត្វាន អនភាវង្គមេត្វានាតិ សន្ទាលយិត្វាន សញ្ញោជនានិ ។

(៣៨៤) អសន្តសំ ជីវិតសង្ខយម្ហីតិ សោ បច្ចេកសម្ពុទ្ធោ ជីវិតបរិយោសានេ អសន្តាសី អបរិសន្តាសី អនុត្រាសី អនុព្វិគ្គោ អនុស្សង្កី អនុត្រាសោ អភីរុ អច្ឆម្ភី អនុត្រាសី អបលាយី បហីនភយភេរវោ វិគតលោមហំសោតិ អសន្តសំ ជីវិតសង្ខយម្ហិ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

## ខគ្គវិសាណសុត្តនិទ្ទេស

(៣៨៣) ពាក្យថា ទំលាយនូវសញ្ញោជនៈទាំងឡាយ អធិប្បាយថា សញ្ញោជនៈ ១០ យ៉ាង គឺ កាមរាគសញ្ញោជនៈ ១ បដិឃសញ្ញោជនៈ ១ ។ បេ ។ អវិជ្ជាសញ្ញោជនៈ ១ ។ ពាក្យថា ទំលាយ នូវសញ្ញោជនៈទាំងឡាយ បានសេចក្តីថា ទំលុះទំលាយ បំបែក បំផ្លាញ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ឲ្យដល់នូវការមិនកើតមាន នូវសញ្ញោជនៈទាំងឡាយ ហេតុនោះ (លោកពោលថា) ទំលាយនូវសញ្ញោជនៈទាំងឡាយ ។

(៣៨៤) ពាក្យថា មិនតក់ស្លុតក្នុងការអស់ជីវិត គឺព្រះបច្ចេកសម្ពុទ្ធនោះ មិនតក់ស្លុត មិនរន្ធត់ មិនញាប់ញ័រ មិនភ្ញាក់ផ្អើល មិនព្រឺព្រួច មិនរំភើប មិនខ្លាច មិនភិតភ័យ មិនស្ញប់ស្ញែង មិនរត់ លះភ័យគួរខ្លាច មិនព្រឺរោម ក្នុងការអស់ជីវិត ហេតុនោះ (លោកពោលថា) មិនតក់ស្លុតក្នុងការអស់ជីវិត ។ គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

រាគញ្ច ទោសញ្ច បហាយ មោហំ
សន្ទាលយិត្វាន សញ្ញោជនានិ
អសន្តសំ ជីវិតសង្ខយម្ហិ
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

(៣៨៥) ភជន្តិ សេវន្តិ ច ការណត្ថា
និក្ការណា ទុល្លភា អជ្ជ មិត្តា
អត្តត្ថបញ្ញា អសុចី មនុស្សា
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

(៣៨៦) ភជន្តិ សេវន្តិ ច ការណត្ថាតិ អត្តត្ថការណា បរត្ថការណា ឧភយត្ថការណា ទិដ្ឋធម្មិកត្ថការណា សម្បរាយិកត្ថការណា បរមត្ថការណា ភជន្តិ សម្ភជន្តិ សេវន្តិ បដិសេវន្តិ ភជន្តិ សេវន្តិ ច ការណត្ថា ។

បុគ្គលលះរាគៈ ទោសៈ និងមោហៈ ទំលាយនូវ
សញ្ញោជនៈទាំងឡាយ មិនតក់ស្លុត ក្នុងការអស់
ជីវិត គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(៣៨៥) ជនទាំងឡាយ អ្នកមានការណ៍ជាប្រយោជន៍
ទើបគប់រក ទើបសេពគប់ ឯមិត្តដ៏ទាំងឡាយដែលឥត
ត្រូវការណ៍ គេពុំងាយនឹងរកបានទេ ចំណែកមនុស្ស
ទាំងឡាយដែលមិនស្អាត ជាអ្នកយល់ប្រយោជន៍របស់
ខ្លួន (ក៏តែងគប់រក តែងសេពគប់ដែរ) បុគ្គលគប្បី
ប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

(៣៨៦) ពាក្យថា ជនទាំងឡាយ អ្នកមានការណ៍ជាប្រយោជន៍ ទើបគប់រក ទើបសេពគប់ សេចក្តីថា ពួកជនមានប្រយោជន៍ខ្លួនជាហេតុ មានប្រយោជន៍ អ្នកដទៃជាហេតុ មានប្រយោជន៍ទាំងពីរជាហេតុ មាន ប្រយោជន៍ក្នុងបច្ចុប្បន្នជាហេតុ មានប្រយោជន៍ ក្នុងបរលោកជាហេតុ មានប្រយោជន៍ ក្នុងព្រះនិព្វានជាហេតុ ទើបគប់ សមគប់ សេពគប់ ពប់រក ហេតុនោះ (លោកពោលថា) ជនទាំងឡាយអ្នកមានការណ៍ជាប្រយោជន៍ ទើបគប់រក ទើបសេពគប់ ។

ខគ្គវិសាណសុត្តនិទ្ទេសោ

[៣៨៧] និក្ការណា ទុល្លភា អជ្ជ មិត្តាតិ ទ្វេ មិត្តា អាគារិកមិត្តោ ច អនាគារិកមិត្តោ ច ។ បេ ។ អយំ អាគារិកមិត្តោ ។ បេ ។ អយំ អនាគារិកមិត្តោ ។ និក្ការណា ទុល្លភា អជ្ជ មិត្តាតិ ឥមេ ទ្វេ មិត្តា អការណា(១) អហេតូ អប្បច្ចយា ទុល្លភាតិ(២) និក្ការណា ទុល្លភា អជ្ជ មិត្តា ។

[៣៨៨] អត្តត្ថបញ្ញា អសុចី មនុស្សាតិ អត្តត្ថបញ្ញាតិ អត្តនោ អត្ថាយ អត្តនោ ហេតុ អត្តនោ បច្ចយា អត្តនោ ការណា ភជន្តិ សម្ភជន្តិ សេវន្តិ និសេវន្តិ សំសេវន្តិ អាចរន្តិ សមាចរន្តិ បយិរុបាសន្តិ បុច្ឆន្តិ បរិបញ្ហន្តិ អត្តត្ថបញ្ញា ។

១ ម. ឯត្ថន្តរេ និក្ការណាតិ ទិស្សតិ ។ ២ ម. ទុល្លភា ទុល្លទ្ធា សុទុល្លទ្ធាតិ ។

## ខគ្គវិសាណសុត្តនិទ្ទេស

(៣៨៧) ពាក្យថា មិត្តថ្មីទាំងឡាយដែលឥតត្រូវការណ៍ គេពុំងាយនឹងរកបានទេ អធិប្បាយថា មិត្តមាន ២ ពួកគឺ អាគារិកមិត្ត ១ អនាគារិកមិត្ត ១ ។ បេ ។ នេះ អាគារិកមិត្ត ។ បេ ។ នេះ អនាគារិកមិត្ត ។ ពាក្យថា មិត្តថ្មីទាំងឡាយ ដែលឥតត្រូវការណ៍ គេពុំងាយនឹងរកបានទេ បានសេចក្តីថា មិត្តទាំងពីរប្រភេទនេះ ដែលមិនមានការណ៍ មិនមានហេតុ មិនមានបច្ច័យ គេរកបានដោយក្រ ហេតុនោះ (លោកពោលថា) មិត្តថ្មីទាំងឡាយ ដែលឥតត្រូវការណ៍ គេពុំងាយនឹងរកបានទេ ។

(៣៨៨) អធិប្បាយពាក្យថា មនុស្សទាំងឡាយដែលមិនស្អាត ជាអ្នកយល់ប្រយោជន៍របស់ខ្លួន ត្រង់ពាក្យថា ជាអ្នកយល់ប្រយោជន៍របស់ខ្លួន គឺ ពួកមនុស្សមិនស្អាត តែងគប់រក សមគប់ សេពគប់ ភប់រក អែប នែប អែបជិត ចូលទៅរក ចូលទៅអង្គុយជិត សាកសួរ ដោះសា ព្រោះតែប្រយោជន៍របស់ខ្លួន ព្រោះតែហេតុរបស់ខ្លួន ព្រោះតែបច្ច័យរបស់ខ្លួន ព្រោះតែការណ៍របស់ខ្លួន ហេតុនោះ (លោកពោលថា) ជាអ្នកយល់ប្រយោជន៍របស់ខ្លួន ។

អសុចី មនុស្សាតិ អសុចិនា កាយកម្មេន សម-
ន្នាគតាតិ អសុចី មនុស្សា ។ អសុចិនា វចីកម្មេន
សមន្នាគតាតិ អសុចី មនុស្សា ។ អសុចិនា
មនោកម្មេន សមន្នាគតាតិ អសុចី មនុស្សា ។
អសុចិនា បាណាតិបាតេន អសុចិនា អទិន្នាទានេន
អសុចិនា កាមេសុ មិច្ឆាចារេន អសុចិនា មុសា-
វាទេន អសុចិយា បិសុណាយ វាចាយ អសុចិយា
ផរុសាយ វាចាយ អសុចិនា សម្ផប្បលាបេន អសុចិ-
យា អភិជ្ឈាយ អសុចិនា ព្យាបាទេន អសុចិយា
មិច្ឆាទិដ្ឋិយា សមន្នាគតាតិ អសុចី មនុស្សា ។ អសុ-
ចិយា ចេតនាយ សមន្នាគតាតិ អសុចី មនុស្សា ។
អសុចិយា បត្ថនាយ សមន្នាគតាតិ អសុចី មនុស្សា ។

ពាក្យថា មនុស្សមិនស្អាត សេចក្តីថា ពួកមនុស្សប្រកបដោយកាយ-កម្មមិនស្អាត ឈ្មោះថា មនុស្សមិនស្អាត ១ ពួកមនុស្សប្រកបដោយវចីកម្មមិនស្អាត ឈ្មោះថា មនុស្សមិនស្អាត ១ ពួកមនុស្សប្រកបដោយមនោកម្មមិនស្អាត ឈ្មោះថា មនុស្សមិនស្អាត ១ ពួកមនុស្សប្រកបដោយការមិនស្អាត គឺបាណាតិបាត ដោយការមិនស្អាត គឺអទិន្នាទាន ដោយការមិនស្អាត គឺកាមេសុមិច្ឆាចារ ដោយការមិនស្អាត គឺមុសាវាទ ដោយការមិនស្អាត គឺបិសុណាវាចា ដោយការមិនស្អាត គឺផរុសវាចា ដោយការមិនស្អាត គឺសម្ផប្បលាបៈ ដោយការមិនស្អាត គឺអភិជ្ឈា ដោយការមិនស្អាត គឺព្យាបាទ ដោយការមិនស្អាត គឺមិច្ឆាទិដ្ឋិ ឈ្មោះថា មនុស្សមិនស្អាត ១ ពួកមនុស្សប្រកប ដោយចេតនាមិនស្អាត ឈ្មោះថា មនុស្សមិនស្អាត ១ ពួកមនុស្សប្រកប ដោយសេចក្តីប្រាថ្នា មិនស្អាត ឈ្មោះថា មនុស្សមិនស្អាត ១

អសុចិនា បឡិពិនា សមន្នាគតាតិ អសុចី មនុស្សា ហីនា និហីនា បរិហីនា ឱមកា លាមកា ឆតុក្កា បរិត្តាតិ អត្តត្ថបញ្ញា អសុចី មនុស្សា ។

[៣៨៩] ឯកោ ចរេ ខគ្គវិសាណកប្បោតិ ឯកោតិ ។ បេ ។ ចរេតិ អដ្ឋ ចរិយាយោ ។ បេ ។ ឯកោ ចរេ ខគ្គវិសាណកប្បោ ។ តេនាហ សោ បច្ចេកសម្ពុទ្ធោ

ភជន្តិ សេវន្តិ ច ការណត្ថា
និក្ការណា ទុល្លភា អជ្ជ មិត្តា
អត្តត្ថបញ្ញា អសុចី មនុស្សា
ឯកោ ចរេ ខគ្គវិសាណកប្បោតិ ។

ខគ្គវិសាណសុត្តនិទ្ទេសោ និដ្ឋិតោ

ខគ្គវិសាណសុត្តនិទ្ទេស

ពួកមនុស្សប្រកបដោយការតាំងសេចក្តីប៉ុនប៉ងមិនស្អាត ឈ្មោះថា មនុស្សមិនស្អាត ថោកទាប ថោកថយ ទន់ទាប អាក្រក់ លាមក គម្រក់ មនុស្សកំទេចកំទី ហេតុនោះ (លោកពោលថា) មនុស្សទាំងឡាយដែលមិនស្អាត ជាអ្នកយល់ប្រយោជន៍របស់ខ្លួន ។

(៣៨៤) អធិប្បាយពាក្យថា គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស គ្រង់ពាក្យថា ម្នាក់ឯង ។ បេ ។ ពាក្យថា គប្បីប្រព្រឹត្ត បានដល់ចរិយា ៨ យ៉ាង ។ បេ ។ ហេតុនោះ (លោកពោលថា) គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលថា

ជនទាំងឡាយអ្នកមានការណ៍ជាប្រយោជន៍ ទើបគប់រក
ទើបសេពគប់ ឯមិត្តថ្មីទាំងឡាយដែលឥតត្រូវការណ៍
គេពុំងាយនឹងរកបានទេ ចំណែកមនុស្សទាំងឡាយ
ដែលមិនស្អាត ជាអ្នកយល់ប្រយោជន៍របស់ខ្លួន (ក៏
តែងគប់រក តែងសេពគប់ដែរ) បុគ្គលគប្បីប្រព្រឹត្ត
ម្នាក់ឯង ដូចកុយរមាស ។

ចប់ ខគ្គវិសាណសុត្តនិទ្ទេស ។

អជិតោ តិស្សមេត្តេយ្យោ បុណ្ណកោ អថ មេត្តគូ
ធោតកោ ឧបសីវោ ច នន្ទោ ច អថ ហេមកោ
តោទេយ្យកប្បា ទុភយោ ជតុកណ្ណី ច បណ្ឌិតោ
ភទ្រាវុធោ ឧទយោ ច បោសាលោ ចាបិ ព្រាហ្មណោ
មោឃរាជា ច មេធាវី បិង្គិយោ ច មហាឥសិ
សោឡសន្នំ បនេតេសំ ព្រាហ្មណានំវ សាសនំ
ចាកយនានំ និទ្ទេសោ តត្តកា ច ករន្តិ ហិ
ចត្តវីសា ឈាសុត្តានំ និទ្ទេសាបិ តត្តេវ ច
និទ្ទេសា ទុវិធា ញេយ្យា បរិបុណ្ណា សុលិក្ខិតាតិ ។

សុត្តនិទ្ទេសោ សមត្តោ ។

និទ្ទេសគឺការសំដែងចេញ នូវពាក្យប្រៀនប្រដៅរបស់ព្រាហ្មណ៍ ជាអ្នកដល់នូវត្រើយ ទាំង ១៦ នាក់នុ៎ះ គឺ អជិត ១ តិស្សមេត្តេយ្យ ១ បុណ្ណកៈ ១ មេត្តគូ ១ ធោតកៈ ១ ឧបសីវៈ ១ នន្ទៈ ១ ហេមកៈ ១ តោទេយ្យៈ ១ កប្បៈ ១ ជតុកណ្ណីបណ្ឌិត ១ ភទ្រាវុធ ១ ឧទយៈ ១ បោសាលព្រាហ្មណ៍ ១ មោឃរាជមេធាវី ១ បិង្គិយមហាឥសី ១ ផង និទ្ទេសគឺការសំដែងចេញនូវខគ្គវិសាណសូត្រទាំងឡាយ ក្នុងទីនោះផង និទ្ទេសទាំងពីរ មានប្រមាណប៉ុណ្ណោះ បណ្ឌិតគប្បីដឹងថា ជានិទ្ទេសដែលបរិបូណ៌ លោកចារិកត្រឹមត្រូវហើយ ។

ចប់ សុត្តនិទ្ទេស ។

# សុត្តន្តបិដកេ

# ខុទ្ទកនិកាយស្ស ចូឡនិទ្ទេសោ

## ទុតិយោ ភាគោ

---

មាតិកា　　　　　　　　　　　　អង្កេ


ចូឡនិទ្ទេសេ ឧទយមាណវកបញ្ហានិទ្ទេសោ តេរសមោ . . . . . ១

បោសាលមាណវកបញ្ហានិទ្ទេសោ ចុទ្ទសមោ . . . ២៣

មោឃរាជមាណវកបញ្ហានិទ្ទេសោ បណ្ណរសមោ . . . ៤៥

បិង្គិយមាណវកបញ្ហានិទ្ទេសោ សោឡសមោ . . . . ៨៥

សោឡសមាណវកបញ្ហានិទ្ទេសោ . . . . . . . . . . ១០១

ខគ្គវិសាណសុត្តនិទ្ទេសោ . . . . . . . . . . . . . . . ១៩១

និទ្ទេសា ទុវិធា . . . . . . . . . . . . . . . . . . . ៣៨៤

# សុត្តន្តបិដក

# ខុទ្ទកនិកាយ ចូឡនិទ្ទេស

# ទុតិយភាគ

## មាតិកា

ទំព័រ


ចូឡនិទ្ទេស ទោទយមាណវកប្បញ្ហានិទ្ទេស ទី ១៣ . . . . . . ១

ហេមកមាណវកប្បញ្ហានិទ្ទេស ទី ១៤ . . . . ២៣

តោទេយ្យមាណវកប្បញ្ហានិទ្ទេស ទី ១៥ . . . . . ៤៥

បិង្គិយមាណវកប្បញ្ហានិទ្ទេស ទី ១៥ . . . . . . ៨៥

សោឡសមាណវកប្បញ្ហានិទ្ទេស . . . . . . . ១០១

ខគ្គវិសាណសុត្តនិទ្ទេស . . . . . . . . . . . ១៩១

និទ្ទេស ២ ប្រការ . . . . . . . . . . . . . ៣៨៤

# វិរុទ្ធាវិរុទ្ធបត្តំ

| វិរុទ្ធបាឋោ | អវិរុទ្ធបាឋោ | អង្កោ | បន្តិលេខាយំ |
|---|---|---|---|
| សព្ពោស្បុក្ការប- | សព្ពោស្បុក្ការប្ប- | ៣ | ១៨ |
| បដិវិនោទេត្វា | បដិវិនោទេត្វា | ” | ២០ |
| ទុកំ | ទុក្ខំ | ១២ | ៤ |
| ជម្មភក្កាបុរេជវ | ជម្មតក្កាបុរេជវំ | ១៤ | ១៤ |
| ភតភាតិ | តភាតិ | ១៩ | ៣ |
| ឧបបជ្ជិស្សតិ | ឧប្បជ្ជិស្សតិ | ៣៧ | ៤ |
| ” | ” | ៣៨ | ៨ |
| អបុច្ឆិស្ស | អបុច្ឆិស្សំ | ៤៥ | ២ |
| សវឌ្ឍានិ | សំវឌ្ឍានិ | ៥៦ | ៦ |
| បណ្ឌរីកានិ | បុណ្ឌរីកានិ | ” | ១០ |
| តិដ្ឋត្តិ | តិដ្ឋន្តិ | ” | ១១ |
| អវស្សិយ | អវសិយ | ៦៦ | ៣ |
| ” | ” | ” | ៥ |
| ” | ” | ៧០ | ១៧ |
| អស្សារំ | អសារំ | ៧១ | ២ |
| ថោសាល | អោឃកដ | ៨៣ | ១ |

# វិរុទ្ធាវិរុទ្ធបត្តំ

| វិរុទ្ធបាឋោ | អវិរុទ្ធបាឋោ | អង្កេ | បន្តិលេខាយំ |
|---|---|---|---|
| បដិសន្ធិ កាលេ | បដិសន្ធិកាលេ | ៩៩ | ៣ |
| អញាណំ | អញ្ញាណំ | ១២៦ | ១៥ |
| ឧបុល្វី | ឧបល្វី | ១៧០ | ៧ |
| ឆ្តិកាយ | ឆ្ឋិកាយ | ១៧២ | ១៦ |
| ឧបុល្វិត្តិ | ឧបល្វិត្តិ | ១៧៤ | ២ |
| វីវដ្ដនតោ | វិវដ្ដនតោ | ១៧៧ | ៧ |
| សព្វត្តា | សព្វថា | ១៩១ | ៧ |
| វំសោ | វំសោ | ២២១ | ២ |
| វីសេកាឡ្បកេវ | វំសេកាឡ្បកេវ | " | ១៧ |
| វិទសាសុ | វិទិសាសុ | ២៣៩ | ៩ |
| អនលោមប្បដិ- | អនុលោមប្បដិ- | | |
| បនាយ | បនាយ | ២៤៤ | ១១ |
| ឋិស្បដ្ឋី | ឋិសដ្ឋី | ២៩៨ | ៥ |
| ឃត្តត្តរេ | ឃត្តធ្តរេ | ៣០០ | ១៥ |
| អបច្ចវេក្ខណា | អប្បច្ចវេក្ខណា | ៣០២ | ១៤ |
| អបច្ចក្ខ- | អប្បច្ចក្ខ- | " | " |

# វិសុទ្ធាវិសុទ្ធបត្តំ

| វិសុទ្ធបាឋោ | អវិសុទ្ធបាឋោ | អង្កេ | បន្តិលេខាយំ |
|---|---|---|---|
| បដភាតិ | បដិភាតិ | ៣ ១ ១ | ១ ៣ |
| កោធិកត្តំ | កេធិកត្តំ | ៣ ១ ៦ | ៨ |
| បុព្វណ្ហំ | បុព្វន្ហំ | ៣ ១ ៧ | ១ ៤ |
| សលិលម្ពុចារី | សលិលម្ពុចារី | ៣ ២ ២ | ១ ៣ |
| អព្ភុត្តចារិកំ | អព្ភុត្តិតចារិកំ | ៣ ៣ ០ | ៣ |
| ឃរំវិហារី | ឃរំវិហារី | ៣ ៣ ៧ | ១ ៦ |
| សន្ថាគារសាលា | សណ្ឋាគារ-<br>សាលា | ៣ ៤ ០ | ៦ |
| អភិក្ក | អភិក្ក- | ៣ ៤ ១ | ៩ |
| បច្ចេកសម្ពុទ្ធោ | បច្ចេកសម្ពុទ្ធោ | ៣ ៤ ១ | ១ ៧ |
| កាដំ | កាឋំ | ៣ ៤ ៩ | ១ ០ |
| បដិវិរតោ | បដិវិរតា | ៣ ៥ ០ | ១ ២ |
| សមាបដិបទា | សម្មាបដិបទា | ៣ ៦ ៤ | ៤ |
| អត្តត្ថបញ្ញា | អត្តត្ថប្បញ្ញា | ៣ ៨ ១ | ១ ២ |
| ខគ្គវិសាណសុ-<br>ត្តនិទ្ទេសា | ខគ្គវិសាណសុ-<br>ត្តនិទ្ទេសោ | ៣ ៨ ៣ | ១ ៣ |

# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ភពថ្មីគឺ | ភពថ្មី គឺ | ៤ | ២ |
| មិនមានដល់ព្រះមាន | របស់ព្រះមានព្រះភាគ | | |
| ព្រះភាគនោះ | នោះមិនមាន | ,, | ,, |
| លោកពោលថា | (លោកពោលថា) | ,, | ៤ |
| មិនមានដល់ព្រះមានព្រះ | របស់ព្រះមានព្រះ | ៦ | ១០ |
| ភាគនោះ | ភាគនោះមិនមាន | ,, | ១១ |
| ឡើយថា | ឡើយ ថា | ១០ | ១៤ |
| គឺ | គឺថា | ១៥ | ៧ |
| នបាដល់ | បានដល់ | ១៦ | ១៥ |
| លះបង់ | គឺលះបង់ | ១៩ | ១៥ |
| អំពីវិញ្ញាណ | អំពីញាណ | ២៩ | ៨ |
| អធិប្បាយថា | អធិប្បាយពាក្យថា | ៣៩ | ២ |
| យថាសន្តតិកង្គ | យថាសន្តតិកង្គៈ | ,, | ១៤ |
| ទេសដ្ឋិកង្គ | ទេសដ្ឋិកង្គៈ | ,, | ,, |
| អធិប្បាយ ពាក្យថា | អធិប្បាយពាក្យថា | ៤៧ | ២ |

# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| គឺកុន | កុន | ៤៧ | ១១ |
| កុនកែកមាន | កុនកែក មាន | ៩៤ | ៤ |
| គឺបុគ្គល | បុគ្គល | ៧០ | ១៥ |
| សរែស | សរសែរ | ៩០ | ១៦ |
| ត្រង់ន្ធត្របៀក | ត្រង់រន្ធត្របៀក | ” | ១៧ |
| បុគលមិន | បុគ្គលមិន | ៩៨ | ១១ |
| គឺ ថាប្រព្រឹត្ត | គឺថា ប្រព្រឹត្ត | ១០៥ | ៦ |
| ការលោស់ | ការរលោស់ | ” | ១៥ |
| គឺ | សេចក្ដីថា | ១១៧ | ១០ |
| ពោថា | ពោលថា | ១១៨ | ៨ |
| គឺ ផ្លូវ | សេចក្ដីថា ឈ្មោះថាមគ្គ | | |
| | បានដល់ | ” | ១០ |
| ចង់គ្រោធ | ចង៌គ្រោធ | ១២៣ | ១៥ |
| កិ លេស | កិលេស | ១២៦ | ១៧ |
| ពោលរូប | ពោលរូម | ១៩១ | ៩ |

# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| តាំ ៤ | តាំង ៤ | ២១០ | ៥ |
| គនរ | គំនរ | ២១២ | ១១ |
| ស្វត | សត្វ | ២៣៩ | ៤ |
| ប្រាត្រ | បាត្រ | ២៥១ | ១៣ |
| បុណ្យ ច្រើន | បុណ្យច្រើន | ២៩៧ | ៥ |
| បុព្វណ្ណជាត | បុព្វន្នជាត | ៣០៧ | ១៣ |
| អធិប្បាយពាច្យថា | អធិប្បាយពាក្យថា | ៣២២ | ៨ |
| មារគន៍បាន | មារគន់បាន | ៣៣៧ | ១៧ |
| ប្រសីនបើ | ប្រសិនបើ | ៣៤១ | ២ |
| ទុបក្កិលេសរបស់ចិត្ត | ទុបក្កិលេសរបស់ចិត្ត | ៣៥៣ | ៤ |
| បឋមយាម | បឋមយាម | ៣៦១ | ២ |
| បឋមវ័យ | បឋមវ័យ | ៣៦២ | ៤ |
| បឋមជ្ឈាន | បឋមជ្ឈាន | ៣៦៣ | ៦ |

សៀវភៅនេះ ត្រូវបានបោះពុម្ពឡើងវិញ ដោយប្រាក់អំណោយនៃ
អ្នកខាងក្រោមនេះ ៖

Printing costs were met through the gift of

**Wat. Soinji Temple**
The Rev. Shigeo Kodama
4-7-23 Benten, Chuo-ku, Chiba-shi, Chiba-ken 260 Japan

この本は次の方によって復刻されました。

宗教法人 宗胤寺 住職　児玉重夫
〒260　千葉県千葉市中央区弁天4-7-23
☎043-251-5541

ព្រះត្រៃបិដក ភាគទី ១១០ " អភិធម្មបិដក "
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ
ការបោះពុម្ពជាថ្មីឡើងវិញ របស់សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ
បោះពុម្ព ថ្ងៃទី ១០ កក្កដា ឆ្នាំ ១៩៩៤
សហប្រតិបត្តិការរៀបរៀង និងបោះពុម្ពនៅប្រទេសជប៉ុន

TRIPITAKA VOL. 68 (of 110 volumes total)
"SUTTANTA PITAKA"
Published by the Buddhist Institute, Phnom Penh
Reproduced with the kind cooperation of the
TRIPITAKA PUBLISHING COMMITTEE
First edition December 8, 1994
Printed in Japan by Hirosaki Sogo Printing Ltd.

トリピタカ（南伝大蔵経）全110巻・第68巻スッタンタピタカ（経部）

発　行：プノンペン仏教研究所
復刻救援：カンボジア版トリピタカ(南伝大蔵経)復刻救援委員会
発　行：1994年12月8日

印刷・製本／弘前相互印刷株式会社
製作にあたり弘前相互印刷株式会社の多大な協力を得ました。

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE